# ព្រះត្រៃបិដកសង្ខេប

## ភាគ ១

## ព្រះវិន័យបិដក

*រៀបរៀងដោយខ្ញុំព្រះករុណា*

*ខ្ញុំបាទ* **សុន្ទរ៍ សាមឿន**

រក្សាសិទ្ធិ

**ព. ស. ២៥៥៤**

# ព្រះត្រៃបិដកសង្ខេប

## ភាគ ១

## ព្រះវិនយបិដក

*រៀបរៀងដោយខ្ញុំព្រះករុណា*

*ខ្ញុំបាទ* **សុន្ទរ៍ សារមៀន**

រក្សាសិទ្ធិ

**ព. ស.២៥៥៤ គ. ស.២០១០**

# ព្រះត្រៃបិដកសង្ខេប
# (ព្រះវិនយបិដក)

សេចក្ដីសង្ខេបនៃព្រះត្រៃបិដក ចែកចេញជាពីរវគ្គ ហើយត្រូវបានបញ្ចូលគ្នាតែមួយភាគ នៅក្នុងវគ្គដំបូងមានន័យសង្ខេបថាក្នុងបិដកនិមួយៗ ចាប់ពីភាគទី ១ ដល់ភាគទី ១១០ ពោលអំពីរឿងអ្វីខ្លះ គឺជាការពោលដោយត្រួសៗ ជាមុនសិន ។ នៅក្នុងវគ្គទី ២ ទើបពោលដោយពិស្ដារ ធ្វើឲ្យយល់រឿងរ៉ាវនៅក្នុងព្រះត្រៃបិដកបានច្បាស់ ហាក់បីដូចជាបានអានចាប់ពីភាគដំបូង រហូតដល់ភាគបញ្ចប់ដោយខ្លួនឯងដូច្នោះដែរ ។ សេចក្ដីសង្ខេបនៅក្នុងវគ្គទី ២ នេះ អ្នកអានហាក់ដូចជាមានចិត្តចុះសិប់ នៅក្នុងព្រះត្រៃបិដក ហើយអាចយល់ចាប់សេចក្ដីសំខាន់បានទាំងអស់ ។ ដោយសារតែវិធីនេះហើយ ទើបអ្នកអានអាចឃើញនូវទម្រង់ ឬរូបភាពរបស់ព្រះត្រៃបិដកបានច្បាស់ ។ ជាធម្មតាបិដក ១១០ ភាគ គឺច្រើនណាស់សម្រាប់អ្នកអានទូទៅ ទម្រាំតែនឹងអានចប់ តែបើយើងរួបរួមយកតែចំណុចសំខាន់មកពោលទុក ដូចដែលយើងបានធ្វើនៅក្នុងសៀវភៅនេះ គឺអាចជួយឲ្យយើងងាយស្រួលក្នុងការអាន និងក្រេបយកសេចក្ដីសំខាន់ៗបានច្រើនឡើង ។

មានបទជួយឲ្យងាយយកយល់មកពោលទុកក្នុងទីនេះ គឺ

**វិនយបិដក** ចាប់ពីភាគទី ១ ដល់ទី ១៣ រួមមាន ១៣ ភាគ ។

**សុត្តន្តបិដក** ចាប់ពីភាគទី ១៤ ដល់ទី ៧៧ រួមមាន ៦៤ ភាគ ។

**អភិធម្មបិដក** ចាប់ពីភាគទី ៧៨ ដល់ទី ១១០ រួមមាន ៣៣ ភាគ, សរុបត្រូវជាបិដក ១១០ ភាគ ។

# មហាវិភង្គ

## (ភាគទី ១ វិនយបិដក)

ដូចបានពោលរួចមកហើយ អំពីការយល់ដឹងនៅក្នុងព្រះត្រៃបិដកភាគទី ១ ថា **វិនយបិដក** គឺពោលអំពីវិន័យ ឬសីលរបស់ភិក្ខុនិងភិក្ខុនី ។ បណ្តាវិនយបិដក ១៣ ភាគនោះ បើយើងពោលតាមលំដាប់, ភាគទី ១ ទី ២ ទី ៣ និងភាគទី ៤ ឈ្មោះថា **មហាវិភង្គ** ឬ**ភិក្ខុវិភង្គ** គឺពោលអំពីសីល ២២៧ របស់ភិក្ខុ, ភាគទី ៥ ឈ្មោះថា **ភិក្ខុនីវិភង្គ** គឺពោលអំពីសីល៣១១ របស់ភិក្ខុនី, ភាគទី ៦ ទី ៧ និងទី ៨ ឈ្មោះថា **មហាវគ្គ** (វគ្គធំ ឬពួកធំ) គឺពោលអំពីរឿងរ៉ាវសំខាន់ៗ ដែលសង្ឃគប្បីធ្វើ ដូចជា ចីវរ ឧបោសថ បវារណា កាចាំវស្សា..., ភាគទី ៩ ទី ១០ និងទី ១១ ឈ្មោះថា **ចុល្លវគ្គ** (វគ្គតូច ឬពួកតូច) គឺពោលអំពីរឿងរ៉ាវសំខាន់ៗ របស់សង្ឃចុះមកជាបន្តទៀត រហូតដល់បកិណ្ណកៈ រឿងរ៉ាវតូចៗ ដូចជាវត្តប្បដិបត្តិផ្សេងៗ និងលំនៅឋានជាដើម, ចំណែកភាគទី ១២-១៣ គឺជាភាគបញ្ចប់ ឈ្មោះថា **បរិវារៈ** ជាសៀវភៅដែលប្រមូលផ្តុំចំណោះដឹងទាំង ១៣ ភាគខាងដើមចូលជាពួកជាក្រុមដើម្បីឲ្យងាយយល់ចូលចិត្ត ។ សមាគមបករណបាលីប្រទេសអង់គ្លេសហៅមហាវិភង្គ និងភិក្ខុនីវិភង្គ រួមគ្នាថា **សុត្តវិភង្គ**។

ចំពោះភាគទី ១ ចែកចេញជាពួកធំៗ ឈ្មោះថា **កណ្ឌ** រួមទាំងអស់មាន ៧ កណ្ឌ គឺ

**១.វេរញ្ជកណ្ឌ** ពោលអំពីរឿងរ៉ាវរបស់ព្រះពុទ្ធ កាលព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងស្រុកវេរញ្ជា រហូតដល់រឿងរ៉ាវរបស់ព្រះសារីបុត្រ ដែលសុំឲ្យព្រះអង្គបញ្ញត្តព្រះវិន័យឡើងដើម្បីឲ្យសាសនាតាំងនៅមាំ ។ រួចមកទើបទ្រង់ស្តេចចេញអំពីស្រុកវេរញ្ជាយាងទៅកាន់ក្រុងពារាណសី (រាជធានីនៃដែនកាសី) និងក្រុងវេសាលី (រាជធានីនៃដែនវជ្ជី) ជាទីបំផុត ។

**២.បឋមបារាជិកកណ្ឌ** ពោលអំពីហេតុការណ៍ដែលនាំឲ្យព្រះអង្គទ្រង់បញ្ញត្តបារាជិកសិក្ខាបទទី ១ គឺសិក្ខាបទដែលព្រះអង្គទ្រង់ហាមសេពមេថុនធម្ម ព្រមទាំងរឿងរ៉ាវដែលទ្រង់កែលម្អដោយការវិនិច្ឆ័យ សាកសួរ និងអនុម័តបន្ថែមដោយលំដាប់ ។

**៣.ទុតិយបារាជិកកណ្ឌ** ពោលអំពីហេតុការណ៍ដែលនាំឲ្យព្រះអង្គទ្រង់បញ្ញត្តបារាជិកសិក្ខាបទទី ២ គឺសិក្ខាបទដែលទ្រង់ហាមការកាន់យករបស់អ្នកដទៃដែលគេមិនបានឲ្យ ចាប់ពីតម្លៃ ៥ មាសកៈឡើងទៅ ព្រមទាំងរឿងរ៉ាវដែលទ្រង់កែលម្អដោយការ

វិនិច្ឆ័យ សាកសួរ និងអនុម័តបន្ថែមដោយលំដាប់ ។

**៤.តតិយបារាជិកកណ្ឌ** ពោលអំពីហេតុការណ៍ដែលនាំឲ្យព្រះអង្គទ្រង់បញ្ញត្តបារាជិកសិក្ខាបទទី ៣ គឺសិក្ខាបទដែលទ្រង់ហាមការសម្លាប់មនុស្ស ព្រមទាំងរឿងរ៉ាវដែលទ្រង់កែលម្អដោយការវិនិច្ឆ័យ សាកសួរ និងអនុម័តបន្ថែមដោយលំដាប់ ។

**៥.ចតុត្ថបារាជិកកណ្ឌ** ពោលអំពីហេតុការណ៍ដែលនាំឲ្យព្រះអង្គទ្រង់បញ្ញត្តបារាជិកសិក្ខាបទទី ៤ គឺសិក្ខាបទដែលទ្រង់ហាមការអួតគុណវិសេស (ឧត្តរិមនុស្សធម៌) ដែលខ្លួនមិនមានពិត ព្រមទាំងរឿងរ៉ាវដែលទ្រង់កែលម្អដោយការវិនិច្ឆ័យ សាកសួរ និងអនុម័តបន្ថែមដោយលំដាប់ ។

**៦.តេរសកណ្ឌ** ប្រែថា កណ្ឌដែលពោលអំពីអាបត្តិសង្ឃាទិសេសទាំង ១៣ សិក្ខាបទ ។ អាបត្តិសង្ឃាទិសេស គឺជាអាបត្តិធ្ងន់ដែលរងពីអាបត្តិបារាជិក កាលណាបើត្រូវអាបត្តិនេះហើយ ត្រូវនៅបរិវាសរហូតដល់អស់ចំនួនថ្ងៃដែលបិទបាំងទុក ហើយត្រូវនៅមានត្តអស់ ៦ រាត្រីទៀត រួចទើបជំនុំសង្ឃ ២១ រូបធ្វើពិធីសូត្រដកពីអាបត្តិសង្ឃាទិសេស ។ សិក្ខាបទទាំង ១៣ នេះ បានពណ៌នារួចមកហើយ ដែលជាហេតុនាំឲ្យព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទព្រមទាំងកែលម្អដោយការវិនិច្ឆ័យ សាកសួរ និងអនុម័តបន្ថែម ដោយលំដាប់ ។

**៧.អនិយតកណ្ឌ** ប្រែថា កណ្ឌពោលអំពីអាបត្តិដែលមិនទៀងទាត់ច្បាស់លាស់ថានឹងត្រូវអាបត្តិណាមួយ ក្នុងចំណោមអាបត្តិ ២ ឬ ៣ សុទ្ធតែជាករណីលំបាកដោះស្រាយសម្រេចសេចក្តីថានឹងត្រូវអាបត្តិអ្វី, អនិយតសិក្ខាបទនេះ មាន ២ សិក្ខាបទ ។

សរុបសេចក្តីក្នុងមហាវិភង្គ ឬវិនយបិដកភាគទី ១-២-៣ នេះ គឺរៀបរាប់អំពីប្រវត្តិនៃការបញ្ញត្តិសិក្ខាបទ បានដល់បារាជិក សិក្ខាបទ ៤, សង្ឃាទិសេស ១៣, អនិយត ២ រួមត្រូវជា ១៩ សិក្ខាបទ ។

## ១.វេរញ្ជកណ្ឌ

អត្ថាធិប្បាយផ្ដើមថា ព្រះមានព្រះភាគទ្រង់ប្រថាប់គង់នៅក្រោមដើមស្ដៅក្បែរស្រុកវេរញ្ជា ព្រមទាំងគណៈសង្ឃជាច្រើនរូប ។ វេរញ្ជព្រាហ្មណ៍បានឮកិត្តិសព្ទព្រះអង្គហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ តែមិនបានក្រាបថ្វាយបង្គំព្រះអង្គឡើយ ក្រោយពីបានប្រាស្រ័យរាក់ទាក់ព្រះអង្គរួចហើយក៏ពោលថា បានឮគេនិយាយតៗ គ្នាមកថា ព្រះសមណគោតម មិនព្រមសំពះ ឬក្រោកទទួលពួកព្រាហ្មណ៍ដែលមានអាយុច្រើនណាមួយឡើយ កាលដែលព្រះសមណគោតមធ្វើដូច្នោះ មិនសមគួរទេ ។ ព្រះអង្គត្រាស់ថា តថាគត មិនសំពះពួកព្រាហ្មណ៍ដែលមានអាយុច្រើន ពិតមែន ។ ទើបវេរញ្ជព្រាហ្មណ៍ ពោលវាចារុកកួនដោយពាក្យសម្ដី ដែលគេនាំគ្នាយល់ក្នុងសម័យនោះថាជាពាក្យប្រមាថមាក់ងាយ រួមមាន ៨ ខ ដូចពាក្យថា ព្រះសមណគោតមមិនមានរសជាតិ, ព្រះសមណគោតមនាំឲ្យវិនាស, ព្រះសមណគោតមដុតបំផ្លាញជាដើម ។ តែព្រះមានព្រះភាគ ទ្រង់ដោះស្រាយពាក្យគ្រោតគ្រាតនោះ ត្រឡប់ឲ្យទៅជាពាក្យល្អវិញ ដូចជាព្រះតម្រាស់ថា នរណាពោលថា មិនមានរសជាតិ ពិតជាត្រឹមត្រូវ ព្រោះតថាគតមិនជាប់នៅក្នុងរស គឺ រូប សំឡេងជាដើម, នរណាពោលថា មិនមានសម្បត្តិ ពិតជាត្រឹមត្រូវ ព្រោះតថាគតមិនជាប់នៅក្នុងសម្បត្តិ គឺ រូបសំឡេងជាដើម, នរណាពោលថា នាំឲ្យវិនាស ពិតជាត្រឹមត្រូវ ព្រោះតថាគតសំដែងធម៌ ដឹកនាំឲ្យធ្វើបាបអកុសលគ្រប់យ៉ាងវិនាស, នរណាពោលថា ដុតបំផ្លាញ ពិតជាត្រឹមត្រូវ ព្រោះតថាគតដុតបំផ្លាញបាបអកុសល ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយទាំងអស់បានហើយ ។ កាលបើត្រាស់កែពាក្យរបស់ព្រាហ្មណ៍ដោយធម៌ទូន្មានចិត្តបានដូច្នេះហើយ ទើបត្រាស់អធិប្បាយហេតុផល ក្នុងការដែលព្រះអង្គមិនព្រមសំពះ ព្រាហ្មណ៍ដែលមានអាយុច្រើន ដោយប្រៀបធៀបថា កូនមាន់ណាចោះ សំបកចេញមកបានមុន កូនមាន់នោះ គួររាប់ថាចាស់ជាងកូនមាន់ដទៃ ព្រះអង្គចោះសំបក គឺអវិជ្ជាបានមុនបុគ្គលដទៃ ទើបឈ្មោះថា ចាស់ជាងបុគ្គលដទៃ វេរញ្ជព្រាហ្មណ៍បានស្ដាប់ហើយ ក៏ជ្រះថ្លា ប្រកាសខ្លួនជាឧបាសកដល់ព្រះរតនត្រ័យជាទីពឹង អស់មួយជីវិត រួចហើយក្រាបទូលអារាធនាព្រះអង្គ ឲ្យគង់ចាំព្រះវស្សានៅក្នុង ស្រុកវេរញ្ជាព្រមទាំងភិក្ខុសង្ឃ ព្រះអង្គទ្រង់ទទួលដោយតុណ្ហីភាព ។ សម័យនោះស្រុកវេរញ្ជាកើតទុព្ភិក្ខភ័យ អាហាររកបានដោយលំបាក រហូតដល់ថ្នាក់ចាប់ស្លាកចែកអាហារ ។ ភិក្ខុទាំងឡាយលំបាកដោយអាហារបិណ្ឌបាត បានអាស្រ័យបាយក្រហម របស់ពួកឈ្មួញ

ដែលមកស្នាក់ជ្រកភ្លៀងនាវដូវវស្សាក្នុងស្រុកនោះ ព្រះមានព្រះភាគទ្រង់សរសើរភិក្ខុទាំងនោះថា ជាអ្នកឈ្នះ (ដែលអាចតស៊ូ នឹងភាពលំបាក ដោយមិនប្រើវិធីស្វែងរកអាហារក្នុងផ្លូវដែលខុសដូចជាអួតខ្លួនថាជាមនុស្សវិសេសជាដើម) ។ ព្រះមោគ្គល្លានសុំព្រះអង្គចេញស្វែងរកអាហារជាច្រើនវិធី រួមទាំងការត្រាច់ទៅបិណ្ឌបាតក្នុងទីដទៃ តែព្រះអង្គទ្រង់មិនអនុញ្ញាត ។

ចំណែកព្រះសារីបុត្រ រំពឹងដល់ការតាំងមាំនៃព្រហ្មចរិយៈ ទើបក្រាបទូលសួរព្រះអង្គ ដល់ហេតុដែលធ្វើឲ្យព្រហ្មចរិយៈតាំងមាំ និងមិនតាំងមាំបាន ទ្រង់ត្រាស់ដល់ការបញ្ញត្តសិក្ខាបទ ការសូត្របាដិមោក្ខ (សូត្ររំលឹកផ្ទៀងផ្ទាត់សិក្ខាបទរាល់កន្លះខែម្តង) ថាជាហេតុធ្វើឲ្យព្រហ្មចរិយៈតាំងមាំបាន ការមិនធ្វើដូចនោះ ជាហេតុធ្វើឲ្យព្រហ្មចរិយៈអន្តរធាន ទើបព្រះសារីបុត្រក្រាបទូលសុំឲ្យព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទ ។ ព្រះពុទ្ធត្រាស់ថា នៅមិនទាន់ដល់ពេល គឺសង្ឃនៅមិនទាន់មានច្រើន លាភសក្ការៈនៅមិនទាន់មានច្រើន ធម៌ជាទីតាំងនៃអាសវៈ (កិលេសដែលដេកត្រាំនៅក្នុងសន្តាន) មិនទាន់ប្រាកដដល់សង្ឃ ទើបមិនទាន់បញ្ញត្តសិក្ខាបទឡើង, បើសង្ឃមានច្រើន លាភសក្ការៈមានច្រើន ធម៌ជាទីតាំងនៃអាសវៈប្រាកដដល់សង្ឃ ទើបគួរបញ្ញត្តសិក្ខាបទឡើង ។ ក៏ក្នុងពេលនោះ ភិក្ខុសង្ឃដែលជាប់តាមព្រះអង្គទៅ សុទ្ធតែជាព្រះអរិយបុគ្គល យ៉ាងទាប ក៏ជាព្រះសោតាបន្ន ។

កាលចេញវស្សារួចហើយ ទើបព្រះពុទ្ធនាំព្រះអានន្ទទៅលាវេរញ្ជព្រាហ្មណ៍ ក្នុងឋានៈដែលបាននិមន្តព្រះអង្គ ឲ្យគង់ចាំព្រះវស្សា ។ វេរញ្ជព្រាហ្មណ៍និមន្តព្រះអង្គព្រមទាំងភិក្ខុសង្ឃ ឲ្យឆាន់ចង្ហាន់ក្នុងថ្ងៃស្អែក ទ្រង់ទទួលនិមន្ត និងយាងទៅឆាន់តាមការកំណត់ ហើយសំដែងធម៌ ប្រោសវេរញ្ជព្រាហ្មណ៍ ទើបស្តេចចារិកទៅកាន់ក្រុងសោរេយ្យៈ ក្រុងសង្កស្សៈ ក្រុងកណ្ណកុជ្ជៈ តាមលំដាប់ ស្តេចឆ្លងស្ទឹងគង្គា ត្រង់កំពង់បយាគៈ ទៅកាន់ក្រុងពារាណសី រួចស្តេចចេញពីក្រុងពារាណសី ទៅកាន់ក្រុងវេសាលី ប្រថាប់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ។

# ២.បឋមបារាជិកកណ្ឌ

## (ពោលអំពីបារាជិកសិក្ខាបទទី ១)

សម័យនោះ នៅមិនឆ្ងាយពីក្រុងវេសាលីមានស្រុកមួយ ឈ្មោះថា កលន្ទះ មានបុត្រសេដ្ឋីម្នាក់ ឈ្មោះថា សុទិន្ន ដែលជាអ្នកស្រុកកលន្ទះ ។ សុទិន្នព្រមទាំងសហាយ (មិត្តសំឡាញ់) នាំគ្នាទៅកាន់ក្រុងវេសាលី លុះឃើញព្រះពុទ្ធកំពុងសំដែងធម៌ ទើបនាំគ្នាចូលទៅស្តាប់ធម៌ រួចហើយមានសេចក្តីជ្រះថ្លាប្រាថ្នានឹងបួស ទើបក្រាបទូលព្រះអង្គសុំបួសក្នុងព្រះពុទ្ធសាសនា តែព្រះសាស្តាទ្រង់មិនទាន់អនុញ្ញាតឲ្យបួស ព្រោះមាតាបិតានៅមិនទាន់បានអនុញ្ញាត, ទើបសុទិន្នត្រឡប់ទៅសុំអនុញ្ញាតពីមាតាបិតា តែលោកទាំងពីរនៅតែមិនព្រមអនុញ្ញាត ទើបអង្វរលោកដល់ទៅ ៣ ដង ក៏នៅតែមិនព្រមអនុញ្ញាតដូចដើម ទើបសុទិន្នដេកនៀលលើដី អត់អាហារដល់ទៅ ៧ ថ្ងៃ មាតាបិតាអង្វរឲ្យលះបង់ការតាំងចិត្ត ក៏នៅតែមិនព្រម ពួកមិត្តសំឡាញ់មកអង្វរ ក៏មិនព្រម ។ ទីបំផុត ពួកមិត្តសំឡាញ់ត្រឡប់បែរជាសុំអង្វរមាតាបិតារបស់សុទិន្នឲ្យព្រមអនុញ្ញាត ក៏ទទួលបានការអនុញ្ញាត នៅពេលបានទទួលការអនុញ្ញាតហើយ ក៏ចេញបួសប្រព្រឹត្តបដិបត្តិយ៉ាងម៉ឺងម៉ាត់នៅក្នុងស្រុកវជ្ជី ។

កាលនោះ ដែនវជ្ជីដែលមានក្រុងវេសាលីជារាជធានីកើតទុព្ភិក្ខភ័យ សុទិន្នភិក្ខុមានញាតិជាអ្នកស្តុកស្តម្ភ ពេលធ្វើដំណើរទៅដល់ក្រុងវេសាលី ពពួកញាតិជ្រាបដំណឹង ក៏នាំអាហារមកប្រគេនច្រើនលើសលប់ សុទិន្នភិក្ខុក៏ប្រគេនបន្តដល់ភិក្ខុទាំងឡាយ ហើយក៏ធ្វើដំណើរទៅកាន់កលន្ទគ្រាម (ស្រុកកំណើតរបស់ខ្លួន) ។ ដំណឹងនេះ បានជ្រាបដល់មាតាបិតា ទើបបិតានិមន្តឆាន់ រួចហើយមាតាក៏នាំយកទ្រព្យសម្បត្តិមកលួងឲ្យសឹក តែមិនសម្រេច ព្រោះសុទិន្នភិក្ខុមិនយល់ព្រម ។ ក្រោយមកមាតារបស់សុទិន្នភិក្ខុ រង់ចាំរហូត ដល់ភរិយារបស់សុទិន្នភិក្ខុ (តាំងពីសម័យនៅមិនទាន់បានបួស) មានរដូវ ដល់ពេលកំណត់ល្មមអាចមានបុត្របាន ទើបនាំនាងទៅជួបសុទិន្នភិក្ខុក្នុងព្រៃមហាវ័ន រួចបបួលឲ្យសឹកម្តងទៀត តែលោកក៏នៅតែមិនព្រម ទើបមាតាពោលថា បើមិនសឹកសុំតែពូជ បន្តត្រកូលក៏បានដែរ ។ គ្រានោះ នៅមិនទាន់មានការបញ្ញត្តិវិន័យហាមសេពមេថុនធម្មនៅឡើយ ទើបសុទិន្នភិក្ខុយល់ថា ការដែល

មានបុត្របន្តត្រកូល គឺជារឿងដែលគួរធ្វើបាន ទើបសេពមេថុនជាមួយភរិយារបស់ខ្លួន ក្រោយមកនាងក៏បានតាំងគភ៌ រួចហើយក៏ប្រសូតបុត្រ ។ ដូច្នេះហើយបុត្ររបស់សុទិន្នភិក្ខុ ទើបមានឈ្មោះថា ពីជៈ, ឯភរិយាមានឈ្មោះថា ពីជមាតា ។ សម័យក្រោយមកទាំងមាតាព្រមទាំងបុត្រ បាននាំគ្នាចេញបួសរួចហើយ ក៏បានសម្រេចអរហត្តផលទាំងពីរនាក់ ។

ដំណាលដល់រឿងសុទិន្នភិក្ខុ លោកកើតការមិនសប្បាយចិត្តជាខាងក្រោយ រហូតដល់ថ្នាក់ស្គមស្លេកស្លាំង ភិក្ខុទាំងឡាយសាកសួរដឹងសេចក្តីហើយ ក៏នាំគ្នាតិះដៀល រួចហើយក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ព្រះអង្គត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចសាកសួរដល់ដំណើររឿងនោះ ទ្រង់ជ្រាបហើយ ទើបតិះដៀល រួចក៏បញ្ញត្តសិក្ខាបទ ហាមភិក្ខុសេពមេថុន ហើយពិន័យអាបត្តិបារាជិកដល់ភិក្ខុដែលប្រព្រឹត្តល្មើស ឬបំពាន [១] ។

[១] សុទិន្នភិក្ខុមិនត្រូវអាបត្តិ ព្រោះជាបុគ្គលដើមបញ្ញត្តិ គ្មានការពិន័យអាបត្តិសារដើមទេ ។



## អនុប្បញ្ញត្តិ (បទបញ្ញត្តិបន្ថែម)

បន្ទាប់មក មានភិក្ខុវជ្ជីបុត្រអ្នកក្រុងវេសាលីយល់ថា ហាមសេពមេថុនចំពោះតែមនុស្សប៉ុណ្ណោះ ទើបសេពមេថុនជាមួយស្វាញី រឿងរ៉ាវបានដឹងដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទបន្ថែមទៀត ដើម្បីឲ្យកាន់តែច្បាស់ឡើងថា ***ហាមសេពសូម្បីតែជាមួយសត្វតិរច្ឆាន ។*** មានភិក្ខុសេពមេថុនដាច់ចាកភាវៈជាភិក្ខុហើយ រួចមកសុំឧបសម្បទាម្តងទៀត ទើបព្រះពុទ្ធទ្រង់បញ្ញត្ត ***ហាមឧបសម្បទាដល់បុគ្គលដូចនោះ ។*** បន្ទាប់ពីនោះមកទៀតមានពាក្យអធិប្បាយលម្អិតសិក្ខាបទគ្រប់បទ ព្រមទាំងសំដែងតួយ៉ាងប្រកបផង ។

ភិក្ខុ ៥ ប្រភេទ មិនត្រូវអាបត្តិ គឺ

១.ភិក្ខុមិនដឹងខ្លួន (ឬត្រូវគេគម្រាមតែមិនត្រេកអរ)

២.ភិក្ខុវិកលចរិត

៣.ភិក្ខុរវើរវាយ (សំដៅដល់វិកលចរិតម្តងម្កាលដោយហេតុដទៃ មិនមែនជាប្រក្រតី អដ្ឋកថាកែថា ខ្មោចចូល តែសម័យនេះប្រៀបមកនឹងមនុស្សវិកលចរិត ព្រោះថ្នាំប្រភេទខ្លះ) ។

៨.ភិក្ខុមានវេទនាខ្លាំងក្លា មិនដឹងខ្លួនថាធ្វើអ្វី លើសលស់ទៅខ្លះ ។

៩.ភិក្ខុដើមបញ្ញត្តិ ។

## វិនីតវត្ថុ

## (រឿងដែលទ្រង់វិនិច្ឆ័យគូសបញ្ជាក់)

បន្តបន្ទាប់មកទៀត មានការសំដែងតួយ៉ាងដែលភិក្ខុធ្វើបន្ថែមទៀតទាក់ទងនឹងសិក្ខាបទនេះ ក្នុងលក្ខណៈផ្សេងៗ គ្នា ហើយព្រះមានព្រះភាគទ្រង់វិនិច្ឆ័យ សាកសួរ និងបញ្ជាក់ថា ត្រូវអាបត្តិខ្លះ មិនត្រូវអាបត្តិខ្លះ តាមលក្ខខណ្ឌនៃព្រះវិន័យ ។

# ៣.ឧត្តិយបារាជិកកណ្ឌ

## (ពោលអំពីបារាជិកសិក្ខាបទទី ២)

មានរឿងដំណាលមកថា ព្រះមានព្រះភាគទ្រង់គង់ប្រថាប់នៅលើភ្នំគិជ្ឈកូដ ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះភិក្ខុជាច្រើនរូបដែលជាសាហាយនឹងគ្នា បាននាំគ្នាធ្វើកុដិស្មៅចាំវស្សានៅលើភ្នំឥសីគិលិ, ធនិយភិក្ខុជាបុត្រនៃជាងស្មូនឆ្នាំង ក៏ធ្វើកុដិស្មៅចាំវស្សានៅទីនោះដែរ ។ ភិក្ខុរូបដទៃ កាលបើចេញវស្សាហើយ ក៏រុះរើកុដិស្មៅ រៀបចំទុកដាក់ឈើ និងស្មៅរួចរាល់ហើយ ក៏នាំគ្នាត្រាច់ចារិកទៅកាន់ជនបទ ។ ចំណែកឯធនិយភិក្ខុនៅគង់ទីនោះ មិនត្រាច់ទៅណាអស់ ៣ រដូវ ខណៈពេលចូលទៅបិណ្ឌបាតក្នុងភូមិស្រុក ពួកមនុស្សក៏នាំគ្នាមករុះរើកុដិ ប្រមូលយកឈើ និងស្មៅទៅអស់ លោកត្រូវធ្វើសារជាថ្មីឡើងវិញ តែត្រូវពួកមនុស្សចេះតែមករុះរើប្រមូលលួចយកឈើ និងស្មៅទៅអស់ ៣ ដង ទើបធនិយភិក្ខុគិតសាងធ្វើកុដិដី ព្រោះលោកជំនាញក្នុងការផ្សំដីសូនឆ្នាំងមកអំពីមុន កាលបើសម្រេចចិត្តដូច្នោះហើយ ទើបយកដីជ្រាយមកច្របាច់ហើយធ្វើជាកុដិដីឆៅ រួចហើយយកស្មៅ ឈើ និងអាចម៍គោមកដុតបំពក់ឲ្យទៅជាកុដិដីឆ្អិន មានពណ៌ក្រហមស្អាតដូចជាពណ៌នៃសត្វមេភ្លៀង[២] ។

---

[២] ***ឥន្ទគោបកៈ*** អាចប្រែបានថា អំពិលអំពែក សត្វល្អិតស៊ីឈើម្យ៉ាង ។ តែទាំងពីរប្រភេទនេះ គ្មានពណ៌ក្រហមទេ ការប្រែសព្ទក្នុងទីនេះ ជាបញ្ហា

ភាពល្បីស្អាតរបស់កុដិនេះ បានឮខ្ចរខ្ចាយទៅគ្រប់ទិសទី ព្រះពុទ្ធទ្រង់ជ្រាបសេចក្តីនេះហើយ ក៏ត្រាស់បង្គាប់ឲ្យវាយទម្លាយចោល ដើម្បីមិនឲ្យភិក្ខុជំនាន់ក្រោយយកតម្រាប់តាម ព្រោះ(ការជីកដីយកមកធ្វើកុដិ) អាចធ្វើសត្វឲ្យស្លាប់បាន ដូច្នេះហើយ ទើបទ្រង់បញ្ញត្តសិក្ខាបទ ហាមធ្វើកុដិដីដៅ ពិន័យអាបត្តិទុក្កដ ដល់ភិក្ខុដែលប្រព្រឹត្តល្មើស ។

ធនិយភិក្ខុមិនបញ្ឈប់ការកសាងត្រឹមតែប៉ុណ្ណឹងទេ ថែមទាំងចូលទៅសុំឈើក្នុងព្រះរាជវាំងពីអ្នកយាមឃ្លាំង ដោយរៀបរាប់ប្រាប់ពីដំណើរដើមទង ដែលមានពួកមនុស្សមករុះរើកុដិរបស់ខ្លួន ហើយលួចយកឈើ និងស្មៅទៅអស់ ៣ ដង ទើបលោកធ្វើកុដិដីតែត្រូវព្រះពុទ្ធទ្រង់បញ្ជាឲ្យទម្លាយចោល ដូច្នេះហើយ ទើបទៅសុំឈើពីអ្នកយាមឃ្លាំងឈើក្នុងព្រះរាជវាំង ។ តែត្រូវអ្នកយាមឃ្លាំងឈើព្រះរាជវាំងបដិសេធថា ខ្លួនមិនមាន ឯឈើដែលត្រូវឲ្យទៅលោកម្ចាស់នោះ មានតែឈើរបស់ព្រះរាជាដែលទុកជួសជុលព្រះនគរ នៅពេលដែលមានអន្តរាយប៉ុណ្ណោះ បើព្រះរាជាទ្រង់ព្រះ

---

សម្រាប់អ្នកសិក្សាស្រាវជ្រាវភាសាបាលីច្រើនប្រទេស, មួយចំណែកធំយល់ឃើញថា បានដល់ សត្វអណ្តើកមាស សត្វប្រភេទនេះ តាមប្រក្រតីមានពណ៌ក្រហមអុចខ្មៅៗ តែសត្វខ្លះ មានពណ៌លឿងត្រង់ខ្លួន ។

រាជទាន ទើបនាំយកទៅបាន ។ ធនិយភិក្ខុប្រាប់ថា "ព្រះរាជាទ្រង់ព្រះរាជទានហើយ" ។ អ្នកយាមឃ្លាំងឈើ ជឿថាជាអ្នកបួសគង់មិននិយាយកុហកទេ ទើបអនុញ្ញាតឲ្យនាំយកទៅ ។ ធនិយ-ភិក្ខុ ក៏នាំយកឈើមកកាត់ជាកំណាត់តូចខ្លី ហើយដាក់លើរទេះ នាំយកទៅធ្វើកុដិ ។

កាលវស្សការព្រាហ្មណ៍ (អាមាត្យធំ) មកពិនិត្យមើលឃើញថាឈើត្រូវបានបាត់ ទើបសាកសួរ រួចហើយក៏នាំសេចក្តីនោះទៅក្រាបទូលដល់ព្រះបាទពិម្ពិសារ ទើបព្រះរាជាមានបញ្ជាឲ្យចាប់ចងអ្នកយាមឃ្លាំងទៅគាល់ព្រះអង្គ ។ ធនិយភិក្ខុឃើញគេនាំបណ្តើរអ្នកយាមឃ្លាំងទៅដូច្នេះ លុះសាកសួរដឹងសេចក្តីហើយ ទើបតាមពីខាងក្រោយទៅ ។ ព្រះបាទពិម្ពិសារនមស្ការធនិយ-ភិក្ខុហើយ ត្រាស់សួរថា "ខ្ញុំព្រះអង្គបានប្រគេនឈើនោះ ជាការពិតឬ?" ។ ធនិយភិក្ខុឆ្លើយថា "ជាការពិតព្រះអង្គ" ។ ព្រះបាទពិម្ពិសារត្រាស់ថា "ព្រះអង្គជាព្រះរាជា មានកិច្ចធុរៈច្រើន អាចប្រគេនទៅហើយតែនឹកមិនឃើញ បើព្រះគុណម្ចាស់ ធនិយៈនឹកឃើញ សូមជួយប្រាប់ខ្ញុំព្រះអង្គផង" ។ ធនិយភិក្ខុទូលសួរថា "ទ្រង់ពិតជារឭកមិនឃើញឬកាលដែលទ្រង់បន្លឺវាចា ក្នុងថ្ងៃអភិសេកឡើងសោយរាជ្យរបស់ព្រះអង្គថា "ខ្ញុំព្រះអង្គ សូមប្រគេនស្មៅឈើ និងទឹក ដល់សមណព្រាហ្មណ៍ទាំងឡាយ សូមសមណ-

ព្រាហ្មណ៍ទាំងនោះ ចូរប្រើប្រាស់ចុះ» ។ ព្រះរាជាត្រាស់តបថា «ទ្រង់រឭកឃើញហើយ តែដែលត្រាស់ដូច្នោះ គឺសម្រាប់សមណព្រាហ្មណ៍ដែលមានហិរិ មានសេចក្ដីរង្កៀស ក្នុងអំពើអាក្រក់សូម្បីតែបន្តិចបន្តួច ប្រាថ្នាដល់ការសិក្សា និងទ្រង់សំដៅដល់ឈើដែលគ្មានគេហួងហែងនៅក្នុងព្រៃ ។ លោកប្រកាន់យកឈើដែលគេមិនបានឲ្យដោយលេសនេះ មនុស្សដូចខ្ញុំព្រះអង្គនឹងគប្បីសម្លាប់ ឬចាប់ចង ឬក៏និរទេសសមណៈ ឬព្រាហ្មណ៍ដូចម្ដេចកើត សូមលោកម្ចាស់និមន្តទៅចុះ លោកម្ចាស់រួចខ្លួន ព្រោះភេទបព្វជិត តទៅសូមកុំធ្វើដូច្នេះទៀត ។

មនុស្សទាំងឡាយ នាំគ្នាតិះដៀល ដោយប្រការផ្សេងៗ រឿងនោះបានឮដល់ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ហៅសង្ឃមកប្រជុំគ្នា រួចសាកសួរ កាលបើធនិយភិក្ខុសារភាពហើយ ទើបទ្រង់ត្រាស់សួរភិក្ខុដែលធ្លាប់ជាអាមាត្យពីមុនថា ព្រះបាទពិម្ពិសារចាប់ចោរបានហើយ ទ្រង់ប្រហារជីវិត ចាប់ចង ឬនិរទេស ដោយកំណត់ទ្រព្យប៉ុន្មាន ព្រះមានព្រះភាគក៏ទទួលបានពាក្យឆ្លើយតបថា មួយបាទ ឬមានតម្លៃស្មើនឹង ១ បាទ ឬក៏ច្រើនជាង ១ បាទខ្លះ ។ កាលនោះ ក្នុងក្រុងរាជគ្រឹះ ១ បាទ ស្មើនឹង ៥ មាសកៈ ទើបទ្រង់បញ្ញត្តសិក្ខាបទ ហាមភិក្ខុកាន់យករបស់ដែល គេមិនបានឲ្យភិក្ខុរូបណាប្រព្រឹត្តល្មើស មានតម្លៃស្មើព្រះរាជាចាប់ ចោរបានហើយប្រហារជីវិត ឬចាប់ចង ឬក៏និរទេស ត្រូវអាបត្តិបារាជិក ។

## អនុប្បញ្ញត្តិ

សម័យនោះ ភិក្ខុឆព្វគ្គិយ៍ (ពួករួមចិត្តគ្នា ៦ រូប) ទៅទីវាលសម្រាប់ហាលក្រណាត់របស់ជាងជ្រលក់ ហើយលួចយកក្រណាត់មកចែកគ្នា រឿងនោះដឹងដល់ភិក្ខុទាំងឡាយ ទើបពួកលោកពោលបង្វែរថា ក្រណាត់នេះ គឺលោកយកមកពីក្នុងព្រៃ មិនបានយកមកពីក្នុងស្រុកទេ សិក្ខាបទដែលទ្រង់បញ្ញត្ត គឺសំដៅយកក្នុងស្រុក (តាមពិត សិក្ខាបទនេះមិនបានបញ្ជាក់ពីទីកន្លែងទេ) តែដើម្បីមិនឲ្យភិក្ខុរកលេសតទៅទៀត ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តបន្ថែមថា លួចរបស់ក្នុងស្រុកក្ដី ក្នុងព្រៃក្ដី (ក្នុងរឿងដែលកើតឡើងនេះ ទ្រង់សម្រេចថា ត្រូវអាបត្តិបារាជិក) ។

បន្ទាប់ពីនោះ ជាពាក្យអធិប្បាយសិក្ខាបទដោយលម្អិតព្រមទាំងបន្ថែមពាក្យការពាររកលេសកែខ្លួន ដូចពាក្យថា របស់តាំងនៅលើដី លើគោក លើអាកាស (សត្វស្លាប) លើលំហ (ដូចជារបស់ព្យួរទុក) ក្នុងទឹក លើទូក លើរថ លើទំនួល ឬកន្ទៀត (ដូច

ជាក្បាល និងចង្កេះជាដើម) ក្នុងអារាម ក្នុងវិហារ ក្នុងស្រែ ក្នុងចម្ការ ក្នុងស្រុក ក្នុងព្រៃជាដើម ។

អនាបត្តិ (លក្ខណៈដែលមិនត្រូវអាបត្តិ) មាន ៨ ប្រការគឺ

១.ភិក្ខុកាន់យកដោយគិតថាជារបស់ខ្លួន (យល់ខុស)

២.កាន់យក ដោយគិតថាស្គាល់គ្នា សូម្បីម្ចាស់របស់ដឹងក៏មិនថាអី ។

៣.កាន់យកជារបស់ខ្ចី

៤.កាន់យករបស់អ្នកស្លាប់ (មិនធានាសិទ្ធិរបស់អ្នកស្លាប់ វៀរលែងតែមានអ្នកទទួលមរតក) ។

៥.កាន់យករបស់ដែលសត្វហួងហែង (ដូចជាខ្លាស៊ីសាច់សត្វស្លាប់ ភិក្ខុកាន់យកមកដើម្បីជាអាហារ) ។

៦.កាន់យកដោយបង្សុកូលសញ្ញា គឺគិតថា ជារបស់គេចោលហើយ ។

៧.ភិក្ខុឆ្កួត

៨.ភិក្ខុដើមបញ្ញត្តិ ។

### វិនីតវត្ថុ

បន្ទាប់ពីនោះ មានការសំដែងតួយ៉ាងដែលភិក្ខុប្រព្រឹត្តធ្វើបន្ថែមទៀត ទាក់ទងនឹងសិក្ខាបទនេះ ក្នុងលក្ខណៈផ្សេងៗ គ្នាប្រមាណ ១៨៩ រឿង ព្រះមានព្រះភាគទ្រង់វិនិច្ឆ័យសាកសួរ ហើយទ្រង់បញ្ជាក់ថា ត្រូវអាបត្តិបារាជិក ឬមិនត្រូវ គឺតាមសមគួរដល់ភាពជាក់ស្តែង ។

## ៤.តតិយបារាជិកកណ្ឌ

### (ពោលអំពីបារាជិកសិក្ខាបទទី ៣)

មានរឿងរ៉ាវដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងផ្ទះកំពូលនាព្រៃមហាវ័នក្បែរក្រុងវេសាលី ។ សម័យនោះ ព្រះអង្គទ្រង់សំដែងអសុភកថា (គឺពាក្យប្រារព្ធវត្ថុដែលមិនស្អាត) សរសើរគុណនៃអសុភៈ និងគុណនៃការចម្រើនអសុភៈ គឺការពិចារណាឃើញ

រាងកាយជារបស់មិនស្អាត ព្រមទាំងគុណនៃអសុភសមាបត្តិ (ចូលឈានមានអសុភៈជាអារម្មណ៍) ដោយអនេកបរិយាយ ។ បន្ទាប់មកព្រះអង្គត្រាស់ថា ទ្រង់មានព្រះបំណងនឹងជៀសចេញទៅ នៅតែមួយអង្គឯងអស់កន្លះខែ នរណាក៏មិនអាចចូលទៅគាល់ព្រះអង្គបានដែរ វៀរលែងតែភិក្ខុដែលនាំអាហារចូលទៅប៉ុណ្ណោះ ។

ភិក្ខុទាំងឡាយ នាំគ្នាបដិបត្តិអសុភភាវនា (ការចម្រើនអសុភកម្មដ្ឋាន គឺពិចារណារាងកាយថាជារបស់មិនស្អាត) ក៏ស្រាប់តែកើតការនឿយណាយរង្កៀសកាយរបស់ខ្លួនឯង ដូចកម្លោះក្រមុំដែលពេញចិត្តក្នុងការប្រដាប់តាក់តែងខ្លួតទឹក ស្អិតស្អាងកាយរួចហើយ រង្កៀសសាកសពពស់ សុនខ មនុស្ស ដែលពាក់នៅនឹងកដូច្នោះ កាលបើនឿយណាយរង្កៀសដោយកាយរបស់ខ្លួនយ៉ាងនេះ ក៏នាំគ្នាសម្លាប់ខ្លួនឯងខ្លះ សម្លាប់គ្នាទៅវិញទៅមកខ្លះ ចូលទៅរកនាយមិគលណ្ឌិកៈ ដែលស្លៀកពាក់ដូចជាសមណៈ ជួលឲ្យសម្លាប់ដោយបាត្រចីវរខ្លះ ដោយន័យនេះ នាយមិគលណ្ឌិកៈក៏ស៊ីឈ្នួលសម្លាប់ភិក្ខុទាំងឡាយ មួយថ្ងៃមួយរូបខ្លះ ពីររូបខ្លះ បីរូបខ្លះ បួនរូបខ្លះ ប្រាំរូបខ្លះ រហូតដល់ហុកសិបរូបខ្លះ [៣] ។

កាលបើគ្រប់មួយខែហើយ ទើបទ្រង់យាងត្រឡប់ចេញពីទីស្ងាត់ ទ្រង់ជ្រាបរឿងរ៉ាវនោះហើយ ក៏ត្រាស់ឲ្យភិក្ខុសង្ឃប្រជុំគ្នារួចទ្រង់សំដែងអានាបានស្សតិសមាធិ (គឺធ្វើចិត្តឲ្យតាំងមាំ ដោយការកំណត់ខ្យល់ដកដង្ហើមចេញចូល) ដោយអនេកបរិយាយ រួចហើយទើបទ្រង់ប្រារព្ធរឿងភិក្ខុសម្លាប់ខ្លួនឯង សម្លាប់គ្នាទៅវិញទៅមក ព្រមទាំងជួលគេឲ្យសម្លាប់ ទ្រង់តិះដៀលហើយបញ្ញត្តសិក្ខាបទ ***ហាមភិក្ខុសម្លាប់មនុស្ស ឬប្រើបុគ្គលដទៃឱ្យសម្លាប់ ទ្រង់ពិន័យអាបត្តិបារាជិកដល់ភិក្ខុដែលប្រព្រឹត្តកន្លងល្មើស។***

## អនុប្បញ្ញត្តិ

---

[៣] អដ្ឋកថាលើកពាក្យសួរថា ព្រះពុទ្ធទ្រង់មិនជ្រាបឬថា ភិក្ខុទាំងនោះនឹងនាំគ្នាសម្លាប់ខ្លួន ឬជួលគេឲ្យសម្លាប់ ។ រួចឆ្លើយថា ទ្រង់ជ្រាប ព្រោះភិក្ខុទាំងនោះក្នុងជាតិមុនធ្លាប់ជាព្រានម្រឹគ សម្លាប់សត្វរហូតដល់អស់ជីវិត ជារឿងរបស់កម្មដែលគ្មាននរណាអាចកែបាន ទើបព្រះអង្គជៀសចេញទៅអស់កន្លះខែ រឿងរបស់កម្មបើមិនស្លាប់យ៉ាងនេះ គង់តែស្លាប់ដោយរឿងដទៃដែរ ។

សម័យនោះ ឧបាសកម្នាក់មានជម្ងឺ ភិក្ខុឆព្វគ្គីយ៍មានសេចក្ដីពេញចិត្តទៅលើភរិយារបស់ឧបាសកនោះ ទើបពណ៌នាគុណនៃសេចក្ដីស្លាប់ ឧបាសកនោះក៏ជឿតាមហើយទទួលទានតែរបស់ដែលប្រឆាំងនឹងជម្ងឺ ជាហេតុនាំឲ្យរោគកម្រើក និងស្លាប់ដោយរោគនោះ ទើបភរិយារបស់ឧបាសកនោះ ពោលតិះដៀលលើកទោសពួកភិក្ខុឆព្វគ្គីយ៍ទាំងនោះ ។ រឿងរ៉ាវបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចត្រាស់សួរដឹងការពិតហើយ ទ្រង់ក៏តិះដៀល និងបញ្ញត្តិបន្ថែម ***ហាមពណ៌នាគុណនៃសេចក្ដីស្លាប់ ឬដឹកនាំគេឱ្យស្លាប់ថា ភិក្ខុរូបណាប្រព្រឹត្តល្មើសត្រូវអាបត្តិបារាជិក។***

បន្ទាប់ពីនោះ ជាពាក្យអធិប្បាយក្នុងបទបញ្ញត្តិសិក្ខាបទដោយលម្អិត និងមានការសំដែងអនាបត្តិមាន ៦ ប្រភេទ គឺ

១.ភិក្ខុមិនដឹង (ដូចជាធ្វើរបស់ធ្លាក់សង្កត់មនុស្សស្លាប់ ដោយអចេតនាជាដើម) ។

២.ភិក្ខុគ្មានបំណងនឹងឲ្យស្លាប់

៣.ភិក្ខុឆ្កួត

៤.ភិក្ខុមានចិត្ត រវើរវាយ (ឆ្កួតម្ដងម្កាល)

៥.ភិក្ខុរសាប់រសល់ ព្រោះវេទនាដ៏ខ្លាំងក្លា (មិនដឹងខ្លួន)

៦.ភិក្ខុដើមបញ្ញត្តិ ។

## វិនីតវត្ថុ

មានរឿងកើតឡើងផ្សេងៗ គ្នាប្រមាណ ១០០ រឿងដែលទាក់ទងនឹងទង្វើរបស់ភិក្ខុដែលមានបញ្ហាថា ត្រូវអាបត្តិបារាជិកព្រោះសិក្ខាបទនេះ ឬក៏ទេ ព្រះមានព្រះភាគទ្រង់សាកសួរ និងបញ្ជាក់ថា ត្រូវអាបត្តិខ្លះ មិនត្រូវអាបត្តិខ្លះ តាមសមគួរដល់ករណីដោយចំពោះគឺរឿងចុងក្រោយដែលទាក់ទងនឹងទង្វើរបស់ភិក្ខុនី ។

# ៥.ចតុត្ថបារាជិកកណ្ឌ

## (ពោលអំពីបារាជិកសិក្ខាបទទី ៤)

ផ្ដើមរឿងរ៉ាវដំណាលថា ព្រះមានព្រះភាគទ្រង់ប្រថាប់គង់នៅក្នុងព្រៃមហាវ័ន ក្បែរក្រុងវេសាលី ។ សម័យនោះមានភិក្ខុជាមិត្តសំឡាញ់នឹងគ្នាជាច្រើនរូប ចាំវស្សានៅក្បែរស្ទឹង

វគ្គមុទា ។ សម័យនោះ ក្នុងដែនវជ្ជី (រាជធានីវេសាលី) ភិក្ខុទាំងឡាយលំបាកដោយអាហារបិណ្ឌបាត ទើបប្រឹក្សាគ្នាថា ត្រូវធ្វើយ៉ាងណាទើបល្អ[៤] ។

រូបខ្លះយល់ថា គួរតែជួយណែនាំកិច្ចការខ្លះដល់គ្រហស្ថ រូបខ្លះទៀតយល់ថា គួរតែធ្វើជាទូត (គឺនាំរឿងខាងនេះទៅប្រាប់ខាងនោះ នាំរឿងខាងនោះមកប្រាប់ខាងនេះ ស្រដៀងគ្នានឹងប្រៃសណីយាករ អ្នកធ្វើការខាងប្រៃសណីយ៍) រូបខ្លះដទៃទៀតយល់ថា គួរតែប្រើវិធីសរសើរគ្នា ទៅវិញទៅមកឲ្យគ្រហស្ថគេស្តាប់ថា ភិក្ខុរូបនោះ ឬរូបនេះ មានគុណវិសេសយ៉ាងនោះ ឬយ៉ាងនេះ ដូចជាបានឈានទី ១ ឈានទី ២ ជាដើម រហូតដល់បានជាសោតាបន្ន សកទាគាមី ឬព្រះអរហន្តដែលមានវិជ្ជា ៣ អភិញ្ញា ៦ ។ កាលបើយល់ឃើញថា វិធីក្រោយបង្អស់ ជាវិធីល្អហើយ ទើបនាំគ្នាដើរសរសើរគុណវិសេស ដល់គ្នាទៅវិញទៅមកឲ្យគ្រហស្ថគេស្តាប់ លុះអ្នកស្ទឹងវគ្គមុទាឃើញដូច្នេះហើយ ទើបនាំគ្នាឧបត្ថម្ភភិក្ខុទាំងឡាយនោះ យ៉ាងគាប់ចិត្ត ។ នៅពេលចេញវស្សាហើយ ទើបរៀបចំទុកដាក់សេនាសនៈ រួចចារិកទៅគាល់ព្រះមានព្រះភាគនៅឯក្រុងវេសាលី ។

ប្រាកដថា ភិក្ខុដែលមកអំពីទិសដទៃសុទ្ធតែស្គមនិងមានពណ៌ សម្បុរគ្រោតគ្រាតរវាមដោយសរសៃ ឯចំណែកភិក្ខុដែលមក អំពីស្ទឹងវគ្គមុទាវិញ មានរាងកាយធំធាត់ ពណ៌សម្បុរស្រស់ថ្លា ទើបព្រះមានព្រះភាគត្រាស់សួរដល់សុខទុក្ខ កាលទ្រង់ជ្រាបដល់ រឿងនោះហើយ ក៏តិះដៀល និងត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចទ្រង់សំដែងរឿងមហាចោរ ៥ ប្រភេទ ប្រៀបធៀបទៅនឹងភិក្ខុគឺ

១.មហាចោរពួកមួយ គិតប្រមូលបក្សពួកមួយរយខ្លះ មួយពាន់ខ្លះ ដើម្បីចូលទៅសម្លាប់ ប្លន់ និងយកភ្លើងដុតកម្ទេចស្រុកខ្លះ រាជធានីខ្លះ ។ ក្រោយមកក៏ប្រមូលបក្សពួកមួយរយខ្លះ មួយពាន់ខ្លះ ទៅសម្លាប់ ប្លន់ និងដុតកម្ទេចស្រុកខ្លះ រាជធានីខ្លះ (តាមការគិត) ធៀបមកភិក្ខុរូបខ្លះ គិតប្រមូលពួកក្រុមមួយរយខ្លះ មួយពាន់ខ្លះ ដើម្បីចារិកទៅក្នុងស្រុក រាជធានី ដើម្បីឲ្យគ្រហស្ថនិងបព្វជិតធ្វើសក្ការៈបូជា (ដោយគិតថា) រួចនឹងបានចីវរ បិណ្ឌ-បាត សេនាសនៈ និងគិលានភេសជ្ជៈ ក្រោយមក ក៏ប្រមូលពួកក្រុម មួយរយខ្លះ មួយពាន់ខ្លះ ចារិកទៅក្នុងស្រុក រាជធានី

[៤] ជាសម័យដូចពោលមកហើយក្នុងបឋមបារាជិកសិក្ខាបទទី ១ ដែលពោលអំពីសុទិន្នភិក្ខុ ។

មានគ្រហស្ថ បព្វជិតធ្វើសក្ការៈបូជា ព្រមទាំងបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជៈ ។ នេះជាមហាចោរប្រភេទទី ១ (ដែលមានសេចក្ដីប្រាថ្នាក្នុងលាភសក្ការៈ រួចក៏ធ្វើឧបាយផ្សេងៗ រហូតដល់បានសម្រេច) ។

២.ភិក្ខុលាមករូបខ្លះ រៀនធម្មវិន័យដែលតថាគតប្រកាសហើយ ក៏ក្លែងថាជារបស់ខ្លួនឯង (សំដែងថា ខ្លួនគិតដោយខ្លួនឯង គ្មានបានរៀន ឬសិក្សាមកពីអ្នកណាឡើយ), នេះជាមហាចោរប្រភេទទី ២ ។

៣.ភិក្ខុលាមករូបខ្លះទៀត ចោទមួលបង្កាច់សំឡាញ់សព្រហ្មចារីយ៍បរិសុទ្ធថា ប្រព្រឹត្តព្រហ្មចរិយៈមិនត្រឹមត្រូវ មិនមានមូល, នេះជាមហាចោរប្រភេទទី ៣ ។

៤.ភិក្ខុលាមករូបខ្លះដទៃទៀត យករបស់សង្ឃដែលជាគរុភណ្ឌ គរុបរិក្ខារ (របស់ដែលហាមបែងចែក) ដូចជា អារាម ទីអារាម វិហារ ទីវិហារ គ្រែ កៅអីជាដើម ទៅសង្គ្រោះគ្រហស្ថ ប្រចុបប្រចែងគ្រហស្ថ (ព្រោះឃើញដល់លាភសក្ការៈ), នេះជាមហាចោរ ប្រភេទទី ៤ ។

៥.ភិក្ខុអួតគុណវិសេសដែលមិនមានពិត មិនកើតពិត ឈ្មោះថាជាកំពូលមហាចោរនៅក្នុងលោក ព្រោះបរិភោគដុំបាយរបស់អ្នកស្រុកដោយអាការលួច, នេះជាមហាចោរប្រភេទទី ៥ ។

លុះទ្រង់តិះដៀលពួកភិក្ខុដែលនៅមាត់ស្ទឹងវគ្គមុទា ដោយអនេកប្បរិយាយហើយ ទ្រង់ក៏បញ្ញត្តសិក្ខាបទហាមអួតគុណវិសេសដែលមិនមានពិតនៅក្នុងខ្លួន ពោលអួតរួចហើយ ក្រោយមកមានការសារភាព ក៏គង់ត្រូវអាបត្តិបារាជិក ។

## អនុប្បញ្ញត្តិ

សម័យនោះ ភិក្ខុជាច្រើនរូបសម្គាល់ខុសថា ខ្លួនបានពន្ធុះគុណវិសេស ទើបប្រកាសខ្លួនថា ជាព្រះអរហន្ត (ព្យាករណ៍អរហត្តផល) ។ សម័យក្រោយមក ចិត្តរបស់ពួកលោកក៏បង្អោនទៅដើម្បីរាគៈ ទោសៈ មោហៈ ទើបនាំគ្នារង្កៀសខ្លួនឯង សង្ស័យថាការប្រកាសខ្លួនថាបានពន្ធុះគុណវិសេស ដោយការសម្គាល់ខុសអាចធ្វើឲ្យត្រូវអាបត្តិបារាជិកឬ ដំណឹងនេះបានជ្រាបដល់ព្រះអង្គ ទើបទ្រង់បញ្ញត្តបន្ថែមទៀត វៀរលែងតែភិក្ខុសម្គាល់ខុសថាបានពន្ធុះ ។

បន្ទាប់មក ជាពាក្យអធិប្បាយសិក្ខាបទដោយលម្អិត រួចក៏សំដែងអនាបត្តិ ៦ ប្រការ គឺ

១ .ព្រោះសម្គាល់ខុសថាបានពន្ទុះ

២ .ភិក្ខុមិនប្រាថ្នានឹងពោលអួត (ដូចជានិយាយប្រាប់ដល់សំឡាញ់ សព្រហ្មចារីយ៍ ដោយមិនសំឡឹងឃើញលាភ) ។

៣ .ភិក្ខុឆ្កួត

៤ .ភិក្ខុ មានចិត្តរវើរវាយ (ឆ្កួតមួយផ្លូវខណៈ)

៥ .ភិក្ខុមានវេទនាខ្លាំង (មិនដឹងខ្លួន)

៦ .ភិក្ខុដើមបញ្ញត្តិ ។

## វិនីតវត្ថុ

បន្ទាប់ពីនោះមក សំដែងតួយ៉ាងផ្សេងៗ ដែលកើតឡើងទាក់ទងនឹងសិក្ខាបទនេះប្រមាណ ៧៥ រឿង ព្រះមានព្រះភាគទ្រង់សាកសួរ និងបញ្ជាក់ថា ត្រូវអាបត្តិបារាជិកខ្លះ មិនត្រូវអាបត្តិបារាជិកខ្លះ ត្រូវអាបត្តិថុល្លច្ច័យខ្លះ ត្រូវអាបត្តិទុក្កដខ្លះ តាមសមគួរដល់ករណីជាក់ស្តែង ។

សរុបអាបត្តិបារាជិកមាន ៤ សិក្ខាបទ បើប្រព្រឹត្តកន្លងហើយត្រូវដាច់ចាកភាវៈជាភិក្ខុ ទោះបីសឹកទៅ មកបួសជាភិក្ខុវិញ ក៏មិនបាន តែបើបួសជាសាមណេរបាន៕

# តេរសកណ្ឌ

## (អាបត្តិសង្ឃាទិសេស ១៣)

## សិក្ខាបទទី ១

## (ហាមធ្វើទឹកអសុចិឱ្យឃ្លាតចាកទី)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យមួយ ភិក្ខុឈ្មោះសេយ្យសកៈត្រូវភិក្ខុឧទាយី[៥] ណែនាំទៅក្នុងផ្លូវខុស បន្ទាប់ឲ្យប្រើដៃបញ្ចេញតម្រេក គឺធ្វើទឹកអសុចិ (ទឹកកាម) ឲ្យឃ្លាតចាកទី ដំណឹងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបព្រះអង្គត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចសាកសួរដើងរឿងសព្វគ្រប់ហើយ សេយ្យសកភិក្ខុក៏ទទួលសារភាពកំហុស ទ្រង់ក៏តិះ-

---

[៥] ភិក្ខុដែលមានឈ្មោះឧទាយីមាន ២ រូប គឺរូបទី ១ មានសម្បុរខ្មៅ ទើបគេនាំគ្នាហៅថា **កាឡុទាយី** (ឧទាយីខ្មៅ) ធ្លាប់ធ្វើជាអាមាត្យនៅក្នុងក្រុងកបិលពស្តុ ចេញបួសនៅពេលដែលព្រះពុទ្ធបិតាត្រាស់បញ្ជាឲ្យទៅទូលយាងព្រះពុទ្ធជាម្ចាស់ ។ ចំណែកភិក្ខុឧទាយីដែលពោលសំដៅយកនៅក្នុងទីនេះ គឺចូលចិត្តបន្តរឿងសៅហ្មងជាញឹកញាប់ ទើបមានឈ្មោះថា **លោលុទាយី** (ឧទាយីលោលា ឬឡេះឡោះ) ។

ដៀលសេយ្យសកភិក្ខុជាច្រើន ហើយទ្រង់បញ្ញត្តសិក្ខាបទហាមធ្វើទឹកអសុចិ ឲ្យឃ្លាតចាកទីដោយចេតនា បើប្រព្រឹត្តល្មើសត្រូវអាបត្តិសង្ឃាទិសេស (អាបត្តិដែលត្រូវឲ្យសង្ឃចូលពាក់ព័ន្ធខាងដើមនិងដីសេស គឺសង្ឃជាអ្នកដាក់ទោសឲ្យនៅក្នុងកម្ម និងសង្ឃជាអ្នករម្ងាប់អាបត្តិ) ជាប្រភេទនៃទណ្ឌកម្មដែលធ្ងន់ជាងសាមណេរ បើប្រៀបធៀបទៅនឹងទណ្ឌកម្មរបស់សាមណេរ ។

## អនុប្បញ្ញត្តិ

សម័យនោះ ភិក្ខុទាំងឡាយសឹង (ដេក) លក់ ទឹកអសុចិក៏ឃ្លាតចេញមកដោយការយល់សប្តិ៍ កើតសេចក្ដីសង្ស័យថា ត្រូវអាបត្តិសង្ឃាទិសេស ទើបនាំគ្នាក្រាបទូលសួរព្រះមានព្រះភាគ ព្រះអង្គត្រាស់ថា ចេតនាមានក៏ពិតមែន តែជាអព្យោហារិក (គឺមិនគួរដល់ការពោលថា មានឧបមាដូចជាចាក់ទឹកចេញពីកែវហើយនៅសល់ទឹកបន្តិចបន្តួចជាប់បាតកែវ ក៏មិនគួរដល់ការពោលថា មានទឹកក្នុងកែវដូច្នោះដែរ) ហើយទើបទ្រង់បញ្ញត្តសិក្ខាបទបន្ថែមទៀត គឺវៀរលែងសម្រាប់ការយល់សប្តិ៍ ។

បន្ទាប់មក ជាពាក្យអធិប្បាយសិក្ខាបទដោយពិស្តារ រួចពោលអំពីអនាបត្តិមាន ៦ ប្រការ គឺ

១.មិនត្រូវអាបត្តិ ព្រោះយល់សប្តិ៍
២.ភិក្ខុគ្មានចេតនានឹងធ្វើឲ្យឃ្លាត
៣.ភិក្ខុឆ្កួត
៤.ភិក្ខុមានចិត្តរវើរវាយ
៥.ភិក្ខុមានវេទនាខ្លាំង
៦.ភិក្ខុដើមបញ្ញត្តិ ។

## វិនីតវត្ថុ

បន្ទាប់មកទៀត សំដែងតួយ៉ាងផ្សេងៗ ដែលកើតឡើងទាក់ទងទៅនឹងទង្វើរបស់ភិក្ខុក្នុងសិក្ខាបទនេះប្រមាណ ៧១ រឿង ដែលព្រះមានព្រះភាគទ្រង់ត្រាស់សួរដោយព្រះអង្គផ្ទាល់ និងវិនិច្ឆ័យបញ្ជាក់ថា ត្រូវអាបត្តិសង្ឃាទិសេសខ្លះ មិនត្រូវខ្លះ តាមសមគួរដល់ករណីជាក់ស្ដែង ។

## សិក្ខាបទទី ២

## (ហាមប៉ះពាល់កាយស្ត្រី)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងជេតវនារាមដូចធ្លាប់បានពោលរួចហើយ ទ្រង់ត្រាស់ដល់វិហារ (ទីលំនៅ) របស់ឧទាយីភិក្ខុថា ស្អាតស្អំល្អ មានគ្រែ កៅអី ពូកខ្នើយ ទឹកបរិភោគប្រើប្រាស់ និងបរិវេណស្អាតរៀបរយល្អ ។ មនុស្សទាំងឡាយនាំគ្នាទៅទស្សនាយ៉ាងច្រើនកុះករ ។ មានព្រាហ្មណ៍ម្នាក់នាំភរិយាទៅទស្សនាវិហារនឹងគេដែរ ឧទាយីភិក្ខុនាំដើរមើល ហើយឲ្យព្រាហ្មណ៍ដើរទៅមុខ ភរិយាដើរខាងក្រោយបន្ទាប់មក ខ្លួនឯងដើរពីក្រោយភរិយាព្រាហ្មណ៍នោះ ស្រាប់តែឆក់ឱកាសប៉ះពាល់អវៈយវៈតូចធំរបស់នាង នាងក៏ប្រាប់ដល់ព្រាហ្មណ៍ជាស្វាមី ព្រាហ្មណ៍ខឹងសម្បារជាខ្លាំង រួចពោលទោសតិះដៀលជាច្រើនដល់ឧទាយីភិក្ខុ ដំណឹងនោះក៏បានជ្រាបដល់ព្រះពុទ្ធទ្រង់ក៏ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចសាកសួរដឹងការពិតហើយទើបទ្រង់តិះដៀលច្រើនជាអនេក រួចហើយបញ្ញត្តសិក្ខាបទហាមភិក្ខុមានចិត្តត្រេកប៉ះពាល់កាយស្ត្រី មិនថាប៉ះពាល់ដៃ សក់ ឬស្ពាបអង្អែលអវៈយវៈត្រង់ណាក៏ដោយ ទ្រង់ពិន័យអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលប្រព្រឹត្តកន្លងល្មើស ។

បន្ទាប់មក ជាពាក្យអធិប្បាយសិក្ខាបទយ៉ាងពិស្តារ និងសំដែងលក្ខណៈដែលមិនត្រូវអាបត្តិ ស្រដៀងគ្នានឹងសិក្ខាបទមុនៗដែរ ចុងបញ្ចប់ទ្រង់សំដែងវិនីតវត្ថុ គឺរឿងដែលកើតឡើងហើយព្រះមានព្រះភាគទ្រង់វិនិច្ឆ័យ សាកសួរ បញ្ជាក់ ដោយព្រះអង្គផ្ទាល់ ដែលទាក់ទងនឹងសិក្ខាបទនេះ ប្រមាណ ២០ រឿង ។

## សិក្ខាបទទី ៣

## (ហាមនិយាយរឿងស្ត្រី)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងជេតវនារាមដូចមុនៗ ដែរ ។ សម័យនោះ មានស្ត្រីជាច្រើន នាំគ្នាទៅទស្សនាវិហាររបស់ឧទាយីភិក្ខុដែលល្បីខ្ទរខ្ទារថា វិចិត្រល្អឥតខ្ចោះ ឧទាយីភិក្ខុក៏ឆក់ឱកាសនោះ និយាយប៉ះពាល់ដល់ទ្វារតូចទ្វារធំរបស់ស្ត្រីទាំងនោះ ។ ស្ត្រីខ្លះជាមនុស្សមិនខ្មាស់អៀន ក៏ញញឹមញញែម ធ្មើបុកម្មិកម្ម៉ក់ កាច់បុកកាច់រាង និយាយលេងខាយជាមួយឧទាយីភិក្ខុ ។ ចំណែកស្ត្រីខ្លះទៀត ជាមនុស្សអៀនខ្មាស់ ក៏ពោលទោសតិះដៀល ដំណឹងនេះបានជ្រាប

ដល់ព្រះមានព្រះភាគ ទ្រង់ក៏ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចសាកសួរដឹងការពិតហើយ ទើបតិះដៀល និងបញ្ញត្តសិក្ខាបទ ***ហាមភិក្ខុមានចិត្តតម្រេក និយាយរឿងស្ត្រីដោយវាចាគ្រោតគ្រាត អាស្រ័យមេថុន ទំនងដូចជាបុរសនិយាយចែចង់ស្រីក្រមុំ[៦] ទ្រង់ពិន័យអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលប្រព្រឹត្តកន្លងល្មើស។***

បន្ទាប់ពីនោះ ជាពាក្យអធិប្បាយសិក្ខាបទយ៉ាងពិស្តារ និងសំដែងដល់អនាបត្តិ សម្រាប់ភិក្ខុដែលនិយាយក្នុងបំណងសំដៅដល់ អត្ថ ធម៌ សាសនៈ ភិក្ខុឆ្កួត និងភិក្ខុដើមបញ្ញត្តិ រួចហើយសំដែងដល់ វិនីតវត្ថុ គឺរឿងដែលកើតឡើង ព្រះពុទ្ធទ្រង់វិនិច្ឆ័យ សាកសួរ បញ្ជាក់ សរុបមាន ១៧ រឿង ។

## សិក្ខាបទទី ៤

## (ហាមនិយាយល្បួងស្ត្រីឱ្យបម្រើខ្លួនដោយកាម)

៦ ការនិយាយរបស់ជនជាតិឥណ្ឌាក្នុងសម័យនោះ អាចជាការនិយាយយ៉ាងនេះ លក្ខណៈក្នុងការប្រើពាក្យអាចផ្លាស់ប្តូរទៅតាមកាលៈទេសៈ គប្បីយល់ថាការ ប្រើពាក្យដែលមានលក្ខណៈចង់ស្ត្រី រមែងរាប់បញ្ចូលក្នុងសិក្ខាបទនេះ ។

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងជេតវនារាមដូចមុនៗ ដែរ ។ សម័យនោះ ឧទាយីភិក្ខុបានចូលទៅរកត្រកូលស្ត្រីមេម៉ាយ ដ៏ស្រស់ស្អាតម្នាក់ រួចហើយទេសនារហូតដល់ស្ត្រីនោះកើតសេចក្តីជ្រះថ្លាលើលោក នាងមានបំណងនឹងប្រគេនបច្ច័យបួន (ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជៈ) តែឧទាយីភិក្ខុត្រឡប់ជានិយាយលួងលោម និងបបួលស្ត្រីនោះឲ្យបម្រើខ្លួនដោយកាមគុណ ដោយជឿថា ជារបស់រកបានដោយលំបាក នាងក៏ផុងខ្លួនជឿតាម សំដែងអាការយល់ព្រម ឧទាយីភិក្ខុត្រឡប់ជាស្តោះទឹកមាត់ដាក់ ដោយសំដែងអាការគួរខ្ពើម ។ ស្ត្រីនោះក៏ពោលទោសតិះដៀលឧទាយីភិក្ខុ ដំណឹង នេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបព្រះអង្គត្រាស់ហៅភិក្ខុ សង្ឃមកប្រជុំគ្នា រួចសាកសួរតិះដៀលហើយ ទ្រង់ក៏បញ្ញត្តសិក្ខា-បទ ***ហាមភិក្ខុមានចិត្តតម្រេក និយាយលួងលោមស្ត្រី ឱ្យបម្រើខ្លួន ដោយកាមគុណ***

*ទ្រង់ពិន័យអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលប្រព្រឹត្តកន្លងល្មើស។*

បន្ទាប់ពីនោះ ជាពាក្យអធិប្បាយសិក្ខាបទដោយពិស្តារ និងសំដែងអនាបត្តិមាន ៣ ប្រការ គឺ

១.និយាយឲ្យទំនុកបម្រុង ដោយបច្ច័យបួន

២.ភិក្ខុឆ្កួត

៣.ភិក្ខុដើមបញ្ញត្តិ ។

រួចហើយសំដែងវិនីវត្ថុ សរុបមាន ៧ រឿង ដែលព្រះមានព្រះភាគបញ្ញាក់ថា ត្រូវអាបត្តិសង្ឃាទិសេស ឬមិនត្រូវអាបត្តិសង្ឃាទិសេស ។

## សិក្ខាបទទី ៥

## (ហាមដឹកនាំកំលោះក្រមុំឱ្យបានគ្នា)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងជេតវនារាមដូចមុនៗ ដែរ ។ សម័យនោះ ភិក្ខុឧទាយីឃើញក្មេងប្រុសនៅលីវ ក្មេងស្រីនៅលីវ ក៏ទៅនិយាយសរសើរក្មេងស្រី ក្នុងសំណាក់មាតាបិតារបស់ក្មេងប្រុស ពួកគេបានពឹងពាក់លោកឲ្យទៅចូលស្តីដណ្តឹងក្មេងស្រី រួចទៅនិយាយសរសើរក្មេងប្រុសក្នុងសំណាក់មាតាបិតារបស់ក្មេងស្រី ពួកគេក៏ពឹងពាក់លោកឲ្យប្រាប់ខាងក្មេងប្រុសមកចូលស្តីដណ្តឹងកូនស្រីរបស់ខ្លួន ។ តាមន័យនេះ ឧទាយីភិក្ខុក៏ធ្វើឲ្យកើតអាវាហៈ វិវាហៈ និងក្លាយជាចៅមហាជាច្រើនកន្លែង ។

សម័យនោះ មានកូនស្រីរបស់សោភិនីម្នាក់មានរូបរាងស្រស់ស្អាត សាវ័ករបស់អាជីវកដែលរស់នៅតំបន់ផ្សេងគ្នាមកសុំកូនស្រីនោះ តែមាតារបស់នាងនិយាយថា នាងមិនស្គាល់ ថែមទាំងមានកូនស្រីតែម្នាក់ទៀត ហើយកូនគាត់នឹងត្រូវទៅនៅតំបន់ដទៃទើបគាត់មិនព្រមប្រគល់ឲ្យទៅ ។ ទើបសាវ័ករបស់អាជីវកចូលទៅរកឧទាយីភិក្ខុ ហើយពឹងឲ្យជួយសុំ និងធានារ៉ាប់រងឲ្យ ឧទាយីភិក្ខុក៏ទៅនិយាយជាមួយស្ត្រីជាម្តាយក្មេងស្រីនោះ នាងជឿថា ឧទាយីភិក្ខុស្គាល់ ទើបព្រមលើកឲ្យ ។ សាវ័ករបស់អាជីវកទទួលយកក្មេងស្រីនោះទៅចិញ្ចឹម ដូចកូនប្រសារបានមួយខែគត់ ក្រោយមកក៏ចិញ្ចឹមដូចជាទាសី ។ ទើបក្មេងស្រីនោះផ្តល់ដំណឹងដល់ម្តាយថា ខ្ញុំគេបានទទួលនូវភាពលំបាក រស់នៅដូចជាទាសី សូមឲ្យម្តាយ មក

ទទួលយកកូនត្រឡប់ទៅវិញ ទើបនាងទៅតវ៉ា ជាមួយនឹងសាវ័កអាជីវកនោះ តែត្រូវគេនិយាយបកមកវិញថា ការនាំមក នាំទៅ មិនទាក់ទងនឹងនាងទេ តែទាក់ទងនឹងឧទាយីភិក្ខុ ទើបមិនទទួលដឹងក្នុងរឿងនេះ នាងក៏ត្រូវវិលត្រឡប់ទៅកាន់ក្រុងសាវត្ថី វិញ ។

ក្មេងស្រីនោះ បញ្ជូនដំណឹងទៅដល់ម្ដាយជាលើកទី ២ និយាយប្រាប់ពីភាពលំបាក ក្នុងការដែលរស់នៅក្នុងសភាពជាទាសី សូមឲ្យម្ដាយមកនាំខ្លួនគេទៅវិញ ទើបម្ដាយរបស់ក្មេងស្រីនោះទៅរកឧទាយីភិក្ខុពឹងលោកឲ្យជួយនិយាយ ។ ឧទាយីភិក្ខុក៏ទៅនិយាយតាមការស្នើរបស់នាងជាម្ដាយ តែត្រូវគេនិយាយបកមកវិញថា មិនទាក់ទងជាមួយឧទាយីភិក្ខុទេ ការនាំមក នាំទៅជារឿងរវាងគេហើយនឹងម្ដាយរបស់ក្មេងស្រី លោកជាសមណៈគួរតែខ្វល់ខ្វាយតិច គួរតែជាសមណៈល្អ ទើបឧទាយីភិក្ខុត្រូវវិលត្រឡប់មកវិញ ។

ក្មេងស្រីនោះ ក៏បញ្ជូនដំណឹងទៅប្រាប់ម្ដាយជាលើកទី ៣ ទៀត សូមឲ្យនាំខ្លួនត្រឡប់ទៅវិញ ម្ដាយក្មេងស្រីនោះ ក៏ចូលទៅរកឧទាយីភិក្ខុៗ ប្រាប់ថា ទៅរួចហើយ លោកក៏ប្រកែកលែងទៅទៀត ។ ម្ដាយក្មេងស្រីនោះ និងស្ត្រីដទៃទៀត ដែលមិនពេញចិត្តម្ដាយក្មេក ឪពុកក្មេក ប្ដី ក៏នាំគ្នាពោលទោស តិះដៀលឧទាយីភិក្ខុ ។ ចំណែកស្ត្រីដែលពេញចិត្តម្ដាយក្មេក ឪពុកក្មេក ប្ដី ក៏នាំគ្នាសរសើរឧទាយីភិក្ខុ ។

ដំណឹងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ហៅសង្ឃមកប្រជុំគ្នា រួចត្រាស់សួរបានជ្រាបការពិតហើយ ទ្រង់ក៏តិះដៀល និងបញ្ញត្តសិក្ខាបទ ហាមភិក្ខុដឹកនាំបុរសស្ត្រីឲ្យបានគ្នាជាប្ដីប្រពន្ធ ទ្រង់ពិន័យអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលប្រព្រឹត្តល្មើស ។

ក្រោយមក ឧទាយីភិក្ខុបង្ករឿងថ្មីមួយទៀត ដោយពួកអ្នកលេងពឹងឲ្យនាំស្រីសោភិនីមក ដើម្បីបំពេញចំណង់របស់ខ្លួនមាន គេពោលទោសតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ បន្ថែមទៀតថា ដោយហោចទៅ សូម្បីការដឹកនាំដូចនោះ ដើម្បីបំពេញបំណងរបស់គេមួយជួរខណៈ ក៏ត្រូវអាបត្តិសង្ឃាទិសេសដែរ ។

បន្ទាប់ពីនោះមក ជាពាក្យអធិប្បាយសិក្ខាបទដោយពិស្ដារ និងសំដែងលក្ខណៈការមិនត្រូវអាបត្តិថា ១.ទៅដោយកិច្ចរបស់សង្ឃ របស់ចេតិយ និងរបស់ភិក្ខុអាពាធ ២.ភិក្ខុឆ្កួត ៣.ភិក្ខុដើមបញ្ញត្តិ មិនត្រូវអាបត្តិ រួចហើយក៏សំដែងតួយ៉ាងដែលកើតឡើង

៧ រឿង ដែលទាក់ទងទៅនឹងសិក្ខាបទនេះ ដោយព្រះមានព្រះភាគ ទ្រង់វិនិច្ឆ័យបញ្ចាក់ ។

## សិក្ខាបទទី ៦

## (ហាមធ្វើកុដិដោយការសុំ)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុង វេឡុវនារាម ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះ ភិក្ខុដែនអាឡវីឲ្យគេ ធ្វើកុដិដែលមិនមានម្ចាស់ (ក្នុងទីដែលគ្មានម្ចាស់) ដើម្បីជាប្រយោជន៍ ដល់ខ្លួន ជាកុដិមិនមានប្រមាណ (មិនកំណត់ទីពិតប្រាកដ) ដោយ ការសុំខ្លួនឯង (គឺសុំទាំងសម្ភារៈនិងមនុស្សធ្វើការ) កុដិនៅមិនទាន់ សម្រេចនៅឡើយ ពួកលោកក៏ច្រើនទៅដោយការសុំ ដូចជា សុំ មនុស្សធ្វើការ គោ រទេះ កាំបិត ពូថៅ ជាដើម បង្កសេចក្តី ក្តៅក្រហាយដល់មនុស្សជាច្រើនៗ ដល់ថ្នាក់ក្រឡេកឃើញភិក្ខុចូល ទៅ នាំគ្នាភ័យខ្លាចរត់ពួនខ្លះ គេចទៅផ្លូវដទៃខ្លះ ងាកមុខចេញខ្លះ បិទទ្វារខ្លះ រហូតដល់ឃើញគោ សម្គាល់ថា ជាភិក្ខុ ហើយ ក៏នាំគ្នារត់ពួនខ្លះ [៧] ។

ព្រះមហាកស្សបៈចារិកទៅកាន់ដែនអាឡវី ហើយក៏សម្រាក នៅត្រង់អគ្គាឡវចេតិយ៍ ពេលលោកចេញទៅបិណ្ឌបាត ក៏ស្រាប់តែ ជួបមនុស្សទាំងឡាយ ដែលកំពុងតែភ័យខ្លាចរត់គេចពួន នៅពេល លោកវិលត្រឡប់មកវិញ ក៏សួរភិក្ខុទាំងឡាយដឹងរឿងសព្វគ្រប់ហើយ ខណៈពេលដែលព្រះពុទ្ធទ្រង់ស្តេចចារិកទៅកាន់ក្រុងអាឡវី លោកក៏ បានប្រាប់រឿងនោះដល់ព្រះអង្គ ទើបទ្រង់ត្រាស់ហៅភិក្ខុសង្ឃមក ប្រជុំគ្នា ទ្រង់ប្រដៅមិនឲ្យប្រាថ្នាច្រើន ទ្រង់សំដែងរឿងប្រកប ៣ រឿង រួចទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុឲ្យគេធ្វើកុដិដោយមិនមានម្ចាស់ ជាទីនៅរបស់ខ្លួនមានការសុំវត្ថុផ្សេងៗ ដោយខ្លួនឯង គប្បីធ្វើមាន ឲ្យប្រមាណ គឺបណ្តោយមិនលើសពី ១២ ហត្ថ ទទឹងមិនលើសពី ៧ ហត្ថ តែត្រូវឲ្យភិក្ខុទាំងឡាយសំដែងទីឲ្យជាមុន, ភិក្ខុទាំងឡាយ គប្បីសំដែងទីដែលគ្មានម្ចាស់ដោយជុំវិញ បើភិក្ខុណាឲ្យគេធ្វើកុដិ មានការសុំរបស់ផ្សេងៗ ដោយខ្លួនឯង ក្នុងទីដែលមានម្ចាស់

---

[៧] រឿងនេះទុកគ្រាន់ទូន្មានចិត្តឲ្យសង្រួមក្នុងការរៃអង្គាសដែលរំខានដល់អ្នកស្រុក រហូតដល់មិនអាចធ្វើអ្វីកើត និងគួរដឹងខ្លួនថា ព្រះពុទ្ធទ្រង់រឹតបន្តឹងរឿងនេះ ជាកំហិត ។

ដោយ មិនជុំវិញ មិនឲ្យភិក្ខុសំដែងទីជាមុនក្តី ធ្វើឲ្យលើសប្រមាណក្តី ត្រូវ អាបត្តិសង្ឃាទិសេស ។

បន្ទាប់ពីនោះ ជាពាក្យអធិប្បាយសិក្ខាបទដោយពិស្តារ និងអធិប្បាយដល់លក្ខណៈមិនត្រូវអាបត្តិ ដែលជាហេតុមិនធ្វើឲ្យអ្នកស្រុកក្តៅក្រហាយ ភិក្ខុឆ្កួត និងភិក្ខុដើមបញ្ញត្តិ ។

## សិក្ខាបទទី ៧

### (ហាមធ្វើវិហារធំដែលសង្ឃមិនបានកំណត់ទីឱ្យ)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងឃោសិតារាម ក្រុងកោសម្ពី ។ គ្រានោះ មានគហបតីម្នាក់ជាអ្នកឧបដ្ឋាក (ទំនុកបម្រុង) ឆន្នភិក្ខុ សុំឲ្យឆន្នភិក្ខុសំដែងទីឲ្យ ហើយគាត់នឹងធ្វើវិហារថ្វាយ ។ ឆន្នភិក្ខុឲ្យគេពង្រាបទី កាប់ដើមឈើដែលអ្នកស្រុកមានជំនឿថាជាវត្ថុសក្តសិទ្ធិ ជាវត្ថុជួយជំរុញកម្លាំងចិត្ត ទើបមនុស្សទាំងឡាយ ពោលទោស តិះដៀល បន្ទោសបង្អាប់ ។ ដំណឹងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់តិះដៀល រួចបញ្ញត្តសិក្ខាបទថា ***ភិក្ខុឱ្យគេធ្វើវិហារធំដែលមានម្ចាស់សម្រាប់ខ្លួន គប្បីនាំភិក្ខុទៅសំដែងទីឱ្យ។ ភិក្ខុទាំងនោះ គប្បីសំដែងទីដែលគ្មានម្ចាស់ ដោយជុំវិញ ភិក្ខុមិនត្រូវឱ្យគេធ្វើវិហារធំដែលជាកន្លែងមានម្ចាស់ ដោយជុំវិញ ឬមិននាំភិក្ខុទាំងឡាយទៅសំដែងទីឱ្យទេ ត្រូវអាបត្តិសង្ឃាទិសេស។***

បន្ទាប់ពីនោះ ជាពាក្យអធិប្បាយសិក្ខាបទ[៨] ដោយពិស្តារ ឯលក្ខណៈមិនត្រូវអាបត្តិ ដូចសិក្ខាបទទី ៦ ដែរ ។

## សិក្ខាបទទី ៨

### (ហាមចោទអាបត្តិបារាជិកដោយគ្មានមូល)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងវេឡុវនារាម ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះ ព្រះទព្វមល្លបុត្រ (បុត្ររបស់មល្លក្សត្រ) បានពន្លះអរហត្តផលតាំងពីនៅព្រះជន្ម ៧ ព្រះវស្សា ពុំមានកិច្ចដែលត្រូវធ្វើតទៅទៀតឡើយ ។ ក្រោយមក

---

[៨] សិក្ខាបទនេះ ផ្សេងពីសិក្ខាបទទី ៦ ដោយន័យសំខាន់ គឺសិក្ខាបទទី ៦ ភិក្ខុធ្វើដោយខ្លួនឯង ដោយការសុំរបស់របរ និងកម្លាំង ។ ចំណែកក្នុងសិក្ខាបទនេះ ឲ្យអ្នកដទៃធ្វើឲ្យ ទើបគ្មានការកំណត់ខ្នាត តែត្រូវឲ្យសង្ឃសម្តែងទីឲ្យ ដូចសិក្ខាបទមុនដែរ ដើម្បីការពារមិនឲ្យធ្វើតាមអំពើចិត្ត ដើម្បីឲ្យមានរបៀប និងដើម្បីមិនឲ្យអ្នកស្រុករង្កៀស ។ គប្បីសង្កេតចំណុចមួយថា ទាំងពីរសិក្ខាបទនេះ អនុញ្ញាតឲ្យកសាងទីលំនៅដោយមានបរិវេណជុំវិញ ទំហំប៉ុនរទេះអាចបត់បាន មិននិយមឲ្យធ្វើជាប់គ្នានោះទេ ។

លោកប្រាថ្នានឹងធ្វើប្រយោជន៍ដល់សង្ឃ គឺធ្វើជាអ្នកចាត់ចែងសេនា-សនៈ (សេនាសនបញ្ញាបកៈ មានតួនាទីរៀបចំចាត់ចែងកន្លែងស្នាក់នៅដល់អាគន្តុកភិក្ខុ គឺភិក្ខុអ្នកដើរផ្លូវ) និងជាអ្នកចែកភត្ត (ភត្តុទ្ទេសកៈ មានតួនាទីចាត់ភិក្ខុទៅទទួលចង្ហាន់ នៅកន្លែងដែលគេបាននិមន្តទុក ក្នុងពេលដែលទាយកមកនិមន្តព្រះសង្ឃ) ទើបក្រាបទូលពីបំណងរបស់លោកដល់ព្រះមានព្រះភាគ ។

ព្រះអង្គប្រទានពរសាធុការ និងទ្រង់សំដែងព្រះទ័យយល់ព្រមដោយឲ្យលោកធ្វើនាទីទាំងពីរនោះ ។

ទើបត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចឲ្យសង្ឃទៅហៅព្រះទព្វមល្លបុត្រមកហើយ ឲ្យភិក្ខុមួយរូបសូត្រប្រកាសសេចក្ដីសម្រេចក្នុងការសន្មតព្រះទព្វមល្លបុត្រជាអ្នកចែកសេនាសនៈ និងចែកភត្ត កាលបើគ្មានអ្នកជំទាស់ហើយ ទើបសង្ឃតែងតាំងលោកតាមរយៈការសន្មត ។

ព្រះទព្វមល្លបុត្រ បានបំពេញតួនាទីយ៉ាងល្អហ្មត់ចត់ ។ គ្រាមួយនោះ ត្រូវពួកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ (ទាំងពីររូបនេះ ជាប្រធានក្រុមរបស់ភិក្ខុដែលពូកែបង្ករឿងអាក្រក់) យល់ខុស ចោទប្រកាន់លោកថា បានទៅណែនាំគហបតីម្នាក់ មិនឲ្យប្រគេនអាហារដល់ពួកខ្លួន តាមការពិតនោះ គឺគហបតីនោះ មិនជ្រះថ្លា និងរង្កៀសពួកលោកដោយខ្លួនឯង ។ ទើបប្រើមេត្តិយាភិក្ខុនី ឲ្យចោទមួលបង្កាច់ព្រះទព្វមល្លបុត្រ ក្នុងបទត្រូវអាបត្តិបារាជិក ព្រោះចាប់រំលោភនាង ។

ព្រះពុទ្ធត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា សាកសួរដឹងថា ជាការមួលបង្កាច់ ទើបផ្សឹកមេត្តិយាភិក្ខុនីនោះទៅ ។ ពួកមេត្តិយ-ភិក្ខុចេញមុខសារភាពកំហុស ក៏ព្រះអង្គមិនព្រម ត្រឡប់ជាទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចតិះដៀលពួកភិក្ខុដែលមានគំនិតអាក្រក់ ចោទមួលបង្កាច់ព្រះទព្វមល្លបុត្រ ដោយអាបត្តិបារាជិកមិនមានមូល រួចហើយទ្រង់បញ្ញត្តសិក្ខាបទ ពិន័យអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលប្រព្រឹត្តដូចនោះ ។

បន្ទាប់ពីនោះមក ជាពាក្យអធិប្បាយសិក្ខាបទដោយពិស្ដារនិងសំដែងលក្ខណៈដែលមិនត្រូវអាបត្តិថាៈ

១.ចោទដោយយល់ខុស លើភិក្ខុបរិសុទ្ធ ថាមិនបរិសុទ្ធ

២.ចោទភិក្ខុមិនបរិសុទ្ធពិតមែន

៣.ភិក្ខុឆ្កួត

៤.ភិក្ខុដើមបញ្ញត្តិ ។

## សិក្ខាបទទី ៩

## (ហាមអាងលេសហើយចោទអាបត្តិ)

ដើមរឿងដំណាលថា ពួកមេត្តេយ្យភិក្ខុ និងភុម្មជ្ជកភិក្ខុដដែល ក្លែងរកលេសចោទប្រកាន់ព្រះទព្វមល្លបុត្រ ដោយអាបត្តិបារាជិក មិនមានមូល គឺឃើញពពែឈ្មោលកំពុងពាក់គ្នាជាមួយពពែញី ក៏បបួលគ្នាតាំងឈ្មោះពពែឈ្មោលថា ព្រះទព្វមល្លបុត្រ តាំងឈ្មោះពពែញីថា មេត្តេយ្យាភិក្ខុនី រួចហើយដើរនិយាយថា ខ្លួនបានឃើញព្រះទព្វមល្លបុត្រខូច (ប្រព្រឹត្តអនាចារ) ជាមួយមេត្តេយ្យាភិក្ខុនី ដោយភ្នែករបស់ខ្លួនផ្ទាល់ ។

រឿងនោះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចត្រាស់សួរទៅព្រះទព្វមល្លបុត្រ ជ្រាបថា ជាការអាងលេសមួលបង្កាច់ បន្ទាប់មកក៏ប្រគល់ឲ្យសង្ឃធ្វើការសាកសួរពួកភិក្ខុដែលអាងលេសមួលបង្កាច់ នៅពេលពួកលោកទទួលសារភាព ទើបព្រះមានព្រះភាគតិះដៀល រួចបញ្ញត្តសិក្ខាបទ ***ហាមភិក្ខុអាងលេសចោទភិក្ខុ ដោយអាបត្តិបារាជិក មិនមានមូល ទ្រង់ពិន័យអាបត្តិសង្ឃាទិសេស ដល់ភិក្ខុដែលប្រព្រឹត្តល្មើស។***

តទៅជាពាក្យអធិប្បាយសិក្ខាបទដោយពិស្តារ និងពាក្យអធិប្បាយលក្ខណៈមិនត្រូវអាបត្តិ ដូចគ្នានឹងសិក្ខាបទទី ៨ ដែរ ។ (ចាប់ពីសិក្ខាបទទី ១ ដល់ទី ៩ ហៅថា បឋមាបត្តិកៈ គឺត្រូវអាបត្តិតាំងតែពីធ្វើដំបូង ចំណែកសិក្ខាបទទី ១០ ដល់ទី ១៣ ហៅថា យាវតតិយកៈ គឺសង្ឃត្រូវសូត្រប្រកាស ៣ ដង បើមិនព្រមលះបង់ ទើបត្រូវអាបត្តិ) ។

## សិក្ខាបទទី ១០

## (ហាមបំបែកសង្ឃ)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងវេឡុវនារាមដដែលនោះ រួចហើយទ្រង់សំដែងរឿងទេវទត្តចូលទៅរកកោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ភិក្ខុដែលជាបុត្ររបស់នាងបណ្ឌទេវី និងសមុទ្ទត្តភិក្ខុ បបួលគ្នាបំបែកសង្ឃ ព្រមទាំងប្រាប់ផែនការដែលដាក់ឡើងដើម្បីឲ្យរឹងមាំថែមទៀត ៥ ចំណុច ដែល

បានគិតរួចហើយថា ព្រះមានព្រះភាគមុខជាទ្រង់មិនអនុញ្ញាត រួចហើយពួកលោកនឹងយកផែនការនោះ ប្រកាសដល់មហាជន ។

ផែនការ ៥ ចំណុចនោះ គឺ

១.ភិក្ខុត្រូវនៅព្រៃអស់មួយជីវិត ចូលស្រុកត្រូវមានទោស

២.ភិក្ខុត្រូវត្រាច់បិណ្ឌបាតអស់មួយជីវិត រូបណាទទួលនិមន្ត (ទៅឆាន់ក្នុងស្រុក) ត្រូវមានទោស ។

៣.ភិក្ខុត្រូវប្រើសំពត់បង្សុកូល (សំពត់ប្រឡាក់ដី គឺសំពត់ ឬផ្ទាំងសំពត់តូចៗ ដែលគេចោលតាមគំនរសម្រាមខ្លះ តាមកន្លែងផ្សេងៗ ខ្លះ យកមកគក់ និងដេរប៉ះកតជាចីវរ) អស់មួយជីវិត ភិក្ខុរូបណាទទួលគហបតីចីវរ (សំពត់ដែលគេប្រគេនស្រាប់) ត្រូវមានទោស ។

៤.ភិក្ខុត្រូវនៅក្រោមដើមឈើអស់មួយជីវិត រូបណាចូលទៅនៅទីប្រក់បិទបាំង ត្រូវមានទោស ។

៥.ភិក្ខុមិនត្រូវឆាន់សាច់សត្វ រូបណាឆាន់ត្រូវមានទោស ។

ពួកភិក្ខុទាំងនោះ ឃើញថាមានផ្លូវឈ្នះព្រះមានព្រះភាគ ក៏រួមដៃគ្នា ក្រោយមកទេវទត្តភិក្ខុក៏ចូលគាល់ព្រះមានព្រះភាគ ទូលស្នើសុំផែនការទាំង ៥ នោះ ។

ព្រះមានព្រះភាគត្រាស់ថា “**ម្នាលទេវទត្ត**[៩] **ភិក្ខុរូបណាប្រាថ្នានៅព្រៃ ក៏នៅចុះ, ភិក្ខុរូបណាប្រាថ្នានៅស្រុក ក៏នៅចុះ, ភិក្ខុរូបណាប្រាថ្នាទៅបិណ្ឌបាត ក៏ទៅចុះ, ភិក្ខុរូបណាប្រាថ្នាទទួលនិមន្ត ក៏ទទួលចុះ, ភិក្ខុរូបណាប្រាថ្នាប្រើសំពត់បង្សុកូល ក៏ប្រើចុះ, ភិក្ខុរូបណាប្រាថ្នាទទួលគហបតីចីវរ (ចីវរដែលទាយកប្រគេន) ក៏ទទួលចុះ, តថាគតអនុញ្ញាតទីដេកទីអង្គុយក្រោមដើមឈើត្រឹម ៨ ខែ (ដែលពុំមែនជារដូវភ្លៀង), តថាគតអនុញ្ញាតសាច់សត្វ ដែលបរិសុទ្ធដោយចំណែក ៣ គឺ មិនបានឃើញ មិនបានឮ មិនបានរង្កៀស (គឺមិនដឹងថា គេសម្លាប់សម្រាប់ភិក្ខុឆាន់)។**

ភិក្ខុទេវទត្តត្រេកអរ ទើបដើរប្រកាសថា ព្រះមានព្រះភាគទ្រង់មិនព្រមអនុញ្ញាតខស្នើដ៏ល្អរបស់ខ្លួន ធ្វើឲ្យបុគ្គលដែលមានបញ្ញាទិនថយខ្លះយល់ថា ព្រះសមណគោតមប្រាថ្នាច្រើន ។ តែបុគ្គលដែលយល់ថាមិនត្រឹមត្រូវ ត្រឡប់ជាពោលទោសតិះដៀលភិក្ខុទេវទត្ត រឿងនោះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចត្រាស់សួរទេវទត្ត លោកក៏ទទួលសារភាពកំហុស បន្ទាប់មកទើបទ្រង់តិះដៀល និងបញ្ញត្តសិក្ខាបទ **ហាម**

[៩] ព្រះតម្រាស់ព្រះមានព្រះភាគប្រព្រឹត្តទៅជាកណ្ដាល មិនតឹងពេក មិនធូរពេក អនុលោមទៅតាមកាលៈទេសៈ ។

***ភិក្ខុព្យាយាមបំបែកសង្ឃ កាលបើភិក្ខុដទៃហាមប្រាមហើយ មិនស្តាប់តាម ភិក្ខុទាំងឡាយ គប្បីសូត្រប្រកាស (ជាកិច្ចការសង្ឃ) ដើម្បីឱ្យលោក លះបង់រឿងនោះចេញ បើសូត្រប្រកាសគម្រប់ ៣ ដងហើយ នៅមិនព្រមលះបង់ទៀត ត្រូវអាបត្តិសង្ឃាទិសេស។***

*បន្ទាប់ពីនោះមក ជាពាក្យអធិប្បាយសិក្ខាបទដោយពិស្តារ និងសំដែងលក្ខណៈមិនត្រូវអាបត្តិ គឺ*

*១.សង្ឃមិនសូត្រប្រកាស*

*២.ភិក្ខុព្រមលះបង់*

*៣.ភិក្ខុឆ្កួត*

*៤.ភិក្ខុដើមបញ្ញត្តិ ។*

## សិក្ខាបទទី ១១

## (ហាមគប់រកភិក្ខុដែលបំបែកសង្ឃ)

*យោងតាមសិក្ខាបទទី ១០ គឺកោកាលិកភិក្ខុជាដើម គាំទ្រភិក្ខុទេវទត្តថា មិនគួរតិះដៀលភិក្ខុទេវទត្តសោះ និយាយត្រូវតាមធម៌វិន័យ ត្រូវតាមការពេញចិត្តរបស់ខ្លួន ។ ភិក្ខុទាំងឡាយ តិះដៀលពួកភិក្ខុដែលគាំទ្រភិក្ខុព្យាយាមបំបែកសង្ឃនោះ ។ រឿងនេះជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា ទ្រង់ជ្រាបការពិតហើយ ក៏តិះដៀល និងបញ្ញត្តសិក្ខាបទហាមគាំទ្រភិក្ខុដែលព្យាយាមបំបែកសង្ឃ បើហាមហើយពុំស្តាប់ ត្រូវឲ្យភិក្ខុទាំងឡាយសូត្រប្រកាសដាស់តឿន (ជាកិច្ចការសង្ឃ) បើគ្រប់៣ដងហើយ នៅតែមិនព្រមលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។*

*បន្ទាប់ពីនោះ ជាពាក្យអធិប្បាយសិក្ខាបទ ឯលក្ខណៈដែលមិនត្រូវអាបត្តិ ស្រដៀងគ្នាទៅនឹងសិក្ខាបទទី ១០ មានបន្ថែមភិក្ខុមានចិត្តរវើរវាយ និងមានវេទនាខ្លាំង ២ ទៀត ។*

## សិក្ខាបទទី ១២

## (ហាមធ្វើខ្លួនជាបុគ្គលទូន្មានលំបាក)

*ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងឃោសិតារាម ក្បែរក្រុងកោសម្ពី ។ សម័យនោះ ឆន្នភិក្ខុ[១០] ប្រព្រឹត្តអនាចារ (ការប្រព្រឹត្តដែលពុំសមគួរ) ភិក្ខុទាំងឡាយពោលដាស់តឿន ត្រឡប់ជាពោលតិះដៀលបកមកវិញ ។ ទើប*

---

*[១០] ឆន្នភិក្ខុរូបនេះ ធ្លាប់តាមព្រះអង្គទៅកាលទ្រង់ចេញសាងព្រះផ្នួស ទើបប្រកាន់ខ្លួនថាជាមនុស្សសំខាន់ មិនព្រមឲ្យអ្នកណាមកប្រដៅឡើយ ក្លាយជាមនុស្សប្រដៅលំបាក អ្នកណានិយាយយ៉ាងម៉េច ក៏ពុំព្រមស្តាប់ ព្រះពុទ្ធទ្រង់ត្រាស់បង្គាប់ឲ្យសង្ឃដាក់ព្រហ្មទណ្ឌ គឺកុំឲ្យអ្នកណាដាស់តឿន និងនិយាយរកទីបំផុត ទើបលោកលះបង់ការប្រកាន់ខ្លួនបាន ។*

ភិក្ខុទាំងឡាយពោលទោសតិះដៀល រឿងនេះបានជ្រាបដល់ព្រះមានព្រះភាគៗ ទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា រួចសាកសួរ ជ្រាបការពិតហើយ ទើបទ្រង់តិះដៀល និងបញ្ញត្តិសិក្ខាបទ ***ហាមធ្វើខ្លួនជាបុគ្គលទូន្មានលំបាក បើពុំព្រមស្តាប់តាម ភិក្ខុទាំងឡាយ សូត្រប្រកាសដាស់តឿន បើគ្រប់ ៣ ដងហើយ នៅតែមិនព្រមលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។***

បន្ទាប់ពីនោះ ជាពាក្យអធិប្បាយសិក្ខាបទដោយពិស្តារ ឯលក្ខណៈដែលមិនត្រូវអាបត្តិ ដូចគ្នានឹងសិក្ខាបទទី ១០ ដែរ ។

## សិក្ខាបទទី ១៣

## (ហាមទ្រុស្តត្រកូល គឺប្រចុបប្រចែងត្រកូល)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងជេតវនារាម ក្បែរក្រុងសាវត្ថី ។ គ្រានោះ ពួកបាបភិក្ខុ (ភិក្ខុលាមក គឺភិក្ខុអាក្រក់) មានឈ្មោះថា អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ ជាភិក្ខុម្ចាស់ស្រុកនៅក្នុងជនបទ ឈ្មោះថា កិដាគិរី ពួកលោកជាអលជ្ជីភិក្ខុ (គឺភិក្ខុដែលមិនខ្មាស់បាប) ។ ភិក្ខុទាំងនោះប្រព្រឹត្តអនាចារមានប្រការផ្សេងៗ ដូចជាការផ្កាប់ផ្កុនគ្រហស្ថ ធ្វើរបស់ផ្សេងៗ ឲ្យទៅគេ លេងរបិលរប៉ូចជាដើម ។

មានភិក្ខុមួយរូប ចាំវស្សានៅក្នុងដែនកាសី ក្រោយមកក៏ទៅសម្រាកនៅក្នុងជនបទនោះ បំណងធ្វើដំណើរទៅកាន់ក្រុងសាវត្ថី ដើម្បីចូលគាល់ព្រះមានព្រះភាគ ។ ភិក្ខុរូបនោះ ចូលទៅបិណ្ឌបាតក្នុងស្រុកដោយអាការសង្រួម តែមនុស្សទាំងឡាយមិនពេញចិត្ត ព្រោះមិនសំដែងអាការប្រចុបប្រចែងដូចពួកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ ទើបមិនប្រគេនអាហារ ។ តែមានឧបាសកម្នាក់ (ជាអ្នកចូលចិត្តធម៌វិន័យ) ឃើញហើយ ក៏និមន្តភិក្ខុរូបនោះ ទៅឆាន់នៅឯផ្ទះរបស់ខ្លួន រួចសុំឲ្យលោកទៅប្រាប់ ដល់ព្រះមានព្រះភាគថា ពួកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ ប្រព្រឹត្តខ្លួនពុំសមគួរផ្សេងៗ ។

រឿងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់តិះដៀល រួចបញ្ញត្តសិក្ខាបទមានន័យថា ***ភិក្ខុប្រទុស្តត្រកូល (ប្រចុបប្រចែងគ្រហស្ថ ដាក់ខ្លួនឱ្យគេប្រើ) មានការប្រព្រឹត្តអាក្រក់ផ្សេងៗ គេឃើញហើយ ដឹងហើយ ភិក្ខុទាំងឡាយគប្បីពោលដាស់តឿនលោក និងបណ្តេញលោកចេញពីទីនោះ បើលោកត្រឡប់ពោលតិះដៀលបកមកវិញ ភិក្ខុទាំងឡាយគប្បីសូត្រប្រកាសឱ្យលោកលះបង់ចេញ បើគ្រប់ ៣ ដងហើយ នៅតែពុំព្រមលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។***

បន្ទាប់ពីនោះ ជាពាក្យអធិប្បាយសិក្ខាបទដោយពិស្តារ និងសំដែងលក្ខណៈដែលមិនត្រូវអាបត្តិ ដូចសិក្ខាបទទី ១១ ដែរ ។ (គប្បីសង្កេតថា ចាប់ពីសិក្ខាបទទី ១០ ដល់សិក្ខាបទទី ១៣ ហៅថា យាវតតិយៈ គឺត្រូវសូត្រប្រកាសសង្ឃគម្រប់ ៣ ដង ទើបត្រូវអាបត្តិ) ។



# អនិយតកណ្ឌ

## (ពោលអំពីអាបត្តិមិនទៀងទាត់)

## សិក្ខាបទទី ១

### (ត្រូវអាបត្តិ ព្រោះអង្គុយក្នុងទីកំបាំងភ្នែកតែពីរនាក់ស្ត្រី)

ដើមរឿងដំណាលថា ព្រះមានព្រះភាគប្រថាប់នៅក្នុងជេតវនារាម ក្បែរក្រុងសាវត្ថី ។ សម័យនោះ ភិក្ខុឧទាយី ច្រើនតែចូលទៅកាន់ត្រកូលក្នុងក្រុងសាវត្ថីដូចគ្នា ថ្ងៃមួយចូលទៅអង្គុយក្នុងបន្ទប់តែពីរនាក់ជាមួយស្រីក្រមុំ និយាយគ្នាលេងខ្លះ ពោលអំពីធម៌ខ្លះ ។ ឧបាសិកាវិសាខា ត្រូវបានគេអញ្ជើញទៅក្នុងត្រកូលនោះ ឃើញហើយ ទើបដាស់តឿនថា ជាការពុំសមគួរ ក៏មិនអើពើស្តាប់ ។ រឿងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា ត្រាស់សួរជ្រាបការពិតហើយ ក៏ទ្រង់តិះដៀល និងបញ្ញត្តសិក្ខាបទដោយន័យថា ភិក្ខុអង្គុយក្នុងទីកំបាំងភ្នែកតែពីរនាក់ស្ត្រី ជាកន្លែងអាចប្រកបកម្ម (សម្រេចមេថុន) បាន បើឧបាសិកា[១១] ដែលមានវាចាគួរទុកចិត្តបាន ពោល

[១១] គឺជាអរិយបុគ្គល ដូចជា ឧបាសិកាវិសាខា តែដោយអត្ថ គឺបានដល់បុគ្គលដែលបានឃើញ ជាអ្នកមានវាចាគួរទុកចិត្តបានធ្វើជាសក្ខីព្យាន ។

ថា ភិក្ខុត្រូវអាបត្តិយ៉ាងណាមួយ ក្នុងបណ្ដាអាបត្តិ ៣ យ៉ាងគឺ

១.អាបត្តិបារាជិក (ព្រោះសេពមេថុន)

២.អាបត្តិសង្ឃាទិសេស ព្រោះពាល់ត្រូវកាយស្ត្រី ឬនិយាយចង់ស្ត្រីជាដើម) ។

៣.អាបត្តិបាចិត្តិយ (ព្រោះអង្គុយក្នុងទីកំបាំងតែពីរនាក់ស្ត្រី)

បើភិក្ខុអង្គុយក្នុងទីកំបាំងភ្នែក សារភាពត្រូវអាបត្តិណាមួយ បណ្ដាអាបត្តិ ៣ យ៉ាង គប្បីពិន័យលោកតាមដែលបានសារភាពនោះ ឬពិន័យតាមដែលគេប្រាប់នោះ (ស្រេចតែសមគួរ) ។

## សិក្ខាបទទី ២

### (ត្រូវអាបត្តិ ព្រោះអង្គុយក្នុងទីកំបាំងត្រចៀកតែពីរនាក់ស្ត្រី)

ដំណាលរឿងតពីសិក្ខាបទមុន, ភិក្ខុឧទាយីយល់ថា ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ហាមអង្គុយក្នុងទីកំបាំងភ្នែក តែពីរនាក់ស្ត្រី ទើបអង្គុយក្នុងទីកំបាំងត្រចៀកតែពីរនាក់ស្ត្រីវិញ រួចនិយាយលេងខ្លះ ពោលធម៌ខ្លះ ។ ឧបាសិកាវិសាខាទៅជួបទៀត ទើបនិយាយដាស់តឿនថា ជាការពុំសមគួរ ភិក្ខុឧទាយីក៏មិនព្រមអើពើស្ដាប់ ។ រឿងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នា ត្រាស់សួរជ្រាបការពិតហើយ ទ្រង់ក៏តិះដៀល និងបញ្ញត្តសិក្ខាបទដោយន័យថា ភិក្ខុអង្គុយក្នុងទីកំបាំងត្រចៀកតែពីរនាក់ស្ត្រី បើឧបាសិកាដែលគួរជឿទុកចិត្តបាន ពោលថា ភិក្ខុត្រូវអាបត្តិយ៉ាងណាមួយ បណ្ដាអាបត្តិពីរយ៉ាងនេះ គឺ

១.អាបត្តិសង្ឃាទិសេស (ព្រោះនិយាយចង់ស្ត្រី ឬលួងលោមស្ត្រី ឲ្យបម្រើខ្លួនដោយកាម) ។

២.អាបត្តិបាចិត្តិយៈ (ព្រោះអង្គុយក្នុង ទីកំបាំងត្រចៀកតែពីរនាក់ស្ត្រី) ។

បើភិក្ខុដែលអង្គុយក្នុងទីកំបាំង ត្រចៀកសារភាពយ៉ាងណាមួយ បណ្ដាអាបត្តិ ២ យ៉ាងនោះ គប្បីពិន័យអាបត្តិលោកតាមដែលបានសារភាពនោះ ឬពិន័យតាមដែលគេបានប្រាប់ (ស្រេចតែសមគួរ) ។

(កត់សម្គាល់ៈ អនិយតសិក្ខាបទ ឬសិក្ខាបទដែលមិនទៀងទាត់នេះ នឹងកំណត់ថាត្រូវអាបត្តិណាមួយ បណ្ដាអាបត្តិ ២-៣ យ៉ាង (គង់លំបាក) ។ ទាំងពីរសិក្ខាបទនេះ សង្កត់ធ្ងន់ ទៅលើវិធីវិនិច្ឆ័យអាបត្តិក៏ពិតមែន តែក៏បង្ហាញឲ្យឃើញថា ហាមភិក្ខុអង្គុយក្នុងទីកំបាំងភ្នែក ឬត្រចៀក តែពីរនាក់ស្ត្រី វៀរលែងក្នុងទីកំបាំងភ្នែកមានបុរសដឹងក្ដីនៅជាមួយ តែក្នុងទីកំបាំងត្រចៀកមានបុរស ឬស្ត្រីដឹងក្ដីនៅជាមួយ ក៏រួចផុតពីទីកំបាំងត្រចៀក បានដែរ) ។

## ភាគទី ៣-៤ (វិនយបិដក)

## មហាវិភង្គ

វិនយបិដកភាគទី ៣-៤ នេះ តមកពីភាគទី ២ គឺពោលអំពីអាបត្តិភិក្ខុដែលបានពោលរួចមកហើយនៅក្នុងភាគទី ២ ចែកចេញ ជា ៤ ពួកធំៗ និងមានធម៌សម្រាប់រម្ងាប់អធិករណ៍នៅខាងចុងគឺ

**១.និស្សគ្គិយកណ្ឌ** ពោលអំពីអាបត្តិបាចិត្តិយដែលត្រូវលះវត្ថុចេញសិន ទើបសំដែងអាបត្តិដាច់ ។ អាបត្តិនិស្សគ្គិយបាចិត្តិយៈនេះ មាន ៣០ សិក្ខាបទ ចែកចេញជា ៣ វគ្គ ហើយក្នុង ១ វគ្គៗ មាន ១០ សិក្ខាបទ ។

**២.បាចិត្តិយកណ្ឌ** ពោលអំពីអាបត្តិបាចិត្តិយសុទ្ធៗ ដោយពុំចាំបាច់មានលក្ខខណ្ឌឲ្យលះវត្ថុចេញឡើយ ។ អាបត្តិបាចិត្តិយនេះមាន ៩២ សិក្ខាបទ ចែកចេញជា ៩ វគ្គ ហើយក្នុង ១ វគ្គៗ មាន ១០ សិក្ខាបទ វៀរតែវគ្គទី ៨ (សហធម្មិកវគ្គ) ចេញ គឺមាន ១២ សិក្ខាបទ ។ (ពាក្យថា **បាចិត្តិយៈ** ប្រែថា អំពើល្មើសដែលញ៉ាំងកុសលធម៌ឲ្យធ្លាក់ចុះ) ។

**៣.បាដិទេសនីយកណ្ឌ** ពោលអំពីអាបត្តិបាដិទេសនីយ (ប្រែថា អាបត្តិដែលគប្បីសំដែងចេញត្រឡប់ ឬសង ស្រាលជាងអាបត្តិបាចិត្តិយៈ) មាន ៤ សិក្ខាបទ ។

**៤.សេខិយកណ្ឌ** ពោលអំពីបទដែលភិក្ខុគប្បីសិក្សា ទាក់ទងនឹងវត្ត, ទំនៀម ឬចរិយាមារយាទផ្សេងៗ មានទាំងអស់ ៧៥ សិក្ខាបទ ចែកចេញជាពួកសារូប (ឧបដិបត្តិដើម្បីឲ្យសមជាសមណៈ) មាន ២៦ សិក្ខាបទ ពួកភោជនប្បដិសំយុត្ត (ឧបដិបត្តិទាក់ទងនឹងការឆាន់អាហារ) មាន ៣០ សិក្ខាបទ ពួកធម្មទេសនាបដិសំយុត្ត (ឧបដិបត្តិទាក់ទងនឹងការសំដែងធម៌) មាន ១៦ សិក្ខាបទ និងពួកបកិណ្ណកៈ ៣ សិក្ខាបទទៀត ទើបត្រូវជា ៧៥ សិក្ខាបទ ។

៥.ធម៌សម្រាប់រម្ងាប់អធិករណ៍ ជាបទខ្លីៗ ដែលបន្ថែមចូលមកដើម្បីសំដែងដល់វិធីរម្ងាប់អធិករណ៍ដោយធម៌ ៨ ប្រការ ។

## ន័យពិស្តារ

## ១.និស្សគ្គិយកណ្ឌ

(ពោលអំពីអាបត្តិបាចិត្តិយ ៣០ សិក្ខាបទ ដែលត្រូវលះវត្ថុ)

**១.ចីវរវគ្គ** ពោលអំពីចីវរ ជាវគ្គទី ១ មាន ១០ សិក្ខាបទ គឺ

## សិក្ខាបទទី ១

### (ហាមទុកចីវរលើសពី ១០ ថ្ងៃ)

ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម ក្បែរក្រុងសាវត្ថី ។ សម័យនោះ ព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យប្រើចីវរបានត្រឹមតែ ៣ ផ្ទាំង (ចីវរ, ស្បង់, សង្ឃាដី) ប៉ុណ្ណោះ ។ ភិក្ខុឆព្វគ្គិយ (ភិក្ខុមានគ្នា ៦ រូប) ទាំងចូលទៅក្នុងស្រុក នៅក្នុងវត្ត និងទៅកាន់ទីស្រង់ទឹក សុទ្ធតែប្រើចីវរ ៣ ផ្ទាំងគ្រប់ៗ គ្នា ។ ភិក្ខុទាំងឡាយតិះដៀល ដំណឹងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទ្រង់ក៏បញ្ញត្តសិក្ខាបទ ***ហាមរក្សាទុកអតិរេកចីវរ***[១២] (ចីវរច្រើនហួសលើសពីតម្រូវការ គឺលើសចំនួនកំណត់) ***បើប្រព្រឹត្តកន្លងល្មើស ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។***

ក្រោយមកមានហេតុកើតឡើង ព្រះអានន្ទមានបំណងទុកចីវរឲ្យព្រះសារីបុត្ត ព្រះមានព្រះភាគជ្រាប ទើបទ្រង់បញ្ញត្តសិក្ខាបទបន្ថែមទៀត គឺអនុញ្ញាតឲ្យទុកបានលើសត្រឹម ១០ ថ្ងៃ ។

[១២] បើចាំវស្សាគ្រប់ ៣ ខែ នុ៎ះអាចទុកបាន ១ ខែ, បើបានក្រាលគ្រងកឋិន នុ៎ះអាចទុកបន្តទៀតបាន ៤ ខែ, សរុបត្រូវជា ៥ ខែ ។

## សិក្ខាបទទី ២

### (ហាមនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់)

ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងជេតវនារាម ។ សម័យនោះ ភិក្ខុទាំងឡាយយកសំពត់សង្ឃាដី (ចីវរពីរជាន់) ផ្ញើទុកនឹងភិក្ខុរូបដទៃ រួចហើយចារិកទៅកាន់ជនបទដោយស្បង់ (សំពត់ស្លៀក) និងចីវរ (សំពត់ដណ្តប់) រួមមានតែត្រឹមពីរផ្ទាំងប៉ុណ្ណោះ ។ សំពត់ដែលផ្ញើទុកយូរ ក៏ប្រឡាក់ប្រឡូស ទើបភិក្ខុដែលទទួលបញ្ញើយកទៅហាលថ្ងៃ ដំណឹងនេះបានជ្រាបដល់ព្រះអង្គៗ ទ្រង់តិះដៀលរួចហើយ ក៏បញ្ញត្តសិក្ខាបទ ***ហាមនៅប្រាសចាកត្រៃចីវរ សូម្បីត្រឹមតែមួយយប់ បើប្រព្រឹត្តកន្លង ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។***

ក្រោយមកមានរឿងកើតឡើង គឺមានភិក្ខុអាពាធ ពុំអាចនាំយកចីវរទាំង ៣ ផ្ទាំងទៅបាន ទើបទ្រង់អនុញ្ញាតសង្ឃសូត្រសន្មតិភិក្ខុឲ្យទុកចីវរដូចពោលមកនោះជាករណីពិសេស ថែមទាំងមិនត្រូវអាបត្តិទៀតផង ។

## សិក្ខាបទទី ៣

### (ហាមទុកសំពត់សម្រាប់ធ្វើចីវរលើសកំណត់)

ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងជេតវនារាម ។ សម័យនោះ អកាលចីវរ (ចីវរកើតឡើងក្រៅកាលដែលព្រះអង្គអនុញ្ញាតឲ្យរក្សាទុកលើស ១០ ថ្ងៃបាន) កើតឡើងដល់ភិក្ខុមួយរូប តែមិនល្មមនឹងធ្វើចីវរបាន លោកក៏ត្រដាងសំពត់ (យកដៃ) សង្កត់ឲ្យរាបស្មើរឿយ ៗ ព្រះមានព្រះភាគ ទ្រង់ទតព្រះនេត្រឃើញ ហើយត្រាស់សួរ ជ្រាបដំណឹង ទើបទ្រង់អនុញ្ញាតឲ្យទុកសំពត់ក្រៅកាលបាន បើប្រាថ្នានឹងធ្វើចីវរ ។ ពិតណាស់ថា ភិក្ខុរូបខ្លះ ទុកលើស ១ ខែ ទើបទ្រង់បញ្ញត្តសិក្ខាបទហាមទុកសំពត់ក្រៅកាលលើស ១ ខែ ទ្រង់ពិន័យអាបត្តិនិស្សគ្គិយ បាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង ។

## សិក្ខាបទទី ៤

### (ហាមប្រើភិក្ខុនីបោកគក់ចីវរ)

ព្រះមានព្រះភាគទ្រង់ប្រថាប់នៅក្នុងជេតវនារាម ។ អតីតភរិយារបស់ភិក្ខុឧទាយីចូលមកបួសជាភិក្ខុនី ទទួលយកអាសាគក់ចីវររបស់ភិក្ខុឧទាយី ដែលមានអសុចិប្រឡាក់ថ្មីៗ នាងក៏នាំយកអសុចិនោះមួយចំណែកដាក់ចូលក្នុងមាត់ ឯមួយចំណែកទៀត ដាក់ក្នុងអង្គកំណើត (យោនី) ក៏តាំងគភ៌ឡើង ទើបទ្រង់បញ្ញត្តសិក្ខាបទ ***ហាមប្រើភិក្ខុនីដែលពុំមែនជាញាតិ[១៣] បោក, ជ្រលក់ ឬញី ចីវរចាស់ (គឺសំពត់ដែលស្លៀក ឬដណ្តប់រួចហើយសូម្បីតែម្តង) ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៥

### (ហាមទទួលយកចីវរពីដៃភិក្ខុនី)

ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងវេឡុវនារាម ក្បែរក្រុងរាជគ្រឹះ ។ ភិក្ខុឧទាយីទាមទារសុំចីវរពីភិក្ខុនីឧប្បលវណ្ណា ដែលមានសំពត់ជាកំណាត់ ទើបនាងប្រគល់អន្តរវាសកៈ (សំពត់ស្លៀក) ដំណឹងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទ ***ហាមទទួលយកចីវរពីដៃភិក្ខុនីដែលពុំមែនជាញាតិ ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។*** ក្រោយមក ទ្រង់បញ្ញត្តបន្ថែមទៀតដោយមានលក្ខខណ្ឌ ***មិនពិន័យអាបត្តិក្នុងករណីមានការផ្លាស់ប្តូរ។***

---

[១៣] ពាក្យថា ***មិនមែនជាញាតិ*** គឺមិនទាក់ទងខាងខ្សែលោហិតមាតា ឬបិតា ។ ចំណែកកូនប្រសារប្រុស ឬកូនប្រសារស្រី រហូតដល់អ្នកដែលធ្លាប់ជាភរិយាស្វាមីជាមួយគ្នា ក៏មិនឈ្មោះថា ជាញាតិ ពីព្រោះក្នុងតួយ៉ាងនេះ អ្នកបង្កហេតុ គឺអ្នកធ្លាប់ជាភរិយាស្វាមីជាមួយគ្នា ។

## សិក្ខាបទទី ៦

**(ហាមសុំចីវរពីគ្រហស្ថដែលពុំមែនជាញាតិ)**

*សេដ្ឋីបុត្រ មានសេចក្តីជ្រះថ្លាចំពោះភិក្ខុឧបនន្ទសាក្យបុត្រ ទើបបវារណាសុំអ្វីក៏បាន លោកក៏សុំចីវរ (សំពត់ដណ្តប់) ពីសេដ្ឋីបុត្រនោះ សូម្បីគេសុំទៅយកពីផ្ទះមកប្រគេន ក៏មិនព្រមៗ ព្រះសាស្តាទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ* ***ហាមសុំចីវរពីគ្រហស្ថដែលពុំមែនជាញាតិ បើសុំបានមក ត្រូវនិស្សគ្គិយបាចិត្តិយ។ ក្រោយមកទ្រង់បញ្ញត្តបន្ថែមទៀតដោយមានលក្ខខណ្ឌ អនុញ្ញាតឱ្យសុំបានក្នុងពេលដែលចីវរត្រូវចោរលួចយកទៅ ឬចីវរបាត់។***

## សិក្ខាបទទី ៧

**(ហាមទទួលចីវរលើសកំណត់ ពេលត្រូវចោរលួច ឬបាត់)**

*ភិក្ខុឆព្វគ្គិយ ដើរសុំចីវរឲ្យក្រុមភិក្ខុដែលមានចីវរត្រូវចោរលួចយកទៅ ឬបាត់ ទាំងដែលភិក្ខុទាំងនោះមានអ្នកប្រគេនចីវររួចហើយ ជាការសុំ ឬរៃអង្គាសដែលមិនស្គាល់ប្រមាណ បានសំពត់ច្រើនរហូតដល់ថ្នាក់ថាតើត្រូវលក់ ឬដូចម្តេច ? ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ក្នុងករណីដែលត្រូវចោរលួច ឬបាត់នោះ បើគ្រហស្ថបវារណាឱ្យទទួលចីវរច្រើនផ្ទាំង ក៏ទទួលបានត្រឹមតែស្បង់ និងចីវរប៉ុណ្ណោះ ទទួលច្រើនជាងនោះត្រូវនិស្សគ្គិយបាចិត្តិយ។***

## សិក្ខាបទទី ៨

**(ហាមនិយាយឱ្យគេទិញចីវរថ្មីផ្សេងទៀតក្រៅពីចីវរដើម)**

*បុរសម្នាក់និយាយជាមួយភរិយាថា នឹងប្រគេនសំពត់ដល់ភិក្ខុឧបនន្ទៗ ដឹងហើយទើបទៅនិយាយឲ្យគេប្រគេនចីវរយ៉ាងនេះ យ៉ាងនោះ បើទិញចីវរដូចដែលលោកមិនប្រើ លោកក៏មុខជាមិនដឹងយកទៅធ្វើអ្វី ទើបគេតិះដៀលថាប្រាថ្នាច្រើន ដំណឹងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមកំណត់គ្រហស្ថដែលពុំមែនជាញាតិ ពុំបានបវារណា ឱ្យទិញចីវរយ៉ាងនេះ យ៉ាងនោះ ប្រគេនដល់ខ្លួន ដោយប្រាថ្នាចង់បានរបស់ល្អៗ ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយ ដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៩

**(ហាមនិយាយឱ្យគេចូលគ្នាទិញចីវរល្អៗ ប្រគេន)**

បុរសពីរនាក់និយាយគ្នាថា យើងនឹងទិញចីវររៀងៗ ខ្លួន ហើយប្រគេនដល់ឧបនន្ទភិក្ខុៗ ដឹងហើយទើបទៅណែនាំគេឲ្យចូលគ្នាទិញចីវរប្រភេទនេះ ប្រភេទនោះ (ចីវរល្អៗ) គេនាំគ្នាតិះដៀលថា ប្រាថ្នាច្រើន ដំណឹងនេះជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទ ***ហាមចូលទៅសុំគ្រហស្ថ ដែលពុំមែនជាញាតិ ពុំបានបវារណា គេតាំងចិត្តថា ទិញចីវររៀងៗ ខ្លួនប្រគេនលោក តែលោកត្រឡប់ទៅសុំឱ្យគេចូលគ្នាទិញចីវរយ៉ាងនេះយ៉ាងនោះ ដោយប្រាថ្នាឱ្យបានចីវរល្អៗ ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ១០
## (ហាមទារចីវរពីអ្នកទទួលបញ្ញើអ្នកដទៃ ដើម្បីជាវចីវរប្រគេនច្រើនជាង ៣ ដង)

មហាអាមាត្យដែលឧបដ្ឋាកភិក្ខុឧបនន្ទសក្យបុត្រ ប្រើទូតឲ្យនាំយកតម្លៃទិញចីវរទៅប្រគេនឧបនន្ទភិក្ខុៗ ឆ្លើយតបថា លោកទទួលយកប្រាក់ពុំបានទេ ទទួលបានតែចីវរដែលគួរដល់កាល ទើបគេសួររកវេយ្យាវច្ចករ (អ្នកខ្វល់ខ្វាយក្នុងការបម្រើ) ទើបលោកសំដែងឧបាសកម្នាក់ថាជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ ទើបគេប្រគល់ប្រាក់ដល់វេយ្យាវច្ចករហើយប្រាប់ឲ្យលោកជ្រាប លោកក៏មិននិយាយអ្វីទៅរកវេយ្យាវច្ចករ សូម្បីបានទទួលពាក្យតឿនពីមហា-អាមាត្យដែលបញ្ជូនទូតមកសុំឲ្យប្រើសំពត់ជាលើកទី ២ ក៏នៅតែពុំនិយាយអ្វីជាមួយវេយ្យាវច្ចករនោះ រហូតដល់បានទទួលពាក្យតឿនជាលើកទី ៣ សុំឲ្យប្រើសំពត់នោះ ក្រោយមកទើបទៅរំអុកយកពីវេយ្យាវច្ចករនោះ ដែលគាប់ជួនកំពុងតែជាប់រវល់ត្រូវចូលប្រជុំសភានិគម ដែលមានកតិកាថា នរណាមកយឺតពេលត្រូវពិន័យ ៥០ (កហាបណៈ) សូម្បីគេបែងឲ្យដឹងអំពីកតិកា ក៏នៅតែពុំស្តាប់ នៅតែរំអុករហូតដល់គេត្រូវទៅទិញយកមកឲ្យ ហើយទៅដល់ត្រូវគេពិន័យ ពីព្រោះចូលប្រជុំយឺតយ៉ាវ ។ ទើបមនុស្សទាំងឡាយតិះដៀលថា (ពុំគួរណា) ធ្វើឲ្យគេបង់ថ្លៃពិន័យ ។ ព្រះមានព្រះភាគជ្រាប ទើបទ្រង់តិះដៀលហើយបញ្ញត្តសិក្ខាបទដោយន័យថា ***បើគេបញ្ជូនទូតមកប្រគេនតម្លៃចីវរ ឯភិក្ខុក៏គេសំដែងវេយ្យាវច្ចករហើយដែរ ភិក្ខុអាចទៅទារយកពីវេយ្យាវច្ចករនោះបានមិន លើសពី ៣ ដង ទៅឈរស្ងៀមឱ្យគេឃើញមិនលើសពី ៦ ដង បើទារលើស ៣ ដង ឬឈរលើស ៦ ដង ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។***

## ២.កោសិយវគ្គ

*គឺវគ្គពោលអំពីសូត្រ ជាវគ្គទី ២ មាន ១០ សិក្ខាបទ គឺ*

### សិក្ខាបទទី ១

### (ហាមត្បាញកម្រាលលាយដោយសូត្រ)

*ភិក្ខុឆព្វគ្គិយចូលទៅរកជាងតម្បាញ សុំឲ្យគេរម្ងាស់សូត្រ និងសុំសរសៃសូត្រខ្លះ ដើម្បីត្បាញសន្ថ័ត (កម្រាល, ទ្រនាប់អង្គុយ) លាយដោយសូត្រ ។ គេស្តីបោទថា បៀតបៀនគេ និងបៀតបៀនដង្កូវសូត្រ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមភិក្ខុត្បាញ សន្ថ័តលាយដោយសូត្រ ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ ភិក្ខុដែលប្រព្រឹត្តកន្លង។***

### សិក្ខាបទទី ២

### (ហាមត្បាញកម្រាលលាយដោយរោមចៀមខ្មៅសុទ្ធ)

*ភិក្ខុឆព្វគ្គិយត្បាញសន្ថ័តលាយដោយរោមចៀម (រោមពពែ និងរោមឈ្លូស) ខ្មៅសុទ្ធ មនុស្សទាំងឡាយតិះដៀលថា ប្រើរបស់ដូចគ្រហស្ថ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ហាមត្បាញដោយខ្លួនឯង ឬប្រើគេឲ្យត្បាញសន្ថ័ត ដោយរោមចៀមខ្មៅសុទ្ធ ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង ។*

### សិក្ខាបទទី ៣

### (ហាមប្រើរោមចៀមខ្មៅពីរភាគបួនត្បាញកម្រាល)

*ភិក្ខុឆព្វគ្គិយត្បាញសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ ដោយគ្រាន់តែយករោមចៀមសបន្តិច មកប៉ះប៉ូវត្រង់ជាយ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***បើភិក្ខុមានបំណងនឹងត្បាញសន្ថ័តដោយសូត្រ ត្រូវយករោមចៀមខ្មៅ ២ ភាគ រោមចៀមស ១ ភាគ និងរោមចៀមក្រហម ១ ភាគ បើមិនធ្វើតាមការកំណត់ខាងលើនេះ ត្រូវអាបត្តិនិស្សគ្គិយ បាចិត្តិយ។***

### សិក្ខាបទទី ៤

### (ហាមត្បាញកម្រាលសូត្រថ្មីក្រោម ៦ ឆ្នាំ)

ភិក្ខុទាំងឡាយត្បាញសន្ថតរៀងរាល់ឆ្នាំ ត្រូវសុំរោមចៀមពីអ្នកស្រុក ជាការរុកកួន (បៀតបៀន) គេ មានគេតិះដៀលដោយពោលសំអាងថា អ្នកស្រុកគេប្រើបានយូរដល់ទៅ ៥-៦ ឆ្នាំ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុត្បាញសន្ថតស្រូវត្រូវប្រើឱ្យបាន ៦ ឆ្នាំ សឹមត្បាញថ្មី បើពុំដូច្នោះទេ ត្រូវ និស្សគ្គិយបាចិត្តិយ។*** ក្រោយមកភិក្ខុអាពាធ គេនិមន្តទៅកាន់ទីដទៃ មិនហ៊ានទៅ ព្រោះនាំយកសន្ថតទៅជាមួយពុំរួច ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យមានការសន្មតជាពិសេសសម្រាប់ភិក្ខុអាពាធ ។

## សិក្ខាបទទី ៥

### (អនុញ្ញាតកាត់របស់ចាស់លាយរបស់ថ្មី)

ភិក្ខុទាំងឡាយបោះបោលសន្ថតក្នុងទីនោះៗ ព្រះមានព្រះភាគទ្រង់ទតព្រះនេត្រឃើញ ទើបបញ្ញត្តសិក្ខាបទថា ***ភិក្ខុមានប្រាថ្នានឹងត្បាញសន្ថតថ្មី គប្បីកាន់យកសន្ថតចាស់ ១ ចង្អាមដោយ ជុំវិញលាយចូលផង ដើម្បីទម្លាយពណ៌ បើពុំធ្វើដូច្នោះទេ ហើយត្បាញសន្ថតថ្មី ត្រូវនិស្សគ្គិយបាចិត្តិយ។*** (សិក្ខាបទនេះ ឆ្លុះបញ្ចាំងពីសារៈសំខាន់របស់សន្ថតចាស់ ដែលគប្បីរក្សាទុក គ្រាន់លាយនៅពេលត្បាញសន្ថតថ្មី) ។

## សិក្ខាបទទី ៦

### (ហាមនាំរោមចៀមទៅដោយខ្លួនឯងលើសពី ៣ យោជន៍)

ភិក្ខុមួយរូបធ្វើដំណើរទៅកាន់ក្រុងសាវត្ថី ក្នុងកោសលជនបទ ។ មានគេប្រគេនរោមចៀមតាមផ្លូវ លោកក៏យកចីវររុំនាំ ទៅ មនុស្សទាំងឡាយនាំគ្នានិយាយបង្អើលថា ទិញមកតម្លៃប៉ុន្មាន ហើយបានកម្រៃប៉ុន្មាន ។ ដំណឹងនេះជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទដោយន័យថា ***ភិក្ខុធ្វើដំណើរផ្លូវឆ្ងាយ ហើយមានគេប្រគេនរោមចៀម បើប្រាថ្នាក៏គប្បីទទួល និងនាំទៅដោយខ្លួនឯងបាន មិនលើសពី ៣ យោជន៍ ក្នុងកាលបើពុំមានអ្នកនាំទៅឱ្យ បើនាំទៅលើសពី ៣ យោជន៍ សូម្បីមិនមានអ្នកនាំទៅឱ្យ ក៏ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយដែរ។***

## សិក្ខាបទទី ៧

### (ហាមប្រើភិក្ខុនីពុំមែនជាញាតិឱ្យសម្អាតរោមចៀម)

ភិក្ខុឆព្វគ្គិយ ប្រើភិក្ខុនីឲ្យបោកគក់រោមចៀម ធ្វើឲ្យខូចពេលសិក្សា ការសាកសួរ និងឧបដិបត្តិ គឺ សីល សមាធិ និងបញ្ញាជាន់ខ្ពស់ ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបទ្រង់បញ្ញត្តសិក្ខាបទ ***ហាមប្រើភិក្ខុនីដែលពុំមែនជាញាតិបោកគក់រោមចៀម ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៨

### (ហាមទទួលមាស និងប្រាក់)

ម្ចាស់ផ្ទះរបស់ភិក្ខុឧបនន្ទ ដែលធ្លាប់តែនិមន្តទៅឆាន់ជាប្រចាំ បានត្រៀមសាច់ទុកប្រគេនពេលព្រឹក តែត្រូវក្មេងយំទារឆីក្នុងវេលាយប់ ទើបយកសាច់នោះឲ្យទៅក្មេងឆី លុះព្រឹកឡើងក៏យកកហាបណៈ (ប្រាក់មានតម្លៃ ៨ បាទ) មកប្រគេន ភិក្ខុឧបនន្ទក៏ទទួល មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ហាមភិក្ខុទទួលដោយខ្លួនឯង ប្រើឱ្យគេទទួលមាសប្រាក់ ឬត្រេកអរ មាសប្រាក់ដែលគេទុកដើម្បីខ្លួន***[១៨] ***ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៩

### (ហាមធ្វើការទិញដូរដោយរូបិយៈ)

ភិក្ខុឆព្វគ្គិយធ្វើការទិញដូរដោយរូបិយៈ (មាស ប្រាក់ ឬវត្ថុដែលប្រើជំនួសប្រាក់ ដែលកំណត់ឲ្យប្រើបានទូទៅក្នុងទីនោះៗ) មនុស្សទាំងឡាយនាំគ្នាតិះដៀលថា ធ្វើទំនងហាក់ដូចជាគ្រហស្ថ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ហាមធ្វើការទិញដូរ ដោយរូបិយៈ ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយ ដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ១០

---

[១៨] ក្រោយមកទ្រង់អនុញ្ញាតឲ្យត្រេកអរបច្ច័យ ៤ បាន គឺ ទាយកគេប្រគល់ប្រាក់ទុកដល់វេយ្យាវច្ចករ ឬកប្បិយការកៈ ឬអារាមិកជន ឬជនណាមួយដែលនៅក្បែរ ដើម្បីឲ្យចាត់ចែងបច្ច័យ ៤ គឺ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជៈ ភិក្ខុត្រូវការអ្វី ក៏ប្រាប់គេឲ្យចាត់ចែង ទើបមានប្រពៃណីបវារណាបច្ច័យ ៤ តែចំពោះមាសប្រាក់ ទ្រង់ហាមឃាត់ដាច់ខាត ។

**(ហាមទិញដូរដោយការផ្លាស់ប្តូរ)**

បរិព្វាជកម្នាក់ ឃើញភិក្ខុឧបនន្ទសក្យបុត្រដណ្តប់សង្ឃាដីល្អ ឆើត ទើបបបួលដូរជាមួយសំពត់របស់ខ្លួន ក្រោយមកដឹងថាសំពត់របស់ខ្លួនល្អជាង ទើបសុំដូរវិញ ភិក្ខុឧបនន្ទពុំព្រមដូរ ទើបតិះដៀលភិក្ខុឧបនន្ទ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទថា ***ភិក្ខុធ្វើការទិញដូរដោយប្រការផ្សេងៗ ត្រូវនិស្សគ្គិយបាចិត្តិយ។*** *(សំដៅដល់ការទិញដូរដែលផ្លាស់ប្តូរដោយវត្ថុ រវាងអ្នកបួសដូចគ្នាក្នុងព្រះពុទ្ធសាសនា គឺអាចធ្វើបាន) ។*

## ៣.បត្តវគ្គ

*វគ្គពោលអំពីបាត្រ គឺជាវគ្គទី ៣ ក្នុងនិស្សគ្គិយកណ្ឌមាន ១០ សិក្ខាបទ គឺ*

### សិក្ខាបទទី ១

**(ហាមទុកបាត្រលើសពី ១ ចំនួន ១០ ថ្ងៃ)**

ភិក្ខុឆព្វគ្គិយសន្សំបាត្រទុកជាច្រើន ត្រូវមនុស្សទាំងឡាយតិះដៀលថា អ្នកជំនួញបាត្រ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទថា ***ភិក្ខុទុកអតិរេកបាត្រ (គឺបាត្រលើសពី ១ ដែលហួសពីសេចក្តីត្រូវការជាប្រចាំ) ហួស ១០ ថ្ងៃ ត្រូវនិស្សគ្គិយបាចិត្តិយ។***

### សិក្ខាបទទី ២

**(ហាមសុំបាត្រនៅពេលមានស្នាមប្រេះតិចជាង ៥ កន្លែង)**

*ជាងស្មូនឆ្នាំង បវារណាភិក្ខុទាំងឡាយសុំបាត្របាន តែភិក្ខុទាំងឡាយសុំលើសប្រមាណ រហូតដល់គេក្តៅក្រហាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុសុំបាត្រ ត្រូវនិស្សគ្គិយបាចិត្តិយ។ ក្រោយមកមានរឿងកើតឡើង ទើបទ្រង់អនុញ្ញាតឱ្យសុំបាននៅពេលបាត្រត្រូវវិនាស ឬបែក ឬក៏ធ្លុះ ៥ កន្លែង។***

### សិក្ខាបទទី ៣

**(ហាមទុកភេសជ្ជៈ ៥ យ៉ាង លើសពី ៧ ថ្ងៃ)**

*មានគេប្រគេនភេសជ្ជៈ ៥ យ៉ាង សម្រាប់ភិក្ខុអាពាធ គឺ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅ ដល់ភិក្ខុបិលិន្ទវច្ឆៈ លោកក៏បែងចែកឲ្យភិក្ខុបរិស័ទរបស់លោក ។ ភិក្ខុទាំង*

នោះទុកក្នុងទីផ្សេងៗ ភេសជ្ជៈក៏ហូរហៀរប្រឡាក់វិហារៗ ក៏ពោរពេញទៅដោយកណ្តុរ ។ មនុស្សទាំងឡាយនាំគ្នាតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **អនុញ្ញាតឱ្យទុកភេសជ្ជៈ ៥ យ៉ាង បរិភោគបាន មិនលើសពី ៧ ថ្ងៃ បើលើសពី ៧ ថ្ងៃ ត្រូវនិស្សគ្គិយបាចិត្តិយ។**

## សិក្ខាបទទី ៤

### (ហាមស្វែងរក និង ធ្វើសំពត់ងូតទឹកភ្លៀងលើសកំណត់)

ភិក្ខុឆព្វគ្គិយដឹងថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតសំពត់ងូតទឹកភ្លៀង ទើបស្វែងរក និងធ្វើសំពត់ស្លៀកមុនពេល (ដល់រដូវភ្លៀង) ក្រោយមកសំពត់ក៏ចាស់ទ្រុឌទ្រោម ពួកលោកក៏អាក្រាតកាយងូតទឹកភ្លៀង ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទ អនុញ្ញាតស្វែងរកសំពត់ងូតទឹកភ្លៀងបានក្នុងរយៈពេល ១ ខែ មុនរដូវភ្លៀង **អនុញ្ញាតធ្វើសំពត់ស្លៀកបានក្នុងរយៈពេល ១៥ ថ្ងៃ មុនរដូវភ្លៀង បើស្វែងរក ឬធ្វើមុនកាលកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ។**

## សិក្ខាបទទី ៥

### (ឱ្យចីវរដល់ភិក្ខុដទៃហើយ ហាមដណ្តើមយកវិញ)

ភិក្ខុឧបនន្ទសក្យបុត្រ បបួលភិក្ខុមួយរូបត្រាច់ទៅកាន់ជនបទ ភិក្ខុរូបនោះប្រាប់ថា ចីវរចាស់ណាស់ លោកមិនទៅទេ ទើបភិក្ខុឧបនន្ទឲ្យចីវរថ្មី ក្រោយមកភិក្ខុរូបនោះប្តូរចិត្តសម្រេចទៅតាមព្រះមានព្រះភាគ ទើបភិក្ខុឧបនន្ទក្រោធរួចហើយដណ្តើមយកចីវរមកវិញ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទថា **ភិក្ខុឱ្យចីវរដល់ភិក្ខុដទៃហើយ ក្រោធ មិនពេញចិត្ត ដណ្តើមយកដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យដណ្តើមយកមកវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។**

## សិក្ខាបទទី ៦

### (ហាមសុំអំបោះយកមកធ្វើចីវរ)

ភិក្ខុឆព្វគ្គិយ ចារិកសុំអំបោះយកមកឲ្យជាងតម្បាញធ្វើចីវរ អំបោះនៅសល់ក៏ទៅសុំគេបន្ថែម ហើយឲ្យជាងតម្បាញធ្វើជាចីវរទៀត អំបោះនៅសល់ទៀត ក៏ទៅសុំគេមកបន្ថែមហើយឲ្យជាងតម្បាញធ្វើចីវរជាគម្រប់ ៣ ដង មនុស្សទាំងឡាយគេពោលទោសតិះដៀល ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទថា **ភិក្ខុ**

*សុំអំពោះគេដោយខ្លួនឯង ហើយឱ្យជាងតម្បាញធ្វើជាចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។*

## សិក្ខាបទទី ៧

### (ហាមទៅប្រាប់ជាងតម្បាញធ្វើឱ្យល្អ)

ភិក្ខុឧបនន្ទសាក្យបុត្រដឹងថា មានបុរសម្នាក់ប្រាប់ភរិយាខ្លួនឲ្យកំម៉ង់ (បង្គាប់) ជាងតម្បាញធ្វើចីវរប្រគេន ទើបទៅប្រាប់ជាងតម្បាញធ្វើឲ្យវែង ធំ ហើយក្រាស់ជាដើម អំបោះដែលប្រគល់ឲ្យពីមុនក៏អស់ ស្រាប់តែជាងតម្បាញទៅសុំអំបោះពីស្ត្រីនោះបន្ថែមទៀត ក្រោយមកបុរសជាស្វាមីដឹងរឿង ក៏តិះដៀល ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទដោយន័យថា ***ភិក្ខុដែលគេពុំបានបវារណាទុកមុន ហើយទៅប្រាប់ជាងតម្បាញឱ្យ ធ្វើយ៉ាងនេះយ៉ាងនោះ ខ្លួននឹងឱ្យរង្វាន់ខ្លះ លុះនិយាយជាមួយគេរួចហើយ សូម្បីឱ្យរបស់បន្តិចបន្តួច ដោយហោចទៅត្រឹមតែបិណ្ឌបាត ក៏ត្រូវនិស្សគ្គិយបាចិត្តិយដែរ។***

## សិក្ខាបទទី ៨

### (ហាមទុកសំពត់ងូតទឹកភ្លៀងលើសកំណត់)

ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតទទួលសំពត់ងូតទឹកភ្លៀង (គឺគេប្រគេនដល់ភិក្ខុដែលបានចាំវស្សា មុនចេញវស្សា) ទុកបាន។ តែភិក្ខុរូបខ្លះ ទុកលើសកំណត់កាលចីវរ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ អនុញ្ញាតទទួលសំពត់ងូតទឹកភ្លៀងបានមុនចេញវស្សា ១០ ថ្ងៃ តែឲ្យទុកក្នុងកំឡុងកាលចីវរប៉ុណ្ណោះ[១៥] ទុកលើសកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ។

## សិក្ខាបទទី ៩

### (ហាមភិក្ខុនៅព្រៃហើយទុកចីវរក្នុងស្រុកលើស ៦ រាត្រី)

ភិក្ខុចាំវស្សារួចហើយ ក៏នាំគ្នាទៅនៅក្នុងព្រៃ ពួកចោរដឹងថាមានចីវរ ក៏លួចយកអស់ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតភិក្ខុនៅព្រៃទុកចីវរផ្ទាំងណាមួយនៅក្នុងស្រុកបាន។ ក៏ស្រាប់តែភិក្ខុទុកចីវរក្នុងស្រុកលើស ៦ រាត្រី ចីវរបាត់ខ្លះ កណ្ដុរកាត់ខ្លះ។ ទើប

[១៥] បើចាំវស្សាគ្រប់ ៣ ខែហើយ អាចទុកបាន ១ ខែ ក្រោយពីចេញវស្សា តែបើបានក្រាលកឋិន អាចទុកបានលើស ៤ ខែទៀត ទើបត្រូវជា ៥ ខែ។

ទ្រង់បញ្ញត្តសិក្ខាបទ ***អនុញ្ញាតភិក្ខុនៅក្នុងព្រៃទុកចីវរផ្ទាំងណាមួយក្នុងស្រុកបាន ប៉ុន្តែនៅប្រាសចាកចីវរនោះបាន មិនលើសពី ៦ រាត្រី បើ លើសពីនោះទៅត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងបានសន្មត (គឺសង្ឃប្រជុំគ្នាសូត្រប្រកាសជាកិច្ចពិសេស)។***

## សិក្ខាបទទី ១០

### (ហាមបង្អោនលាភសង្ឃមកដើម្បីខ្លួន)

*ភិក្ខុឆព្វគ្គិយទៅនិយាយជាមួយគណៈបុគ្គល ដែលបានត្រៀមអាហារ និងចីវរទុកប្រគេនដល់សង្ឃ ដើម្បីឲ្យគេប្រគេនដល់ខ្លួន ពួកគេត្រូវពួកលោករុកកួនខ្លាំងពេកទើបប្រគេនទៅ ដំណឹងនេះដឹងដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុដឹងថា លាភគេបង្អោនទៅដើម្បីសង្ឃ ហើយបង្អោនមកដើម្បីខ្លួនវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។***

## បាចិត្តិយកណ្ឌ

### (ពោលអំពីអាបត្តិបាចិត្តិយដែលពុំចាំបាច់លះវត្ថុ)

*កណ្ឌនេះមាន ៩២ សិក្ខាបទ ចែកចេញជា ៩ វគ្គ ក្នុង ១ វគ្គមាន ១០ សិក្ខាបទ វៀរលែងតែវគ្គទី ៨ មាន ១២ សិក្ខាបទ។*

## ១.មុសាវាទវគ្គ

## សិក្ខាបទទី ១

### (ហាមនិយាយកុហក)

*ភិក្ខុហត្ថកសាក្យបុត្រ និយាយសន្ទនាជាមួយពួកអន្យតិរត្ថិយ បដិសេធហើយត្រឡប់ជាទទួលៗ ហើយត្រឡប់ជាបដិសេធ ហ៊ាននិយាយមុសាទាំងដែលដឹងខ្លួន ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលនិយាយកុហក ទាំងដែលដឹងខ្លួន។***

## សិក្ខាបទទី ២

### (ហាមជេរ)

*ភិក្ខុឆព្វគ្គិយ បង្កជម្លោះជាមួយភិក្ខុដែលមានសីលជាទីស្រឡាញ់*

ជាច្រើនរូប ហើយជេរ ប្រទេច ដោយពាក្យជេរ ១០ ប្រការ គឺពាក្យជេរដែលអាងដល់ជាតិ (កំណើត), នាម, គោត្រ, ការងារ, សិល្បៈ, អាពាធ, ភេទ, កិលេស, អាបត្តិ និងពាក្យជេរគ្រោតគ្រាត ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលជេរភិក្ខុដទៃ។***

## សិក្ខាបទទី ៣

### (ហាមនិយាយស៊កសៀត)

ភិក្ខុឆព្វគ្គិយ និយាយស៊កសៀតភិក្ខុពីរក្រុមដែលឈ្លោះគ្នា ស្តាប់រឿងខាងនេះទៅប្រាប់ខាងនោះ ស្តាប់រឿងខាងនោះមកប្រាប់ខាងនេះ ធ្វើឲ្យជម្លោះកាន់តែខ្លាំងឡើងថែមទៀត ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលនិយាយស៊កសៀតភិក្ខុដទៃ។***

## សិក្ខាបទទី ៤

### (ហាមបង្រៀនធម៌ជាបទដល់អនុបសម្បន្ន)

ភិក្ខុឆព្វគ្គិយ បង្រៀនឧបាសកទាំងឡាយឲ្យនិយាយធម៌ (ព្រមគ្នា) ដោយបទ ធ្វើឲ្យឧបាសកទាំងនោះខ្វះការគោរពចំពោះភិក្ខុទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុបង្រៀនធម៌ដល់អនុបសម្បន្ន (គឺអ្នកដែលមិនមែនជាភិក្ខុ ឬភិក្ខុនី) ព្រមគ្នាដោយបទ។***

## សិក្ខាបទទី ៥

### (ហាមដេករួមជាមួយអនុបសម្បន្នលើស ៣ រាត្រី)

ឧបាសកទៅស្តាប់ធម៌ ដេកយាំងនៅទីវត្តក្នុងសាលាប្រជុំ ភិក្ខុបួសថ្មីក៏ដេករួមជាមួយពួកគេផងដែរ ជាអ្នកដែលពុំមានសតិសម្បជញ្ញៈ ដេកអាក្រាតកាយ មមើ ស្រមុ៉ក គួរជាទីតិះដៀលនៃឧបាសកទាំងនោះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុដេករួមអនុបសម្បន្ន[១៦] (គឺមិនមែនជាភិក្ខុ) ក្រោយមកទ្រង់អនុញ្ញាតដេករួមគ្នាបាន មិនឱ្យលើសពី ៣ រាត្រី។***

---

[១៦] ក្នុងទីនេះ សំដៅយកបុរស, តែក្នុងសិក្ខាបទទី ៤ សំដៅយក ទាំងបុរសទាំងស្ត្រី ។

## សិក្ខាបទទី ៦

### (ហាមដេករួមជាមួយស្ត្រី)

*ភិក្ខុអនុរុទ្ធ ចារិកតាមកោសលជនបទទៅកាន់ក្រុងសាវត្ថី បិណ្ឌបាតអាស្រ័យក្នុងផ្ទះសំណាក់ស្ត្រីម្នាក់ ក្រោយមកក៏មានអ្នកដំណើរមកសុំអាស្រ័យក្នុងផ្ទះសំណាក់នោះទៀត ស្ត្រីម្ចាស់ផ្ទះពេញចិត្តក្នុងរូបឆោមរបស់ភិក្ខុអនុរុទ្ធ ទើបរៀបចំឲ្យសម្រាកនៅក្នុងបន្ទប់ថ្មីជាមួយនាង រួចទាក់ទាញលោកដោយប្រការផ្សេងៗ តែលោកបែរជានៅស្ងៀម ហើយក៏សំដែងធម៌ឲ្យស្តាប់ រហូតដល់ស្ត្រីនោះប្តេជ្ញាខ្លួនដល់ព្រះរតនត្រ័យអស់មួយជីវិត ព្រះពុទ្ធអង្គទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលដេករួមជាមួយមាតុគ្រាម (ស្ត្រីភេទ)។***

## សិក្ខាបទទី ៧

### (ហាមសំដែងធម៌តែពីរនាក់ស្ត្រី)

*ភិក្ខុឧទាយី សំដែងធម៌ខ្សឹបដាក់ត្រចៀកស្រីៗ ធ្វើឲ្យគេសង្ស័យ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមសំដែងធម៌ដល់ស្ត្រី*** *ក្រោយមកមានហេតុកើតឡើង ទ្រង់ក៏បញ្ញត្តបន្ថែមថា* ***ភិក្ខុសំដែង ធម៌ដល់មាតុគ្រាមលើស ៦ បទ ត្រូវបាចិត្តិយ វៀរលែងមានបុរសដឹងក្តីនៅជាមួយ។***

## សិក្ខាបទទី ៨

### (ហាមប្រាប់គុណវិសេសពិតដល់អ្នកពុំបានបួស)

*ព្រះពុទ្ធអង្គ ទ្រង់ប្រារព្ធរឿងដូចគ្នាដែលកើតឡើងក្នុងបារាជិកសិក្ខាបទទី ៤ គឺអួតគុណវិសេសដែលមិនមានក្នុងខ្លួន តែលើកនេះទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុប្រាប់គុណវិសេសដែលមានពិតដល់អ្នកដែលពុំបានបួស (គឺមិនមែនភិក្ខុ ឬភិក្ខុនី)។***

## សិក្ខាបទទី ៩

### (ហាមប្រាប់អាបត្តិគ្រោតគ្រាតរបស់ភិក្ខុដល់អ្នកពុំបានបួស)

*ភិក្ខុឆព្វគ្គិយ បង្កជម្លោះជាមួយភិក្ខុឧបនន្ទសាក្យបុត្រ រួចហើយមកក្លែងផ្សាញ់ផ្សាលភិក្ខុឧបនន្ទជាមួយពួកឧបាសក ដែលកំពុងផ្គត់ផ្គង់បង្អាន់ភិក្ខុសង្ឃថា ភិក្ខុឧបនន្ទត្រូវអាបត្តិសង្ឃាទិសេសសិក្ខា-បទទី ១ ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទថា* ***ភិក្ខុ***

***ប្រាប់អាបត្តិ របស់ភិក្ខុផងគ្នាដល់អនុបសម្បន្ន (គឺពុំមែនភិក្ខុ ឬភិក្ខុនី) ត្រូវបាចិត្តិយ វៀរលែងតែបានទទួលសន្មត។***

## សិក្ខាបទទី ១០

## (ហាមជីកដី ឬប្រើគេឱ្យជីក)

*ភិក្ខុក្រុងអាឡវី ធ្វើការកសាង ទើបនាំគ្នាជីកដីដោយខ្លួនឯងខ្លះ ប្រើគេឲ្យជីកខ្លះ មនុស្សម្នាទាំងឡាយនាំគ្នាតិះដៀលថា ខុសប្រពៃណីនិយមរបស់សមណៈ ព្រះមានព្រះភាគ (ទ្រង់អនុលោមតាមប្រពៃណីដែលប្រកាន់ថា ផែនដីជាវត្ថុមានជីវិត គឺមានឥន្ទ្រីយ៍មួយ) ទើបបញ្ញត្តសិក្ខាបទថា* ***ភិក្ខុជីកដី*** [១៧] ***ដោយខ្លួនឯង ឬប្រើគេឱ្យជីក ត្រូវបាចិត្តិយ។***

## ២.ភូតគាមវគ្គ

*គឺវគ្គពោលអំពីពូជរុក្ខជាតិ ជាវគ្គទី ២ មាន ១០ សិក្ខាបទ គឺ*

## សិក្ខាបទទី ១

## (ហាមកាប់ដើមឈើ)

*ភិក្ខុក្រុងអាឡវី ធ្វើការកសាង នាំគ្នាកាប់ដើមឈើដោយខ្លួនឯងខ្លះ ប្រើគេឲ្យកាប់ខ្លះ មនុស្សម្នាទាំងឡាយនាំគ្នាតិះដៀលដោយប្រកាន់ថា ដើមឈើមានជីវិត មានឥន្ទ្រីយ៍មួយ ព្រះមានព្រះភាគ (ទ្រង់អនុលោមតាមការសន្មតរបស់សត្វលោក) ទើបទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលធ្វើដើមឈើឱ្យស្លាប់*** [១៨] *(ដើមឈើមាន ៥ យ៉ាង គឺមានមើមជាពូជ ដូចជាខ្ញី..., មានដើមជាពូជ ដូចជាជ្រៃ..., មានថ្នាំងជាពូជ ដូចជាអំពៅ ឫស្សី..., មានចុង ឬត្រួយជាពូជ ដូចជាម្អម..., មានគ្រាប់ជាពូជ ដូចជាស្រូវ សណ្តែក...) ។*

## សិក្ខាបទទី ២

## (ហាមនិយាយបង្វែងដាននៅពេលសាកសួរ)

*ឆន្នភិក្ខុ ប្រព្រឹត្តអនាចារត្រូវបានចោទកណ្តាលជំនុំសង្ឃ ត្រឡប់ជានិយាយបន្វែបន្ទំខ្លះ អង្គុយស្ងៀមខ្លះ ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនិយាយ***

---

[១៧] *សំដៅយកដីដែលមានភ្លៀងធ្លាក់ជាប់លើសពី ៤ ខែឡើងទៅ, សិក្ខាបទនេះគួរយល់ថា ដើម្បីការពារសត្វមានជីវិតដែលរស់នៅក្នុងដី មានដូចជា ជន្លេនជាដើម.*

[១៨] *ពាក្យថា ដើមឈើ ក្នុងសិក្ខាបទនេះ ប្រែពីពាក្យថា ភូតគាម ។*

***បង្វែងដាន ធ្វើឱ្យសង្ឃលំបាក*** (អន្ទុយស្មៀមនៅពេលសង្ឃសាកសួរដេញដោលកណ្ដាលជំនុំសង្ឃ) ។

## សិក្ខាបទទី ៣

## (ហាមតិះដៀលភិក្ខុដែលធ្វើការឱ្យសង្ឃដោយប្រពៃ)

ភិក្ខុទាំងឡាយដែលមានមេត្តិយភិក្ខុ និងភុម្មជ្ជកភិក្ខុជាប្រធាន នាំគ្នាពោលទោស តិះដៀល ព្រះទព្វមល្លបុត្រដែលជាអ្នកចែកសេនាសនៈ និងភត្ត ព្រះមានព្រះភាគទ្រង់សាកសួរជ្រាបហើយ ទើបបញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលពោលទោសតិះដៀល (ភិក្ខុដែលធ្វើការឱ្យសង្ឃដោយប្រពៃ)។**

## សិក្ខាបទទី ៤

## (ហាមចោលគ្រែកៅអីសង្ឃទុកកណ្ដាលវាល)

ភិក្ខុទាំងឡាយនាំសេនាសនៈ (ទីដេក និងទីអង្គុយ) មកទុកកណ្ដាលវាលក្នុងរដូវរងារ ហើយគេចចេញទៅអស់ មិនរៀបចំទុកដាក់ មិនប្រើគេឲ្យរៀបចំទុកដាក់ មិនប្រាប់ឲ្យគេដឹង សេនាសនៈក៏ត្រូវទឹកភ្លៀង (ទទឹកអស់) ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុទុកដោយខ្លួនឯងក្ដី ប្រើគេឱ្យទុកក្ដី នូវគ្រែ តាំង ពូក កៅអី ចោលនៅកណ្ដាលវាល កាលបើចៀសចេញទៅ មិនរៀបចំទុកដាក់ ដោយខ្លួនឯង មិនប្រើគេឱ្យរៀបចំ ឬទៅដោយពុំបានប្រាប់គេឱ្យដឹង ត្រូវបាចិត្តិយ។*** ក្រោយមកទ្រង់អនុញ្ញាតពិសេស ***គឺឱ្យរៀបចំសេនាសនៈទុកក្នុងមណ្ឌប ឬក្រោមដើមឈើ*** គឺគប្បីសង្កេតថា ភ្លៀងនឹងមិនលិច កណ្ដៀរនឹងមិនឡើងបានអស់ ៨ ខែ (នៃរដូវរងារ និងរដូវក្ដៅ ក្នុងមួយរដូវមាន ៤ ខែ) ។

## សិក្ខាបទទី ៥

## (ហាមចោលកម្រាលដេកទៅដោយពុំបានរៀបចំ)

ពួកភិក្ខុ ១៧ រូប ក្រាលកម្រាលដេកក្នុងវិហាររបស់សង្ឃ ហើយចេញទៅដោយពុំបានរៀបចំដោយខ្លួនឯង មិនប្រើគេឲ្យរៀបចំ ឬមិនប្រាប់គេឲ្យដឹង ពួកកណ្ដៀរក៏កាត់ស៊ីសេនាសនៈ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុក្រាល ឬប្រើគេឱ្យក្រាលកម្រាលដេកក្នុងវិហាររបស់សង្ឃ កាលបើចៀសចេញទៅ មិនរៀបចំទុកដាក់ដោយខ្លួនឯង មិនប្រើគេរៀបចំទុកដាក់ ឬមិនប្រាប់គេឱ្យដឹង ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៦

### (ហាមដេកប្រជ្រៀតភិក្ខុដែលចូលទៅដេកមុន)

ភិក្ខុឆព្វគ្គិយ រកវិធីទៅដណ្ដើមយកទីកន្លែងភិក្ខុដទៃដោយចូលទៅដេកប្រជ្រៀតភិក្ខុជាព្រះថេរៈ ដោយគិតថា លោកធុញទ្រាន់ហើយនឹងចៀសចេញ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដឹងហើយ ចូលទៅដេកប្រជ្រៀតភិក្ខុដែលចូលទៅដេកក្នុងវិហាររបស់សង្ឃមុន ដោយគិតថា លោកធុញទ្រាន់ហើយនឹងចៀសចេញទៅ លោកមានបំណងយ៉ាងនេះតែម្យ៉ាង ពុំមែនដទៃ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៧

### (ហាមបណ្ដេញភិក្ខុចេញពីវិហារសង្ឃ)

ភិក្ខុឆព្វគ្គិយ ដណ្ដើមយកកន្លែងសត្តរសភិក្ខុ (ភិក្ខុមានគ្នា ១៧) ពួកលោកមិនព្រម ក៏ខឹងសម្បាហើយបណ្ដេញចេញ ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទថា ***ភិក្ខុក្រោធមិនពេញចិត្តភិក្ខុផងគ្នា បណ្ដេញដោយខ្លួនឯងក្ដី ប្រើគេឱ្យបណ្ដេញក្ដី ចេញពីវិហាររបស់សង្ឃ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៨

### (ហាមដេក ឬអង្គុយសង្កត់គ្រែ ឬតាំងនៅជាន់ខាងលើ)

ភិក្ខុ ២ រូបនៅក្នុងកុដិជាមួយគ្នា គ្រែមួយនៅខាងលើ គ្រែមួយទៀតនៅខាងក្រោម ភិក្ខុដែលនៅលើគ្រែខាងលើអង្គុយសង្កត់គ្រែខ្លាំង ជើងគ្រែក៏បាក់ធ្លាក់ត្រូវក្បាលភិក្ខុដែលនៅខាងក្រោម ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដេក ឬអង្គុយលើគ្រែដែលមានជើង (ស៊កចូលក្នុងមេគ្រែ) ក្នុងវិហាររបស់សង្ឃ ត្រូវបាចិត្តិយ***[១៩] ។

## សិក្ខាបទទី ៩

### (ហាមពូនជម្លូលវិហារលើស ៣ ជាន់)

មហាអាមាត្យដែលឧបដ្ឋាកឆន្នភិក្ខុ ឲ្យគេសាងវិហារប្រគេន

---

[១៩] សេចក្ដីក្នុងសិក្ខាបទនេះ ហាមប្រើគ្រែដូចនោះ វៀរតែបានធ្វើឲ្យជាប់ល្អ ។

*លោក នៅពេលរួចរាល់ហើយ ឆន្នភិក្ខុរៀបចំពូនដម្បូលវិហារឡើង រឿយៗ ដំម្បូលវិហារក៏បាក់ធ្លាក់ចុះមក ឆន្នភិក្ខុរៀបចំស្មៅ និង ឈើបានធ្ងើ សន្ទូងរបស់ព្រាហ្មណ៍ម្នាក់ឲ្យខូចអស់ ព្រាហ្មណ៍ ក៏ពោលទោសតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ថា* ***បើភិក្ខុឱ្យគេ ធ្វើវិហារធំ គប្បីរកទីដែលពុំមានសន្ទូង (ពូជវុក្ខ-ជាតិ) ហើយសឹម ធ្វើការពូនដម្បូលវិហារកុំឱ្យលើស ៣ ជាន់ រហូត ដល់ស៊ុំទ្វារដើម្បីតាំងសន្លឹកទ្វារបាន និងលាបពណ៌បង្អួចបាន បើធ្វើ ឱ្យលើសពីនោះ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ១០

### (ហាមយកទឹកមានសត្វស្រោចស្មៅ ឬដី)

*ភិក្ខុក្រុងអាឡវីធ្វើការកសាង ដឹងថា ទឹកមានសត្វហើយ នៅតែយកទឹកនោះទៅស្រោចស្មៅខ្លះ ដីខ្លះ ប្រើគេឲ្យស្រោចខ្លះ ជាការដែលនាំឲ្យភិក្ខុទាំងឡាយតិះដៀល ទើបព្រះមានព្រះភាគទ្រង់ បញ្ញត្តសិក្ខាបទថា* ***ភិក្ខុដឹងហើយ នៅតែនាំយកទឹកដែលមានសត្វ ទៅស្រោចស្មៅ ឬដី ឬក៏ប្រើគេឱ្យស្រោច ត្រូវបាចិត្តិយ។***

**៣.ឱវាទវគ្គ** គឺវគ្គពោលអំពីការឲ្យឱវាទ ជាវគ្គទី ៣ មាន ១០ សិក្ខាបទ គឺ

## សិក្ខាបទទី ១

**(ហាមបង្រៀនភិក្ខុនីដោយគ្មានការសន្មត)**

ភិក្ខុឆព្វគ្គិយ ឃើញភិក្ខុដទៃបង្រៀនភិក្ខុនីហើយបានរបស់ប្រគេនផ្សេងៗ ចង់បានលាភដែរ ក៏ប្រាប់ដំណឹងដល់ភិក្ខុនីទាំងឡាយ ពេលភិក្ខុនីទៅស្តាប់ឱវាទក៏ផ្ទៀតបង្រៀនមួយភ្លែតៗ ហើយបបួលនិយាយរឿងគ្មានប្រយោជន៍ជាច្រើន ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដែលពុំទាន់បានទទួលការសន្មតអំពីសង្ឃ បង្រៀនភិក្ខុនី ត្រូវបាចិត្តិយ។*** ក្រោយមក ភិក្ខុឆព្វគ្គិយរកវិធីសន្មតគ្នាឯងខាងក្រៅសីមា (ព្រោះមានគ្នាចំនួន ៦ រូប ល្មមធ្វើកម្មរបស់សង្ឃបាន) ទើបព្រះមានព្រះភាគទ្រង់កំណត់នូវគុណសម្បត្តិបន្ថែមទៀត សម្រាប់ភិក្ខុបង្រៀនភិក្ខុនី មាន ៨ យ៉ាង ដោយកំណត់ ឲ្យមានវស្សា ២០ ឬច្រើនជាងជាខចុងក្រោយ ។

## សិក្ខាបទទី ២

**(ហាមបង្រៀនភិក្ខុនីចាប់តាំងពីព្រះអាទិត្យលិច)**

ភិក្ខុចូឡបន្ថកៈ បង្រៀនភិក្ខុនីរហូតដល់យប់ មនុស្សទាំងឡាយតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***កាលបើព្រះអាទិត្យលិចហើយ ភិក្ខុបង្រៀនភិក្ខុនី ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៣

**(ហាមទៅបង្រៀនភិក្ខុនីដល់ទីលំនៅ)**

ភិក្ខុឆព្វគ្គិយ ចូលទៅបង្រៀនភិក្ខុនីដល់ទីលំនៅ ភិក្ខុនីទាំងឡាយតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុទៅបង្រៀនភិក្ខុនីដល់ទីលំនៅ ត្រូវបាចិត្តិយ។ ក្រោយមក ទ្រង់អនុញ្ញាត បើមានភិក្ខុនីអាពាធ។***

## សិក្ខាបទទី ៤

**(ហាមដៀលភិក្ខុដទៃថាបង្រៀនភិក្ខុនីព្រោះឃើញលាភ)**

ភិក្ខុឆព្វគ្គិយពោលថា ព្រះថេរៈទាំងឡាយបង្រៀនភិក្ខុនីទាំងឡាយព្រោះសម្លឹងឃើញដល់លាភ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនិយាយថា ភិក្ខុទាំងឡាយបង្រៀនភិក្ខុនី***

***ព្រោះសម្លឹងឃើញដល់អាមិស ត្រូវបាចិត្តិយ*** (ហាមប្រណែនគ្នា ទោះបីឃើញដល់អាមិសក៏ដោយ បើដើរនិយាយ ត្រូវនូវអាបត្តិទុក្កដ) ។

## សិក្ខាបទទី ៥

### (ហាមឱ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ)

ភិក្ខុមួយរូប ឲ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ មានអ្នកតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុឱ្យចីវរដល់ភិក្ខុនី ពុំមែនជាញាតិ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៦

### (ហាមដេរចីវរឱ្យដល់ភិក្ខុនីមិនមែនជាញាតិ)

ភិក្ខុឧទាយី ដេរចីវរឲ្យដល់ភិក្ខុនី មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដេរដោយខ្លួនឯងក្តី ប្រើគេឱ្យដេរក្តី ដើម្បីភិក្ខុនីមិនមែនជាញាតិ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៧

### (ហាមដើរផ្លូវរួមគ្នាជាមួយភិក្ខុនី)

ភិក្ខុឆព្វគ្គិយ បបួលភិក្ខុនីដើរផ្លូវឆ្ងាយរួមគ្នា មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុបបួលភិក្ខុនីដើរផ្លូវឆ្ងាយរួមគ្នា សូម្បីចម្ងាយស្រុកមួយ ត្រូវបាចិត្តិយ***[២០] ។

## សិក្ខាបទទី ៨

### (ហាមបបួលភិក្ខុនីដើរទូករួមជាមួយគ្នា)

ភិក្ខុឆព្វគ្គិយ បបួលភិក្ខុនីដើរទូកជាមួយគ្នា មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុបបួលភិក្ខុនីដើរទូកជាមួយគ្នា ទាំងបញ្ច្រាស់ ឬបណ្តោយខ្សែទឹក ត្រូវបាចិត្តិយ,*** ក្រោយមក ទ្រង់អនុញ្ញាតឲ្យឆ្លង ទៅត្រើយម្ខាងបាន ។

## សិក្ខាបទទី ៩

### (ហាមឆាន់អាហារដែលភិក្ខុនីបង្គាប់ឱ្យធ្វើ)

---

[២០] ***សត្ថគមនីយោ*** ប្រែបានពីរយ៉ាង គឺផ្លូវត្រូវទៅដោយពួករទេះ សឹងកាន់យកន័យថា ត្រូវទៅជាគណៈ, មយ៉ាងទៀត ប្រែថា ផ្លូវត្រូវទៅដោយសស្ត្រាវុធ គឺត្រូវមានសស្ត្រាវុធ ។

ថុល្លនន្ទាភិក្ខុនី ចូលទៅកាន់ត្រកូល បង្គាប់ឲ្យគេប្រគេនអាហារដល់ភិក្ខុទេវទត្តព្រមទាំងគ្នារបស់លោក មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដឹងហើយ ឆាន់បិណ្ឌបាត ដែលភិក្ខុនីបង្គាប់ឱ្យគេប្រគេន ត្រូវបាចិត្តិយ។*** ក្រោយមកទ្រង់អនុញ្ញាតថា បើគ្រហស្ថគេផ្តើមទុកមុនដោយខ្លួនឯង ឆាន់បាន ។

## សិក្ខាបទទី ១០

### (ហាមអង្គុយក្នុងទីកំបាំងតែពីរនាក់ភិក្ខុនី)

ភិក្ខុឧទាយី អង្គុយក្នុងទីកំបាំងតែពីរនាក់ភិក្ខុនីដែលជាអតីតភរិយារបស់ខ្លួនរឿយៗ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុអង្គុយក្នុងទីកំបាំងតែពីរនាក់ភិក្ខុនី ត្រូវបាចិត្តិយ។***

**៤.ភោជនវគ្គ** *គឺវគ្គពោលអំពីការឆាន់អាហារ ជាវគ្គទី ៤ មាន ១០ សិក្ខាបទ គឺ*

## សិក្ខាបទទី ១

### (ហាមឆាន់អាហារក្នុងសាលាសំណាក់ច្រើនជាងមួយពេល)

ភិក្ខុឆព្វគ្គិយ ទៅឆាន់អាហារក្នុងសាលាសំណាក់ ដែលម្ចាស់ទានគេរៀបចំទុកសម្រាប់អ្នកដំណើរតាមផ្លូវចូលមកសំណាក់ ហើយក៏ឆក់យកឱកាសទៅស្នាក់ និងឆាន់អាហារជាប្រចាំ គួរជាទីតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុគប្បីឆាន់អាហារក្នុងសាលាសំណាក់តែមួយពេល បើលើសពីកំណត់នោះ ត្រូវបាចិត្តិយ,*** ក្រោយមក ទ្រង់អនុញ្ញាតភិក្ខុអាពាធដែលធ្វើដំណើរតទៅទៀតពុំរួច ឆាន់ច្រើនជាងមួយពេលបាន ។

## សិក្ខាបទទី ២

### (ហាមឆាន់អាហាររួមក្រុម)

ភិក្ខុទេវទត្ត វិនាសលាភសក្ការៈ ទើបដើរអង្វៀសអាហារគេតាមត្រកូល ឆាន់រួមក្រុមជាមួយបរិស័ទរបស់ខ្លួន មនុស្សទាំងឡាយ

តិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុឆាន់អាហាររួមគ្នា***[២១] ***ត្រូវអាបត្តិបាចិត្តិយ។***

## សិក្ខាបទទី ៣

### (ហាមទទួលនិមន្តហើយទៅឆាន់ក្នុងទីដទៃ)[២២]

កម្មករដឹកកម្សត់កម្រមួយរូប និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានទៅឆាន់នៅឯផ្ទះ ភិក្ខុទាំងឡាយទៅបិណ្ឌបាតឆាន់រួចហើយ (អាចក្រែងថា អាហារមិនឆ្ងាញ់ ឬមិនគ្រប់គ្រាន់) នៅពេលទៅឆាន់នៅផ្ទះកម្មករនោះ ទើបឆាន់បានតែបន្តិច (ព្រោះឆ្អែតរួចហើយ) តាមពិតអាហារនៅសល់ពាសពេញ ពីព្រោះអ្នកស្រុកដឹងដំណឹងក៏យករបស់របរទៅជួយយ៉ាងច្រើន ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ត្រូវបាចិត្តិយ ព្រោះទទួលនិមន្តហើយទៅឆាន់អាហាររបេះរបោះ ។*** ក្រោយមក ទ្រង់អនុញ្ញាតក្នុងពេលមានអាពាធ, ក្នុងពេលប្រគេនចីវរ, ក្នុងពេលធ្វើចីវរ ប្រគល់ឲ្យភិក្ខុដទៃទៅឆាន់ក្នុងទីនិមន្តជំនួសបាន ។

## សិក្ខាបទទី ៤

### (ហាមទទួលបិណ្ឌបាតលើសបីបាត្រ)

មាតានាងកាណា ធ្វើនំទុកឲ្យកូនស្រីយកទៅកាន់ត្រកូលខាងស្វាមី ភិក្ខុចូលទៅបិណ្ឌបាតហើយត្រឡប់មកប្រាប់គ្នាឲ្យទៅទទួលបិណ្ឌបាតទៀត ទើបនាងប្រគេនរហូតដល់អស់ សូម្បីលើកទី ២ ទី ៣ ទើបធ្វើឲ្យកូនស្រីរបស់នាងកាណា ខានបានទៅកាន់ត្រកូលស្វាមី ធ្វើឲ្យកើតក្ដីវិនាសដល់បុត្រីរបស់នាង ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុចូលទៅកាន់ត្រកូល បើគេបវារណាដោយនំ ឬដោយបាយសង្ហូវផង់ ដើម្បីនាំទៅបានតាមប្រាថ្នា គប្បីទទួលពេញត្រឹម ២_៣ បាត្រ បើទទួលលើសកំណត់នោះ ត្រូវបាចិត្តយ។*** (វិធីល្អ គឺភិក្ខុទទួលបាន ២-៣ បាត្រហើយ គប្បីនាំទៅបែងចែកដល់ភិក្ខុទាំងឡាយ) ។

## សិក្ខាបទទី ៥

### (ហាមឆាន់ទៀតនៅពេលឆាន់ក្នុងទីនិមន្តហើយ)

ភិក្ខុទទួលនិមន្តទៅឆាន់នៅឯផ្ទះព្រាហ្មណ៍ម្នាក់ ហើយរូបខ្លះទៀតទៅឆាន់ក្នុងទីដទៃ ឬទៅទទួលបិណ្ឌបាតទៀត ព្រាហ្មណ៍ ក៏តិះ

---

[២១] ការឆាន់អាហារជាគណៈ ក្នុងទីនេះ សំដៅយកភិក្ខុ ៤ រូបឡើងទៅ ។

[២២] ធ្វើឲ្យម្ចាស់ផ្ទះធ្លាក់ទឹកចិត្តថា គេឲ្យឆាន់មិនឆ្អែត ឬយ៉ាងណា ?

ដៀល និងសំដែងការតូចចិត្ត ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុឆាន់រួចរាល់ហើយប្រាប់ថា មិនទទួលអាហារដែលគេថែមឱ្យ រួចទៅទំពា ឬឆាន់របស់ទំពា និងរបស់ឆាន់ ត្រូវជាចិត្តិយ,*** *ក្រោយមក ទ្រង់អនុញ្ញាតឆាន់សំណល់អាហារបាន ។*

## សិក្ខាបទទី ៦

### (ហាមថាឱ្យភិក្ខុដែលឆាន់ម្តងជាពីរដងដើម្បីចាប់កំហុស)

*ភិក្ខុមួយរូបដឹងថា ភិក្ខុមួយរូបទៀត ឆាន់ក្នុងទីនិមន្តរួចហើយ ក្លែងសងគំនុំក៏បានឲ្យលោកឆាន់អាហារថែមទៀត ដើម្បីចាប់កំហុសលោក (តាមសិក្ខាបទទី ៥) ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តដូចនោះ។***

## សិក្ខាបទទី ៧

### (ហាមឆាន់អាហារក្នុងវេលាវិកាល)

*ភិក្ខុមានគ្នា ១៧ រូប ឆាន់អាហារក្នុងវេលាវិកាល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុឆាន់អាហារក្នុងវេលាវិកាល (ចាប់ពីថ្ងៃត្រង់រហូតដល់អរុណរះ)។***

## សិក្ខាបទទី ៨

### (ហាមឆាន់អាហារទុករំលងរាត្រី)

*ភិក្ខុវេឡដ្ឋសីសៈ សំដិលអាហារទុកឆាន់ក្នុងថ្ងៃដទៃ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុឆាន់អាហារទុករំលងរាត្រី។***

## សិក្ខាបទទី ៩

### (ហាមសុំអាហារប្រណីតឆាន់ខ្លួនឯង)

*ភិក្ខុឆព្វគ្គិយ សុំអាហារប្រណីត គឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ មកឆាន់ខ្លួនឯង គួរជាទីតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុប្រព្រឹត្តដូចនោះ វៀរលែងតែមានអាពាធ។***

## សិក្ខាបទទី ១០

### (ហាមឆាន់អាហារមិនបានប្រគេន)

*ភិក្ខុមួយរូប មិនចូលចិត្តអាហារដែលមានមនុស្សប្រគេន*

ទើបទៅកាន់យកគ្រឿងសំណែន ដែលគេបោះចោលតាមព្រៃស្មសានខ្លះ តាមដើមឈើខ្លះ តាមក្បាលដណ្ដើរខ្លះ មកឆាន់ គួរជាទីរង្កៀសរបស់មនុស្សទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុឆាន់អាហារដែលគេពុំបានប្រគេន វៀរលែងតែទឹក និងឈើចាក់ធ្មេញ។***

**៥. អចេលកវគ្គ** *គឺវគ្គពោលអំពីអ្នកបួសអាក្រាតកាយ ជាវគ្គទី ៥ មាន ១០ សិក្ខាបទ គឺ*

## សិក្ខាបទទី ១

## (ហាមហុច[២៣] អាហារដល់អ្នកបួសអាក្រាត ឬអ្នកបួសដទៃទៀត)

*នំកើតឡើងដល់សង្ឃ (សល់ពោរពាស) ទើបព្រះមានព្រះភាគទ្រង់ប្រទានដល់ព្រះអានន្ទចែកជាទានដល់មនុស្សកំសត់ទុគ៌ត លោកក៏បានយកទៅចែកដល់ពពួកមនុស្សទាំងនោះ មានអ្នកបួសក្រៅសាសនាជាស្ត្រីមកទទួលយកចំណែកចែកនោះដែរ គាប់ជួនឲ្យលើសទៅមួយចំណែកដល់អ្នកបួសស្ត្រីរូបនោះ ដោយពួកគេមានការយល់ខុស ទើបនាំគ្នានិយាយចំអន់ថា ព្រះអានន្ទទាក់ទង (មានអីៗ) ជាមួយស្ត្រីនោះ ក៏ស្រាប់តែមានភិក្ខុមួយរូប ឆាន់រួចរាល់ហើយយកបាយលាយទឹកដោះថ្លាទៅឲ្យស្ត្រីអាជីវកមួយរូបដែរ ។ មានគេឃើញហើយនិយាយថា ពុំសមគួរនឹងធ្វើដូច្នោះ (ពីព្រោះការហុចឲ្យដោយដៃ ប្រៀបបីដូចជាសិស្ស ឬគ្រហស្ថប្រគេនដល់ភិក្ខុ និងហាក់ដូចដាក់ខ្លួនឯងជាគ្រហស្ថអីចឹងដែរ) ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមឱ្យអាហារដល់អ្នកបួសអាក្រាត បរិព្វាជក បរិព្វាជិកា ដោយដៃរបស់ខ្លួនផ្ទាល់ ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តល្មើស។***

## សិក្ខាបទទី ២

## (ហាមបបួលភិក្ខុទៅបិណ្ឌបាតជាមួយហើយដេញមកវិញ)

*ភិក្ខុឧបនន្ទសក្យបុត្រ បបួលភិក្ខុមួយរូបទៅបិណ្ឌបាតជាមួយ បានភិក្ខាហើយបណ្ដេញលោកឲ្យត្រឡប់មកវិញ ទើបព្រះមានព្រះភាគ*

---

[២៣] *ដាក់ចុះហើយឲ្យ មិនត្រូវអាបត្តិ ។*

*ទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមធ្វើផ្លូវថ្ពោះ ទ្រង់ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុដែលប្រព្រឹត្តល្មើស។***

## សិក្ខាបទទី ៣

## (ហាមចូលទៅជ្រៀតជ្រែកដែលមានគ្នាតែពីរនាក់)[២៤]

*ព្រះឧបនន្ទសក្យបុត្រ ចូលទៅក្នុងត្រកូលដែលស្វាមីភរិយា កំពុងអន្ទុយជាមួយគ្នា បានភិក្ខាហើយ ស្វាមីក៏បណ្តេញលោកឲ្យត្រឡប់វិលវិញ តែត្រូវភរិយានិមន្តឲ្យគង់បន្ត ទើបលោកគង់នៅតទៅទៀត គេបណ្តេញដល់ទៅ ៣ ដង ក៏ពុំព្រមត្រឡប់ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមភិក្ខុចូលទៅកាន់ត្រកូលដែលមានស្វាមីភរិយានៅជាមួយគ្នា ទ្រង់ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៤

## (ហាមអង្គុយក្នុងទីកំបាំងជាមួយមាតុគ្រាម)

*ព្រះឧបនន្ទសក្យបុត្រ ទៅកាន់ផ្ទះសំឡាញ់ហើយអង្គុយក្នុងទីកំបាំងជាមួយភរិយារបស់សំឡាញ់នោះ គេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមអង្គុយក្នុងទីកំបាំង ជាមួយមាតុគ្រាម ទ្រង់ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៥

## (ហាមអង្គុយក្នុងទីកំបាំងត្រចៀកតែពីរនាក់មាតុគ្រាម)

*ព្រះឧបនន្ទសក្យបុត្រ ទៅកាន់ផ្ទះសំឡាញ់ហើយអង្គុយ ក្នុងទីកំបាំងត្រចៀកជាមួយភរិយារបស់សំឡាញ់នោះតែពីរនាក់ គេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមអង្គុយក្នុងទីកំបាំងត្រចៀកតែពីរនាក់មាតុគ្រាម ទ្រង់ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៦

## (ហាមទទួលនិមន្តហើយទៅកាន់ទីដទៃដោយពុំបានប្រាប់)

---

[២៤] *អ្នកប្រាជ្ញខ្លះយល់ផ្សេងថា ត្រកូលដែលគេកំពុងបរិភោគអាហាររួមគ្នា ។*

ព្រះឧបនន្ទសក្យបុត្រ ទទួលនិមន្តទៅឆាន់កន្លែងមួយ ហើយឆៀតទៅកាន់ត្រកូលដទៃទៀត ធ្វើឲ្យភិក្ខុដទៃ និងម្ចាស់ផ្ទះ ដែលបាននិមន្តរង់ចាំយូរ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ហាមធ្វើដូច្នោះ ។ ក្រោយមក មានហេតុកើតឡើងទើបទ្រង់បញ្ញត្តបន្ថែមទៀតជាច្រើនលើក សរុបសេចក្តីក្នុងសិក្ខាបទនេះថា ***ភិក្ខុទទួលនិមន្តហើយ មិនប្រាប់ភិក្ខុដទៃដែលមាននៅ (ក្នុងវត្ត) រួចទៅកាន់ត្រកូលដទៃ មុនពេលឆាន់ក្តី ក្រោយក្តី ត្រូវអាបត្តិបាចិត្តិយ វៀរតែមានសម័យ គឺសម័យប្រគេនចីវរ និងសម័យធ្វើចីវរ។***

## សិក្ខាបទទី ៧

### (ហាមសុំរបស់លើសពេលកំណត់ដែលគេអនុញ្ញាតទុក)

សក្យមហានាម បវារណានូវភេសជ្ជៈដល់ភិក្ខុសង្ឃ ៤ ខែ ហើយបវារណា ៤ ខែបន្តទៀត ចុងក្រោយគាត់បវារណាអស់មួយជីវិត ។ ភិក្ខុឆព្វគ្គិយ សុំទឹកដោះថ្លាក្នុងខណៈពេលដែលអ្នកបម្រើរបស់គាត់ទៅធ្វើការងារ សូម្បីគេឲ្យរង់ចាំក៏ពុំព្រម ត្រឡប់ជានិយាយថា បវារណារួចហើយម្តេចក៏មិនឲ្យ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុគ្មានអាពាធ គប្បីសុំបច្ច័យសម្រាប់ភិក្ខុអាពាធដែលគេបវារណា ៤ ខែបាន បើសុំលើសកំណត់នោះ ត្រូវបាចិត្តិយ វៀរលែងគេបវារណាជាថ្មីទៀត និងបវារណាអស់មួយជីវិត*** (គ្មានអាពាធ គឺសុំមិនបាន ក្រៅពីសុំពេលគ្មានរឿងចាំបាច់ ក៏មិនបាន) ។

## សិក្ខាបទទី ៨

### (ហាមទៅមើលកងទ័ពដែលគេលើកទៅ)

ភិក្ខុឆព្វគ្គិយ ទៅមើលកងទ័ពដែលគេលើកទៅ ព្រះបាទបសេនទិ ទ្រង់ទតឃើញហើយក៏ទទួលរាក់ទាក់លោក មនុស្សទាំងឡាយនាំគ្នាតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុទៅមើល កងទ័ពដែលគេលើកទៅ ត្រូវបាចិត្តិយ, ក្រោយមកទ្រង់អនុញ្ញាត ឱ្យទៅក្នុងកងទ័ពបានពេលមានហេតុសមគួរ។***

## សិក្ខាបទទី ៩

### (ហាមស្នាក់នៅក្នុងកងទ័ពលើស ៣ យប់)

ភិក្ខុឆព្វគ្គិយ មានហេតុចាំបាច់ទៅក្នុងកងទ័ពហើយស្នាក់នៅលើស ៣ យប់ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***កាលបើមានហេតុចាំបាច់ត្រូវទៅក្នុងកងទ័ព ភិក្ខុ***

*ស្នាក់នៅក្នុងកងទ័ពបានមិនលើស ៣ រាត្រី បើនៅលើសពីកំណត់នោះ ត្រូវបាចិត្តិយ។*

## សិក្ខាបទទី ១០

**(ហាមមើលគេច្បាំងគ្នាជាដើម នៅពេលទៅក្នុងកងទ័ព)**

*ភិក្ខុឆព្វគ្គិយ មានហេតុចាំបាច់ទៅស្នាក់ក្នុងកងទ័ព ២-៣ រាត្រី លោកបានមើលចម្បាំង ត្រួតពល រៀបចំទ័ព និងមើលទ័ពដែលចាត់ជាក្បួនហើយ ។ បណ្ដាភិក្ខុទាំង ៦ រូបនោះ មានភិក្ខុមួយរូប (ទៅមើលគេច្បាំងគ្នា) ត្រូវគ្រាប់ព្រួញ ជាទីគួរតិះដៀលរបស់មនុស្សទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមភិក្ខុដែលស្នាក់នៅក្នុងកងទ័ព ២-៣ រាត្រី ទៅមើលចម្បាំង ត្រួតពល រៀបចំទ័ព និងទ័ពដែលគេចាត់ជាក្បួនរួចរាល់ហើយ ទ្រង់ ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

**៦. សុរាបានវគ្គ** *គឺវគ្គពោលអំពីការផឹកសុរា ជាវគ្គទី ៦ មាន ១០ សិក្ខាបទ គឺ*

## សិក្ខាបទទី ១

**(ហាមផឹកសុរាមេរ័យ)**

*សាគតភិក្ខុ ទូន្មាននាគ (ពស់ធំ) របស់ពួកជដិលបាន អ្នកស្រុកចូលចិត្តហើយជំនុំគ្នាថា ប្រគេនអ្វីល្អ ភិក្ខុឆព្វគ្គិយណែនាំគេឲ្យប្រគេនស្រាដែលមានពណ៌ក្រហមដូចជើងព្រាប ទើបអ្នកស្រុកត្រៀមស្រាក្រហមប្រគេនសាគតភិក្ខុ លោកស្រវឹងសឹង (ដេក) នៅត្រង់ទ្វារក្រុង ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមផឹកសុរា (ស្រាដែលគេបិទ) និងមេរ័យ (ស្រាដែលគេអប់ ឬត្រាំ) ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ២

**(ហាមចាក់ពញាក់ភិក្ខុ)**

*ភិក្ខុឆព្វគ្គិយ យកម្រាមដៃចាក់ពញាក់សត្តរសគ្គិយភិក្ខុ (ភិក្ខុមានគ្នា ១៧) មួយរូប លោកភ្ញាក់ ក៏ដាច់ខ្យល់សុគត*

មួយរំពេច ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុចាក់ពញាក់ភិក្ខុផងគ្នា ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៣

### (ហាមហែលទឹកលេង)

*សត្តរសគ្គិយភិក្ខុ លេងទឹកក្នុងស្ទឹងអចិរវតី ព្រះបាទបសេនទិទ្រង់ប្រើខបាយផ្ញើនំទៅថ្វាយព្រះពុទ្ធដើម្បីឲ្យទ្រង់ជ្រាបថា ភិក្ខុទាំងនេះនាំគ្នាមកលេងទឹក ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ហាមភិក្ខុហែលទឹកលេង ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៤

### (ហាមសំដែងអាការៈមិនអើពើក្នុងវិន័យ)

*ឆន្នភិក្ខុប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយពោលទូន្មានអប់រំត្រឡប់ជាមិនអើពើ ហើយនៅតែចចេសរឹងរូសផ្ទើតទៅទៀត ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុមិនអើពើក្នុងវិន័យត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៥

### (ហាមបន្លាចភិក្ខុ)

*ភិក្ខុឆព្វគ្គិយ បន្លាចសត្តរសគ្គិយភិក្ខុឲ្យខ្លាចខ្មោច រហូតដល់ស្រែកយំ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុធ្វើភិក្ខុឲ្យខ្លាច[២៥] ត្រូវបាចិត្តិយ ។*

## សិក្ខាបទទី ៦

### (ហាមបង្កាត់ភ្លើងអាំង)

*ភិក្ខុទាំងឡាយ បង្កាត់ភ្លើងអាំងក្នុងរដូវរងា ពស់នៅក្នុងរូងក្តៅក៏ចេញមកដេញចឹកភិក្ខុទាំងនោះ ហើយនាំគ្នារត់ខ្ចាត់ខ្ចាយទៅ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុបង្កាត់ភ្លើងខ្លួនឯងក្តី ប្រើគេឱ្យបង្កាត់ក្តី ប្រយោជន៍ដើម្បីអាំង ត្រូវបាចិត្តិយ, ក្រោយមកទ្រង់អនុញ្ញាតឱ្យធ្វើបានសម្រាប់ភិក្ខុអាពាធ (អាំងភ្លើងដែលគេបង្កាត់ទុកហើយមិនខុសទេ)។***

---

[២៥] *ក្លែងនិយាយឲ្យខ្លាច ចោរ សត្វសាហាវ ខ្មោច សន្ត្រោះចូលក្នុងទីនេះទាំងអស់ ។*

## សិក្ខាបទទី ៧

### (ហាមងូតទឹកញឹកញាប់រៀរតែមានហេតុ)

ភិក្ខុទាំងឡាយងូតទឹកក្នុងស្ទឹងតបោទា ព្រះបាទពិម្ពិសារស្តេចយាងទៅស្រង់ព្រះកេសា ទ្រង់រង់ចាំភិក្ខុទាំងនោះងូតទឹករួចរហូតដល់យប់ ទើបព្រះអង្គបានស្រង់ព្រះកេសាហើយយាងត្រឡប់មកវិញមិនទាន់ ទ្វារក្រុងក៏បិទ ព្រះអង្គត្រូវសម្រាកព្រះកាយនៅក្រៅក្រុង ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទ ***ហាមភិក្ខុងូតទឹកមុនកំណត់កន្លះខែ ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។*** ក្រោយមក ទ្រង់អនុញ្ញាតងូតទឹកមុនកំណត់កន្លះខែបាន បើមានហេតុចាំបាច់ ដូចជាក្តៅខ្លាំង មានអាពាធ (ក្នុងបច្ចន្តប្រទេសដូច ជាស្រុកទេសក្តៅ មិនទាក់ទងនឹងសិក្ខាបទនេះទេ ពីព្រោះទ្រង់បញ្ញត្តសម្រាប់ប្រទេសភាគកណ្តាលនៃប្រទេសឥណ្ឌា ។

## សិក្ខាបទទី ៨

### (អនុញ្ញាតឱ្យធ្វើគ្រឿងសម្គាល់ស្បង់ចីវរ)

ភិក្ខុនិងបរិព្វាជក ធ្វើដំណើរពីក្រុងសាកេតមកកាន់ក្រុងសាវត្ថី ចោរប្លន់តាមផ្លូវ សមត្ថកិច្ចចាប់ចោរព្រមទាំងប្រមូលវត្ថុតាងបាន ទើបឲ្យភិក្ខុទៅរើសយកចីវររបស់ខ្លួនដែលចោរប្លន់ទៅ ភិក្ខុទាំងនោះចាំមិនបាន ដាទីគួរតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុបានចីវរថ្មីមក គប្បីកាន់យកគ្រឿងធ្វើឱ្យខូចពណ៌ណាមួយបណ្តាពណ៌ទាំង ៣ គឺ ពណ៌ខៀវ (ផ្ទៃមេឃក្រម៉ៅ) ពណ៌ភក់ (ដីស្អិត) និងពណ៌ខ្មៅ (មកធ្វើគ្រឿងសម្គាល់), បើពុំធ្វើដូច្នោះទេ ហើយប្រើប្រាសចីវរថ្មី ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៩

### (វិកប្បចីវរទុកហើយ មុននឹងប្រើ ត្រូវដកជាមុន)

ព្រះឧបនន្ទសក្យបុត្រ វិកប្បចីវរទុកនឹងភិក្ខុដទៃហើយនៅពុំទាន់បានដក ក៏ប្រើចីវរនោះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុវិកប្បចីវរទុកនឹងភិក្ខុ, ភិក្ខុនី, សិក្ខមានា, សាមណេរ***

*ឬសាមណេរីហើយ ប្រើប្រាស់ចីវរនោះទាំងពុំទាន់បានដកវិកប្ប ត្រូវបាចិត្តិយ*[២៦] ។

## សិក្ខាបទទី ១០

### (ហាមលេងលាក់បរិក្ខាររបស់ភិក្ខុដទៃ)

*ភិក្ខុឆព្វគ្គិយ លាក់បាត្រខ្លះ ចីវរខ្លះ របស់សត្តរសគ្គិយភិក្ខុ ដែលពុំធ្លាប់ទុកដាក់បរិក្ខារ (គ្រឿងប្រើប្រាស់) របស់ខ្លួនឲ្យរៀបរយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុលាក់បាត្រ ចីវរ បំពង់ម្ជុល វត្ថពន្ធចង្កេះ របស់ភិក្ខុ សូម្បីដើម្បីសើចលេង ត្រូវបាចិត្តិយ។***

**៧. សប្បាណកវគ្គ** *គឺវគ្គពោលអំពីសត្វមានជីវិត ជាវគ្គទី ៧ មាន ១០ សិក្ខាបទ គឺ*

## សិក្ខាបទទី ១

### (ហាមសម្លាប់សត្វ)

*ភិក្ខុឧទាយី រង្កៀសសត្វក្អែក ទើបបោលក្អែក កាត់ចំណែកក្បាល សៀតទុកលើលំពែង ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុតាំងចិត្តហើយសម្លាប់សត្វ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ២

### (ហាមប្រើប្រាស់ទឹកមានសត្វ)

*ភិក្ខុឆព្វគ្គិយដឹងហើយ នៅតែប្រើប្រាស់ទឹកមានសត្វ ជាទីគួរតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុដឹងហើយនៅតែប្រើប្រាស់ទឹកមានសត្វ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៣

### (ហាមសើរើអធិករណ៍ដែលជម្រះដោយធម៌ហើយ)

---

[២៦] ***វិកប្ប*** *គឺធ្វើឲ្យជាម្ចាស់ពីរ, បើសំពត់កើតឡើងច្រើនលើសចំនួនដែលទ្រង់អនុញ្ញាតឲ្យមាន ភិក្ខុត្រូវធ្វើឲ្យជាម្ចាស់ពីរជាមួយភិក្ខុ ភិក្ខុនីជាដើម វេលាប្រើត្រូវសុំអនុញ្ញាតចំពោះអ្នកដែលខ្លួនប្រគល់ឲ្យរួមម្ចាស់ជាមួយខ្លួនជាមុនសិន ។*

ភិក្ខុឆព្វគ្គិយដឹងហើយ នៅតែសើរើអធិករណ៍ដែលជម្រះត្រឹមត្រូវតាមធម៌ ដើម្បីឲ្យជម្រះសារជាថ្មី ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដឹងហើយនៅតែសើរើអធិករណ៍ដែលជម្រះត្រឹមត្រូវតាមធម៌ ដើម្បីឱ្យជម្រះសារជាថ្មី ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៤

### (ហាមបិទបាំងអាបត្តិគ្រោតគ្រាតរបស់ភិក្ខុដទៃ)

ព្រះឧបនន្ទសក្យបុត្រ ត្រូវអាបត្តិសង្ឃាទិសេសហើយប្រាប់ដល់ភិក្ខុឯទៀតឲ្យជួយលាក់បាំងផង ភិក្ខុនោះក៏ជួយលាក់បាំងលោក ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដឹងហើយ បិទបាំងអាបត្តិគ្រោតគ្រាតរបស់ភិក្ខុផងគ្នា ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៥

### (ហាមបំបួសបុគ្គលអាយុមិនគ្រប់ ២០)

ភិក្ខុទាំងឡាយ ឲ្យក្មេងៗ បព្វជ្ជាឧបសម្បទា ក្មេងៗ ទាំងនោះ ភ្ញាក់ឡើងយំទាររកអាហារស៊ីនាពាក់កណ្ដាលយប់ ពីព្រោះអត់ទ្រាំនឹងការស្រេកឃ្លានពុំបាន ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដឹងហើយ ឱ្យបុគ្គលមានអាយុតិចជាង ២០ ឧបសម្បទា បុគ្គលនោះមិនឈ្មោះថាបានឧបសម្បទាទេ ភិក្ខុទាំង-ឡាយ (ដែលអង្គុយជាបន្ទាល់) ត្រូវគួរដល់ការតិះដៀល និងក្នុងសេចក្ដីនោះ ភិក្ខុ (ដែលជាឧបជ្ឈាយ៍បំបួស) ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៦

### (ហាមបបួលពួកឈ្មួញលួចគេចពន្ធធ្វើដំណើររួមគ្នា)

ភិក្ខុមួយរូបដឹងហើយ បបួលពួកឈ្មួញដែលលួចគេចពន្ធ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដឹងហើយ បបួលពួកឈ្មួញលួចគេចពន្ធធ្វើដំណើរផ្លូវឆ្ងាយរួមគ្នា សូម្បីចន្លោះស្រុកមួយ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៧

### (ហាមបបួលមាតុគ្រាមធ្វើដំណើររួមគ្នា)

ភិក្ខុមួយរូបធ្វើដំណើរតាមកោសលជនបទ ឆ្ពោះទៅកាន់ក្រុងសាវត្ថី ទៅដល់ស្រុកមួយ មានស្ត្រីម្នាក់ឈ្លោះជាមួយស្វាមី សុំធ្វើដំណើរទៅជាមួយភិក្ខុនោះ ស្វាមីតាមប្រទូស្តវ៉ាយភិក្ខុនោះពីក្រោយ

ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា **ភិក្ខុបបួលមាតុគ្រាម ធ្វើដំណើរផ្លូវឆ្ងាយរួមគ្នា សូម្បីចន្លោះស្រុកមួយ ត្រូវបាចិត្តិយ។**

## សិក្ខាបទទី ៨

## (ហាមពោលបង្អាច់ព្រះធម៌វិន័យ)

អរិដ្ឋភិក្ខុ ធ្លាប់សម្លាប់សត្វត្មាតមកអំពីមុន មានការយល់ខុស ពោលបង្អាច់ធម៌វិន័យ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទដោយន័យថា **កាលបើមានភិក្ខុពោលបង្អាច់ធម៌វិន័យ ភិក្ខុដទៃគប្បីហាមប្រាម បើពុំព្រមស្តាប់ សង្ឃគប្បីសូត្រប្រកាស ដើម្បីឱ្យលោកលះបង់ សូត្រប្រកាសគ្រប់ ៣ ដងហើយ នៅតែមិនព្រមលះបង់ ត្រូវបាចិត្តិយ។**

## សិក្ខាបទទី ៩

## (ហាមគប់រកភិក្ខុពោលបង្អាច់ធម៌វិន័យ)

ភិក្ខុឆព្វគ្គិយ នៅតែគប់រកអរិដ្ឋភិក្ខុដែលពោលបង្អាច់ធម៌វិន័យ ជាបុគ្គលដែលពុំព្រមលះបង់ការយល់ខុសនោះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ហាមគប់រក ហាមដេកនៅរួមជាមួយភិក្ខុដូចនោះ ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។**

## សិក្ខាបទទី ១០

## (ហាមគប់រកសាមណេរដែលពោលបង្អាច់ធម៌វិន័យ)

សាមណេរឈ្មោះកណ្ដកៈ មានការយល់ខុសពោលបង្អាច់ធម៌វិន័យ ទើបសង្ឃបណ្ដេញចាកពួក ភិក្ខុឆព្វគ្គិយត្រឡប់ជាគប់រក និយាយរក បរិភោគរួម ដេករួមជាមួយសាមណេរនោះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ហាមនិយាយជាមួយ ហាមប្រើរបស់រួម**[២៧] **ឬដេករួមជាមួយសាមណេរដូចនោះ ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។**

**៨. សហធម្មិកវគ្គ** គឺវគ្គសំដែងអំពីការពោលប្រពៃតាមធម៌ជាវគ្គទី ៨ មាន ១២ សិក្ខាបទ គឺ

---

[២៧] សព្ទបាលីថា **សម្ភុញ្ជេយ្យ** មានពាក្យអធិប្បាយខាងចុងសិក្ខាបទថា ការប្រើអាមិសរួម ដូចជា ឲ្យអាមិស ឬទទួលរបស់យ៉ាងណាមួយ ការប្រើធម៌រួម ដូចជាសម្ដែងធម៌ ឬឲ្យសម្ដែងធម៌រួមគ្នាដោយបទ ដោយអក្ខរៈ ។

## សិក្ខាបទទី ១

### (ហាមនិយាយដោះសារនៅពេលធ្វើខុសហើយ)

ឆន្នភិក្ខុប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយពោលដាស់តឿន ត្រឡប់ជានិយាយថា សុំសួរភិក្ខុដែលឈ្លាសក្នុងវិន័យសិន ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុដែលភិក្ខុដទៃពោលដាស់តឿនត្រូវតាមធម៌ហើយ ត្រឡប់ជានិយាយបកថា នៅពុំទាន់បានសិក្សាក្នុងសិក្ខាបទនេះ រហូតដល់បានសួរភិក្ខុឈ្លាសក្នុងវិន័យសិន ត្រូវបាចិត្តិយ គឺភិក្ខុដែលមានការសិក្សាត្រូវដឹង ត្រូវស៊ើបសួរនិងសាកសួរ។***

## សិក្ខាបទទី ២

### (ហាមពោលតិះដៀលសិក្ខាបទ)

ភិក្ខុឆព្វគ្គិយ ក្លែងពោលតិះដៀលព្រះវិន័យថា សិក្ខាបទតូចៗ ស្រាលៗ គួរឲ្យមានការរំខាន និងរុកគួន ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ដោយន័យថា ***កាលបើសូត្រព្រះបាដិមោក្ខ ភិក្ខុក្លែងពោលតិះដៀលសិក្ខាបទ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៣

### (ហាមនិយាយកែខ្លួនថា ទើបតែដឹងថាមានក្នុងបាដិមោក្ខ)

ភិក្ខុឆព្វគ្គិយប្រព្រឹត្តអនាចារ នៅពេលស្តាប់បាដិមោក្ខថា ភិក្ខុមិនដឹងក៏ត្រូវអាបត្តិ ទើបនិយាយថា ទើបដឹងថា បទនេះមានក្នុងបាដិមោក្ខ (ទាំងដែលបានស្តាប់មកហើយជាច្រើនលើក ជាការនិយាយកែខ្លួន) ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលនិយាយកែខ្លួនដូចនោះ ជាការពិន័យអាបត្តិដល់ភិក្ខុ (ដែលនិយាយកែខ្លួនថា) ភ្លេចផងដែរ។***

## សិក្ខាបទទី ៤

### (ហាមប្រទូស្តវាយរាងកាយភិក្ខុ)

ភិក្ខុឆព្វគ្គិយ ក្រោធហើយប្រទូស្តវាយរាងកាយសត្តរសគ្គិយ-ភិក្ខុ ពួកលោកស្រែកយំ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខា-បទថា ***ភិក្ខុក្រោធខឹងហើយប្រទូស្តវាយភិក្ខុ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៥

(ហាមងាដៃប្រហារភិក្ខុ)

ភិក្ខុឆព្វគ្គិយ ក្រោធហើយងាដៃប្រហារសត្តរសគ្គិយភិក្ខុ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុក្រោធខឹង ងាដៃ (លើកដៃ) បំណងប្រហារភិក្ខុ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៦

(ហាមចោទភិក្ខុដោយអាបត្តិសង្ឃាទិសេសមិនមានមូល)

ភិក្ខុឆព្វគ្គិយ ក្លែងចោទភិក្ខុដោយអាបត្តិសង្ឃាទិសេសមិនមានមូល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ។***

## សិក្ខាបទទី ៧

(ហាមបង្កការរំខានដល់ភិក្ខុដទៃ)

ភិក្ខុឆព្វគ្គិយ ក្លែងនិយាយឲ្យសត្តរសគ្គិយភិក្ខុកន្លល់សង្ស័យថា កាលបួសអាយុគ្រប់ ២០ ឬមិនទាន់គ្រប់ហ្ន៎ បើដូច្នោះ គង់ពុំមែនជាភិក្ខុ ពួកលោកយំកន្ទក់កន្ទេញ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុក្លែងបង្កការរំខានដល់ភិក្ខុ ដោយគិតថាភាព មិនសប្បាយនឹងកើតមានដល់ភិក្ខុនោះ សូម្បីតែមួយភ្លែតគិតតែ រឿងនេះម្យ៉ាង ពុំមែនគិតរឿងដទៃ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៨

(ហាមលបស្តាប់រឿងភិក្ខុឈ្លោះគ្នា)

ភិក្ខុឆព្វគ្គិយឈ្លោះគ្នាជាមួយភិក្ខុទាំងឡាយ ហើយទៅលបស្តាប់រឿងថា ភិក្ខុទាំងឡាយនិយាយពីរឿងរបស់ខ្លួនដូចម្តេចខ្លះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***កាលបើភិក្ខុទាំងឡាយឈ្លោះប្រកែកគ្នា ភិក្ខុលបស្តាប់រឿងដោយបំណងចង់ដឹងថា ភិក្ខុទាំងនោះនិយាយដូចម្តេច គិតរឿងនេះតែម្យ៉ាង ពុំមែនគិតរឿងដទៃ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ៩

(ឱ្យឆន្ទៈហើយហាមនិយាយតិះដៀល)

ភិក្ខុឆព្វគ្គិយ ឲ្យឆន្ទៈក្នុងការប្រជុំធ្វើកម្មរបស់សង្ឃហើយ ត្រឡប់ជានិយាយតិះដៀលជាខាងក្រោយ ទើបព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុឱ្យឆន្ទៈ (គឺសេចក្តីពេញចិត្ត ឬការប្រគល់អំណាចឱ្យសង្ឃធ្វើកម្មបាន) ដើម្បីកម្មប្រកបដោយធម៌ ហើយត្រឡប់ជាតិះដៀលជាខាងក្រោយ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ១០

### (ខណៈកំពុងប្រជុំសង្ឃហាមក្រោកទៅដោយមិនឱ្យឆន្ទៈ)

សង្ឃកំពុងប្រជុំគ្នាធ្វើកម្ម ភិក្ខុឆព្វគ្គិយ ឲ្យឆន្ទៈដល់ភិក្ខុមួយរូប ដែលជាបក្ខពួករបស់ខ្លួនឲ្យចូលទៅប្រជុំជំនួស ក្រោយមកភិក្ខុរូបនោះ មិនពេញចិត្តក៏ស្ទុះក្រោកចេញពីទីប្រជុំសង្ឃទាំងពុំបានឲ្យឆន្ទៈ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុមិនឱ្យឆន្ទៈ ក្រោកចាកអាសនៈចៀសចេញទៅ ក្នុងពេលដែលពាក្យវិនិច្ឆ័យរបស់សង្ឃនៅមិនទាន់ចប់សព្វគ្រប់ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ១១

### (សង្ឃឱ្យចីវរដល់ភិក្ខុហើយហាមតិះដៀលជាខាងក្រោយ)

ចីវរកើតឡើងដល់សង្ឃៗ ប្រជុំគ្នាឲ្យដល់ ភិក្ខុទព្វមល្លបុត្រ ភិក្ខុឆព្វគ្គិយត្រឡប់ជានិយាយថា សង្ឃឲ្យចីវរព្រោះពេញចិត្តគ្នាឯង ភិក្ខុទាំងឡាយក៏តិះដៀលថា រួមប្រជុំគ្នាជាមួយសង្ឃហើយ ដូចម្តេចបែរជានិយាយតិះដៀលជាខាងក្រោយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ហាមធ្វើដូច្នោះ ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ១២

### (ហាមបង្អោនលាភសង្ឃមកជាបុគ្គល)

ភិក្ខុឆព្វគ្គិយដឹងថា គេត្រៀមរៀបចំចីវរទុកប្រគេនដល់សង្ឃ ទៅនិយាយឲ្យគេប្រគេនដល់ភិក្ខុ (ដែលជាបក្ខពួករបស់ខ្លួន) គេមិនព្រម លោកនិយាយទាល់តែបានគេប្រគេន ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុបង្អោនលាភដែលគេប្រគេនដល់សង្ឃ ទៅដើម្បីបុគ្គល ត្រូវបាចិត្តិយ។***

**៩. រតនវគ្គ** គឺវគ្គពោលអំពីស្រីកែវ (ព្រះរាជទេពី) ជាវគ្គទី ៩ មាន ១០ សិក្ខាបទ គឺ

## សិក្ខាបទទី ១

(ហាមចូលទៅក្នុងដំណាក់របស់ព្រះរាជា)

ព្រះបាទបសេនទិកោសល សុំឲ្យព្រះមានព្រះភាគបញ្ជូនភិក្ខុទៅសំដែងធម៌ដល់ព្រះអង្គ ទើបព្រះមានព្រះភាគទ្រង់បញ្ជូនព្រះអានន្ទទៅសំដែងជាប្រចាំ ។ ព្រឹកថ្ងៃមួយ ព្រះអានន្ទចូលទៅកាន់ដំណាក់របស់ព្រះបាទបសេនទិកោសល ព្រះនាងមល្លិកាក៏ប្រញាប់យាងចេញពីដំណាក់នោះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទដោយន័យថា ***ភិក្ខុពុំបានទទួលនិមន្តទុក ឈានកន្លងធរណីទ្វារ ចូលទៅ (ក្នុងក្រឡាព្រះបន្ទំ) របស់ព្រះរាជាដែលបានរាជាភិសេកហើយ កាលបើព្រះរាជា ពុំទាន់ស្ដេចយាងចេញ ព្រះមហេសីក៏នៅពុំទាន់យាងចេញ ត្រូវបាចិត្តិយ។***

## សិក្ខាបទទី ២

(ហាមរើសរបស់មានតម្លៃដែលធ្លាក់)

ភិក្ខុមួយរូប រើសថង់លុយរបស់ព្រាហ្មណ៍ម្នាក់ដោយបំណងល្អ កាលបើព្រាហ្មណ៍មកសួររក ក៏ហុចឲ្យទៅវិញ ព្រាហ្មណ៍ក្លែងពោលថា លុយក្នុងថង់របស់ខ្លួនមានច្រើនជាងនោះ (ដើម្បីមិនចាំបាច់ត្រូវសងសគុណ) ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ហាមរើសដោយខ្លួនឯង ឬប្រើឱ្យគេរើសនូវរតនៈ (លុយកាក់ប្រាក់មាស) ឬវត្ថុដែលសន្មតថាជារតនៈ ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។*** ក្រោយមក ទ្រង់ក៏បញ្ញត្តបន្ថែមថា របស់ធ្លាក់ក្នុងវត្ត ឬទីលំនៅ គួររើសដើម្បីទុកឲ្យម្ចាស់គេវិញ ឈ្មោះថា ជាការបដិបត្តិប្រពៃ ។

## សិក្ខាបទទី ៣

(ចូលស្រុកក្នុងវេលាវិកាលត្រូវប្រាប់ភិក្ខុជាមុន)

ភិក្ខុឆព្វគ្គិយ ចូលទៅកាន់ស្រុកក្នុងវេលាវិកាល (ថ្ងៃជ្រេហើយទៅ) បបួលអ្នកស្រុកនិយាយរឿងឥតប្រយោជន៍ គួរជាទីតិះដៀលនៃមនុស្សទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ហាមចូលទៅកាន់ស្រុកក្នុងវេលាវិកាល ទ្រង់ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុដែលប្រព្រឹត្តកន្លងល្មើស។*** ក្រោយមក ទ្រង់អនុញ្ញាត ឲ្យចូលទៅកាន់ស្រុកក្នុងវេលាវិកាលបាន នៅពេលបានប្រាប់ភិក្ខុដែលមាននៅក្នុងវត្ត ឬកាលបើមានកិច្ចប្រញាប់ ។

## សិក្ខាបទទី ៤

### (ហាមធ្វើបំពង់ម្ជុលដោយឆ្អឹង, ភ្លុក, ស្នែងសត្វ)

ជាងក្រឡឹងភ្លុកដំរី បវារណាភិក្ខុសុំបំពង់ម្ជុលបាន ភិក្ខុទាំង-ឡាយ ក៏ទៅសុំជារឿយៗ មានបំពង់តូចសុំបំពង់ធំ មានបំពង់ធំ សុំបំពង់តូច រហូតដល់ជាងខានធ្វើលក់ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុឱ្យគេធ្វើបំពង់ម្ជុល ដោយឆ្អឹង, ភ្លុកដំរី, ស្នែងសត្វ ត្រូវបាចិត្តិយ*** **(គឺត្រូវវាយកម្ទេចជាមុនសិន ទើបសំដែងអាបត្តិដាច់)។**

## សិក្ខាបទទី ៥

### (ហាមធ្វើគ្រែតាំងមានជើងខ្ពស់ជាងប្រមាណ)

ព្រះឧបនន្ទសក្យបុត្រ ដេកលើគ្រែខ្ពស់ ព្រះមានព្រះភាគស្តេចទតពីវិហារទៅឃើញ ទើបទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុធ្វើគ្រែ ឬតាំងថ្មី គប្បីធ្វើមានជើងត្រឹមប្រមាណ ៨ ធ្នាប់ ដោយធ្នាប់ព្រះសុគត វៀរមេគ្រែថ្នាក់ក្រោម បើធ្វើមានជើងលើសកំណត់នោះត្រូវបាចិត្តិយ*** (គឺត្រូវកាត់ចេញសិន ទើបសំដែងអាបត្តិដាច់) ។

## សិក្ខាបទទី ៦

### (ហាមធ្វើគ្រែតាំងញាត់ដោយគ)

ភិក្ខុឆព្វគ្គិយ ឲ្យគេធ្វើគ្រែខ្លះ តាំងខ្លះ ញាត់ដោយគ គួរជាទីតិះដៀលរបស់ភិក្ខុទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុឱ្យគេធ្វើគ្រែ ឬតាំងញាត់ដោយគ***[២៨] ***ត្រូវបាចិត្តិយ*** (គឺឲ្យរុះចេញសិន ទើបសំដែងអាបត្តិដាច់) ។

## សិក្ខាបទទី ៧

### (ហាមធ្វើកម្រាលអង្គុយលើសប្រមាណ)

ភិក្ខុឆព្វគ្គិយ ប្រើកម្រាលអង្គុយពុំមានប្រមាណ សំពត់ហៀរធ្លាក់ទៅខាងមុខខាងក្រោយនៃគ្រែនិងតាំង ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុធ្វើកម្រាលអង្គុយ គប្បីធ្វើឱ្យត្រូវប្រ-មាណ គឺបណ្តោយ ៣ ចង្អាម ទទឹង ១ ចង្អាមកន្លះ ដោយចង្អាមព្រះសុគត បើធ្វើឱ្យលើសប្រមាណនោះទៅ ត្រូវបាចិត្តិយ***

---

[២៨] ពាក្យថា គ សំដៅយកគ ឬសំឡីដែលយកពីដើមរុក្ខជាតិដែលនៅរស់ វល្លិ៍ និងស្មៅ, ក្នុងវិន័យអនុញ្ញាតឲ្យប្រើធ្វើខ្នើយបាន ។

*(គឺត្រូវកាត់ចេញ ទើបសំដែងអាបត្តិដាច់), ក្រោយមកទ្រង់អនុញ្ញាតជាយកម្រាលអង្គុយ ១ ចង្អាមទៀត។*

## សិក្ខាបទទី ៨

**(ហាមធ្វើសំពត់បិទបូសមានខ្នាតលើសប្រមាណ)**

ភិក្ខុឆព្វគ្គិយ ប្រើសំពត់បិទបូសពុំមានប្រមាណ ដើរទៅស្ទុយសំពត់ ទៅខាងមុខខ្លះ មកខាងក្រោយខ្លះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុធ្វើសំពត់បិទបូស គប្បីធ្វើឱ្យត្រូវប្រមាណ គឺបណ្តោយ ៤ ចង្អាម ទទឹង ២ ចង្អាម ដោយចង្អាមព្រះសុគត បើធ្វើលើសប្រមាណនោះ ត្រូវបាចិត្តិយ (គឺត្រូវកាត់ចេញសិន ទើបសំដែងអាបត្តិដាច់)។***

## សិក្ខាបទទី ៩

**(ហាមធ្វើសំពត់ងូតទឹកភ្លៀងមានខ្នាតលើសប្រមាណ)**

ភិក្ខុឆព្វគ្គិយ ប្រើសំពត់ងូតទឹកភ្លៀងពុំមានប្រមាណ ដើរទៅស្ទុយទៅខាងមុខខ្លះ មកខាងក្រោយខ្លះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុធ្វើសំពត់ងូតទឹកភ្លៀង គប្បីធ្វើឱ្យត្រូវប្រមាណ គឺបណ្តោយ ៦ ចង្អាម ទទឹង ២ ចង្អាមកន្លះ ដោយចង្អាមព្រះសុគត បើធ្វើឱ្យលើសប្រមាណនោះ ត្រូវបាចិត្តិយ*** (គឺត្រូវកាត់ចេញសិន ទើបសំដែងអាបត្តិដាច់) ។

## សិក្ខាបទទី ១០

**(ហាមធ្វើចីវរមានខ្នាតលើសប្រមាណ)**

ព្រះនន្ទដែលត្រូវជាពុទ្ធអនុជា ប្រើចីវរមានខ្នាតប៉ុននឹងចីវរព្រះសុគត ភិក្ខុទាំងឡាយក្រឡេកឃើញលោកដើរមកអំពីចម្ងាយក៏ក្រោកឡើងទទួល ដោយនឹកថា ព្រះមានព្រះភាគស្តេចយាងមក កាលបើចូលមកដល់ជិតយល់ថា ពុំមែន ក៏តិះដៀលថា ប្រើចីវរមានខ្នាតប៉ុននឹងព្រះសុគត ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុធ្វើចីវរមានខ្នាតប៉ុននឹងចីវរព្រះសុគត ឬធំជាង ត្រូវបាចិត្តិយ (គឺត្រូវកាត់ចេញសិន ទើបសំដែងអាបត្តិដាច់), ប្រមាណនៃចីវរព្រះសុគត គឺបណ្តោយ ៩ ចង្អាម ទទឹង ៦ ចង្អាម។***

# ៣.បាដិទេសនីយកណ្ឌ

**(ពោលអំពីអាបត្តិបាដិទេសនីយ មាន ៤ សិក្ខាបទ)**

## សិក្ខាបទទី ១

### (ហាមទទួលរបស់ទំពាររបស់ឆាន់អំពីដៃភិក្ខុនីមកឆាន់)

ភិក្ខុនីមួយរូប ត្រាច់ទៅបិណ្ឌបាត បានហើយត្រឡប់មកវិញ ឃើញភិក្ខុមួយរូប ទើបប្រគេនអាហារដែលបានមក ភិក្ខុនោះ ក៏ទទួលរហូតដល់អស់ ភិក្ខុនីក៏អត់អាហារ ពីព្រោះអស់ពេលដែលត្រូវចូលទៅបិណ្ឌទៀត លុះព្រឹកឡើងភិក្ខុនីនោះទៅបិណ្ឌបាត បានជួបភិក្ខុនោះម្តងទៀត ក៏ប្រគេនទៅលោកៗ ក៏ទទួលរហូតដល់អស់ ទើបភិក្ខុនីនោះអត់អាហារទៀត ក្នុងថ្ងៃទី ៣ ក៏ដូច្នោះទៀត រហូតដល់ថ្នាក់គេចចេញពីរថសេដ្ឋី ភិក្ខុនីនោះក៏អស់កម្លាំងដួលចុះ សេដ្ឋីសុំខមាទោស ដឹងរឿងហើយក៏តិះដៀលភិក្ខុនោះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុចូលទៅកាន់ចន្លោះស្រុក ទទួលរបស់ទំពា របស់ឆាន់អំពីដៃភិក្ខុនី មកទំពា ឬឆាន់ ត្រូវអាបត្តិបាដិ-ទេសនីយ។***

## សិក្ខាបទទី ២

### (ឱ្យដេញភិក្ខុនីដែលមកបញ្ចុះបញ្ចូលគេឱ្យប្រគេនអាហារ)

ភិក្ខុទាំងឡាយបានទទួលនិមន្តទៅឆាន់ក្នុងត្រកូល ឆព្វគ្គិយា-ភិក្ខុនី (ភិក្ខុនីមានគ្នា ៦ រូប) ដែលចូលចិត្តពួកភិក្ខុឆព្វគ្គិយបានឈរនៅក្បែរនោះផងដែរ ហើយក៏បានប្រាប់គេថា ចូរប្រគេនសម្លដល់ភិក្ខុរូបនេះ ចូរប្រគេនបាយដល់ភិក្ខុរូបនេះ ភិក្ខុឆព្វគ្គិយបានតាមតម្រូវការ ប៉ុន្តែភិក្ខុដទៃទៀត ឆាន់ទាំងដោយពុំសប្បាយចិត្ត ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុទាំងឡាយដែលបានទទួលនិមន្តទៅឆាន់ក្នុងត្រកូល បើភិក្ខុនីធ្លាប់ស្និតស្នាលមកឈរនៅក្បែរទីនោះ ប្រាប់គេថា ចូរប្រគេនសម្លដល់ភិក្ខុរូបនេះ ចូរប្រគេនបាយដល់ភិក្ខុរូបនេះ ភិក្ខុទាំងឡាយគប្បីដេញភិក្ខុនីនោះចេញ ដរាបដល់ភិក្ខុទាំងឡាយឆាន់រួច បើភិក្ខុរូបណាមិនបានដេញភិក្ខុនីនោះទេ ត្រូវអាបត្តិបាដិទេសនីយ។***

## សិក្ខាបទទី ៣

### (ហាមទទួលអាហារក្នុងត្រកូលដែលសង្ឃសន្មតថាជាសេក្ខៈ)

ក្នុងសម័យនោះ មានត្រកូលខ្លះជ្រះថ្លាទាំងស្វាមី និងភរិយា ជាត្រកូលចម្រើនដោយសទ្ធា (ជាត្រកូលអរិយបុគ្គល) តែឱ្យត់ទ្រព្យបុគ្គលទាំងនេះ តែងបរិច្ចាគរបស់ទំពា និងរបស់ឆាន់ដែលកើតឡើង

ទាំងអស់ដល់ភិក្ខុទាំងឡាយ ពេលខ្លះរហូតដល់ខ្លួនឯងអត់ក៏មាន ។ មនុស្សទាំងឡាយនាំគ្នាតិះដៀលពួកភិក្ខុថា ទទួលមិនដឹងប្រមាណ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យសង្ឃ សូត្រប្រកាសសន្មតត្រកូលនោះថា ជាត្រកូលសេក្ខៈ ហើយទ្រង់បញ្ញត្តសិក្ខាបទ ***ហាមចូលទៅទទួលរបស់ទំពា និងរបស់ឆាន់ក្នុងត្រកូលដែលសង្ឃសន្មតថា ជាសេក្ខៈដោយដៃរបស់ខ្លួនមកទំពា ឬឆាន់ ទ្រង់ពិន័យអាបត្តិបាដិទេសនីយដល់ភិក្ខុដែលប្រព្រឹត្តកន្លង។ ក្រោយមកទ្រង់អនុញ្ញាតថា បើគេនិមន្តទុកមុន ឬមានអាពាធ ចូលទៅសុំអាហារមកឆាន់បាន។***

## សិក្ខាបទទី ៤

### (ហាមទទួលអាហារដែលគេពុំបានរៀបចំទុកជាមុនពេលនៅព្រៃ)

ពួកសក្យៈដែលជាស្ត្រី នាំអាហារទៅដើម្បីទទួលទានក្នុងសេនាសនៈព្រៃ ត្រូវពួកទាសៈប្ចន់របស់របរ និងរំលោភ ពួកសក្យៈដែលជាបុរសចេញទៅចាប់ពួកនោះបាន តិះដៀលភិក្ខុទាំងឡាយថា មិនប្រាប់ថាមានចោរអាស្រ័យនៅក្នុងវត្ត ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនៅក្នុងសេនាសនៈស្ងាត់ ក្នុងព្រៃគួរខ្លាច ទទួលរបស់ទំពា របស់ឆាន់ ដែលគេពុំបានរៀបចំទុកជាមុន ដោយ ដៃរបស់ខ្លួនខាងក្នុងអារាមមកឆាន់ ត្រូវបាដិទេសនីយៈ, ក្រោយ មកទ្រង់អនុញ្ញាតសម្រាប់ភិក្ខុអាពាធ។***

## ៤.សេខិយកណ្ឌ

### (ពោលអំពីវត្ត និងចរិយាមារយាទដែលភិក្ខុត្រូវសិក្សា)

ដើមហេតុនៃការបញ្ញត្តិសិក្ខាបទគ្រប់ទាំង ៧៥ បទ ក្នុងសេខិយកណ្ឌនេះ បណ្ដាលមកពីភិក្ខុឆព្វគ្គិយប្រព្រឹត្តអំពើមិនស្អាតស្អំទាំងអស់ ក្នុងសិក្ខាបទមិនបានពិន័យអាបត្តិទុក គ្រាន់តែពោលថាភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងធ្វើយ៉ាងនោះយ៉ាងនេះ ឬមិនធ្វើយ៉ាងនោះយ៉ាងនេះ ប៉ុន្តែក្នុងពាក្យអធិប្បាយខាងចុងសិក្ខាបទបញ្ជាក់ថា បើធ្វើបំពានត្រូវអាបត្តិទុក្កដ (ប្រែថា ធ្វើអាក្រក់) ព្រមទាំងសំដែងលក្ខណៈមិនត្រូវអាបត្តិទុកផងដែរ ។ ក្នុងទីនេះ នឹងរៀបរាប់ចំពោះតែតួសិក្ខាបទប៉ុណ្ណោះ ឯវត្ថុបំណងដែលបញ្ញត្តសិក្ខាបទ ព្រមទាំងពាក្យអធិប្បាយខាងចុងសិក្ខាបទនោះ បទណាដែលគួរពោលទុកក៏ពោលទុកក្នុងវង្វង់ក្រចក ម្យ៉ាងទៀត កាលបើ

ចាត់ជាពួកធំៗ ទុកហើយ នៅចាត់ជាវគ្គទុកអមពួកធំៗ ទៀតដែរ ។ ក្នុងទីនេះ ទើបជ្រើសរើសសំដែងទុកតែពួកធំៗ ដើម្បីការពារភាពច្របូកច្របល់ ការរៀបចំជាវគ្គអាចងាយស្រួលក្នុងការសូត្រក៏បាន តែបច្ចុប្បន្នការសូត្របាដិមោក្ខរបស់ភិក្ខុ ពុំបានបញ្ជាក់វគ្គទុកទេ គ្រាន់តែចេញឈ្មោះពួកធំៗ ប៉ុណ្ណោះ ។

## (១) សារូប

**(ពួកពោលអំពីភាពសមរម្យដល់សមណភេទ)**

*មាន ២៦ សិក្ខាបទ*

**សិក្ខាបទទី ១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងស្លៀកស្បង់ ឲ្យជាបរិមណ្ឌល (ខាងក្រោមបិទជង្គង់ ខាងលើបិទផ្ចិត មិនស្រុយទៅខាងមុខ មកខាងក្រោយ) ។*

**សិក្ខាបទទី ២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងដណ្ដប់ចីវរ ឲ្យជាបរិមណ្ឌល (ឲ្យជាយសំពត់ស្មើគ្នា មិនស្រុយទៅខាងមុខ មកខាងក្រោយ) ។*

**សិក្ខាបទទី ៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងបិទបាំងកាយឲ្យល្អ ទៅក្នុងចន្លោះផ្ទះ (គឺមិនបើកកាយ ឬមិនសើយចីវរ) ។*

**សិក្ខាបទទី ៤** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងបិទបាំងកាយឲ្យល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ៥** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងសង្រួមឲ្យល្អ ទៅក្នុងចន្លោះផ្ទះ (គឺមិនឆ្កាដៃ ឆ្កាជើង) ។*

**សិក្ខាបទទី ៦** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងសង្រួមឲ្យល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ៧** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមានភ្នែកសំឡឹងចុះ ទៅក្នុងចន្លោះផ្ទះ (គឺមិនសម្លឹងទៅឯណោះ ឯណេះ ដូចជារកអ្វីមួយ) ។*

**សិក្ខាបទទី ៨** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមានភ្នែកសំឡឹងចុះ អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ៩** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសើយសំពត់ ទៅក្នុងចន្លោះផ្ទះ (គឺមិនលើកសំពត់ម្ខាង ឬទាំងសងខាងឡើងលើ) ។*

**សិក្ខាបទទី ១០** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសើយសំពត់ អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសើច ព្ចខ្លាំង ទៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសើច ព្ចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិននិយាយ ព្ចខ្លាំង ទៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១៤** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិននិយាយ ព្ចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១៥** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនគ្រវែង កាយ ទៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១៦** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនគ្រវែង កាយ អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១៧** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹង មិនបង់ប្រាយដៃ ទៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១៨** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹង មិនបង់ប្រាយដៃ អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ១៩** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនគ្រវី ដៃ ទៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ២០** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនគ្រវី ក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ២១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនយក ដៃច្រត់ចង្កេះ ទៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ២២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនយក ដៃច្រត់ចង្កេះ អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ២៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនយក សំពត់ទទូរក្បាល ទៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ២៤** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនយក សំពត់ទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ២៥** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនចំអើត ជើង ដើរទៅក្នុងចន្លោះផ្ទះ ។*

**សិក្ខាបទទី ២៦** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនអង្គុយ ត្របោមក្បាលជង្គង់ នៅក្នុងចន្លោះផ្ទះ ។*

## (២) ភោជនប្បដិសំយុត្ត

### (ពួកពោលអំពីការឆាន់អាហារ) មាន ៣០ សិក្ខាបទ

**សិក្ខាបទទី ១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាតដោយគោរព ។*

**សិក្ខាបទទី ២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងសំឡឹងមើលតែក្នុងបាត្រ ហើយទទួលបិណ្ឌបាត ។*

**សិក្ខាបទទី ៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាត ឲ្យល្មមគ្នានឹងសំឡ (មិនទទួលសំឡច្រើនជាងបាយ) ។*

**សិក្ខាបទទី ៤** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាតស្មើត្រឹមកណ្ដាប់មាត់បាត្រ ។*

**សិក្ខាបទទី ៥** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាតដោយគោរព ។*

**សិក្ខាបទទី ៦** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងសំឡឹងមើលតែក្នុងបាត្រ ហើយឆាន់បិណ្ឌបាត ។*

**សិក្ខាបទទី ៧** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាត ទៅតាមលំដាប់ (មិនចោះឲ្យខូង) ។*

**សិក្ខាបទទី ៨** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាតឲ្យល្មមសមគួរនឹងសំឡ (មិនឆាន់សំឡច្រើនជាងបាយ) ។*

**សិក្ខាបទទី ៩** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាតមិនជ្រើតែកំពូលបាយចុះទៅ ។*

**សិក្ខាបទទី ១០** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនយកបាយលុបសម្ល ដោយប្រាថ្នាចង់បានច្រើន ។*

**សិក្ខាបទទី ១១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញមិនមានជម្ងឺនឹងមិនសុំសំឡ ឬបាយ ដើម្បីប្រយោជន៍ដល់ខ្លួនមកឆាន់ ។*

**សិក្ខាបទទី ១២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំឡឹងមើលបាត្រភិក្ខុដទៃ ដោយគិតនឹងលើកទោស ។*

**សិក្ខាបទទី ១៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនធ្វើពំនូតបាយឲ្យធំពេក ។*

**សិក្ខាបទទី ១៤** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងធ្វើពំនូតបាយឲ្យមូល ។*

**សិក្ខាបទទី ១៥** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនហាមាត់ រង់ចាំពំនូតបាយ ។*

**សិក្ខាបទទី ១៦** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនយកដៃទាំងពីរដាក់ចូលទៅក្នុងមាត់ក្នុងខណៈនោះ ។*

**សិក្ខាបទទី ១៧** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិននិយាយ ទាំងពំនូតបាយនៅក្នុងមាត់ ។*

**សិក្ខាបទទី ១៨** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់បោះគ្រាប់បាយចូលទៅក្នុងមាត់ ។*

**សិក្ខាបទទី ១៩** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់កាត់ពំនូតបាយ ។*

**សិក្ខាបទទី ២០** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់ធ្វើមាត់ឲ្យប៉ោង ។*

**សិក្ខាបទទី ២១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់ឆ្កាដៃ ។*

**សិក្ខាបទទី ២២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់រោយគ្រាប់បាយ ។*

**សិក្ខាបទទី ២៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធមាត់ ។*

**សិក្ខាបទទី ២៤** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់ឲ្យឮផ្លុប់ៗ ។*

**សិក្ខាបទទី ២៥** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់ឲ្យឮគ្រូកៗ ។*

**សិក្ខាបទទី ២៦** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធដៃ ។*

**សិក្ខាបទទី ២៧** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធបាត្រ[២៩] ។*

**សិក្ខាបទទី ២៨** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធបបូរមាត់ ។*

**សិក្ខាបទទី ២៩** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនយកដៃប្រឡាក់ ចាប់កែវទឹកផឹក ។*

**សិក្ខាបទទី ៣០** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនយកទឹកលាងបាត្រមានគ្រាប់បាយ ចាក់ចោលក្នុងចន្លោះផ្ទះ ។*

---

[២៩] *បាត្រក្នុងសម័យនោះ មិនជ្រៅដូចបច្ចុប្បន្ននេះទេ សូម្បីភាជនៈដាក់របស់របរ ស្រដៀងចានចៀម ក៏ហៅថា បាត្រ ទើបលិទ្ធបាន ។*

## (៣) ធម្មប្បដិសំយុត្ត

### (ពួកពោលអំពីការសំដែងធម៌) មាន ១៦ សិក្ខាបទ

**សិក្ខាបទទី ១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺមានឆត្រក្នុងដៃ ។*

**សិក្ខាបទទី ២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺមានដំបងក្នុងដៃ ។*

**សិក្ខាបទទី ៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានសស្ត្រា (របស់មានមុខមុត) ក្នុងដៃ ។*

**សិក្ខាបទទី ៤** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺមានអាវុធ (របស់បាញ់ទៅ ឬបោលទៅបាន) ក្នុងដៃ ។*

**សិក្ខាបទទី ៥** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺពាក់ទ្រនាប់ជើង (ស្បែកជើងឈើ) ។*

**សិក្ខាបទទី ៦** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺពាក់ស្បែកជើង ។*

**សិក្ខាបទទី ៧** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺទៅដោយយាន ។*

**សិក្ខាបទទី ៨** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺនៅលើដំណេក ។*

**សិក្ខាបទទី ៩** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយត្របោមក្បាលជង្គង់ ។*

**សិក្ខាបទទី ១០** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺជួតក្បាល ។*

**សិក្ខាបទទី ១១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺទទូកក្បាល ។*

**សិក្ខាបទទី ១២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឈរលើផែនដី សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយលើអាសនៈ (សំពត់ ឬកម្រាល) ។*

**សិក្ខាបទទី ១៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនអង្គុយលើអាសនៈទាប សំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយលើអាសនៈខ្ពស់ ។*

**សិក្ខាបទទី ១៤** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនឈរសំដែងធម៌ដល់មនុស្សគ្មានជម្ងឺដែលអង្គុយ ។*

**សិក្ខាបទទី ១៥** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនដើរពីក្រោយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរពីខាងមុខ ។*

**សិក្ខាបទទី ១៦** *ភិក្ខុគប្បីសិក្សាថា អាត្មាអញនឹងមិនដើរក្រៅផ្លូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរក្នុងផ្លូវ ។*

## (៤) បកិណ្ណកៈ (ពួករាត់រាយ)

*មាន ៣ សិក្ខាបទ*

**សិក្ខាបទទី ១** *ភិក្ខុគប្បីសិក្សាថា អាត្មាអញគ្មានជម្ងឺនឹងមិនឈរបន្ទោបង់ឧច្ចារៈ (បត់ជើងតូច) ឬបស្សាវៈ (បត់ជើងធំ) ។*

**សិក្ខាបទទី ២** *ភិក្ខុគប្បីសិក្សាថា អាត្មាអញគ្មានជម្ងឺនឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះទឹកមាត់ លើរបស់ខៀវ (រុក្ខជាតិ មានស្មៅជាដើម) ។*

**សិក្ខាបទទី ៣** *ភិក្ខុគប្បីសិក្សាថា អាត្មាអញគ្មានជម្ងឺនឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះទឹកមាត់ដាក់ទឹក ។*

## ៥. ធម៌សម្រាប់រម្ងាប់អធិករណ៍ ៧ យ៉ាង

**១.សម្មុខាវិន័យ** *ការរម្ងាប់អធិករណ៍ ក្នុងទីចំពោះមុខ (បុគ្គល, វត្ថុ, ធម៌) ។*

**២.សតិវិន័យ** *ការរម្ងាប់អធិករណ៍ដោយលើកយកព្រះអរហន្តថាជាបុគ្គលមានសតិ ។*

**៣.អមូឡ្ហវិន័យ** *ការរម្ងាប់អធិករណ៍ ដោយលើកយកប្រយោជន៍ឲ្យក្នុងខណៈឆ្កួត ។*

**៤.បដិញ្ញាតករណៈ** *ការរម្ងាប់អធិករណ៍ដោយកាន់យកតាមពាក្យចុងចោទ ។*

**៥.យេភុយ្យសិកា** *ការរម្ងាប់អធិករណ៍ដោយកាន់យកសំឡេងខាងច្រើនជាប្រមាណ ។*

**៦.តស្សបាបិយសិកា** *ការរម្ងាប់អធិករណ៍ដោយការដាក់ទោសដល់បុគ្គលដែលប្រព្រឹត្តខុស ។*

**៧.តិណវត្ថារកៈ** *ការរម្ងាប់អធិករណ៍ដោយលួងលោម ឬបំភ្លេចចោល ។*

## ភាគទី ៥

## ភិក្ខុនីវិភង្គ (ជាវិនយបិដក)

ក្នុងភាគទី ១-២-៣ និងទី ៤ នៃវិនយបិដក ដែលសង្ខេបមកហើយនោះ ពោលអំពីសីលរបស់ភិក្ខុ គឺមាន ២២៧ សិក្ខាបទ ដែលត្រូវសូត្រក្នុងទីប្រជុំសង្ឃរៀងរាល់កន្លះខែម្តង ។ ឥឡូវនេះ ទើបមកដល់វិនយបិដកភាគទី ៥ ដែលមានឈ្មោះថា ភិក្ខុនីវិភង្គ ប្រែថា ចែកសិក្ខាបទដែលទាក់ទងនឹងភិក្ខុនី [៣០] និយាយឲ្យងាយស្តាប់ គឺសំដែងដល់សីល ៣១១ សិក្ខាបទរបស់ភិក្ខុនី ដែលត្រូវសូត្រក្នុងទីប្រជុំភិក្ខុនីសង្ឃរៀងរាល់កន្លះខែម្តងជាមួយភិក្ខុសង្ឃ ។

ក្នុងសីល ៣១១ របស់ភិក្ខុនីនោះ ដែលជាសិក្ខាបទរបស់ភិក្ខុនីពិតៗ នោះ មានត្រឹមតែ ១៣០ សិក្ខាបទ ឯចំណែក ១៨១ សិក្ខាបទទៀត នាំមកអំពីសីល ២២៧ របស់ភិក្ខុ ។ ហេតុដែលនាំយកមក ១៨១ សិក្ខាបទនោះ ពីព្រោះជ្រើសរើសយកតែសិក្ខាបទណា ដែលប្រើចូលគ្នាបាន (មាន) ទាំងភិក្ខុ និងភិក្ខុនី ឯសិក្ខាបទណា ដែលជារបស់ភិក្ខុពិតៗ នោះ ពុំបាននាំយកមកប្រើសម្រាប់ភិក្ខុនីទេ ។

បាលីវិនយបិដកភាគទី ៥ ដែលឈ្មោះថា ភិក្ខុនីវិភង្គនេះ ចែកចេញជាមេធំៗ ៧ គឺ

**១.បារាជិកកណ្ឌ** ពោលអំពីអាបត្តិបារាជិក គឺអាបត្តិដែលត្រូវហើយធ្វើឲ្យដាច់ចាកភាវៈជាភិក្ខុនី អាបត្តិបារាជិករបស់ភិក្ខុនីមាន ៨ តែសំដែងទុកក្នុងទីនេះត្រឹមតែ ៤ ឯចំណែក ៤ សិក្ខាបទទៀត អនុលោមតាមសិក្ខាបទរបស់ភិក្ខុ ។

**២.សត្តរសកណ្ឌ** ពោលអំពីអាបត្តិសង្ឃាទិសេស ១៧ សិក្ខាបទ (សត្តរស ប្រែថា ១៧) អាបត្តិសង្ឃាទិសេសនោះ ត្រូវហើយ ត្រូវនៅប្រព្រឹត្តមានត្ត ១៥ ថ្ងៃ (គឺ ១ បក្ខ) ក្នុងសង្ឃពីរចំណែក គឺទាំងភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ពោលដោយងាយៗ គឺត្រូវប្រគល់ខ្លួនដល់សង្ឃទាំងពីរចំណែក និងក្នុងកំឡុងពេល ១៥ ថ្ងៃ នោះ ត្រូវអស់សិទ្ធិច្រើនយ៉ាង ។ អាបត្តិសង្ឃាទិសេស សម្រាប់ភិក្ខុមាន ១៣ សិក្ខាបទ ប្រើដល់ភិក្ខុនីបានត្រឹមតែ ៧ សិក្ខាបទ ជារបស់ភិក្ខុនីពិតៗ ដែលសំដែងទុកក្នុងវិនយបិដកភាគ ទី ៥ នេះ មានត្រឹមតែ ១០ សិក្ខាបទ ។

---

[៣០] ពាក្យថា ***ភិក្ខុនី*** ជាភាសាបាលី ឯ ***ភិក្សុនី*** ជាភាសាសំស្ក្រឹត ។

**៣.និស្សគ្គិយកណ្ឌ** *ពោលអំពីអាបត្តិបាចិត្តិយ*[៣១] *ដែលត្រូវលះវត្ថុ ហៅពេញថា អាបត្តិនិស្សគ្គិយបាចិត្តិយ មាន ៣០ សិក្ខាបទស្មើនឹងសិក្ខាបទរបស់ភិក្ខុដែរ តែនាំសិក្ខាបទភិក្ខុមកប្រើត្រឹមតែ ១៨ សិក្ខាបទ ឯចំណែក ១២ សិក្ខាបទទៀតដែលសំដែងទុកក្នុងទីនេះ ជារបស់ភិក្ខុនីដោយត្រង់ ។*

**៤.បាចិត្តិយកណ្ឌ** *ពោលអំពីអាបត្តិបាចិត្តិយតាមប្រក្រតីដែលពុំចាំបាច់លះវត្ថុ សរុបមាន ១៦៦ សិក្ខាបទ ក្នុងចំនួនដែលសំដែងទុកក្នុងទីនេះ ដែលជារបស់ភិក្ខុនីដោយត្រង់មានត្រឹមតែ ៩៦ សិក្ខាបទ នាំរបស់ភិក្ខុមកប្រើ ៧០ សិក្ខាបទ, អាបត្តិបាចិត្តិយរបស់ភិក្ខុមាន ៩២ សិក្ខាបទ ។*

**៥.បាដិទេសនីយកណ្ឌ** *ពោលអំពីអាបត្តិបាដិទេសនីយៈ គឺអាបត្តិដែលគួរសំដែងចេញ សរុបមាន ៧ សិក្ខាបទ គឺមិនលាយជាមួយអាបត្តិបាដិទេសនីយៈ ៤ សិក្ខាបទរបស់ភិក្ខុឡើយ ចំណុចដែលគួរសង្កេត គឺអាបត្តិរបស់ភិក្ខុនីទាក់ទងនឹងការសុំរបស់បរិភោគទាំង ៨ សិក្ខាបទ ។*

[៣១] **អាបត្តិបាចិត្តិយ** *ប្រែថា ការប្រព្រឹត្តកន្លងដែលញុំាងកុសល គឺអំពើល្អ ឲ្យធ្លាក់ចុះ ។*

**៦.សេខិយកណ្ឌ** *ពោលអំពីបែបបទមារយាទដែលត្រូវសិក្សាសរុបមាន ៧៥ សិក្ខាបទ គឺនាំរបស់ភិក្ខុមកប្រើទាំងអស់ គ្រាន់តែក្នុងទីនេះ ពុំបានសំដែងរឿងរ៉ាវដែលកើតឡើងទាក់ទងនឹងការស្លៀកដណ្តប់ ការបន្ទោបង់ខច្ចារបស្សាវៈ និងការស្តោះទឹកមាត់ដាក់ទឹកទេ ពីព្រោះមានហាមនៅក្នុងសេខិយវត្តទាំង ៧៥ របស់ភិក្ខុរួចហើយ ។*

**៧.អធិករណសមថៈ** *វិធីរម្ងាប់អធិករណ៍មានត្រឹមតែ ៧ យ៉ាង ដូចភិក្ខុដែរ ។*

## ពណ៌នាសេចក្តី

# ១.បារាជិកកណ្ឌ

**(ពោលអំពីអាបត្តិបារាជិក ៨ សិក្ខាបទ)**

## សិក្ខាបទទី ១

**(ហាមត្រេកត្រអាលនូវការប៉ះពាល់បុរស)**

មានរឿងរ៉ាវថា ភិក្ខុនីឈ្មោះសុន្ទរីនន្ទា មានតម្រេកក្នុងការប៉ះពាល់កាយចៅប្រុស របស់នាងវិសាខា ឈ្មោះថា សាឡ្ហៈ ដំណើងនេះជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទ ដោយន័យថាៈ

***ភិក្ខុនីត្រេកត្រអាលក្នុងការប៉ះពាល់ ស្ទាប អង្អែល ច្របាច់ របស់បុរសដែលមានតម្រេក ខាងលើចាប់ពីត្រឹមឆ្អឹងដងកាំបិតចុះទៅ ខាងក្រោមតាំងពីត្រឹមជង្គង់ឡើងមក ត្រូវអាបត្តិបារាជិក។***

## សិក្ខាបទទី ២

## (ហាមបិទបាំងអាបត្តិបារាជិករបស់ភិក្ខុនីដទៃ)

ភិក្ខុនីថុល្លនន្ទាដឹងថា ភិក្ខុនីសុន្ទរីនន្ទាមានគភ៌ជាមួយសាឡ្ហៈមាណព ក៏ពុំបានប្រាប់ឲ្យដឹង ។ ភិក្ខុនីសុន្ទរីនន្ទាលាក់បាំង ការមានគភ៌របស់ខ្លួន រហូតដល់គភ៌ចាស់ទើបសឹក (លាចាកសិក្ខាបទ) ទៅយកចេញ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ដោយន័យថាៈ

***ភិក្ខុនីដឹងថា ភិក្ខុនីដទៃត្រូវអាបត្តិបារាជិក មិនចោទដោយខ្លួនឯង និងមិនប្រាប់ដល់ពួកគណៈ ត្រូវអាបត្តិបារាជិក។***

## សិក្ខាបទទី ៣

## (ហាមចូលជាមួយពួកភិក្ខុដែលសង្ឃបណ្តេញចេញពីពួក)

ភិក្ខុនីថុល្លនន្ទាប្រព្រឹត្តតាមភិក្ខុឈ្មោះអរិដ្ឋៈ ដែលជាបុគ្គលប្រព្រឹត្តអាក្រក់[៣៧] ទើបសង្ឃសូត្រប្រកាសបណ្តេញចេញពីពួក (មិនឲ្យបរិភោគ ឬដេករួម) ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ដោយន័យថាៈ

***ភិក្ខុនីប្រព្រឹត្តតាមភិក្ខុដែលសង្ឃសូត្រប្រកាស បណ្តេញចេញពីពួកហើយ ជាបុគ្គលមិនអើពើ មិនធ្វើតប មិនព្រមធ្វើខ្លួនឱ្យជាសហធម្មិក និងតាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា។ ភិក្ខុនីនោះ គឺសង្ឃគប្បីដាស់តឿន កាលបើមិនព្រមស្តាប់តាម ទើបសូត្រប្រកាសដាស់តឿន បើសូត្រប្រកាសគ្រប់ ៣ ដងហើយ នៅតែពុំព្រមលះបង់ ត្រូវអាបត្តិបារាជិក។***

---

[៣៧] ភិក្ខុ ឬភិក្ខុនីដែលពុំឃើញអាបត្តិ មិនធ្វើតបអាបត្តិ ត្រូវដាក់ទោស ដែលហៅថា ឧក្ខេបនីយកម្ម គឺការប្រកាសមិនឲ្យបរិភោគរួម មិនឲ្យចូលពួក, កាលបើប្រព្រឹត្តល្អហើយ ទើបដកប្រកាសនោះចេញ ។

## សិក្ខាបទទី ៤

### (ហាមទាក់ទងមានណាត់ជួបជាដើមជាមួយបុរស)

ឆព្វគ្គិយាភិក្ខុនី (ភិក្ខុនីមានគ្នា ៦ រូប) ប្រព្រឹត្តខ្លួនពុំសមគួរ មានតម្រេកក្នុងការចាប់ដៃខ្លះ ចាប់ជាយសង្ឃាដីខ្លះ របស់បុរសឈរជាមួយបុរសខ្លះ និយាយចរចាជាមួយខ្លះ មានការណាត់ខ្លះ ត្រេកអរ ការមករបស់បុរសតាមការណាត់ខ្លះ ចូលទៅកាន់ទីបិទបាំងជាមួយគ្នាខ្លះ អាក្រាតកាយឲ្យគេដើម្បីសេពអសទ្ធម្មខ្លះ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបារាជិកដល់ ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។***

(កត់សម្គាល់: បារាជិក ៤ សិក្ខាបទទៀត គឺចាប់ពីទី ៥ ដល់ទី ៨ អនុលោមតាមសិក្ខាបទរបស់ភិក្ខុដែរ) ។

## ២.សត្តរសកណ្ឌ

### (ពោលអំពីអាបត្តិសង្ឃាទិសេស ១៧ សិក្ខាបទ)

## សិក្ខាបទទី ១

### (ហាមបង្ករឿងក្តីក្នុងតុលាការជាមួយគ្រហស្ថនិងអ្នកបួស)

ភិក្ខុនីថុល្លនន្ទា មានរឿងជាមួយបុរសម្នាក់ក្នុងរឿងបន្ទប់ដាក់របស់របរ ដែលបិតារបស់បុរសនោះប្រគេនជារបស់ភិក្ខុនីសង្ឃ តែនៅពេលបិតាស្លាប់ បុរសនោះក៏ជញ្ជូនយករបស់របរចេញពីបន្ទប់នោះ តុលាការសម្រេចឲ្យភិក្ខុនីថុល្លនន្ទាឈ្នះ ។ បុរសនោះចោទថានាងនិយាយមួលបង្កាច់ និយាយបំផ្លើស តុលាការបានដាក់ទោសបុរសនោះ ។ បុរសនោះ ក៏ទៅសាងសង់ទីលំនៅឲ្យពួកអាជីវកហើយឲ្យពួកអាជីវកមកជេរប្រទេចនាងៗ ក៏ប្តឹងឲ្យតុលាការដាក់គុកបុរសនោះ ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទដោយន័យថា:

***ភិក្ខុនីប្តឹងផ្តល់រឿងក្តីជាមួយគហបតី[៣៣] បុត្រគហបតី ទាស-កម្មករ ឬដោយហោចទៅ សូម្បីជាមួយសមណៈ ត្រូវអាបត្តិសង្ឃាទិសេស។***

## សិក្ខាបទទី ២

### (ហាមបំបួសស្ត្រីជាចោរ)

---

[៣៣] ***គហបតី*** ប្រែថា អ្នកគ្រប់គ្រងផ្ទះ ឬម្ចាស់ផ្ទះ ។

*ជាយារបស់ស្ដេចលិច្ឆវីមួយរូប ក្បត់ចិត្តស្វាមីៗ តាមសម្លាប់ ទើបរត់គេចទៅ ព្រមទាំងលួចយករបស់មានតម្លៃទៅជាមួយផង នាងបានទៅសុំបួសក្នុងលទ្ធិដទៃ ក៏មិនមាននរណាបំបួសឲ្យ ប៉ុន្តែភិក្ខុនីថុល្លនន្ទា សំឡឹងឃើញដល់របស់ជំនូន ក៏ព្រមបំបួសឲ្យស្វាមីតាមមកទាន់ដល់ក្រុងសាវត្ថី ប្ដឹងដល់ព្រះបាទបសេនទិសុំឲ្យផ្សឹកនាង ព្រះបាទបសេនទិពុំព្រម ទ្រង់ព្រះតម្រិះថា បួសហើយ ក៏ហឺទៅចុះ ទើបស្វាមីរបស់នាងនោះ ពោលទោសតិះដៀលភិក្ខុនីថុល្លនន្ទា ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទដោយន័យថាៈ*

***ភិក្ខុនីដឹងហើយ ទទួលស្ត្រីជាចោរដែលមនុស្សទាំងឡាយដឹងថា មានទោសប្រហារ[៣៤] ឱ្យនៅ (គឺបំបួសឱ្យ[៣៥]) ដោយមិនប្រាប់ដល់ព្រះរាជា សង្ឃ គណៈ ត្រូវអាបត្តិសង្ឃាទិសេស វៀរលែងអ្នកដែលសមគួរ*** *(គឺបួសក្នុងលទ្ធិដទៃ ឬបួសក្នុងសំណាក់ភិក្ខុនីដទៃហើយ) ។*

---

*[៣៤] សម័យនោះ បុគ្គលណាលួចទ្រព្យចាប់ពី ១ បាទ គឺ ៥ មាសកៈឡើងទៅ ត្រូវប្រហារជីវិត ។*

*[៣៥] តាមសិក្ខាបទនេះ សម្ដែងថា ភិក្ខុនីត្រូវនៅក្នុងពួកគណៈ ទោះគេចខ្លួនទៅណា ឬសូម្បីដេកម្នាក់ឯង ដោយពុំមានភិក្ខុនីជាសម្លាញ់នៅជាមួយ ក៏ត្រូវអាបត្តិ ។*

## សិក្ខាបទទី ៣

## (ហាមចូលចន្លោះស្រុក ឆ្លងទឹក យាំងរាត្រីតែម្នាក់ឯង)

*មានច្រើនរឿងដែលភិក្ខុនីឆ្លងទឹក ដេកតែម្នាក់ឯង ដើរបែកក្រុមត្រូវគេចាប់រំលោភ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទដោយន័យថាៈ*

*ភិក្ខុនីតែម្នាក់ឯង ទៅកាន់ចន្លោះស្រុកក្តី ឆ្លងទឹកក្តី យាំងរាត្រីក្តី យឺតយ៉ាវបែកពីក្រុម (ក្នុងការធ្វើដំណើរ) ក្តី ត្រូវអាបត្តិសង្ឃាទិសេស[៣៦] ។*

## សិក្ខាបទទី ៤

## (ហាមសូត្រប្រកាសលើកទោសដោយពុំប្រាប់សង្ឃ)

*ភិក្ខុនីសង្ឃ សូត្រប្រកាសដាក់ទោសភិក្ខុនីមួយរូបដែលមិនឃើញអាបត្តិ ថុល្លនន្ទាភិក្ខុនីរកបក្សពួកមកសូត្រប្រកាសលើកទោស ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទដោយន័យថាៈ*

---

*[៣៦] តាមសិក្ខាបទនេះ សម្ដែងថា ភិក្ខុនីត្រូវនៅក្នុងពួកគណៈ គេចខ្លួនទៅណា ឬសូម្បីតែដេកម្នាក់ឯង ពុំមានភិក្ខុនីជាសម្លាញ់នៅជាមួយផង គោងត្រូវអាបត្តិ ។*

*ភិក្ខុនីមិនប្រាប់សង្ឃដែលធ្វើការ មិនដឹងឆន្ទៈ (ពុំបានទទួលការយល់ព្រម) របស់គណៈ លើកទោសភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នា បណ្តេញចេញពីពួកគណៈ តាមធម៌ តាមវិន័យ តាមសត្ថុសាសន៍ ត្រូវអាបត្តិសង្ឃាទិសេស។*

## សិក្ខាបទទី ៥

### (ហាមទទួលរបស់ទំពារបស់ឆាន់ពីដៃរបស់បុរស)

ភិក្ខុនីមួយរូប មានរូបរាងល្អស្អាត មនុស្សម្នាក៏នាំគ្នាចោមរោមប្រគេនអាហារល្អៗ កើតមានសំឡេងរិះគន់ឡើង ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ដោយន័យថាៈ

ភិក្ខុនីមានតម្រេក ទទួលរបស់ទំពារបស់ឆាន់អំពីដៃបុរសដែលមានតម្រេក ដោយដៃរបស់ខ្លួនមកទំពា ឬឆាន់ ត្រូវអាបត្តិសង្ឃាទិសេស ។

## សិក្ខាបទទី ៦

### (ហាមនិយាយទាក់ទាញចិត្តភិក្ខុនីឱ្យប្រព្រឹត្តធូរថយ)

សុន្ទរីនន្ទាភិក្ខុនីដែលមានរូបឆោមល្អស្អាត ឃើញមនុស្សគេនាំគ្នាប្រគេនអាហារល្អៗ ជាច្រើន និងដឹងថា មនុស្សទាំងនោះមានតម្រេក ទើបមិនទទួល ។ អនន្តរិកាភិក្ខុនីបែរជានិយាយទាញចិត្តថា ពួកគេត្រេកអរ ឬមិនត្រេកអរ ក៏ហើយចុះ គួរទទួលបាននាងមិនត្រេកអរទៅ លែងអីហើយ ។ រឿងនេះជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិសង្ឃាទិសេសដល់ភិក្ខុនីដែលនិយាយទាក់ទាញចិត្តឱ្យប្រព្រឹត្តធូរថយដូចនោះ។***

## សិក្ខាបទទី ៧

### (ហាមនិយាយមើលងាយភិក្ខុនីសង្ឃនៅពេលក្រោធខឹង)

ចណ្ឌកាឡីភិក្ខុនី ឈ្លោះជាមួយភិក្ខុនីរូបដទៃ មានសេចក្តីក្រោធខឹង និយាយថា ខ្ញុំសូមប្រាប់ដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃថា ពួកសមណីសក្យបុត្រនេះគ្មានអីអស្ចារ្យទេ ពួកសមណីល្អៗដទៃទៀតក៏មាន ខ្ញុំនឹងទៅប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសម្នាក់សមណីទាំងនោះ ។

ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ***ហាមពោលវាចាផ្តេសផ្តាសនៅពេលក្រោធ និងកាលបើពោលរួចហើយ ឱ្យភិក្ខុនីសង្ឃដាស់តឿន បើមិនព្រមស្តាប់តាម ទើបឱ្យសូត្រប្រកាសដាស់តឿន បើគ្រប់ ៣ ដងហើយនៅតែមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។***

## សិក្ខាបទទី ៨

### (ហាមតិះដៀលពេលដាក់ទោសត្រូវតាមធម៌ហើយ)

ចណ្ឌកាឡីភិក្ខុនី ត្រូវដាក់ទោសក្នុងរឿងអធិករណ៍មួយ ក្រោធខឹង ក៏និយាយរករឿងថា ភិក្ខុនីទាំងឡាយលុះក្នុងអគតិ ៤ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ***ហាមតិះដៀលដូចនោះ និងឱ្យភិក្ខុនីសង្ឃដាស់តឿន កាលបើមិនស្តាប់តាម ទើបសូត្រប្រកាសដាស់តឿន បើគ្រប់ ៣ ដងហើយនៅតែពុំលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។***

## សិក្ខាបទទី ៩

### (ហាមប្រមូលគ្នាប្រព្រឹត្តអាក្រក់)

ចណ្ឌកាឡីភិក្ខុនីជាកូនសិស្សរបស់ថុល្លនន្ទាភិក្ខុនី ប្រមូលគ្នាប្រព្រឹត្តអាក្រក់ មានឈ្មោះសំឡេងមិនល្អ បៀតបៀនភិក្ខុនីសង្ឃ បិទបាំងអំពើអាក្រក់គ្នាទៅវិញទៅមក ៗ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ***ហាមប្រព្រឹត្តដូចនោះ និងឱ្យភិក្ខុនីសង្ឃដាស់តឿន កាលបើមិនស្តាប់តាម ទើបសូត្រប្រកាសដាស់តឿន បើគ្រប់ ៣ ដងហើយនៅតែពុំលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។***

## សិក្ខាបទទី ១០

### (ហាមនិយាយញុះញង់ភិក្ខុនីដែលប្រព្រឹត្តខុស)

ថុល្លនន្ទាភិក្ខុនី និយាយជាមួយភិក្ខុនីទាំងឡាយដែលសង្ឃសូត្រប្រកាសដាស់តឿន (តាមសិក្ខាបទទី ៩) ថា ហៃនាងភិក្ខុនីទាំងឡាយ ពួកនាងចូររួបរួមគ្នា កុំបែកគ្នា ៗ សូម្បីពួកភិក្ខុនីដទៃដែលមានការប្រព្រឹត្តយ៉ាងនេះ មានឈ្មោះសម្លេងយ៉ាងនេះ បៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសគ្នាទៅវិញទៅមកក៏មាននៅក្នុងសង្ឃ តែសង្ឃក៏ពុំបានពោលអ្វីនឹងភិក្ខុនីទាំងនោះ ៗ សង្ឃពោលស្តីថា ពួកលោក ព្រោះមើលងាយ ព្រោះគម្រាម ព្រោះមិនពេញចិត្ត ព្រោះខ្សឹបខ្សៀវគ្នា និងព្រោះ(ពួកលោក) មានកម្លាំងតិច ៗ

ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ***ហាមភិក្ខុនីនិយាយរកភិក្ខុនី ដែលត្រូវសង្ឃស្វូត្រ ប្រកាសដាស់តឿនដូចនោះ បើមាននរណាចចេសធ្វើ ឱ្យភិក្ខុនីសង្ឃដាស់តឿន បើមិនស្ដាប់តាម ឱ្យស្វូត្រប្រកាសដាស់តឿន គ្រប់ ៣ ដង ហើយនៅតែពុំលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។***

*(កត់សម្គាល់ៈ សិក្ខាបទ ៧ ទៀតដែលពុំបានពោលទុក តែឲ្យប្រើសិក្ខាបទរបស់ភិក្ខុ គឺសិក្ខាបទទី ៥, ៨, ៩ និង ១០, ១១, ១២, ១៣ រួមមាន ៧ សិក្ខាបទ) ។*

## ៣.និស្សគ្គិយកណ្ឌ

### (ពោលអំពីអាបត្តិនិស្សគ្គិយបាចិត្តិយ ៣០ សិក្ខាបទ)

*ក្នុងទីនេះ មានត្រឹមតែ ១២ សិក្ខាបទ ឯ ១៨ សិក្ខាបទទៀតនាំមកអំពីសិក្ខាបទរបស់ភិក្ខុ ។*

**បត្តវគ្គ** (វគ្គពោលអំពីបាត្រ) (មាន ១០ សិក្ខាបទ)

## សិក្ខាបទទី ១

### (ហាមសន្សំបាត្រទុក)

*ភិក្ខុនីដែលមានគណៈតែមួយ ៦ រូប សន្សំបាត្រទុកយ៉ាងច្រើន ជាទីគួរតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីសន្សំបាត្រ ត្រូវនិស្សគ្គិយបាចិត្តិយ។*** *(បាត្រដែលបានឈ្មោះថាសន្សំ គឺសំដៅយកបាត្រក្រៅពីប្រើជាប្រចាំមួយចេញ និងក្រៅពីបាត្រដែលធ្វើវិកប្បចេញ ឬបានធ្វើឲ្យជាម្ចាស់ពីរគឺអនុញ្ញាតឲ្យអ្នកដទៃមានសិទ្ធិដែរ) ។*

## សិក្ខាបទទី ២

### (ហាមអធិដ្ឋានចីវរក្រៅកាល និងចែកចាយ)

*អ្នកស្រុកឃើញភិក្ខុនីមួយក្រុមមានចីវរចាស់ តែប្រព្រឹត្តសង្រួមល្អ ទើបជ្រះថ្លាប្រគេនចីវរក្រៅកាល ដល់ភិក្ខុនីសង្ឃ ។ ថុល្លនន្ទាភិក្ខុនីអាងថាខ្លួនបានក្រាលកឋិនរួចហើយ ទើបអធិដ្ឋានចីវរ*

ក្នុងកាល ឲ្យចែកចាយ (កាលបើដូច្នេះ ចីវរត្រូវធ្លាក់ជារបស់ថុល្លនន្ទាភិក្ខុនី ក្នុងឋានៈជាអ្នកមានវស្សាច្រើន) ។ ម្ចាស់ចីវរសួរភិក្ខុនីដែលខ្លួនប្រាថ្នាឲ្យបានទទួលចីវរ ដឹងថា ពុំបានទទួល ពីព្រោះថុល្លនន្ទាភិក្ខុនីធ្វើដូច្នោះ ទើបនាំគ្នាតិះដៀល ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ***ហាមអធិដ្ឋានចីវរក្រៅកាល ជាចីវរក្នុងកាល ហើយចែកចាយ ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តកន្លង។***

## សិក្ខាបទទី ៣

### (ហាមដណ្តើមយកចីវរវិញ ពេលប្តូរគ្នារួចហើយ)

ថុល្លនន្ទាភិក្ខុនី ដូរចីវរជាមួយភិក្ខុនីមួយរូបហើយ ក្រោយមកបបួលដូរគ្នាវិញ ព្រមទាំងដណ្តើមយកមកវិញ ទាំងដែលគេពុំទាន់បានយល់ព្រមអ្វីឡើយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុនី ដែលដណ្តើមយកដោយខ្លួនឯង ឬប្រើគេឱ្យដណ្តើមយក។***

## សិក្ខាបទទី ៤

### (ហាមសុំរបស់អ្វីមួយហើយសុំរបស់ដទៃទៀត)

ឧបាសកម្នាក់ សួរថុល្លនន្ទាភិក្ខុនីថា ត្រូវការអ្វី នាងឆ្លើយថា ត្រូវការទឹកដោះថ្លា ទើបគេទិញទឹកដោះថ្លាមកប្រគេន នាងត្រឡប់ជានិយាយថា មិនត្រូវការទឹកដោះថ្លាទេ តែចង់បានប្រេង ។ ទើបគេយកទឹកដោះថ្លាទៅប្តូរយកប្រេងមកជំនួស តែត្រូវអ្នកលក់ពុំព្រមដូរឲ្យ គេក៏តិះដៀលថុល្លនន្ទាភិក្ខុនី ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ហាមសុំរបស់មួយហើយទៅសុំរបស់ដទៃទៀត ទ្រង់ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយ ដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។***

## សិក្ខាបទទី ៥

### (ហាមបញ្ជាទិញរបស់ផ្លាស់ប្តូរ)

មានឧបាសកម្នាក់ យកប្រាក់ ១ កហាបណៈផ្ញើទុកនឹងអ្នកលក់ក្នុងផ្សារ ហើយប្រាប់ដល់ថុល្លនន្ទាភិក្ខុនីថា ត្រូវការអ្វីដោយតម្លៃនោះ ឲ្យនាំមកចុះ ។ នាងប្រើសិក្ខមានា (សាមណេរីដែលកំពុងសិក្សា គឺសាមណេរីដែលត្រៀមខ្លួនបួសជាភិក្ខុនីតាមកាលកំណត់) ម្នាក់ឲ្យទៅនាំប្រេងមកក្នុងតម្លៃ ១ កហាបណៈ លុះនាំមកហើយ បញ្ជាឲ្យផ្លាស់ថ្មីថា មិនត្រូវការប្រេង តែត្រូវការទឹក

ដោះថ្លា ។ សិក្ខមានានាំប្រេងទៅប្តូរយកទឹកដោះថ្លាមក អ្នកលក់មិនព្រមដូរឲ្យ នាងក៏ឈរស្រែកយំ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយ ដល់ភិក្ខុនីដែលបញ្ជាឱ្យទិញរបស់ផ្លាស់ប្តូរដូច្នោះ។***

## សិក្ខាបទទី ៦

### (ហាមចំណាយខុសគោលបំណងដើម)

ពួកឧបាសក វែអង្កៀសគ្នាដើម្បីធ្វើចីវរប្រគេនភិក្ខុនីសង្ឃ ហើយទុកដាក់របស់នៅផ្ទះអ្នកលក់សំពត់ម្នាក់ ចូលទៅរកភិក្ខុនីទាំងឡាយ ប្រាប់ថា បើត្រូវការចីវរ សូមទៅយកមកចែកគ្នាចុះ ។ ភិក្ខុនីសុំសំពត់នោះដោយខ្លួនឯងហើយ យកបរិក្ខារនោះទៅចំណាយដូរយកភេសជ្ជៈមកបរិភោគវិញ ។ ពួកឧបាសកដឹងហើយ ក៏នាំគ្នាតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុនី ដែលទៅយករបស់ ដែលគេប្រាថ្នាចោះចំពោះដើម្បីប្រយោជន៍តែម៉្យាងប្រគេនដល់សង្ឃ ដែលខ្លួនសុំមកដោយខ្លួនឯង ទៅចំណាយដូរយករបស់ដទៃវិញ។***

## សិក្ខាបទទី ៨

### (ហាមចំណាយរបស់គណៈដូរយករបស់ដទៃ)

មានជនមួយក្រុម វែអង្កៀសគ្នាដើម្បីធ្វើយាគូប្រគេនភិក្ខុនីទាំងឡាយ (ក្នុងទីនេះមិនប្រើពាក្យថា សង្ឃ ដោយគិតដល់ពួកភិក្ខុនីដែលលំបាកដោយយាគូ) ហើយផ្ញើរបស់ទុកក្នុងផ្ទះរបស់អ្នកលក់ម្នាក់ ចូលទៅរកភិក្ខុនីទាំងឡាយ ប្រាប់ថា បើត្រូវការយាគូ ឲ្យទៅយកអង្ករមកចំអិនយាគូបរិភោគ ។ ពួកគេដឹងហើយ ក៏នាំគ្នាតិះដៀល ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុនីដែលទៅយករបស់ ដែលគេប្រាថ្នាចោះចំពោះដើម្បីប្រយោជន៍ទុកប្រគេនដល់គណៈម៉្យាង ភិក្ខុនីយកមកចំណាយរបស់យ៉ាងដទៃ។*** (សេចក្តីផ្សេងគ្នានៃសិក្ខាបទនេះជាមួយសិក្ខាបទទី ៦ ទី ៧ អាស្រ័យលើគណៈ និងសង្ឃ, គណៈ សំដៅយក ២-៣ រូប, សង្ឃសំដៅយក ៤ រូបឡើងទៅ) ។

## សិក្ខាបទទី ៩

### (ហាមសុំរបស់របរពីគណៈមកចំណាយដូរយករបស់ដទៃ)

រឿងដូចគ្នានឹងសិក្ខាបទទី ៨ ដែរ ប្លែកត្រង់ថា ភិក្ខុនីសុំជាមុនហើយ ទើបធ្វើការចែកចាយរបស់ជាខាងក្រោយ ហើយក៏

មានទំនងដូចគ្នានឹងសិក្ខាបទទី ៧ ដងដែរ គ្រាន់តែសិក្ខាបទនេះ គេប្រគេនដល់គណៈ ។

## សិក្ខាបទទី ១០

**(ហាមសុំរបស់របរពីបុគ្គលមកចំណាយដូរយករបស់ដទៃ)**

*រឿងរ៉ាវមានទំនងដូចគ្នានឹងសិក្ខាបទទី ៩ ដែរ ខុសគ្នាត្រង់ថា គេប្រគេនរបស់ជាចំណែកបុគ្គល សម្រាប់ថ្ងៃធ្វើការសម្អាតបរិវេណ តែអ្នកទទួលបែរជាយកមកចំណាយដូរយកភេសជ្ជៈវិញ ។*

## ចីវរវគ្គ (វគ្គពោលអំពីចីវរ)

## សិក្ខាបទទី ១

**(ហាមសុំសំពត់ដណ្ដប់ក្នុងរដូវរងាតម្លៃលើស ១៦ កហាបណៈ)**

*ព្រះបាទបសេនទិកោសល ទ្រង់ជ្រះថ្លាក្នុងព្រះធម៌ទេសនារបស់ថុល្លនន្ទាភិក្ខុនី បវារណាឲ្យសុំរបស់របរបាន ទើបនាងសុំសំពត់កម្ពលដែលមានតម្លៃថ្លៃ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិនិស្សគ្គិយបាចិត្តិយដល់ភិក្ខុនីដែលសុំ (ឬឱ្យគេចំណាយ) សំពត់ដណ្ដប់ក្នុងរដូវរងាដែលមានតម្លៃលើស ៤ កង្សៈ (ត្រូវជា ១៦ កហាបណៈ) ។***

## សិក្ខាបទទី ២

**(ហាមសុំសំពត់ដណ្ដប់ក្នុងរដូវក្ដៅតម្លៃលើស ១០ កហាបណៈ)**

*ព្រះបាទបសេនទិកោសល ទ្រង់ជ្រះថ្លាក្នុងព្រះធម៌ទេសនារបស់ថុល្លនន្ទាភិក្ខុនី បវារណាឲ្យសុំរបស់ដែលខ្លួនត្រូវការបាន នាងសុំសំពត់សម្បកឈើ ក៏ប្រគេនតាមបំណង ។ មនុស្សទាំងឡាយនាំគ្នាតិះដៀលថា ប្រាថ្នាច្រើន (យល់ថាសុំសំពត់ដែលមានតម្លៃថ្លៃ) ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិ***

***និស្សគ្គិយបាចិត្តិយ ដល់ភិក្ខុនីដែលសុំសំពត់ដណ្តប់ ក្នុងរដូវក្តៅ មានតម្លៃលើសពី ២ កង្សៈកន្លះ*** (ត្រូវជា ១០ កហាបណៈ)[៣៧] ។

(កត់សម្គាល់ៈ និស្សគ្គិយកណ្ឌដែលសំដែងទុកក្នុងទីនេះ មានត្រឹមតែ ១២ សិក្ខាបទ ទាំងដែលបានពោលមកមាន ៣០ សិក្ខាបទ ពីព្រោះនាំយករបស់ភិក្ខុមកប្រើ ១៨ សិក្ខាបទ។ ពោលម្យ៉ាងទៀត និស្សគ្គិយបាចិត្តិយរបស់ភិក្ខុទាំង ៣០ សិក្ខាបទនោះ ដកចេញ ១២ សិក្ខាបទ ហើយនាំយកមកប្រើសម្រាប់ភិក្ខុនីមាន ១៨ សិក្ខាបទ, ដែលដកចេញ ១២ សិក្ខាបទ គឺសិក្ខាបទ ទី ៨ និងទី ៥ នៃចីវរវគ្គ, សិក្ខាបទទី ១ ដល់ទី ៧ នៃកោសិយ-វគ្គ, សិក្ខាបទទី ១-៨ និងទី ៩ នៃបត្តវគ្គ) ។

---

[៣៧] មានបទដែលគួរសង្កេត ២ យ៉ាង គឺសំពត់ដណ្តប់ក្នុងរដូវរងា ប្រើពាក្យថា សំពត់ដណ្តប់ធ្ងន់ ***(គរុបាបុរណំ)***, សំពត់ដណ្តប់ក្នុងរដូវក្តៅ ប្រើពាក្យថា សំពត់ដណ្តប់ស្រាល ***(លហុបាបុរណំ)***។ ពាក្យថា **សុំ** ប្រែកាច់ពីពាក្យថា ***ចេតាបេយ្យ*** (ធ្វើឲ្យគេចាយ) ។

# បាចិត្តិយកណ្ឌ

## (ពោលអំពីអាបត្តិបាចិត្តិយ គឺមិនចាំបាច់មានការលះវត្ថុ)

(ក្នុងសៀវភៅនេះ សំដែងចំពោះតែសិក្ខាបទរបស់ភិក្ខុនីសុទ្ធ ៩៦ សិក្ខាបទ ឯ ៧០ សិក្ខាបទទៀត នាំយករបស់ភិក្ខុមកប្រើទើបរួមទៅត្រូវជា ១៦៦ សិក្ខាបទ។ ក្នុង ៩៦ សិក្ខាបទនេះ បែកចេញជា ៩ វគ្គៗ ទី ១ ដល់វគ្គទី ៧ ក្នុងមួយវគ្គៗ មាន ១០ សិក្ខាបទ វគ្គទី ៨ និងទី ៩ ក្នុងមួយវគ្គៗ មាន ១៣ សិក្ខាបទ) ។

## លសុណវគ្គទី ១ (វគ្គពោលអំពីខ្ទឹម)

### សិក្ខាបទទី ១ (ហាមឆាន់ខ្ទឹម)

ឧបាសកម្នាក់បវារណាឲ្យភិក្ខុនីសង្ឃសុំខ្ទឹមបាន ព្រមទាំងប្រាប់អ្នកចាំចំការឲ្យរៀបចំប្រគេន ។ ថ្ងៃមួយភិក្ខុនីជាច្រើនរូប ទៅសុំខ្ទឹមគាប់ជួនខ្ទឹមក្នុងផ្ទះអស់ ទើបគេឲ្យលោកទៅបេះខ្លួនឯងក្នុងចំការ ។ ថុល្លនន្ទាភិក្ខុនីមិនស្គាល់ប្រមាណ ប្រើគេឲ្យបេះរលួសអស់ជាច្រើន អ្នកចាំចំការតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលឆាន់ខ្ទឹមស*** (មុខជាដើម្បីការ

ពារមិនឲ្យទៅសុំខ្ទឹមអ្នកស្រុកទៀត) ។

## សិក្ខាបទទី ២

### (ហាមនាំរោមក្នុងទីកំបាំងចេញ)

ភិក្ខុនីទៅកំពង់ទឹកជាមួយពួកស្ត្រីពេស្យា ងូតទឹកអាក្រាតកាយ ត្រូវពួកស្ត្រីពេស្យាទាំងនោះតិះដៀលថា នាំរោមក្នុងទីកំបាំងចេញ ដូចពួកគ្រហស្ថអ្នកបរិភោគកាម ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលនាំរោមក្នុងទីកំបាំង**[៣៨] **ចេញ។**

## សិក្ខាបទទី ៣

### (ហាមប្រើបាតដៃទះគ្នាដោយតម្រេក)

ភិក្ខុនី ២ រូបមានតម្រេកកើតឡើង ក៏នាំគ្នាចូលក្នុងបន្ទប់ ប្រើបាតដៃទះគ្នា[៣៩] (គឺទះសាច់ខ្លួនគ្នាទៅវិញទៅមក) ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។**

## សិក្ខាបទទី ៤

### (ហាមប្រើរបស់ដែលធ្វើដោយជ័រឈើ)

ភិក្ខុនីមានតម្រេក ប្រើរបស់ដែលធ្វើដោយជ័រឈើស៊កចូលក្នុងអង្គកំណើត ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។** (ពាក្យថា ជ័រឈើ មានន័យសំដៅយកឈើ, ម្សៅ, ដីស្អិត ដោយហោចទៅ សូម្បីតែស្លឹកឈូក, ពាក្យអធិប្បាយខាងចុងសិក្ខាបទ) ។

## សិក្ខាបទទី ៥

### (ហាមលាងសម្អាតលើសជម្រៅ ២ ថ្នាំងម្រាម)

ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុនីប្រើទឹកលាងសម្អាតបាននៅពេលបស្សាវៈហើយ ភិក្ខុនីរូបខ្លះប្រើទឹកលាងសម្អាតលូកចូលទៅជ្រៅ ធ្វើឲ្យមានដំបៅ ទើបទ្រង់បញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិ**

---

[៣៨] ពាក្យថា **ទីកំបាំង** សំដៅដល់រន្ធក្លៀកទាំងពីរ និងអង្គកំណើត ។

[៣៩] មានពាក្យអធិប្បាយខាងចុងសិក្ខាបទថា ពេលមានតម្រេកក្នុងសម្ផស្ស សូម្បីប្រើស្លឹកឈូកទះអង្គកំណើត ក៏ត្រូវបាចិត្តិយ ។

***បាចិត្តិយដល់ភិក្ខុនីដែលប្រើទឹកលាងសម្អាត ចូលទៅជ្រៅលើសពី ២ ថ្នាំងម្រាម*** (ដើម្បីការពារមិនឲ្យមានតម្រេក ពាក្យអធិប្បាយខាងចុងសិក្ខាបទ) ។

## សិក្ខាបទទី ៦

### (ហាមចូលទៅឈរកាន់ទឹកនិងបក់ផ្លិតក្នុងខណៈភិក្ខុកំពុងឆាន់)

*មហាអាមាត្យម្នាក់ចេញបួស ភរិយាក៏ចេញបួសជាភិក្ខុនីតាម ពេលឆាន់ ភិក្ខុនីដែលធ្លាប់ជាអតីតភរិយា ក៏មកឈរកាន់ភាជន៍ទឹក និងកាន់ផ្លិតបក់ឲ្យ ។ ភិក្ខុដែលធ្លាប់ជាអតីតស្វាមីឃើញថា ពុំសមគួរហាមប្រាម នាងក្រោធ ទើបយកភាជន៍ទឹកផ្កាប់ចុះទៅលើក្បាល និងយកផ្លិតវាយទៅលើភិក្ខុនោះ ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលចូលទៅឈរកាន់ភាជន៍ទឹក និងបក់ផ្លិតនៅពេលដែលភិក្ខុកំពុងឆាន់។***

## សិក្ខាបទទី ៧

### (ហាមធ្វើការច្រើនយ៉ាងជាមួយស្រូវស្រស់)

*ភិក្ខុនីទៅសុំស្រូវស្រស់បានមក តែត្រូវគេឆក់ដណ្តើមត្រង់ទ្វារក្រុង ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុនីដែលសុំខ្លួនឯង, ប្រើគេឱ្យសុំ, អុំដោយខ្លួនឯង, ប្រើគេឱ្យអុំ, បុកដោយខ្លួនឯង, ប្រើគេឱ្យបុកនូវស្រូវស្រស់ ដាំដោយខ្លួនឯង ប្រើគេឱ្យដាំ ហើយឆាន់បាយនោះ*** *(គឺឆាន់បាយដែលខ្លួនធ្វើ ឬប្រើគេឲ្យធ្វើយ៉ាងណានីមួយ ដែលទាក់ទងនឹងស្រូវស្រស់នោះ ត្រូវអាបត្តិ) ។*

## សិក្ខាបទទី ៨

### (ហាមចោលរបស់ក្រៅជញ្ជាំង ឬកំពែង)

*ភិក្ខុនីបន្ទោបង់ខច្ចារៈដាក់ភាជន៍ ចាក់ចោលទៅក្រៅជញ្ជាំងធ្លាក់ត្រូវក្បាលព្រាហ្មណ៍ម្នាក់ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលចោល ឬប្រើគេឱ្យចោលនូវឧច្ចារៈ បស្សាវៈ ឬរបស់សំណល់ (សម្រាម) ក្រៅជញ្ជាំង ឬកំពែង។***

## សិក្ខាបទទី ៩

### (ហាមបោះចោលរបស់ដូចនោះលើរបស់ខៀវស្រស់)

ភិក្ខុនីបន្ទោបង់ខច្ចារៈជាដើម ដាក់ចុះក្នុងស្រែព្រាហ្មណ៍ម្នាក់ ព្រាហ្មណ៍ក៏តិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលបោះចោល ឬប្រើគេឱ្យចោល នូវឧច្ចារៈ បស្សាវៈ ឬរបស់សំណល់ (សម្រាម) លើរបស់ខៀវស្រស់*** *(រុក្ខជាតិ មានស្មៅជាដើម) ។*

## សិក្ខាបទទី ១០

### (ហាមទៅមើលគេរាំច្រៀង)

*មានពិធីរៀបចំមហោស្រពលើកំពូលភ្នំរាជគ្រឹះ ភិក្ខុនីទៅមើល មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលទៅមើលការប្រគុំរាំច្រៀង។***

## **អន្ធការវគ្គ** (វគ្គពោលអំពីពេលរាត្រី)

## សិក្ខាបទទី ១

### (ហាមឈរ ឬសន្ទនាជាមួយបុរសក្នុងទីងងឹត)

*ភិក្ខុនីរូបខ្លះឈរ រូបខ្លះសន្ទនា ជាមួយបុរសតែពីរនាក់ ក្នុងទីងងឹត ដោយពុំបានអុចប្រទីប ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។***

## សិក្ខាបទទី ២

### (ហាមឈរ ឬសន្ទនាជាមួយបុរសតែពីរនាក់ក្នុងទីកំបាំង)

*ភិក្ខុនីរូបខ្លះឈរ រូបខ្លះសន្ទនា ជាមួយបុរសតែពីរនាក់ ក្នុងទីកំបាំង ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។***

## សិក្ខាបទទី ៣

### (ហាមឈរ ឬសន្ទនាជាមួយបុរសតែពីរនាក់ក្នុងទីវាល)

*ភិក្ខុនីរូបខ្លះយល់ថា ហាមធ្វើក្នុងទីកំបាំងដូចសិក្ខាបទទី ២*

ទើបឈរខ្លះ សន្ទនាខ្លះ ជាមួយបុរសតែពីរនាក់ក្នុងទីវាល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។***

## សិក្ខាបទទី ៤

### (ហាមធ្វើដូច្នោះក្នុងទីដទៃទៀត)

ថុល្លនន្ទាភិក្ខុនីជាមួយបុរសតែពីរនាក់ ឈរខ្លះ សន្ទនាខ្លះ ខ្សឹបខ្លះ ឲ្យភិក្ខុនីជាសំឡាញ់ទៅមុនខ្លះ លើផ្លូវខ្លះ លើផ្លូវទាល់ខ្លះ (ផ្លូវដូចនេះ ចូលទៅតាមច្រកណា ត្រូវចេញតាមច្រកនោះវិញ) លើផ្លូវបំបែកខ្លះ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។***

## សិក្ខាបទទី ៥

### (ហាមចូលផ្ទះអ្នកស្រុកហើយមិនប្រាប់លា)

ភិក្ខុនីរូបខ្លះ ទៅឆាន់ក្នុងផ្ទះអ្នកស្រុកម្នាក់ ជាប្រចាំ ។ ថ្ងៃមួយ ពេលឆាន់រួចរាល់ហើយ ចេញមកដោយពុំបានប្រាប់លាម្ចាស់ផ្ទះ នាងទាសីបោសផ្ទះ ក៏យកកម្រាលដាក់ចូលទៅក្នុងភាជនៈ ម្ចាស់ផ្ទះមិនឃើញកម្រាល ទើបសួររកដល់ភិក្ខុនីៗ តបថាមិនដឹង គេក៏ទាមទារយកពីភិក្ខុនី បរិភាស(តិះដៀល)ហើយ លើការប្រគេនអាហារជាប្រចាំ ។ ក្រោយមកគេរកឃើញកម្រាលនោះ នៅក្នុងភាជនៈ ក៏ឲ្យម្ចាស់ផ្ទះទៅសុំខមាទោសនឹងភិក្ខុនីរូបនោះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលចូលទៅកាន់ត្រកូល មុនពេលអាហារ (មុនថ្ងៃត្រង់) អង្គុយលើអាសនៈហើយចេញមកដោយពុំបានប្រាប់លាម្ចាស់ផ្ទះ។***

## សិក្ខាបទទី ៦

### (ហាមអង្គុយ ឬដេកលើអាសនៈដោយពុំប្រាប់ម្ចាស់ផ្ទះជាមុន)

ថុល្លនន្ទាភិក្ខុនី ចូលទៅកាន់ត្រកូលក្នុងពេលក្រោយអាហារ (ថ្ងៃជ្រេ) មិនប្រាប់ម្ចាស់ផ្ទះជាមុនហើយអង្គុយ ឬដេកលើអាសនៈ[៤០] មនុស្សទាំងឡាយខ្លាចរអានាង ក៏មិនហានអង្គុយ ឬដេកលើអាសនៈ (ខ្លាចក្រែងជាការអង្គុយស្មើ) ក៏នាំគ្នាតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយ***

---

[៤០] **អាសនៈ:** គឺគ្រឿងក្រាល ឬកម្រាល តែខាងចុងសិក្ខាបទកែថា ទីសម្រាប់ដាក់បល្លង្ក ទើបសំដៅយកការអង្គុយលើកៅអី ក៏ឈ្មោះថា អង្គុយលើអាសនៈ ។

***ដល់ភិក្ខុនីដែលចូលទៅកាន់ត្រកូល ក្នុងពេលក្រោយអាហារ មិនប្រាប់ម្ចាស់ផ្ទះជាមុនហើយអង្គុយ ឬដេកលើអាសនៈ។***

## សិក្ខាបទទី ៧

### (ហាមក្រាលកម្រាលដេកដោយពុំបានប្រាប់ម្ចាស់ផ្ទះ)

*ភិក្ខុនីរូបខ្លះ ធ្វើដំណើរទៅកាន់ក្រុងសាវត្ថី តាមផ្លូវឆ្ងៀតទៅសុំសម្នាក់ជាមួយត្រកូលព្រាហ្មណ៍ម្នាក់ នាងព្រាហ្មណីសូមឲ្យចាំព្រាហ្មណ៍ជាស្វាមីត្រឡប់មក ភិក្ខុនីក៏ក្រាលកម្រាលដោយគិតថានឹងអង្គុយ ឬដេកចាំ ។ ព្រាហ្មណ៍នោះត្រឡប់មកក្នុងវេលាយប់ សួរដឹងរឿងហើយ ប្រាប់ឲ្យដេញចេញ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលចូលទៅកាន់ត្រកូលក្នុងវេលាវិកាល មិនប្រាប់ម្ចាស់ផ្ទះជាមុន ហើយក្រាលកម្រាល ឬប្រើគេឱ្យក្រាលកម្រាលដេក ឬអង្គុយ។***

## សិក្ខាបទទី ៨

### (ហាមតិះដៀលអ្នកដទៃមិនដូចការបានឮ)

*នាងភទ្ទាកាបិលានី ឃើញសិស្សដែលខ្លួនជាឧបជ្ឈាយ៍[៨១] បួសឲ្យបម្រើបានល្អ ទើបនិយាយជាមួយភិក្ខុនីទាំងឡាយថា «នាងម្ចាស់ទាំងឡាយ ភិក្ខុនីរូបនេះឧបដ្ឋាកយើងបានល្អ យើងនឹងឲ្យចីវរដល់នាង» ភិក្ខុនីនោះក៏ដើរនិយាយលើកទោសដល់អ្នកដទៃ ដោយពាក្យ (បញ្ឆិតបញ្ឆៀង) ដែលប្រកាន់ខុស ចាំមកខុសថា «ព្រោះថា ខ្ញុំឧបដ្ឋាកនាងម្ចាស់មិនល្អ ទើបនាងម្ចាស់មិនឲ្យចីវរដល់ខ្ញុំ» ។ ដំណឹងនេះបានជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនី ដែលលើកទោសអ្នកដទៃ ដោយពាក្យប្រកាន់ខុស ចាំមកខុស។***

## សិក្ខាបទទី ៩

### (ហាមជេរប្រទេចដោយរឿងនរក ឬព្រហ្មចរិយៈ)

*របស់របរភិក្ខុនីទាំងឡាយបាត់ ក៏នាំគ្នាសួរចណ្ឌកាឡីភិក្ខុនីថា ឃើញរបស់ខ្ញុំទេ ? ចណ្ឌកាឡីភិក្ខុនី ក៏ជេរខ្លួនឯងខ្លះ ជេរអ្នកដទៃខ្លះថា បើខ្ញុំយកមែន សូមឲ្យខ្ញុំឃ្លាតចាកព្រហ្មចរិយៈ ធ្លាក់នរក តែបើមិនពិត ក៏សូមឲ្យពួកនាងឃ្លាតចាកព្រហ្មចរិយៈ និងធ្លាក់នរក*

---

[៨១] *ពាក្យថា* **ឧបជ្ឈាយ៍** *សម្រាប់ភិក្ខុនីប្រើជា បវត្តិនី ក៏បាន ៗ*

*ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលជេរប្រទេចខ្លួនឯង ឬអ្នកដទៃដោយនរក ឬក៏ព្រហ្មចរិយៈ។***

## សិក្ខាបទទី ១០

### (ហាមប្រទូស្តវាយខ្លួនឯងហើយទួញយំ)

*ចណ្ឌកាឡីភិក្ខុនី ឈ្លោះទាស់ទែងជាមួយភិក្ខុនីរូបដទៃ បែរជាមកគក់ទ្រូងវាយក្បាលហើយទួញយំ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រទូស-វាយខ្លួនឯង ឬអ្នកដទៃដោយរឿងនរក ឬក៏ព្រហ្មចរិយៈ។***

## នគ្គវគ្គទី ៣ (ពោលអំពីរឿងអាក្រាតកាយ)

## សិក្ខាបទទី ១

### (ហាមអាក្រាតកាយងូតទឹក)

*ភិក្ខុនីអាក្រាតកាយងូតទឹកជាមួយនឹងស្រីពេស្យា ក្នុងកំពង់ទឹកជាមួយគ្នា ត្រូវគេនិយាយចំអែរចំអន់ដោយប្រការផ្សេងៗ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីអាក្រាតកាយងូតទឹក។***

## សិក្ខាបទទី ២

### (ហាមធ្វើសំពត់ងូតទឹកវែង និងធំហួសប្រមាណ)

*ឆព្វគ្គិយាភិក្ខុនី ធ្វើសំពត់ងូតទឹកលើសប្រមាណ វែងស្ទុយទៅខាងមុខខាងក្រោយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលធ្វើសំពត់ងូតទឹកលើសប្រមាណ គឺវែងលើស ៤ ធ្នាប់ ខ្វាំងជាង ២ ធ្នាប់ ដោយធ្នាប់ព្រះសុគត។***

## សិក្ខាបទទី ៣

### (ហាមនិយាយហើយមិនធ្វើតាម)

*ថុល្លនន្ទាភិក្ខុនី និយាយជាមួយភិក្ខុនីមួយរូបថា សំពត់ចីវររបស់នាងល្អ តែដេរមិនល្អ, ភិក្ខុនីរូបនោះ ក៏និយាយថា ខ្ញុំនឹងរុះចេញ នាងដេរឲ្យខ្ញុំទេ។ ថុល្លនន្ទាភិក្ខុនី ក៏ទទួលសម្តីថា នឹងដេរឲ្យ,*

ភិក្ខុនីរូបនោះ ក៏រុះចីវរចេញហើយប្រគល់ឲ្យទៅថុល្លនន្ទាភិក្ខុនី ។ នាងនិយាយថាដេរឲ្យ ក៏មិនព្រមដេរ ឬពឹងពាក់អ្នកដទៃឲ្យដេរ ក៏មិនព្រមពឹង ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលរុះ ឬឱ្យគេរុះចីវរហើយ ក្រោយមកពុំមានហេតុអាក់ខាន មិនព្រមដេរខ្លួនឯង ឬក៏ពឹងពាក់អ្នកដទៃឱ្យដេរ វៀរតែផ្អាក ឬពន្យាទុក ៤-៥ ថ្ងៃ។***

## សិក្ខាបទទី ៤

### (ហាមវៀរការប្រើសង្ឃាដីលើស ៥ ថ្ងៃ)

ភិក្ខុនីទាំងឡាយ ផ្ញើចីវរនឹងនាងភិក្ខុនីដូចគ្នាហើយត្រាច់ទៅកាន់ជនបទ ចីវរនោះទុកយូរក៏ប្រឡាក់ ។ ភិក្ខុនីដែលទទួលបញ្ញើ ក៏នាំចេញយកមកសំដិលថ្ងៃ ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនី ដែលវៀរការប្រើ សង្ឃាដីលើស ៥ ថ្ងៃ។***

(កត់សម្គាល់ៈ តាមធម្មតា ភិក្ខុនីមានសំពត់សម្រាប់ប្រើជាប្រចាំ ៥ ផ្ទាំង គឺ

១.សង្ឃាដិ (សំពត់ត្រួតគ្នាពីរជាន់ សម្រាប់ ប្រើពេលរងា)

២.ឧត្តរាសង្គៈ (សំពត់ដណ្តប់)

៣.អន្តរាវាសកៈ (សំពត់ស្លៀក)

៤.សង្កច្ចិកៈ (សំពត់រុំ ឬចង)

៥.ឧទកសាដិកា (សំពត់ងូតទឹក) ។

ពិចារណាតាមសិក្ខាបទនេះ ជាការហាមឃាត់ វៀរការប្រើសង្ឃាដិចេញតែម្យ៉ាង តែពាក្យអធិប្បាយខាងចុងសិក្ខាបទ ពង្រីកន័យថា វៀរផ្ទាំងណាមួយ ទាំង ៥ ផ្ទាំងលើស ៥ ថ្ងៃ ពុំបាន ពាក្យថាវៀរ គឺមិនស្លៀក មិនដណ្តប់ ឬមិនសំដិលថ្ងៃ ។)

## សិក្ខាបទទី ៥

### (ហាមប្រើចីវរលាយឡំជាមួយអ្នកដទៃ)

ភិក្ខុនីមួយរូបត្រាច់ទៅបិណ្ឌបាត រួចសំដិលចីវរដែលទទឹកទុក ភិក្ខុនីមួយរូបទៀត ក៏យកចីវរនោះដណ្តប់រួចចូលទៅកាន់ស្រុក ម្ចាស់ចីវរចេញមកសួររក ដឹងហើយក៏តិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រើចីវរលាយឡំជាមួយភិក្ខុនីដទៃ (បើបានអនុញ្ញាតពីម្ចាស់ចីវរជាមុនមិនត្រូវអាបត្តិ)។***

## សិក្ខាបទទី ៦

(ហាមធ្វើឱ្យចីវរលាភរបស់សង្ឃអន្តរាយ)

ត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនីនិយាយថា ប្រាថ្នានឹងប្រគេនចីវរដល់ភិក្ខុនីសង្ឃ ។ នាងត្រឡប់កាត់បទដោយវាចាថា អ្នកទាំងឡាយមានកិច្ចច្រើន មានធុរៈច្រើន, ភ្លើងឆេះផ្ទះរបស់ពួកគេ ទើបពួកគេតិះដៀលថាធ្វើឲ្យអន្តរាយដល់ទេយ្យធម៌របស់ពួកគេ គឺវិនាសចាកទ្រព្យ និងបុណ្យ ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលធ្វើអន្តរាយចីវរលាភរបស់សង្ឃ។***

## សិក្ខាបទទី ៧

(ហាមជំទាស់ការចែកចីវរប្រកបដោយធម៌)

ចីវរក្រៅកាលបានកើតឡើងដល់ភិក្ខុនីសង្ឃ ទើបភិក្ខុនីសង្ឃប្រជុំគ្នាដើម្បីចែកចីវរនោះ ។ ថុល្លនន្ទាភិក្ខុនីកាន់យកហេតុ ដែលសិស្សរបស់ខ្លួនគេចទៅកាន់ទីដទៃ ហាមឃាត់មិនឲ្យចែក ភិក្ខុនីទាំងឡាយ ក៏អាក់ខានចែក ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីរារាំងការចែកចីវរដែលប្រកបដោយធម៌។***

## សិក្ខាបទទី ៨

(ហាមឱ្យសមណចីវរដល់គ្រហស្ថ ឬអ្នកបួស)

ថុល្លនន្ទាភិក្ខុនីឲ្យសមណចីវរ (សំពត់ដែលសម្រេចរូបសម្រាប់ភិក្ខុនី) ដល់អ្នកសំដែងល្ខោនខ្លះ អ្នករាំខ្លះ អ្នកលោតខ្លះ អ្នកលេងស្គរខ្លះ[៤២] ដោយសុំឲ្យគេសរសើរខ្លួនក្នុងទីប្រជុំជន ពួកនោះក៏ដើរសរសើរក្នុងទីផ្សេងៗ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនី ដែលឱ្យចីវរដល់អ្នកគ្រប់គ្រងផ្ទះ អ្នកបួស (ក្រៅសាសនា) ជាបុរស ឬស្ត្រី។***

## សិក្ខាបទទី ៩

(ហាមធ្វើឱ្យកិច្ចការអាក់ខានដោយការរំពឹងចាំ)

---

[៤២] *ពាក្យថា* **អ្នកលេងស្គរ** *ប្រែចេញពីពាក្យថា កុម្ភថូនិកា ។*

គ្រូកូលខបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនីនិយាយថា បើពួកយើងអាច (មានឱកាស) ក៏នឹងប្រគេនចីវរដល់ភិក្ខុនីសង្ឃ។ កាលបើភិក្ខុនីទាំងឡាយចាំវស្សារួចហើយ ក៏ប្រជុំគ្នាចែកចីវរ តែត្រូវថុល្លនន្ទាភិក្ខុនីឃាត់ឲ្យរង់ចាំ ដោយអាងថា ភិក្ខុនីសង្ឃកំពុងនៅប្រាថ្នាចីវរទៀត។ កាលបើ (រង់ចាំល្មមសមគួរហើយ) ភិក្ខុនីទាំងឡាយក៏គៀនរឿងចីវរដែលបាននោះ ថុល្លនន្ទាភិក្ខុនី ក៏ទៅគៀនគ្រូកូលដែលគេនិយាយថានឹងប្រគេន គេតបថា គេពុំអាចប្រគេនបានទេ។ ភិក្ខុនីទាំងឡាយ ក៏តិះដៀលថុល្លនន្ទាភិក្ខុនីដែលចេះតែឲ្យរង់ចាំរហូតដល់ហួសសម័យកាលដែលត្រូវធ្វើចីវរ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលធ្វើឱ្យកន្លង ហួសសម័យធ្វើចីវរ ដោយអាងការរង់ចាំថា នឹងបានចីវរដែលគេធ្លាប់បាននិយាយទុក។***

## សិក្ខាបទទី ១០

### (ហាមចចេសដកកឋិនដែលប្រកបដោយធម៌)

ឧបាសកម្នាក់សង់វិហារប្រគេនសង្ឃ និងប្រាថ្នាប្រគេនចីវរក្រៅកាលដល់ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃក្នុងការឆ្លងវិហារនោះ ទើបចូលទៅរកព្រះមានព្រះភាគដើម្បីសុំឲ្យទ្រង់ដក (ដោះ) កឋិន ព្រះអង្គក៏អនុញ្ញាតដោយឲ្យប្រជុំសង្ឃសូត្រប្រកាស សុំមតិក្នុងការដកកឋិន ប៉ុន្តែខាងភិក្ខុនីសង្ឃ ពុំមានរូបណាមួយធ្វើការនេះ ឲ្យសម្រេចបាន ពីព្រោះថុល្លនន្ទាភិក្ខុនីជំទាស់ ដោយគិតចង់បានចីវរលាភមកធ្វើជារបស់ខ្លួន

ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខា-បទ

***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនី ដែលចចេសដកកឋិន ប្រកបដោយធម៌។***

## តុវដ្តវគ្គទី ៤ (ពោលអំពីការដេករួមគ្នា)

## សិក្ខាបទទី ១

### (ហាមដេកលើគ្រែជាមួយគ្នាពីរនាក់)

ភិក្ខុនីពីររូបដេករួមគ្នាលើគ្រែតែមួយ មនុស្សទាំងឡាយនាំគ្នាតិះដៀលថា ប្រព្រឹត្តដូចគ្រហស្ថ។ ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិដល់ភិក្ខុនី ដែលដេកលើគ្រែមួយពីរនាក់។***

## សិក្ខាបទទី ២

(ហាមប្រើកម្រាល និងសំពត់ដណ្តប់រួមគ្នាពីរនាក់)

ភិក្ខុនីពីររូបដេករួមគ្នា ប្រើកម្រាល និងសំពត់ដណ្តប់ជាមួយគ្នា ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។***

## សិក្ខាបទទី ៣

### (ហាមក្លែងបង្កការរំខានដល់ភិក្ខុនី)

មនុស្សទាំងឡាយ នាំគ្នាសរសើរភទ្ទាកាបិលានីភិក្ខុនី ដោយប្រការផ្សេងៗ ថុល្លនន្ទាភិក្ខុនីច្រណែន ក៏ដើរចង្ក្រម (ដើរទៅមក) ខ្លះ ឈរខ្លះ អង្គុយខ្លះ ដេកខ្លះ បង្រៀនធម៌ខ្លះ ប្រើគេឲ្យបង្រៀនខ្លះ រអ៊ូរទាំខ្លះ ពីមុខភទ្ទាកាបិលានីភិក្ខុនី (ដើម្បីបង្កការរំខាន) ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលក្លែងបង្កការរំខានដល់ភិក្ខុនីឯទៀត។***

## សិក្ខាបទទី ៤

### (ហាមព្រងើយកន្តើយពេលសិស្សពុំសប្បាយ)

ថុល្លនន្ទាភិក្ខុនីមិនរក្សាដោយខ្លួនឯង មិនខ្វល់ខ្វាយដើម្បីឲ្យអ្នកដទៃមើលថែទាំសហជីវិនី (គឺភិក្ខុនីដែលខ្លួនជាឧបជ្ឈាយ៍បំបួសឲ្យ) មានអាពាធ គួរជាទីតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនី ដែលប្រព្រឹត្តដូច្នោះ។***

## សិក្ខាបទទី ៥

### (ហាមបណ្តេញភិក្ខុនីចេញពីលំនៅឋាន)

ថុល្លនន្ទាភិក្ខុនី ឲ្យទីលំនៅដល់ភទ្ទាកាបិលានីភិក្ខុនីហើយ ក្រោយមកមានចិត្តច្រណែន ក្រោធខឹង ដេញភទ្ទាកាបិលានីភិក្ខុនីចេញពីទីលំនៅ គួរជាទីតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលឱ្យទីលំនៅ ដល់ភិក្ខុនីហើយ ក្រោធខឹង បណ្តេញខ្លួនឯង ឬប្រើគេឱ្យមកបណ្តេញចេញ។***

## សិក្ខាបទទី ៦

### (ហាមនៅច្របូកច្របល់ជាមួយគហបតី ឬបុត្រគហបតី)

ចណ្ឌកាឡីភិក្ខុនីនៅច្រឡូកច្របល់ជាមួយគហបតីខ្លះ បុត្រគហបតីខ្លះ គួរជាទីតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលនៅច្រឡូកច្របល់ជាមួយគហបតី ឬបុត្រគហបតី ជាអ្នកដែលភិក្ខុនីទាំងឡាយ ដាស់តឿនហើយ ពុំស្តាប់ ភិក្ខុនីសង្ឃសូត្រប្រកាសឱ្យលះបង់គ្រប់ ៣ ដងហើយនៅតែមិនព្រមលះបង់។***

## សិក្ខាបទទី ៧

### (ហាមដើរផ្លូវស្ងាត់តែម្នាក់ឯង)

ភិក្ខុនីដើរផ្លូវស្ងាត់ មានភ័យចំពោះមុខនៅក្នុងដែន ដោយពុំបានទៅជាមួយពួករទេះ ត្រូវពួកអ្នកលេងប្រទូស្តរ៉ាយ គួរជាទីតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលដើរផ្លូវដូច្នោះ។***

## សិក្ខាបទទី ៨

### (ហាមដើរផ្លូវដូចនោះក្រៅពីដែន)

សេចក្តីនៅក្នុងសិក្ខាបទនេះ ដូចសិក្ខាបទទី ៧ ដែរ ផ្សេងគ្នាត្រង់ដើរផ្លូវដូចនោះក្រៅពីដែន គឺចេញក្រៅចាករដ្ឋ (ដូចជាពីដែនកាសី ទៅកាន់ដែនមគធៈ) ។

## សិក្ខាបទទី ៩

### (ហាមចេញដើរក្នុងវស្សា)

ភិក្ខុនីចេញដើរក្នុងវស្សា គួរជាទីតិះដៀលនៃមនុស្សទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញតសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តដូច្នោះ។***

## សិក្ខាបទទី ១០

### (ហាមនៅមួយកន្លែងពេលចេញវស្សាហើយ)

ភិក្ខុនីនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ទាំងក្នុងរដូវរងា រដូវក្តៅក៏នៅជាប្រចាំក្នុងទីនោះ គួរជាទីតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលចាំវស្សារួចហើយ មិនរើចេញទៅកាន់ទីដទៃ សូម្បីមានចម្ងាយផ្លូវប្រមាណ ៥-៦ យោជន៍។***

## ចិត្តាគារវគ្គទី ៥ (ពោលអំពីអាគារដ៏វិចិត្រ)

### សិក្ខាបទទី ១

(ហាមទៅមើលវាំង និងអាគារដ៏វិចិត្រជាដើម)

មនុស្សទាំងឡាយនាំគ្នាទៅមើលអាគារដ៏វិចិត្រ (ដោយក្បាច់ក្បូរ) ក្នុងព្រះរាជឧទ្យានរបស់ព្រះបាទបសេនទិកោសល ឆព្វគ្គិយាភិក្ខុនី ក៏នាំគ្នាទៅមើល មានគេតិះដៀលថា ប្រព្រឹត្តដូចគ្រហស្ថ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលទៅមើលវាំងក្តី អាគារដ៏វិចិត្រក្តី ព្រៃក្តី សួនច្បារក្តី ស្រះទឹកក្តី។**

### សិក្ខាបទទី ២

(ហាមប្រើអាសន្ទិ និងបល្លង្ក)

ភិក្ខុនីប្រើអាសន្ទិ (ជើងម៉ាវែង) ខ្លះ បល្លង្ក (កៅអីទន់ញាត់ដោយរោមសត្វ) ខ្លះ មានគេតិះដៀលថា ប្រើរបស់ដូចគ្រហស្ថ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រើអាសន្ទិ និងបល្លង្ក (អាសន្ទិ កាត់ជើងចេញ, បល្លង្ក រុះរោមសត្វទន់ចេញ ប្រើបាន មិនត្រូវអាបត្តិ)។**

### សិក្ខាបទទី ៣

(ហាមខារអំបោះ)

ឆព្វគ្គិយាភិក្ខុនីខារអំបោះ មានគេតិះដៀលថា ធ្វើការដូចគ្រហស្ថ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលខារអំបោះ។**

### សិក្ខាបទទី ៤

(ហាមបម្រើគ្រហស្ថ)

ភិក្ខុនីធ្វើការខ្វល់ខ្វាយ (បម្រើ) ដើម្បីគ្រហស្ថ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ **ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុនីដែលបម្រើគ្រហស្ថ (ដូចជាដាំបាយ ឬគក់ចីវរ)។**

### សិក្ខាបទទី ៥

(ហាមទទួលសម្តីហើយមិនរម្ងាប់អធិករណ៍)

ថុល្លនន្ទាភិក្ខុនីទទួលពាក្យថា នឹងរម្ងាប់អធិករណ៍ ហើយបែរជា

មិនរម្ងាប់ មិនខ្វល់ខ្វាយដើម្បីរម្ងាប់ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលធ្វើដូច្នោះ កាលបើមិនមានហេតុរារាំង ។***

## សិក្ខាបទទី ៦

### (ហាមឱ្យរបស់បរិភោគដល់គ្រហស្ថជាដើមដោយដៃ)

ថុល្លនន្ទាភិក្ខុនីឲ្យរបស់ទំពាររបស់បរិភោគដោយដៃ ដល់អ្នកសំដែងល្ខោនខ្លះ អ្នករាំខ្លះ អ្នកលោតខ្លះ អ្នកលេងកលខ្លះ អ្នកលេងស្គរខ្លះ ដើម្បីឲ្យគេសរសើរខ្លួនក្នុងទីប្រជុំជន ។ ពួកនោះ ក៏នាំគ្នាសរសើរគ្រប់គ្នា មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលឱ្យរបស់ទំពា របស់បរិភោគដោយដៃរបស់ខ្លួនដល់គ្រហស្ថក្តី អ្នកបួសបុរសក្តី អ្នកបួសស្ត្រីក្តី ។***

## សិក្ខាបទទី ៧

### (ហាមប្រើសំពត់ស្លៀកសម្រាប់អ្នកមានរដូវលើស ៣ ថ្ងៃ)

ថុល្លនន្ទាភិក្ខុនី ប្រើសំពត់ស្លៀកសម្រាប់អ្នកមានរដូវហើយមិនលះចេញ (គឺមិនគក់ហើយផ្លាស់ឲ្យអ្នកដទៃប្រើខ្លះ)[៥១] ។

## សិក្ខាបទទី ៨

### (ហាមគ្រប់គ្រងលំនៅឋានជាប្រចាំ)

ថុល្លនន្ទាភិក្ខុនីមិនព្រមលះបង់លំនៅឋាន ហើយទៅកាន់ចារិកលំនៅឋាន ត្រូវភ្លើងឆេះ ពុំមាននរណាហានជួយជញ្ជូនរបស់របរចេញ ដោយខ្លាចក្រែងគេចោទថា ធ្វើឲ្យរបស់គេបាត់ ថុល្លនន្ទាភិក្ខុនី ត្រឡប់មកវិញសាកសួរដឹងដំណឹងហើយ ក៏ពោលទោសតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនី ដែលមិនព្រមលះបង់លំនៅឋានហើយទៅកាន់ចារិក (កាលបើទៅកាន់ទីដទៃ ត្រូវប្រគល់ទីលំនៅដល់ភិក្ខុនី ឬសិក្ខមានា ឬក៏សាមណេរី)។***

## សិក្ខាបទទី ៩

---

[៥១] សម័យនោះ សំពត់រកបានដោយលំបាក ទើបមានគេប្រគេនទុកជារបស់កណ្តាល សម្រាប់ប្រើចំពោះអ្នកមានរដូវ នៅពេលប្រើរួចហើយត្រូវគក់សម្អាតចេញ ហើយឲ្យអ្នកដទៃប្រើខ្លះ ។

### (ហាមរៀនតិរច្ឆានវិជ្ជា)

ឆព្វគ្គិយាភិក្ខុនីរៀនតិរច្ឆានវិជ្ជា (វិជ្ជាក្រៅសាសនាដែលពុំមានប្រយោជន៍) មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនី ដែលរៀនតិរច្ឆាន-វិជ្ជា ។***

## **អារាមវគ្គទី ៦** (ពោលអំពីអារាម)

### សិក្ខាបទទី ១

### (ហាមចូលវត្តដែលមានភិក្ខុនៅដោយពុំបានប្រាប់ជាមុន)

ភិក្ខុទាំងឡាយស្លៀកសំពត់មួយផ្ទាំង (មិនបានដណ្ដប់ចីវរ) កំពុងធ្វើចីវរនៅក្នុងវត្តដែលឋិតនៅក្បែរស្រុក ភិក្ខុនីមិនបានប្រាប់ជាមុន ចូលទៅក្នុងវត្ត (ជាការគួរឲ្យខ្មាស់អៀនដែលចូលទៅឃើញភិក្ខុស្លៀកតែស្បង់ ពុំបានដណ្ដប់ចីវរ) ។ ភិក្ខុទាំងនោះ នាំគ្នាតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ និងបញ្ញត្តបន្ថែមពីរលើកទៀត សរុបមានន័យថា ***ភិក្ខុនីដឹងហើយ មិនប្រាប់ (ជាមុន) ចូលទៅកាន់វត្តដែលមានភិក្ខុត្រូវបាចិត្តិយ ។***

### សិក្ខាបទទី ២

### (ហាមជេរបរិភាសភិក្ខុ)

ឆព្វគ្គិយាភិក្ខុនី ក្រោធខឹងនឹងកប្បិតកភិក្ខុដែលជាឧបជ្ឈាយ៍របស់ព្រះឧបាលី គិតចង់សម្លាប់ចោល រូបខ្លះនិយាយឲ្យព្រះឧបាលីស្ដាប់ ព្រះឧបាលីក៏ប្រាប់ឲ្យឧបជ្ឈាយ៍ជ្រាប ទើបកប្បិតកភិក្ខុសម្ងំលាក់ខ្លួន ពួកភិក្ខុនីនោះតាមសម្លាប់មិនបាន ក៏ក្រោធនឹងព្រះឧបាលីថាជាអ្នកប្រាប់ហើយក៏នាំគ្នាជេរបរិភាសលោក ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលជេរ បរិ-ភាសភិក្ខុ***[៥២] ។

### សិក្ខាបទទី ៣

---

[៥២] **អក្កោសេយ្យ** *(ជេរ)*, **បរិភាសេយ្យ** *(បរិភាស)* ។ *តាមសព្ទគួរមានន័យថាពាក្យថា* **ជេរ** *គឺជេរត្រង់ ៗ,* **បរិភាស** *គឺជេរដោយអម ប៉ុន្តែពាក្យអធិប្បាយខាងចុងសិក្ខាបទថា* **បរិភាស** *គឺនិយាយឲ្យគេខ្លាច ។*

(ហាមបរិភាសភិក្ខុនី)

ថុល្លនន្ទាភិក្ខុនីក្រោធខឹងនឹងភិក្ខុនីសង្ឃ ដែលសូត្រប្រកាសដាក់ឧក្ខេបនីយកម្ម (ដកចេញពីពួក) ដល់ចណ្ឌកាឡីភិក្ខុនី ដោយសារមិនឃើញអាបត្តិ ក៏ជេរបរិភាសភិក្ខុនីសង្ឃថា "ភិក្ខុនីទាំងអស់នេះជាមនុស្សល្ងង់ខ្លៅ មិនដឹងធម៌ មិនដឹងទោសរបស់កម្ម កម្មវិបត្តិ ឬកម្មសម្បត្តិ"[៥៣]

*ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ**ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលបរិភាសភិក្ខុនីសង្ឃ ។***

## សិក្ខាបទទី ៤

### (ហាមឆាន់ទៀតនៅពេលទទួលនិមន្ត ឬ លើកឆាន់ហើយ)

ព្រាហ្មណ៍ម្នាក់ និមន្តភិក្ខុនីជាច្រើនរូបទៅឆាន់, រូបខ្លះឆាន់រួចហើយ មិនទទួលអាហារដែលគេថែមឲ្យទៀត ក៏ទៅកាន់ត្រកូលញាតិ, រូបខ្លះទទួលបិណ្ឌបាតហើយក៏ចេញទៅ ។ ព្រាហ្មណ៍នោះដឹងហើយក៏ពោលទោសតិះដៀល ដោយការអាក់អន់ចិត្តថា ខ្ញុំពុំអាចប្រគេនអាហារតាមសេចក្តីត្រូវការ ឬយ៉ាងណា ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុនីទទួលនិមន្តហើយ ឬមិនទទួលអាហារដែលគេថែមឲ្យទៀត ទំពាក្តី ឆាន់ក្តី នូវរបស់ទំពា ឬរបស់ឆាន់ ត្រូវបាចិត្តិយ ។

## សិក្ខាបទទី ៥

### (ហាមនិយាយរារាំងភិក្ខុនីដទៃ)

ភិក្ខុនីទៅបិណ្ឌបាតតាមច្រកមួយកន្លែង នៅក្នុងក្រុងសាវត្ថី ម្ចាស់ផ្ទះនិមន្តឆាន់អាហារ រួចហើយឲ្យប្រាប់ភិក្ខុនីដទៃនិមន្តមកខ្លះផង នាងគិតរារាំង ទើបនិយាយជាមួយភិក្ខុនីដទៃថា ទីនោះមានសុនខ (ឆ្កែ) កាច មានគោកាច ជាកន្លែងស្មោគគ្រោក កុំទៅឡើយ ។ ក្រោយមកបែករឿង ពីព្រោះភិក្ខុនីរូបនោះទៅតាមច្រកនោះ បានទទួលនិមន្តឲ្យឆាន់ហើយត្រូវគេសួរថា ហេតុដូចម្តេច ទើបភិក្ខុនីទាំងឡាយមិននិមន្តមក កាលបើគេបានដឹងរឿងហើយ ក៏នាំគ្នាតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលកំណាញ់ត្រកូល*** (គឺនិយាយរារាំងមិនឲ្យ

---

*[៥៣] ពាក្យថា **បរិភាស** ទីនេះ សំដែងច្បាស់ថា ជាការជេរដោយអម, ពាក្យថា **កម្ម** សំដៅយកសង្ឃកម្ម គឺកម្មដែលជាកិច្ចការរបស់សង្ឃ, **កម្មវិបត្តិ** គឺសង្ឃកម្មដែលមិនសម្បូរ, **កម្មសម្បត្តិ** គឺសង្ឃកម្មដែលសម្បូរត្រឹមត្រូវ ។*

ភិក្ខុនីដទៃទៅកាន់ត្រកូល ឬក្លែងនិយាយតិះដៀលភិក្ខុនីផងគ្នាឲ្យគេស្តាប់ ដើម្បីបានទទួលនិមន្តតែម្នាក់ឯង) ។

## សិក្ខាបទទី ៦

### (ហាមចាំវស្សាក្នុងអាវាសដែលពុំមានភិក្ខុ)

ភិក្ខុនីចាំវស្សាក្នុងអាវាសដែលពុំមានភិក្ខុ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយ ដល់ភិក្ខុនីចាំវស្សាក្នុងអាវាសដែលពុំមានភិក្ខុ ។***

(កត់សម្គាល់ៈ ពាក្យអធិប្បាយខាងចុងសិក្ខាបទអាងថា ធ្វើឲ្យពុំបានស្តាប់ឱវាទ និងពុំបាននៅរួម ។ ពាក្យថា នៅរួម មានន័យថា ធ្វើកម្មរួមគ្នា រៀនរួមគ្នា សិក្សារួមគ្នា ។ ហេតុផលមួយទៀតដែលឲ្យភិក្ខុនីនៅក្នុងវត្តមានភិក្ខុ គឺដើម្បីការពារ ការគំរាមកំហែងអំពីជនដទៃ) ។

## សិក្ខាបទទី ៧

### (ហាមអាក់ខានបវារណាក្នុងសំណាក់សង្ឃទាំងពីរ)

ភិក្ខុនីជាច្រើនរូបចាំវស្សារួចហើយ មិនបវារណាចំពោះភិក្ខុសង្ឃ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីចាំវស្សារួចហើយ មិនបវារណាក្នុងសំណាក់សង្ឃទាំងពីរ (ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ) ដោយឋានៈ ៣ គឺ ដោយបានឃើញ ឮ និងរង្កៀស ត្រូវបាចិត្តិយ*** (បវារណា គឺការអនុញ្ញាតឲ្យនិយាយដាស់តឿនគ្នាបាន) ។

## សិក្ខាបទទី ៨

### (ហាមការអាក់ខានស្តាប់ឱវាទ និងការនៅរួមគ្នា)

ឆព្វគ្គិយាភិក្ខុនីមានឆព្វគ្គិយាភិក្ខុនីដទៃមកឲ្យឱវាទហើយ ក៏មិនព្រមទៅស្តាប់ជាមួយភិក្ខុនីទាំងឡាយ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីមិនទៅស្តាប់ឱវាទ មិននៅរួមគ្នា ត្រូវបាចិត្តិយ*** (ការនៅរួម គឺរួមសាមគ្គីធ្វើកម្ម ឬសិក្សារួមគ្នាជាមួយភិក្ខុនីឯទៀត) ។

## សិក្ខាបទទី ៩

### (ហាមការអាក់ខានសួរឧបោសថ និងការទៅស្តាប់ឱវាទ)

ភិក្ខុនីមិនសួរថ្ងៃឧបោសថ មិនទៅស្តាប់ឱវាទ មានគេ

តិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា *ភិក្ខុនីត្រូវប្រាថ្នាធម៌ ២ យ៉ាងអំពីភិក្ខុសង្ឃរៀងរាល់កន្លះខែ គឺការសួរថ្ងៃឧបោសថ និងការចូលទៅដើម្បីស្តាប់ឱវាទ បើឱ្យកន្លងផុតថ្ងៃនោះទៅ ត្រូវបាចិត្តិយ ។*

## សិក្ខាបទទី ១០

(ហាមឱ្យបុរសស្ទាប វះ ឬជួសបុសជាដើម)

ភិក្ខុនីមួយរូប នៅតែពីនាក់ជាមួយបុរស ឲ្យបុរសស្ទាបបូសដែលកើតនៅត្រង់ភ្លៅ "បសាខា" (ក្រោមផ្ចិតចុះទៅ លើជង្គង់ឡើងមក) បុរសនោះ ព្យាយាមរំលោភនាង ក៏ស្រែកឡើង ព្រះមានព្រះភាគទ្រង់ជ្រាបទើបបញ្ញត្តសិក្ខាបទថា *ភិក្ខុនីមិនប្រាប់សង្ឃ ឬគណៈជាមុន នៅតែពីនាក់ជាមួយបុរស ឱ្យស្ទាបក្តី ឱ្យវះ ឬជួសក្តី ឱ្យលាងក្តី ឱ្យរុំសំពត់ក្តី ឱ្យស្រាយសំពត់ក្តី នូវបូស ឬដំបៅដែលកើតឡើងត្រង់ភ្លៅ "បសាខា" ត្រូវបាចិត្តិយ ។*

## គព្ភិនីវគ្គទី ៧ (វគ្គពោលអំពីស្ត្រីមានគភ៌)

## សិក្ខាបទទី ១

(ហាមបំបួសស្ត្រីមានគភ៌)

ភិក្ខុនីឲ្យស្ត្រីមានគភ៌បួស នាងចេញទៅបិណ្ឌបាត មនុស្សទាំងឡាយនិយាយថា ចូរឲ្យចង្ហាន់ដល់នាងចុះ ពីព្រោះនាងមានគភ៌ចាស់ហើយ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា *ភិក្ខុនីឱ្យស្ត្រីមានគភ៌បួស ត្រូវបាចិត្តិយ ។*

## សិក្ខាបទទី ២

(ហាមបំបួសស្ត្រីមានកូននៅមិនទាន់ផ្តាច់ដោះ)

ភិក្ខុនីឲ្យស្ត្រីមានកូនដែលនៅមិនទាន់ផ្តាច់ដោះបួស នាងចេញទៅបិណ្ឌបាត មនុស្សទាំងឡាយនិយាយថា ចូរឲ្យចង្ហាន់ដល់នាងចុះ ពីព្រោះនាងមានគ្នាពីរនាក់ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា *ភិក្ខុនីឱ្យស្ត្រីមានកូនដែលនៅមិនទាន់ផ្តាច់ដោះ បួស ត្រូវបាចិត្តិយ* (ស្រីដូចនេះ សំដៅយកទាំងម្តាយទារក និងអ្នកមើលទារក ឬមេដោះ) ។

## សិក្ខាបទទី ៣

### (ហាមបំបួសសិក្ខមានាដែលនៅសិក្សាមិនទាន់គ្រប់ ២ ឆ្នាំ)

ភិក្ខុនីឲ្យបំបួសសិក្ខមានាដែលនៅសិក្សាធម៌ ៦ យ៉ាង[៥៤] មិនទាន់គ្រប់ ២ ឆ្នាំនៅឡើយ នាងក៏ជាមនុស្សល្ងង់ មិនឆ្លាត មិនដឹងវត្ថុដែលគួរ ឬមិនគួរ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់ត្រាស់ពន្យល់វិធីដែលសិក្ខមានាសុំសិក្ខាសម្មតិ (ការសូត្រប្រកាសឲ្យការសិក្សា) អំពីភិក្ខុនីសង្ឃ និងការសូត្រសន្មតរបស់ភិក្ខុនីសង្ឃរហូតដល់ការបន្ទឺវាចាសមាទាន និងការមិនប្រព្រឹត្តកន្លងធម៌ ៦ យ៉ាង។ ក្រោយមក ទើបទ្រង់បញ្ញត្តសិក្ខាបទថា *ភិក្ខុនីបំបួសសិក្ខមានាដែលសិក្សាធម៌ ៦ យ៉ាងគ្រប់ ២ ឆ្នាំហើយ តែសង្ឃនៅមិនទាន់បានសូត្រសម្មតិ ត្រូវបាចិត្តិយ។*

## សិក្ខាបទទី ៤

### (ហាមបំបួសសិក្ខមានាដែលសង្ឃមិនបានសូត្រសន្មត)

ភិក្ខុនីបំបួសសិក្ខមានាដែលបានសិក្សាក្នុងធម៌ ៦ យ៉ាង គ្រប់ ៣ ឆ្នាំហើយ តែសង្ឃនៅមិនទាន់បានសូត្រសន្មត មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់សំដែងវិធីដែលសិក្ខមានា សិក្សាគ្រប់ ២ ឆ្នាំហើយ គប្បីចូលទៅរកភិក្ខុនីសង្ឃដើម្បីសុំវុដ្ឋានសម្មតិ (ការសូត្រប្រកាស សំដែងសេចក្ដីយល់ឃើញត្រូវក្នុងការបំបួសបាន) រួចហើយទ្រង់ក៏បញ្ញត្តសិក្ខាបទថា *ភិក្ខុនីបំបួសសិក្ខមានាដែលបានសិក្សាធម៌ ៦ យ៉ាង គ្រប់ ២ ឆ្នាំហើយ តែសង្ឃនៅ មិនទាន់បានសូត្រសន្មត ត្រូវបាចិត្តិយ។*

[៥៤] ធម៌ ៦ យ៉ាង គឺ សីល ៥ និងការមិនបរិភោគអាហារក្នុងវេលាវិកាល។ ម្យ៉ាងទៀត ចំពោះសីលទី ៣ វៀរចាកការប្រព្រឹត្តកន្លងព្រហ្មចារីយ៍។

## សិក្ខាបទទី ៥

### (ហាមបំបួសស្ត្រីមានប្ដីហើយ តែអាយុនៅតិចជាង ១២ ឆ្នាំ)

ភិក្ខុនីឲ្យស្ត្រីដែលមានស្វាមីហើយបួស តែអាយុនៅមិនទាន់ដល់ ១២ ឆ្នាំ នាងមិនចេះអត់ធន់ចំពោះរងា ក្ដៅ ឃ្លាន ស្រេក របោម មូស ខ្យល់ កំដៅថ្ងៃ សត្វវារលូន ពាក្យជ្រុលជ្រួស និងទេវនាដ៏ក្លា ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា *ភិក្ខុនីឱ្យស្ត្រីដែលមានស្វាមីហើយបួស តែអាយុនៅមិនទាន់ដល់ ១២ ឆ្នាំ ត្រូវបាចិត្តិយ។*

## សិក្ខាបទទី ៦

(ហាមបំបួសស្ត្រីអាយុគ្រប់ ១២ ឆ្នាំដូចនោះ តែនៅមិនទាន់បានសិក្សាគ្រប់ ២ ឆ្នាំ)

## សិក្ខាបទទី ៧

(ហាមបំបួសស្ត្រីដូចនោះដែលសិក្សាគ្រប់ ២ ឆ្នាំហើយ ) តែសង្ឃនៅពុំទាន់បានសូត្រសម្មតិ

*ទាំងពីរសិក្ខាបទនេះ មានន័យស្រដៀងគ្នានឹងសិក្ខាបទទី ៣ និងទី ៤ ដែរ គឺត្រូវសុំសិក្ខាសម្មតិ និងវុដ្ឋានសម្មតិអំពីភិក្ខុនីសង្ឃជាមុនសិន ទើបបួសបាន បើបំបួសទាំងដែលមានគុណសម្បត្តិ មិនសម្បូរបែប ត្រូវបាចិត្តិយ ។*

## សិក្ខាបទទី ៨

(ហាមព្រងើយមិនអនុគ្រោះចំពោះសិស្សដែលបួសហើយ)

*ថុល្លនន្ទាភិក្ខុនីឲ្យសហជីវិនី (សទ្ធិវិហារិក គឺបុគ្គលដែលឧបជ្ឈាយ៍ ឬបវត្តិនីបំបួសឲ្យ) បួសហើយ មិនសង្គ្រោះដោយខ្លួនឯង ឬឲ្យអ្នកដទៃសង្គ្រោះ (ដោយការបង្រៀនធម៌ ការសួរនាំការឲ្យឱវាទ) ឲ្យគ្រប់ ២ ឆ្នាំ នាងក៏ជាមនុស្សល្ងង់ មិនឆ្លាត មិនដឹងវត្ថុដែលគួរ ឬមិនគួរ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីជាឧបជ្ឈាយ៍ (បវត្តិនី) ដែលប្រព្រឹត្តដូច្នោះ ។***

## សិក្ខាបទទី ៩

(ហាមភិក្ខុនីបែកចេញពីឧបជ្ឈាយ៍ មុនគ្រប់ ២ ឆ្នាំ)

*ភិក្ខុនីទាំងឡាយ ពុំបាននៅជាប់តាម[៥៥] បវត្តិនី (ឧបជ្ឈាយ៍) គឺអ្នកបំបួសឲ្យគ្រប់ ២ ឆ្នាំ ក៏ក្លាយជាមនុស្សល្ងង់ មិនឆ្លាត មិនដឹងវត្ថុដែលគួរ និងមិនគួរ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីជាសហជីវិនី (សទ្ធិវិហារិក) ដែលប្រព្រឹត្តដូច្នោះ ។***

## សិក្ខាបទទី ១០

---

[៥៥] *ពាក្យថា* ***មិនជាប់តាម*** *នេះ ពាក្យខាងចុងសិក្ខាបទសំដៅយកការមិនបម្រើលោក ។ គប្បីសង្កេតថា ភិក្ខុនីបួសហើយត្រូវជាប់តាមបម្រើឧបជ្ឈាយ៍ ដើម្បីទទួលបានការសិក្សា និងការមើលថែទាំគ្រប់ ២ ឆ្នាំ, សម្រាប់ភិក្ខុវិញត្រូវកាន់និស្ស័យ គឺនៅក្រោមការមើលថែទាំអំពីឧបជ្ឈាយ៍ ឬអាចារ្យ ៥ ឆ្នាំ ។*

(ហាមព្រងើយដោយពុំនាំសិស្សទៅកាន់ទីដទៃ)

*ថុល្លនន្ទាភិក្ខុនីបំបួសសហជីវិនី (សទ្ធិវិហារិក) រួចហើយ ពុំបាននាំទៅកាន់ទីដទៃ ពុំបានប្រើគេឲ្យនាំទៅកាន់ទីដទៃ ប្ដី (របស់ភិក្ខុនីនោះ) មកទទួលយកទៅ (គឺបបួលឲ្យសឹកទៅ) មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីបំបួសសហជីវិនីរួចហើយ មិននាំទៅកាន់ទីដទៃ ដោយហោចទៅសូម្បីត្រឹមតែ ៥-៦ យោជន៍ ត្រូវបាចិត្តិយ ។***

## កុមារីភូតវគ្គ

(វគ្គពោលអំពីក្មេងស្រីមិនទាន់មានប្ដី)

### សិក្ខាបទទី ១

(ហាមបំបួសក្មេងស្រីអាយុមិនគ្រប់ ២០ ឆ្នាំ)

*ភិក្ខុនីទាំងឡាយ ឲ្យក្មេងស្រីមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំបួស នាងពុំចេះអត់ធន់ចំពោះរងា ក្ដៅ ឃ្លាន ស្រេកជាដើមបាន មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីឱ្យក្មេងស្រីអាយុតិចជាង ២០ ឆ្នាំបួស ត្រូវបាចិត្តិយ ។***

*(កត់សម្គាល់ៈ គប្បីសង្កេតថា ស្រីដែលមានប្ដីហើយអាយុគ្រប់ ១២ ឆ្នាំ បួសជាភិក្ខុនី ត្រូវនៅជាសិក្ខមានា សិក្សាអស់ ២ ឆ្នាំទៀត រហូតដល់អាយុគ្រប់ ១៤ ឆ្នាំបរិបូរណ៍ ទើបបួសជាភិក្ខុនីបាន ប៉ុន្តែបើនៅមិនទាន់មានប្ដី ត្រូវមានអាយុគ្រប់ ២០ ឆ្នាំទើបបួសបាន មុននឹងបួសជាភិក្ខុនីត្រូវនៅជាសិក្ខមានា អស់ ២ ឆ្នាំដូចគ្នា ដូច្នេះ ស្ត្រីដែលមានបំណងបួសជាភិក្ខុនី កាលបើមានអាយុគ្រប់ ២០ ឆ្នាំបរិបូរណ៍ហើយ ត្រូវបួសជាសាមណេរីនិងនៅជាសិក្ខមានាមុនអាយុគ្រប់ ដើម្បីពុំចាំបាច់ពន្យា ពេលនៅជាសិក្ខមានា ពេលដែលមានអាយុគ្រប់ហើយ) ។*

### សិក្ខាបទទី ២

(ហាមបំបួសស្ត្រីមានអាយុគ្រប់ តែមិនទាន់សិក្សាគ្រប់ ២ ឆ្នាំ)

### សិក្ខាបទទី ៣

(ហាមបំបួសស្ត្រីដែលសិក្សាគ្រប់ ២ ឆ្នាំហើយ )
តែសង្ឃមិនទាន់បានសន្មត

*ទាំងពីរសិក្ខាបទនេះ មានន័យទំនងដូចគ្នានឹងសិក្ខាបទទី ៣*

ទី ៨ ទី ៦ និងទី ៧ នៃគព្ភិនីវគ្គដែលពោលរួចមកហើយដែរ គ្រាន់តែនាំមកប្រើក្នុងករណីជាស្រីក្រមុំមានអាយុគ្រប់ ២០ ឆ្នាំ មានសិទ្ធិអាចបួសបាន តែត្រូវឲ្យសិក្សាជាមុន លុះសិក្សាហើយត្រូវឲ្យសង្ឃសូត្រសន្មតអនុញ្ញាតឲ្យឧបសម្ប័ទជាមុនសិន ។

## សិក្ខាបទទី ៤

### (ហាមធ្វើជាឧបជ្ឈាយ៍ បើវស្សាមិនគ្រប់ ១២)

*ភិក្ខុនីមានវស្សាមិនគ្រប់ ១២ ឲ្យអ្នកដទៃបួស ។ ខ្លួនឯង ក៏នៅល្ងង់ មិនឆ្លាត មិនដឹងវត្ថុដែលគួរ និងមិនគួរ ។ សូម្បីសទ្ធិ-វិហារិនី (បុគ្គលដែលខ្លួនបំបួសឲ្យ ប្រែតាមសព្ទថា អ្នកនៅរួម) ក៏ជាបុគ្គលល្ងង់ខ្លៅ មិនឆ្លាត មិនដឹងវត្ថុដែលគួរ និងមិនគួរ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីមានវស្សាតិចជាង ១២ ឱ្យអ្នកដទៃបួសត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ៥

### (ហាមធ្វើជាឧបជ្ឈាយ៍ដោយសង្ឃពុំបានសម្មតិ)

*ភិក្ខុនីមានវស្សាគ្រប់ ១២ ហើយ តែសង្ឃនៅមិនទាន់បានសម្មតិ (តែងតាំង) ឲ្យបុគ្គលដទៃបួស មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីមានវស្សាគ្រប់ ១២ ហើយ តែសង្ឃនៅមិនទាន់បានសម្មតិ ឱ្យអ្នកដទៃបួស ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ៦

### (ហាមយល់ព្រមហើយតិះដៀលជាខាងក្រោយ)

*ចណ្ឌកាឡីភិក្ខុនីចូលទៅរកភិក្ខុនីសង្ឃ សុំឲ្យតែងតាំងជាឧបជ្ឈាយ៍ ភិក្ខុនីសង្ឃពិចារណាហើយមិនអនុញ្ញាត (ពីព្រោះយល់ឃើញថា នៅពុំទាន់សមគួរ) នាងក៏ទទួលថា "សាធុ" ក្រោយមកភិក្ខុនីសង្ឃតែងតាំងភិក្ខុនីដទៃឲ្យធ្វើជាឧបជ្ឈាយ៍ ទើបចណ្ឌកាឡីភិក្ខុនីដើរនិយាយដើម (តិះដៀល) ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីដែលសង្ឃនៅមិនទាន់អនុញ្ញាតឱ្យធ្វើជាឧបជ្ឈាយ៍ ទទួលពាក្យថាសាធុហើយ ក្រោយមកត្រឡប់តិះដៀល ត្រូវបាចិត្តិយ*** *(សិក្ខាបទនេះ ឲ្យអំណាចភិក្ខុនីសង្ឃ ពិចារណាបុគ្គលដែលត្រូវធ្វើជាឧបជ្ឈាយ៍ផង សូម្បីមានវស្សាគ្រប់ ១២ ហើយ ទោះបីពុំបានតែងតាំងសូត្រសម្មតិឲ្យក៏បាន) ។*

## សិក្ខាបទទី ៧

### (ហាមនិយាយថាបំបួសឱ្យហើយត្រឡប់ជាមិនបំបួសឱ្យ)

ថុល្លនន្ទាភិក្ខុនីយល់ព្រមជាមួយសិក្ខមានាម្នាក់ថា បើឲ្យចីវរយើងនឹងបំបួសឲ្យ ហើយត្រឡប់ជាមិនបំបួសឲ្យ មិនខ្វល់ខ្វាយឲ្យបុគ្គលដទៃបំបួសឲ្យ ទើបព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីនិយាយជាមួយសិក្ខមានាថា បើអ្នកឱ្យចីវរដល់យើង[៥៦] ៗ នឹងបំបួសឱ្យ ហើយក្រោយមកមិនមានហេតុរារាំង មិនបំបួសឱ្យដោយខ្លួនឯងក្តី មិនខ្វល់ខ្វាយឱ្យអ្នកដទៃបំបួសឱ្យក្តី ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ៨

### (ហាមយល់ព្រមហើយមិនបំបួសឱ្យក្នុងរឿងដទៃ)

ថុល្លនន្ទាភិក្ខុនីយល់ព្រមជាមួយសិក្ខមានាម្នាក់ថា បើនៅជាមួយគ្រប់ ២ ឆ្នាំនឹងបំបួសឲ្យ ហើយមិនបំបួសឲ្យ មិនខ្វល់ខ្វាយ ឲ្យអ្នកដទៃបំបួសឲ្យ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីនិយាយជាមួយសិក្ខមានាថា បើនៅជាមួយ (បម្រើ) យើងគ្រប់ ២ ឆ្នាំហើយ យើងនឹងបំបួសឱ្យ ក្រោយមកពុំមានហេតុរារាំង មិនបំបួសឱ្យខ្លួនឯងក្តី មិនខ្វល់ខ្វាយឱ្យគេបំបួសឱ្យក្តី ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ៩

### (ហាមបំបួសសិក្ខមានាដែលប្រព្រឹត្តមិនល្អ)

ថុល្លនន្ទាភិក្ខុនី បំបួសសិក្ខមានាដែលជាអ្នកឡេះឡោះ ជាមួយបុរស និងក្មេងកម្លោះ ជាមនុស្សអាក្រក់ បង្កភាពសៅហ្មងចិត្តដល់អ្នកដទៃ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីបំបួសសិក្ខមានា ដែលជាអ្នកឡេះឡោះជាមួយបុរស និងក្មេងកម្លោះ ជាមនុស្សអាក្រក់ បង្កសេចក្តីសៅហ្មងចិត្តដល់អ្នកដទៃ ត្រូវបាចិត្តិយ (បុរស គឺមនុស្សមានអាយុគ្រប់ ២០ ហើយ, កុមារ ឬក្មេងកម្លោះ គឺអ្នកដែលមានអាយុមិនដល់ ២០)។***

## សិក្ខាបទទី ១០

### (ហាមបំបួសសិក្ខមានាដែលមាតាបិតា ឬប្តីមិនអនុញ្ញាតឱ្យ)

---

[៥៦] មានផ្លូវសន្និដ្ឋានបាន ២ ប្រការ គឺនិយាយខាងរឿងសំណូក ឬរបស់តបស្នងយ៉ាងណាមួយ ម្យ៉ាងទៀត និយាយសំដៅយកឲ្យតែរកចីវរបានមក នឹងបំបួសឲ្យ គឺពុំមែនទទួលទុកជារបស់ខ្លួន ពីព្រោះជាប្រពៃណីដែលអ្នកសុំបួសត្រូវប្រគល់ចីវរដល់ឧបជ្ឈាយ៍ ហើយឧបជ្ឈាយ៍ធ្វើពិធីប្រគល់ឲ្យក្នុងពេលបួស ។

ថុល្លនន្ទាភិក្ខុនី បំបួសឲ្យសិក្ខមានាដែលមាតាបិតាពុំទាន់បានអនុញ្ញាតខ្វះ ប្តីមិនទាន់បានអនុញ្ញាតខ្វះ មាតាបិតាផង ប្តីផង ក៏នាំគ្នាតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីបំបួសសិក្ខមានាដែលមាតាបិតា ឬប្តីមិនទាន់អនុញ្ញាតឱ្យ ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ១១

### (ហាមធ្វើឡេះឡោះក្នុងការបំបួស)

ថុល្លនន្ទាភិក្ខុនី គិតថានឹងបំបួសសិក្ខមានា ទើបនិមន្តភិក្ខុដែលជាថេរៈទាំងឡាយមកប្រជុំគ្នា លុះឃើញរបស់ទំពាររបស់ឆាន់មានច្រើន ក៏និយាយថា “ខ្ញុំមិនទាន់បំបួសសិក្ខមានាទេ” ហើយក៏បញ្ជូនភិក្ខុជាថេរៈទាំងនោះឲ្យត្រឡប់ទៅវិញ និមន្តភិក្ខុទេវទត្តជាដើម (រួម ៥ រូប សុទ្ធតែជាភិក្ខុបក្ករៀនច្រើន) មកប្រជុំគ្នា បំបួសសិក្ខមានា មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រព្រឹត្តធ្វើដូចនោះ***[៥៧] ។

[៥៧] ច្បាប់បារាំងប្រែពាក្យថា ***បារិវាសិកឆន្ទទានេន*** ទៅក្នុងរឿងពេញចិត្តភិក្ខុដែលនៅបរិវាស (ក្នុងការចេញពីអាបត្តិ) តែពាក្យអធិប្បាយខាងចុងសិក្ខាបទនិងអដ្ឋកថាបំណងប្រែទៅក្នុងរឿងធ្វើឲ្យភិក្ខុដែលមកប្រជុំពេលមុន ត្រូវរំសាយ ។

## សិក្ខាបទទី ១២

### (ហាមបំបួសមនុស្សរាល់ឆ្នាំ)

សម័យនោះ ភិក្ខុនីបំបួសក្មេងស្រីរៀងរាល់ឆ្នាំ កន្លែងស្នាក់នៅមិនល្មមគ្រាន់ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលបំបួសក្មេងស្រី រៀងរាល់ឆ្នាំ (ត្រូវបំបួសរំលងឆ្នាំ)*** ។

## សិក្ខាបទទី ១៣

### (ហាមបំបួសក្នុងមួយឆ្នាំពីរនាក់)

សម័យនោះ ភិក្ខុនីបំបួសក្នុងមួយឆ្នាំពីរនាក់ កន្លែងស្នាក់នៅមិនគ្រប់គ្រាន់ (សល់កន្លែង) មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនី ដែលបំបួសក្នុងមួយឆ្នាំពីរនាក់*** ។

# ឆត្តុបាហនវគ្គទី ៩

(ពោលអំពីឆត្រ និងស្បែកជើង)

## សិក្ខាបទទី ១

(ហាមប្រើឆត្រ និងស្បែកជើង វៀរតែមិនស្រួល)

សម័យនោះ ឆព្វគ្គិយាភិក្ខុនីប្រើឆត្រ និងស្បែកជើង មនុស្សទាំងឡាយនាំគ្នាតិះដៀលថា ប្រើរបស់ដូចគ្រហស្ថអ្នកបរិភោគកាម ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីប្រើឆត្រ និងស្បែកជើង ត្រូវបាចិត្តិយ។*** ក្រោយមក ទ្រង់អនុញ្ញាតឲ្យប្រើបាន បើមានអាពាធ ឬបើមិនប្រើទេ ពុំស្រួល ។

## សិក្ខាបទទី ២

(ហាមទៅដោយយាន វៀរតែមិនស្រួល)

ឆព្វគ្គិយាភិក្ខុនីទៅដោយយាន មនុស្សទាំងឡាយតិះដៀលថា ធ្វើដូចគ្រហស្ថអ្នកបរិភោគកាម ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីទៅដោយយាន ត្រូវបាចិត្តិយ។*** ក្រោយមក ទ្រង់អនុញ្ញាតឲ្យទៅដោយយានបាន បើមិនស្រួល ។

(កត់សម្គាល់ៈ ទាំងពីរសិក្ខាបទនេះ សំដែងឲ្យឃើញថា ដើម្បីមិនឲ្យដំណិះថា ធ្វើដូចគ្រហស្ថ ជាការបញ្ញត្តតាមកាលៈទេសៈ និងបរិស្ថាន ។ មកដល់សម័យនេះ ការវង្វៀសដូចនោះ គង់មានការផ្លាស់ប្តូរ ។ សិក្ខាបទទាំងអស់នេះ ទើបតាំងមាំនៅក្នុងប្រទេស ដែលព្រះអង្គអនុញ្ញាតទុកមុននឹងបរិនិព្វានថា បើដកសិក្ខាបទតូចតាចចេញ ជាការបើកឱកាសឲ្យដល់កាលៈទេសៈ តែសាវ័កសម័យសង្គាយនាយល់ថា បើបណ្ដោយឲ្យដកតាមទំនើងចិត្ត នឹងបង្កឲ្យមានបញ្ហាច្រើន គឺអាចទៅដកសិក្ខាបទសំខាន់ៗបាន ដោយយល់ថា មិនសំខាន់ ដូច្នេះហើយ ទើបលោកសូត្រប្រកាសហាមដក ជាការប្រើអំណាចសង្ឃដើម្បីទប់ស្កាត់) ។

## សិក្ខាបទទី ៣

(ហាមប្រើសំពត់កំបិត)

*ភិក្ខុនីត្រូវគ្រកូលដែលខ្លួនចូលទៅឆាន់ អង្វរឲ្យជួយនាំសំពត់ "សង្ឃាណី"[៥៨] (សំពត់តូចខ្លី តែវែងល្មមស្លៀកបិទទ្រគាកបាន ពេលស្លៀកហើយ មើលទៅហាក់ដូចជាសំពត់កំប៉ិត បារាំង*

---

[៥៨] អដ្ឋកថាសម្ដែងថា មានលក្ខណៈជាគ្រឿងឡាសំណាញ់ប៉ាក់ផ្កា អំបោះធ្លាក់ ផ្កាឈើធ្លាក់រោយរាយ ទើបសន្និដ្ឋានថាជាគ្រឿងប្រដាប់ចង្កេះ តែអ្នកខ្លះប្រែពាក្យ

*ហៅថា* Lion-cloth *គឺសំពត់បិទទ្រគាក សំដែងរូបជនជាតិឥណ្ឌា ស្លៀកសំពត់ដូចនេះឲ្យមើលផង)» ទៅឲ្យស្រ្តីម្នាក់ទៀត ភិក្ខុនីនោះគិតថា បើដាក់បាត្រនាំទៅក្រែងលោពុំសម ទើបស្លៀកទៅ ខណៈពេលទៅដល់ផ្លូវ ក៏ដាច់អំបោះ សំពត់ក៏ធ្លាក់ចុះមកខ្លៀក ត្រូវគេតិះដៀលថា ប្រើសំពត់ស្លៀកដូចគ្រហស្ថ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ* ***ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុនីដែលប្រើសំពត់សង្ឃាណី ។***

## សិក្ខាបទទី ៤

### (ហាមប្រើគ្រឿងប្រដាប់កាយស្ត្រី)

*ឆព្វគ្គិយាភិក្ខុនី ប្រើគ្រឿងប្រដាប់កាយស្ត្រី (គ្រឿងប្រដាប់ក្បាល ក ដៃ ជើង និងចង្កេះ) មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីប្រើគ្រឿងប្រដាប់កាយសម្រាប់ស្ត្រី ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ៥

### (ហាមងូតទឹកក្រអូប និងទឹកមានពណ៌)

*ឆព្វគ្គិយាភិក្ខុនី ងូតដោយទឹកក្រអូប និងទឹកមានពណ៌ (អាចប្រើជ្រលក់កាយបាន) មានគេតិះដៀលថា ធ្វើដូចគ្រហស្ថដែលបរិភោគកាម ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីងូតដោយទឹកក្រអូប និងទឹកមានពណ៌ ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ៦

### (ហាមងូតទឹកដោយម្សៅល្ងអប់)

*ឆព្វគ្គិយាភិក្ខុនី ងូតទឹកដោយម្សៅដែលធ្វើដោយល្ងអប់ក្លិន មានគេតិះដៀលថា ធ្វើដូចគ្រហស្ថបរិភោគកាម ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា* ***ភិក្ខុនីងូតទឹកដោយម្សៅល្ងអប់ក្លិន ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ៧

### (ហាមឱ្យភិក្ខុនីលាបប្រេង និងគក់ច្របាច់)

---

*នេះថា* Petticoat *ឬសំពត់ហ្សីបស្ត្រី, កាលបើប្រៀបធៀបមើលសិក្ខាបទតទៅទៀតឃើញថា ជាគ្រឿងប្រដាប់ចង្កេះ ។*

សម័យនោះ ភិក្ខុនីឲ្យភិក្ខុនីផងគ្នាលាបប្រេងខ្លះ គក់ច្របាច់ខ្លះ មានគេតិះដៀលថា ធ្វើដូចគ្រហស្ថបរិភោគកាម ទើបព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីឱ្យភិក្ខុនីផងគ្នាលាបប្រេង ឬគក់ច្របាច់ ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ៨-៩-១០

### (ហាមឱ្យអ្នកដទៃលាបប្រេង ឬ គក់ច្របាច់)

សិក្ខាបទទាំង ៣ នេះ ក៏ដូចសិក្ខាបទទី ៧ ដែរ គ្រាន់តែផ្សេងអ្នកលាបប្រេង និងគក់ច្របាច់ ក្នុងសិក្ខាបទទី ៨ ជាសិក្ខមានា សិក្ខាបទទី ៩ ជាសាមណេរី និងសិក្ខាបទទី ១០ ជាគិហិនី (គ្រហស្ថជាស្ត្រី) ។

## សិក្ខាបទទី ១១

### (ហាមអង្គុយពីមុខភិក្ខុដោយមិនបានប្រាប់ជាមុន)

សម័យនោះ ភិក្ខុនីទាំងឡាយមិនបានអាបុច្ឆា[៥៩] អង្គុយលើអាសនៈពីមុខភិក្ខុ មានគេតិះដៀល ទើបព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីមិនបានអាបុច្ឆា (សុំឱកាស) អង្គុយលើអាសនៈពីមុខភិក្ខុ ត្រូវបាចិត្តិយ ។***

## សិក្ខាបទទី ១២

### (ហាមសួររឿងភិក្ខុដោយពុំសុំឱកាស)

សម័យនោះ ភិក្ខុនីសួរបញ្ហាភិក្ខុដែលខ្លួនពុំបានសុំឱកាស មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ***ភិក្ខុនីសួររឿងភិក្ខុដែលខ្លួនពុំបានសុំឱកាស ត្រូវបាចិត្តិយ*** (ជាទំនៀមនៃការគោរពគ្នាទៅវិញទៅមក) ។

## សិក្ខាបទទី ១៣

### (ហាមចូលស្រុកដោយមិនប្រើវត្ថពន្ធចង្កេះ និងវត្ថពន្ធទ្រូង)

ភិក្ខុនីចូលស្រុក មិនមានសំពត់សង្កច្ចិកៈ (សំពត់ចងចង្កេះ និងសំពត់រុំដោះ គឺប្រើបិទតាំងពីក្រឡុកកចុះទៅ និងតាំងពីផ្ចិតឡើងមក) មនុស្សទាំងឡាយនាំគ្នាចោមរោមគន់មើលរូបឆោម ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុនីមិនប្រើសំពត់សង្កច្ចិកៈ (វត្ថពន្ធចង្កេះ ឬវត្ថពន្ធទ្រូង) ចូលទៅក្នុងស្រុក (កំណត់តាំងអំពី

---

[៥៩] តាមសព្ទប្រែថា សួរដោយអើពើ តាមន័យ គឺសុំឱកាស ឬសុំអនុញ្ញាត ។

ព្រំប្រទល់របងចូលទៅ) ត្រូវបាចិត្តិយ ។

(កត់សម្គាល់ៈ បាចិត្តិយរបស់ភិក្ខុនីទាំងអស់មាន ១៦៦ សិក្ខាបទ តែសំដែងទុកក្នុងភិក្ខុនីវិភង្គមានត្រឹមតែ ៩៦ សិក្ខាបទ ចែកចេញជា ៩ វគ្គ, ៧ វគ្គដំបូង ក្នុងមួយវគ្គមាន ១០ សិក្ខាបទ, ២ វគ្គក្រោយ ក្នុងមួយវគ្គមាន ១៣ សិក្ខាបទ និងបាននាំយកបាចិត្តិយរបស់ភិក្ខុមកប្រើ ៧០ សិក្ខាបទ (៩៦+៧០=១៦៦) គឺបាចិត្តិយរបស់ភិក្ខុមាន ៩២ សិក្ខាបទ នាំយកចេញ ២២ សិក្ខាបទ ចំពោះសិក្ខាបទដែលពុំចាំបាច់សម្រាប់ភិក្ខុនី, ២២ សិក្ខា-បទ ដែលមិនទាក់ទងនឹងភិក្ខុនី គឺ ឱវាទវគ្គទី ៣ រួមទាំងអស់ ១០ សិក្ខាបទ, ភោជនវគ្គទី ៥ ចំពោះសិក្ខាបទទី ៣, ៥, ៦ និងទី ៩ រួម ៤ សិក្ខាបទ, អចេលកវគ្គទី ៥ ចំពោះសិក្ខាបទទី ១; សប្បាណកវគ្គទី ៧ ចំពោះសិក្ខាបទទី ៤, ៥ និងទី ៧ រួម ៣ សិក្ខាបទ, រតនវគ្គទី ៩ ចំពោះសិក្ខាបទទី ១, ៣, ៧ និងទី ៩ រួម ៤ សិក្ខាបទ, រួមទាំងអស់មាន ២២ សិក្ខាបទ) ។

## ៥.បាដិទេសនីយកណ្ឌ

(ពោលអំពីអាបត្តិបាដិទេសនីយ ៨)

## សិក្ខាបទទី ១

(ហាមសុំភោជនប្រណីត ៨ យ៉ាង តាមលំដាប់សិក្ខាបទមកឆាន់)

ន័យនៅក្នុងសិក្ខាបទទាំង ៨ នេះដូចគ្នា ផ្សេងគ្នាតែរបស់សុំ ៨ យ៉ាង តាមលំដាប់សិក្ខាបទ គឺភិក្ខុនីមិនមានអាពាធ សុំរបស់ទាំងអស់នេះមកបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ គឺ

១. ទឹកដោះថ្លា

២. ប្រេង

៣. ទឹកឃ្មុំ

៤. ទឹកអំពៅ

៥. ត្រី

៦. សាច់

៧. ទឹកដោះស្រស់

៨. ទឹកដោះជូរ (រៀងលំដាប់សិក្ខាបទតាមលំដាប់របស់) ។

(កត់សម្គាល់ៈ អាបត្តិបាដិទេសនីយៈ ប្រែថា អាបត្តិត្រូវសំដែងចេញទាំង ៨ សិក្ខាបទនេះ ពុំមានលាយឡំជាមួយរបស់ភិក្ខុឡើយ ។ម្យ៉ាងទៀត របស់បរិភោគទាំង ៨ យ៉ាងដែលហាមសុំយកមកឆាន់ពេលមិនមានជម្ងឺនេះ ធ្លាប់បានហៅនៅក្នុងសិក្ខាបទរបស់ភិក្ខុថា ភោជនប្រណីតមាន ៩ យ៉ាង ដោយបន្ថែមទឹក

ដោះខាប់ (**នវនីតំ**) ចូលទៅក្នុងលំដាប់ទី ២ ហើយរៀងសិក្ខាបទដទៃទុកក្នុងលំដាប់បន្ទាប់ទៅ តាមន័យនេះ ទើបខ្ទះទឹកដោះខាប់តែម្យ៉ាង ពីព្រោះអាចមកពីពុំមានអ្នកណាធ្វើជាតួយ៉ាង ទើបមិនបញ្ញត្តសិក្ខាបទក៏ថាបាន) ។

## ៩.សេក្ខិយកណ្ឌ

(ពោលអំពីវត្ត និងមារយាទដែលភិក្ខុនីត្រូវសិក្សា)

ក្នុងព្រះត្រៃបិដកហៅថា **សេក្ខិយធមិ** គឺធម៌ដែលត្រូវសិក្សារបស់ភិក្ខុនី គង់មានតែ ៧៥ សិក្ខាបទដូចភិក្ខុដែរ គ្រាន់តែសំដែងដើមរឿងទុក ២ សិក្ខាបទ ដែលឆព្វគ្គិយាភិក្ខុនីស្លៀកដណ្តប់មិនជាបរិមណ្ឌល និងបន្ទោបង់ខច្ចារៈខ្ទះ បស្សាវៈខ្ទះ ស្តោះទឹកមាត់ក្នុងទឹកខ្ទះ ជាហេតុឲ្យទ្រង់បញ្ញត្តសិក្ខាបទឡើង ដែលមាននៅក្នុងសិក្ខាបទរបស់ភិក្ខុស្រាប់ហើយ ។

## ៧.អធិករណសមថៈ

(ពោលអំពីធម៌សម្រាប់រម្ងាប់អធិករណ៍ ៧ យ៉ាង)

ទាំង ៧ សិក្ខាបទនេះ ក៏ដូចសិក្ខាបទរបស់ភិក្ខុដែរ ។

## សរុបសីលរបស់ភិក្ខុនី

| ឈ្មោះ | របស់ភិក្ខុនី | យករបស់ភិក្ខុមកប្រើ | រួមមាន |
|---|---|---|---|
| បារាជិក | ៤ | ៥ | ៨ |
| សង្ឃាទិសេស | ១០ | ៧ | ១៧ |
| និស្សគ្គិយបាចិត្តិយៈ | ១២ | ១៨ | ៣០ |
| បាចិត្តិយៈ | ៩៦ | ៧០ | ១៦៦ |
| បាដិទេសនីយៈ | ៨ | - | ៨ |
| សេក្ខិយៈ | - | ៧៥ | ៧៥ |
| អធិករណសមថៈ | - | ៧ | ៧ |
| រួមទាំងអស់ | ១៣០ | ១៨១ | ៣១១ |

## វិនយបិដកភាគទី ៦

## ឈ្មោះ មហាវគ្គ

ពាក្យថា **មហាវគ្គ** ប្រែថា វគ្គធំ, ពីព្រោះបញ្ចុះន័យនៅក្នុងព្រះត្រៃបិដកច្រើនដល់ទៅ ២ ភាគ គឺភាគទី ៦ និងទី ៧ ។ ចំពោះនៅក្នុងភាគទី ៦ នេះ ចែកចេញជាពួក ឬវគ្គសំខាន់ ហៅថា “**ខន្ធកៈ**” រួមមាន ៤ ខន្ធកៈ ឬ ៤ វគ្គ គឺ

**១.មហាខន្ធកៈ** (ពួកធំ ឬវគ្គធំ) និយាយអំពីហេតុការណ៍តាំងអំពីត្រាស់ដឹង រហូតដល់សំដែងបឋមទេសនា, សំដែងអនត្តលក្ខណសូត្រ, សំដែងធម៌ប្រោសយសកុលបុត្រព្រមទាំងគ្រួសារ និងមិត្តសម្លាញ់, សំដែងធម៌ប្រោសភទ្ទវគ្គិយកុមារ ៣០ នាក់, សំដែងអាទិត្តបរិយាយសូត្រប្រោសជដិល ១០០០ នាក់, សំដែងធម៌ប្រោសព្រះបាទពិម្ពិសារ, សារីបុត្រ និងមោគ្គល្លានចេញបួស ឧបជ្ឈាយវត្ត (កិច្ចបដិបត្តិចំពោះអ្នកបំបួសឲ្យ), សទ្ធិវិហារិកវត្ត (កិច្ចបដិបត្តិចំពោះសិស្សដែលខ្លួនបំបួសឲ្យ), ការបណ្តេញចេញ, ការសុំខមាទោស, ការបំបួសដោយញត្តិចតុត្ថកម្មវាចា, ការប្រាប់និស្ស័យ ៤, អាចរិយវត្ត (កិច្ចបដិបត្តិចំពោះអាចារ្យ), អន្តេវាសិកវត្ត (កិច្ចបដិបត្តិចំពោះភិក្ខុដែលត្រូវជាសិស្សនៅក្នុងការគ្រប់គ្រងរបស់ខ្លួន), ការរម្ងាប់និស្ស័យ, បុគ្គលគួរឲ្យបួស, ការទូន្មានអន្យតិរ្ថិយ៍មុនបំបួស, ភណ្ឌុកម្ម, ការខ្វះគុណសម្បត្តិក្នុងការបួស, ការបំបួសសាមណេរ, សិក្ខាបទ និងការដាក់ទោសសាមណេរ, ការហាមបំបួសបុគ្គល, វិធីការឧបសម្ប័ទ និងរឿងភិក្ខុដែលត្រូវសង្ឃដាក់ទោស ពីព្រោះមិនឃើញកំហុស (អាបត្តិ) ។

**២.ឧបោសថខន្ធកៈ** (ពួក ឬវគ្គ ពោលអំពីឧបោសថ) និយាយដល់ការស្តាប់ធម៌, ការសូត្របាដិមោក្ខក្នុងថ្ងៃឧបោសថ, ការសម្មតិសីមា, ការសម្មតិរោងឧបោសថ, រឿងសីមា, ការសូត្របាដិមោក្ខសង្ខេប, ការអនុញ្ញាតឲ្យរៀនបក្ខគណនា, ចំណែកអង្គប្រកបដទៃទៀត ក្នុងការបដិបត្តិមុនសូត្របាដិមោក្ខ ការរាប់ថ្ងៃឧបោសថ និងបុគ្គលដែលមិនអនុញ្ញាតឲ្យធ្វើឧបោសថ ។

**៣.វស្សូបនាយិកាខន្ធកៈ** (ពួក ឬវគ្គ ពោលអំពីថ្ងៃចូលវស្សា) ការចាំវស្សា, ថ្ងៃចូលវស្សា ២ យ៉ាង, ការបន្ទិតថ្ងៃចូលវស្សាឲ្យជិតឡើង, ការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ, អន្តរាយរបស់ភិក្ខុចាំវស្សា, ការចាំវស្សាក្នុងទីផ្សេងៗ និងអាបត្តិទុក្កដ ពីព្រោះទទួលពាក្យហើយ មិនធ្វើតាមពាក្យដែលទាក់ទងនឹងការចាំវស្សា ។

**៤.បវារណាខន្ធកៈ** (ពួក ឬវគ្គ ពោលអំពីការបវារណា គឺការអនុញ្ញាតឲ្យភិក្ខុដទៃដាស់តឿនបាន) ពោលអំពីសេចក្តីលម្អិតផ្សេងៗ ដែលគប្បីជ្រាប និងគប្បីបដិបត្តិទាក់ទងនឹងការចាំវស្សា ។

នេះជាន័យសង្ខេបនៃព្រះត្រៃបិដក ភាគទី ៦-៧ មហាវគ្គ វិនយបិដក ។

## ន័យពិស្តារ

## ១.មហាខន្ធកៈ (ពួកធំ)

ព្រះមានព្រះភាគត្រាស់ដឹងថ្មីៗ ប្រថាប់គង់ក្រោមដើមពោធិ៍ក្បែរមាត់ស្ទឹងនេរញ្ជរា ក្នុងតំបន់ឧរុវេលា ។ ព្រះអង្គប្រថាប់គង់សោយវិមុត្តិសុខក្រោមដើមពោធិ៍អស់ ៧ ថ្ងៃ។ ក្នុងបឋមយាមនៃរាត្រី ***ទ្រង់ពិចារណាបដិច្ចសមុប្បាទ*** (ធម៌កើតឡើង ព្រោះអាស្រ័យហេតុបច្ច័យ) ខាងការកើតឡើង ហើយទ្រង់បន្លឺឧទាន ដោយន័យថា កាលបើធម៌ប្រាកដដល់ព្រាហ្មណ៍អ្នកសម្លឹងពិនិត្យពិចារណា គេរមែងអស់សេចក្តីសង្ស័យ ពីព្រោះបានដឹងធម៌ព្រមទាំងហេតុ ។ ក្នុងមជ្ឈិមយាមនៃរាត្រី ***ទ្រង់ពិចារណាបដិច្ចសមុប្បាទ*** ខាងការរលត់ ហើយទ្រង់បន្លឺឧទាន ដោយន័យថា កាលបើធម៌ប្រាកដដល់ព្រាហ្មណ៍អ្នកមានសេចក្តីព្យាយាម សម្លឹងពិនិត្យពិចារណា គេរមែងអស់សេចក្តីសង្ស័យ ពីព្រោះបានដឹងដល់ការអស់ទៅនៃបច្ច័យ ។ ក្នុងបច្ឆិមយាមនៃរាត្រី ***ទ្រង់ពិចារណាបដិច្ចសមុប្បាទទាំងអនុលោម*** (តាមលំដាប់) និង ***បដិលោម*** (បញ្ច្រាស់លំដាប់) ហើយទ្រង់បន្លឺឧទាន ដោយន័យថា កាលបើធម៌ប្រាកដដល់ព្រាហ្មណ៍អ្នកមានព្យាយាមសម្លឹងពិនិត្យពិចារណា ព្រាហ្មណ៍នោះ តែងកម្ចាត់នូវមារព្រមទាំងសេនាបាន ដូចដួងអាទិត្យធ្វើឲ្យលោកភ្លឺស្វាងដូច្នោះ ។

## ទ្រង់ផ្ចាញ់ផ្ចាលព្រាហ្មណ៍ដែលចូលចិត្តនិយាយគំហក

កាលបើគ្រប់ ៧ ថ្ងៃហើយ ទ្រង់ចេញពីសមាធិនោះ ស្តេចចេញអំពីក្រោមដើមពោធិ៍ យាងទៅកាន់អជបាលនិគ្រោធ (ដើមជ្រៃដែលក្មេងចិញ្ចឹមពពែចូលចិត្តនាំគ្នាមកលេង) ប្រថាប់គង់សោយវិមុត្តិសុខ ក្រោមដើមឈើនោះអស់ ៧ ថ្ងៃ។ មានព្រាហ្មណ៍ដែលចូលចិត្តនិយាយគំហកអ្នកដទៃម្នាក់ មកចូលគាល់ ទូលសួរដល់ធម៌ដែលធ្វើបុគ្គលឲ្យក្លាយជាព្រាហ្មណ៍ ទ្រង់បន្លឺឧទាន ដោយន័យថា បុគ្គលឈ្មោះថាជាព្រាហ្មណ៍ គឺជាអ្នកបណ្តែតចោលនូវបាប មិនគំហកដាក់អ្នកដទៃ មិនមានកិលេសដូចទឹកអម្ចត់ សង្រួមខ្លួន ចេះចប់ត្រៃវេទ ប្រព្រឹត្តព្រហ្មចរិយៈចប់បរិបូរណ៍ហើយ មិនរីកប៉ោង[៦០] (ឆ្មើងឆ្មៃ) ។

## ទ្រង់បន្លឺឧទានក្បែរដើមជ្រៃក្រឹម

លុះគ្រប់ ៧ ថ្ងៃហើយ ទ្រង់ចេញពីសមាធិនោះ ស្តេចចេញពីដើមអជបាលនិគ្រោធ យាងទៅកាន់ដើមជ្រៃក្រឹម ប្រថាប់គង់សោយវិមុត្តិសុខក្រោមដើមជ្រៃក្រឹមនោះអស់ ៧ ថ្ងៃ។ មាន

[៦០] អដ្ឋកថាកែថា ការរីកប៉ោងមាន ៥ យ៉ាង គឺប៉ោងព្រោះរាគៈ, ទោសៈ, មោហៈ, មានះ និងទិដ្ឋិ ។

ពពកខ្មៅធំខុសរដូវកាល មានភ្លៀងធ្លាក់ជោគជាំ លាយឡំដោយខ្យល់ត្រជាក់អស់ ៧ ថ្ងៃ។ ពញានាគ ឈ្មោះថា មុចលិន្ទ មកវុំពទ្ធបាំងព្រះវរកាយព្រះអង្គដល់ទៅ ៧ ផ្នត់ ដើម្បីការពារត្រជាក់ក្តៅ របោម មូសជាដើម ។ ទ្រង់បន្លឺឧទានប្រារព្ធសុខ ៤ ប្រការ **គឺសុខព្រោះស្ងាត់, សុខព្រោះមិនបៀតបៀន, សុខព្រោះប្រាសចាករាគៈ ឈានកន្លងចាកកាមបាន** និងប្រការចុងក្រោយ **សុខដ៏កំពូល គឺលះបង់ការប្រកាន់ខ្លួនបាន** ។

## ហេតុការណ៍នៅក្បែរដើមរាជាយតនៈ

លុះគ្រប់ ៧ ថ្ងៃហើយ ទ្រង់ចេញពីសមាធិនោះ ស្តេចចេញពីដើម (ជ្រៃក្រឹម) យាងទៅកាន់ដើមរាជាយតនៈ (ដើមកែស) ប្រថាប់គង់សោយវិមុត្តិសុខក្រោមដើមឈើនោះអស់ ៧ ថ្ងៃ។ មានពួកឈ្មួញពីរនាក់ ឈ្មោះថា តបុស្សៈ និងភល្លិកៈ ធ្វើដំណើរមកពីឧក្កលជនបទ ថ្វាយសដូវដុំ និងសដូវដង់ ទ្រង់ទទួលដោយបាត្រ ដែលស្តេចចាតុម្មហារាជិកាបានថ្វាយ ហើយទ្រង់សោយនូវបាយនោះ ។ ពួកឈ្មួញទាំងពីរបានប្តេជ្ញាខ្លួនជាឧបាសក ដល់ព្រះពុទ្ធ និងព្រះធម៌ជាសរណៈ ឈ្មោះថា ជាឧបាសកដំបូងបំផុត ក្នុងលោក ដែលបន្លឺវាចាដល់រតនៈ ២ (គឺព្រះពុទ្ធ និងព្រះធម៌) ។

## ស្តេចយាងត្រឡប់ទៅកាន់ដើមជ្រៃវិញ

គ្រប់ ៧ ថ្ងៃហើយ ទ្រង់ចេញពីសមាធិនោះ ស្តេចចេញពីដើមកែស យាងទៅកាន់ដើមជ្រៃដែលក្មេងឃ្វាលពពែចូលចិត្តមកសម្រាកនៅទីនោះ (ដើមអជបាលនិគ្រោធ) និងប្រថាប់គង់នៅក្រោមដើមជ្រៃនោះ ទ្រង់ពិចារណាឃើញថា ធម៌ដែលព្រះអង្គត្រាស់ដឹងមានជម្រៅណាស់ អ្នកដទៃលំបាកនឹងត្រាស់ដឹងបាន ទើបទ្រង់បង្អោនព្រះទ័យទៅក្នុងការមិនសំដែងព្រះធម៌ ។

## ព្រហ្មមកអារាធនា

ស្តេចសហម្បតីព្រហ្មបានជ្រាបព្រះពុទ្ធតម្រិះ ទើបចុះមកទូលអារាធនាឲ្យទ្រង់សំដែងធម៌ សំអាងហេតុផលថា បុគ្គលដែលមានកិលេសតិច ល្មមអាចដឹងព្រះធម៌បាន ក៏មាន។ ព្រះមានព្រះភាគទ្រង់ពិចារណាមើលសត្វលោក ដោយប្រៀបធៀបផ្កាឈូក ៣ ប្រភេទ គឺ ដុះនៅក្រោមទឹក, ដុះស្មើនឹងទឹក និងដុះផុតពីទឹកទៅនឹងបុគ្គល ៣ ប្រភេទ (ដែលអាចត្រាស់ដឹងបាន ចំណែកប្រភេទទី

៤ គឺផ្កាឈូកដែលមិនសង្ឃឹមថាអាចនឹងដុះផុតពីទឹកបាន ប្រៀបធៀប ទៅនឹងបុគ្គលដែលពុំមានសង្ឃឹមថា អាចនឹងត្រាស់ដឹងបាន) ទើបទ្រង់បង្អោនព្រះទ័យទៅដើម្បីសំដែងធម៌ ។ ទ្រង់ប្រារព្ធអាឡារតាបស កាលាមគោត្រ ក៏ជ្រាបថា អស់អាយុជីវិតកន្លងទៅបាន ៧ ថ្ងៃហើយ ទ្រង់ប្រារព្ធឧទ្ទកតាបសរាមបុត្រ ក៏ជ្រាបថា អស់ជីវិតទៅ កាលពីម្សិលមិញនេះឯង ទើបទ្រង់បង្អោនព្រះទ័យ យាងទៅប្រោសបញ្ចវគ្គិយ (ពួក ៥) ដែលនៅក្នុងព្រៃឥសិបតនមិគទាយវ័ន នៅតាមផ្លូវទ្រង់ជួបឧបកាជីវក បានដោះវាទៈជាមួយអាជីវកនោះ តែឧបកៈមិនស្ដាប់តាម ។

## ទ្រង់សំដែងធម៌លើកតម្បូង

កាលស្ដេចយាងដល់ព្រៃឥសិបតនមិគទាយវ័ន ក្រុងពារាណសីហើយ តម្បូងឡើយ ភិក្ខុបញ្ចវគ្គិយសំដែងអាការក្រអឺតក្រទម តែកាលបើទ្រង់ទូន្មានឲ្យរំពឹងដល់រឿងថា កាលពីមុន តថាគតពុំធ្លាប់បានត្រាស់ថា ត្រាស់ដឹងឡើយ ឥឡូវនេះ តថាគតត្រាស់ដឹងហើយ ទើបគួរតាំងចិត្តស្ដាប់ ក៏នាំគ្នាតាំងចិត្តស្ដាប់ ។ ទើបព្រះមានព្រះភាគទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ មានន័យសំខាន់ គឺ

១.ទ្រង់បង្ហាញផ្លូវខុស បានដល់ កាមសុខល្លិកានុយោគ (ការប្រកបខ្លួនឲ្យជប់ងុលនៅក្នុងកាម) និងអត្តកិលមថានុយោគ (ការប្រកបខ្លួនឲ្យលំបាក) ថា ជាទីបំផុតនៃទិសដៅដែលអ្នកបួសត្រូវធ្វើដំណើរទៅ ហើយទ្រង់សំដែងមជ្ឈិមាបដិបទា (ខបដិបត្តិកណ្ដាល) បានដល់ មគ្គមានអង្គ ៨ ថា ព្រះអង្គត្រាស់ដឹងហើយ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

២.ទ្រង់សំដែងអរិយសច្ច ៤ គឺ ទុក្ខ, ហេតុឲ្យកើតទុក្ខ, ការរំលត់ទុក្ខ និងខបដិបត្តិឲ្យដល់ទីរំលត់ទុក្ខ ដោយពិស្ដារ ។

៣.ទ្រង់សំដែងថា ទ្រង់ដឹងអរិយសច្ចទាំង ៤, ទ្រង់ដឹងកិច្ចដែលគួរធ្វើក្នុងអរិយសច្ចទាំង ៤ និងទ្រង់ដឹងថា ទ្រង់ធ្វើកិច្ចនេះចប់ហើយ ទើបទ្រង់ដឹងច្បាស់ក្នុងព្រះទ័យថា បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណហើយ (បានន័យថា ទ្រង់បដិបត្តិ រហូតដល់បានសម្រេចផលដោយខ្លួនព្រះអង្គ ហើយនៅពេលចប់ព្រះធម៌ទេសនា ព្រះកោណ្ឌញ្ញៈបានធម្មចក្ខុ[៦១] ហើយក៏បានសុំបួស ។ ក្រោយមកព្រះវប្បៈជាមួយព្រះភទ្ទិយៈ ស្ដាប់ព្រះធម៌ទេសនាបានធម្មចក្ខុហើយ ក៏បានសុំបួស ។ ក្រោយមកទៀត ព្រះមហានាម និងព្រះអស្សជិស្ដាប់ព្រះធម៌ទេសនា បានធម្មចក្ខុហើយ ក៏សុំបួសដែរ គឺបានបួសទាំង ៥ រូប ។

---

[៦១] ជាសោតាបន្ន គឺព្រះអរិយបុគ្គលលំដាប់តម្បូងក្នុងព្រះពុទ្ធសាសនា ។

## ទ្រង់សំដែងអនត្តលក្ខណសូត្រ

បន្ទាប់មក ទើបព្រះមានព្រះភាគទ្រង់សំដែងអនត្តលក្ខណ-សូត្រដល់ភិក្ខុបញ្ចវគ្គិយនោះ មានន័យសំខាន់ គឺ

១.រូប (រាងកាយ), វេទនា (ការដឹងនូវសុខ ទុក្ខ ឬព្រងើយៗ), សញ្ញា (ការចាំបាន គ្រឿងសម្គាល់), សង្ខារ (ការគិត ឬចេតនា) និងវិញ្ញាណ (ការដឹងអារម្មណ៍តាមភ្នែក ត្រចៀកជាដើម) ពុំមែនខ្លួនៗ បើជាតួខ្លួន ក៏អាចបង្គាប់ឲ្យជាយ៉ាងនេះយ៉ាងនោះបាន ពីព្រោះពុំមែនខ្លួន ទើបបង្គាប់បញ្ជាមិនបាន ។

២.ហើយត្រាស់សួរឲ្យឆ្លើយជាបទៗ ទៅថា ខន្ធ ៥ (មានរូបជាដើមនោះ) ទៀង ឬមិនទៀង? ឆ្លើយថា មិនទៀង, របស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ? ឆ្លើយថា ជាទុក្ខ, របស់ណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា គួរយល់ថា នោះជារបស់យើងៗ ជារបស់នោះៗ ជាតួខ្លួនរបស់យើង? ឆ្លើយថា មិនគួរ ។

៣.ត្រាស់សរុបថា ព្រោះហេតុនោះ គួរឃើញដោយបញ្ញាដ៏ប្រពៃថា រូបជាដើមនោះ គ្រប់យ៉ាង ពុំមែនជារបស់យើងៗ ពុំមែនជារបស់នោះៗ ពុំមែនជាតួខ្លួនរបស់យើង ។

៤.ត្រាស់សំដែងផលថា អរិយសាវក ឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងរូបជាដើមនោះ កាលបើនឿយណាយក៏លះបង់តម្រេក ព្រោះលះបង់តម្រេកទើបរួចផុត កាលបើរួចផុត ក៏ដឹងថា រួចផុតហើយ, ដឹងថា ជាតិអស់ហើយ ប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ ធ្វើកិច្ចចប់បរិបូរណ៍ហើយ មិនត្រូវធ្វើកិច្ចអ្វីដើម្បីយ៉ាងនេះទៀតឡើយ ។ ភិក្ខុបញ្ចវគ្គិយមានចិត្តរួចផុតចាកអាសវៈ មិនប្រកាន់មាំដោយឧបាទាន ។ កាលនោះ មានព្រះអរហន្តក្នុងលោក ៦ អង្គ (រួមទាំងព្រះពុទ្ធផង) ។

## សំដែងធម៌ប្រោសយសកុលបុត្រ និងគ្រួសារ ព្រមទាំងមិត្តសំឡាញ់

យសកុលបុត្រ នឿយណាយនឹងជីវិតជាយរាវាស ប្រាថ្នាចេញចាកផ្ទះ ទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ក្នុងវេលាព្រលឹមស្រាងៗ បានជួបនឹងព្រះមានព្រះភាគ ស្ដាប់ព្រះធម៌ទេសនាបានធម្មចក្ខុ ។ សេដ្ឋីជាបិតាចេញតាមរក ជួបព្រះមានព្រះភាគស្ដាប់ព្រះធម៌ទេសនា ក៏បានធម្មចក្ខុ ប្រកាសខ្លួនជាឧបាសក ដល់

ព្រះរតនត្រៃ (ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ) ជាសរណៈអស់មួយជីវិត ឈ្មោះថា ជាឧបាសកតម្បូងបង្អស់ដែលដល់ព្រះរតនត្រៃ ។ ក្នុងខណៈដែលកំពុងស្ដាប់ព្រះធម៌ទេសនា ដែលទ្រង់សំដែងដល់សេដ្ឋីជាបិតា យសកុលបុត្រក៏បានត្រាស់ដឹងជាព្រះអរហន្ត ហើយក៏សុំបួស ។ កាលនោះ មានព្រះអរហន្តក្នុងលោក ៧ អង្គ ។ វេលាព្រឹកឡើងព្រះមានព្រះភាគព្រមដោយព្រះយស ស្ដេចយាងទៅឆាន់នៅឯផ្ទះសេដ្ឋីជាបិតា ទ្រង់សំដែងធម៌ប្រោសមាតា និងភរិយារបស់ព្រះយស ឲ្យបានធម្មចក្ខុ ប្រកាសខ្លួនជាឧបាសិកាដល់ព្រះរតនត្រៃអស់មួយជីវិត ឈ្មោះថា ជាឧបាសិកាតម្បូងបំផុតនៅក្នុងលោក ។ ក្រោយមកមានសំឡាញ់របស់ព្រះយស ៤ នាក់ និង ៥០ នាក់ទៀត តាមលំដាប់ បានមកស្ដាប់ព្រះធម៌ទេសនា សម្រេចជាព្រះអរហន្ត ទើបមានព្រះអរហន្តក្នុងលោក ៦១ អង្គ ។

## ទ្រង់បញ្ជូនសាវកទៅប្រកាសសាសនា

ទើបព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយ ឲ្យទៅប្រកាសព្រះសាសនា ដោយឲ្យទៅក្នុងទិសមួយតែមួយរូប កុំទៅជាមួយគ្នា ២ រូប ចំណែកព្រះអង្គវិញទ្រង់ត្រាស់ថា *តថាគតទៅសំដែងធម៌ក្នុងឧរុវេលាសេនានិគម ។*

## ទ្រង់អនុញ្ញាតការបព្វជ្ជាឧបសម្បទា

ភិក្ខុដែលទៅប្រកាសព្រះសាសនាទាំងអស់នោះ នាំកុលបុត្រដែលមានបំណងបព្វជ្ជាឧបសម្បទាមកគាល់ ដើម្បីឲ្យព្រះមានព្រះភាគទ្រង់បព្វជ្ជាឧសម្បទាឲ្យ បានទទួលនូវការលំបាក ទើបទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នាហើយ អនុញ្ញាតឲ្យភិក្ខុទាំងអស់នោះធ្វើកិច្ចការបំបួសដោយខ្លួនឯង ដោយឲ្យអ្នកដែលមានបំណងនឹងបួស ត្រូវកោរសក់ កោរពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់ដែលជ្រលក់ដោយទឹកអម្ចត់ ធ្វើចីវរឆៀងស្មាម្ខាង ក្រាបសំពះបាទាភិក្ខុទាំងឡាយ បញ្ចេញវាចាដល់ព្រះរតនត្រៃជាសរណៈគម្រប់ ៣ ដង ឈ្មោះថា ជាការបួសដោយការដល់សរណៈ ៣ (**តិសរណ-គមនូបសម្បទា**) ។

## ត្រាស់អនុត្តរវិមុត្តិ

កាលបើព្រះមានព្រះភាគទ្រង់គង់ចាំព្រះវស្សារួចហើយ ត្រាស់ទូន្មានភិក្ខុទាំងឡាយថា តថាគតបានពន្ទុះ បានធ្វើឲ្យជាក់ច្បាស់ហើយ

នូវការរួចផុតដ៏ប្រសើរ (អនុត្តរវិមុត្តិ) គឺការពិចារណាដោយឧបាយនៃបញ្ញា (យោនិសោមនសិការ) ការព្យាយាមដោយប្រពៃនៃបញ្ញា (យោនិសោ សម្មប្បធាន) សូម្បីអ្នកទាំងឡាយ ក៏បានពន្ទុះ បានធ្វើឲ្យជាក់ច្បាស់នូវការរួចផុតដ៏ប្រសើរ គឺការពិចារណាដោយឧបាយនៃបញ្ញា និងការព្យាយាមដោយប្រពៃនៃបញ្ញាដូចគ្នាដែរ ។

## ប្រោសសំឡាញ់ ៣០ នាក់

លុះគង់ប្រថាប់នៅក្នុងក្រុងពារាណសី ល្មមសមគួរដល់ព្រះអធ្យាស្រ័យហើយ ស្តេចក៏យាងទៅកាន់តំបន់ឧរុវេលា នៅតាមដងផ្លូវ ទ្រង់ក៏ចូលទៅសម្រាកព្រះកាយក្រោមដើមឈើមួយហើយ បានសំដែងធម៌ប្រោសភទ្ទវគ្គិយកុមារ ដែលត្រូវជាសំឡាញ់នឹងគ្នា ៣០ នាក់ ឲ្យបានធម្មចក្ខុ រួចក៏សុំបួស ព្រះអង្គក៏ប្រទានការបួសដោយ **ឯហិភិក្ខុឧបសម្បទា** (គឺត្រាស់ថា ចូរមកជាភិក្ខុចុះ) ។

## ប្រោសជដិល ៣ នាក់បងប្អូនព្រមទាំងបរិវារ

លុះស្តេចយាងទៅដល់តំបន់ឧរុវេលា ដែលជដិល ៣ នាក់បងប្អូន កំពុងតែអាស្រ័យនៅ គឺ ឧរុវេលាកស្សប នទីកស្សប និងគយាកស្សប តែក្នុងម្នាក់ៗ មានបរិវារ ៥០០ នាក់ ៣០០ នាក់ ២០០ នាក់ តាមលំដាប់ ។ លំដាប់ដំបូង គឺទ្រង់សុំសម្រាកនៅក្នុងបរិវេណអាស្រមរបស់ឧរុវេលាកស្សប ទ្រង់បានសំដែងបាដិហារ្យច្រើនយ៉ាង រហូតដល់ឧរុវេលាកស្សបជម្រុះទិដ្ឋិមានះ សុំបួសក្នុងព្រះពុទ្ធសាសនា កាលបើព្រះមានព្រះភាគត្រាស់ប្រាប់ឲ្យចេញចាកបរិវារសិន បរិវារក៏ស្ម័គ្រចិត្ត សុំបួសតាម ទើបបណ្តែតបរិក្ខារចុះទៅក្នុងទឹក សុំបួសព្រមគ្នា ព្រះមានព្រះភាគក៏ទ្រង់ប្រទានការបួសដោយឯហិភិក្ខុឧបសម្បទា (គឺត្រាស់ថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ) ។

នទីកស្សបត្រូវជាប្អូនទី ២ ឃើញបរិក្ខារអណ្តែតមកតាមទឹក ក៏គិតថា មានអន្តរាយដល់បងរបស់ខ្លួន ប៉ុន្តែ ពេលសាកសួរដឹងរឿងរ៉ាវសព្វគ្រប់ហើយ ក៏បណ្តែតបរិក្ខាររបស់ខ្លួន និងបរិវារហើយ សុំបួសទាំងអស់គ្នា ទំនងដូចបងប្រុសដែរ ។ ចំណែកគយាកស្សបឃើញបរិក្ខារអណ្តែតមក ក៏មានសេចក្តីសង្ស័យ កាលបើសាកសួរដឹងរឿងរ៉ាវសព្វគ្រប់ហើយ ក៏សុំបួសព្រមទាំងបរិវារដូចគ្នាដែរ ។

## ទ្រង់សំដែងអាទិត្តបរិយាយសូត្រ

កាលទ្រង់គង់ប្រថាប់នៅក្នុងតំបន់ឧរុវេលា ល្មមសមគួរដល់ព្រះអធ្យាស្រ័យហើយ ក៏ស្តេចយាងទៅកាន់តំបន់គយាសីសៈមួយអន្លើដោយភិក្ខុសង្ឃដែលធ្លាប់បួសជាជដិលជាច្រើន ។ នៅក្នុងទីនោះ ទ្រង់សំដែងអាទិត្តបរិយាយសូត្រ មានន័យថាៈ

១.ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត (ដែលជាអាយតនៈខាងក្នុង) ជារបស់ក្តៅ ។ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ (គឺអ្វីដែលប៉ះពាល់បានដោយកាយ) និងធម្មៈ (គឺអ្វីដែលដឹងបានដោយចិត្ត) (ដែលជាអាយតនៈខាងក្រៅ) ជារបស់ក្តៅ ។ វិញ្ញាណ គឺការដឹងអារម្មណ៍តាមទ្វារភ្នែក ត្រចៀក ច្រមុះជាដើម ជារបស់ក្តៅ ។ ផស្សៈ គឺការប៉ះខ្ទប់អារម្មណ៍តាមទ្វារភ្នែកជាដើម ជារបស់ក្តៅ ។ វេទនា គឺការសោយអារម្មណ៍ជាសុខជាទុក្ខ ឬមិនសុខមិនទុក្ខ ដែលកើតអំពីផស្សៈ តាមទ្វារភ្នែកជាដើម ជារបស់ក្តៅ ។ ក្តៅ ព្រោះភ្លើង គឺរាគៈ ទោសៈ មោហៈ, ក្តៅ ព្រោះការកើត ចាស់ ស្លាប់ សោយសោក កន្ទក់កន្ទេញ ការមិនសប្បាយកាយ ការមិនសប្បាយចិត្ត និងទោមនស្ស ។

២.កាលបើអរិយសាវកបានស្តាប់មក មានការយល់ឃើញដូចនេះ រមែងនឿយណាក្នុងភ្នែក ត្រចៀកជាដើម (ជាអាយតនៈខាងក្នុង) ។ រមែងនឿយណាយក្នុងរូប សំឡេងជាដើម (ជាអាយតនៈខាងក្រៅ) ។ រមែងនឿយណាយក្នុងវិញ្ញាណ មានការដឹងអារម្មណ៍តាមផ្លូវភ្នែកជាដើម ។ រមែងនឿយណាយក្នុងផស្សៈ មានការប៉ះខ្ទប់អារម្មណ៍តាមផ្លូវភ្នែកជាដើម ។ រមែងនឿយណាយក្នុងវេទនា មានការសោយអារម្មណ៍ដែលកើតអំពីចក្ខុសម្ផស្សជាដើម ។ កាលបើនឿយណាយហើយ ក៏លះបង់តម្រេកបាន ព្រោះការលះបង់តម្រេក ក៏រួចផុត កាលបើរួចផុត វិញ្ញាណក៏ដឹងថា រួចផុតហើយ ។ ដឹងថា មិនមានកំណើត ប្រព្រឹត្តព្រហ្មចរិយៈរួចរាល់ហើយ បានធ្វើកិច្ចចប់ហើយ មិនមានកិច្ចដទៃដែលត្រូវធ្វើឲ្យក្រៃលែងជាងនេះទៀតឡើយ ។

ផលនៃការសំដែងព្រះធម៌ទេសនានេះ ភិក្ខុមួយពាន់រូបមានចិត្តរួចផុតចាកអាសវៈ មិនប្រកាន់មាំដោយឧបាទាន ។

## ប្រោសព្រះបាទពិម្ពិសារ

កាលទ្រង់គង់ប្រថាប់នៅក្នុងតំបន់គយាសីសៈ ល្មមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទើបស្តេចយាងទៅកាន់ក្រុងរាជគ្រឹះមួយអន្លើដោយភិក្ខុសង្ឃដែលធ្លាប់ជាជដិលច្រើនពាន់រូប ប្រថាប់គង់នៅត្រង់ចេតិយដែលប្រតិស្ឋានទុកល្អហើយ ក្នុងសួនត្នោតជំទង់ ។ ព្រះបាទពិម្ពិសារជាកំពូលមេទ័ពដែនមគធៈ ព្រមទាំង

ព្រាហ្មណ៍គហបតី អ្នកដែនមគធៈចំនួន ១២ នហុត[៦២] បានព្រះកិត្តិនាមរបស់ព្រះមានព្រះភាគ ទើបស្ដេចយាងទៅគាល់ព្រះអង្គ ។ ជាតម្បូង ព្រះមានព្រះភាគទ្រង់ឲ្យឧរុវេលាកស្សប ប្រកាសប្រាប់រឿងរ៉ាវដែលខ្លួនលះបង់លទ្ធិដើម ហើយចូលមកបួស ដោយមានហេតុផលយ៉ាងណាៗ ដើម្បីទម្លាយទិដ្ឋិមានះ របស់បុគ្គលបាបជាមុនសិន ទើបទ្រង់សំដែងអនុបុព្វីកថា (សំដែងពីរឿងទាន, សីល, ឋានសួគ៌, ទោសនៃកាម និងអានិសង្សនៃការចេញចាកកាម ដោយលំដាប់) រួចមកទើបទ្រង់សំដែងអរិយសច្ច ៤ ព្រះបាទពិម្ពិសារ ព្រមទាំងព្រាហ្មណ៍ គហបតី ១១ នហុត បានធម្មចក្ខុ (ព្រះសោតាបន្ន) ។

ព្រះបាទពិម្ពិសារ ក្រាបទូលរឿងដែលទ្រង់សមតាមព្រះរាជ-បំណង ៥ ប្រការ គឺ

១ – សុំឲ្យបានរាជាភិសេកក្នុងរាជ្យសម្បត្តិ

២ – សុំឲ្យព្រះអរហន្តសម្មាសម្ពុទ្ធ យាងមកកាន់ដែនដី របស់ព្រះអង្គ ។

៣ – សុំឲ្យបានចូលទៅអង្គុយជិត

៤ – សុំឲ្យព្រះមានព្រះភាគទ្រង់សំដែងធម៌ប្រោស

៥ – សុំឲ្យបានត្រាស់ដឹងធម៌ព្រះមានព្រះភាគ ។

[៦២] មួយនហុត ស្មើនឹងមួយម៉ឺន ។

បន្ទាប់មក ត្រាស់សរសើរព្រះធម៌ទេសនា ប្រកាសព្រះអង្គជាឧបាសកដល់នូវព្រះរតនត្រ័យ ជាសរណៈរហូតដល់អស់ព្រះជន្មរួចហើយក៏អារាធនាព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃសោយចង្ហាន់ក្នុងថ្ងៃស្អែក ។

លុះព្រឹកឡើង ទើបព្រះមានព្រះភាគស្ដេចយាងទៅសោយនៅក្នុងព្រះរាជនិវេសន៍ព្រមទាំងភិក្ខុសង្ឃ លុះអង្គាស (សោយ) រួចស្រេចហើយ ព្រះបាទពិម្ពិសារទ្រង់ក៏ប្រួចទឹកអំពីកន្ទីមាសហើយប្រគេនវេឡុវ័នដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះមានព្រះភាគទ្រង់ទទួលរួចហើយ ក៏ស្ដេចយាងត្រឡប់ទៅវិញ ។ ទ្រង់ប្រារព្ធហេតុនោះ ទើបទ្រង់អនុញ្ញាតឲ្យមានអារាម (គឺវត្ត) បាន ។

## ព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានចេញបួស

សម័យនោះ សញ្ជ័យបរិព្វាជកអាស្រ័យនៅក្នុងក្រុងរាជគ្រឹះ ព្រមទាំងបរិវារជាច្រើនចំនួន ២៥០ នាក់ ។ នាកាលនោះ សារីបុត្រ និងមោគ្គល្លាន ប្រព្រឹត្តព្រហ្មចរិយធម៌នៅក្នុងសំណាក់សញ្ជ័យបរិព្វាជក ហើយធ្វើកតិកាជាមួយគ្នាថា នរណាចាក់ធ្លុះធម៌មុន ត្រូវប្រាប់ដល់ម្នាក់ទៀត ។ លុះព្រះសារីបុត្រក្រឡេកឃើញព្រះអស្សជិ និមន្តបិណ្ឌបាតនៅក្នុងក្រុងរាជគ្រឹះ ក៏មាន

សេចក្ដីជ្រះថ្លាការសង្រួមរបស់លោក ទើបរង់ចាំឱកាសចូលទៅសាកសួរគោលធម៌នៅក្នុងព្រះសាសនា ដែលលោកបានចូលមកបួស ។ លោកក៏បានសំដែងគោលធម៌ខ្លីៗ ឲ្យស្ដាប់ថា “**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ** ... ធម៌ទាំងឡាយណាកើតអំពីហេតុ ព្រះតថាគតទ្រង់សំដែងហេតុ ព្រមទាំងការរំលត់នៃធម៌ទាំងឡាយនោះ ...។

ព្រះសារីបុត្រស្ដាប់ហើយ ក៏បានធម្មចក្ខុ រួចនាំយកមកសំដែងឲ្យព្រះមោគ្គល្លានស្ដាប់ ក៏បានធម្មចក្ខុដូចគ្នា ទើបនាំគ្នាទៅលាបរិព្វាជកទាំង ២៥០ នាក់ ដើម្បីទៅបួសនៅក្នុងសំណាក់ព្រះបរមសាស្ដា ។ ប៉ុន្តែបរិព្វាជកទាំងនោះសុំទៅដែរ ក៏បបួលគ្នាទៅលាសញ្ជ័យបរិព្វាជក ជាអាចារ្យ ។ សញ្ជ័យជាគ្រូអង្វរសុំឲ្យនៅជួយគ្រប់គ្រងសិស្សគណ អស់ ៣ ដង ប៉ុន្តែព្រះសារីបុត្រ និងព្រះមោគ្គល្លានបដិសេធ មិនយល់ព្រម ទើបនាំគ្នាលាគ្រូសញ្ជ័យចាកចេញទៅ ។ គ្រូសញ្ជ័យខូចចិត្ត រហូតដល់ថ្នាក់ក្អួតឈាម ។

លុះពេលទៅគាល់ទូលសុំបួសចំពោះព្រះមានព្រះភាគនៅក្នុងសំណាក់ព្រះពុទ្ធសាសនា ក៏បានទទួលពុទ្ធានុញ្ញាតបួសជាឯហិភិក្ខុ ។

គ្រានោះ មនុស្សសំខាន់ៗ នៅក្នុងដែនមគធៈបានចេញបួសប្រព្រឹត្តព្រហ្មចរិយធម៌នៅក្នុងសំណាក់ព្រះពុទ្ធសាសនាយ៉ាងច្រើន ។ ទើបមនុស្សទាំងឡាយនាំគ្នាតិះដៀលថា ជាបដិបទាធ្វើឲ្យត្រកូលដាច់វង្ស (ដាច់ពូជ) ព្រះមានព្រះភាគទ្រង់ក៏ណែនាំភិក្ខុទាំងឡាយ ឲ្យឆ្លើយតបទៅវិញថា ព្រះអង្គណែនាំដោយធម៌ មិនមែនដោយអធម៌ទេ ។ កាលបើមនុស្សទាំងឡាយចុះចាញ់ត្រង់ពាក្យថា “ធម៌” និងរកវិធីចាប់កំហុសថាមានអ្វីជា “អធម៌” ពុំបាន ក៏នាំគ្នាបញ្ឈប់ការតិះដៀលអស់រយៈពេល ៧ ថ្ងៃ ។

## ព្រះអង្គអនុញ្ញាតឱ្យមានឧបជ្ឈាយ៍

សម័យនោះ ភិក្ខុទាំងឡាយនៅពុំទាន់មានឧបជ្ឈាយ៍ មិនមានអ្នកឲ្យឱវាទប្រៀនប្រដៅ ទើបស្លៀកដណ្ដប់ពុំបានសមរម្យ មានអាកប្បកិរិយាមិនល្អ ត្រាច់ទៅបិណ្ឌបាត ។ នៅពេលដែលគេកំពុងតែបរិភោគ ក៏ឈរលូកបាត្រទៅលើម្ហូបអាហារ និងនំចំណីជាដើម ។ ភិក្ខុរូបខ្លះសុំសម្ល រូបខ្លះសុំបាយ ដោយខ្លួនឯងមកឆាន់ ។ រូបខ្លះទៀត ក៏និយាយមាត់ឮខ្លាំងនៅក្នុងសាលាឆាន់ គួរជាទីតិះដៀល ។ ព្រះមានព្រះភាគទ្រង់ជ្រាបរឿងហេតុនេះ ទើបទ្រង់អនុញ្ញាតឲ្យមានឧបជ្ឈាយ៍, ឲ្យឧបជ្ឈាយ៍តាំងចិត្តចំពោះសទ្ធិវិហារិកដូចជាកូន, ឲ្យសទ្ធិវិហារិក តាំងចិត្តចំពោះឧបជ្ឈាយ៍ដូចជាឪពុក ។ ទ្រង់ប្រាប់អំពីវិធីកាន់យកឧបជ្ឈាយ៍ ដោយការបញ្ចេញវាចាទាំងពីរខាង (គឺទាំងឧបជ្ឈាយ៍ និងសទ្ធិវិហារិក) ។ (ឧបជ្ឈាយ៍ ប្រែថា អ្នកមើល

ការខុសត្រូវ សំដៅយកអ្នកបំបួស និងប្រាប់ហេតុផល, ឯសទ្ធិ-វិហារិក ប្រែថាអ្នកអាស្រ័យនៅជាមួយ សំដៅយកសិស្ស ដែលឧបជ្ឈាយ៍បំបួសឲ្យ) ។

## ព្រះអង្គបញ្ញត្តឧបជ្ឈាយវត្ត

បន្ទាប់មក ទ្រង់ក៏បញ្ញត្តឧបជ្ឈាយវត្ត គឺបទដែលសទ្ធិវិហារិកគប្បីបដិបត្តិឲ្យប្រពៃចំពោះឧបជ្ឈាយ៍ មានការទទួលបម្រើលោកដោយការជួយរៀបចំរបស់របរផ្សេងៗ ជាដើម មានប្រមាណមិនតិចជាង ១០០ ខ។

## ព្រះអង្គបញ្ញត្តសទ្ធិវិហារិកវត្ត

បន្ទាប់មកទៀត ទ្រង់ក៏បញ្ញត្តសទ្ធិវិហារិកវត្ត គឺបទដែលឧបជ្ឈាយ៍គប្បីបដិបត្តិឲ្យប្រពៃចំពោះសទ្ធិវិហារិក មានការប្រាប់ហេតុផល ការសង្គ្រោះដោយបាត្រ ចីវរ ព្យាបាលជម្ងឺ និងផ្ញើអ្វីៗ ដទៃទៀត មានប្រមាណមិនតិចជាង ១០០ ខដូចគ្នា ។

## ព្រះអង្គពិន័យអាបត្តិ, អនុញ្ញាតការប្រណាម និងសុំខមាទោស

១.ភិក្ខុប្រាប់និស្ស័យមុន បព្វជ្ជាបេក្ខៈមិនពេញចិត្ត ទើបទ្រង់ហាមប្រាប់និស្ស័យមុន ប៉ុន្តែឲ្យប្រាប់នៅពេលបួសរួចហើយក្នុងវេលាបន្តបន្ទាប់គ្នា ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលប្រាប់និស្ស័យមុន ។

២.ភិក្ខុដែលចូលរួមក្នុងការបំបួសជាគណៈ គឺ ២ រូបខ្លះ ៣ រូបខ្លះ ៤ រូបខ្លះ ទ្រង់ជ្រាបទើបបញ្ញត្តព្រះវិន័យពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលបំបួសមានគណៈតិចជាង ១០ រូប, គណៈគ្រប់ ១០ ឬច្រើនជាង ១០ រូប អនុញ្ញាតឲ្យបំបួសបាន ។

៣.ភិក្ខុមានវស្សា ១ ខ្លះ ២ ខ្លះ ឲ្យសទ្ធិវិហារិកបួស សូម្បីព្រះឧបសេនវង្គន្តបុត្រមានវស្សាត្រឹមតែមួយ ក៏ឲ្យសទ្ធិវិហារិកឧបសម្ប័ទ ទើបទ្រង់បញ្ញត្តព្រះវិន័យពិន័យអាបត្តិដល់ភិក្ខុ ដែលមានវស្សាតិចជាង ១០ បំបួសសទ្ធិវិហារិក, វស្សាគ្រប់ ១០ ឬច្រើនជាង ១០ អនុញ្ញាតឲ្យបំបួសបាន ។

៤.ភិក្ខុមានវស្សាគ្រប់ ១០ ប៉ុន្តែជាបុគ្គលល្ងង់ខ្លៅ មិនឆ្លាត ឲ្យសទ្ធិវិហារិកបួស ប្រាកដជាអន់ជាងសទ្ធិវិហារិក,

ទើបទ្រង់អនុញ្ញាត ឲ្យភិក្ខុឆ្លាត អង់អាច ក្លាហាន មានវស្សាគ្រប់ ១០ ឬច្រើនជាង ១០ បំបួសសទ្ធិវិហារិកបាន ។

## ព្រះអង្គអនុញ្ញាតឱ្យមានអាចារ្យ

សម័យនោះ ឧបជ្ឈាយ៍ទាំងឡាយធ្វើដំណើរទៅកាន់ទីដទៃខ្លះ សឹក (លាចាកសិក្ខាបទ) ខ្លះ សុគត (ធ្វើមរណភាព) ខ្លះ ចូលទៅកាន់លទ្ធិសាសនាដទៃខ្លះ ភិក្ខុទាំងឡាយពុំមានអ្នកឲ្យឱវាទ ប្រៀន-ប្រដៅ ទើបស្លៀកដណ្តប់មិនមានរបៀបរៀបរយល្អ ប្រកបដោយអាកប្បកិរិយា ពុំសមគួរផ្សេងៗ ។ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យមានអាចារ្យ, ឲ្យអាចារ្យតាំងចិត្តចំពោះអន្តេវាសិក (អ្នកដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន) ដូចជាកូន ឯចំណែកអន្តេ-វាសិកវិញ ត្រូវតាំងចិត្តចំពោះអាចារ្យដូចជាឪពុក ។ បន្ទាប់មក ទើបទ្រង់សំដែងអំពីវិធីកាន់យកនិស្ស័យ (ការសុំអាស្រ័យនៅក្រោមការគ្រប់គ្រង) របស់អន្តេវាសិក និងការនិយាយដាស់តឿន របស់អាចារ្យ ។

## អាចរិយវត្ត និងអន្តេវាសិកវត្ត

បន្ទាប់មក ទ្រង់ក៏សំដែងវត្តដែលអន្តេវាសិកត្រូវបដិបត្តិចំពោះអាចារ្យ និងវត្តដែលអាចារ្យត្រូវបដិបត្តិចំពោះអន្តេវាសិក ។ បទដែលត្រូវបដិបត្តិដល់គ្នានឹងគ្នា នៅក្នុងវត្តនីមួយៗ មិនតិចជាង ១០០ បទ ។

## ការបណាម, ការសុំខមាទោស និងការអត់ឱនទោសឱ្យ

មានអន្តេវាសិកមិនបដិបត្តិប្រពៃចំពោះអាចារ្យ ទើបទ្រង់អនុញ្ញាតឲ្យមានការបណាម (បណ្តេញចេញ) ការសុំខមាទោស និងការអត់ឱនទោស ក្នុងទំនងដូចគ្នានឹងរឿងឧបជ្ឈាយ៍និងសទ្ធិវិហារិកដែរ រួចមកទ្រង់ក៏សំដែងអ្នកដែលប្រកបដោយអង្គ ៥ គួរបណាម និងមិនគួរបណាម រហូតដល់ឲ្យអាចារ្យដែលមានវស្សាគ្រប់ ១០ ឬច្រើនជាង ១០ ជាអ្នកឆ្លាតឈ្លាស អង់អាចក្លាហាន ទើបអាចឲ្យនិស្ស័យ (ទទួលយកអ្នកដទៃឲ្យនៅក្រោមការគ្រប់គ្រង) បាន ។

## និស្ស័យរម្ងាប់អំពីឧបជ្ឈាយ៍ និងអាចារ្យ

សម័យនោះ ឧបជ្ឈាយ៍និងអាចារ្យធ្វើដំណើរទៅកាន់ទីដទៃខ្លះ លាចាកសិក្ខាបទខ្លះជាដើម ។ ទើបព្រះមានព្រះភាគទ្រង់សំដែងលក្ខណៈ ៥ ប្រការដែលធ្វើឲ្យនិស្ស័យ (ការនៅក្រោមការគ្រប់គ្រង) រម្ងាប់អំពីឧបជ្ឈាយ៍ គឺ

*១.ឧបជ្ឈាយ៏ទៅកាន់ទីដទៃ*

*២.ឧបជ្ឈាយ៏ លាចាកសិក្ខាបទ*

*៣.ឧបជ្ឈាយ៏សុគត (ធ្វើមរណភាព)*

*៤.ឧបជ្ឈាយ៏ ចូលទៅកាន់លទ្ធិអន្យត្ថិរិយ៏*

*៥.ឧបជ្ឈាយ៏មានបញ្ជា* (ដូចជាបញ្ជា ឲ្យបណាម គឺបណ្ដេញចេញមិនឲ្យនៅក្រោមការគ្រប់គ្រង) ។

បន្ទាប់មក ទ្រង់សំដែងលក្ខណៈ ៦ ប្រការ ដែលនាំឲ្យនិស្ស័យរម្ងាប់អំពីអាចារ្យ គឺ ៥ ខដំបូងដូចនិស្ស័យរម្ងាប់អំពីឧបជ្ឈាយ៍ដែរ ចំណែកខទី ៦ កាលបើអន្តេវាសិករកបានឧបជ្ឈាយ៍ (គឺកាលបើជួបអ្នកដែលមានសិទ្ធិគ្រប់គ្រងខ្ពស់ជាង ការនៅក្រោមការគ្រប់គ្រងរបស់អាចារ្យ ក៏រម្ងាប់ទៅ) ។

## គុណសម្បត្តិឧបជ្ឈាយ៍ ៥ យ៉ាង

ព្រះមានព្រះភាគទ្រង់បានសំដែងការខ្វះគុណសម្បត្តិ ៥យ៉ាង និងការប្រកបដោយគុណសម្បត្តិ ៥ យ៉ាងរបស់ភិក្ខុ ដែលពុំសមគួរធ្វើជាអ្នកឲ្យឧបសម្ប័ទ, មិនគួរឲ្យនិស្ស័យ, មិនគួរឲ្យសាមណេរបម្រើ រួមមាន ១៦ ពួក ។ ពួកខាងខ្វះគុណសម្បត្តិ ៥ យ៉ាងក្នុងលក្ខណៈផ្សេងគ្នា រួមមាន ៨ ប្រភេទ ឬ ៨ ពួក ។ ពួកប្រកបដោយគុណសម្បត្តិ ៥ យ៉ាងក្នុងលក្ខណៈផ្សេងគ្នា រួមមាន ៨ ប្រភេទ ឬ ៨ ពួក ។

## គុណសម្បត្តិរបស់ឧបជ្ឈាយ៍ ៦ យ៉ាង

បន្ទាប់មកទ្រង់ក៏សំដែងការខ្វះគុណសម្បត្តិ និងការប្រកបដោយគុណសម្បត្តិ ៦ យ៉ាងក្នុងលក្ខណៈផ្សេងគ្នា លក្ខណៈនីមួយៗមាន ៨ ពួក រួមទាំងពីរលក្ខណៈត្រូវជា ១៦ ពួករបស់ភិក្ខុថា គួរឲ្យឧបសម្ប័ទ គួរឲ្យនិស្ស័យ និងគួរមានសាមណេរបម្រើ ឬក៏អត់ ។ (កត់សម្គាល់ៈ ៥ ខ ឬ ៦ ខ នោះ ផ្សេងគ្នាត្រង់ខចុងក្រោយ គឺមានវស្សាគ្រប់ ១០ ឬច្រើនជាង ១០ គឺថា គុណសម្បត្តិ ៥ យ៉ាង មិនមានខកំណត់រឿងវស្សា បើបន្ថែមខកំណត់រឿងវស្សាត្រូវជា ៦ យ៉ាង) ។

នៅទីបញ្ចប់ បានសរុបនូវគុណសម្បត្តិ ៥ យ៉ាង ដែលមាន ១៦ ពួក និងគុណសម្បត្តិ ៦ យ៉ាង ដែលមាន ១៦ ពួក ដើម្បីកំណត់ឲ្យបានងាយ ។

## វិធីបដិបត្តិចំពោះបុគ្គលធ្លាប់ចូលលទ្ធិអន្យតិរ្ថិយ៍

មានហេតុការណ៍កើតឡើងចំពោះអ្នកបួសរួចហើយ ទៅចូលលទ្ធិអន្យតិរ្ថិយ៍ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលធ្លាប់ជាអន្យតិរ្ថិយ៍ចូលមកបួស ឧបជ្ឈាយ៍ប្រៀនប្រដៅដោយធម៌ ត្រឡប់ជាបដិសេធ រួចហើយក៏ចូលទៅកាន់លទ្ធិអន្យតិរ្ថិយ៍ ។ ក្រោយមកសុំបួសម្តងទៀត មិនគួរបំបួសឲ្យ ។

ចំណែកបុគ្គលធ្លាប់ជាអន្យតិរ្ថិយ៍ ចង់បព្វជ្ជាឧបសម្បទា ក្នុងធម្មវិន័យនេះ លុះណាត្រូវបានទទួលការអប់រំ (នៅបរិវាស) ៤ ខែសិន គឺឲ្យកោរសក់ កោរចិញ្ចើម កោរពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវៈ ឆៀងស្មាម្ខាង សំពះបាទាភិក្ខុទាំងឡាយ បន្លឺវាចាដល់ព្រះរតនត្រ័យ ៣ ចប់ ។ បន្ទាប់មកឲ្យភិក្ខុមួយរូបសូត្រប្រកាសសុំសង្ឃឲ្យបរិវាស (ការអប់រំ) ៤ ខែ បើមិនមានអ្នកណាជំទាស់ទេ ទើបសម្រេចរួចរាល់មួយសារ ។ ក្នុងចន្លោះ ៤ ខែ បើប្រព្រឹត្ត មិនសមរម្យ មិនជាទីពេញចិត្ត គឺមិនគួរឲ្យបួស តែបើប្រព្រឹត្តសមរម្យ គួរជាទីពេញចិត្ត ទើបអនុញ្ញាតឲ្យបួស ។

ម្យ៉ាងទៀត បានទទួលការអនុញ្ញាតពិសេសអំពីព្រះញាតិនៅក្នុងសាក្យត្រកូល បើធ្លាប់ជាអន្យតិរ្ថិយ៍មកពីមុន ហើយមកបួស អនុញ្ញាតឲ្យបួសតែម្តង ពុំចាំបាច់ទទួលការអប់រំ (បរិវាស) ៤ ខែ ឡើយ ។

## ហាមបំបួសបុគ្គលមានរោគ ៥ ប្រភេទ

សម័យនោះ មានរោគ ៥ ប្រភេទកើតឡើងជាច្រើននៅក្នុងដែនមគធៈ គឺរោគឃ្លង់ រោគស្រែង រោគរីងរៃ និងរោគឆ្កួតជ្រូក មនុស្សទាំងឡាយដែលកើតរោគនេះ នាំគ្នាទៅរកពេទ្យ (ហ្ម) ជីវក ដើម្បីឲ្យជួយព្យាបាល ។ ពេទ្យជីវកមិនព្រមព្យាបាលដោយសំអាងថា មានភារៈត្រូវរក្សាព្រះរាជា, បុគ្គលនៅក្នុងព្រះរាជដំណាក់ និងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ មនុស្សម្នាទាំងនោះ ឃើញថាគ្មានផ្លូវដទៃទៀត ទើបសុំបួស, ភិក្ខុទាំងឡាយ ក៏បំបួសឲ្យជាភារៈដល់ភិក្ខុទាំងឡាយដែលត្រូវព្យាបាល ។ សូម្បីពេទ្យជីវក ក៏ត្រូវធ្វើការធ្ងន់ រហូតដល់ខូចព្រះរាជកិច្ច ។ បុរសម្នាក់ចូលមកបួស ឲ្យពេទ្យជីវកព្យាបាល លុះជាសះស្បើយហើយ ក៏លាចាកសិក្ខាបទទៅ ។ ពេទ្យជីវកចំណាំបាន សាកសួរដឹងរឿងរ៉ាវហើយ ក៏តិះដៀល ។

ទើបព្រះមានព្រះភាគបញ្ញត្តវិន័យ ហាមបំបួសបុគ្គលដែលមានរោគ ៥ ប្រភេទ ភិក្ខុរូបណាបំបួសឲ្យ ត្រូវអាបត្តិទុក្កដ ។

## ហាមបំបួសបុគ្គលបម្រើរាជការ

កើតភាពវឹកវរមិនស្ងប់នៅតាមជាយដែន ព្រះបាទពិម្ពិសារ
ត្រាស់បញ្ជាមហាអាមាត្យដែលជាមេទ័ពធំឲ្យទៅបង្ក្រាប
មានមនុស្សម្នា ជាច្រើនគេចចូលទៅបួស ភិក្ខុទាំងឡាយក៏បំបួសឲ្យ ទើបព្រះបាទពិម្ពិសារ សុំឲ្យព្រះមានព្រះភាគទ្រង់បញ្ញត្តព្រះវិន័យ មិនឲ្យបំបួស បុគ្គលដែលជាខ្ញុំរាជការ ពីព្រោះអាចព្រះរាជា ដែលមិនជ្រះថ្លានូវព្រះពុទ្ធសាសនាបៀតបៀនភិក្ខុទាំងនោះ ។

ទើបព្រះមានព្រះភាគ ត្រាស់ហាមមិនឲ្យបំបួសខ្ញុំរាជការ ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលបំបួសឲ្យ (ក្នុងសម័យនេះ អ្នកបម្រើរាជការ ត្រូវមានលិខិត អនុញ្ញាត ជាលាយលក្ខណ៍អក្សរអំពីអាជ្ញាធរ ទើបឧបជ្ឈាយ៍ និងភិក្ខុសង្ឃអាចបំបួសបាន) ។

## ហាមបំបួសចោរដែលមានឈ្មោះ

សម័យនោះ ចោរអង្គុលីមាលបួសនៅក្នុងសំណាក់ភិក្ខុទាំង-ឡាយ ។ មនុស្សទាំងឡាយឃើញហើយ ក៏ភ័យខ្លាចរត់គេចចេញទៅ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តវិន័យ ហាមបំបួសចោរដែលមានឈ្មោះល្បី ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលជាអ្នកបំបួសឲ្យ ។

## ហាមបំបួសចោរដែលលួចចេញពីពន្ធនាគារ

ក្នុងកាលនោះ ព្រះបាទពិម្ពិសារទ្រង់ប្រកាសមិនឲ្យបុគ្គលណាធ្វើអ្វី (ដូចជាការចាប់ឃុំឃាំង) ដល់អ្នកដែលចូលមកបួសនៅក្នុងព្រះពុទ្ធសាសនា ។ មានចោរមួយរូបធ្វើចោរកម្ម ត្រូវគេចាប់ឃុំនៅក្នុងគុក តែទម្លាយគុកចេញមកបាន ទើបចូលទៅបួស ។ មនុស្សទាំងឡាយនាំគ្នាតិះដៀលភិក្ខុដែលបំបួសឲ្យ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តព្រះវិន័យ ហាមបំបួសចោរដែលទម្លាយគុកចេញមកភិក្ខុណាបំបួសត្រូវអាបត្តិទុក្កដ ។

## ហាមបំបួសបុគ្គលដែលពុំសមគួរនឹងឱ្យបួសជាថ្មីទៀត

មានហេតុការណ៍កើតឡើងដល់ភិក្ខុដែលបំបួសបុគ្គល ពុំសមគួរនឹងឲ្យបួស មានគេតិះដៀល ទើបព្រះមានព្រះភាគ ទ្រង់បញ្ញត្តព្រះវិន័យ ហាមបំបួសបុគ្គលដែលពុំសមគួរនឹងឲ្យបួសដទៃទៀត គឺ

- ចោរដែលត្រូវគេប្រកាសឲ្យសម្លាប់
- ជនដែលគេវាយដោយរំពាត់ហើយត្រូវដាក់ទោសឲ្យនិរទេស
- ជនដែលគេឈូតដោយរងើកដែកឲ្យមានស្នាម
- ជនជំពាក់បំណុលគេ
- ជនដែលជាខ្ញុំបម្រើគេ ។

## អនុញ្ញាតឱ្យប្រាប់សង្ឃជាមុនៗនឹងកោរសក់នាគ

កូនជាងមាស[៦៣] ឈ្លោះជាមួយឪពុកម្ដាយ គេចចូលមកបួស ឪពុកម្ដាយមកសាកសួរ ភិក្ខុទាំងឡាយមិនជ្រាបក៏បានបដិសេធ លុះគេឃើញមកបួសក៏តិះដៀល ចោទថាភិក្ខុទាំងនោះនិយាយកុហក (ការពិតគឺពួកលោកមិនដឹងមែន) ។ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាត ឲ្យប្រាប់សង្ឃជាមុនសិន សឹមកោរសក់នាគ (ភណ្ឌុកម្ម គឺកោរសក់) ។

## ហាមបំបួសកុលបុត្រអាយុតិចជាង ២០ ឆ្នាំ

កុមារទាំង ១៧ នាក់ សុំអនុញ្ញាតឪពុកម្ដាយមកបួស លុះដល់កណ្ដាលរាត្រី ស្រាប់តែស្រែកយំទារអាហារ ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តព្រះវិន័យ ហាមបំបួសកុមារដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ ទាំងដែលដឹងថាអាយុមិនទាន់គ្រប់ ។ បើនៅតែបំបួស អនុញ្ញាតឲ្យពិន័យអាបត្តិតាមសមគួរ (មាននៅក្នុងសិក្ខាបទទី ៥ នៃសប្បាណកវគ្គ) ។

## បទហាមឃាត់ទាក់ទងនឹងសាមណេរ

អហិវាតករោគបានកើតឡើង មានត្រកូលមួយ គឺឪពុកនិងកូនប្រុសរួចផុតអំពីសេចក្ដីស្លាប់ ទាំងពីរនាក់បានចូលមកបួស ។ ពេលដែលមានទាយកគេប្រគេនអាហារដល់ឪពុក ស្រាប់តែកូនរត់ទៅសុំចែក គួរជាទីតិះដៀល ទើបទ្រង់ហាមបព្វជ្ជា (បួសជាសាមណេរ) ដល់ក្មេងដែលមានអាយុតិចជាង ១៥ ឆ្នាំ ។

---

[៦៣] កូនជាងមាសម្នាក់ ក្នុងភាសាបាឡីប្រើពាក្យថា កម្មារភណ្ឌុ, បារាំងប្រែថា កូនជាងមាសដែលមានក្បាលត្រងោល ឬទំពែក ។ ប៉ុន្តែអដ្ឋកថាអធិប្បាយថា ទុកសក់ ៥ កញ្ចុំ កន្លែងដទៃទៀតកោរទាំងអស់ ។

ក្រោយមក មានហេតុចាំបាច់ត្រូវសង្គ្រោះក្មេងៗ ដែលឪពុកម្ដាយស្លាប់ចោលអស់ឲ្យបួស ទើបទ្រង់អនុញ្ញាតឲ្យបំបួសក្មេងអាយុតិចជាង ១៥ ឆ្នាំ ដែលអាចគប់បង្អើលក្អែកបាន (គឺល្មមដឹងក្ដី) និងមានហេតុកើតឡើងទាក់ទងនឹងសាមណេរ ទើបទ្រង់បញ្ញត្តមិនឲ្យភិក្ខុមួយរូបមានសាមណេរបម្រើ ២ រូប, បើនៅតែធ្វើដូច្នោះត្រូវអាបត្តិទុក្កដ[៦៤] ។

## ការបន្ធូររឿងកាន់និស្ស័យ

សម័យនោះ ភិក្ខុត្រូវតែកាន់និស្ស័យ (នៅក្នុងការគ្រប់គ្រងនៃឧបជ្ឈាយ៍ ឬអាចារ្យ) រហូតដល់ ១០ ឆ្នាំ ក៏ពុំមានសេចក្ដីសុខ ទើបទ្រង់អនុញ្ញាតឲ្យភិក្ខុដែលឆ្លាតឈ្លាសកាន់និស្ស័យត្រឹមតែ ៥ ឆ្នាំ ។ ចំណែកភិក្ខុមិនឆ្លាត ឲ្យកាន់និស្ស័យអស់មួយជីវិត ។ បន្ទាប់មក ទ្រង់សំដែងការខ្វះគុណសម្បត្តិ ៥ យ៉ាង រួមមាន ៤ រឿង និងការប្រកបដោយគុណសម្បត្តិ រួមមាន ៤ រឿងដូចគ្នាដែលភិក្ខុត្រូវតែកាន់និស្ស័យ ឬមិនត្រូវកាន់និស្ស័យ ។ បន្ទាប់មកទៀត ទ្រង់សំដែងការខ្វះគុណសម្បត្តិ ៦ យ៉ាង រួមមាន ៤ រឿង និងការប្រកបដោយគុណសម្បត្តិ ៦ យ៉ាង រួមមាន ៤ រឿងដែលភិក្ខុត្រូវតែកាន់និស្ស័យ ឬមិនត្រូវកាន់និស្ស័យ ។ ការខ្វះគុណសម្បត្តិ ឬការប្រកបដោយគុណសម្បត្តិនោះ មានលក្ខណៈស្រដៀងគ្នាទៅនឹងការកំណត់ទុកសម្រាប់ឧបជ្ឈាយ៍ និងអាចារ្យ ជាពិសេស ដែលមាននិយាយអំពីគុណសម្បត្តិ ៦ យ៉ាង, ត្រង់ចំណុចទី ៦ កំណត់ថា ត្រូវតែមានវស្សាគ្រប់ ៥ ឬលើសពី ៥ ។

## ព្រះរាហុលបួសជាសាមណេរ

ព្រះមានព្រះភាគស្ដេចយាងទៅកាន់ក្រុងកបិលពស្ដុ ព្រះរាហុលក្រាបទូលសុំរាជសម្បត្តិ ។ ព្រះអង្គត្រាស់ឲ្យព្រះសារីបុត្រជាអ្នកបំបួស ទ្រង់កំណត់វិធីបព្វជ្ជាជាសាមណេរដោយការដល់សរណៈ៣ (ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ) ។ ព្រះបាទសុទ្ធោទនៈទ្រង់ស្នើសុំចំពោះព្រះមានព្រះភាគ កុំឲ្យបំបួសកុលបុត្រដែលឪពុក ម្ដាយមិនទាន់បានអនុញ្ញាត ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទហាមបំបួសបុគ្គល ដែលឪពុកម្ដាយមិនទាន់បានអនុញ្ញាត, ភិក្ខុណាបំបួសត្រូវអាបត្តិទុក្កដ ។

## អនុញ្ញាតឱ្យមានសាមណេរច្រើនជាង ១ រូប

[៦៤] ក្រោយមកទ្រង់អនុញ្ញាតឲ្យភិក្ខុវៃឆ្លាត អាចអប់រំទូន្មានបាន មានសាមណេរបម្រើមិនកំណត់ចំនួន ។

ព្រះសារីបុត្រមានសាមណេររាហុលតែ ១ រូបគត់ ក្រោយមក មានសាមណេរបួសជាច្រើនរូប ស្រាប់តែពុំហ៊ានឲ្យនៅក្នុងការគ្រប់គ្រងរបស់ខ្លួន ។ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុឆ្លាតអាចមានសាមណេរបម្រើ ២ រូប ព្រមទាំងអាចអប់រំទូន្មានបានចំនួនប៉ុន្មាន អនុញ្ញាតឲ្យមានតាមចំនួនប៉ុណ្ណោះ គឺមិនកំណត់ចំនួនទេ ។ ពិតណាស់ ការដែលមានសាមណេរបម្រើ មិនដូចមានគ្រហស្ថបម្រើទេ ពីព្រោះភិក្ខុត្រូវគ្រប់គ្រងអប់រំទូន្មានប្រៀនប្រដៅ ផ្តល់ចំណេះដឹងនៅក្នុងព្រះពុទ្ធសាសនា ការប្រើបន្តិចបន្តួច អាចគង់នឹងមានខ្លះពុំខាន ។

## សីល ១០ របស់សាមណេរ

សាមណេរទាំងឡាយសង្ស័យថា សិក្ខាបទ ឬសីលរបស់ខ្លួនមានប៉ុន្មាន និងត្រូវសិក្សានៅក្នុងសិក្ខាបទណាខ្លះ ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ១០ ដល់សាមណេរ គឺ

១.វៀរចាកការសម្លាប់សត្វ

២.វៀរចាកការលួចទ្រព្យរបស់អ្នកដទៃ

៣.វៀរចាកការប្រព្រឹត្តខុសក្នុងកាម

៤.វៀរចាកការនិយាយកុហក

៥.វៀរចាកការផឹកទឹកស្រវឹង និងមេរ័យ

៦.វៀរចាកការបរិភោគក្នុងវេលាវិកាល (ហួសថ្ងៃត្រង់)

៧.វៀរចាកការរាំច្រៀងប្រគុំ និងមើលមហោស្រព

៨.វៀរចាកការប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

៩.វៀរចាកទីដេកទីអង្គុយខ្ពស់ហួសប្រមាណ (គឺលើគ្រែ និងតាំងដែលមានជើងខ្ពស់ហួសប្រមាណ និងធំដែលមានគ ឬសំឡីនៅពីខាងក្នុង) ។

១០.វៀរចាកការទទួលមាស និងប្រាក់ ទោះត្រេកអរក៏ដោយ មិនត្រេកអរក៏ដោយ ។

## ការដាក់ទោសសាមណេរ

សម័យនោះ សាមណេរមិនមានសេចក្តីគោរពចំពោះភិក្ខុទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តអង្គ ៥ នៃសាមណេរដែលដល់ទណ្ឌកម្ម (ដាក់ទោស) គឺ

១.ព្យាយាមធ្វើឲ្យវិនាសលាភនៃភិក្ខុទាំងឡាយ

២.ព្យាយាមធ្វើឲ្យមានសេចក្តីវិនាស (អនត្ថភាព) ដល់ភិក្ខុទាំងឡាយ ។

៣.ព្យាយាមធ្វើឲ្យភិក្ខុទាំងឡាយនៅមិនបាន

៤.ជេរប្រទេចភិក្ខុទាំងឡាយ

៥.ធ្វើឲ្យភិក្ខុទាំងឡាយបែកបាក់គ្នា ។

## រឿងទាក់ទងនឹងការដាក់ទោស

ភិក្ខុទាំងឡាយសង្ស័យថា គួរដាក់ទោសសាមណេរដូចម្តេច ទើបទ្រង់អនុញ្ញាតឲ្យមានខកំណត់ហាមប្រាម ។ ភិក្ខុទាំងឡាយហាមឲ្យចូលសង្ឃារាម (វត្តដែលសង្ឃគង់នៅ) ។ សាមណេរចូលមិនបាន ទើបធ្វើដំណើរទៅកាន់ទីដទៃខ្លះ លាចាកសិក្ខាបទខ្លះ ចូលទៅកាន់លទ្ធិអន្យតិរ្ថីយ៍ខ្លះ ។ ទើបទ្រង់មិនឲ្យភិក្ខុហាមសាមណេរចូលទៅកាន់សង្ឃារាមទាំងអស់ បើធ្វើដូច្នោះ ត្រូវអាបត្តិទុក្កដ ។ អនុញ្ញាតឲ្យហាមបានតែនៅក្នុងបរិវេណដែលទៅមកបាន ។ ភិក្ខុទាំងឡាយហាមលេបអាហារ (គឺហាមប្រើមាត់បរិភោគអាហារ ឬឆាន់យាគូ) ។ មនុស្សទាំងឡាយប្រគេនយាគូ សាមណេរទាំងឡាយ ក៏មិនហ៊ានឆាន់ ។ មានគេតិះដៀល ទើបទ្រង់ពិន័យអាបត្តិទុក្កដ ដល់ភិក្ខុដែលធ្វើការហាមឃាត់ដូចនោះ ។

ភិក្ខុឆព្វគ្គិយហាមឃាត់បរិវេណសាមណេរជាច្រើនរូប ឧបជ្ឈាយ៍ទាំងឡាយដើរតាមរកគ្រប់ច្រកល្ហក ដឹងហើយក៏តិះដៀល ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តព្រះវិន័យថា បើនៅមិនទាន់បានប្រាប់ដល់ឧបជ្ឈាយ៍ជាមុន មិនគួរធ្វើការហាមប្រាម (ឃាត់បរិវេណ) សាមណេរទេ ភិក្ខុរូបណាធ្វើដូច្នោះ ត្រូវអាបត្តិទុក្កដ ។

## ហាមដឹកនាំសាមណេររបស់ភិក្ខុដទៃ នាំនៅជាមួយខ្លួន

ភិក្ខុឆព្វគ្គិយបបួលសាមណេររបស់ព្រះថេរៈ ទៅនៅជាមួយខ្លួន ។ ព្រះថេរៈទាំងនោះ លំបាកក្នុងការរកឈើស្ទន់ (ឈើចាក់ធ្មេញ) និងទឹកលាងមុខ ។ ទើបទ្រង់បញ្ញត្តព្រះវិន័យ ហាមបបួលបរិស័ទ (សាមណេរ) នៃភិក្ខុដទៃទៅនៅជាមួយខ្លួន បើធ្វើដូចនោះ ត្រូវអាបត្តិទុក្កដ ។

## ការឱ្យសាមណេរលាចាកសិក្ខាបទ

សាមណេររបស់ព្រះឧបនន្ទសាក្យបុត្រ ប្រទូស្ត (រំលោភ) ភិក្ខុនី ។ ភិក្ខុទាំងឡាយតិះដៀល ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យនាសនៈ (ចាប់ផ្សឹក) សាមណេរប្រកបដោយអង្គ ១០ គឺ

១.សម្លាប់សត្វ ២.លួចទ្រព្យគេ

៣.ប្រព្រឹត្តខុសក្នុងកាម ៤.និយាយកុហក

៥.ផឹកសុរានិងមេរ័យ ៦.តិះដៀលព្រះពុទ្ធ

៧.តិះដៀលព្រះធម៌ ៨.តិះដៀលព្រះសង្ឃ

៩.យល់ខុស ១០.ប្រទូស្ត(រំលោភ)ភិក្ខុនី ។

## បុគ្គលដែលមិនគួរបំបួសដទៃទៀត

ក្រោយមកមានហេតុការណ៍កើតឡើង ដោយសារភិក្ខុទាំង-ឡាយ បំបួសបុគ្គលដែលមិនសមគួរ ទើបទ្រង់បញ្ញត្តព្រះវិន័យហាមបំបួសបុគ្គលដែលមិនសមគួរដូចតទៅនេះ គឺ

១.ខ្ទើយ

២.បុគ្គលលួចភេទ (គឺបួសដោយខ្លួនឯងមិនត្រឹមត្រូវ)

៣.ភិក្ខុចូលអន្យតិរ្ថីយ៍

៤.សត្វតិរច្ឆាន

៥.បុគ្គលសម្លាប់មាតា

៦បុគ្គលសម្លាប់បិតា

៧.បុគ្គលសម្លាប់ព្រះអរហន្ត

៨.បុគ្គលរំលោភភិក្ខុនី

៩.បុគ្គលបំបែកសង្ឃ

១០.បុគ្គលប្រទូស្តរ៉ាយព្រះពុទ្ធឲ្យពុះពងព្រះលោហិត

១១.បុគ្គលមានអវយវៈ ២ ភេទ (ឧភតោព្យញ្ជនកៈ) ។

ទាំង ១១ ប្រភេទនេះ បើបំបួសឲ្យ លុះក្រោយមកដឹងត្រូវផ្សឹកចេញ ។

## លក្ខណៈមិនគួរឱ្យឧបសម្បទា (បួសជាភិក្ខុ) ២០ ប្រភេទដទៃទៀត

បន្ទាប់មកទ្រង់បញ្ញត្តព្រះវិន័យ សំដែងលក្ខណៈមិនគួរឧប-សម្បទា ជាភិក្ខុរួមមាន ២០ ប្រភេទ ដូចតទៅនេះ

១.បុគ្គលមិនមានឧបជ្ឈាយ៍

២.បុគ្គលយកសង្ឃជាឧបជ្ឈាយ៍ (ឧបជ្ឈាយ៍ត្រូវមានតែមួយរូប មិនមែនច្រើនរូបទេ) ។

៣.បុគ្គលយកគណៈជាឧបជ្ឈាយ៍ (២, ៣ ឈ្មោះថា ជាគណៈ, ៤ ឡើងទៅ ជាសង្ឃ) ។

៤.បុគ្គលមានឧបជ្ឈាយ៍ជាខ្ទើយ

៥.បុគ្គលមានឧបជ្ឈាយ៍ជាអ្នកលួចភេទ

៦.បុគ្គលមានឧបជ្ឈាយ៍ជាអ្នកចូលអន្យតិរ្ថីយ៍

៧.បុគ្គលមានឧបជ្ឈាយ៍ជាសត្វតិរច្ឆាន (មានរឿងដំណាលថានាគក្លែងភេទមកបួស) ។

៨.បុគ្គលមានខបជ្ឈាយ៍ជាអ្នកសម្លាប់មាតា

៩.បុគ្គលមានខបជ្ឈាយ៍ជាអ្នកសម្លាប់បិតា

១០.បុគ្គលមានខបជ្ឈាយ៍ជាអ្នកសម្លាប់ព្រះអរហន្ត

១១.បុគ្គលមានខបជ្ឈាយ៍ជាអ្នករំលោភភិក្ខុនី

១២.បុគ្គលមានខបជ្ឈាយ៍ជាអ្នកបំបែកសង្ឃ

១៣.បុគ្គលមានខបជ្ឈាយ៍ជាអ្នកប្រទូស្តវាយព្រះពុទ្ធ រហូតដល់ថ្លាក់ពុះពង់ព្រះលោហិត ។

១៤.បុគ្គលមានខបជ្ឈាយ៍ជាអ្នកមានអវយវៈ ២ ភេទ

១៥.បុគ្គលគ្មានបាត្រ

១៦.បុគ្គលគ្មានចីវរ

១៧.បុគ្គលគ្មានទាំងបាត្រនិងចីវរ

១៨.បុគ្គលខ្ចីបាត្រគេមកបួស

១៩.បុគ្គលខ្ចីចីវរគេមកបួស

២០.បុគ្គលខ្ចីទាំងបាត្រនិងចីវរគេមកបួស ។

ទាំង ២០ ប្រភេទនេះ ប្រសិនបើ (សង្ឃ) បំបួសឲ្យត្រូវអាបត្តិទុក្កដ ។

## លក្ខណៈមិនគួរឱ្យបព្វជ្ជា (បួសជាសាមណេរ) ៣២ ប្រភេទ

១.មនុស្សដាច់ដៃ

២.មនុស្សដាច់ជើង

៣.មនុស្សដាច់ដៃ-ជើង

៤.មនុស្សដាច់ត្រចៀក

៥.មនុស្សឆែបច្រមុះ

៦.មនុស្សដាច់ត្រចៀក និងឆែបច្រមុះ

៧.មនុស្សដាច់ម្រាមដៃ

៨.មនុស្សដាច់មេដៃ

៩.មនុស្សដាច់សរសៃជើង

១០.មនុស្សមានម្រាមជាប់គ្នា

១១.មនុស្សគម

១២.មនុស្សគឿពេក

១៣.មនុស្សពកក

១៤.មនុស្សដែលគេដុតដោយដែកក្រហម ធ្វើឲ្យខូចរូបឆោម (ការដាក់ទោស) ។

១៥.មនុស្សដែលគេវាយដោយរំពាត់ (មានដំបៅ)

១៦.មនុស្សដែលគេតាមចាប់ (បើជួបឲ្យសម្លាប់)

១៧.មនុស្សជើងកែក

១៨.មនុស្សដែលមានរោគជាផលនៃបាប (ជម្ងឺរ៉ាំរ៉ៃដែលព្យាបាលមិនបាត់) ។

១៩.មនុស្សប្រទូស្តរ៉ាយបរិស័ទ (គឺអាស្រ័យនៅក្នុងពួកហើយធ្វើឲ្យក្រុមវិបរិត្តដោយរូបខុសប្រក្រតីរបស់ខ្លួន ដូចជា ខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ស្គមពេក ធាត់ពេក ជាដើម) ។

២០.មនុស្សខ្វាក់ភ្នែកម្ខាង ឬទាំងសងខាង

២១.មនុស្សខ្វិន

២២.មនុស្សខ្វកជើង (ជើងខុសធម្មតា គឺដើរដោយខ្នងជើងជាដើម) ។

២៣.មនុស្សមានជម្ងឺស្លាប់មួយចំហៀងខ្លួន

២៤.មនុស្សមានកម្លាំងខ្សោយ (ដើរខ្លួនឯងមិនបាន)

២៥.មនុស្សជរាទុព្វលភាព

២៦.មនុស្សខ្វាក់អំពីកំណើត

២៧.មនុស្សគ

២៨.មនុស្សថ្លង់

២៩.មនុស្សខ្វាក់-គ

៣០.មនុស្សខ្វាក់-ថ្លង់

៣១.មនុស្សគ-ថ្លង់

៣២.មនុស្សខ្វាក់-គ-ថ្លង់ ។

បុគ្គលទាំង ៣២ ប្រភេទនេះ ភិក្ខុរូបណាឲ្យបព្វជ្ជាត្រូវអាបត្តិទុក្កដ ។

(កត់សម្គាល់ៈ ការកំណត់បទហាមប្រាមមិនឲ្យបំបួសបុគ្គល ៣២ ប្រភេទជាសាមណេរនេះ ជាការហាមឃាត់ក្នុងការបំបួសជាភិក្ខុផងដែរ ពីព្រោះតាមវិធីបំបួស បុគ្គលដែលបួសជាភិក្ខុត្រូវតែឆ្លងកាត់លំដាប់នៃការបួសជាសាមណេរមកអំពីមុន សូម្បីមួយរយៈពេលខ្លី ។ ការតាំងខកំណត់នេះ ដើម្បីមិនឲ្យព្រះពុទ្ធសាសនាដូចជាធុងសម្រាម ទទួលយកមនុស្សដែលគេមិនត្រូវការហើយ ។ ប៉ុន្តែមិនមានបទហាមឃាត់ដល់ថ្នាក់ថា បួសហើយត្រូវតែឲ្យលាចាកសិក្ខាបទដូចបុគ្គល ១១ ប្រភេទដែលពោលទុកនៅក្នុងបទហាមបំបួសដាច់ខាតនោះដែរ) ។

## ការកំណត់រឿងឱ្យនិស្ស័យបន្ថែម

ក្រោយមកមានហេតុការណ៍កើតឡើង ទើបទ្រង់បញ្ញត្តព្រះវិន័យ មានការកំណត់បន្ថែមនូវការឲ្យនិស្ស័យ (ទទួលយកមកគ្រប់គ្រង) ដូចតទៅនេះៈ

១.ហាមឲ្យនិស្ស័យដល់អលជ្ជីភិក្ខុ (ភិក្ខុដែលមិនខ្មាស់មិនខ្លាចក្នុងការត្រូវអាបត្តិ) បើឲ្យនិស្ស័យត្រូវអាបត្តិទុក្កដ ។

២.ដើម្បីដឹងថាជាលជ្ជី ឬអលជ្ជី អនុញ្ញាតឲ្យរង់ចាំមើល ៤-៥ ថ្ងៃបាន និងដើម្បីដឹងថាអាចនៅរួមជាមួយភិក្ខុទាំងឡាយបាន ឬមួយក៏អត់ ។

៣.ភិក្ខុធ្វើដំណើរផ្លូវឆ្ងាយ អនុញ្ញាតឲ្យមិនចាំបាច់កាន់និស្ស័យ ក្នុងពេលដែលមិនមានភិក្ខុឲ្យនិស្ស័យ ។

៤.អនុញ្ញាតឲ្យភិក្ខុអាពាធ, ភិក្ខុរក្សាភិក្ខុអាពាធ ពុំចាំបាច់កាន់និស្ស័យក្នុងពេលដែលមិនមានភិក្ខុឲ្យនិស្ស័យ ។

៥.អនុញ្ញាតឲ្យភិក្ខុនៅព្រៃពុំចាំបាច់កាន់និស្ស័យ ក្នុងពេលមិនមានភិក្ខុឲ្យនិស្ស័យ តែបើមានភិក្ខុឲ្យនិស្ស័យ ត្រូវតែកាន់និស្ស័យ ។

## បទកំណត់ក្នុងការឧបសម្បទា

ក្រោយមក ទ្រង់បញ្ញត្តឲ្យសូត្រអនុសាវនា មិនចាំបាច់បញ្ជាក់ឈ្មោះ តែត្រូវបញ្ជាក់ត្រកូល (គោត្រ) និងអនុញ្ញាតឲ្យសូត្រប្រកាសម្ដង ២-៣ រូប ដោយមានឧបជ្ឈាយ៍តែមួយរូបបាន។ ទ្រង់ឲ្យរាប់អាយុអ្នកចូលមកបួសឲ្យគ្រប់ ២០ ឆ្នាំ ដោយគិតតាំងពីនៅក្នុងគភ៌ ។

## បទបញ្ញត្តិនៅក្នុងពិធីកម្មឧបសម្ប័ទ

បន្ទាប់មក ទ្រង់សំដែងពិធីកម្មផ្សេងៗ ក្នុងការឧបសម្ប័ទដូចជាការសាកសួរអន្តរាយិកធម៌ (ឧបសគ្គដែលត្រូវហាមឃាត់ក្នុងការបួស) ១៧ ចំណុច មានរោគ ៥ យ៉ាងជាដើម និងសាកសួរ សាមីខ្លួនជាមុន រួចទើបសាកសួរប្រជុំសង្ឃ រហូតដល់ការសូត្រប្រកាស ៣ ចប់ និងអនុម័តជាភិក្ខុបាន ។

កាលបើបួសរួចហើយ ឲ្យប្រាប់ស្រមោលថ្ងៃ (ម៉ោង) រដូវ ថ្ងៃ សង្គីតិ គឺប្រាប់រួមខាងដើមទាំងអស់ដើម្បីជាសាក្សី ។

បន្ទាប់មក ឲ្យប្រាប់និស្ស័យ ៤ (បច្ច័យ គឺគ្រឿងអាស្រ័យរបស់បព្វជិត) ៤ យ៉ាង គឺបិណ្ឌបាត ចីវរ សេនាសនៈ និងគិលានភេសជ្ជៈ ។

បន្ទាប់មកទៀត ឲ្យប្រាប់អករណីកិច្ច (វត្ថុដែលមិនគួរធ្វើ) ៤ យ៉ាង គឺការសេពមេថុន ការលួចទ្រព្យគេ ការសម្លាប់សត្វនិងមនុស្ស និងការអួតគុណវិសេសដែលមិនមាននៅក្នុងខ្លួន (ដើម្បីការពារកំហុសធ្ងន់ធ្ងរលើកដំបូង) ។

## វិធីបដិបត្តិចំពោះកំហុស

មានរឿងកើតឡើង ទើបទ្រង់សំដែងកិច្ចបដិបត្តិ នៅក្នុងករណីនោះៗ គឺ

១.កាលបើភិក្ខុ (ត្រូវអាបត្តិរួចហើយ មិនព្រមទទួល) មិនឃើញអាបត្តិ ត្រូវសង្ឃប្រកាសបណ្តេញចេញពីក្រុម ទើបលាចាកសិក្ខាបទ ក្រោយមកសុំចូលបួសជាថ្មី, បើសាកសួរហើយព្រមទទួលថា ត្រូវអាបត្តិពិតមែន អនុញ្ញាតឲ្យបួសបាន។ នៅពេលបួសរួចហើយ អនុញ្ញាតឲ្យធ្វើពិធីសំដែងអាបត្តិដែលត្រូវអំពីមុន។

២.កាលបើភិក្ខុមិនសំដែងអាបត្តិចេញ ត្រូវសង្ឃសូត្រប្រកាសបណ្តេញចេញពីពួក ទើបលាចាកសិក្ខាបទ ក្រោយមកសុំបួសវិញ បើព្រមសំដែងអាបត្តិចេញ អនុញ្ញាតឲ្យបួស។ នៅពេលបួសរួចហើយ អនុញ្ញាតឲ្យសំដែងអាបត្តិដែលត្រូវអំពីមុន។

៣.កាលបើភិក្ខុយល់ថា អាក្រក់ខ្លាំង គឺឃើញកំហុសធ្ងន់ ត្រូវសង្ឃសូត្រប្រកាសបណ្តេញចេញអំពីក្រុម ទើបលាចាកសិក្ខាបទ ក្រោយមកសុំបួសវិញ បើព្រមលះបង់កំហុសនោះ អនុញ្ញាតឲ្យបួសបាន។

កាលបើបួសរួចហើយ មិនព្រមសំដែងអាបត្តិក្តី មិនព្រមលះបង់កំហុសក្តី សង្ឃមានសិទ្ធិប្រកាសបណ្តេញចេញអំពីក្រុម។ ប៉ុន្តែបើមិនមានភិក្ខុគ្រប់អង្គ សង្ឃដែលសូត្រប្រកាសនៅរួមជាមួយលោកបាន មិនត្រូវអាបត្តិទេ។

## **២.ឧបោសថក្ខន្ធកៈ** (វគ្គពោលអំពីឧបោសថ)

ព្រះបាទពិម្ពិសារសេនាយោធានៃដែនមគធៈទ្រង់ទតឃើញ អ្នកបួសលទ្ធិដទៃប្រជុំគ្នាសន្ទនាធម៌នៅក្នុងថ្ងៃ ១៤ កើត, ១៥ កើត និង ៨ កើតនៃបក្ស មានមនុស្សទៅស្តាប់ធម៌ មានការពេញចិត្តជ្រះថ្លា ធ្វើឲ្យអ្នកបួសទាំងនោះ មានអ្នកចុះចូលជាច្រើន ទ្រង់ប្រារព្ធដោយមានព្រះបំណងឲ្យភិក្ខុនៅក្នុងព្រះពុទ្ធសាសនាធ្វើយ៉ាងនោះខ្លះ ទើបចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលព្រះរាជតម្រិះនោះ ព្រះមានព្រះភាគទ្រង់ក៏អនុម័តិប្រទានពុទ្ធានុញ្ញាតឲ្យភិក្ខុទាំងឡាយប្រជុំគ្នាក្នុងថ្ងៃ ១៤ កើត, ១៥ កើត និង ៨ កើតនៃបក្ស។

ដំបូងឡើយ ភិក្ខុទាំងឡាយប្រជុំគ្នា តែអង្គុយនៅស្ងៀម ពុទ្ធបរិស័ទចំណុះជើងវត្តជិតឆ្ងាយ មិនបានស្តាប់ធម៌ ក៏តិះដៀល ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យប្រជុំគ្នាដើម្បីសន្ទនាធម៌។

## **ការសូត្របាតិមោក្ខជាឧបោសថកម្ម**

ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា សិក្ខាបទដែលទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយ គួរតែអនុញ្ញាតឲ្យសូត្រជាបាតិមោក្ខ ការសូត្រ

បាតិមោក្ខនោះនឹងជាឧបោសថកម្ម គឺការធ្វើឧបោសថរបស់ភិក្ខុទាំងនោះ ។ ទើបទ្រង់បញ្ញត្តតាមដែលទ្រង់ព្រះតម្រិះនោះ និងសំដែងវិធីសូត្របាតិមោក្ខចាប់តាំងអំពីកិច្ចដំបូង ។

## កតិកាបន្ថែមទាក់ទងនឹងបាតិមោក្ខ

១.ភិក្ខុទាំងឡាយសូត្របាតិមោក្ខរាល់ថ្ងៃ ទ្រង់ត្រាស់ហាម និងពិន័យអាបត្តិទុក្កដដល់អ្នកធ្វើដូចនោះ ។ ទ្រង់អនុញ្ញាតឲ្យសូត្រចំពោះតែថ្ងៃឧបោសថ ។

២.ភិក្ខុទាំងឡាយសូត្របាតិមោក្ខ ៣ ដងក្នុង ១ បក្ស (កន្លះខែ) គឺក្នុងថ្ងៃ ១៤ កើត, ១៥ កើត និង ៨ កើត ទ្រង់ត្រាស់ហាម និងពិន័យអាបត្តិទុក្កដដល់អ្នកធ្វើដូចនោះ ។ ទ្រង់អនុញ្ញាតឲ្យសូត្របាតិមោក្ខតែម្តងក្នុង ១ បក្ស គឺក្នុងថ្ងៃ ១៤ រោច ឬ ១៥ កើត ។

៣.ភិក្ខុឆព្វគ្គិយសូត្របាតិមោក្ខតែក្នុងបក្សពួករបស់ខ្លួន ទ្រង់ត្រាស់ហាម និងពិន័យអាបត្តិទុក្កដដល់អ្នកធ្វើដូចនោះ ។ ទ្រង់អនុញ្ញាតឲ្យធ្វើឧបោសថដោយព្រមព្រៀងគ្នា ។

៤.ភិក្ខុទាំងឡាយសង្ស័យថា នឹងកំណត់ទីព្រមព្រៀងគ្នាក្នុងអាវាសមួយ ឬកំណត់ទីទាំងអស់ ទ្រង់ត្រាស់ឲ្យប្រើអាវាសតែមួយជាខេត្តសាមគ្គី ។

៥.ព្រះមហាកប្បិន (ជាព្រះអរហន្ត) គិតថា លោកបរិសុទ្ធហើយ តើគួរធ្វើឧបោសថសង្ឃកម្មដែលឬទេ ព្រះមានព្រះភាគទ្រង់ជ្រាបទើបត្រាស់ថា បើលោកមិនសក្ការៈ គោរព ជឿ បូជាឧបោសថហើយនោះ តើអ្នកណាមួយនឹងធ្វើតាម ។ ទើបទ្រង់ត្រាស់ឲ្យធ្វើឧបោសថកម្ម ។

៦.ភិក្ខុទាំងឡាយសង្ស័យថា អាវាសនោះកំណត់ដូចម្តេច ទើបទ្រង់អនុញ្ញាតឲ្យសន្មត គឺប្រកាសសីមា (ខេត្តដែន) ដោយការកំណត់ភ្នំ ដុំថ្ម ព្រៃ ដើមឈើ ផ្លូវ ដំបូក ស្ទឹង ឬថ្លុកទឹកជាគ្រឿងសម្គាល់ (និមិត្ត) រួចទ្រង់ក៏សំដែងវិធីសូត្រសន្មតសីមា ដោយគ្រឿងសម្គាល់នោះ ។

៧.ភិក្ខុឆព្វគ្គិយសន្មតសីមាធំលើស ៤ យោជន៍ខ្លះ ៥ យោជន៍ខ្លះ ៦ យោជន៍ខ្លះ ។ ភិក្ខុទាំងឡាយមកចំពេលសូត្របាដិមោក្ខក៏មាន សូត្រចប់ក៏មាន កំពុងសូត្រក៏មាន ទើបទ្រង់ហាមសន្មតសីមាធំពេក ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកបំពាន រួចទ្រង់អនុញ្ញាតឲ្យសន្មតសីមាធំត្រឹម ៣ យោជន៍ ។

៨.ភិក្ខុឆព្វគ្គិយសន្មតសីមាមាត់ស្ទឹង ភិក្ខុដែលមកធ្វើឧបោ-សថ ក៏ត្រូវទឹកផាត់ក្លួចយកទៅព្រមទាំងបាត្រចីវរ ទើបទ្រង់ត្រាស់ហាមសន្មតសីមាដូចនោះ ទ្រង់អនុញ្ញាតឲ្យធ្វើបានលុះត្រាមានទូកចតនៅជាប្រចាំ ឬមានស្ពានជាប់នៅជាប្រចាំ ។

៩.ភិក្ខុទាំងឡាយសូត្របាតិមោក្ខតាមបរិវេណ មិនមានទីសម្គាល់ ។ អាគន្តុកភិក្ខុ (ភិក្ខុដែលមកអំពីទីដទៃ) មិនដឹងថាធ្វើឧបោសថនៅទីណា ទើបទ្រង់អនុញ្ញាតឲ្យសន្មតរោងឧបោសថ ទោះជាវិហារ (កុដិអាស្រ័យនៅ) ក្តី រានហាលក្តី ប្រាសាទ (ផ្ទះមានជាថ្នាក់ៗ) ក្តី ផ្ទះត្រងិល (ដំបូលកាត់) ក្តី ល្ហាងក្តី ។

១០.ភិក្ខុទាំងឡាយសន្មតរោងឧបោសថ ២ កន្លែងនៅក្នុងអាវាសតែមួយ ។ ទ្រង់ត្រាស់ហាម និងណែនាំឲ្យសូត្រដករោងឧបោសថ ១ ចេញ (ឲ្យប្រើតែមួយ) ។

១១.ភិក្ខុទាំងឡាយសន្មតរោងឧបោសថតូចពេក មានភិក្ខុមកប្រជុំគ្នាច្រើន រូបខ្លះត្រូវអង្គុយនៅក្រៅខេត្ត ។ ព្រះមានព្រះភាគត្រាស់ថា ជាការធ្វើឧបោសថ និងត្រាស់ណែនាំឲ្យកំណត់គ្រឿងសម្គាល់ (និមិត្ត) រួចប្រជុំសង្ឃសូត្រសន្មតនៅចំពោះមុខ ឧបោ-សថរីកចេញទៅតាមត្រូវការ ។

១២.ភិក្ខុបួសថ្មីមកប្រជុំគ្នាមុននៅក្នុងថ្ងៃឧបោសថ គិតថាព្រះថេរៈមិននិមន្តមក ទើបនាំគ្នាត្រឡប់ទៅវិញ ។ ទម្រាំនឹងបានធ្វើឧបោសថក៏យប់ជ្រៅល្មម ទើបទ្រង់ត្រាស់អនុញ្ញាតឲ្យភិក្ខុជាថេរៈមកប្រជុំគ្នាមុននៅក្នុងថ្ងៃឧបោសថ ។

១៣.មានវត្តច្រើននៅក្នុងសីមាតែមួយ ភិក្ខុដែលនៅក្នុងវត្តណាក៏ធ្វើឧបោសថនៅក្នុងវត្តនោះ ។ ព្រះមានព្រះភាគទ្រង់ឲ្យប្រជុំគ្នានៅក្នុងកន្លែងតែមួយ មិនឲ្យញែកគ្នាធ្វើឧបោសថទេ ។

១៤.ទ្រង់ត្រាស់អនុញ្ញាតឲ្យសន្មតសីមា នៅក្នុងខេត្តតែមួយធ្វើឧបោសថរួមគ្នា ឲ្យជាខេត្តមិននៅប្រាសចាកត្រៃចីវរ (ខាងក្នុងបរិវេណសីមានោះទៅណាក៏បាន មិនចាំបាច់នាំយកចីវរគ្រប់សម្រាប់ជាប់ទៅជាមួយទេ) និងឲ្យសន្មតដោយវៀរចាកខេត្តស្រុក និងលង្វែកស្រុក (ប្រយោជន៍ដើម្បីមិនឲ្យទុកចីវរនៅក្នុងស្រុក) ។

១៥.ទ្រង់ត្រាស់អនុញ្ញាតថា នៅពេលសូត្រដក (ឈប់ប្រើ) ឲ្យដកខេត្តដែលនៅប្រាសចាកត្រៃចីវរជាមុន រួចដកខេត្តដែលនៅរួមគ្នាជាខាងក្រោយ ។

១៦.បើនៅមិនទាន់បានសន្មតសីមា ឲ្យប្រើស្រុក ឬនិគមដែលនៅនោះ ជាគាមសីមានិងនិគមសីមាបាន ហើយទ្រង់អនុញ្ញាតឲ្យប្រើខេត្តដែលនៅផុតរយៈទឹកសាចដល់ នៅក្នុងស្ទឹងជាឧទកុក្ខេប-សីមា (ខេត្តបាចទឹក) ជាខេត្តបណ្តែតទឹក ឬក្បូន ឬសង់រោងធ្វើឧបោសថកណ្តាលស្ទឹង ទន្លេ ឬស្រះបាន ប៉ុន្តែមិនអនុញ្ញាតស្ទឹងទន្លេ ឬស្រះទាំងអស់ជាខេត្ត (សីមា) ទេ ។

១៧.ទ្រង់ត្រាស់ហាមសន្មតសីមាជាប់គ្នា ឲ្យមានគំលាតសីមា

១៨.ទ្រង់ត្រាស់ពន្យល់ថា ថ្ងៃឧបោសថ ១៤ រោចក៏មាន ថ្ងៃ ១៥ កើតក៏មាន (ពាក់កណ្ដាលខែជា ១៥ កើត ចុងខែជា ១៤ រោចខ្លះ ១៥ រោចខ្លះ អាស្រ័យទៅលើខែខ្វះ ឬខែពេញ) ។

១៩.ទ្រង់ត្រាស់ពន្យល់អំពីរបៀប នៃការសូត្របាតិមោក្ខ នៅពេលមានហេតុសមគួរ ១០ យ៉ាងកើតឡើង ។

២០.ធម្មកថិកត្រូវតែទទួលការអារាធនា ទ្រង់អនុញ្ញាតឲ្យព្រះថេរៈសំដែងធម៌ម្នាក់ឯង ឬអារាធនាភិក្ខុដទៃសំដែង ។

២១.ទ្រង់ត្រាស់អនុញ្ញាតឲ្យមានការសន្មតអ្នកសួរវិន័យ និងអ្នកឆ្លើយវិន័យ ។

២២.ទ្រង់ត្រាស់អនុញ្ញាតឲ្យសុំឱកាសជាមុន រួចទើបចោទអាបត្តិ ។

២៣.ក្នុងពេលធ្វើការវិវាទរបស់សង្ឃ ទ្រង់អនុញ្ញាតឲ្យសំដែងមតិជំទាស់បាន ដោយអធិដ្ឋានក្នុងចិត្តថា មិនយល់ឃើញតាមនៅពេលមាននរណាម្នាក់ជំទាស់ឡើង ។

២៤.ទ្រង់ត្រាស់ហាមក្លែងសូត្របាតិមោក្ខ ដោយមិនឲ្យអ្នកដទៃបានឮផង បើមានសំឡេងខុសពីធម្មតា និងព្យាយាមហើយមិនត្រូវអាបត្តិ ។

២៥.ទ្រង់ត្រាស់ហាមសូត្របាតិមោក្ខ ដោយមានគ្រហស្ថឋិតនៅក្នុងចំណោមបរិស័ទ ។

២៦.ភិក្ខុដែលមិនបានអារាធនា ទ្រង់ហាមសូត្របាតិមោក្ខ, ទ្រង់អនុញ្ញាតឲ្យព្រះថេរៈជាប្រធាននៅក្នុងរឿងបាតិមោក្ខ (ទោះបីសូត្រខ្លួនឯង ឬឲ្យអ្នកដទៃសូត្រក៏បាន) ។

២៧.ព្រះថេរៈសូត្រខ្លួនឯងមិនបាន ទើបទ្រង់អនុញ្ញាតឲ្យភិក្ខុឈ្លាសក្នុងរឿងបាតិមោក្ខជាប្រធានបាន ។

២៨.ភិក្ខុទូទាំងវត្តមិនអាចសូត្របាតិមោក្ខបាន អនុញ្ញាតឲ្យបញ្ជូនភិក្ខុមួយរូបទៅរៀនអំពីអាវាសជិតខាង ទោះបីដោយសង្ខេប ឬដោយពិស្ដារ ឲ្យព្រះថេរៈជាអ្នកបញ្ជូនទៅ អ្នកដែលត្រូវបញ្ជូនទៅបើប្រកែកមិនព្រមទៅដោយមិនមានអាពាធ ត្រូវអាបត្តិទុក្កដ ។

២៩.ទ្រង់ត្រាស់អនុញ្ញាតឲ្យរៀនគណនាបក្ខ (រាប់ចំនួនបក្ខ) គ្រប់រូប ដើម្បីប្រាប់តិថីដល់មនុស្សម្នាបាន ។

៣០.ទ្រង់ត្រាស់អនុញ្ញាតឲ្យហៅឈ្មោះ ឲ្យចាប់ស្លាកដើម្បីរាប់ចំនួនភិក្ខុក្នុងថ្ងៃធ្វើឧបោសថ ។

៣១.ទ្រង់ត្រាស់អនុញ្ញាតឲ្យបោសសម្អាត, ក្រាលអាសនៈ, តាំងប្រទីប, តម្កល់ទឹកផឹក ទឹកប្រើប្រាស់ក្នុងរោងឧបោសថ ដោយឲ្យព្រះថេរៈជាអ្នកមើលការខុសត្រូវ ។

៣២.ទ្រង់ត្រាស់ហាមភិក្ខុដែលទៅកាន់ទីដទៃ ដោយមិនបានប្រាប់លាឧបជ្ឈាយ៍ ឬអាចារ្យ, ឲ្យឧបជ្ឈាយ៍ ឬអាចារ្យសាកសួរថាទៅទីណា ទៅជាមួយអ្នកណា បើឃើញថាពុំសមគួរ មិនត្រូវអនុញ្ញាត បើមិនអនុញ្ញាតហើយនៅតែចចេសទៅ ត្រូវអាបត្តិទុក្កដ ។

៣៣.មានភិក្ខុជាអ្នកឈ្លាសវៃ ប្រព្រឹត្តខ្លួនល្អមក ឲ្យទទួលដោយល្អ បើមិនទទួលដោយល្អទេ ត្រូវអាបត្តិទុក្កដ ។

៣៤.បើមិនមានអ្នកណាសូត្របាតិមោក្ខបាន និងមិនអាចបញ្ជូនអ្នកណាទៅរៀនបាន ហាមនៅចាំវស្សារួមជាមួយភិក្ខុទាំងនោះ បើនៅតែរឹងទទឹង ត្រូវអាបត្តិទុក្កដ ។

៣៥.ភិក្ខុអាពាធ ទ្រង់ត្រាស់ឲ្យប្រាប់សេចក្ដីបរិសុទ្ធដល់ភិក្ខុមួយរូបដើម្បីនាំទៅប្រាប់ដល់សង្ឃ ។ បើមិនមានអ្នកនាំដំណឹងទៅប្រាប់ទេ អនុញ្ញាតឲ្យដាក់លើគ្រែ ឬតាំង ហាមទៅធ្វើឧបោសថ។ មិនឲ្យធ្វើឧបោសថបែកគ្នា បើឲ្យឃ្លាតចាកទីអាពាធនឹងកម្រើក ឬអាចដល់ថ្នាក់មរណភាព អនុញ្ញាតឲ្យសង្ឃទៅធ្វើឧបោសថ ដល់កន្លែងភិក្ខុនោះ ។

បន្ទាប់មកត្រាស់ឲ្យភិក្ខុអ្នកទទួលប្រាប់បារិសុទ្ធិត្រូវទៅប្រាប់ដល់សង្ឃឲ្យខាងតែបាន បើទៅមិនបានដោយខ្លួនឯង អនុញ្ញាតឲ្យប្រគល់ដល់អ្នកដទៃទៅជំនួសបាន ។

៣៦.ក្នុងសង្ឃកម្មដទៃអំពីឧបោសថ បើភិក្ខុអាពាធ ទ្រង់ត្រាស់អនុញ្ញាតឲ្យប្រគល់ឆន្ទៈ និងមានលក្ខណដូចឧបោសថ (ឆន្ទៈគឺសេចក្ដីពេញចិត្ត ប្រគល់ឲ្យសង្ឃធ្វើកម្មដោយខ្លួនមិនបានទៅរួម) ។

៣៧.ក្នុងថ្ងៃឧបោសថ បើមានសង្ឃកម្មដទៃដែរ ទ្រង់ត្រាស់អនុញ្ញាតឲ្យភិក្ខុប្រាប់សេចក្ដិបរិសុទ្ធ និងប្រាប់ឆន្ទៈផង ។

៣៨.ភិក្ខុត្រូវញាតិឃាត់ខ្លួន ឬមនុស្សដទៃឃាត់ខ្លួន មិនអាចមកចូលរួមធ្វើឧបោសថបាន អនុញ្ញាតឲ្យបរចាសុំខ្លួនមកធ្វើឧបោ-សថ បើចរចាមិនសម្រេច អនុញ្ញាតឲ្យនាំចេញឲ្យផុតអំពីខេត្តសីមាដើម្បីឲ្យសង្ឃធ្វើឧបោសថ ហាមធ្វើឧបោសថទាំងដែលមានភិក្ខុដទៃនៅក្នុងខេត្តសីមា តែមិនបានចូលរួមប្រជុំ ។

៣៩.បើនៅក្នុងឧបោសថ ឬសង្ឃកម្មដទៃ មានភិក្ខុឆ្កួតអនុញ្ញាតឲ្យសង្ឃសូត្រសន្មតដើម្បីបានធ្វើឧបោសថ ឬសង្ឃកម្មដទៃដោយមិនឲ្យមានលោកនៅជាមួយផង ។

៤០.ភិក្ខុមាន ៤ រូប ទ្រង់ត្រាស់អនុញ្ញាតឲ្យសូត្របាតិ-មោក្ខ, បើមាន ៣ រូប ឬ ២ រូប ឲ្យប្រជុំគ្នាប្រាប់សេចក្ដីបរិសុទ្ធដល់គ្នានឹងគ្នា ហៅថាបារិសុទ្ធិឧបោសថ។ បើមានតែមួយរូប ឲ្យបោសសម្អាត ស្ថានទីរង់ចាំភិក្ខុដទៃ កាលបើមិនឃើញមក ឲ្យអធិដ្ឋាន គឺតាំងចិត្ត រំពុកថា ថ្ងៃនេះជាថ្ងៃឧបោសថ បើមិនធ្វើដូច្នេះទេ ត្រូវអាបត្តិទុក្កដ ។

៤១.មិនអនុញ្ញាតឲ្យធ្វើឧបោសថ ទាំងដែលនៅមានអាបត្តិ ឲ្យសំដែងអាបត្តិចេញសិន សឹមធ្វើឧបោសថ បើសង្ស័យក្នុងអាបត្តិ ត្រូវប្រាប់ដល់ភិក្ខុមួយរូប ។

៤២.ហាមភិក្ខុដែលត្រូវអាបត្តិដូចគ្នា (សភាគាបត្តិ) សំដែងអាបត្តិនោះដល់គ្នា បើសំដែង ឬទទួល ត្រូវអាបត្តិទុក្កដ ។

៤៣.បើរឭកបានថា នៅមានអាបត្តិ ឬសង្ស័យថា ត្រូវអាបត្តិណាមួយក្នុងខណៈពេលកំពុងស្តាប់បាតិមោក្ខ ឲ្យប្រាប់ដល់ភិក្ខុដែលនៅជិតខ្លួនដើម្បីទទួលដឹងឮ កាលបើឧបោសថចប់រួចរាល់ហើយ ឲ្យសំដែងចេញ ។

៤៤.បើសង្ស័យត្រូវអាបត្តិក្នុងរឿងដូចគ្នា (សភាគាបត្តិ) ទូទាំងវត្ត ឲ្យបញ្ជូនភិក្ខុមួយរូបទៅសំដែងនៅវត្តដទៃ បើមិនមានវត្តនៅជិតខាង ឲ្យទៅ ៧ ថ្ងៃ ដើម្បីរកកន្លែងសំដែងអាបត្តិជាប្រយោជន៍រួម ។

៤៥.បើសង្ឃទាំងវត្តត្រូវអាបត្តិក្នុងរឿងដូចគ្នា តែមិនដឹងឈ្មោះ ឬមូលហេតុនៃអាបត្តិ ឲ្យសាកសួរភិក្ខុដែលឈ្លាសក្នុងរឿងវិន័យដែលចូលមកស្នាក់អាស្រ័យ ហើយសំដែងអាបត្តិចេញ ។ ប៉ុន្តែបើបានសាកសួរប្រាស្រ័យគ្នារួចហើយ ភិក្ខុទាំងឡាយមិនព្រមសំដែងអាបត្តិចេញ (ពីព្រោះមិនស្តាប់តាមជាដើម) ក៏ឲ្យបណ្តោយទៅលោកចុះ មិនត្រូវនិយាយជាមួយទេ ។

៤៦.បន្ទាប់មក ទ្រង់សំដែងលក្ខណ្ឌ ក្នុងការធ្វើឧបោសថដែលមិនត្រូវអាបត្តិទាក់ទងនឹងការមិនដឹងថា នៅមានភិក្ខុដទៃទៀតទើបធ្វើឧបោសថមុន រួមមាន ១៥ ខ ។

៤៧.បន្ទាប់មកទៀត ទ្រង់សំដែងលក្ខណ្ឌក្នុងការធ្វើឧបោសថដែលធ្វើដោយចិត្តបរិសុទ្ធ ប៉ុន្តែដឹងថានៅមានភិក្ខុដទៃទៀតនៅមិនទាន់មកធ្វើឧបោសថ ត្រូវពិន័យអាបត្តិទុក្កដដល់ភិក្ខុអ្នកសូត្រ រួមមាន ១៥ ខ ។

៤៨.បន្តមក ទ្រង់សំដែងលក្ខណ្ឌក្នុងការធ្វើឧបោសថ (ដូចខ ៤៧) ដែរ ប៉ុន្តែសង្ស័យថា ជាការគួរ ឬមិនគួរ ហើយនៅតែចចេសសូត្របាតិមោក្ខ ត្រូវពិន័យអាបត្តិទុក្កដដល់អ្នកសូត្រ រួមមាន ១៥ ខ ។

៤៩.បន្តមកទៀត ទ្រង់សំដែងលក្ខណ្ឌក្នុងការធ្វើឧបោសថ (ដូចខ ៤៨) តែរង្កៀស ឬសង្ស័យថា គួរ ឬមិនគួរ ហើយនៅតែចចេសសូត្របាតិមោក្ខ ត្រូវពិន័យអាបត្តិដល់អ្នកសូត្រ រួមមាន ១៥ ខ ។

៥០.បន្តបន្ទាប់មក ទ្រង់សំដែងលក្ខណ្ឌ ក្នុងការធ្វើឧបោសថ (ដូចខ ៤៩) ប៉ុន្តែមានបំណងឲ្យបែកគ្នា ហើយនៅតែចចេសសូត្របាតិមោក្ខ ។ ពិន័យអាបត្តិថុល្លច្ច័យ (ធ្ងន់ជាងទុក្កដ) ដល់ភិក្ខុអ្នកសូត្រ រួមមាន ១៥ ខ ។

៥១.បន្តបន្ទាប់មកទៀត ទ្រង់សំដែងលក្ខណ្ណដូចមុនៗ រវាងភិក្ខុដែលនៅក្នុងវត្តជាមួយភិក្ខុដែលនៅក្នុងវត្ត, រវាងភិក្ខុដែលនៅក្នុងវត្តជាមួយអាគន្តុកភិក្ខុ, រវាងអាគន្តុកភិក្ខុជាមួយភិក្ខុដែលនៅក្នុងវត្ត និងរវាងអាគន្តុកភិក្ខុជាមួយអាគន្តុកភិក្ខុ រួមមាន ១៥ ខ ។

៥២.ជាបន្តបន្ទាប់មកទៀត ទ្រង់សំដែងលក្ខណ្ណនៃការរាប់ថ្ងៃឧបោសថ ១៤ រោច ឬ ១៥ កើត ដែលភិក្ខុនៅក្នុងវត្ត ជាមួយអាគន្តុកភិក្ខុមានការយល់ឃើញផ្សេងគ្នា ឲ្យអនុលោមតាមភិក្ខុដែលមានចំនួនច្រើនជាដើមរាប់រយខ ។

៥៣.ក្នុងទីបំផុត ទ្រង់សំដែងគោលការណ៍មិនឲ្យអ្នកដែលមិនសមគួរអង្គុយរួមជាមួយក្នុងការសូត្របាតិមោក្ខ នៅក្នុងថ្ងៃឧបោសថ រួមមាន ២២ ខ ដែលមិនឲ្យសូត្របាតិមោក្ខ ដូចជាមានភិក្ខុនី អង្គុយរួមជាមួយជាដើម ។

(កត់សម្គាល់ៈ តាមលំដាប់លេខពី ១ ដល់ ៥៣ ខនេះ គឺកំណត់ដោយខ្លួនឯងដើម្បីឲ្យយល់បានងាយ បើតាមលំដាប់ខដែលទ្រង់បញ្ញត្តទុក គឺមានចំនួនច្រើនរាប់ពាន់ខ) ។

## វិនយបិដកភាគ ៧

## ៣.វស្សូបនាយិកខន្ធកៈ (វគ្គនៃថ្ងៃចូលវស្សា)

ព្រះមានព្រះភាគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ក្រុងរាជគ្រឹះ ។ សម័យនោះ ទ្រង់មិនទាន់បានបញ្ញត្តរឿងការចាំវស្សា (គឺអាស្រ័យនៅក្នុងវត្តអស់រយៈពេល ៣ ខែក្នុងរដូវភ្លៀង) នៅឡើយ ភិក្ខុទាំងឡាយត្រាច់ទៅកាន់ទីផ្សេងៗ គ្រប់រដូវកាល ។ មានគេតិះដៀលថា ដើរជាន់សំណាបសន្ទូង និងសត្វតូចៗ ស្លាប់អស់ ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តព្រះវិន័យឲ្យភិក្ខុចាំវស្សា ។

បន្ទាប់មកទ្រង់សំដែងថា ថ្ងៃចាំវស្សាមាន ២ យ៉ាង គឺថ្ងៃចាំវស្សាមុន និងថ្ងៃចាំវស្សាក្រោយ (កាលបើព្រះចន្ទបានបុក្សអាសាឍកន្លងទៅមួយថ្ងៃ គឺថ្ងៃ ១ រោច ខែអាសាឍ ជាថ្ងៃចូលវស្សាមុន, កាលបើព្រះចន្ទបានបុក្សអាសាឍកន្លងទៅមួយខែ គឺ ១រោច ខែស្រាពណ៍ ជាថ្ងៃចូលវស្សាក្រោយ អាចសន្និដ្ឋានបានថា ទ្រង់បញ្ញត្ត តាមឆ្នាំធម្មតា និងឆ្នាំមានអធិកមាស ទើបមាន ២ យ៉ាងដូច្នេះ) ។

បន្ទាប់ពីនោះមកទ្រង់ហាមត្រាច់ទៅណាមកណាអស់ ៣ ខែ នៃថ្ងៃចូលវស្សាមុន ឬចូលវស្សាក្រោយ ដោយយោងទៅលើហេតុនេះ ។ ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលប្រព្រឹត្តកន្លងល្មើស ។

បន្ទាប់ពីនោះមកទៀត ទ្រង់បញ្ញត្តព្រះវិន័យ ពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលដល់ថ្ងៃចូលវស្សាហើយមិនចាំវស្សា ឬឃើញវត្តហើយក្លែងដើរហួសទៅ ។

## ទ្រង់អនុម័តការពន្យារថ្ងៃចូលវស្សា

ព្រះបាទពិម្ពិសារទ្រង់បញ្ជូនទូតទៅគាល់ព្រះមានព្រះភាគ សុំឲ្យពន្យារថ្ងៃចាំវស្សាក្នុងថ្ងៃពេញបូរមីខាងមុខ (សរុបត្រូវជា ១ ខែ) ទើបទ្រង់អនុញ្ញាតឲ្យអនុវត្តតាមព្រះរាជសំណើ (សន្និដ្ឋានថា ទ្រង់សុំឲ្យពន្យារការចាំវស្សាទៅតាមឆ្នាំអធិកមាសខាងផ្លូវលោក) ។

## ទ្រង់អនុញ្ញាតឱ្យត្រឡប់វិលវិញក្នុងចន្លោះ ៧ ថ្ងៃ

បន្ទាប់អំពីនោះ ទ្រង់អនុញ្ញាតឲ្យធ្វើដំណើរទៅបាននៅក្នុងចន្លោះថ្ងៃចាំវស្សា ដោយឲ្យត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ នៅពេលមានករណីចាំបាច់កើតឡើង ហៅថា «សត្តាហករណីយៈ» ដូចតទៅៈ

១.ទាយកប្រាថ្នាបំពេញបុណ្យកុសល បញ្ជូនមនុស្សមកនិមន្ត ក្នុងករណីនេះ ទ្រង់អនុញ្ញាតឲ្យទៅបានចំពោះទីដែលគេនិមន្តប៉ុណ្ណោះ បើមិនបញ្ជូនមនុស្សមកនិមន្ត ហាមទៅ ។

២.សំឡាញ់សហធម្មិក គឺអ្នកបួសជាមួយគ្នា (ភិក្ខុ, ភិក្ខុនី, សិក្ខមានា, សាមណេរ, សាមណេរី) អាពាធបញ្ជូនមនុស្សមកនិមន្ត ឬមិនបញ្ជូនក៏ដោយ ទ្រង់អនុញ្ញាតឲ្យទៅបាន ។ ក្រៅពីនោះ ទ្រង់ក៏បានបញ្ញត្តលម្អិតបន្ថែមទៀតទាក់ទងទៅនឹងសម្លាញ់សហធម្មិក គឺនៅពេលសម្លាញ់សហធម្មិកអាពាធ ភិក្ខុប្រាថ្នាជួយស្វែងរកអាហារ, មើលព្យាបាល និងស្វែងរកថ្នាំ ក៏ទៅបាន ។ កាលបើសម្លាញ់ សហធម្មិកកើតការមិនត្រេកអរ មានសេចក្តីរង្កៀស ឬមានមិច្ឆាទិដ្ឋិ ទ្រង់អនុញ្ញាតឲ្យទៅរម្ងាប់ហេតុនោះៗបាន ។ កាលបើសម្លាញ់ សហធម្មិក (ភិក្ខុ, ភិក្ខុនី) ត្រូវអាបត្តិសង្ឃាទិសេស ប្រាថ្នាចេញចាកអាបត្តិលំដាប់ណាៗ ក៏បាន ឬសង្ឃប្រាថ្នាធ្វើសង្ឃកម្មដាក់ទោស ភិក្ខុរូបណាមួយ ភិក្ខុរូបនោះត្រូវការឲ្យលោកទៅ ក៏ទៅបាន ដើម្បីសម្រុះសម្រួលមិនឲ្យធ្វើកម្ម ឬឲ្យដាក់ទោសស្រាល, ដើម្បីឲ្យបដិបត្តិប្រពៃតាមព្រះវិន័យ និងដើម្បីលើកទឹកចិត្តជាដើម ឬកាលបើសិក្ខមានា ឬសាមណេរប្រាថ្នាបួស ទៅដើម្បីជួយរៀបចំក្នុងកិច្ចការនោះ បាន ។

៣.មាតា បិតា បងប្អូន ឬញាតិឈឺ បញ្ជូនមនុស្សមកនិមន្ត ឬមិនបញ្ជូនមកក៏ដោយ បើដឹងដំណឹង ទៅបាន ។

៤.វិហារទ្រុឌទ្រោម ទៅដើម្បីរកវត្ថុមកបដិសង្ខរណ៍ (ជួសជុល) បាន ។

## ដាច់វស្សាតែមិនត្រូវអាបត្តិ

កាលបើមានហេតុកើតឡើង មិនអាចចាំវស្សានៅក្នុងទីនោះៗ បានតទៅទៀត ទ្រង់អនុញ្ញាតឲ្យចេញចាកអំពីទីនោះបានដោយមិនត្រូវអាបត្តិដូចតទៅនេះ

១.ត្រូវសត្វសាហាវបៀតបៀន ត្រូវចោរប្លន់ វិហារត្រូវភ្លើងឆេះ ឬត្រូវទឹកជន់លិច ។

២.អ្នកស្រុកត្រូវចោរប្លន់ រើទីលំនៅចេញ ទ្រង់អនុញ្ញាតឲ្យទៅជាមួយគេបាន ។ អ្នកស្រុកបែកគ្នាជាពីរបក្ស ទ្រង់អនុញ្ញាតឲ្យទៅខាងច្រើនបាន ឬបើបក្សខាងច្រើនមិនមានសទ្ធា តែខាងតិចមានសទ្ធា ទ្រង់អនុញ្ញាតឲ្យទៅខាងតិចបាន ។

៣.ខ្វះខាតអាហារ ឬថ្នាំព្យាបាលរោគ ឬខ្វះអ្នកទំនុកបម្រុងទទួលនូវទុក្ខលំបាក ទ្រង់អនុញ្ញាតឲ្យទៅបាន ។

៤.មានមនុស្សយកទ្រព្យមកលួងលោម ទ្រង់អនុញ្ញាតឲ្យទៅបាន ។

៥.ភិក្ខុសង្ឃ ឬភិក្ខុនីសង្ឃបែកគ្នា ឬមានអ្នកព្យាយាមកំពុងបំបែក ឬបែកគ្នារួចហើយ ទៅដើម្បីរកវិធីរម្ងាប់បាន ។

## **ទ្រង់អនុញ្ញាតការចាំវស្សានៅក្នុងកន្លែងខ្លះ**

មានភិក្ខុសង្ឃដទៃទៀតចាំវស្សានៅក្នុងទីផ្សេងៗ គ្នា ទ្រង់បន្ធូរបន្ថយការចាំវស្សាបាន គឺ

១.នៅក្នុងក្រោលសត្វ (មានក្រោលគោជាដើម)

២.នៅពេលក្រោលសត្វផ្លាស់ទី ទ្រង់អនុញ្ញាតឲ្យផ្លាស់ទីបាន

៣.នៅក្នុងក្បួនរទេះ

៤.នៅក្នុងទូក ។

## **ទ្រង់ហាមចាំវស្សានៅក្នុងទីមិនសមគួរ**

ទ្រង់ហាមការចាំវស្សានៅក្នុងទីមិនសមគួរ គឺ

១.នៅក្នុងរូងឈើ

២.នៅលើមែក ឬប្រគាបឈើ

៣.នៅកណ្ដាលវាល

៤.គ្មានសេនាសនៈ (គឺទីដេកទីអង្គុយ)

៥.នៅក្នុងមឈូស

៦.នៅក្នុងរោង (ដូចជារោងនាយគោបាលជាដើម)

៧.នៅក្នុងពាង ។

## **បទបញ្ញត្តិដទៃទៀត**

១.ហាមតាំងកតិកាមិនសមគួរ ដូចជា មិនបំបួសសាមណេរនៅក្នុងវស្សា ។

២.ហាមទទួលពាក្យចាំវស្សានៅក្នុងទីណាមួយហើយ មិនចាំវស្សានៅក្នុងទីនោះៗ ។

## ៤.បវារណាខន្ធកៈ (វគ្គនៃការបវារណា)

មានរឿងភិក្ខុចាំវស្សានៅក្នុងដែនកោសលតាំងកតិកា មិននិយាយរកគ្នា ដោយប្រើវិធីកប្រាស្រ័យរកគ្នា ឬប្រើដៃជំនួសសម្តី កាលបើចេញវស្សាហើយ ទើបនាំគ្នាទៅគាល់ព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់សួរដឹងរឿងរ៉ាវសព្វគ្រប់ហើយ ក៏តិះដៀល និងអនុញ្ញាតការបវារណា (គឺអនុញ្ញាតឲ្យភិក្ខុដទៃនិយាយដាស់តឿនបាន) នៅពេលចេញវស្សារួចហើយ ដោយសូត្រប្រកាសតាំងញត្តិរួចហើយឲ្យភិក្ខុដែលមានវស្សាចាស់ជាងបវារណា ៣ ដងមុន បន្ទាប់មកសឹមឲ្យភិក្ខុដែលមានវស្សាតិច បវារណាជាបន្តបន្ទាប់តាមក្រោយ ។

ទ្រង់ហាមមិនឲ្យអង្គុយរាបផ្ទាល់ផ្ទៃ (គឺឲ្យអង្គុយច្រហោង) រហូតដល់បវារណារួចរាល់ គឺឲ្យអង្គុយច្រហោងគ្រប់រូបៗណាបវារណាហើយមុនអង្គុយរាបផ្ទៃបាន ។

ទ្រង់សំដែងថ្ងៃបវារណាមាន ២ គឺថ្ងៃ ១៤ រោច និង ១៥ កើត បន្ទាប់មកសំដែងបវារណា ៤ យ៉ាង គឺបវារណាបែកគ្នាមិនប្រកបដោយធម៌, បវារណាព្រមគ្នាមិនប្រកបដោយធម៌, បវារណាបែកគ្នាប្រកបដោយធម៌, បវារណាព្រមគ្នាប្រកបដោយធម៌ សរុបមកទ្រង់អនុញ្ញាតឲ្យបវារណាព្រមគ្នាប្រកបដោយធម៌ ។

បន្ទាប់មកទៀត ទ្រង់សំដែងការប្រាប់បវារណា (ប្រាប់ឲ្យបុគ្គលដទៃបវារណាជំនួស) ភិក្ខុអាពាធ មានលក្ខណៈស្រដៀងគ្នានឹងការប្រាប់ភាពបរិសុទ្ធិ ឬឆន្ទៈនៅក្នុងវិធីធ្វើបាតិមោក្ខដែរ ។

ក្រោយមកទ្រង់អនុញ្ញាតឲ្យបវារណាជាសង្ឃ នៅពេលដែលមានភិក្ខុ ៥ រូបឡើងទៅ ភិក្ខុ ៤ រូបចុះមកសល់ត្រឹម ២ រូប ឲ្យបវារណាគ្នាឯង (ជាបុគ្គល) ។ បើមានត្រឹមតែមួយរូបឲ្យអធិដ្ឋាន គឺតាំងចិត្តថា ថ្ងៃនេះជាថ្ងៃបវារណាទី ... របស់អាត្មាអញ ។

ទ្រង់សំដែងការបវារណា ដោយមិនដឹងថាមានភិក្ខុមកគ្រប់ ១៥ ប្រភេទដែលមិនត្រូវអាបត្តិ និងសំដែងលក្ខខណ្ឌមានរបៀបដូចខបោសថដែរ ។

ម្យ៉ាងទៀត ទ្រង់សំដែងថា កាលបើមានហេតុចាំបាច់ត្រូវបវារណា ៣ ដងមិនបាន ទ្រង់អនុញ្ញាតឲ្យបវារណា ២ ដង ឬតែមួយដងក៏បាន និងអនុញ្ញាតឲ្យភិក្ខុដែលមានវស្សាស្មើគ្នា បវារណា

ព្រមគ្នាបាន ។ (ការបវារណានោះ គឺអនុញ្ញាតឲ្យពោលដាស់តឿនដោយការបានឃើញ (កំហុស) បានឮ ឬរង្កៀសសង្ស័យ) ។

ម្យ៉ាងវិញទៀត ទ្រង់ហាមភិក្ខុមានអាបត្តិមិនឲ្យធ្វើបវារណា បើចបេសធ្វើត្រូវអាបត្តិទុក្កដ ។ ទ្រង់អនុញ្ញាតឲ្យសុំឱកាសជាមុនសឹមចោទអាបត្តិ ។ បើភិក្ខុត្រូវអាបត្តិ មិនព្រមឲ្យឱកាសចោទអាបត្តិ ឲ្យសង្ឃសូត្រប្រកាសបញ្ឈប់ការបវារណាដោយអាងថា បុគ្គលនោះ ឬបុគ្គលនេះមានអាបត្តិ ។ ទ្រង់សំដែងលក្ខណៈបញ្ឈប់ការបវារណា ឬបញ្ឈប់មិនបាន (ពីព្រោះបានបវារណារួចហួសទៅហើយ) ជាដើម ។

មានភិក្ខុដទៃមកដោយមានបំណងបង្កជម្លោះ ឬអធិករណ៍ ទ្រង់អនុញ្ញាតឲ្យបវារណាដោយឆាប់រហ័សបាន មុនភិក្ខុទាំងនោះមកដល់ បើធ្វើដូច្នោះពុំបាន ឲ្យសូត្របាដិមោក្ខជំនួស ដោយពន្យាថ្ងៃបវារណាបានមួយបក្ស (១៥ ថ្ងៃ) ។ បើភិក្ខុនោះស្នាក់នៅរហូតដល់គ្រប់ ១៥ ថ្ងៃ អនុញ្ញាតឲ្យសូត្រប្រកាសពន្យាថ្ងៃបវារណាបានមួយបក្សទៀត រួចសូត្របាដិមោក្ខជំនួស ។ បើភិក្ខុទាំងនោះនៅតែស្នាក់នៅបន្តទៅទៀត ទោះបីមិនប្រាថ្នាបវារណា ក៏ត្រូវតែបវារណាទាំងអស់គ្នា (ពន្យាតទៅទៀតមិនបាន) ។

ភិក្ខុរួមរស់នៅជាមួយគ្នាជាសុខ បើបវារណាទៅអាចនាំឲ្យបែកគ្នា ទ្រង់អនុញ្ញាតឲ្យពន្យាថ្ងៃបវារណាបានមួយខែទៀត ។

## **មហាវគ្គ** (វិនយបិដក) ភាគ ៧

**១.ចម្មក្ខន្ធកៈ** (និយាយអំពីស្បែក) ក្នុងវគ្គនេះពោលអំពីប្រវត្តិព្រះសោណកោឡិវិសៈជាបុត្រសេដ្ឋី ចេញបួសបំពេញព្យាយាមរហូតដល់បែកបាតជើង ។ ទ្រង់អនុញ្ញាតឲ្យប្រើស្បែកជើងស្មោតែម្យ៉ាង ហាមប្រើស្បែកជើងមានពណ៌ផ្សេងៗ និងហាមប្រើស្បែកជើងស្បែកសត្វដែលមិនសមគួរផ្សេងៗ ទ្រង់សំដែងអំពីមារយាទក្នុងការប្រើស្បែកជើងថា ប្រើយ៉ាងណាគួរ យ៉ាងណា មិនគួរ ។ ហាមប្រើស្បែកជើងឈើ, ហាមប្រើយានដែលមិនសមគួរ, ហាមប្រើទីដេកទីអង្គុយធំខ្ពស់ ហាមប្រើស្បែកផ្ទាំងធំ ។ រឿងព្រះសោណកុដិកណ្ណនៅក្នុងដែនអវន្តី និងកំណត់ព្រំប្រទល់ជនបទ ភាគកណ្ដាល និងជនបទជាយដែន ។

**២.ភេសជ្ជខន្ធកៈ** (និយាយអំពីថ្នាំព្យាបាលជម្ងឺ) សំដែងអំពីថ្នាំផ្សេងៗ និយាយពីរឿងព្រះវេឡដ្ឋសីសៈ, ព្រះបិលិន្ទវច្ឆៈ ។ ទ្រង់អនុញ្ញាតការវះកាត់, អនុញ្ញាតថ្នាំ ៤ ប្រភេទ និងសម៉ត្រាំទឹកមូត្រ, អនុញ្ញាតមនុស្សធ្វើការវត្ត, អនុញ្ញាតភេសជ្ជៈ ៥ យ៉ាង, និយាយពីរឿងព្រះកង្ខារេវតៈ, ព្រះមានព្រះភាគទ្រង់ប្រឈួនខ្យល់ក្នុងព្រះឧទរ, ហាមទុកដាក់អាហារ និងចម្អិននៅក្នុងទីលំនៅ ។ រឿង

*សាច់មិនគួរឆាន់, ទ្រង់យាងទៅកាន់បាដលិគ្រាម, រឿងនាងអម្ពបាលី, រឿងទឹកបរិភោគ ៨ យ៉ាង និងរឿងកាលិកទាំង ៤ ។*

## វិនយបិដកភាគ ៨

**៣.កឋិនក្ខន្ធកៈ** *(និយាយអំពីកឋិន) រៀបរាប់ដល់ដើមហេតុ ដែលទ្រង់អនុញ្ញាតកឋិន អានិសង្ស ៥ នៃការក្រាល*[៦៥] *គ្រងកឋិន, កឋិនមិនឈ្មោះថាជាការក្រាល, ខកំណត់ ៨ យ៉ាងក្នុងការដោះកឋិន (ដកឈើស្នឹង), ការកង្វល់ និងការមិនកង្វល់ទាក់ទងទៅនឹងកឋិន ។*

**៤.ចីវរក្ខន្ធកៈ** *(ពោលអំពីចីវរ) រៀបរាប់អំពីរឿងរ៉ាវផ្សេងៗ តាំងអំពីការដែលទ្រង់អនុញ្ញាតឲ្យទទួលចីវរបាន រហូតដល់សំពត់ច្រើនប្រភេទ ព្រមទាំងសំពត់ដែលកើតឡើងតាមរយៈអ្នកប្រគេនដាក់លក្ខខណ្ឌផ្សេងៗ ។*

## វិនយបិដកភាគ ៩

[៦៥] *ក្រាល គឺត្រដាងសំពត់ដាក់ពីលើឈើស្នឹង, កឋិន ជាឈ្មោះនៃឈើស្នឹង គឺឈើសម្រាប់ដេរប៉ះចីវរ ។*

**៥.ចម្បេយ្យខន្ធកៈ***(ពោលអំពីហេតុការណ៍នៅក្នុងក្រុងចម្បា) ពណ៌នាអំពីកម្មរបស់សង្ឃផ្សេងៗ ដោយច្រើនជារឿងដាក់ទោសដូចជា ឧក្ខេបនីយកម្ម (ការលើកឡើងអំពីគណៈ) ជាដើម ។*

**៦.កោសម្ពីខន្ធកៈ** *(ពោលអំពីហេតុការណ៍នៅក្នុងក្រុងកោសម្ពី) ភាគច្រើនពណ៌នាអំពីរឿងសង្ឃបែកសាមគ្គីគ្នា រួចទ្រង់សំដែងវិធីបង្រួបបង្រួមសង្ឃតាមផ្លូវវិន័យ ។*

## សេចក្ដីអធិប្បាយ

### ១.ចម្មក្ខន្ធកៈ (ពោលអំពីស្បែក)

*ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះ ។ ព្រះបាទពិម្ពិសារជាអគ្គមហាសេនាបតីនៃដែនមគធៈ ទ្រង់ប្រកាសប្រជុំអ្នកស្រុកដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ស្រាប់តែជ្រាបថាបុត្រសេដ្ឋីឈ្មោះសោណកោឡិវិសៈមានរោមដុះចេញអំពីបាតជើង ទ្រង់ក៏មានព្រះបំណងដើម្បីទតមើល រួចក៏ឲ្យនាំខ្លួនមកដើម្បីទ្រង់ទត បន្ទាប់មកទ្រង់អប់រំអ្នកស្រុកទាំងនោះ អំពីប្រយោជន៍បច្ចុប្បន្ន ហើយឲ្យជនទាំងនោះ ចូលទៅគាល់ព្រះមានព្រះភាគ ដើម្បីស្ដាប់អំពីប្រយោជន៍ទៅអនាគត ។*

ព្រះមានព្រះភាគទ្រង់សំដែងអនុបុព្វីកថា (ពាក្យពោលតាមលំដាប់ គឺរឿងទាន សីល ឋានសួគ៌ ទោសនៃកាម និងអានិសង្សនៃការចេញចាកកាម) និងអរិយសច្ច ៤ ប្រការ ។ អ្នកស្រុកទាំងនោះ ប្តេជ្ញាខ្លួនជាឧបាសកដល់ព្រះរតនត្រ័យជាទីពឹងអស់មួយជីវិត ។

ចំណែកឯសោណកោឡិវិសៈវិញសុំបួស នៅពេលបួសហើយ បំពេញសេចក្តីព្យាយាមដើរចង្ក្រម (ដើរទៅវិញទៅមកដោយការអប់រំចិត្ត) រហូតដល់ជើងបែកចេញឈាម ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រះសោណកោឡិវិសៈកាលពីនៅមិនទាន់បួសធ្លាប់បានដេញពិណ ទើបទ្រង់សំដែងធម៌ឲ្យប្រព្រឹត្តជាកណ្តាល មិនតឹងពេក មិនធូរពេក ដូចដំឡើងខ្សែពិណឲ្យតឹងល្មម រមែងដេញឮសូរពីរោះ, ព្រះសោណកោឡិវិសៈបដិបត្តិតាម ក៏បានសម្រេចអរហត្តផល ។

## ទ្រង់អនុញ្ញាតស្បែកជើងស្នឹកឈើ

ព្រះពុទ្ធទ្រង់ជ្រាបថា ព្រះសោណកោឡិវិសៈជាសុខុមាលបុគ្គល (ទន់ជ្រាយ) ទ្រង់ក៏អនុញ្ញាតប្រើស្បែកជើងស្នឹកឈើមួយជាន់ ព្រះសោណៈស្នើថា បើអនុញ្ញាតដល់សង្ឃទើបលោកប្រើ ទ្រង់ក៏អនុញ្ញាតស្បែកជើងធ្វើដោយស្នឹកឈើមួយជាន់ ហាមប្រើ ២-៣ ជាន់ ឬត្រួតគ្នាច្រើនជាន់ជាងនោះ ។

## ទ្រង់ហាមស្បែកជើងមិនសមគួរ

ភិក្ខុឆព្វគ្គិយប្រើស្បែកជើងពណ៌ផ្សេងៗ មានគេតិះដៀល ទើបទ្រង់ហាមប្រើ ។ ពួកលោកប្រើត្រចៀកស្បែកជើង (ប្រកបដោយចំពាម) ពណ៌ផ្សេងៗ មានគេតិះដៀល ទ្រង់ហាមប្រើ ។ ពួកលោកត្រឡប់ទៅប្រើស្បែកជើងមានលក្ខណៈផ្សេងៗ ដូចជាស្បែកជើងបិទកែង, បិទខ្នងជើង និងកែច្នៃលម្អផ្សេងៗ ដែលគ្រហស្ថគេនាំគ្នាប្រើទូទៅ ទ្រង់ហាមទាំងអស់ ។ ក្រៅពីនោះ ទ្រង់ក៏ហាមប្រើស្បែកជើងស្បែកសត្វមិនសមគួរផ្សេងៗ ដែលគ្រហស្ថគេប្រើនៅក្នុងសម័យនោះ ដូចជា ស្បែកជើងធ្វើដោយស្បែកសត្វរាជសីហ៍, ខ្លាដំបង, អូដ្ឋជាដើម ។

## ការអនុញ្ញាត និង ការហាមឃាត់ ទាក់ទងនឹងស្បែកជើង

១-ទ្រង់អនុញ្ញាតស្បែកជើងច្រើនជាន់ ដែលគេប្រើហើយ ហាមប្រើស្បែកជើងថ្មី ។

២-បើភិក្ខុជាអាចារ្យ ឬឧបជ្ឈាយ៍មិនពាក់ស្បែកជើងដើរចង្ក្រម ហាមភិក្ខុពាក់ស្បែកជើងដើរចង្ក្រម ។

៣-ទ្រង់ហាមពាក់ស្បែកជើងក្នុងវត្ត ក្រោយមកទ្រង់អនុញ្ញាតឲ្យពាក់បាន ព្រមទាំងអនុញ្ញាតឲ្យប្រើគុកភ្លើង ប្រទីប និងឈើច្រត់ (ដើម្បីការពារបន្លា ដង្កូត់ និងដើម្បីងាយស្រួលក្នុងវេលាយប់ ។

៤-ទ្រង់អនុញ្ញាតឲ្យភិក្ខុឈឺជើង ជើងបែក ឬមានជម្ងឺត្រង់ជើង ពាក់ស្បែកជើងបាន ។

៥-ទោះបីជាឡើងលើគ្រែ លើតាំង ទ្រង់ក៏អនុញ្ញាតឲ្យពាក់ស្បែកជើងបាន (ដើម្បីការពារមិនឲ្យគ្រែ ឬតាំង ប្រឡាក់ ឬខូច) ។

៦-ហាមប្រើស្បែកជើងឈើ (ព្រោះមានសំឡេងខ្លាំង) ។

៧-ហាមប្រើស្បែកជើងស្លឹកត្នោត និងស្លឹកឫស្សី (ព្រោះភិក្ខុដើរសុំកាត់ដើមត្នោត និងដើមឫស្សីគេទាំងដែលនៅខ្ចី) ។

៨-ហាមប្រើស្បែកជើងស្មៅ និងស្បែកជើងឈើគ្រប់ប្រភេទ រហូតព្រមទាំងស្បែកជើងធ្វើអំពីពេជ្រ និងលោហៈផ្សេងៗ (ព្រោះនាំឲ្យមានកង្វល់ក្នុងរឿងស្បែកជើង ខូចពេលវេលាក្នុងការរៀនសូត្រ និងបដិបត្តិ) ។

៩-ទ្រង់អនុញ្ញាតជ្រញ (ទ្រនាប់) ជើងដែលជាប់នៅនឹងមួយកន្លែង សម្រាប់ប្រើក្នុងការបន្ទោបង់ខច្ចារៈ បស្សាវៈ និងជម្រះមន្ទិលផ្សេងៗ ។

ទាំងអស់នេះ បើប្រព្រឹត្តល្មើសត្រូវអាបត្តិទុក្កដ ។

## ការហាមឃាត់ទាក់ទងនឹងគោញី

គេដឹកគោញីឆ្លងកាត់ស្ទឹងអចិរវតី ភិក្ខុឆព្វគ្គិយដើរចាប់ស្នែងខ្លះ ត្រចៀកខ្លះ កខ្លះ កន្ទុយខ្លះ ឡើងជិះលើខ្នងខ្លះ ប៉ះអង្គជាតិដោយតម្រេកខ្លះ ចាប់ប្រមុជកូនគោឲ្យស្លាប់ខ្លះ មានគេធ្វើលឆោឡោតិះដៀល ។ ទើបទ្រង់ហាមធ្វើដូច្នោះ បើនៅតែរឹងទទឹង ពិន័យអាបត្តិគ្រប់ៗ ករណី (មានសិក្ខាបទក្នុងទីដទៃហាមគ្រប់ខ្សួចហើយ ទើបការហាមក្នុងទីនេះមិនបានបញ្ជាក់អាបត្តិទុក) ។

## ការហាមឃាត់ទាក់ទងនឹងយាន

ទ្រង់ហាមទៅដោយសារយាន វៀរលែងតែមិនសប្បាយ ទ្រង់អនុញ្ញាតឲ្យមនុស្សប្រុសអូស ទ្រង់អនុញ្ញាតគ្រែស្នែងមានតាំង

(កៅអី) អង្គុយ និងអង្រឹងស្នែងដែលគេចងភ្ជាប់នឹងដងរែក (ក្នុងរឿងនេះជាការហាមទៅតាមស្រុកទេស គឺមនុស្សក្នុងសម័យនោះឃើញភិក្ខុអង្គុយលើយាន ក៏នាំគ្នាតិះដៀល ទើបទ្រង់ហាមដើម្បីបញ្ចប់បញ្ហា ប៉ុន្តែទ្រង់អនុញ្ញាតនៅពេលមានហេតុសមគួរ ចំណែកការអនុញ្ញាតក្រែស្នែង អង្រឹងស្នែង ក៏ដើម្បីងាយស្រួលក្នុងពេលមានអាពាធ) ។

## ការហាមឃាត់ទាក់ទងនឹងទីអង្គុយ-ទីដេក

ទ្រង់ហាមទីអង្គុយទីដេកដ៏ខ្ពស់ហួសប្រមាណ មានលក្ខណៈវិចិត្រល្អឆើតជារបស់គ្រហស្ថគេប្រើប្រាស់ និងហាមប្រើស្បែកសត្វធំហួសប្រមាណ (សម្រាប់ក្រាលអង្គុយ ឬដេក) ដូចជាគ្រហស្ថ ។ ក្រោយមកមានភិក្ខុត្រូវការប្រើស្បែកគោ និងមានអ្នកសម្លាប់គោនាំស្បែកមកប្រគេន ទើបទ្រង់ហាមប្រើស្បែកសត្វគ្រប់ប្រភេទ វៀរលែងអង្គុយលើរបស់គ្រហស្ថ ដែលគេមានប្រើស្រាប់ ប៉ុន្តែហាមដេកលើនោះ (វិន័យត្រង់ចំណុចនេះ ដើម្បីការពារមិនឲ្យភិក្ខុមានគ្រឿងដេកសម្បូរហូរហៀដូចគ្រហស្ថ តែក្នុងករណីដែលគេនិមន្តឲ្យអង្គុយលើទីអង្គុយរបស់គេ ដែលមានស្រាប់ ទ្រង់អនុញ្ញាត) ។ ក្រៅពីនោះ ទ្រង់អនុញ្ញាតឲ្យប្រើស្បែកសត្វដែលគេធ្វើជាខ្សែ ។

## ហាមពាក់ស្បែកជើងចូលស្រុក

ទ្រង់ហាមពាក់ស្បែកជើងចូលស្រុក វៀរលែងតែមានអាពាធ (ទាំងនេះ ពីព្រោះមនុស្សទាំងឡាយនាំគ្នាតិះដៀលឆព្វគ្គិយភិក្ខុដែលធ្វើដូចនោះ សឲ្យឃើញថា បញ្ញត្តិនេះអនុលោមតាមការនិយម ឬមិននិយមរបស់ពពួកជន) ។

## សោណកុដិកណ្ណភិក្ខុ

សោណកុដិកណ្ណឧបាសកប្រាថ្នាបួស ទើបចូលទៅរកព្រះមហាកច្ចាយនៈសុំឲ្យជួយសង្គ្រោះបំបួសឲ្យ ។ លោកយល់ថាលំបាកក្នុងការបដិបត្តិទើបហាមឃាត់ នៅពេលសុំបួសជាលើកទីពីរ លោកយល់ថាតាំងចិត្តពិតប្រាកដ ទើបបំបួសឲ្យជាសាមណេរ និងទម្រាំរកភិក្ខុមកប្រជុំគ្នាបាន ១០ រូប ដើម្បីបំបួសជាភិក្ខុឲ្យ ក៏មានការលំបាកក្រៃលែង ពីព្រោះនៅតាមជនបទដាច់ស្រយាលដូចនោះមានភិក្ខុតិច ។ ព្រះសោណកុដិកណ្ណៈបួសហើយ មកចូលគាល់ព្រះមានព្រះភាគបាននាំសំណើព្រះមហាកច្ចាយនៈ ដែលជាឧបជ្ឈាយ៍មកក្រាបទូលជាច្រើនខ ទាក់ទងនឹងការដក ឬបន្ធូរព្រះវិន័យខ្លះៗ សម្រាប់ជនបទដាច់ស្រយាល ។

## ការអនុញ្ញាតសម្រាប់ជនបទដាច់ស្រយាល

១- ទ្រង់អនុញ្ញាតឲ្យឧបសម្បទកុលបុត្រក្នុងជនបទជាយដែន (បច្ចន្តជនបទ) ទាំងពួង ដោយមានគណៈភិក្ខុត្រឹម ៥ រូប (ជាប្រក្រតីត្រូវមាន ១០ រូប) ។

២- ទ្រង់កំណត់ជនបទភាគកណ្ដាល (មជ្ឈិមជនបទ) ដូចនេះគឺ

**ទិសខាងកើត** ខាងក្នុងចាប់អំពីមហាសាលនគរចូលមក

**ទិសខាងកើតឆៀងខាងត្បូង** ខាងក្នុងចាប់អំពីស្ទឹងសល្ល-វតីចូលមក ។

**ទិសខាងត្បូង** ខាងក្នុងចាប់អំពីសេតកណ្ណិគមចូលមក

**ទិសខាងលិច** ខាងក្នុងចាប់អំពីស្រុកព្រាហ្មណ៍ឈ្មោះថូនៈចូលមក ។

**ទិសខាងជើង** ខាងក្នុងចាប់អំពីភ្នំឧសីរធជៈចូលមក ។

ទាំងអស់នេះ រួមខាងក្នុងចូលមកជាមជ្ឈិមជនបទ ផុតអំពីខេត្តនោះចេញទៅជាបច្ចន្តជនបទ ទ្រង់អនុញ្ញាតឲ្យភិក្ខុ ៥ រូបបំបួសកុលបុត្របាន ។

៣-ទ្រង់អនុញ្ញាតឲ្យប្រើស្បែកជើងច្រើនជាន់បាន (ពីព្រោះមានផ្ទៃដីក្រហេងក្រហូងបែកក្រហែង ។

៤-ទ្រង់អនុញ្ញាតឲ្យងូតទឹកជាប្រចាំបាន (មើលសិក្ខាបទទី ៧ សុរាបានវគ្គ) ។

៥-ទ្រង់អនុញ្ញាតឲ្យប្រើស្បែកចៀម ស្បែកពពែ ស្បែកម្រឹគជាកម្រាលបាន តាមដែលគេប្រើនៅក្នុងតំបន់នោះ ។

៦-ទ្រង់អនុញ្ញាតឲ្យភិក្ខុនៅក្រៅសីមា ទទួលចីវរដែលទាយកប្រគេនបាន ដោយមិនចាំបាច់រាប់ថ្ងៃ រហូតដល់ពេលដែលសំពត់នៅមិនទាន់ទៅដល់ដៃភិក្ខុ (ពីព្រោះមានការហាមឃាត់មិនឲ្យភិក្ខុទុកចីវរច្រើនជាង ៣ ផ្ទាំង ដែលលើសពីតម្រូវការចាំបាច់ប្រចាំថ្ងៃហួស ១០ ថ្ងៃទៅត្រូវវិកប្ប គឺធ្វើឲ្យមានម្ចាស់ពីរ ទើបទុកបាន និងបើចីវរប្រើជាប្រចាំមិនមាន ក៏ត្រូវអធិដ្ឋានចីវរថ្មីធ្វើជាចីវរប្រចាំបាន) ។

## ២.ភេសជ្ជខន្ធកៈ (វគ្គពោលអំពីថ្នាំ)

ទ្រង់អនុញ្ញាតភេសជ្ជៈ ៥ និងដទៃទៀតៈ

១-ភិក្ខុទាំងឡាយអាពាធ ហុតបបរ ឬឆាន់អាហារក៏ក្អួតចេញមកវិញ (ពីព្រោះអាហារមិនរលាយ) ទើបស្គមស្លេកស្លាំង ។ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតទឹកដោះថ្លា ប្រេង ទឹកឃ្មុំ ទឹកអំពៅ ឲ្យឆាន់បានទាំងក្នុងកាល (មុនថ្ងៃត្រង់) និងក្នុងវិកាល (ចាប់តាំងពីថ្ងៃត្រង់ទៅ) ។

២-ទ្រង់អនុញ្ញាតខ្លាញ់សត្វច្រើនយ៉ាង ឲ្យបរិភោគជាថ្នាំបានចំពោះតែក្នុងកាល ។

៣-ទ្រង់អនុញ្ញាតឲ្យឆាន់មូលភេសជ្ជៈ (ថ្នាំប្រភេទមើម ឬឫសឈើ) ដូចជា រមៀត ខ្ញី ជាដើម បានរហូតមិនមានកំណត់កាល ប៉ុន្តែត្រូវមានហេតុសមគួរ បើមិនមានហេតុសមគួរទេ ត្រូវអាបត្តិទុក្កដ សម្រាប់ភិក្ខុអាពាធ ទ្រង់អនុញ្ញាតឲ្យប្រើថ្នបុក ឬកិនបាន ។

៤-ទ្រង់អនុញ្ញាតឲ្យឆាន់កសាវភេសជ្ជៈ (ថ្នាំប្រភេទទឹកអម្ចត់អំពីដើមឈើ) បានអស់មួយជីវិត កាលបើមានហេតុសមគួរ ។

៥-ទ្រង់អនុញ្ញាតឲ្យឆាន់បណ្ណភេសជ្ជៈ (ប្រភេទស្លឹកឈើជាថ្នាំ) បានអស់មួយជីវិត កាលបើមានហេតុសមគួរ ។

៦-ទ្រង់អនុញ្ញាតឲ្យឆាន់ផលភេសជ្ជៈ (ប្រភេទផ្លែឈើជាថ្នាំ) បាន ដូចជា ដីប្លី សម៉ កន្ទួតព្រៃ បានអស់មួយជីវិត កាលបើមានហេតុសមគួរ ។

៧-ទ្រង់អនុញ្ញាតឲ្យឆាន់ជតុភេសជ្ជៈ (ប្រភេទជ័រឈើជាថ្នាំ) ដូចជា មហាហិង្គុ បានអស់មួយជីវិត កាលបើមានហេតុសមគួរ ។

៨-ទ្រង់អនុញ្ញាតលោណភេសជ្ជៈ (ប្រភេទអំបិលជាថ្នាំ) ដូចជាអំបិលសមុទ្រ អំបិលសិន្ធោរ៍ បានអស់មួយជីវិត កាលបើមានហេតុសមគួរ ។

៩-ទ្រង់អនុញ្ញាតឲ្យប្រើផង់ថ្នាំ កាលបើមានដំបៅឡើងពងបុក្ខិនខ្ទួនអាក្រក់ ដើម្បីមិនឲ្យដំបៅប្រឡាក់ជាប់ចីវរ សម្រាប់ភិក្ខុមិនអាពាធទ្រង់អនុញ្ញាតឲ្យប្រើអាចម៍គោ (ស្ងួត) ដី (ស្ងួត) និងកាកគ្រឿងជ្រលក់ ទ្រង់អនុញ្ញាតត្បាល់ អង្រែ និងក្ងាក់ (សម្រាប់កូរផង់ថ្នាំ) ដើម្បីធ្វើកិច្ចការនេះ ។

១០-ទ្រង់អនុញ្ញាតសាច់សត្វឆៅ ឈាមស្រស់ កាលបើមានអាពាធបណ្តាលមកពីអមនុស្ស ។

១១-ទ្រង់អនុញ្ញាតថ្នាំភ្នែក និងក្លាក់ដាក់ថ្នាំភ្នែក សម្រាប់ភិក្ខុអាពាធរោគភ្នែក ប៉ុន្តែហាមប្រើក្លាក់ដាក់ថ្នាំភ្នែកធ្វើអំពីប្រាក់មាសដូចគ្រហស្ថ ព្រមទាំងទ្រង់អនុអញ្ញាតគម្របក្លាក់ និងឲ្យប្រើអំបោះចងភ្ជាប់នឹងតួក្លាក់ការពារធ្លាក់ ថែមទាំងបានអនុញ្ញាតឲ្យប្រើឈើឆ្កិះថ្នាំភ្នែក និងថង់សម្រាប់ដាក់ឈើឆ្កិះថ្នាំ ព្រមទាំងខ្សែសម្រាប់ពាក់ស្មាស្តាយ ។

១២-ទ្រង់អនុញ្ញាតឲ្យលាបប្រេងក្បាល កាលបើកើតរោគក្តៅក្បាល និងអនុញ្ញាតឲ្យហឺតថ្នាំ និងបំពង់ថ្នាំហឺត តែហាមប្រើបំពង់ដែលធ្វើដោយមាស ឬប្រាក់ ឬវិចិត្រដូចគ្រហស្ថ, ទ្រង់អនុញ្ញាតបំពង់ថ្នាំដែលមានបំពង់ហឺតគូ ។ ទ្រង់អនុញ្ញាតឲ្យហឺតផ្សែង (ថ្នាំ) តាមច្រមុះ, ទ្រង់អនុញ្ញាតបំពង់ថ្នាំជក់ (សម្រាប់ប្រើរក្សារោគ) តែមិនឲ្យប្រើបំពង់ដែលធ្វើដោយមាស ឬប្រាក់ ឬវិចិត្រដូចគ្រហស្ថ, ទ្រង់អនុញ្ញាតឲ្យមានគ្រឿងបិទបំពង់ថ្នាំជក់ (ដើម្បីការពារសត្វចូលទៅខាងក្នុង), ទ្រង់អនុញ្ញាតថង់ដាក់បំពង់ថ្នាំជក់និងថង់គូ ព្រមទាំងខ្សែសម្រាប់ដាក់ពាក់ស្តាយលើស្មា ។

១៣-ទ្រង់អនុញ្ញាតឲ្យបៀមប្រេង (ធ្វើថ្នាំ) និងអនុញ្ញាតឲ្យបន្ថែមស្រាចូលទៅក្នុងប្រេងសម្រាប់ធ្វើថ្នាំបាន ដោយមានលក្ខខណ្ឌថា ស្រាដែលដាក់នោះ មិនត្រូវមានពណ៌ ក្លិន រស ប្រាកដឡើយ ។

ទ្រង់អនុញ្ញាតភាជនៈសម្រាប់ដាក់ប្រេងដែលធ្វើដោយលោហៈ ឬដ្លែឈើ ។ ទ្រង់អនុញ្ញាតការធ្វើឲ្យញើសចេញ ចាប់តាំងអំពីធម្មតារហូតដល់កញ្ចុះ ដោយមានខ្ទះទឹកក្តៅនៅក្នុងនោះ ។

១៤-ទ្រង់អនុញ្ញាតឲ្យនាំឈាមចេញ ដោយប្រើស្នែងក្របីស្រូប (គឺការបឺត សំដៅយកការដោះឈាមចេញបន្តិចរួចសឹមប្រើស្នែងក្របីសង្កត់ចុះទៅឲ្យបឺតឈាមចេញ ក្នុងអដ្ឋកថាមិនបានប្រាប់ថាត្រូវបង្កាត់ភ្លើងដែរ ឬមួយក៏ពុំចាំបាច់ទេ តាមធម្មតាការធ្វើដូចនេះត្រូវមានការបង្កាត់ភ្លើងដោយកម្ទេចក្រដាស់ ឬគ្រឿងបង្កាត់ដទៃទៀតដើម្បីបណ្តេញខ្យល់អាកាស ទើបស្នែងក្របីមានកម្លាំងបឺត) ។

១៥-ទ្រង់អនុញ្ញាតថ្នាំលាបជើង កាលបើជើងបែក និងទ្រង់អនុញ្ញាតឲ្យផ្សំថ្នាំលាបជើងបាន ។

១៦-ទ្រង់អនុញ្ញាតការវះបូស និងអនុញ្ញាតវិធីទាំងពួងដែលទាក់ទងនឹងការវះកាត់នោះ ។

១៧-ទ្រង់អនុញ្ញាតថ្នាំ ៤ ប្រភេទ ខណៈពេលពស់ចឹក គឺ មូត្រ (បស្សាវៈ) គូថ (ឧច្ចារៈ) ផេះ និងដី ក្នុងពេលប្រញាប់ប្រញាល់ដូចនោះ បើគ្មានអ្នកធ្វើឲ្យ កាន់យកខ្លួនឯងហើយឆាន់បាន មិនត្រូវអាបត្តិ (ថ្នាំប្រភេទនេះប្រហែលដើម្បីឲ្យក្អួតចេញ ឬដូចម្តេច មិនបានប្រាប់ទុកទេ) ។

១៨-ទ្រង់អនុញ្ញាតថ្នាំ និងអាហារទន់ខ្លះតាមសមគួរដល់រោគ និងសេចក្តីត្រូវការចាំបាច់ ដូចជា ទឹកក្បុងដែលបានមកពីបាយក្តាំងកែរោគហើមពោះ, សម៉ត្រាំមូត្រ (ទឹកនោម) គោ កែរោគស្លាំងលឿង, ការលាបខ្លួនដោយគ្រឿងក្រអូបកែរោគស្បែក, ទឹកបាយថ្លា, ទឹកសណ្តែកថ្លា, ទឹកសណ្តែកខាប់តិចតួច, ទឹកការបបរ (ជាការអនុគ្រោះដល់អ្នកមានអាពាធ) ។

## ទ្រង់ហាមទុកភេសជ្ជៈ ៥ យ៉ាងលើស ៧ ថ្ងៃ

មនុស្សទាំងឡាយជ្រះថ្លានឹងព្រះបិលិន្ទវច្ឆៈ ក្នុងឋានៈមានអំណាចចិត្តខ្ពស់ ប្រើអំណាចចិត្តបានច្រើនយ៉ាង នាំគ្នាប្រគេនភេសជ្ជៈ ៥ គឺ ទឹកដោះថ្លា, ទឹកដោះខាប់, ប្រេង, ទឹកឃ្មុំ, ទឹកអំពៅ ដ៏ច្រើនសន្ធឹកសន្ធាប់ លោកក៏បែងចែកដល់ភិក្ខុដែលជាបរិស័ទរបស់ខ្លួន ។ ភិក្ខុទាំងនោះ ទុកដាក់របស់ទាំងនេះក្នុងសំពត់តម្រងខ្លះ ថង់ខ្លះ ព្យួរទុកខ្លះ ពាក់ទុកត្រង់មាត់បង្អួចខ្លះ មានកណ្តុរជាច្រើនមករំខាន គួរជាទីតិះដៀលនៃជនទាំងឡាយ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តថា ភិក្ខុទទួលប្រគេនភេសជ្ជៈ ៥ យ៉ាងហើយអាចទុកបរិភោគបានមិនលើស ៧ ថ្ងៃ បើហួសថ្ងៃនោះទៅ ឲ្យពិន័យអាបត្តិតាមសមគួរ (គឺអាបត្តិបាចិត្តិយ ចំណែកឯអាហារហាមទុកយាំងរាត្រីដើម្បីឆាន់ សូម្បីត្រឹមតែមួយយប់ក៏មិនបាន) ។

## ទ្រង់អនុញ្ញាតឱ្យឆាន់របស់ខ្លះៗ

ទ្រង់អនុញ្ញាតឲ្យឆាន់ទឹកអំពៅដែលដាក់ដេះ និងម្សៅចូលបន្តិច (ដើម្បីឲ្យចូលគ្នា) ទ្រង់អនុញ្ញាតឲ្យឆាន់សណ្ដែកខៀវ និងបបរជ្រក់ដាក់អំបិលបាន [៦៧] សម្រាប់ភិក្ខុមិនអាពាធ ឲ្យលាយទឹកឆាន់បាន ។

## ហាមទុកអាហារយាំងរាត្រីក្នុងទីលំនៅជាដើម

ព្រះមានព្រះភាគទ្រង់ អាពាធដោយរោគខ្យល់ក្នុងព្រះឧទរ ។ ព្រះអានន្ទសុំល្ង អង្ករ សណ្ដែកខៀវដោយខ្លួនឯង ទុកយាំងរាត្រីនៅក្នុងទីលំនៅហើយ ចម្អិនដោយខ្លួនឯង រួចរាល់ហើយទើបថ្វាយ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបហាមទុកអាហារយាំងរាត្រីនៅក្នុងទីលំនៅ (អន្តោវុត្ថៈ) ហាមចម្អិនអាហារនៅក្នុងទីលំនៅ (អន្តោបក្កៈ) និងហាមចម្អិនខ្លួនឯង (សាមបក្កៈ) ភិក្ខុអ្នកធ្វើល្មើសត្រូវអាបត្តិទុក្កដ ។ ប៉ុន្តែការកម្ដៅរបស់ដែលឆ្អិនស្រាប់ អនុញ្ញាតឲ្យធ្វើបាន ។ ក្រោយមករកអាហារបានដោយលំបាកនៅក្នុងក្រុងរាជគ្រឹះ ទ្រង់អនុញ្ញាតឲ្យទុកអាហារយាំងរាត្រីនៅក្នុងទីលំនៅ, ឲ្យចម្អិនដោយខ្លួនឯងបាន ។ (ប៉ុន្តែនៅពេលស្រុកទេសត្រឡប់មានសភាពដូចដើមវិញ ទ្រង់ក៏ធ្វើការហាមឃាត់ការទុកដាក់អាហារយាំងរាត្រី នៅក្នុងទីលំនៅជាដើមនោះវិញ ដូចប្រាកដខាងមុខ) ។

ម្យ៉ាងទៀត ទ្រង់អនុញ្ញាតថា (ក្នុងការធ្វើដំណើរផ្លូវឆ្ងាយ) ឃើញផ្លែឈើជ្រុះចោល បើមិនមានកប្បិយការកៈ (អ្នកធ្វើរបស់ដែលគួរ) ក៏អនុញ្ញាតឲ្យរើសទុកនាំទៅដោយខ្លួនឯង រហូតដល់ជួបកប្បិយការកៈទើបឲ្យដាក់ចុះលើដី ឲ្យគេរៀបចំប្រគេនឆាន់បាន ។ ទ្រង់អនុញ្ញាតឲ្យទទួលប្រគេនផ្លែឈើ ដែលរើសមកដោយខ្លួនឯងបាន ។ (បញ្ហានេះក្រោយមកទ្រង់ពិសោធន៍ចោលដូចគ្នានឹងរឿងទុកអាហារនៅក្នុងទីលំនៅដែរ) ។

## ទ្រង់អនុញ្ញាតរឿងការឆាន់ច្រើនយ៉ាង

ទ្រង់អនុញ្ញាតឲ្យភិក្ខុដែលឆាន់រួចហើយ ប្រាប់មិនទទួលអាហារដែលគេថែមឲ្យ ឆាន់អាហារដែលមិនមែនជារបស់ដែល (សល់) ដែលនាំមកអំពីផ្ទះម្ចាស់បុណ្យបាន (ហាមទុកនៅក្នុងសិក្ខាបទទី ៥ ភោជនវគ្គ បាចិត្តិយកណ្ឌ ប៉ុន្តែទ្រង់បញ្ញត្តិបន្ថែមថា បើម្ចាស់បុណ្យ នាំមកប្រគេននៅទីវត្តទៀតឲ្យឆាន់បាន) ។ ម្យ៉ាងទៀត បើគេប្រគេនមុនអាហារ និងបើរបស់នោះ ជារបស់កើតក្នុង

---

[៦៧] បបរជ្រក់ដាក់អំបិល ប្រែចេញពីពាក្យថា **លោណសោចិរកំ**, ក្នុងច្បាប់អឺរ៉ុបជា **លោណសោវីរកៈ**, ក្នុងសំស្ក្រឹតជា **សោវីរកៈ** (sour gruel) ប្រើជាអាហារទន់សម្រាប់អ្នកជម្ងឺ ។

ព្រៃ កើតក្នុងស្រះ ទ្រង់ក៏អនុញ្ញាតឲ្យឆាន់បាន ។ ម្យ៉ាងវិញទៀត ផ្លែឈើដែលមិនមានគ្រាប់ ឬដែលអាចពន្លេចយកគ្រាប់ចេញបាន មិនមានអ្នកធ្វើឲ្យគួរ ទ្រង់ក៏អនុញ្ញាតឲ្យឆាន់បាន ។ (បញ្ញត្តិក្រោយនេះ បំណងមិនឲ្យទម្លាយគ្រាប់ បើឆាន់ដោយមិនទម្លាយគ្រាប់ ក៏បាន) ។

## ទ្រង់ហាមធ្វើការវះកាត់ ឬចងរុំត្រង់ទ្វារធំ

ទ្រង់ហាមវះកាត់ ឬចងរុំដោយស្បែក ឬសំពត់ ក្នុងបរិវេណជុំវិញទ្វារធំ ២ ធ្នាប់ អ្នកបំពានត្រូវអាបត្តិថុល្លច្ច័យ (ទាក់ទងនឹងឫសដូងបាត) ។

## ទ្រង់ហាមឆាន់សាច់មិនគួរ

១ – ទ្រង់ហាមឆាន់សាច់មនុស្ស អ្នកឆាន់ ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុឆាន់សាច់សត្វ ត្រូវពិចារណាជាមុន បើចចេសឆាន់ទាំងមិនពិចារណា ត្រូវអាបត្តិទុក្កដ ។ (សុប្បិយាឧបាសិកាឃើញភិក្ខុចង់ឆាន់សាច់ រកសាច់មិនបាន ទើបពន្លះសាច់ខ្លួនឯងធ្វើអាហារប្រគេន) ។

២ – ទ្រង់ហាមឆាន់សាច់សត្វដែលមិនសមគួរ ៩ ប្រភេទទៀត គឺសាច់ដំរី, សេះ, ឆ្កែស្រុក, ពស់, រាជសីហ៍ (គោ), ខ្លាដំបង, ខ្លារខិន, ខ្លាឃ្មុំ និងឆ្កែព្រៃ ។

## ទ្រង់អនុញ្ញាត និងមិនអនុញ្ញាតរបស់ឆាន់ខ្លះៗ

១ – ទ្រង់អនុញ្ញាតបបរ និងនំលាយទឹកឃ្មុំ, ទ្រង់សរសើរបបរថា មានអានិសង្សច្រើន ។

២ – បើបបររាងខាប់ មានកាកច្រើន ហៅថា ភោជនយាគូដែលអាចឆាន់ឆ្អែត បើទទួលនិមន្តឆាន់ក្នុងទីដទៃ ហាមឆាន់បបររបស់អ្នកដទៃប្រភេទនេះ មុននឹងទៅឆាន់ក្នុងទីនិមន្ត ។

៣ – ទ្រង់សំដែងធម៌ប្រោសវេលដ្ឋៈ កច្ចានៈ អ្នកប្រគេនទឹកអំពៅគាបដល់ភិក្ខុទាំងឡាយឲ្យបានធម្មចក្ខុ (យល់ធម៌) ប្ដេជ្ញាខ្លួនជាឧបាសកដល់ព្រះរតនត្រៃជាសរណៈអស់មួយជីវិត បន្ទាប់មកទ្រង់ប្រារព្ធរឿងទឹកអំពៅគាប ទ្រង់អនុញ្ញាតឲ្យភិក្ខុអាពាធឆាន់បាន ប៉ុន្តែភិក្ខុមិនអាពាធ ឲ្យលាយជាមួយទឹកឆាន់ ។

## ទ្រង់សំដែងធម៌នៅឯបាដលិគ្រាម និងកោដិគ្រាម

ព្រះមានព្រះភាគ ស្ដេចយាងចេញពីក្រុងរាជគ្រឹះទៅកាន់បាដលិគ្រាម ទ្រង់សំដែងធម៌ប្រោសឧបាសកអ្នកស្រុកបាដលិគ្រាមអំពីទោសនៃសីលវិបត្តិ (សេចក្ដីសៅហ្មងនៃសីល) របស់អ្នកទ្រុស្ដសីល និងអានិសង្សនៃសីលសម្បទា (សេចក្ដីផូរផង់នៃសីល) របស់អ្នកមានសីល ។

មហាអាមាត្យនៃដែនមគធៈឈ្មោះសុនីធវស្សការ និមន្តព្រះពុទ្ធជាម្ចាស់ព្រមទាំងភិក្ខុសង្ឃដើម្បីសោយ និងឆាន់ភត្តាហារ រួចហើយព្រះមានព្រះភាគ ស្តេចឆ្លងស្ទឹងគង្គាយាងទៅកាន់កោដិគ្រាម (តាំងនៅក្នុងដែនវជ្ជី) ទ្រង់សំដែងធម៌អំពីអរិយសច្ច ៤ ។

## នាងអម្ពបាលីថ្វាយចម្ការស្វាយ

នាងអម្ពបាលី (ជាស្រីនគរសោភិនី) បានធ្វើដំណើរជាក្បួនយានចេញអំពីក្រុងវេសាលី (រាជធានីនៃដែនវជ្ជី) ទៅគាល់ព្រះមានព្រះភាគដល់កោដិគ្រាម រួចហើយនិមន្តឲ្យសោយចង្ហាន់ក្នុងថ្ងៃស្អែក ។ គណៈក្សត្រិយ៍លិច្ឆវីនៃក្រុងវេសាលីយាងទៅកាន់កោដិ-គ្រាម ដើម្បីគាល់ព្រះមានព្រះភាគ ទូលនិមន្តឲ្យសោយចង្ហាន់ក្នុងថ្ងៃស្អែក ប៉ុន្តែព្រះអង្គបានទទួលនិមន្តនាងអម្ពបាលីជាមុនហើយ គណៈក្សត្រិយ៍លិច្ឆវីសុំអង្វរនាងអម្ពបាលី ដើម្បីឲ្យពួកខ្លួនទទួលនិមន្តមុន តែនាងមិនយល់ព្រម ។ លុះថ្ងៃស្អែកឡើងនៅពេលថ្វាយអាហារដល់ព្រះមានព្រះភាគរួចហើយ ទើបនាងទូលថ្វាយចម្ការស្វាយឲ្យទៅជាសង្ឃារាម ។

## សីហសេនាបតីដូរលទ្ធិសាសនា

សីហសេនាបតីជាសាវ័កនិគ្រន្ថ (សាសនាជេន) បានឮគណៈក្សត្រិយ៍លិច្ឆវីសរសើរគុណព្រះរតនត្រ័យ ក៏មានបំណងចូលទៅគាល់ព្រះមានព្រះភាគ នៅពេលបានប្រឹក្សាជាមួយនឹងអាចារ្យ គឺនិគន្ថ-នាដបុត្ររួចហើយ ក៏មានការហាមប្រាមដល់ទៅ ៣ ដង ទីបំផុតបានសម្រេចចិត្តចូលទៅគាល់ព្រះអង្គ ដោយមិនប្រាប់អាចារ្យ ។ លុះចូលទៅគាល់ហើយ បានក្រាបទូលដល់រឿងរ៉ាវដែលមានមនុស្សពោលតិះដៀល ព្រះអង្គបានពន្យល់ដោយលម្អិត បន្ទាប់មកទ្រង់សំដែងធម៌ប្រោស ។ សីហសេនាបតីបានសម្រេចធម្មចក្ខុ (សោតាបន្នបុគ្គល) និងបាននិមន្តសោយភត្តាហារក្នុងថ្ងៃស្អែក ។ ពួកនិគ្រន្ថដើរនិយាយថា សីហសេនាបតីសម្លាប់សត្វមកធ្វើជាអាហារប្រគេនដល់ភិក្ខុទាំងឡាយ ព្រះសមណគោតមដឹងហើយក៏នៅតែសោយសាច់សត្វនោះ ។ សីហសេនាបតីដឹងហើយក៏បដិសេធថាមិនពិត រួចហើយថ្វាយអាហារដល់ព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃទាំងឡាយជាបន្តរហូតដល់ចប់រួចរាល់ ។

ព្រះមានព្រះភាគទ្រង់ប្រារព្ធហេតុនោះ ទើបបញ្ញត្តព្រះវិន័យហាមឆាន់សាច់សត្វដែលគេសម្លាប់ធ្វើប្រគេនសំដៅចំពោះភិក្ខុ ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុអ្នកឆាន់ រួចទ្រង់អនុញ្ញាតត្រី និងសាច់

ដែលបរិសុទ្ធដោយលក្ខណៈ ៣ ប្រការ គឺមិនបានឃើញ, មិនបានឮ និងមិនរង្កៀសថា (គេសម្លាប់ដើម្បីខ្លួន) ។

## ទ្រង់លើកការអនុញ្ញាតសម័យរកបាយបានដោយលំបាក

ក្រោយមក ក្នុងក្រុងវេសាលីមានភាពសម្បូរសប្បាយឡើងវិញ ទើបព្រះមានព្រះភាគទ្រង់លើកការអនុញ្ញាតក្នុងសម័យរកបាយបានដោយលំបាក មានការផ្លាស់ប្តូរបទហាមឃាត់ដូចតទៅ គឺ

ហាមទុកអាហារយាំងរាត្រីនៅក្នុងទីលំនៅ, ហាមចម្អិនបបរនៅក្នុងទីលំនៅ, ហាមចម្អិនបបរខ្លួនឯង, ហាមឆាន់ផ្លែឈើដែលរើសខ្លួនឯង ដោយរកមនុស្សប្រគេនជាខាងក្រោយ ទាំង ៤ ខនេះ ពិន័យអាបត្តិទុក្កដដល់ភិក្ខុអ្នកប្រព្រឹត្តល្មើស ។ ហាមឆាន់អាហាររហូតដល់មិនទទួលវត្ថុដែលគេប្រគេនបន្ថែម ត្រឡប់ឆាន់អាហារដែលគេនាំមកប្រគេនអំពីផ្ទះម្ចាស់បុណ្យទៀត, ឬឆាន់អាហារដែលទទួលប្រគេនទុកមុន ឬឆាន់អាហារដែលកើតក្នុងព្រៃ ក្នុងស្រះដូចជា ផ្លែឈើ មើមឈូក ឲ្យពិន័យអាបត្តិដល់អ្នកបរិភោគ តាមសមគួរដល់ករណី (អាបត្តិបាចិត្តិយ) ។

## ទ្រង់អនុញ្ញាតកន្លែងទុកអាហារ

មានអ្នកនាំយកវត្ថុជាអាហារ ដូចជា អំបិល, ប្រេង, អង្ករ, របស់ទំពា (ផ្លែឈើ) មកប្រគេន ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតកប្បិយភូមិ គឺកន្លែងទុកវត្ថុដែលសមគួរ ដោយការសូត្រប្រកាសជាកិច្ចការរបស់សង្ឃ ដោយទ្រង់បញ្ញាក់កប្បិយភូមិ ៤ ប្រភេទ គឺ

១.ឧស្សាវនន្តិកា កប្បិយភូមិដែលប្រកាសឲ្យដឹងទាំងអស់គ្នា

២.គោនិសាទិកា កប្បិយភូមិដែលគ្មានអ្វីបិទបាំង

៣.គហបតិកា កប្បិយភូមិដែលគហបតីប្រគេន

៤-សម្មតិកា កប្បិយភូមិ ដែលសង្ឃសន្មត គឺសូត្រប្រកាសជាកិច្ចការរបស់សង្ឃ ។

## ទ្រង់សំដែងធម៌ប្រោសមេណ្ឌកគហបតី

ព្រះមានព្រះភាគ ស្តេចយាងចេញពីក្រុងវេសាលីទៅកាន់ភទ្ទិយនគរ ទ្រង់គង់ប្រថាប់នៅក្នុងជាតិយាវ័ន។ ក្នុងទីនោះ មេណ្ឌកគហបតី (សេដ្ឋី) បានចូលទៅគាល់ បានស្តាប់ព្រះធម៌ទេសនាសម្រេចនូវធម្មចក្ខុ រួចក៏និមន្តឲ្យសោយចង្ហាន់ក្នុងថ្ងៃស្អែក។ លុះសោយចង្ហាន់រួចហើយ ព្រះអង្គសំដែងធម៌ប្រោសគ្រួសារព្រមទាំងទាសាទាសីរបស់មេណ្ឌកគហបតីឲ្យបានសម្រេចធម៌ គ្រប់គ្នាប្តេជ្ញា

ខ្លួនជាឧបាសក ឬឧបាសិកា ដល់នូវព្រះរតនត្រ័យជាទីពឹងអស់មួយជីវិត ។

## ទ្រង់អនុញ្ញាតតាមដែលមេណ្ឌកគហបតីទូលស្នើ

មេណ្ឌកគហបតីដឹងថា ព្រះមានព្រះភាគទ្រង់យាងទៅកាន់អង្គុត្តរាបៈមានរយៈផ្លូវឆ្ងាយ ទើបក្រាបទូលសុំឲ្យទ្រង់អនុញ្ញាតស្បៀង ទ្រង់ក៏អនុញ្ញាតដូចតទៅនេះ ៖

១–ទ្រង់អនុញ្ញាតវត្ថុ ៥ យ៉ាងដែលកើតអំពីគោ (បញ្ចគោរស) គឺ ទឹកដោះស្រស់, ទឹកដោះជូរ, ខ្លាញ់គោ, ទឹកដោះខាប់, ទឹកដោះថ្លា ។

២–ទ្រង់អនុញ្ញាតឲ្យស្វែងរកស្បៀងដើរផ្លូវបាន គឺ អង្ករ, សណ្ដែកខៀវ (សណ្ដែកបាយ), សណ្ដែករាជមាស (សណ្ដែកសៀង), អំបិល, ទឹកអំពៅគាប, ប្រេង, ទឹកដោះថ្លា តាមសេចក្ដីត្រូវការ ។

៣–កាលបើមានទាយកប្រគេនមាសប្រាក់ ដល់កប្បិយការកៈ ទ្រង់អនុញ្ញាតឲ្យត្រេកអរវត្ថុគួរ ដែលបានមកអំពីមាសប្រាក់នោះ តែទ្រង់មិនអនុញ្ញាតឲ្យត្រេកអរមាសប្រាក់ ឬឲ្យស្វែងរកមាសប្រាក់ឡើយ ។

## ទ្រង់អនុញ្ញាតទឹកអដ្ឋបាន (ទឹកឆាន់ ៨ យ៉ាង)

នៅក្នុងដែនអាបណៈ ទ្រង់អនុញ្ញាតតាមពាក្យទូលស្នើសុំរបស់កេណិយៈជាជដិលដែលបានធ្វើទឹកបាន (ទឹកផ្លែឈើ) មកថ្វាយ ទើបទ្រង់អនុញ្ញាតទឹកបាន ៨ យ៉ាង[៦៨] គឺ ១.ទឹកផ្លែស្វាយ ២.ទឹកផ្លែជម្ពូ ឬផ្លែព្រីង ៣.ទឹកផ្លែចេកមានគ្រាប់ ៤.ទឹកផ្លែចេកឥតគ្រាប់ ៥.ទឹកផ្លែស្រគំ ៦.ទឹកផ្លែចាន់ ឬផ្លែទំពាំងបាយជូរ ៧.ទឹកក្រអៅឈូក ៨.ទឹកផ្លែមាក់ប្រាង ឬផ្លែគូលែន ។

ទ្រង់អនុញ្ញាតទឹកចម្រាញ់អំពីផ្លែឈើគ្រប់ប្រភេទ វៀរលែងតែប្រភេទបាយ (ឆាន់ចូលទៅឆ្អែតមានកម្លាំងដូចបាយ) ។ ទ្រង់អនុញ្ញាតទឹកចម្រាញ់អំពីស្លឹកឈើគ្រប់ប្រភេទ លើកលែងតែរសជាតិទឹកបន្លែដែលគេចម្អិនរួចហើយ ។ ទ្រង់អនុញ្ញាតទឹកចម្រាញ់អំពីផ្កាឈើគ្រប់ប្រភេទ វៀរលែងតែផ្កាមាក់សាង (មធុកបុប្ផរស) និងទ្រង់អនុញ្ញាតទឹកចម្រាញ់អំពីដើមអំពៅ (ឲ្យឆាន់បន្ទាប់ពីថ្ងៃត្រង់ទៅបាន) ។

## ទ្រង់អនុញ្ញាតបន្លែ និងរបស់ទំពាធ្វើអំពីម្សៅ

នៅក្នុងក្រុងកុសិនារា ទ្រង់ប្រារព្ធពាក្យមល្លក្សត្រឈ្មោះរោជៈដែលធ្លាប់ជាសម្លាញ់របស់ព្រះអានន្ទ ទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់

---

[៦៨] ទឹកឆាន់ធ្វើអំពីផ្លែឈើ ៨ យ៉ាងនេះ អដ្ឋកថាពន្យល់ថា ជារបស់ត្រជាក់ ឬហាលថ្ងៃ ប្រើបានដូចគ្នា តែចម្អិនដោយភ្លើង ឆាន់ក្នុងវេលាវិកាលមិនបាន ពីព្រោះអាចក្លាយជាម្សៅខាប់ធ្វើឲ្យឆ្អែតដូចអាហារបាន ។

បន្លែ និងរបស់ទំពាធ្វើដោយម្សៅគ្រប់ប្រភេទ (មុនថ្ងៃត្រង់) ។

## ទ្រង់ហាម និងអនុញ្ញាតយ៉ាងដទៃ

នៅក្នុងតំបន់អាតុមា ទ្រង់ប្រារព្ធការប្រព្រឹត្តរបស់ភិក្ខុបួសនៅពេលចាស់ដែលធ្លាប់ធ្វើជាជាងកាត់សក់ ទើបទ្រង់ហាមមិនឲ្យដឹកនាំបុគ្គលទៅក្នុងផ្លូវមិនសមគួរ ព្រមទាំងហាមភិក្ខុដែលធ្លាប់ធ្វើជាជាងកាត់សក់មិនឲ្យប្រើគ្រឿងកោរ ។ ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុប្រព្រឹត្តល្មើស ។

នៅក្នុងក្រុងសាវត្ថី ទ្រង់អនុញ្ញាតរបស់ទំពាដែលជាផ្លែឈើគ្រប់ប្រភេទឲ្យឆាន់បាន ។

ពូជរបស់សង្ឃ ដាំនៅក្នុងដីបុគ្គល ឲ្យបែងចែកហើយបរិភោគបាន (អដ្ឋកថាពន្យល់ថា ឲ្យបែងជា ១ ភាគ ១០ គឺម្ចាស់ដីបាន ១ ភាគ ឯម្ចាស់ពូជបាន ៩ ភាគ) ។

## ទ្រង់បង្ហាញខសម្រេច

ទ្រង់បង្ហាញថា វត្ថុដែលទ្រង់មិនបានហាម កាលបើចូលជាមួយវត្ថុមិនគួរ ជំទាស់ជាមួយវត្ថុគួរ រាប់ថាមិនគួរ, ចូលជាមួយវត្ថុគួរ ជំទាស់ជាមួយវត្ថុមិនគួរ រាប់ថាគួរ ។ វត្ថុដែលទ្រង់មិនបានអនុញ្ញាត កាលបើចូលជាមួយវត្ថុមិនគួរ ជំទាស់ជាមួយវត្ថុគួរ រាប់ថាមិនគួរ, ចូលជាមួយវត្ថុគួរ ជំទាស់ជាមួយវត្ថុមិនគួរ រាប់ថាគួរ ។

ម្យ៉ាងទៀត ទ្រង់បង្ហាញច្បាស់អំពីរឿងកាលិក (គឺរបស់ឆាន់ដែលទ្រង់អនុញ្ញាតតាមកាលកំណត់) សរុបមាន ៤ យ៉ាង គឺ

**១.យាវកាលិក** របស់ឆាន់បានចាប់ពីព្រឹករហូតដល់ថ្ងៃត្រង់

**២.យាមកាលិក** របស់ឆាន់បាន មិនកន្លងរាត្រី

**៣.សត្តាហកាលិក** របស់ឆាន់បាន មិនលើស ៧ ថ្ងៃ

**៤.យាវជីវិក** របស់ឆាន់បានរហូតដល់អស់អាយុ ។

វត្ថុទាំងអស់នេះ នៅពេលណាលាយគ្នា ឲ្យគិតតាមអាយុវត្ថុដែលមានពេលតិច ។ (ដូចជាយកទឹកត្នោត ដែលអាចឆាន់បាន ៧ ថ្ងៃ លាយជាមួយបាយ អាចឆាន់បានត្រឹមពេលព្រឹក ដល់ថ្ងៃត្រង់ប៉ុណ្ណោះ) ។

## ៣.កឋិនខន្ធកៈ (ពោលអំពីកឋិន)

ភិក្ខុក្រុងបាឋា (ឬបាវា) ៣០ រូបដែលជាអ្នកកាន់វត្តនៅព្រៃ, ដើរបិណ្ឌបាត, ស្លៀកសំពត់បង្សុកូល (សំពត់ដែលរើសយកមកដេរប៉ះតគ្នាធ្វើជាចីវរ) និងប្រើចីវរ ៣ ផ្ទាំង (មិនច្រើនជាងនោះ) ធ្វើដំណើរទៅគាល់ព្រះមានព្រះភាគនៅឯក្រុងសាកេត ដល់

ថ្ងៃចូលវស្សាត្រូវដាក់ចិត្តចាំវស្សានៅក្នុងក្រុងសាកេត មានការរពុកនឹកដល់ព្រះសាស្ដា ចេញវស្សារួចហើយ ទើបមកគាល់ព្រះអង្គទាំងដែលចីវរទទឹកទឹកភ្លៀង និងត្រូវដើរលុយទឹកលុយភក់ ទ្រង់ប្រារព្ធហេតុនោះ ទើបអនុញ្ញាតឲ្យភិក្ខុដែលចាំវស្សារួចហើយក្រាលកឋិនបាន ។

## អានិសង្ស ៥ នៃភិក្ខុដែលបានក្រាលកឋិន

ទ្រង់សំដែងអានិសង្ស ៥ សម្រាប់ភិក្ខុដែលបានក្រាលកឋិន គឺ

១.ទៅណាមិនចាំបាច់ប្រាប់លាភិក្ខុដទៃ តាមន័យនៅក្នុងសិក្ខាបទទី ៦ នៃអចេលកវគ្គ បាចិត្តិយកណ្ឌ ។

២.ទៅណាមិនចាំបាច់ នាំយកត្រៃចីវរទៅគ្រប់សម្រាប់ តាមន័យនៅក្នុងសិក្ខាបទទី ២ នៃចីវរវគ្គ និស្សគ្គិយកណ្ឌ ។

៣.ឆាន់អាហាររួមក្រុមគ្នាបាន តាមន័យនៅក្នុងសិក្ខាបទទី ២ នៃភោជនវគ្គ បាចិត្តិយកណ្ឌ ។

៤.ទុកចីវរបានច្រើនផ្ទាំងតាមសេចក្ដីត្រូវការ ដោយមិនចាំបាច់វិកប្ប (គឺធ្វើឲ្យមានម្ចាស់ពីរ) តាមន័យនៅក្នុងសិក្ខាបទទី ១ នៃចីវរវគ្គ និស្សគ្គិយកណ្ឌ ។

៥.សំពត់ដែលកើតឡើងក្នុងវត្តនោះ ជារបស់លោក (គឺលោកមានសិទ្ធិទទួលបានចំណែកដែលត្រូវបែងចែក, ភិក្ខុនៅក្នុងខេត្តដទៃមក មិនមានសិទ្ធិឡើយ) ។

## ទ្រង់អនុញ្ញាតឱ្យសូត្រប្រកាសកឋិន

ទ្រង់អនុញ្ញាតឲ្យសូត្រប្រកាសប្រគល់សំពត់កឋិន ដល់ភិក្ខុរូបណាទីមួយ ជាការផងសង្ឃដោយតាំងញត្តិម្ដង សូត្រប្រកាសសុំការយល់ឃើញត្រូវម្ដង (សរុបហៅថា ញត្តិទុតិយកម្ម) ។

## ទ្រង់សំដែងរឿងកឋិនបានក្រាល និងមិនបានក្រាល

ទ្រង់សំដែងថា កឋិនឈ្មោះថាមិនបានក្រាលដោយហេតុត្រឹមតែគូស, គណនា, គក់, ដាន, កាត់, ដេរជាដើម ព្រមទាំងឈ្មោះថាមិនបានក្រាលដោយសំពត់ដែលធ្វើនិមិត្ត (និយាយឲ្យគេប្រើសំពត់នោះៗ ធ្វើជាសំពត់កឋិន) និងដោយសំពត់ដែលបញ្ចុះបញ្ចូលគេឲ្យថ្វាយជាសំពត់កឋិន[៦៩] ។

---

[៦៩] មានហេតុកើតឡើងជាញឹកញាប់ ភិក្ខុដែលមិនដឹងវិន័យត្រង់នេះ ដឹកនាំអ្នកស្រុក ឬនិយាយបញ្ចុះបញ្ចូលគេឲ្យធ្វើកឋិនដាក់វត្តរបស់ខ្លួន កឋិននោះមិនឈ្មោះថា ជាកឋិន គឺជាមោឃៈ មិនបានទទួលប្រយោជន៍ទាំងអ្នកប្រគេន និងអ្នកទទួល រឿងនេះ គួរនាំគ្នាសិក្សាឲ្យបានចេះដឹងទាំងអស់គ្នា ។

បន្ទាប់មកទ្រង់សំដែងថា កឋិនឈ្មោះថាបានក្រាលដោយសំពត់ថ្មី, សំពត់និម្មិតថ្មី, សំពត់ចាស់ជាដើម ព្រមទាំងការបដិបត្តិឲ្យបានត្រឹមត្រូវតាមព្រះវិន័យច្រើនប្រការទៀត ។

## បទកំណត់ក្នុងការដោះកឋិន

ទ្រង់សំដែងមាតិកា គឺមេបទ ឬខកំណត់ក្នុងការដោះកឋិន (គឺរើ ឬដោះឈើស្នឹងចេញបាន) សរុបមាន ៨ ប្រការ គឺ

១.ធ្វើដំណើរទៅកាន់ទីដទៃដោយមិនគិតត្រឡប់មកវិញ

២.ធ្វើចីវររួចរាល់ហើយ

៣.តាំងចិត្តឈប់ធ្វើចីវរ

៤.ចីវរដែលកំពុងធ្វើ ត្រូវខូច ឬបាត់

៥.ដោយបានឮដំណឹង គឺលោកមុនចេញទៅគិតថានឹងត្រឡប់មកវិញ តែបានឮដំណឹងថា ក្នុងវត្តដែលលោកនៅនោះ គេឈប់ធ្វើចីវរហើយ ។

៦.ដោយការអស់សង្ឃឹម គឺបំណងថានឹងបានចីវរ តែត្រឡប់ជាមិនបានវិញ ។

៧.នៅក្រៅសីមា គឺគិតថានឹងត្រឡប់មកកាន់វត្តនោះវិញ រហូតដល់ផុតសម័យកឋិន ។

៨.លើកកឋិន ព្រមជាមួយនឹងភិក្ខុទាំងឡាយ គឺនៅពេលផុតកំណត់ ឈ្មោះថាលើកកឋិនព្រមគ្នា ។

(បន្ទាប់ពីនោះទៅ ជាពាក្យអធិប្បាយមាតិកាទាំង ៨ ដោយពិស្តារ) ។ នៅចុងបញ្ចប់មានសរុបបលិពោធ (សេចក្តីកង្វល់ ឬការ គិតគូរ) ២ ប្រការ គឺអាវាសបលិពោធ កង្វល់រឿងវត្ត (គឺតាំង ចិត្តនឹងត្រឡប់មកកាន់វត្ត) និងចីវរបលិពោធ កង្វល់រឿងចីវរ (គឺ គិតគូរធ្វើចីវរនៅក្នុងកាលកំណត់) កាលបើអស់បលិពោធ ឈ្មោះ ថាជាការលើកកឋិន ។

## ៤.ចីវរក្ខន្ធកៈ (ពោលអំពីចីវរ)

គណៈអ្នកមានស្តុកស្តម្ភនៅក្នុងក្រុងរាជគ្រឹះ ទៅលេងកំសាន្តនៅក្នុងក្រុងវេសាលី ឃើញស្រុកទេសគេរីកចម្រើន និងមានស្រីនគរសោភិនីឈ្មោះថា អម្ពបាលី ។ នៅពេលត្រឡប់ទៅកាន់ក្រុងរាជគ្រឹះវិញ ទើបនាំដំណឹងទៅទូលគាល់ព្រះបាទពិម្ពិសារ សុំព្រះរាជានុញ្ញាតឲ្យមានស្រីនគរសោភិនីដូចនគរគេដែរ កាលបើទ្រង់អនុញ្ញាត ក៏នាំគ្នាទៅរកស្រីក្រមុំរូបស្អាតឈ្មោះសាលវតី មកធ្វើជាស្រីនគរសោភិនីប្រចាំក្រុងរាជគ្រឹះ ។ នាងក៏មានគភ៌ បង្កើតបានកូនប្រុស ទើបឲ្យនាំយកទៅចោលក្នុងគំនរសម្រាម អភ័យរាជកុមារយាងទៅឃើញ ក៏បញ្ជាឲ្យយកទៅចិញ្ចឹមនៅក្នុងវាំង ។ ទើបក្មេង

នោះ មានឈ្មោះថា ជីវក (រួចពីស្លាប់) កោមារភច្ច (ព្រះរាជាកុមារជាអ្នកចិញ្ចឹម) ។ កាលបើជីវកកោមារភច្ចចម្រើនវ័យធំឡើង ក៏បានទៅសិក្សាវិជ្ជាពេទ្យនៅក្នុងក្រុងតក្កសិលាអស់រយៈពេល ៧ ឆ្នាំ លុះរៀនចប់ហើយនៅពេលធ្វើដំណើរត្រឡប់មកវិញ នៅតាមផ្លូវបានព្យាបាលជម្ងឺភរិយាសេដ្ឋីម្នាក់ ដែលចេះតែឈឺក្បាលអស់រយៈពេល ៧ ឆ្នាំមកហើយ ដោយប្រើថ្នាំប្រេងបញ្ចូលតាមច្រមុះ បានទទួលលាភសក្ការៈជាច្រើន ក៏មកសាងសង់លំនៅឋានក្បែរវាំងដែលអភ័យរាជកុមារទ្រង់គង់នៅ ។

បន្ទាប់មក បានព្យាបាលជម្ងឺឫសដូងបាតរបស់ព្រះបាទពិម្ពិសារ ឲ្យបាត់ដោយលាបថ្នាំតែម្តងគត់ ទើបតែងតាំងឲ្យធ្វើជាពេទ្យប្រចាំព្រះរាជដំណាក់ និងប្រចាំព្រះពុទ្ធជាម្ចាស់ ព្រមទាំងភិក្ខុសង្ឃ ។

ក្រោយមកបានព្យាបាលរោគឈឺក្បាលរបស់សេដ្ឋីម្នាក់ នៅក្នុងក្រុងរាជគ្រឹះដោយការវះកាត់, ព្យាបាលរោគពោះវៀនធំ នៃបុត្រសេដ្ឋីម្នាក់នៅក្នុងក្រុងពារាណសីដោយការវះកាត់, ព្យាបាលរោគលឿងស្លេកស្លាំង នៃព្រះបាទចណ្ឌបជ្ជោត នៅក្នុងក្រុងឧជ្ជេនី ដោយការថ្វាយថ្នាំឲ្យទ្រង់សោយ ទទួលបានផលល្អគ្រប់អន្លើ ។ ចុងក្រោយបានថ្វាយថ្នាំបញ្ចុះដល់ព្រះមានព្រះភាគ ដោយមិនចាំបាច់ឲ្យទ្រង់សោយឡើយ គ្រាន់តែអប់ថ្នាំដាក់ផ្កាឧប្បល ៣ ក្តាប់ រួចហើយឲ្យប្រើព្រះហស្តញីម្តងមួយក្តាប់ ក៏ទទួលបានផលល្អ ។ ទីបំផុតបានក្រាបទូលព្រះមានព្រះភាគ ដើម្បីឲ្យភិក្ខុទាំងឡាយទទួលគហបតីចីវរ (គឺចីវរដែលអ្នកមានសទ្ធាប្រគេន សម័យមុនអនុញ្ញាត តែចីវរដែលរើសកម្ទេចសំពត់មកដេរប៉ះតគ្នាប្រើ) ។ ទ្រង់ប្រារព្ធពាក្យរបស់ហ្មជីវក ទើបអនុញ្ញាតឲ្យទទួលគហបតីចីវរបាន តែបើភិក្ខុរូបណានៅប្រើចីវរ ដែលរើសកម្ទេចសំពត់មកដេរប៉ះតគ្នា គឺបង្សុកូលចីវរ ក៏ឲ្យប្រើទៅតាមអធ្យាស្រ័យចុះ ។

## ទ្រង់អនុញ្ញាតអ្នកទុកដាក់ចីវរ

កាលបើមនុស្សទាំងឡាយដឹងថា ទ្រង់អនុញ្ញាតឲ្យប្រគេនចីវរបាន ក៏នាំគ្នាប្រគេនចីវរច្រើនសន្ធឹកសន្ធាប់ ។ ពេលដែលចីវរមានច្រើន ទ្រង់ក៏អនុញ្ញាតឲ្យសូត្រប្រកាសតែងតាំងភិក្ខុអ្នកទទួលចីវរ (ក្នុងនាមជារបស់សង្ឃ) , ភិក្ខុទុកចីវរ, ភិក្ខុរក្សាឃ្លាំងដាក់ចីវរ, ភិក្ខុចែកចីវរ ព្រមទាំងកំណត់គុណសម្បត្តិនៃភិក្ខុទាំងនោះទៀត ។

## ទ្រង់អនុញ្ញាតពណ៌ និងវិធីជ្រលក់ចីវរ

ទ្រង់អនុញ្ញាតពណ៌ជ្រលក់ចីវរ ៦ ប្រភេទ គឺធ្វើអំពីឫសឈើ, ដើម, សម្បក, ស្លឹក, ផ្កា និងផ្លែ ព្រមទាំងអនុញ្ញាតវិធីការផ្សេងៗ ក្នុងការជ្រលក់ចីវរ ។

## ទ្រង់អនុញ្ញាតវិធីកាត់ចីវរ

កាលបើស្តេចយាងទៅកាន់ទក្ខិណាគិរី (តំបន់ភ្នំភាគខាងត្បូង) ទ្រង់ទតព្រះនេត្រឃើញស្រែអ្នកដែនមគធៈមានភ្លឺនិងខ្វង់ ទើបត្រាស់ឲ្យព្រះអានន្ទល្បងកាត់ចីវរតាមរូបនោះលមើល ។ ពេលព្រះអានន្ទធ្វើសម្រេចហើយ ទ្រង់សរសើរថាឆ្លាតមែន។ ក្រោយមកទ្រង់អនុញ្ញាតចីវរ ៣ ផ្ទាំង (ត្រៃចីវរ) គឺ សង្ឃាដី (សំពត់គ្រួតពីក្រៅ) ២ ជាន់ ចីពរ ១ ជាន់ ស្បង់ ១ ជាន់។ បន្ទាប់មកទ្រង់អនុញ្ញាតឲ្យទុកចីវរដែលលើសចំនួន ៣ ផ្ទាំងបានមិនហួសពី ១០ ថ្ងៃ បើទុកហួសកំណត់នោះឲ្យវិកប្ប (គឺធ្វើឲ្យមានម្ចាស់ពីរ) បន្ទាប់មកទៀតទ្រង់អនុញ្ញាតថា បើសំពត់ចាស់ឲ្យប្រើសង្ឃាដី ៤ ជាន់ ចីពរ ២ ជាន់ ស្បង់ ២ ជាន់ (ដើម្បីមិនឲ្យមើលឃើញធ្លុះទៅខាងក្នុង) ។

## ទ្រង់អនុញ្ញាតពរ (ពាក្យទូលសុំ) ៨ ប្រការរបស់នាងវិសាខា

នាងវិសាខាប្រាថ្នាឲ្យភិក្ខុសង្ឃមានភាពងាយស្រួល ទើបក្រាបទូលសុំពរ ៨ ប្រការដើម្បីប្រគេនវត្ថុផ្សេងៗ ដល់ភិក្ខុសង្ឃសំអាងលើហេតុផលដែលធ្លាប់មានកន្លងមក ឃើញថាសមគួរនឹងអនុញ្ញាត ទើបទ្រង់អនុញ្ញាតតាមការទូលសុំ គឺ

១.សំពត់ងូតទឹកភ្លៀង

២.អាគន្តុកភត្ត (អាហារសម្រាប់ភិក្ខុមកថ្មី)

៣.គមិកភត្ត (អាហារសម្រាប់ភិក្ខុចាកចេញទៅ)

៤.គិលានភត្ត (អាហារសម្រាប់ភិក្ខុអាពាធ)

៥.គិលានុបដ្ឋាកភត្ត (អាហារសម្រាប់ភិក្ខុមើលថែទាំភិក្ខុអាពាធ) ។

៦.ថ្នាំសម្រាប់ភិក្ខុអាពាធ

៧.បាយយាគូប្រគេនជាប្រចាំ

៨.សំពត់ងូតទឹកសម្រាប់ភិក្ខុនី ។

## ទ្រង់អនុញ្ញាតសំពត់ដទៃទៀត

ក្រោយមកទ្រង់អនុញ្ញាតកម្រាលសឹង (សំពត់ក្រាលដេក) (ដើម្បីការពារសេនាសនៈកុំឲ្យប្រឡាក់), ទ្រង់អនុញ្ញាតសំពត់រុំបូស, ទ្រង់អនុញ្ញាតសំពត់ជូតមុខ និងសំពត់ដទៃទៀតសម្រាប់ប្រើជាបរិក្ខារ ដូចជា សំពត់តម្រង, ថង់ (យាម) ដាក់របស់របរ និងត្រាស់

សរុបថា ត្រៃចីវរ ឲ្យអធិដ្ឋាន មិនឲ្យវិកប្ប[៧០], សំពត់ងូតទឹកភ្លៀង ឲ្យអធិដ្ឋានប្រើរហូត ៤ ខែនៃរដូវភ្លៀង បន្ទាប់ពីនោះ ឲ្យវិកប្ប, សំពត់ក្រាលអង្គុយ, សំពត់ក្រាលដេក ឲ្យអធិដ្ឋាន មិនឲ្យវិកប្ប, សំពត់រុំបូស ឲ្យអធិដ្ឋានទុកប្រើរហូតដល់ជាអាពាធ ពេលអាពាធជាសះស្បើយហើយ ឲ្យវិកប្ប, សំពត់ជូតមុខ និងសំពត់ដែលប្រើជាបរិក្ខារដទៃទៀត ឲ្យអធិដ្ឋាន មិនឲ្យវិកប្បទេ ។

## ទ្រង់អនុញ្ញាត និងហាមឃាត់ទាក់ទងនឹងចីវរផ្សេងៗ

បន្តបន្ទាប់មកទ្រង់អនុញ្ញាតថា (ក្នុងត្រៃចីវរនោះ) ឲ្យប្រើសំពត់ដែលពុំចាំបាច់កាត់ (ដេរធ្វើជាខ្នង់) បានត្រឹម ២ ផ្ទាំង (តែ) ត្រូវកាត់ ១ ផ្ទាំង បើកាត់សំពត់មិនល្មមឲ្យប្រើសំពត់ភ្ជោះ (នាំកំណាត់សំពត់ដទៃមកផ្សំ) ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុស្លៀកដណ្ដប់សំពត់ដែលមិនបានកាត់ (ដេរធ្វើជាខ្នង់) សោះ ។ ម្យ៉ាងទៀតទ្រង់អនុញ្ញាតភិក្ខុឲ្យសំពត់ដល់មាតាបិតាបាន តែមិនឲ្យនាំរបស់ដែលគេឲ្យដោយសទ្ធាឲ្យធ្លាក់ទេ (ពាក្យថា ធ្វើសទ្ធាទាយកឲ្យធ្លាក់ គឺយករបស់ដែលគេប្រគេន ឲ្យដល់ជនគ្រហស្ថដទៃ ដែលមិនមែនជាមាតាបិតា) ។

មានរឿងនាំចីវរទៅមិនគ្រប់សម្រាប់ ចីវរដែលទុកនោះត្រូវចោរលួចយកទៅ ទើបទ្រង់កំណត់លក្ខណៈថា ទុកដាក់ចីវរហើយចូលទៅក្នុងស្រុកបាន ដោយមិនចាំបាច់នាំទៅគ្រប់សម្រាប់បាន ដូចជាវិហារមានរនុកការពារបានល្អជាដើម និងមានរឿងទាយកប្រគេនចីវរដល់សង្ឃត្រូវមានការបែងចែកយ៉ាងណា រួមទាំងរឿងភិក្ខុចាំវស្សាក្នុងវត្តមួយ តែល្មោភទៅទទួលចីវរក្នុងវត្តដទៃ ដែលជាចំណែកបែងចែក ឬសំដែងធ្វើជានៅកន្លែងពីរ នឹងត្រូវដោះស្រាយយ៉ាងណា ។

## ព្រះពុទ្ធទ្រង់ព្យាបាលភិក្ខុអាពាធ

រឿងនេះបានរៀបរាប់ដោយពិស្ដាររួចហើយ ដែលនិយាយអំពីអ្នកជម្ងឺជាបុគ្គលល្អ និងមិនល្អ អ្នកព្យាបាលអ្នកជម្ងឺជាបុគ្គលល្អ និងមិនល្អ ។ ក្រៅពីនេះ ទ្រង់បានសំដែងអំពីវិធីសូត្រប្រកាសសង្ឃ ដើម្បីប្រគល់បរិក្ខារ (គ្រឿងប្រើប្រាស់) របស់អ្នកជម្ងឺដែលអស់ជីវិតដល់ភិក្ខុអ្នកព្យាបាលជម្ងឺ ប៉ុន្តែបើជាគរុភណ្ឌ គរុបរិក្ខារ (គឺរបស់ប្រើប្រាស់ដែលមានទំហំធំ ហាមធ្វើការបែងចែក ឲ្យទុកនៅជារបស់សង្ឃ ។

[៧០] **អធិដ្ឋាន** គឺតាំងចិត្តយកប្រើ, ចំណែកឯ **វិកប្ប** គឺធ្វើឲ្យមានម្ចាស់ពីរ នៅពេលយកប្រើត្រូវសុំអនុញ្ញាតជាមុន ។

## ការអាក្រាតកាយ និងការប្រើសំពត់

ទ្រង់ហាមការអាក្រាតកាយដូចពួកអន្យតិរ្ថិយ៍ និងពិន័យអាបត្តិថុល្លច្ច័យដល់អ្នកប្រព្រឹត្តល្មើស ។ ម្យ៉ាងទៀត ទ្រង់ហាមប្រើសំពត់បិទបាំងកាយ (ធ្វើអំពីស្មៅ) ដូចឥសី, សម្បកឈើក្រង់, ផ្លែឈើក្រង់, សំពត់កម្ពល់ធ្វើអំពីសក់មនុស្ស, សំពត់កម្ពលធ្វើអំពីរោមកន្ទុយសត្វស្លាបទីទុយ (ឬមៀម) ឬស្បែកខ្លា ដែលជារបស់ពួកអន្យតិរ្ថិយ៍ ភិក្ខុរូបណាប្រើប្រាស់ ត្រូវអាបត្តិថុល្លច្ច័យ សំពត់ធ្វើដោយផ្លែ (ឬក្រចៅ) ត្រូវអាបត្តិទុក្កដ (ន័យនៅក្នុងទីនេះ គឺមិនឲ្យស្លៀកដណ្តប់តាមបែបតិរ្ថិយ៍) ។

## ទ្រង់ហាមប្រើចីវរមានពណ៌មិនគួរ និងហាមប្រើអាវ មួក សំពត់រុំ

ទ្រង់ហាមប្រើចីវរមានពណ៌មិនសមគួរផ្សេងៗ គឺខៀវសុទ្ធ, លឿងសុទ្ធ, ក្រហមសុទ្ធ, ថ្លាសុទ្ធ, ខ្មៅសុទ្ធ, ក្រមៅ, ក្រហមព្រឿង (ស្រដៀងពណ៌ជម្ពូ) ។ ម្យ៉ាងទៀត ទ្រង់ហាមប្រើចីវរ មិនកាត់ជាយ, ចីវរមានជាយវែង, ចីវរមានជាយរំលេចជាផ្កាឈើផ្សេងៗ, ចីវរមានជាយធំជាផ្ទាំង និងទ្រង់ហាមប្រើអាវ, មួក, សំពត់រុំ ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកប្រើ ។

## ទ្រង់កំណត់គោលការណ៍ពាក់ព័ន្ធនឹងចីវរដទៃទៀត

កាលបើភិក្ខុចាំវស្សារួចហើយ ចីវរនៅមិនទាន់កើតឡើងនៅឡើយ ក្រោយពេលដែលមានចីវរកើតឡើង បើមានអ្នកសមគួរទទួលជំនួសបានក៏អនុញ្ញាតឲ្យទទួល ប៉ុន្តែបើលោកសឹកជាដើម សង្ឃជាធំក្នុងការទទួលភារៈ ។ បើសង្ឃបែកបាក់សាមគ្គីគ្នា ឲ្យចែកសំពត់តាមបំណងទាយក បើគេមិនចោះចំពោះខាងណាមួយ ឲ្យបែងជាពីរចំណែកស្មើគ្នា ។

ម្យ៉ាងទៀត ទ្រង់ដាក់គោលការណ៍ កាន់យកចីវរភិក្ខុដទៃដោយវិសាសៈ គឺធ្លាប់ស្គាល់គ្នាថាត្រូវមានហេតុផលសមគួរ ។

បន្ទាប់មកទ្រង់សំដែងកតិកា (ខកំណត់ ឬមេបទ) ៨ ប្រការដែលនាំឲ្យកើតមានចីវរ គឺ

១.គេប្រគេនកំណត់ភិក្ខុដែលនៅក្នុងសីមា

២.គេប្រគេនកំណត់កតិកា

៣.គេប្រគេនកំណត់ខេត្ត ឬវត្តដែលគេធ្វើបុណ្យជាប្រចាំ

៤.គេប្រគេនដល់សង្ឃ

៥.គេប្រគេនដល់សង្ឃពីរពួក (គឺភិក្ខុ និងភិក្ខុនី)

៦.គេប្រគេនដល់សង្ឃដែលបានគង់ចាំវស្សា

៧.គេប្រគេនចោះចំពោះ (ប្រគេនព្រមជាមួយ ការប្រគេនបាយយាគូ ឬអាហារដទៃទៀតជាដើម) ។

៨.គេប្រគេនចំពោះបុគ្គល (គឺដល់ភិក្ខុរូបនោះ រូបនេះ) ។

## ៥.ចម្បេយ្យក្ខន្ធកៈ

### (ពោលអំពីហេតុការណ៍នៅក្នុងក្រុងចម្បា)[៧១]

### ការធ្វើកម្មប្រកបដោយធម៌ និងមិនប្រកបដោយធម៌

កស្សបគោត្រភិក្ខុ ជាអ្នកអើពើចំពោះអាគន្តុកភិក្ខុ នៅពេលដែលអាគន្តុកភិក្ខុមកដល់ ក៏ស្វាគមន៍ដោយការផ្តល់សេចក្តីសុខមានប្រការផ្សេងៗ ពួកលោកមានសេចក្តីពេញចិត្តចង់នៅ ប៉ុន្តែពេលនៅយូរទៅ កស្សបគោត្រភិក្ខុក៏លែងខ្វល់ខ្វាយបម្រើដោយអាហារ ព្រោះប្រកាន់ថាបំផ្លាញបិណ្ឌបាត បើនៅតែខំប្រឹង អាចរុកកួនដល់អ្នកស្រុក ។ អាគន្តុកភិក្ខុមិនពេញចិត្ត សូត្រប្រកាសដកលោកចេញពីពួក (ដាក់ឧក្ខេបនីយកម្មដែលមិនប្រកបដោយធម៌) ។ ទើបលោកទៅគាល់ទូលសួរដល់ព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់បញ្ជាឲ្យលោកត្រឡប់ទៅកាន់កន្លែងដើមវិញ ទ្រង់ពន្យល់ថា ភិក្ខុដែលដាក់ទោសដល់លោកនោះ ធ្វើមិនប្រកបដោយធម៌ លោកពុំមានអាបត្តិអ្វីឡើយ ។ ពួកភិក្ខុដែលដាក់ទោសដល់លោក ក្តៅក្រហាយ ទើបមកសុំខមាទោសចំពោះព្រះមានព្រះភាគ ព្រះអង្គប្រទានអភ័យហើយ ទើបទ្រង់សំដែងការធ្វើសង្ឃកម្មប្រកបដោយធម៌ និងមិនប្រកបដោយធម៌ជាអនេក ព្រមទាំងទ្រង់កំណត់ចំនួនសង្ឃធ្វើសង្ឃកម្មដូច្នេះ ៖

១.សង្ឃ ៤ រូប ធ្វើកម្មទាំងពួងបាន លើកលែងឧបសម្ប័ទ, បវារណា និងសូត្រដកចេញចាកអាបត្តិសង្ឃាទិសេស (សំដែងថាកឋិនប្រើសង្ឃ ៤ រូប ក៏បាន តែអដ្ឋកថាកែថា កឋិនត្រូវមាន ៥ រូប កាលបើអដ្ឋកថាជំទាស់ជាមួយនឹងបាលី គួរកាន់យកតាមបាលីវិញ) ។

២.សង្ឃ ៥ រូប ធ្វើកម្មទាំងពួងបាន លើកលែងឧបសម្ប័ទកុលបុត្រនៅក្នុងមជ្ឈិមប្រទេស និងការសូត្រដកចេញចាកអាបត្តិសង្ឃាទិសេស ។

៣.សង្ឃ ១០ រូប ធ្វើកម្មទាំងពួងបាន លើកលែងការសូត្រដកចេញចាកអាបត្តិសង្ឃាទិសេស ។

៤.សង្ឃ ២០ រូប ធ្វើកម្មទាំងពួងបាន ។

៥.សង្ឃច្រើនជាង ២០ រូបឡើងទៅ ធ្វើកម្មទាំងពួងបាន ។

តែបច្ចុប្បន្ន ត្រូវតែព្រមព្រៀងគ្នាប្រជុំប្រកបដោយធម៌ត្រឹមត្រូវតាមព្រះវិន័យ ។ បន្ទាប់មកទ្រង់អធិប្បាយដោយពិស្តារទាក់ទងទៅនឹងសង្ឃ ៤ រូប ៥ រូប ១០ រូប ២០ រូប ធ្វើកម្មផ្សេងៗគ្នា ដោយពិស្តារ ។

[៧១] ក្រុងចម្បា ជានគរនៃដែនអង្គៈ ។

### ឧក្ខេបនីយកម្ម (ដកចេញចាកក្រុម)

បន្ទាប់មក ទ្រង់សំដែងគោលការណ៍ឧក្ខេបនីយកម្ម គឺការសូត្រប្រកាសដកចេញពីក្រុម មិនឲ្យបរិភោគរួម ដេករួម ឬសេពគប់ជាមួយ សំដែងថាអាចធ្វើបានលុះត្រាតែក្នុងករណីមិនឃើញអាបត្តិ, មិនបំពានអាបត្តិ, មិនលះទិដ្ឋិអាក្រក់ ។ បន្ទាប់ពីនោះ ទ្រង់អធិប្បាយការធ្វើកម្មប្រកបដោយធម៌ និងមិនប្រកបដោយធម៌ដល់ព្រះឧបាលី ។

### តជ្ជនីយកម្ម (ការសង្កត់សង្កិន)

ទ្រង់សំដែងគោលការណ៍ដាក់តជ្ជនីយកម្ម គឺការសូត្រប្រកាសដាក់ទោស ជាការតិះដៀលភិក្ខុដែលចូលចិត្តរករឿងបង្កទំនាស់ និងអធិករណ៍ដល់សង្ឃ ។

### និយសកម្ម (ដកយស ឬកាត់សិទ្ធិ)

ទ្រង់សំដែងគោលការណ៍ដាក់និយសកម្ម គឺការដកយស ឬកាត់សិទ្ធិដល់ភិក្ខុដែលយកចិត្តគ្រហស្ថ (ព្រមឲ្យគេប្រើ) មានការប្រព្រឹត្តអាក្រក់ ។

### បដិសារណីយកម្ម (សុំខមាទោសគ្រហស្ថ)

ទ្រង់សំដែងគោលការណ៍ដាក់បដិសារណីយកម្ម ដល់ភិក្ខុអ្នកជេរ អ្នកបរិភាស គឺការឲ្យទៅសុំទោសគ្រហស្ថ ។

## ៦.កោសម្ពិក្ខន្ធកៈ

### (ពោលអំពីហេតុការណ៍នៅក្នុងក្រុងកោសម្ពី)

ផ្ដើមពណ៌នាអំពីភិក្ខុទំនាស់គ្នា ២ រូប គឺមួយរូបចោទអាបត្តិដល់ភិក្ខុមួយរូបទៀត ហើយមិនឃើញអាបត្តិ ទើបនាំបក្សពួកមកប្រជុំគ្នាសូត្រប្រកាសដាក់ឧក្ខេបនីយកម្មដល់ភិក្ខុរូបនោះ ទាំងពីរភាគីសុទ្ធតែមានបក្សពួកច្រើន តែងចោទប្រកាន់គ្នាទៅវិញទៅមករហូតដល់សង្ឃបែកបាក់គ្នាជាពីរពួក និងបែកគ្នាធ្វើឧបោសថ ទោះបីព្រះមានព្រះភាគទ្រង់សំដែងដាស់តឿនក៏មិនស្ដាប់ ទីបំផុត ក៏ទំនាស់ និងសំដែងអាការគាមផ្លូវកាយវាចាមិនសមគួរដល់គ្នា ។

ព្រះមានព្រះភាគទ្រង់ដាស់តឿនម្ដងទៀត ភិក្ខុទាំងនោះ ក៏ត្រឡប់និយាយសុំឲ្យព្រះមានព្រះភាគកុំពាក់ពន្ធជាមួយ សុំឲ្យទ្រង់គង់នៅជាសុខ ពួកលោកនឹងដំណើរការបន្ត ។ ទើបព្រះមានព្រះភាគទ្រង់សំដែងរឿងទីឃាវុកុមារនៃដែនកោសលជាឧទាហរណ៍ ដែលគិតចងគំនុំនឹងព្រះបាទព្រហ្មទត្តនៃដែនកាសី ក្នុងរឿងចាប់ព្រះរាជ-បិតារបស់ព្រះអង្គ គឺព្រះបាទទីឃីតិ យកទៅធ្វើទារុណកម្ម និងប្រហារជីវិត នៅពេលមានឱកាសទើបសងសឹកបាន ក៏នៅនឹកដល់

ទិវាទរបស់បិតាដែលមិនឲ្យឃើញវែង (គឺមិនឲ្យចងកម្មពៀរ) មិនឲ្យឃើញខ្លី (គឺមិនឲ្យផ្តាច់ចំណងមិត្តភាព) និងឲ្យរឭកថា ពៀររមែងរម្ងាប់ដោយការមិនចងពៀរ ទើបទុកជីវិតដល់ព្រះបាទព្រហ្ម-ទត្ត ហើយត្រឡប់បានរាជសម្បត្តិ ព្រមទាំងព្រះរាជធីតារបស់ព្រះបាទព្រហ្មទត្តមកវិញ ។ ទ្រង់សរុបថា ព្រះរាជាដែលកំពុងតែចាប់សស្ត្រាវុធ ក៏គង់នៅមានខន្តី (សេចក្តីអត់ធន់) និងសោរច្ចៈ (សេចក្តីស្ងប់) បាន ដូច្នេះទើបភិក្ខុដែលបួសនៅក្នុងព្រះពុទ្ធសាសនានេះ គួរតែមានខន្តី និងសោរច្ចៈ ។ តែភិក្ខុទាំងនោះក៏មិនព្រមជឿតាម ទើបស្តេចចេញចាកទីនោះ យាងទៅកាន់ពាលកលោណកា-រកគ្រាម, យាងទៅកាន់ព្រៃបាចីនវង្សតាមលំដាប់ ទ្រង់ជួបព្រះថេរៈផ្សេងៗ នៅក្នុងទីដែលស្តេចយាងទៅនោះ ទីបំផុតស្តេចយាងទៅគង់សម្រាកនៅក្រោមដើមសាលព្រឹក្ស នាព្រៃបារិលេយ្យកៈ ។ ត្រង់ចំណុចនេះ មានសំដែងរឿងស្តេចដំរីបារិលេយ្យកៈមកឧបដ្ឋាកព្រះមានព្រះភាគ ។ បន្ទាប់មក ទើបស្តេចយាងទៅកាន់ក្រុងសាវត្ថី ។

ឧបាសកឧបាសិកាក្រុងកោសម្ពី មិនពេញចិត្តពួកភិក្ខុ ដែលបែកគ្នានោះ ទើបបបួលគ្នាមិនសំដែងសេចក្តីគោរព មិនប្រគេនអាហារបិណ្ឌបាត ភិក្ខុបានទទួលនូវការលំបាកទើបដឹងខ្លួនខុស រួចនាំគ្នាធ្វើដំណើរទៅកាន់ក្រុងសាវត្ថី និងយល់ព្រមរម្ងាប់បទវិវាទដោយភិក្ខុដែលជាដើមហេតុព្រមសំដែងអាបត្តិចេញ ភិក្ខុដែលទទួលភារៈជាអ្នកសូត្រប្រកាសដាក់ទោស ត្រូវដកប្រកាស ទើបព្រះមានព្រះភាគត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ សូត្រប្រកាសរម្ងាប់រឿងនោះ ជាសង្ឃសាមគ្គី បន្ទាប់ទើបឲ្យសូត្របាតិមោក្ខ ។

ម្យ៉ាងទៀត ទ្រង់សំដែងរឿងសង្ឃសាមគ្គី គឺការព្រមព្រៀងនៃសង្ឃ ដែលមិនប្រកបដោយធម៌ និងប្រកបដោយធម៌ ដោយសំដែងថា សាមគ្គីគ្នាក្រោយពេលបែកគ្នា ត្រូវកែ ឬដោះស្រាយអំពីដើមហេតុ វិនិច្ឆ័យរឿងក្តី ចូលទៅរករឿងដើមឲ្យចប់សព្វគ្រប់ មិនមែនសើៗ លំៗ ឲ្យតែបានរួបសាមគ្គីគ្នានោះទេ ។

## **ចុល្លវគ្គ** (វគ្គតូច) **ជាវិនយបិដកភាគ ៩**

ដូចសំដែងរួមមកហើយថា មហាវគ្គ (វគ្គធំ) បានដល់ព្រះត្រៃបិដកក្បាលទី ៦-៧ និងក្បាលទី ៨ បំព្រួញរួចហើយ ។ ក្នុងក្បាលទី ៩ មាន ៣ ខន្ធកៈ ឬ ៣ ពួក ។ ក្នុងក្បាលទី ១០ និងទី ១១ មាន ៦ ខន្ធកៈ ឬ ៦ ពួក រួមមហាវគ្គមាន ១០ ខន្ធកៈ ។ ពេលនេះ ជាការបំព្រួញសេចក្តីនៃចុល្លវគ្គ (វគ្គតូច) ទើបគួរជ្រាបថា ចុល្លវគ្គនេះ សំដៅយកព្រះត្រៃបិដកក្បាលទី ៩-១០ និងក្បាលទី ១១ ដែលជាវិនយបិដក ។

ចំពោះក្បាលទី ៩-១០ នេះ មាន ៤ ខន្ធកៈនោះដូច្នេះ៖

១.កម្មក្ខន្ធកៈ (ពោលអំពីសង្ឃកម្ម) ក្នុងពួកនេះបាននាំរឿងដាក់ទោសដែលធ្លាប់បានរៀបរាប់រួចហើយនៅក្នុងក្បាលទី ៩ មកអធិប្បាយជាបទៗ គឺតជ្ជនីយកម្ម (សង្កត់សង្កិន) និយសកម្ម (ដកយស ឬកាត់សិទ្ធិ) បព្វាជនីយកម្ម (បណ្តេញចេញ) បដិសារណីយកម្ម (សុំខមាទោសគ្រហស្ថ) និងឧក្ខេបនីយកម្ម (លើកចេញពីក្រុម) ព្រមទាំងវិធីរម្ងាប់ទោសនោះៗ ។

២.បារិវាសិកខន្ធកៈ (ពោលអំពីភិក្ខុនៅបរិវាសដើម្បីចេញចាកអាបត្តិសង្ឃាទិសេស) សំដៅយកវត្ត ឬខបដិបត្តិរបស់ភិក្ខុអ្នកនៅបរិវាស រួមមាន ៩៤ ខ និងវិធីទាក់ទងនឹងការចេញចាកអាបត្តិសង្ឃាទិសេស ដូចជាខកំណត់ក្នុងការនៅបរិវាស ការទាញចូលរកអាបត្តិដើម ការប្រព្រឹត្តមានត្ត និងការសូត្រដកចាកអាបត្តិ ។

៣.សមុច្ចយក្ខន្ធកៈ (ពោលអំពីការរួបរួម គឺរួបរួមរឿងដែលទាក់ទងទៅនឹងការចេញចាកអាបត្តិសង្ឃាទិសេស ក្រៅពីបរិវាសិកក្ខន្ធកៈ) មានរឿងសុំមានត្ត ការឲ្យមានត្ត ការសុំអព្ភាន (សូត្រដកចេញពីអាបត្តិសង្ឃាទិសេស) ជាដើម ។

៤.សមថក្ខន្ធកៈ (ពោលអំពីវិធីរម្ងាប់អធិករណ៍) វិធីរម្ងាប់អធិករណ៍ ៧ យ៉ាង មានអ្វីខ្លះ បានរៀបរាប់រួចហើយនៅព្រះត្រៃបិដកក្បាលទី ១០ បន្តទៅជាការអធិប្បាយដោយពិស្តារទាំង ៧ខគឺ

១.សម្មុខាវិន័យ ការរម្ងាប់ចំពោះមុខ

២.សតិវិន័យ ការរម្ងាប់ដោយលើកឲ្យព្រះអរហន្តថាជាអ្នក មានសតិ ។

៣.អមូឡ្ហវិន័យ ការរម្ងាប់ដោយលើកប្រយោជន៍ឲ្យក្នុងខណៈពេលឆ្កួត ។

៤.បដិញ្ញាតករណៈ ការរម្ងាប់ដោយកាន់យកតាមពាក្យសារភាពរបស់ចុងចោទ ។

៥.យេភុយ្យសិកា ការរម្ងាប់ដោយកាន់យកសម្លេងខាងច្រើនជាប្រមាណ ។

៦.តស្សបាបិយសិកា ការរម្ងាប់ដោយការដាក់ទោសដល់អ្នកធ្វើខុស ។

៧.តិណវត្ថារកៈ ការរម្ងាប់ដោយការលើកលែង ឬប្រានបោល ។

# សេចក្តីអធិប្បាយ

## ១.កម្មក្ខន្ធកៈ (ពោលអំពីសង្ឃកម្ម)

ភិក្ខុ ២ រូប ឈ្មោះបណ្ឌុកៈ និងលោហិតកៈចូលចិត្តបង្កទំនាស់ បង្កអធិករណ៍នៅក្នុងសង្ឃ គាំទ្រភិក្ខុដែលចូលចិត្តបង្កទំនាស់មានគេតិះដៀល ព្រះមានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃសាកសួរដឹង

ការពិតហើយ ទើបទ្រង់អនុញ្ញាតឲ្យសង្ឃដាក់តជ្ជនីយកម្ម (ការសង្កត់សង្កិន) ដល់លោកទាំងពីរ ដោយការឲ្យចោទអាបត្តិ ឲ្យនឹកឃើញថា ខ្លួនបានធ្វើខុសពិត ឬមិនពិត បន្ទាប់មកឲ្យលើកអាបត្តិឡើងជាដើមហេតុ សូត្រប្រកាសសុំមតិសង្ឃដាក់តជ្ជនីយកម្មដល់លោក (សូត្រស្នើញត្តិ ១ ដង, សូត្របញ្ជាក់សុំមតិ ៣ ដង) សរុបហៅថាញត្តិចតុត្ថកម្មវាចា ។

រួចហើយទ្រង់សំដែងលក្ខណៈ នៃការធ្វើតជ្ជនីយកម្មថាដូចម្តេចប្រកបដោយធម៌ និងមិនប្រកបដោយធម៌ ។ ការធ្វើមិនប្រកបដោយធម៌ ដូចជា មិនធ្វើចំពោះមុខ, មិនសាកសួរ (គឺដាក់ទោសដោយមិនស្តាប់យោបល់), មិនស្តាប់បដិញ្ញា (គឺការសារភាពកំហុសរបស់ចុងចោទ) ។ ចំណែកឯប្រកបដោយធម៌ គឺធ្វើក្នុងទីចំពោះមុខ មានការសាកសួរ មានការស្តាប់បដិញ្ញារបស់ចុងចោទជាដើម ។

## លក្ខណៈបុគ្គលដែលគួរដាក់តជ្ជនីយកម្ម

ភិក្ខុដែលសង្ឃប្រាថ្នាដាក់តជ្ជនីយកម្ម (សង្កត់សង្កិន) អាចដាក់បាន គឺ

១.ជាអ្នកចូលចិត្តបង្កទំនាស់ បង្កអធិករណ៍នៅក្នុង សង្ឃ

២.ជាអ្នកច្រើនទៅដោយអាបត្តិ មានការប្រព្រឹត្តិមិនសមរម្យ

៣.ជាអ្នកនៅប្រឡូកប្រឡល់ដោយគ្រហស្ថក្នុងផ្លូវអាក្រក់ ។

ឬជាអ្នក ១.មានសីលវិបត្តិ គឺវិនាសចាកសីល ២.មានអាចារវិបត្តិ គឺខូចការប្រព្រឹត្ត ឬមារយាទ ៣.មានទិដ្ឋិវិបត្តិ ។

ឬជាអ្នក ១.តិះដៀលព្រះពុទ្ធ ២.តិះដៀលព្រះធម៌ ៣.តិះដៀលព្រះសង្ឃ ។

ឬភិក្ខុ ៣ រូបៗ ណានីមួយៗធ្វើខុសយ៉ាងណាមួយ ដូចនិយាយរួចមកហើយ (ការដាក់ទោសមិននិយមធ្វើដល់ភិក្ខុដែលមានចំនួន ៤ រូបឡើងទៅទេ ពីព្រោះក្លាយជាសង្ឃដាក់ទោសសង្ឃ បើមានរឿងកើតឡើង ត្រូវរកមធ្យោបាយឲ្យសង្ឃដាក់ទោសបុគ្គលមិនលើសពី ៣ រូប) ។

## ការដាក់ទោសជាហេតុនាំឱ្យវិនាសសិទ្ធិផ្សេងៗ

ភិក្ខុដែលសង្ឃដាក់តជ្ជនីយកម្ម ត្រូវតែប្រព្រឹត្តវត្ត ឬនិយាយម្យ៉ាងទៀត គឺត្រូវកាត់សិទ្ធិផ្សេងៗ រួមមាន ១៨ យ៉ាង គឺ

១.មិនគប្បីឲ្យឧបសម្បទ (ហាមធ្វើជាឧបជ្ឈាយ៍)

២.មិនគប្បីឲ្យនិស្ស័យ (ហាមទទួលយកបុគ្គលមកគ្រប់គ្រង)

៣.មិនគប្បីមានសាមណេរបម្រើ

៤.មិនគប្បីតែងតាំងឲ្យជាអ្នកទូន្មានភិក្ខុនី

៥. ទោះបីបានទទួលការតែងតាំងហើយ ក៏មិនគួរទៅទូន្មានភិក្ខុនីឡើយ ។

៦.ត្រូវសង្ឃដាក់ទោសដោយអាបត្តិណា មិនគប្បីឲ្យត្រូវអាបត្តិនោះទៀតទេ ។

៧.មិនគួរត្រូវអាបត្តិប្រភេទដូចគ្នានោះទៀត

៨.មិនគួរត្រូវអាបត្តិគ្រោតគ្រាតជាងនោះ

៩.មិនត្រូវតិះដៀលកម្មនោះ

១០.មិនត្រូវតិះដៀលសង្ឃដែលធ្វើកម្មនោះ

១១.មិនត្រូវហាមឃាត់ឧបោសថដល់បកតត្តភិក្ខុ

១២.មិនត្រូវហាមឃាត់បវារណាដល់បកតត្តភិក្ខុ

១៣.មិនត្រូវសួរភិក្ខុដទៃ

១៤.មិនត្រូវតាំងផ្ដើមអនុវាទាធិករណ៍ (ការចោទអាបត្តិ)

១៥.មិនត្រូវសុំឲ្យភិក្ខុដទៃធ្វើឱកាស (ដើម្បីចោទអាបត្តិ)

១៦.មិនត្រូវចោទអាបត្តិភិក្ខុដទៃ

១៧.មិនត្រូវធ្វើភិក្ខុដទៃឲ្យរពុក (ថាធ្វើខុសត្រង់ចំណុចនោះ ចំណុចនេះឬទេ) ។

១៨.មិនត្រូវជួយភិក្ខុទាំងឡាយ ឲ្យនាំគ្នាតស៊ូ នៅក្នុងរឿងអធិករណ៍ ។

## ការមិនរម្ងាប់ និងការរម្ងាប់ទោស

ភិក្ខុដែលសង្ឃដាក់តជ្ជនីយកម្ម វិនាសសិទ្ធិផ្សេងៗហើយ បំពានធ្វើរឿងដែលត្រូវកាត់សិទ្ធិនោះ មិនត្រូវរម្ងាប់ការដាក់ទោស ដរាបណាបានបដិបត្តិតាមក្នុងការលះបង់សិទ្ធិផ្សេងៗ ទើបគួរសូត្រប្រកាសរម្ងាប់ទោស ។

## ព្រះសេយ្យសកៈ និងនិយសកម្ម (ការដកយស)

សេយ្យសកភិក្ខុ ជាអ្នកច្រើនដោយអាបត្តិ មានឥរិយាបថមិនសមរម្យ នៅច្រឡូកច្រឡំជាមួយគ្រហស្ថ ដែលមិនសមគួរ ។ បកតត្តភិក្ខុទាំងឡាយ នៅតែឲ្យបរិវាសជាដើម គឺជួយធ្វើពិធីចេញចាកអាបត្តិសង្ឃាទិសេសដល់លោក ។ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់ប្រជុំភិក្ខុសង្ឃ សាកសួរដឹងការពិតហើយ ទ្រង់អនុញ្ញាតឲ្យសង្ឃដាក់និយសកម្ម (គឺការដកយស ឬកាត់សិទ្ធិ) ដល់លោកដោយវិធីដាក់តជ្ជនីយកម្ម ។

ក្រៅពីនោះ ទ្រង់សំដែងលក្ខណៈនៃការធ្វើនិយសកម្មប្រកបដោយធម៌ដូចម្ដេច និងមិនប្រកបដោយធម៌ដូចម្ដេច ដែលមានកំណត់ដូចតជ្ជនីយកម្មដែរ ។

បន្ទាប់មកទ្រង់សំដែងលក្ខណៈនៃភិក្ខុ ដែលគួរធ្វើនិយសកម្មច្រើនប្រការ ដូចការដាក់តជ្ជនីយកម្មដែរ ។

ការវិនាសសិទ្ធិ ការរម្ងាប់ការដាក់ទោស ការមិនរម្ងាប់ការដាក់ទោស ក៏មានលក្ខណៈដូចតជ្ជនីយកម្មដែរ (ប៉ុន្តែគួរសង្កេតថា តជ្ជនីយកម្មនោះ គឺជារឿងបន្តវិវាទ, ចំណែកឯនិយសកម្មវិញ គឺ

ជារឿងត្រូវអាបត្តិច្រើន មានឥរិយាបថមិនសមរម្យ និងការនៅច្របូកច្របល់ជាមួយគ្រហស្ថ) ។

## ការដាក់ទោសដោយការបណ្តេញចេញ

## (បព្វាជនីយកម្ម)

ភិក្ខុជាបក្សពួករបស់អស្សជិភិក្ខុ[៧២] និងបុនព្វសុកដែលអាស្រ័យ នៅក្នុងកិដាគីរីជនបទ ជាភិក្ខុអលជ្ជី ប្រព្រឹត្តធ្វើរឿងពុំសមគួរ ដូច ជា ដាំដើមឈើដោយខ្លួនឯង ប្រើឲ្យដាំដើមឈើដល់គ្រហស្ថ ក្រង ផ្កាឲ្យគ្រហស្ថ បរិភោគអាហារនៅក្នុងវេលាវិកាល ផឹកទឹកស្រវឹង តុបតែងផ្កាឈើ រាំច្រៀង និងលេងល្បែងភ្នាល់ដទៃទៀត ។

ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ជាព្រះសារីបុត្រ និងព្រះមោគ្គល្លានឲ្យទៅដាក់បព្វាជនីយកម្ម ដល់ភិក្ខុទាំងនោះ ទ្រង់ណែនាំរបៀបធ្វើ និងពិធីសូត្រប្រកាស មិនឲ្យពួកភិក្ខុអស្សជិ និងបុនព្វសុកៈនៅក្នុងជនបទនោះតទៅទៀត ។

[៧២] អស្សជិភិក្ខុរូបនេះ មិនមែនជាអាចារ្យរបស់ព្រះសារីបុត្រទេ ។

ទ្រង់សំដែងលក្ខណៈនៃការធ្វើបព្វាជនីយកម្ម ដូចម្តេចប្រកបដោយធម៌ និងមិនប្រកបដោយធម៌ ដែលមានខកំណត់ដូចតជ្ជនីយ-កម្មដែរ ។

បន្ទាប់មកទៀត ទ្រង់សំដែងលក្ខណៈនៃភិក្ខុដែលគួរដល់ការដាក់បព្វាជនីយកម្ម (បណ្តេញចេញ) ច្រើនប្រការ មានទាំងចំណុចមិនល្អដូចដែលបានរៀបរាប់ទុកនៅក្នុងតជ្ជនីយកម្ម និងនិយស-កម្ម ព្រមទាំងចំណុចមិនល្អទាក់ទងទៅនឹងការប្រព្រឹត្តមិនសមគួរ តាមផ្លូវកាយវាចា និងចិញ្ចឹមជីវិតខុសជាដើម ។

ការវិនាសសិទ្ធិរបស់ភិក្ខុដែលត្រូវដាក់បព្វាជនីយកម្មនោះ មាន ១៨ យ៉ាងដូចតជ្ជនីយកម្មដែរ (ជាពិសេស គឺការបណ្តេញចេញ មិនឲ្យនៅជាមួយ) ។

រួចហើយ ទ្រង់សំដែងលក្ខណៈដែលមិនគួរដល់ការរម្ងាប់ការដាក់ទោស និងគួរដល់ការរម្ងាប់ការដាក់ទោសនោះៗ ។

ការដាក់ទោសឲ្យខមាទោសគ្រហស្ថ (បដិសារណីយកម្ម)

ព្រះសុធម្មអាស្រ័យនៅក្នុងវត្តចិត្តគហបតី នៅនាព្រៃមច្ឆិកាក្រោធថា គហបតីនិមន្តតែព្រះថេរៈដទៃទៅឆាន់ ដោយពុំបានប្រាប់ឬប្រឹក្សាជាមួយខ្លួនជាមុន ទើបក្លែងនិយាយប៉ះពាល់ដល់ត្រកូលរបស់គហបតី ដែលមានព្រះថេរៈដទៃនៅជាមួយដែរថា វត្ថុទំពាវត្ថុឆាន់របស់លោកសម្បូរអស់ មិនមាននៅសល់សូម្បីតែនំលាយ

លាយល្វ (តិលសគ្គុលិកា)[៧៣] និងបានសំដែងអាការដទៃទៀត ក្នុងផ្លូវដែលមិនសមគួរ ។

ព្រះមានព្រះភាគទ្រង់ជ្រាប ទើបណែនាំឲ្យសង្ឃសូត្រប្រកាសដាក់បដិសារណីយកម្ម គឺឲ្យទៅសុំទោសគ្រហស្ថដែលខ្លួនបានបំពានទៅលើ ។

រួចហើយ ទ្រង់សំដែងលក្ខណៈនៃការធ្វើបដិសារណីយកម្ម ដែលប្រកបដោយធម៌ និងមិនប្រកបដោយធម៌ ក្នុងទំនងដូចតជ្ជនីយកម្មដែរ ។

ចំណែកឯលក្ខណៈភិក្ខុ ដែលគួរដាក់ទោសដូចនេះ លោកសំដែងទុក ៤ ពួកៗ នីមួយមាន ៥ ចំណុច គឺ

**១.**

ក) ខ្វល់ខ្វាយដើម្បីឲ្យវិនាសលាភគ្រហស្ថ

ខ) ខ្វល់ខ្វាយដើម្បីឲ្យវិនាសប្រយោជន៍ (អនត្ថ) គ្រហស្ថ

គ) ខ្វល់ខ្វាយដើម្បីឲ្យគ្រហស្ថ នៅមិនបាន

ឃ) ជេរ ឬបរិភាស (ជេរអម) គ្រហស្ថ

ង) ធ្វើឲ្យគ្រហស្ថបែកបាក់គ្នា ។

**២.**

ក) តិះដៀលព្រះពុទ្ធឲ្យគ្រហស្ថស្តាប់

ខ) តិះដៀលព្រះធម៌ ឲ្យគ្រហស្ថស្តាប់

គ) តិះដៀលព្រះសង្ឃឲ្យគ្រហស្ថស្តាប់

ឃ) ជេរ ឬនិយាយសង្កត់សង្កិនដោយពាក្យអាក្រក់

ង) ទទួលពាក្យដែលប្រកបដោយធម៌ជាមួយគ្រហស្ថហើយធ្វើឲ្យអាក់ខាន គឺមិនធ្វើតាមនោះទេ ។

**៣.**

ភិក្ខុ ៥ រូបៗនីមួយៗធ្វើអំពើអាក្រក់ ដូចបានរៀបរាប់ទុកនៅក្នុងពួក ១ រូបនីមួយៗធ្វើផ្សេងៗគ្នា ។

**៤.**

ភិក្ខុ ៥ រូបៗនីមួយៗធ្វើអំពើអាក្រក់ ដូចបានរៀបរាប់ទុកនៅក្នុងពួក ២ រូបនីមួយៗធ្វើផ្សេងៗគ្នា ។

ទាំង ៤ ពួកៗនីមួយៗ ៥ ខនេះ ពួកណានីមួយដែលភិក្ខុធ្វើល្មើស បើសង្ឃបវារណាដាក់ទោស ឲ្យសុំខមាទោសគ្រហស្ថ (បដិសារណីយកម្ម) ក៏ធ្វើបាន ។

បន្ទាប់មក ទ្រង់សំដែងការវិនាសសិទ្ធិ ឬការប្រព្រឹត្តវត្ត ១៨ យ៉ាង ដូចបានរៀបរាប់ទុកនៅក្នុងតជ្ជនីយកម្ម ។

---

[៧៣] គ្រកូលគហបតីនេះ មានអាជីពជាអ្នកធ្វើនំលាយល្វលក់ ។ ម្យ៉ាងទៀត គហបតីនេះ ជាព្រះអនាគាមី ។

*រួចហើយទ្រង់សំដែងវិធីបដិបត្តិសុំខមាទោសគ្រហស្ថ ដើម្បីជួយចរចាឲ្យគេលើកលែងទោស កាលបើធ្វើបានដូច្នេះ សង្ឃគប្បីសូត្រប្រកាសលើកលែងទោសនោះ ។*

*បន្ទាប់មកទៀត ទើបទ្រង់សំដែងលក្ខណៈភិក្ខុដែលគួរ និងមិនគួរលើកលែងទោសដូចនេះ មួយក្រុម ១៨ ខ ដូចតជ្ជនីយកម្មដែរ ។*

## ឆន្នភិក្ខុនឹងការលើកចេញចាកក្រុម (ឧក្ខេបនីយកម្ម)

*ឆន្នភិក្ខុត្រូវអាបត្តិហើយមិនឃើញអាបត្តិ ដំណឹងនេះដឹងដល់ព្រះមានព្រះភាគ ទើបទ្រង់ណែនាំឲ្យសង្ឃដាក់ទោសលើកចេញពីក្រុម គឺមិនឲ្យសេពគប់ជាមួយ ។ ទ្រង់សំដែងលក្ខណៈនៃការដាក់ទោសប្រកបដោយធម៌ និងមិនប្រកបដោយធម៌ដូចតជ្ជនីយកម្មដែរ ប៉ុន្តែមិនបានបញ្ជាក់អំពីការដាក់ទោសលើកចេញពីក្រុមនេះទេ ពីព្រោះភិក្ខុមិនឃើញអាបត្តិ, មិនសំដែងអាបត្តិ, មិនលះបង់ទិដ្ឋិអាក្រក់, និងនៅមានចំណុចមិនល្អផ្សេងទៀត ដូចតជ្ជនីយកម្មដែរ ។*

*រួចហើយទ្រង់សំដែងការវិនាសសិទ្ធិជាដើម ដូចបានរៀបរាប់ទុកនៅក្នុងតជ្ជនីយកម្មដែរ ។ (ម្យ៉ាងទៀត គប្បីសង្កេតថា ពាក្យថាការវិនាសសិទ្ធិនោះ គឺជាការរៀបរាប់ឲ្យយល់បានដោយងាយស្រួលនៅក្នុងភាសាបាលី ប្រើពាក្យថា វត្ត ឬខបដិបត្តិ ១៨ ខ) ។*

## ២.បរិវាសិកខន្ធកៈ (ពោលអំពីអ្នកនៅបរិវាស)

*(កាលបើរៀបរាប់ដល់វិនយកម្មទាក់ទងទៅនឹងការចេញចាកអាបត្តិសង្ឃាទិសេសនៅក្នុងពួកនេះ គួរជ្រាបអត្ថន័យនៃសព្ទ និងលំដាប់នៃការបដិបត្តិដែលមាននៅក្នុងពួកនេះជាមុន ដូចតទៅនេះ ៖*

**១.ការនៅបរិវាស** *គឺការដាក់ទោសទូន្មានខ្លួនឯង រហូតដល់គ្រប់កាលកំណត់ដែលត្រូវ និងបិទបាំងអាបត្តិសង្ឃាទិសេសទុក បើបិទបាំងទុកប៉ុន្មានថ្ងៃ ប៉ុន្មានខែ ត្រូវនៅបរិវាសឲ្យគ្រប់ចំនួនដែលបិទបាំងទុកនោះ ។*

**២.ការទាញចូលរកអាបត្តិដើម** *ឬមូលាយបដិកស្សនា គឺក្នុងពេលនៅបរិវាស ឬកំពុងប្រព្រឹត្តមានត្ត (មានសំដែងតទៅខាងមុខ) ធ្វើឲ្យត្រូវអាបត្តិសង្ឃាទិសេសដដែលនោះ ត្រូវចាប់ផ្តើមសារជាថ្មី គឺត្រូវត្រឡប់មកនៅបរិវាស ឬប្រព្រឹត្តមានត្តសារជាថ្មី ។*

**៣.ការប្រព្រឹត្តមានត្ត** *កាលបើនៅបរិវាសគ្រប់កំណត់ដែលបានបិទបាំងទុកហើយនោះ ឬមិនបានបិទបាំងទុកទេ ក៏ពុំចាំបាច់នៅបរិវាសឡើយ ត្រូវឲ្យប្រព្រឹត្តមានត្តតែម្តង គឺត្រូវដាក់ទោសឲ្យរៀងចាលទៅនឹងកំហុសរបស់ខ្លួនដូចនៅបរិវាសដែរ ប៉ុន្តែមានកំណត់ត្រឹមតែ ៦ រាត្រី មិនថាបានបិទបាំង ឬមិនបិទបាំងអាបត្តិ*

សង្ឃាទិសេសឡើយ គឺត្រូវតែប្រព្រឹត្តមានត្ត ៦ រាត្រីដូចគ្នាទាំងអស់ ។

**៤.ការសូត្រដកចេញពីអាបត្តិសង្ឃាទិសេស ឬអព្ភាន**

នៅពេលដែលភិក្ខុត្រូវដាក់ទោសឲ្យនៅបរិវាស (បើបិទបាំងអាបត្តិទុក) និងឲ្យប្រព្រឹត្តមានត្តត្រឹមត្រូវហើយ ជាបុគ្គលគួរដល់ការសូត្រដកចេញពីអាបត្តិនោះ ការសូត្រដកចេញពីអាបត្តិ នេះហៅថា អព្ភាន ត្រូវឲ្យភិក្ខុប្រជុំគ្នាមិនតិចជាង ២០ រូប ។

ក្នុងខណៈពេលដែលកំពុងដាក់ទោសនេះ ភិក្ខុត្រូវកាត់សិទ្ធិជាច្រើន ទាំងការប្រាប់កំហុសខ្លួនដល់ភិក្ខុដែលធ្វើដំណើរឆ្លងកាត់ទៅមក និងប្រាប់នៅក្នុងទីប្រជុំសង្ឃនៅពេលដែលធ្វើឧបោសថកម្ម សរុបសេចក្តីថា ជាការដាក់ទោសដែលធ្វើឲ្យដឹងខ្លួនថាមានទោសធ្ងន់ ភាគច្រើនត្រូវទាក់ទងជាមួយនឹងសង្ឃ ដោយការរុញច្រាន និងការសូត្រប្រកាសជាច្រើនដំណាក់កាល ។

## កាត់សិទ្ធិភិក្ខុនៅបរិវាស

សម័យនោះ ភិក្ខុនៅបរិវាសត្រេកអរនឹងការសំពះជាដើមរបស់បកតត្តភិក្ខុ (ភិក្ខុមិនត្រូវអាបត្តិ) ព្រះមានព្រះភាគទ្រង់ជ្រាបទើបដាក់ខកំណត់មិនឲ្យភិក្ខុនៅបរិវាសត្រេកអរនឹងការសំពះ, ការក្រោកទទួល, ការធ្វើអញ្ជលី, ការធ្វើប្រពៃ (ដូចជាសំដែងសេចក្តីគោរព), ការយកអាសនៈឲ្យ, ការរៀបចំទីដេកឲ្យ, ការលាងជើង, ការតម្កល់តាំងទ្រជើង, ការតម្កល់ក្បឿងដុតជើង, ការទទួលបាត្រចីវរ, ការដុសខ្នងវេលាងូតទឹក ។ បើនៅតែត្រេកអរទង្វើដែលគេធ្វើមកលើខ្លួនដូចនោះ ត្រូវអាបត្តិទុក្កដ ។ ទ្រង់អនុញ្ញាតឲ្យភិក្ខុនៅបរិវាសដូចគ្នា សំដែងសេចក្តីគោរពដល់គ្នានឹងគ្នាបានតាមលំដាប់វស្សា រួចហើយទ្រង់អនុញ្ញាតឲ្យភិក្ខុនៅបរិវាសដូចគ្នាធ្វើឧបោសថ, បវារណា, ចែកសំពត់ងូតទឹកភ្លៀង, ទទួលអាហារ និងចែកអាហារតាមលំដាប់វស្សាបាន ។

## វត្ត ៩៤ ខ របស់អ្នកនៅបរិវាស

ទ្រង់សំដែងវត្ត ៩៤ ខ នៃភិក្ខុនៅបរិវាស ឬនិយាយម្យ៉ាងទៀត គឺការកាត់សិទ្ធិផ្សេងៗ ហាមធ្វើយ៉ាងនោះយ៉ាងនេះរួមទាំងអស់ ៩៤ ខ (តែក្នុងទីនេះ រួបរួមចំណុចខ្លះៗដែលជាមេបទសំខាន់ៗដូចតទៅ) ៖

១.មិនឲ្យធ្វើតួនាទីជាព្រះថេរៈ សូម្បីជាព្រះថេរៈហើយក៏ដោយ ក៏ត្រូវរម្ងាប់បណ្តោះអាសន្ន ដូចជាហាមបំបួសកុលបុត្រ, ហាមឲ្យនិស្ស័យជាដើម ។

២.កំពុងជាក់ទោសដោយអាបត្តិណា ហាមត្រូវអាបត្តិនោះទៀត ឬត្រូវអាបត្តិផ្សេងដែលមានលក្ខណៈដូចគ្នា ឬគ្រោតគ្រាតជាងនោះ ។

៣.ហាមកាន់យកសិទ្ធិជាបកតត្តភិក្ខុ ដូចជា មិនឲ្យមានសិទ្ធិហាមឧបោសថ ឬបវារណាដល់បកតត្តភិក្ខុ ហាមចោទប្រកាន់ភិក្ខុដទៃជាដើម ។

៤.ហាមកាន់យកសិទ្ធិតាមលំដាប់វស្សា ដូចជាមិនឲ្យដើរនាំមុខ មិនឲ្យអង្គុយពីមុខបកតត្តភិក្ខុនៅពេលមានការចែករបស់របរគប្បីត្រេកអររបស់មិនល្អដែលចែកពេលក្រោយ ទាំងអស់នេះសំដៅយករួមទាំងទីអង្គុយ ទីដេក និងទីលំនៅ ។

៥.ហាមធ្វើអាការដូចអ្នកទ្រង់យស ដូចជា មានបកតត្តភិក្ខុដើរនាំមុខ ឬដើរតាមក្រោយ ឬឲ្យគេនាំអាហារមកឲ្យ ដោយមិនចង់ឲ្យគេដឹងថា កំពុងជាប់ទោស ។

៦.ឲ្យបន្ទាបខ្លួន ដូចជាទៅកាន់វត្តដទៃ ត្រូវប្រាប់អាបត្តិខ្លួនដល់ភិក្ខុដែលនៅក្នុងវត្តនោះ នៅពេលមានភិក្ខុដទៃមកត្រូវប្រាប់អាបត្តិដល់ភិក្ខុនោះ ត្រូវប្រាប់អាបត្តិក្នុងពេលធ្វើឧបោសថ បវារណា បើអាពាធត្រូវផ្ដាំផ្ញើភិក្ខុដទៃ ។

៧.ហាមនៅវត្តដែលមិនមានភិក្ខុសង្ឃ (ដើម្បីការពារគេចវេសទៅនៅវត្តស្ងាត់ដែលមិនមានភិក្ខុនៅ ដោយសារខ្ជិលធ្វើវត្ត) ។

៨.ហាមនៅរួមក្នុងទីប្រក់ទីបាំងជាមួយនឹងបកតត្តភិក្ខុ ដើម្បីកាត់សិទ្ធិការនៅរួមជាមួយនឹងភិក្ខុដទៃបណ្ដោះអាសន្ន ។

៩.ឃើញបកតត្តភិក្ខុ ត្រូវក្រោកចាកអាសនៈ ហើយនិមន្តលោកឲ្យអង្គុយលើអាសនៈ មិនឲ្យអង្គុយ ឈរ ឬដើរ ក្នុងទីខ្ពស់ជាងបកតត្តភិក្ខុ ។

១០.សូម្បីភិក្ខុដែលត្រូវជាប់ទោសដូចគ្នា ក៏មិនឲ្យនៅរួមក្នុងទីប្រក់ទីបាំងជាមួយគ្នាដែរ ត្រូវនៅផ្សេងៗគ្នា ។

ចាប់ពីខទី ៦ ដល់ខទី ១០ បើភិក្ខុប្រព្រឹត្តល្មើស ការប្រព្រឹត្តវត្តដើម្បីចេញចាកអាបត្តិរបស់លោក ត្រូវទុកជាមោឃៈមានសព្ទហៅថា វត្តភេទ (បែកធ្លាយវត្ត) និងរត្តិច្ឆេទ (ដាច់រាត្រី) ថ្ងៃដែលប្រព្រឹត្តល្មើសនោះ មិនឲ្យរាប់ជាថ្ងៃពេញក្នុងការលើកលែងទោស ត្រូវធ្វើនិងរាប់ជាថ្មីទៀត ក្នុងការសារភាពទោសកំហុសខ្លួនឯង ។

១១.ក្នុងការធ្វើសង្ឃកម្មទាក់ទងទៅនឹងការនៅបរិវាស, ការទាញចូលរកអាបត្តិដើម ដែលត្រូវការសង្ឃ ៤ រូប ហាមភិក្ខុដែលត្រូវជាប់ទោសចូលរួមធ្វើកម្មជាគម្រប់ ៤ បើមានបកតត្តភិក្ខុ ៤ រូប អាចឲ្យភិក្ខុដែលត្រូវជាប់ទោសចូលរួមបាន មិនខូចកម្ម ហើយការសូត្រដកអាបត្តិសង្ឃាទិសេសរបស់ភិក្ខុដទៃ ដែលត្រូវការសង្ឃ

២០ រូប ភិក្ខុដែលត្រូវដាប់ទោសមិនអាចចូលរួមគម្រប់ ២០ រូប បានឡើយ ត្រូវមានបកតត្តភិក្ខុគ្រប់ ២០ រូប ទើបធ្វើបាន ។

បន្ទាប់ពីនេះទៅ នឹងសំដែងដល់ភិក្ខុដែលត្រូវដាប់ទោសក្នុងលំដាប់ផ្សេងៗគ្នា ត្រូវប្រព្រឹត្តវត្តដូចភិក្ខុនៅបរិវាសដែរគឺ

១.ភិក្ខុដែលគួរទាញចូលរកអាបត្តិដើម (ព្រោះត្រូវអាបត្តិដូចគ្នាទៀត ក្នុងពេលកំពុងប្រព្រឹត្តវត្តដើម្បីចេញចាកអាបត្តិនោះ) ។

២.ភិក្ខុគួរដល់មានត្ត (ព្រោះនៅបរិវាសរួចហើយ ឬព្រោះមិនបានបិទបាំងអាបត្តិ) ។

៣.ភិក្ខុកំពុងប្រព្រឹត្តមានត្ត ។

៤.ភិក្ខុគួរដល់អព្ភាន គឺគួរសូត្រដកចេញចាកអាបត្តិបាន (ព្រោះនៅបរិវាស និងប្រព្រឹត្តមានត្តរួចហើយ) ។

## រត្តិច្ឆេទ (ការដាច់រាត្រី)

ព្រះឧបាលីបានក្រាបទូលសួរព្រះមានព្រះភាគ អំពីការដាច់រាត្រី (រត្តិច្ឆេទ) នៃភិក្ខុអ្នកនៅបរិវាស ឬប្រព្រឹត្តមានត្ត ដែលប្រព្រឹត្តល្មើសខហាមប្រាមថា មានចំណុចផ្សេងគ្នាដូចម្តេច ព្រះមានព្រះភាគត្រាស់តបថា ការដាច់រាត្រីនៃភិក្ខុអ្នកនៅបរិវាស ព្រោះហេតុ ៣ យ៉ាងគឺ

១.នៅក្នុងទីប្រក់ទីបាំងជាមួយភិក្ខុដទៃ

២.នៅក្នុងវត្តដែលមិនមានភិក្ខុ

៣.មិនប្រាប់ ឬប្រកាសខ្លួនឯងដែលទាក់ទងទៅនឹងអាបត្តិនោះដល់ភិក្ខុ ឬសង្ឃ ។ ចំណែកការដាច់រាត្រី នៃភិក្ខុអ្នកប្រព្រឹត្តមានត្តមាន ៤ យ៉ាងគឺ ៣ ចំណុចដំបូងដូចភិក្ខុ អ្នកនៅបរិវាសដែរ ចំពោះខទី ៤ គឺប្រព្រឹត្តមានត្តក្នុងសង្ឃ ដែលមិនគ្រប់គណៈ (ក្នុងពេលប្រព្រឹត្តមានត្ត សង្ឃនៅក្នុងវត្តនោះ មិនត្រូវមានចំនួនថយចុះតិចជាង ៤ រូបឡើយ) ឯការនៅបរិវាសវិញ មានតែភិក្ខុចំនួន ១ រូបក៏បានដែរ វៀរលែងតែនៅម្នាក់ឯង ។

## ការរក្សាបរិវាស និងមានត្ត

ក្នុងករណីមានហេតុការកើតឡើង មិនអាចនៅបរិវាស ឬប្រព្រឹត្តមានត្តបានស្រួល ដូចជា សង្ឃមកប្រជុំគ្នាច្រើន មិនអាចដើរប្រាប់កំហុសខ្លួនឯងឲ្យគ្រប់អង្គបាន ទ្រង់អនុញ្ញាតឲ្យរក្សាបរិវាស ឬមានត្តបាន នៅពេលហេតុការណ៍ស្ងប់ហើយ ទើបឲ្យសមាទានគឺកាន់យកការនៅបរិវាស ឬប្រព្រឹត្តមានត្តជាបន្តទៅទៀត ។

## ៣.សមុច្ចយក្ខន្ធកៈ

(ពោលអំពីការរួបរួមរឿងការចេញចាកអាបត្តិសង្ឃាទិសេស)

ក្នុងចំណុចនេះ សំដែងអំពីវិធីចេញចាកអាបត្តិសង្ឃាទិសេស ដោយដំណាលរឿងព្រះឧទាយីប្រឹក្សាសង្ឃថា ត្រូវអាបត្តិសង្ឃាទិសេសហើយ គួរបដិបត្តិដូចម្តេច (ប្រៀបដូចការតាំងតុក្កតាឲ្យមើលតាំងពីដើមដល់ចប់) មានការសំដែងពិស្តារ ដែលព្រះមានព្រះភាគទ្រង់ណែនាំដូចតទៅនេះ ៖

១.ត្រូវអាបត្តិសង្ឃាទិសេសមួយហើយ មិនបានបិទបាំងទុក ឲ្យសុំមានត្ត ឲ្យសូត្រប្រកាសដាក់មានត្ត ៦ រាត្រី នៅពេលប្រព្រឹត្តមានត្តរួចហើយ ឲ្យសុំអព្ភាន (សុំឲ្យសង្ឃសូត្រចេញចាកអាបត្តិ) ឲ្យសូត្រ ប្រកាសចេញចាកអាបត្តិ ។

២.ត្រូវអាបត្តិសង្ឃាទិសេសមួយហើយ បិទបាំងទុកមួយថ្ងៃ ឲ្យសុំបរិវាសមួយថ្ងៃ រួចហើយទើបសុំមានត្ត ៦ រាត្រី ដំណើរការជាបន្ត ។

៣.ត្រូវអាបត្តិសង្ឃាទិសេសមួយហើយ បិទបាំងទុក ២ ថ្ងៃខ្លះ ៣ ថ្ងៃខ្លះ ៤ ថ្ងៃខ្លះ ៥ ថ្ងៃខ្លះ ឲ្យសុំបរិវាស ២ ថ្ងៃ ៣ ថ្ងៃ ៤ ថ្ងៃ ៥ ថ្ងៃ តាមសមគួរដល់ហេតុ រួចហើយសុំមានត្ត ៦ រាត្រី និងដំណើរការជាបន្ត ។

៤.ត្រូវអាបត្តិសង្ឃាទិសេសហើយ បិទបាំងទុក ៥ ថ្ងៃ សុំបរិវាស ៥ ថ្ងៃ ពេលកំពុងនៅបរិវាសត្រូវអាបត្តិដូចនោះទៀត ឲ្យទាញចូលរកអាបត្តិដើម ដោយសុំចំពោះសង្ឃ ឲ្យទាញចូលរកអាបត្តិដើមហើយសុំបរិវាសជាថ្មី នៅបរិវាស ៥ ថ្ងៃទៀត ទើបដំណើរការជាបន្ត ។

៥.ត្រូវអាបត្តិសង្ឃាទិសេសហើយ បិទបាំងទុក ១ បក្ស (១៥ ថ្ងៃ) ឲ្យសុំបរិវាស ១ បក្ស ពេលកំពុងនៅបរិវាស ត្រូវអាបត្តិដដែលទៀត បិទបាំងទុក ៥ ថ្ងៃ ឲ្យសុំចំពោះសង្ឃ ដើម្បីទាញចូលរកអាបត្តិដើម ចាប់ផ្តើមសុំបរិវាសថ្មី ដោយរួមជាមួយនឹងអាបត្តិដែលបិទបាំងទុក (នៅពេលរួមគ្នា ឲ្យរាប់ខាងច្រើនតែម្យ៉ាង គឺ ១៥ ថ្ងៃ ពុំចាំបាច់បន្ថែម ៥ ថ្ងៃទៀតទេ) ។ ក្រោយមកពេលលោកនៅបរិវាសរួចហើយ សុំប្រព្រឹត្តមានត្ត នៅពេលកំពុងប្រព្រឹត្តមានត្ត ត្រូវអាបត្តិដដែលទៀត ឲ្យសង្ឃទាញចូលរកអាបត្តិដើម គឺត្រូវចាប់ផ្តើមនៅបរិវាសសារជាថ្មី (១៥ ថ្ងៃទៀត) រួចហើយទើបសុំមានត្ត ប្រព្រឹត្តមានត្តជាថ្មី រហូតដល់សូត្រដកជាទីបំផុត ។

ក្រៅពីនេះ នៅមានសំដែងតួយ៉ាងជាច្រើនទៀត ដែលមានសភាពច្របូកច្របល់ក្នុងពេលកំពុងប្រព្រឹត្តមានត្តខ្លះ ក្នុងករណីដទៃខ្លះ ។ (បើភិក្ខុរូបណាប្រព្រឹត្តមានសភាពសាំញ៉ាំដូច្នេះ គឺនៅពេលចេញចាកអាបត្តិ ក៏ពុំអាចចេញបានឡើយ ត្រឡប់ធ្វើខុសម្តងហើយម្តងទៀត ។ ក្នុងវិធីបដិបត្តិក៏អាចបណ្តេញចេញ គឺដាក់បព្វាជនីយកម្មព្រោះសីលវិបត្តិបាន ប៉ុន្តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់ណែ

នាំឲ្យដោះស្រាយបញ្ហាទាក់ទងទៅនឹងវិធីចេញចាកអាបត្តិ ដូចគ្នានឹងការឆ្លើយតបបញ្ហាច្បាប់យ៉ាងណាមួយដែរ ជាពិសេសមិនបានលើកយកចំណុចដទៃមកកាត់បទទេ ។ ទោះបីជាយ៉ាងណា រឿងរ៉ាវនៅក្នុងសមុច្ចយក្ខន្ធកៈនេះ ក៏ជាការរួបរួមវិធីបដិបត្តិក្នុងការចេញចាកអាបត្តិសង្ឃាទិសេសដែលមានភាពសាំញ៉ាំ ព្រមទាំងសំដែងបាលីសម្រាប់សូត្រប្រកាសទុកយ៉ាងពិស្ដារ) ។

## ៥.សមថក្ខន្ធកៈ (ពោលអំពីវិធីរម្ងាប់អធិករណ៍)[៧៤]

ភិក្ខុឆព្វគ្គិយ (ពួកលោកដែលមានគ្នា ៦ រូប) ធ្វើកម្មបែបដាក់ទោសដល់ភិក្ខុទាំងឡាយ ដែលមិនបាននៅចំពោះមុខ (ជាការធ្វើកំបាំងមុខ) គឺតជ្ជនីយកម្មខ្វះ, និយសកម្មខ្វះ, បព្វាជនីយកម្មខ្វះ, បដិសារណីយកម្មខ្វះ, ឧក្ខេបនីយកម្មខ្វះ ។ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តព្រះវិន័យ ហាមដាក់ទោសក្នុងទីកំបាំងមុខ ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកប្រព្រឹត្តល្មើស ។

## ១.សម្មុខាវិន័យ (ការរម្ងាប់ចំពោះមុខ)

ទ្រង់សំដែងអំពីពួកភិក្ខុមិនល្អ ៣ ប្រភេទគឺ ១.បុគ្គល (តែមួយរូប) ២.បុគ្គលច្រើនរូប ៣.សង្ឃ (៤ រូបឡើងទៅ) ដែលនិយាយមិនប្រកបដោយធម៌ រួចហើយទ្រង់សំដែងអំពីពួកភិក្ខុល្អ ៣ ប្រភេទគឺ ១.បុគ្គល (តែមួយរូប) ២.បុគ្គលច្រើនរូប ៣.សង្ឃ (៤ រូបឡើងទៅ) ដែលនិយាយប្រកបដោយធម៌ ។

ពួកភិក្ខុដែលនិយាយមិនប្រកបដោយធម៌ ទោះបីរម្ងាប់រឿងដែលកើតឡើងនៅក្នុងទីចំពោះមុខ ក៏ហៅថា សម្មុខាវិន័យប្លម និងរម្ងាប់មិនក្រុបកដោយធម៌ ។ ចំណែកឯភិក្ខុដែលនិយាយប្រកបដោយធម៌ រម្ងាប់រឿងដែលកើតឡើង ហៅថា សម្មុខាវិន័យ និងរម្ងាប់ប្រកបដោយធម៌ ។

## ព្រះទព្វមល្លបុត្រធ្វើការខារសង្ឃ

ព្រះទព្វមល្លបុត្រ បានសម្រេចព្រះអរហត្តផលតាំងអំពីអាយុនៅតិច លោកប្រាថ្នាធ្វើប្រយោជន៍ដល់សង្ឃ ទើបទៅគាល់ព្រះមានព្រះភាគសុំទទួលនាទីជាអ្នករៀបចំសេនាសនៈ (ទីស្នាក់នៅ) និងសំដែងភត្ត (ចាត់ភិក្ខុឲ្យទៅឆាន់ក្នុងទីនិមន្ត) ។ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថាប្រពៃ ទើបត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ សុំមតិសូត្រប្រកាស តែងតាំងព្រះទព្វមល្លបុត្រ ជាអ្នករៀបចំសេនាសនៈ

[៧៤] អធិករណ៍ គឺរឿងដែលកើតឡើងហើយ ត្រូវរៀបចំធ្វើ ចែកចេញជា ៤ យ៉ាង ដូចមានសម្ដែងទុកនៅក្នុងពួកនេះ ព្រមទាំងមានព្រះពុទ្ធភាសិតអធិប្បាយទុកផងដែរ ។

(សេនាសនគ្គាហាបកៈ) និងអ្នកសំដែងភត្ត (ភត្តុទ្ទេសក៍) នៅពេលមិនមានអ្នកជំទាស់ ទើបប្រកាសតែងតាំង ។ កាលបើបានទទួលការតែងតាំងហើយប្រាកដថារៀបចំសេនាសនៈបានល្អ និងមានសណ្ដាប់ធ្នាប់ ទោះបីមានភិក្ខុមកភ្លែងឲ្យចាត់សេនាសនៈនៅក្នុងទីផ្សេងៗ ដែលមានរយៈឆ្ងាយពីគ្នាយ៉ាងណា ដើម្បីមើលសេចក្ដីអង់អាចរបស់លោកក៏ដោយ ក៏លោកនៅតែមានការចាត់ចែងសេនាសនៈបានល្អ គួរជាទីអស្ចារ្យ ។

ចំណែកឯការចាត់ភិក្ខុទៅឆាន់ក៏ធ្វើបានល្អ តែមានភិក្ខុពួកមួយដែលជាបក្សពួកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិនពេញចិត្តថា ខ្លួនមិនដែលបានទទួលអាហារល្អៗ (ការពិតព្រោះពួកលោកសុទ្ធតែជាភិក្ខុបួសថ្មី ទើបគេមិនសូវយកចិត្តទុកដាក់ប្រគេនអាហារល្អៗ ដូចភិក្ខុដទៃ) ។ ពួកភិក្ខុនោះយល់ខុសថា ព្រះទព្វមល្លបុត្រភ្លែងធ្វើ ទើបរកលេសឲ្យនាងមេត្តិយាភិក្ខុនីចោទប្រកាន់លោកថា បានចាប់រំលោភនាង ។ កាលបើសាកសួរដឹងការពិតហើយ ទើបភិក្ខុទាំងឡាយឲ្យមេត្តិយាភិក្ខុនីសឹកចេញ ទោះបីមានការទទួលសារភាពកំហុសអំពីភិក្ខុអ្នកបង្ករឿងក៏ដោយ ក៏ពុំមានការបន្ធូរបន្ថយដែរ ។

## ២.សតិវិន័យ

### (ការរម្ងាប់ដោយការលើកឱ្យជាអ្នកមានសតិ)

ព្រះមានព្រះភាគ ទ្រង់ណែនាំវិធីរម្ងាប់អធិករណ៍ប្រភេទនេះដែលកើតមានឡើងដល់ព្រះអរហន្ត ឲ្យសង្ឃសូត្រប្រកាសឲ្យសតិវិន័យដល់ព្រះទព្វមល្លបុត្រ រួចហើយទ្រង់សំដែងលក្ខណ្ឌ ៥ ប្រការ ក្នុងការឲ្យសតិវិន័យគឺ

១.ភិក្ខុដែលជាដើមចោទ ជាអ្នកបរិសុទ្ធិ មិនមានអាបត្តិ

២.មានអ្នកប្ដឹងដល់លោក

៣.លោកសុំសតិវិន័យ

៤.សង្ឃឲ្យសតិវិន័យដល់លោក

៥.សង្ឃព្រមព្រៀងគ្នាឲ្យដោយធម៌ យ៉ាងនេះ ទើបហៅថាការឲ្យសតិវិន័យដែលជាធម៌ ។

## ៣.អមូឡ្ហវិន័យ

### (ការរម្ងាប់ដោយកំណត់ថាជាមនុស្សឆ្កួត)

គគ្គភិក្ខុជាមនុស្សឆ្កួត បានធ្វើខុសជាច្រើនរឿង មានអ្នកប្ដឹងតវ៉ា ទើបព្រះមានព្រះភាគទ្រង់ណែនាំឲ្យរម្ងាប់ដោយអមូឡ្ហវិន័យ ដោយឲ្យអ្នកប្ដឹង (ស្ងប់រម្ងាប់ហើយ) សុំអមូឡ្ហវិន័យ និងឲ្យសង្ឃ សូត្រប្រកាសឲ្យអមូឡ្ហវិន័យ ជាការរម្ងាប់ដោយលើកឲ្យថាជាមនុស្សឆ្កួតក្នុងខណៈធ្វើខុស ។ ប៉ុន្តែទ្រង់ដាក់លក្ខណ្ឌថា បើធ្វើ

ខុសក្នុងខណៈពេលដែលដឹងខ្លួន ឬដឹងខ្លួនដូចយល់សប្តិ៍ ឬរកលេស ដោយអាងថាជាមនុស្សឆ្កួត សង្ឃឲ្យអមូឡ្ហវិន័យដល់លោក ដូច្នេះ ហៅថា មិនប្រកបដោយធម៌ ប្រសិនបើផ្ទុយគ្នា គឺធ្វើទៅក្នុងខណៈ ពេលកំពុងឆ្កួតមិនដឹងខ្លួនពិតមែន ទើបការឲ្យអមូឡ្ហវិន័យ ប្រកប ដោយធម៌ ។

## ៤.បដិញ្ញាតករណៈ (ការរម្ងាប់ដោយពាក្យសារភាព)

ភិក្ខុឆព្វគ្គិយដាក់កម្មដល់ភិក្ខុទាំងឡាយ ដោយមិនស្តាប់ពាក្យ សារភាពរបស់ភិក្ខុទាំងនោះ មានគេតិះដៀល ។ ទើបព្រះមាន ព្រះភាគទ្រង់បញ្ញត្តព្រះវិន័យហាមធ្វើដូច្នោះ បើនៅតែល្មើស ត្រូវ អាបត្តិទុក្កដ ។

ទើបទ្រង់សំដែងវិធីរម្ងាប់អធិករណ៍ ដោយការទទួលសារភាព របស់ចុងចោទដែលមិនប្រកបដោយធម៌ និងប្រកបដោយធម៌ ។ មិនប្រកបដោយធម៌ គឺសារភាពខុសពីការពិត ដូចជា ត្រូវអាបត្តិ ធ្ងន់ សារភាពថាត្រូវអាបត្តិរងបន្ទាប់ ឬត្រូវអាបត្តិស្រាល សារ-ភាពថាត្រូវអាបត្តិធ្ងន់ ។ ចំណែកឯប្រកបដោយធម៌ គឺត្រូវអាបត្តិ ណា ក៏សារភាពថាត្រូវអាបត្តិនោះមែន ។

## ៥.យេភុយ្យសិកា (ការរម្ងាប់ដោយសំឡេងច្រើន)

ភិក្ខុទាំងឡាយមានទំនាស់នឹងគ្នា ទើបព្រះមានព្រះភាគទ្រង់ អនុញ្ញាត ឲ្យរម្ងាប់អធិករណ៍ប្រភេទនេះ ដោយកាន់យកសំឡេង ភាគច្រើន ឲ្យសន្មត់ភិក្ខុអ្នកចែកស្លាក (ពាក្យថា ស្លាក ប្រែថា ចំរៀកឈើសម្រាប់ឲ្យពិន្ទុ) ភិក្ខុអ្នកចែកស្លាកត្រូវប្រកបដោយអង្គ ៥ គឺមិនលំអៀងព្រោះស្រឡាញ់, ព្រោះស្អប់, ព្រោះវង្វេង, ព្រោះខ្លាច ហើយនិងដឹងថា យ៉ាងណាបានចាប់ យ៉ាងណានៅមិន ទាន់បានចាប់ (ឃ្លាំមើលការឲ្យពិន្ទុបានល្អ) រួចហើយឲ្យសូត្រ ប្រកាសតែងតាំងភិក្ខុអ្នកចែកស្លាកជាការងាររបស់សង្ឃ ។

បន្ទាប់មកទ្រង់សំដែងការចាប់ស្លាក (ឲ្យពិន្ទុ) ដែលមិន ប្រកបដោយធម៌ និងប្រកបដោយធម៌ មួយមុខ ១០ ប្រការ គឺ

១.គ្រាន់តែជារឿងតូចតាច
២.មិនរាលដាលទៅកាន់វត្តដទៃ
៣. មិនត្រូវគិតហើយគិតទៀត
៤.ដឹងថាអ្នកពោលមិនប្រកបដោយធម៌ ច្រើនជាង
៥.ដឹងថាអ្នកពោលមិនប្រកបដោយធម៌ អាចមានច្រើនជាង
៦.ដឹងថាសង្ឃបែកគ្នា (បើនៅតែសុំមតិ)
៧.ដឹងថាសង្ឃអាចបែកគ្នា
៨.ចាប់ស្លាកមិនប្រកបដោយធម៌

៩.ចាប់ស្លាកជាក្រុម (មិនចាប់ម្ដងមួយ)

១០.មិនបានចាប់ស្លាកតាមការយល់ឃើញរបស់ខ្លួន យ៉ាងនេះហៅថា មិនប្រកបដោយធម៌ ។ ចំណែកឯប្រកបដោយធម៌ គឺផ្ទុយគ្នា ។

## ៦.តស្សបាបិយសិកា (ការរម្ងាប់ដោយការដាក់ទោស)

ឧបវាឡភិក្ខុ ត្រូវបានគេប្ដឹងអំពីរឿងត្រូវអាបត្តិនៅក្នុងទីជំនុំសង្ឃ បដិសេធហើយត្រឡប់ទទួលសារភាព១ហើយត្រឡប់បដិសេធ ផ្ដល់ចម្លើយច្របូកច្របល់ ពោលកុហកទាំងដឹងខ្លួន ។ ទើបព្រះមានព្រះភាគទ្រង់ណែនាំឲ្យសង្ឃប្រើវិធីតស្សបាបិយសិកា គឺឲ្យសូត្រប្រកាសជាការផ្ទេរសង្ឃដាក់ទោសចុងចោទ (តាមសមគួរដល់អាបត្តិ) ។

ទ្រង់សំដែងការធ្វើតស្សបាបិយសិកាកម្ម ដែលប្រកបដោយធម៌ថា ប្រកបដោយអង្គ ៥ គឺ

១.ភិក្ខុមិនបរិសុទ្ធិ

២.ជាអ្នកមិនខ្មាស់បាប

៣.មានអ្នកប្ដឹង

៤.សង្ឃធ្វើតស្សបាបិយសិកាកម្ម (ដាក់ទោស) ដល់លោក

៥.សង្ឃព្រមព្រៀងដាក់ទោសប្រកបដោយធម៌ ។

ម្យ៉ាងទៀត ទ្រង់សំដែងលក្ខណៈនៃការធ្វើកម្មប្រភេទនេះ ដែលប្រកបដោយធម៌ និងមិនប្រកបដោយធម៌ តាមដែលទ្រង់សំដែងទុកនៅក្នុងរឿងតជ្ជនីយកម្ម, ទ្រង់សំដែងលក្ខណៈដែលសង្ឃគួរដាក់ទោសប្រភេទនេះ និងការវិនាសសិទ្ធិនៃភិក្ខុដែលត្រូវទោសប្រភេទនេះ ដូចតជ្ជនីយកម្មដែរ ។

## ៧.តិណវត្ថារកៈ (ការរម្ងាប់ដោយការលើកលែង)

ភិក្ខុទាំងឡាយទាស់ទែងគ្នា និងយល់ថា បើនៅតែទាស់គ្នាតទៅ រឿងកាន់តែធ្ងន់ទៅរហូតដល់ថ្នាក់បែកគ្នា ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យរម្ងាប់អធិករណ៍ប្រភេទនេះ ដោយឲ្យលើកលែងទោសគ្នាទៅវិញទៅមក (តិណវត្ថារកៈ) ។

ទ្រង់សំដែងវិធីសូត្រប្រកាសសុំមតិក្នុងទីជំនុំសង្ឃ ឲ្យផុតចាកអាបត្តិទាំងពីរពួក ដោយមានតំណាងភិក្ខុទាំងពីរពួក មួយពួកមួយរូបដែលស្នើញត្តិនោះ ជាអ្នកសំដែងជំនួស លើកលែងអាបត្តិធ្ងន់, លើកលែងអាបត្តិដែលទាក់ទងជាមួយនឹងគ្រហស្ថ, លើកលែងអ្នកសំដែងការយល់ឃើញប្រដែង, លើកលែងអ្នកដែលមិនបានប្រជុំនៅក្នុងទីនោះ (គឺមានអ្នកខកខានប្រជុំ) ។

# អធិករណ៍ ៤

អធិករណ៍មាន ៤ គឺ

១.វិវាទាធិករណ៍ ការវិវាទគ្នា នៅក្នុងរឿងដែលទាក់ទងទៅនឹងព្រះធម៌វិន័យ ។

២.អនុវាទាធិករណ៍ ការប្តឹងចោទដោយសីលវិបត្តិជាដើម

៣.អាបត្តាធិករណ៍ ការត្រូវអាបត្តិ

៤.កិច្ចាធិករណ៍ រឿងដែលសង្ឃត្រូវរៀបចំធ្វើសង្ឃកម្ម ។

បន្ទាប់មកទ្រង់សំដែងលក្ខណៈនៃអធិករណ៍នីមួយៗ ព្រមទាំងមូលហេតុដោយពិស្តារ នៅទីបំផុតទ្រង់សរុបថា អធិករណ៍នីមួយៗ ត្រូវរម្ងាប់ដោយសមថៈ (វិធីរម្ងាប់) អ្វីខ្លះ ដូច្នេះ៖

១.វិវាទាធិករណ៍ ការទំនាស់គ្នាក្នុងរឿងព្រះធម៌វិន័យ ត្រូវរម្ងាប់ដោយវិធី ២ ប្រការ គឺ

ក) រម្ងាប់នៅក្នុងទីចំពោះមុខ (សម្មុខាវិន័យ)

ខ) រម្ងាប់ដោយកាន់យកសំឡេងខាងច្រើន ជាប្រមាណ (យេភុយ្យសិកា) ។

២.អនុវាទាធិករណ៍ ការប្តឹងចោទដោយសីលវិបត្តិ (សេចក្តីវិនាសទាក់ទងទៅនឹងសីល) អាចារវិបត្តិ (សេចក្តីវិនាសទាក់ទងទៅនឹងការប្រព្រឹត្ត) ទិដ្ឋិវិបត្តិ (សេចក្តីវិនាសទាក់ទងនឹងការយល់ឃើញ) និងអាជីវវិបត្តិ (សេចក្តីវិនាសទាក់ទងទៅនឹងការចិញ្ចឹមជីវិត) ។ រម្ងាប់ដោយវិធី ៤ ប្រការ គឺ

១.រម្ងាប់នៅក្នុងទីចំពោះមុខ (សម្មុខាវិន័យ)

២.រម្ងាប់ដោយលើកឲ្យថាមានសតិ (សតិវិន័យ)

៣.រម្ងាប់ដោយលើកឲ្យថាជាមនុស្សឆ្កួត (អមូឡ្ហវិន័យ)

៤.រម្ងាប់ដោយការដាក់ទោស (តស្សបាបិយសិកា) ។

៣.អាបត្តាធិករណ៍ ការត្រូវអាបត្តិផ្សេងៗ រម្ងាប់ដោយវិធី ៣ ប្រការ គឺ

ក) រម្ងាប់នៅក្នុងទីចំពោះមុខ (សម្មុខាវិន័យ)

ខ) រម្ងាប់ដោយកាន់យកពាក្យសារភាព (បដិញ្ញាតករណៈ)

គ) រម្ងាប់ដោយឲ្យលើកលែងទោសដល់គ្នា(តិណវត្ថារកៈ) ។

ឃ) កិច្ចាធិករណ៍ រឿងដែលសង្ឃត្រូវធ្វើការងារសង្ឃ រម្ងាប់ដោយវិធីតែមួយ គឺរម្ងាប់នៅក្នុងទីចំពោះមុខ (សម្មុខាវិន័យ) ។

ទ្រង់ពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុ ដែលសើរើអធិករណ៍ដែលសង្ឃជម្រះរួចហើយ និងពិន័យអាបត្តិបាចិត្តិយដល់ភិក្ខុអ្នកឲ្យឆន្ទៈហើយតិះដៀលជាខាងក្រោយ (លើកលែងអធិករណ៍នោះជម្រះមិនប្រកបដោយធម៌)[៧៥] ។

---

[៧៥] សិក្ខាបទទី ៣ និងសិក្ខាបទទី ៩ ។

# ភាគទី ១០

## ចុល្លវគ្គ (ជាវិនយបិដក)

អធិប្បាយរួចមកហើយថា ចុល្លវគ្គមាន ៣ ក្បាល គឺក្បាលទី ៩ ដែលសង្ខេបរួចមកហើយមាន ៣ ពួក ឬ ៣ ខន្ធកៈ នៅក្នុងក្បាលទី ១០ មាន ៣ ពួក ឬ ៣ ខន្ធកៈ នៅក្នុងក្បាលទី ១១ មាន ៦ ពួក ឬ ៦ ខន្ធកៈ ដូចតទៅនេះ ៖

**១.ខុទ្ទកវត្ថុខន្ធកៈ** (ពោលអំពីរឿងតូចៗ ខ្ចីៗ) នៅក្នុងពួកនេះជារឿងរាត់រាយ ដូចជាឧបដិបត្តិនៅក្នុងពេលងូតទឹក, ការមើលមហោស្រព, បទហាមឃាត់ និងអនុញ្ញាតទាក់ទងទៅនឹងរឿងបាត្រជាដើម រហូតដល់ឧបករណ៍ប្រើប្រាស់ដែលធ្វើអំពីលោហៈ, ធ្វើអំពីឈើ និងធ្វើអំពីដីស្អិត ។

**២.សេនាសនក្ខន្ធកៈ** (ពោលអំពីទីលំនៅ) នៅក្នុងពួកនេះពោលដល់ទីស្នាក់អាស្រ័យនៅ, គ្រឿងប្រើប្រាស់ ដូចជា គ្រែតាំង, កម្រាលអង្គុយ និងដេក, គ្រឿងប្រើប្រាស់ជាប្រចាំនៅក្នុងទីលំនៅ រហូតដល់ការកសាងជាដើម ។

**៣.សង្ឃភេទក្ខន្ធកៈ** (ពួកពោលអំពីសង្ឃបែកគ្នា) និយាយពីរឿងទេវទត្តគិតនឹងប្រទូសរ៉ាយព្រះពុទ្ធជាម្ចាស់ ប៉ុន្តែមិនសម្រេចរហូតដល់ហេតុការណ៍ដែលធ្វើឲ្យព្រះទេវទត្តធ្លាក់ឈាម និងរឿងដែលធ្វើឲ្យសង្ឃបែកគ្នា ព្រមទាំងខកំណត់ផ្សេងៗទាក់ទងទៅនឹងការបែកបាក់គ្នានៃសង្ឃ ។

**៤.វត្តក្ខន្ធកៈ** (ពោលអំពីវត្ត ឬឧបដិបត្តិ) និយាយអំពីវត្ត ឬឧបដិបត្តិផ្សេងៗ ១៣ រឿង គឺឧបដិបត្តិនៃភិក្ខុអាគន្តុកៈ, ឧបដិបត្តិនៃភិក្ខុម្ចាស់វត្ត, ឧបដិបត្តិនៃភិក្ខុអ្នកធ្វើដំណើរតាមផ្លូវ, ឧបដិបត្តិនៅក្នុងរោងអាហារ, ឧបដិបត្តិនៃភិក្ខុអ្នកបិណ្ឌបាត, ឧបដិបត្តិនៃភិក្ខុអ្នកនៅព្រៃ, ឧបដិបត្តិទាក់ទងទៅនឹងទីស្នាក់អាស្រ័យ, ឧបដិបត្តិនៅក្នុងផ្ទះភ្លើង, ឧបដិបត្តិទាក់ទងទៅនឹងវច្ចកុដិ (បង្គន់), ឧបដិបត្តិចំពោះឧបជ្ឈាយ៍, ឧបដិបត្តិចំពោះសទ្ធិវិហារិក, ឧបដិបត្តិចំពោះអាចារ្យ, ឧបដិបត្តិចំពោះអន្តេវាសិក ។

**៥.បាដិមោក្ខឋបនក្ខន្ធកៈ** (ពោលអំពីការលើក ឬឈប់សូត្របាដិមោក្ខ) និយាយពីការឈប់សូត្របាដិមោក្ខ ព្រោះមានភិក្ខុមិនបរិសុទ្ធិនៅលាយឡំ ព្រមទាំងលក្ខខណ្ឌជាច្រើនទៀត ។

**៦.ភិក្ខុនីខន្ធកៈ** (ពោលអំពីភិក្ខុនី) និយាយអំពីប្រវត្តិរឿងរ៉ាវនៃភិក្ខុនី និងឧបដិបត្តិ ខហាមឃាត់ ខអនុញ្ញាតផ្សេងៗដែលទាក់ទងជាមួយនឹងភិក្ខុនី ។

**៧.បញ្ចសតិកខន្ធកៈ** *(ពោលអំពីព្រះអរហន្ត ៥០០ អង្គ ដែលកំពុងធ្វើសង្គាយនាលើកទី ១) រៀបរាប់អំពីហេតុការណ៍ក្រោយពីព្រះពុទ្ធបរិនិព្វានរហូតដល់ការធ្វើសង្គាយនាលើកទី ១ ចប់ ។*

**៨.សត្តសតិកខន្ធកៈ** *(ពោលអំពីព្រះអរហន្ត ៧០០ អង្គ ធ្វើសង្គាយនាលើកទី ២) រៀបរាប់អំពីមូលហេតុ និងកិច្ចដំណើរការនៃការធ្វើសង្គាយនាលើកទី ២ ។*

## សេចក្ដីអធិប្បាយ

### ១.ខុទ្ទកវត្ថុខន្ធកៈ (ពោលអំពីរឿងតូចៗ ខ្លីៗ)

### រឿងងូតទឹក

*ទ្រង់ប្រារព្ធរឿងការប្រព្រឹត្តនៃឆព្វគ្គិយភិក្ខុ ដែលមានគេតិះដៀល ទើបត្រាស់ហាមមិនឲ្យភិក្ខុយកកាយត្រដុសនឹងដើមឈើ, ត្រដុសនឹងសសរ, ត្រដុសនឹងជញ្ជាំងក្នុងពេលងូតទឹក ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកប្រព្រឹត្តល្មើស (ព្រោះមានអ្នកស្រុកតិះដៀលថាធ្វើដូចអ្នកប្រដាល់ចំបាប់) ។*

*ទ្រង់ហាមងូតទឹកយកកាយត្រដុសនឹងផែនក្ដារ (ដែលគេធ្វើរាងជាក្រឡាអុក រួចយកសាប៊ូរោយពីលើដុសកាយ) ។ ម្យ៉ាងទៀត ទ្រង់ហាមប្រើគ្រឿងដុសកាយដោយវត្ថុមិនគួរ ដូចជាឈើធ្វើជារូបដៃ ឬធ្មេញនាគ និងវេញខ្សែចងយកខ្នងនិងខ្នងត្រដុសគ្នាក៏ទ្រង់ហាម ទ្រង់ពិន័យអាបត្តិទុក្កដ ដល់អ្នកដែលប្រព្រឹត្តល្មើស (ព្រោះមានគេតិះដៀលថាធ្វើដូចគ្រហស្ថអ្នកបរិភោគកាមគុណ) ។ ទ្រង់អនុញ្ញាតឲ្យប្រើឈើមិនធ្វើជាចំរៀក និងឲ្យវេញសំពត់ ឬបាតដៃដុសខ្លួនបាន) ។*

### ហាមប្រើគ្រឿងប្រដាប់ដូចគ្រហស្ថ

*ទ្រង់ហាមការប្រដាប់កាយដោយក្រវិល, ខ្សែសង្វារ, ខ្សែក, ខ្សែចង្កេះ, ខ្សែក្រវ៉ាត់, កងពាក់ដើមដៃ, កងដៃ និងចិញ្ចៀន ។ ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកធ្វើដូចនោះ ។*

### បទហាមប្រាមទាក់ទងទៅនឹងសក់

*ទ្រង់ហាមទុកសក់លើស ២ ខែ ឬទុកសក់វែងលើស ២ ធ្នាប់ ។ ម្យ៉ាងទៀត ទ្រង់ហាមប្រើច្រាស់, ប្រើក្រាស់, ប្រើដៃច្បូតសក់, ប្រើប្រេង ឬប្រេងលាយទឹកលាបសក់ ដែលមានសភាពដូចជាគ្រហស្ថបរិភោគកាម ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកធ្វើដូច្នោះ ។*

### បទហាមប្រាមទាក់ទងទៅនឹងការឆ្លុះកញ្ចក់

ទ្រង់ហាមផ្ទុះស្រមោលខ្លួនឯងនៅក្នុងកញ្ចក់ ឬនៅក្នុងភាជនៈទឹក (ព្រោះអ្នកស្រុកគិះដៀលថាធ្វើដូចគ្រហស្ថបរិភោគកាម) មានហេតុសមគួរ ដូចជាកើតដំបៅនៅលើផ្ទៃមុខ ទ្រង់អនុញ្ញាត ឲ្យមើលបាន ។

## ហាមលាបមុខលាបខ្លួន

ទ្រង់ហាមផាត់មុខ, រឹមុខ (ប្រើផង់ម្សៅលាយទឹកយកមករឹលើផ្ទៃមុខឲ្យស្មើ), លាបមុខ (ដូចជាលាបម្សៅ) ប៉ះចិញ្ចើម អប់ខ្លួន, អប់ទាំងខ្លួនទាំងមុខ ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកធ្វើដូចនោះ ។ ប្រើផង់ម្សៅផាត់មុខ ដើម្បីរក្សារោគបាន (នៅក្នុងរឿងពោលថា **រក្ខារោគតា** ផង់នោះគង់ផ្សំជាមួយថ្នាំយ៉ាងណាមួយ) ។

## ហាមមើលការរាំរែក និងច្រៀងដោយសម្លេងវែង

ទ្រង់ហាមទៅមើលការរាំច្រៀង ហាមច្រៀង (ស្វូត) ធម៌ដោយសម្លេងវែង ទ្រង់សំដែងទោស ៥ ប្រការ, ប៉ុន្តែទ្រង់អនុញ្ញាតឲ្យសូត្រសរភញ្ញៈ (សូត្រធ្វើសម្លេងមិនឲ្យខូចសមណសារូប) ។

## ហាមប្រើសំពត់រោមចៀម

ទ្រង់ហាមប្រើសំពត់រោមចៀម ដែលមានរោមនៅខាងក្រៅដូចគ្រហស្ថគេប្រើ ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកប្រព្រឹត្តល្មើស ។

## បទហាមប្រាម និងអនុញ្ញាតទាក់ទងទៅនឹងផ្លែឈើ

ទ្រង់ហាមឆាន់ផ្លែស្វាយ ព្រោះឆព្វគ្គិយភិក្ខុឲ្យគេដោលទម្លាក់ផ្លែស្វាយនៅក្នុងព្រះរាជឧទ្យានរបស់ព្រះបាទពិម្ពិសារ ដែលទ្រង់អនុញ្ញាតឲ្យភិក្ខុសង្ឃឆាន់ផ្លែស្វាយបាន រហូតដល់ទ្រង់រកសោយខ្លួនព្រះអង្គឯងមិនបាន ។ ចំរៀកសម្បកស្វាយដាក់សម្ល អនុញ្ញាតឲ្យឆាន់បាន ។ នៅទីបំផុតទ្រង់អនុញ្ញាតឲ្យឆាន់ផ្លែឈើបានគ្រប់ប្រភេទបើជារបស់សមគួរដល់សមណៈ ៥ យ៉ាង គឺយកភ្លើងរោល, យកកាំបិតឆ្កូត, យកក្រចកបោះ (សំដៅយកអ្នកដទៃធ្វើឲ្យ), ផ្លែឈើដែលមិនមានគ្រាប់, ផ្លែឈើដែលបកសម្បកចេញហើយ (ការឆាន់ផ្លែឈើនៅក្នុងសម័យពុទ្ធកាល ដែលអនុញ្ញាតដូច្នេះ ដើម្បីរក្សាប្រពៃណីថា អ្នកបួសមិនគួរទម្លាយពូជ តាមការនិយម របស់មនុស្សនាសម័យនោះទេ ទើបត្រូវមានខកំណត់ធ្វើ ឲ្យគួរជាមុនសិន) ។

## ទ្រង់ត្រាស់ឱ្យផ្សាយមេត្តា

ភិក្ខុត្រូវពស់ចឹករហូតដល់ធ្វើមរណកាល ទើបទ្រង់ត្រាស់ឲ្យផ្សាយមេត្តាដល់ត្រកូលពស់ទាំងបួន ព្រមទាំងពពួកសត្វទាំងឡាយ

ដែលមានជើង ២ ជើង ៤ មានជើងច្រើន ឬមិនមានជើង សូមឲ្យសត្វទាំងអស់នោះជួបតែសំណាងល្អ ។

## ហាមកាត់អង្គជាត

ភិក្ខុមួយរូបកើតតម្រេក ទើបកាត់អង្គជាតចោល ព្រះមានព្រះភាគទ្រង់តិះដៀល និងទ្រង់បញ្ញត្តព្រះវិន័យហាមកាត់អង្គជាត, បើកាត់ត្រូវអាបត្តិថុល្លច្ច័យ ។

## ខហាមប្រាម និងអនុញ្ញាតទាក់ទងទៅនឹងរឿងបាត្រ

ទ្រង់ប្រារព្ធព្រះបិណ្ឌោលភារទ្វាជៈ ដែលបានបាត្រខ្លឹមចន្ទន៍មក ព្រោះសំដែងអំណាចចិត្តទៅលើម្ចាស់លទ្ធិទាំង ៦ ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបបញ្ញត្តិព្រះវិន័យហាមសំដែងឥទ្ធិបាដិហារ្យដល់គ្រហស្ថ, បើសំដែងត្រូវអាបត្តិទុក្កដ ។ម្យ៉ាងទៀត ទ្រង់បញ្ជាឲ្យបំផ្លាញបាត្រខ្លឹមចន្ទន៍នោះចោល ដើម្បីប្រើជាប្រយោជន៍ដទៃដូចជា បុកធ្វើជាថ្នាំបន្តក់ភ្នែក រួចត្រាស់ហាមប្រើបាត្រឈើ និងពិន័យអាបត្តិទុក្កដដល់អ្នកប្រើ ។

ម្យ៉ាងទៀត ទ្រង់ហាមប្រើបាត្រដែលធ្វើដោយមាស, ប្រាក់, កែវមណី, កែវពិទូរ្យ, កែវផលិ្ទក, សំរិទ្ធិ, កែវ, សំណ, សង្កសី, ទង់ដែង (រួមទាំងបាត្រឈើផង ត្រូវជា ១១) ។ ទ្រង់អនុញ្ញាតបាត្រ ២ ប្រភេទ គឺបាត្រដែក និងបាត្រដី ។

ទ្រង់អនុញ្ញាតឲ្យប្រើជើងបាត្រ (ដើម្បីការពារបាត្រមិនឲ្យខូចពណ៌) ប៉ុន្តែមិនអនុញ្ញាតជើងបាត្រដែលធ្វើអំពីមាស ប្រាក់ ឬវិចិត្រផ្សេងៗ ទ្រង់អនុញ្ញាតធ្វើអំពីសំណ ឬសង្កសី ។

ទ្រង់ហាមទុកបាត្រទាំងទទឹក ទ្រង់អនុញ្ញាតឲ្យសំដិលថ្ងៃ ឬជូតឲ្យស្ងួត សំដិលរួចហើយទើបយកទុក ទ្រង់ហាមទុកបាត្រហាលថ្ងៃ ទ្រង់អនុញ្ញាតឲ្យសំដិលថ្ងៃមួយស្របក់ហើយ ទើបយកទុក ។

ទ្រង់អនុញ្ញាតទីតម្កល់បាត្រ ដើម្បីការពារមិនឲ្យខ្យល់បក់រមៀលធ្លាក់បែក ទ្រង់ហាមទុកបាត្រលើភ្នាក់ លើបន្ទះក្តារខាងក្រៅភ្នាក់ ទ្រង់អនុញ្ញាតវត្ថុសម្រាប់តម្កល់បាត្រវេលាផ្កាប់បាត្រ (មិនឲ្យមាត់បាត្រកោសផ្ទាល់នឹងផ្ទៃ) ដែលធ្វើអំពីស្មៅ ឬសំពត់ក៏បាន ។

ទ្រង់អនុញ្ញាតធ្នាក់ទុកបាត្រ (ដើម្បីការពារសត្វកណ្តៀរឡើងសំពត់ ឬក្រណាត់ដែលទ្របាត្រ), ទ្រង់អនុញ្ញាតភាជនៈមាត់ធំសម្រាប់ដាក់បាត្រ (ដើម្បីការពារបាត្ររមៀលធ្លាក់អំពីធ្នាក់), ទ្រង់អនុញ្ញាតស្រោមបាត្រ (ដើម្បីការពារមិនឲ្យបាត្រត្រគោះនឹងភាជនៈសម្រាប់ទុក), ទ្រង់ហាមព្យួរបាត្រទុកនឹងជញ្ជាំង, ទ្រង់ហាមទុកបាត្រលើគ្រែ, លើតាំង, លើភ្លៅ, លើឆត្រ (ដើម្បីការពារធ្លាក់បែក),

ម្យ៉ាងទៀត ទ្រង់ហាមបើកទ្វារនៅពេលកំពុងកាន់បាត្រ និងហាមប្រើខ្ទះដី, ត្រឡោកឃ្លោក, ត្រឡោកក្បាលខ្មោចមកធ្វើជាបាត្រផ្សេងៗ ក្រៅអំពីនោះ ទ្រង់ក៏នៅមានការហាមចោលកាកសំណល់អាហារ, ឆ្អឹងសត្វ និងសំណល់ទឹក ដូចជា ទឹកខ្ពុរមាត់ចូលទៅក្នុងបាត្រ ។

## ទ្រង់អនុញ្ញាតកាំបិត និង ម្ជុល

បន្ទាប់ពីនោះមក រៀបរាប់អំពីទ្រង់អនុញ្ញាតកាំបិតសម្រាប់កាត់សំពត់ ព្រមទាំងអនុញ្ញាតស្រោមកាំបិត និងទ្រង់អនុញ្ញាតដងកាំបិត តែមិនអនុញ្ញាតដងដែលធ្វើអំពីមាស ប្រាក់ វិចិត្រ, ទ្រង់អនុញ្ញាតដងកាំបិតដែលធ្វើអំពីឆ្អឹង, ភ្លុក, ស្នែង, បបុស, ឫស្សី, ឈើ, ជ័រ, ផ្លែឈើ, លោហៈ និងសម្បកសង្ខ ។

ភិក្ខុសម័យនោះ ប្រើរោមមាន់ខ្លះ ចំរៀកឫស្សីខ្លះដេរចីវរ ស្រាប់តែប្រាកដថា មិនស្អាត ទើបទ្រង់អនុញ្ញាតម្ជុល និងដើម្បីការពារម្ជុលកើតស្នឹម ទ្រង់ក៏អនុញ្ញាតបំពង់ម្ជុល និងផង់ (និយមដាក់អង្កាំចូលទៅក្នុងបំពង់) ព្រមទាំងអនុញ្ញាតឲ្យសៀតម្ជុលទុកនៅក្នុងក្រមួន ។

## ទ្រង់អនុញ្ញាត និងហាម ចាក់ចងទៅនឹងឈើប្លង់ ឬឈើស្ដឹង

ទ្រង់អនុញ្ញាតឈើស្ដឹង និងខ្សែចងចីវរភ្ជាប់ទៅនឹងឈើស្ដឹង រួចហើយធ្វើការដេរប៉ាក់ ព្រមទាំងវិធីផ្សេងទៀតដើម្បីដេរបានល្អ ។

ទ្រង់ហាមជាន់ឈើស្ដឹងទាំងដែលនៅមិនទាន់លាងជើង សូម្បីជើងនៅសើមក៏ហាមជាន់លើ ព្រមទាំងហាមជាន់ពីលើទាំងដែលពាក់ស្បែកជើង ។

ទ្រង់អនុញ្ញាតស្រោមដៃ (ដើម្បីការពារមុតម្ជុលក្នុងខណៈដេរ) ប៉ុន្តែមិនអនុញ្ញាតស្រោមដៃដែលធ្វើអំពីមាសប្រាក់ ទ្រង់អនុញ្ញាត ដូចដងកាំបិតដែរ គឺដែលធ្វើអំពីឆ្អឹងជាដើម ។ ទ្រង់អនុញ្ញាតឧបករណ៍ ដាក់ម្ជុល កាំបិត និងស្រោមដៃ ព្រមទាំងថង់សម្រាប់ដាក់ស្រោមដៃ អំបោះសម្រាប់ពាក់ស្មា (វេលានាំឧបករណ៍ប្រើប្រាស់ទាំងនោះ ដាប់តាមខ្លួនទៅ) ។

ទ្រង់អនុញ្ញាតរោងដេរចីវរ (កឋិនសាលា) និងមណ្ឌបដេរចីវរ រួចហើយទ្រង់អនុញ្ញាតឲ្យលើកទំនប់ការពារទឹកលិច ទ្រង់អនុញ្ញាតឲ្យធ្វើដោយឥដ្ឋ, ថ្ម, ឬឈើ ទ្រង់អនុញ្ញាតឲ្យមានបង្កាន់ដៃ ឬរបង (សម្រាប់ស្ទូឡើង) ។

កម្ទេចស្មៅនៅក្នុងរោងដេរចីវរធ្លាក់ចុះមក (អំពីដម្បូល) ទើបទ្រង់អនុញ្ញាតឲ្យប្រើដែរណែង និងកំបោរបាយអ និងលាបពណ៌ជាដើម រហូតដល់ទ្រង់អនុញ្ញាតឲ្យមានក្រវិលពាក់ចីវរ និងស្នូចីវរ ។ ម្យ៉ាងទៀត នៅពេលធ្វើកឋិនរួចរាល់ហើយ ទ្រង់អនុញ្ញាត

ឲ្យទុកដាក់ឈើស្ដឹងឲ្យរៀបរយល្អ ដូចជា ឲ្យមានបុស្សី ឬបណ្ដូលឈើពីខាងក្នុងដើម្បីការពារឈើស្ដឹងបែកឬបាក់, ឲ្យមានខ្សែចង, ពាក់នឹងទំពក់ឬស្នួ (ដើម្បីការពារធ្លាក់បែក និងជាជាងទុកចោលអាចធ្លាក់ចុះបែក) ។

## ទ្រង់អនុញ្ញាតថង់ដាក់របស់របរ ថង់យាម តម្រងទឹក និងមុង

ទ្រង់អនុញ្ញាតថង់ដាក់ថ្នាំ ថង់ដាក់ស្បែកជើង និងថង់យាម, ទ្រង់អនុញ្ញាតឲ្យប្រើតម្រងទឹក, តម្រងមានដង និងបំពង់ត្រងទឹក ។ កាលបើភិក្ខុដទៃសុំប្រើតម្រងទឹក ភិក្ខុដទៃទៀតមិនឲ្យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើដំណើរផ្លូវឆ្ងាយ មិនមានតម្រងទឹក ត្រូវអាបត្តិទុក្កដ ។ បើមិនមានតម្រងទឹក ឬបំពង់ត្រងទឹក ឲ្យអធិដ្ឋានជាយសង្ឃាដីធ្វើជាតម្រងទឹក ។ ក្នុងការកសាង ទ្រង់អនុញ្ញាតឧបករណ៍ត្រងទឹកខ្នាតធំ ៧ ប្រភេទ រួចហើយទ្រង់អនុញ្ញាតមុងដើម្បីការពារមូស ។

## ទ្រង់អនុញ្ញាតការចង្ក្រម និងផ្ទះភ្លើងជាដើម

ទ្រង់ប្រារព្ធពាក្យណែនាំរបស់ហ្មជីវកកោមារភច្ច ទើបទ្រង់អនុញ្ញាតការចង្ក្រម (ដើរទៅដើរមកដើម្បីអប់រំចិត្តនិងបញ្ចេញកម្លាំងកាយ) និងផ្ទះភ្លើងសម្រាប់កម្ដៅកាយ (ឲ្យញើសចេញដូចងូតទឹកក្ដៅឧណ្ហៗ) ។ បន្ទាប់ពីនោះមក ទ្រង់អនុញ្ញាតឲ្យកែលម្អទីចង្ក្រមឲ្យប្រសើរឡើង មានទីចង្ក្រម និងលើកខឿនការពារទឹកចូល, ជណ្ដើរ និងបង្កាន់ដៃ ។ ចំណែកឯផ្ទះភ្លើង ទ្រង់អនុញ្ញាតចំណែកប្រកប និងឧបករណ៍លម្អផ្សេងៗ ដូចជា បំពង់ផ្សែង, ប្រឡាយបង្ហូរទឹកដើម្បីការពារទឹកដក់កខ្វក់ ។ ទ្រង់ហាមអាក្រាតកាយគោរពគ្នា ឬដុសខ្នងឲ្យគ្នា រហូតដល់ទ្រង់ហាមអាក្រាតកាយឲ្យរបស់របរ, ទទួល, ទំពា, បរិភោគ, ហុត, ផឹកទឹក, ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលប្រព្រឹត្តធ្វើដូច្នោះ ។

ទ្រង់ប្រារព្ធការផឹកទឹក ទើបទ្រង់អនុញ្ញាត និងឧបករណ៍ប្រកបផ្សេងៗក្នុងការផឹកនោះ ដូចជា ផ្តិលធ្វើអំពីលោហៈ, ឈើ, ឬស្បែកសត្វ ព្រមទាំងរោងសម្រាប់ដាក់ទឹក, គម្រប, ស្នូក, ពាង ។

ទ្រង់អនុញ្ញាតទីងូតទឹកដែលមានប្រឡាយបង្ហូរទឹក មានជញ្ជាំងការពារ និងទ្រង់អនុញ្ញាតកន្សែងជូតខ្លួន [៧៦] ។ ម្យ៉ាងទៀត ទ្រង់អនុញ្ញាតស្រះទឹក និងឲ្យធ្វើកណ្ដាប់មាត់ស្រះអំពីឥដ្ឋ, ថ្ម, ឬឈើ ។ ទ្រង់អនុញ្ញាតឲ្យមានជណ្ដើរបង្កាន់ដៃ និងទ្រង់អនុញ្ញាតឲ្យមានប្រឡាយ

[៧៦] អដ្ឋកថាសំដៅយកនៅពេលងូតទឹករួច ត្រូវមានគ្រឿងទ្រសម្រាប់ជូតជើងការពារទឹកស្រក់ នៅពេលមិនមានទើបអនុញ្ញាតឲ្យប្រើកន្សែង ។

ទឹក ទទឹក (ដើម្បីបង្ហូរទឹកចូលទៅក្នុងស្រះ) នៅទីបំផុតទ្រង់អនុញ្ញាតផ្ទះភ្លើងដែលមានដម្បូលរាងមូល[៧៧] ។

## ទីអង្គុយ ទីដេក និងទីដាក់អាហារ

ទ្រង់ហាមនៅប្រាសចាកកម្រាលរហូត ៤ ខែ ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលប្រព្រឹត្តកន្លង[៧៨] ។ ទ្រង់ហាមដេកលើទីដែលក្រាលដោយផ្កាឈើ ទ្រង់អនុញ្ញាតឲ្យទទួលរបស់ក្រអូបបាន ដោយឲ្យបន្ថែម ៥ ធ្នាប់ នៅត្រង់សន្ទឹកទ្វារ ទ្រង់អនុញ្ញាតឲ្យទទួលផ្កាឈើបាន ប៉ុន្តែឲ្យទុកមួយកន្លែងនៅក្នុងវិហារ ។ ទ្រង់អនុញ្ញាតកម្រាលដែលធ្វើអំពីរោមសត្វ និងមិនត្រូវអធិដ្ឋាន (គឺតាំងចិត្តយកប្រើ) ឬវិកប្ប (ធ្វើឲ្យមានម្ចាស់ពីរ) ឡើយ ។

ទ្រង់ហាមឆាន់អាហារនៅក្នុងភាជនៈដែលធ្វើអំពីទង់ស្ពាន់ ឬប្រាក់ ។ ភិក្ខុមានជម្ងឺមិនអាចកាន់បាត្រឆាន់ ទើបទ្រង់អនុញ្ញាតទីទ្រដែលធ្វើអំពីឈើ ។

[៧៧] **និល្លេខំ ជន្តាឃរំ** បូរាណប្រែថា ផ្ទះភ្លើងដែលមិនមានទីប្រក់ ។

[៧៨] យោងតាមរឿងនេះសម្តែងឲ្យឃើញថា កម្រាលជាបរិក្ខារប្រចាំសម្រាប់ភិក្ខុ ពេលអង្គុយផ្ទាល់នឹងផ្ទៃចីវរអាចប្រឡាក់ ដូច្នេះទើបត្រូវការចាំបាច់ ។

## ហាមឆាន់អាហារ និងផឹកទឹក នៅក្នុងភាជនៈតែមួយជាដើម

ទ្រង់ហាមឆាន់អាហារនៅក្នុងភាជនៈតែមួយ, ហាមផឹកទឹកផ្តិលតែមួយ, ហាមដេករួមគ្នាលើគ្រែតែមួយ, លើកម្រាលតែមួយ, ដណ្តប់ភួយតែមួយដូចគ្រហស្ថបរិភោគកាម ទ្រង់ពិន័យអាបត្តិទុក្កដ ដល់ភិក្ខុអ្នកប្រព្រឹត្តកន្លង ។

## ការដាក់ទោសមិនឱ្យរាប់រកដល់វឌ្ឍនលិច្ឆវី

វឌ្ឍនលិច្ឆវីជាបក្សពួករបស់មេត្តិយៈ និងភុម្មជ្ឈកៈ ដឹងថាភិក្ខុទាំងនោះ មិនចូលចិត្តព្រះទព្វមល្លបុត្រ (ជាព្រះអរហន្ត) ទើបប្រើឧបាយកលកម្ចាត់លោក ដោយទៅប្តឹងព្រះមានព្រះភាគថាព្រះទព្វមល្លបុត្ររំលោភប្រពន្ធរបស់ខ្លួន ។ ព្រះមានព្រះភាគទ្រង់ប្រជុំភិក្ខុសង្ឃត្រាស់សួរដឹងការពិតថា ជារឿងមូលបង្កាច់ហើយទើបទ្រង់ណែនាំឲ្យដាក់ទោសមិនឲ្យនិយាយរកដល់ពួកវឌ្ឍនលិច្ឆវី ។

ទ្រង់កំណត់អង្គ ៨ ប្រការ សម្រាប់ឧបាសកដែលគួរដាក់ទោសមិនឲ្យនិយាយរក គឺ

១.ព្យាយាមធ្វើឲ្យវិនាសលាភសង្ឃ
២. ព្យាយាមធ្វើអន្តរាយដល់ភិក្ខុ
៣.ព្យាយាមដើម្បីឲ្យភិក្ខុទាំងឡាយ នៅមិនបាន
៤.ជេរ ឬបរិភាសភិក្ខុ

៥.ធ្វើភិក្ខុឲ្យបែកគ្នា

៦.តិះដៀលព្រះពុទ្ធ

៧.តិះដៀលព្រះធម៌

៨.តិះដៀលព្រះសង្ឃ ។

បន្ទាប់ពីនោះមក ទ្រង់សំដែងវិធីសូត្រប្រកាសមិនឲ្យនិយាយរកដោយពិស្តារ ។ នៅពេលព្រះអានន្ទទៅប្រាប់ពួកវឌ្ឍនលិច្ឆវីឲ្យដឹងថា ឥឡូវនេះសង្ឃដាក់ទោសមិនឲ្យនិយាយរក វឌ្ឍនលិច្ឆវីក៏ខូចចិត្តរហូតដល់ថ្នាក់សន្លប់[៧៩] ទើបមិត្រ អាមាត្យ សាច់សាលោហិតណែនាំឲ្យទៅក្រាបទូលសុំខមាទោសព្រះមានព្រះភាគ វឌ្ឍនលិច្ឆវីព្រម ធ្វើតាមគ្រប់យ៉ាង ។ កាលបើទ្រង់ជ្រាបថា ពួកវឌ្ឍនលិច្ឆវីព្រមកែខ្លួនហើយ ទើបត្រាស់ឲ្យសង្ឃសូត្រប្រកាសលើកលែងទោសក្នុងការមិនឲ្យនិយាយរក ដោយការឲ្យវឌ្ឍលិច្ឆវីចូលទៅសុំការលើកលែងទោស រួចហើយឲ្យសង្ឃសូត្រប្រកាសលើកលែងទោស ។

## រឿងការឱ្យឆាន់សំពត់សបាន និងឆាន់មិនបាន

ពោធិរាជកុមារធ្វើបុណ្យឆ្លងប្រាសាទ និមន្តព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃទៅឆាន់ ទ្រង់បញ្ជាឲ្យក្រាលសំពត់សរហូតដល់មាត់ជណ្តើរ ព្រះមានព្រះភាគទ្រង់មិនយាងជាន់ (មានរឿងដំណាលថា ពោធិរាជកុមារអធិដ្ឋានថា បើមានបុត្រសូមឲ្យទ្រង់យាងជាន់) បន្ទាប់មកទ្រង់ប្រារព្ធរឿងនោះ ទើបហាមមិនឲ្យជាន់សំពត់ស បើជាន់ត្រូវអាបត្តិទុក្កដ ។

បើម្ចាស់កម្មវិធីសុំឲ្យជាន់ដើម្បីជាមង្គល ទ្រង់អនុញ្ញាតឲ្យជាន់បាន សូម្បីសំពត់ជូតជើង ទ្រង់ក៏អនុញ្ញាតឲ្យជាន់បានដែរ ។

## ឧបាសិកាវិសាខាថ្វាយបរិក្ខារប្រើប្រាស់

ឧបាសិកាវិសាខានាំយកធុងទឹក, វត្ថុសម្រាប់ជូតជើងធ្វើជារាងត្របកផ្កាឈូក, អំបោសទៅប្រគេន ព្រះមានព្រះភាគទ្រង់ទទួលយកធុងទឹក និងអំបោស និងអនុញ្ញាតឲ្យភិក្ខុប្រើប្រាស់បាន ហាមមិនឲ្យប្រើវត្ថុសម្រាប់ជូតជើង ដែលធ្វើជារាងត្របកផ្កាឈូក ។ ចំណែកឯគ្រឿងជូតជើងដែលធ្វើអំពីក្បឿង និងថ្មរៀតដែលកើតពីពពុះទឹកសមុទ្រ ទ្រង់អនុញ្ញាតឲ្យប្រើបាន ។

ឧបាសិកាវិសាខានាំផ្លិតគ្នោតមកប្រគេន ទ្រង់ទទួល និងអនុញ្ញាតឲ្យប្រើបាន ។ ទ្រង់អនុញ្ញាតឲ្យប្រើសម្រាប់បក់ដេញរុយ ប៉ុន្តែទ្រង់មិនអនុញ្ញាតផ្លិតដែលធ្វើអំពីរោមចាមរី, ទ្រង់អនុញ្ញាតផ្លិត

[៧៩] ការមិនឲ្យនិយាយរក គឺមិនឲ្យទទួលយកអាហារអំពីអ្នកនោះ មិនឲ្យទាក់ទងជាមួយ មើលទៅហាក់ដូចជាមិនធ្ងន់ធ្ងរ ហេតុអ្វីទើបដល់ថ្នាក់សន្លប់ គិតថាជាការសាបសូន្យខាងសង្គមយ៉ាងខ្លាំង ទើបវឌ្ឍនលិច្ឆវីប្រញាប់កែខ្លួន ដោយពុំមានទិដ្ឋិមានះអ្វីឡើយ ។

៣ យ៉ាង គឺធ្មើអំពីសម្បកឈើ, ធ្មើអំពីស្បូវភ្លាំង និងធ្មើអំពីរោមស្វាបក្ងោក ។

## ទ្រង់អនុញ្ញាត និងហាមប្រើឆត្រ

ដម្បូងឡើយទ្រង់អនុញ្ញាតឲ្យប្រើឆត្រ ក្រោយមកភិក្ខុឆព្វគ្គិយបាំងឆត្រដើរទៅក្នុងទីផ្សេងៗ មានគេតិះដៀលថាធ្វើដូចជាមហាអាមាត្យ ទើបទ្រង់ហាមប្រើឆត្រ តែទ្រង់អនុគ្រោះអនុញ្ញាតប្រើឆត្រ បាននៅពេលមិនសប្បាយ ។ កាលបើប្រើនៅក្នុងវត្ត ឬនៅក្នុងបរិវេណវត្ត (កាន់យកសេចក្ដីថា បើប្រើឆត្រដើម្បីការពារកម្ដៅថ្ងៃ និងភ្លៀងធម្មតា ទ្រង់ក៏អនុញ្ញាតឲ្យប្រើបាន ក្នុងន័យថាបើមិនប្រើទេ មិនសប្បាយ ។ ប៉ុន្តែបើប្រើឆត្រដើម្បីសំដែងកិត្តិយស ដូចជាមហាអាមាត្យ ឬព្រះរាជា ទ្រង់ហាម) ។

## ទ្រង់ហាមនិងអនុញ្ញាតដងរែកនិងសង្រែក

ដម្បូងទ្រង់ហាមភិក្ខុមិនឲ្យប្រើដងរែក សង្រែក នាំរបស់ទៅក្នុងទីផ្សេងៗ ក្រោយមកមានភិក្ខុអាពាធ ត្រូវការប្រើដងរែកជញ្ជូនរបស់ទៅ ទ្រង់ក៏អនុញ្ញាត ដោយការឲ្យសង្ឃសូត្រប្រកាសសន្មតជាពិសេស ។ ក្រោយមកទៀត មានភិក្ខុអាពាធត្រូវការប្រើសង្រែកជញ្ជូនបាត្រទៅ ទ្រង់ក៏អនុញ្ញាតទៀត ដោយឲ្យសង្ឃសូត្រប្រកាសសន្មតជាពិសេស ។ បន្តបន្ទាប់មកទៀត ភិក្ខុអាពាធចាំបាច់ត្រូវប្រើទាំងដងរែកនិងសង្រែក ទ្រង់ក៏អនុញ្ញាត រួចហើយឲ្យសង្ឃសូត្រប្រកាសសន្មត ។

## រឿងភើ និងគ្រាប់បាយ

ភិក្ខុមួយរូបភើៗ ចេញមកហើយក៏លេបចូលទៅវិញ ត្រូវគេនិយាយថា ឆាន់អាហារក្នុងវេលាវិកាល ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតជាពិសេសសម្រាប់ភិក្ខុភើនេះ តែហាមថា បើភើចេញមកក្រៅមាត់ហើយ មិនអនុញ្ញាតឲ្យលេបចូលទៅវិញទេ ។

នៅក្នុងរោងឆាន់ (ផ្ទះបាយ) មានគ្រាប់បាយកំពប់ជ្រុះរាត់រាយ មានគេតិះដៀល ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតថា វត្ថុដែលទាយកប្រគេនបើជ្រុះឲ្យរើសមកទុកឆាន់ខ្លួនឯង ពីព្រោះទាយកគេបរិច្ចាគវត្ថុនោះរួចហើយ (ក្នុងចំណុចនេះ កាលបើឆាន់វត្ថុមិនបានប្រគេន មើលទៅហាក់ដូចជាមិនត្រូវអាបត្តិ, ប៉ុន្តែរបស់នោះកខ្វក់ ក៏ត្រូវតែពិចារណាជាបន្តទៅ ។ នៅក្នុងរឿងនេះ មិនតម្រូវឲ្យឆាន់របស់ដែលធ្លាក់នោះទេ, ប៉ុន្តែអនុញ្ញាតថា របស់ដែលធ្លាក់បើមានទាយកគេប្រគេនហើយ អនុញ្ញាតឲ្យរើសយកមកឆាន់បាន ទើបគួរវិភាគមើលថា ក្នុងករណីវត្ថុនោះមិនប្រឡាក់ គួរឆាន់បាន ។

## ទ្រង់អនុញ្ញាតកន្ត្រៃកាត់ក្រចកជាដើម

ទ្រង់ហាមទុកក្រចកវែង ភិក្ខុទុកក្រចកវែងត្រូវអាបត្តិទុក្កដ, រួចហើយទ្រង់អនុញ្ញាតកន្ត្រៃកាត់ក្រចក ឲ្យកាត់ទុកស្មើសាច់ ។ ទ្រង់ហាមខាត់ក្រចកធ្វើឲ្យរលើបរលោងទាំង ២០ ម្រាម (ដើម្បីល្អ) ទ្រង់ពិន័យអាបត្តិទុក្កដ ។ ទ្រង់អនុញ្ញាតការនាំយកមូល (អាចម៍) ក្រចកចេញ ។

## រឿងសក់ និងពុកចង្កា

ទ្រង់សាកសួរថា អាចកោរសក់ដោយខ្លួនឯងបានដែលទេ? កាលបើភិក្ខុទាំងឡាយឆ្លើយទូលថាបាន, ទើបទ្រង់អនុញ្ញាតកាំបិតកោរ, ថ្មសំលៀង, ស្រោមកាំបិត, គ្រឿងដន្ទោះកាំបិតកោរ, និងឧបករណ៍ប្រើប្រាស់ ដែលទាក់ទងជាមួយនឹងកាំបិតកោរគ្រប់ប្រភេទ ។ (សម្រាប់ភិក្ខុដែលធ្លាប់ធ្វើជាជាងកាត់សក់ មានហាមទុកនៅក្នុងទីដទៃថាមិនឲ្យមានគ្រឿងកាំបិតកោរឡើយ ដោយក្រែងលោលោកចង់ទៅប្រកបអាជីពនោះទៀត) ។

ភិក្ខុឆព្វគ្គិយនាំគ្នាលំអពុកចង្កាដោយកន្ត្រៃ និងទុកពុកចង្កាធ្វើជារូបផ្សេងៗ រហូតដល់ឲ្យនាំរោមនៅក្នុងទីចង្អៀតចេញ ទ្រង់ហាមនិងពិន័យអាបត្តិទុក្កដ ។ ក្នុងករណីអាពាធ ទ្រង់អនុញ្ញាតឲ្យនាំរោម

នៅក្នុងទឹចផ្សៀតចេញបាន ដូចជា កើតដំបៅ រួចហើយត្រូវការលាបថ្នាំ ។

ទ្រង់ហាមកាត់សក់ដោយកន្ត្រៃ, ទ្រង់អនុញ្ញាតឲ្យប្រើកាំបិតកោរ, ប៉ុន្តែបើអាពាធ ទ្រង់អនុញ្ញាតឲ្យកាត់សក់ដោយកន្ត្រៃបាន ។

ទ្រង់ហាមទុករោមច្រមុះវែង ពីព្រោះមានគេតិះដៀល, ទ្រង់អនុញ្ញាតឲ្យដកដោយដង្កៀប, ទ្រង់ហាមដកសក់ស្កូវ និងពិន័យអាបត្តិទុក្កដនៅពេលដែលប្រព្រឹត្តល្មើស ។

## គ្រឿងប្រើប្រាស់តូចតាច

ទ្រង់អនុញ្ញាតគ្រឿងត្បារត្រចៀក តែមិនអនុញ្ញាតធ្វើអំពីមាស, ទ្រង់អនុញ្ញាតគ្រឿងត្បារត្រចៀកធ្វើអំពីភ្លុក និងស្នែងសត្វជាដើម ។

ទ្រង់ហាមសន្សំទុកដាក់គ្រឿងប្រើប្រាស់ធ្វើអំពីលោហៈ និងសំរឹទ្ធិ រួចហើយពិន័យអាបត្តិទុក្កដនៅពេលដែលប្រព្រឹត្តល្មើស ។ ទ្រង់អនុញ្ញាតថង់ ឬស្រោមថ្នាំភ្នែក, ឈើបៀកថ្នាំភ្នែក, ឈើត្បារត្រចៀក ។

## ក្រណាត់ប្រើប្រាស់

ទ្រង់ហាមរុំជង្គង់ដោយសង្ឃាដី និងធ្វើការពិន័យដល់ភិក្ខុដែលប្រព្រឹត្តល្មើស, ប៉ុន្តែមានភិក្ខុខ្លះអាពាធ មិនមានអ្វីរុំជង្គង់ស្រាប់តែមិនសប្បាយ ទើបទ្រង់អនុញ្ញាតក្រណាត់រុំជង្គង់ ។ ទ្រង់អនុញ្ញាតឧបករណ៍ជាផតម្បាញគ្រប់ប្រភេទ ដើម្បីធ្វើខ្សែរុំជង្គង់ (ការចងជង្គង់នៃមនុស្សសម័យនោះមាន ៣ ប្រភេទ គឺចងដោយគ្រឿងវាស់ (អាយោគបល្លត្ថិកា), ចងដោយដៃ (ហត្ថបល្លត្ថិកា) និងចងដោយក្រណាត់ (ទុស្សបល្លត្ថិកា) ជាទម្លាប់បើមិនបានធ្វើដូច្នោះក៏មិនសប្បាយ ជាធម្មតាគ្រឿងចងនោះ គឺគេចងផ្ដោបខ្នងត្រគាកនិងជង្គង់, នៅពេលចងរួចហើយអង្គុយស្រួល ។ ម្យ៉ាងទៀតនៅក្នុងរឿងនេះ រហូតដល់ថ្នាក់ទ្រង់អនុញ្ញាតឲ្យភិក្ខុត្បាញគ្រឿងរុំជង្គង់ដោយខ្លួនឯងបាន សំដែងថា ជារឿងតូចតាច មិនត្រូវប្រើពេលយូរដូចត្បាញសំពត់នោះទេ បើពុំដូច្នោះទេ ភិក្ខុអាចត្រូវខ្វល់ខ្វាយនៅក្នុងការងារនេះ រហូតដល់រំខានក្នុងការសិក្សា ឬអប់រំចិត្តបាន) ។

ទ្រង់ហាមចូលទៅកាន់ស្រុក ដោយមិនមានវត្ថពន្ធចង្កេះ (ព្រោះប្រាកដថា ភិក្ខុមួយរូបមានសំពត់របូតធ្លាក់នៅក្នុងស្រុក) ទ្រង់ហាមប្រើវត្ថពន្ធចង្កេះ ដែលវិចិត្រមានសណ្ឋានផ្សេងៗ ដែលគ្រហស្ថសម័យនោះគេនិយមប្រើ ។ ទ្រង់អនុញ្ញាតវត្ថពន្ធចង្កេះដែលត្បាញតាមធម្មតាហៅថា ផ្ទាំងវត្ថពន្ធ និងវត្ថពន្ធមានសណ្ឋានដូច

ពោះវៀនជ្រូក ទ្រង់អនុម័តវិធីការផ្សេងៗ ដែលអាចធ្វើឲ្យវត្ថពន្ធជាប់បានយូរអង្វែង ដូចជាការត្បាញ និងដេរជាយឲ្យជាប់ ។ ទីបំផុតទ្រង់អនុញ្ញាតក្រវិល គឺអន្ទាក់សម្រាប់ទាក់វត្ថពន្ធចង្កេះ ទ្រង់ហាមប្រើក្រវិលដែលធ្វើអំពីមាសប្រាក់ ។ ទ្រង់អនុញ្ញាតក្រវិលធ្វើអំពីឆ្អឹង, ភ្លុក, ស្នែងសត្វ, ឈើបបុះ, ឫស្សី, ខ្ចឹម, ជ័រ, ផ្លែ (ដូចជាត្រឡោកដូង), លោហៈ, សម្បកសង្ខ, និងអំបោះជាដើម ។

ទ្រង់អនុញ្ញាឡេវ និងអន្ទាក់ឡេវសម្រាប់សង្ឃាដី (វេលាដណ្តប់ចូលទៅកាន់ស្រុក ខ្យល់មិនអាចបក់បើកបាន) និងទ្រង់អនុញ្ញាត និងហាមឡេវតែម្យ៉ាងដូចក្រវិលដែរ ។

ទ្រង់អនុញ្ញាតឲ្យភ្ជាប់ផ្ទាំងសំពត់សម្រាប់ភ្ជាប់ឡេវ និងអន្ទាក់ឡេវ (ដើម្បីការពារចីវរ) នៅពេលភ្ជាប់រួចហើយ មុំចីវរនៅចំហរ ក៏ទ្រង់អនុញ្ញាតឲ្យភ្ជាប់ឡេវត្រង់ជាយចីវរ ។ ចំណែកអន្ទាក់ឡេវឲ្យភ្ជាប់ចូលទៅជ្រៅ ៧ ឬ ៨ ធ្នាប់ ។

ទ្រង់ហាមស្លៀកដូចគ្រហស្ថ ដូចជាស្លៀកដូចប្រមោយដំរី, ស្លៀកដូចកន្ទុយត្រី, ស្លៀកប្រលែងជាយទាំង ៤, ស្លៀកដូចផាងត្នោត និងស្លៀកលើកជាស្រទាប់ៗ ។ ម្យ៉ាងទៀត ទ្រង់ហាមដណ្តប់ដូចគ្រហស្ថ និងហាមស្លៀកសំពត់កំប៉ិតដូចអ្នកប្រដាល់ និងកម្មករ ។

## រឿងរែកពន់ សែង

ទ្រង់ហាមរែករបស់ដែលមានទាំងសងខាង (អ្នករែកនៅកណ្តាល) ព្រោះមានគេនិយាយថា ធ្វើដូចអ្នកនាំបរិក្ខារឲ្យព្រះរាជា ។ ទ្រង់អនុញ្ញាតការរែក (មានរបស់តែម្ខាង), ការរែក (របស់នៅកណ្តាល មានមនុស្សនៅសងខាងពីរនាក់), ការទូលលើក្បាល, ការរែកនៅលើស្មា, ការកណ្តៀត (លើចង្កេះ) និងការស្ពាយ (ពន់ ឬយួរ) ។

## ការទំពារឈើស្ទន់

ទ្រង់សំដែងទោសក្នុងការទំពាឈើស្ទន់ ៥ យ៉ាង និងសំដែងអានិសង្ស (ផលល្អ) ក្នុងការទំពាឈើស្ទន់ ៥ យ៉ាង, ទ្រង់ហាមទំពាឈើស្ទន់វែងលើស ៨ ធ្នាប់ (របស់មនុស្សធម្មតា) និងហាមយកឈើស្ទន់វាយសាមណេរ, ទ្រង់ហាមទំពាឈើស្ទន់ខ្លីពេក ទ្រង់អនុញ្ញាតយ៉ាងខ្លីបំផុតត្រឹម ៤ ធ្នាប់ និងពិន័យអាបត្តិទុក្កដនៅពេលប្រព្រឹត្តល្មើស ។

## ហាមដុតព្រៃ និងឡើងដើមឈើ

ទ្រង់ហាមដុតព្រៃ និងពិន័យអាបត្តិទុក្កដ, នៅពេលមានភ្លើងឆេះរាលមក ទ្រង់អនុញ្ញាតឲ្យដុតដេញទៅវិញបាន ។ ទ្រង់ហាមឡើងដើមឈើ នៅពេលមានហេតុចាំបាច់ទ្រង់អនុញ្ញាតឲ្យឡើងបានមួយជំហមនុស្ស ។ តែបើមានអន្តរាយ ទ្រង់អនុញ្ញាតឲ្យឡើងខ្ពស់បានតាមតម្រូវការ ។

## ហាមលើកពុទ្ធវចនៈឡើងដោយឆន្ទៈ

ទ្រង់ហាមលើកពុទ្ធវចនៈឡើងដោយឆន្ទ ទ្រង់អនុញ្ញាតឲ្យរៀនពុទ្ធវចនៈរបស់ខ្លួនបាន (អដ្ឋកថាពន្យល់ថា ហាមលើកពុទ្ធវចនៈឡើងកាន់ភាសាសំស្ក្រឹតទំនងដូចជាព្រះវេទរបស់ព្រាហ្មណ៍ តែមានផ្លូវសន្និដ្ឋានថា ហាមតែងព្រះពុទ្ធវចនៈជាបទឆន្ទ ពីព្រោះអាចធ្វើឲ្យអត្ថន័យដើមប្រែប្រួល ឬខុសទៅតាមការបង្ខាប់ឆ្ងន់ស្រាលនៃពាក្យឆន្ទ ក្រៃលែងជាងនេះ បើអ្នកតែងមិនបានចាក់ធ្លុះនៅក្នុងភាសាគ្រប់គ្រាន់ទេ ក៏ជាការទម្លាយពុទ្ធវចនៈ ធ្វើឲ្យអត្ថន័យប្រែប្រួលទៅបាន ប៉ុន្តែការហាមទាំងអស់នេះ ហាក់ដូចជាសំដៅយកន័យថា ការតែងដើម្បីប្រើជាក្បួនតម្រា ដើម្បីសិក្សាទន្ទេញរៀនសូត្រ ។ ចំណែកឯការតែងសរសើរតាមធម្មតា ដែលជារបស់ផ្ទាល់ខ្លួនបុគ្គល មិនឋិតនៅក្នុងខនេះទេ) ។ ក្នុងរឿងដើមរៀបរាប់ដល់ភិក្ខុដែលកើតនៅក្នុងត្រកូលព្រាហ្មណ៍ ២ រូប ទៅសុំអនុវត្តដល់ព្រះមានព្រះភាគដើម្បីលើកព្រះពុទ្ធវចនៈឡើងជាឆន្ទ តែទ្រង់បដិសេធ និងបញ្ញត្តខហាមទុក ។

## ហាមរៀន ហាមបង្រៀនលោកាយតនៈ និងតិរច្ឆានវិជ្ជា

ទ្រង់ហាមរៀន និងបង្រៀនលោកាយតនៈ (គឺគតិដែលជឿថា គួរស្វែងរកសេចក្តីសុខតែមួយថ្ងៃៗ ល្អជាង ចាំបាច់ទៅគិតដល់រឿងបុណ្យបាបធ្វើអ្វី គួរសប្បាយផឹកស្រា ដើរខ្ចីប្រាក់គេដែលឆ្ងន់ទៅនៅក្នុងវត្តនិយម តែនៅក្នុងអដ្ឋកថាពន្យល់ថា ជាគម្ពីរ ឬតម្រារបស់អ្នកក្រៅសាសនា ដូចជាជំណាលអំពីក្អែកស កុកខ្មៅ ។ កន្លែងខ្លះកែថា ជាវិតណ្ឌាសាស្ត្រដែលជាផ្នែកមួយ នៃការសិក្សារបស់ព្រាហ្មណ៍) ព្រមទាំងហាមរៀន ហាមបង្រៀននូវតិរច្ឆានវិជ្ជា (វិជ្ជាខាងក្រៅដែលគ្មានប្រយោជន៍) ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកប្រព្រឹត្តល្មើស ។

## ហាមជឿរឿងមង្គល តែមិនរំខានអ្នកដទៃ

សម័យមួយព្រះមានព្រះភាគកំពុងសំដែងធម៌ ទ្រង់កណ្តាស់ឡើង ។ ភិក្ខុទាំងឡាយក៏បន្លឺសំឡេងខ្លាំងឡើងថា ព្រះមានព្រះភាគចូរចម្រើន រហូតក្លាយជាឧបសគ្គដល់ការសំដែងធម៌ ។ ព្រះមាន

ព្រះភាគត្រាស់សួរថា កាលបើពោលដូច្នោះ អាចធ្វើឲ្យមានជីវិត ឬធ្វើឲ្យស្លាប់ទៅបានពិតៗឬ កាលបើភិក្ខុទាំងនោះក្រាបទូលថា មិនប្រព្រឹត្តទៅបាន ទើបទ្រង់ត្រាស់ហាមនិយាយដោះសារនៅពេលកណ្តាស់ និងពិន័យអាបត្តិទុក្កដដល់អ្នកប្រព្រឹត្តល្មើស ។

តែជាទំនៀមរបស់មនុស្សក្នុងសម័យនោះ បើភិក្ខុកណ្តាស់ មានគ្រហស្ថនិយាយថា សូមឲ្យលោកមានជីវិតរស់នៅ ភិក្ខុត្រូវពោលតប (ដោយអធ្យាស្រ័យរាប់អាន) ថា សូមឲ្យពួកលោកមានជីវិតរស់នៅដូចគ្នា ។ ភិក្ខុទាំងឡាយមិនហ៊ានពោលតប ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យពោលតបគេបាន (តែមិនឲ្យប្រើជាមួយពួកភិក្ខុដូចគ្នាទេ) ។

## ហាមឆាន់ខ្ទឹម

ភិក្ខុមួយរូបឆាន់ខ្ទឹម ខ្លាចភិក្ខុដទៃធុំក្លិនស្អុយនៅពេលអង្គុយស្តាប់ធម៌ ទើបអង្គុយនៅឆ្ងាយពីភិក្ខុដទៃ មិនចូលទៅជិតនរណាឡើយ ។ ទើបព្រះមានព្រះភាគទ្រង់ហាមឆាន់ខ្ទឹម និងពិន័យអាបត្តិទុក្កដដល់អ្នកប្រព្រឹត្តល្មើស ។ ក្រោយមកទ្រង់អនុញ្ញាតឲ្យភិក្ខុអាពាធឆាន់បាន (អាចជាការហាមចំពោះការឆាន់ខ្ទឹមទទេ បើឆាន់លាយជាមួយវត្ថុដទៃ ឬគេផ្សំឡើងនោះ មិនគួរចាត់ចូលនៅក្នុងបទហាមឃាត់នេះទេ ។ បើពិចារណាដល់វត្ថុបំណងក្នុងការហាមឃាត់ សរឲ្យឃើញថា ធ្វើមិនឲ្យចូលមកក្នុងក្រុមបាន ឬបង្កសេចក្តីរំខានដល់ក្រុម ឬជាហេតុរំខានដល់ការស្តាប់ធម៌ ព្រោះហេតុដូច្នោះ រឿងចំហាយក្លិននៃខ្ទឹម ទើបចាត់ជាចំណុចសំខាន់នៅក្នុងរឿងនេះ) ។

## ទ្រង់អនុញ្ញាតទីបន្ទោបង់បស្សាវៈ និងឧច្ចារៈ

នៅក្នុងរឿងបស្សាវៈ ទ្រង់អនុញ្ញាតឲ្យបន្ទោបង់នៅក្នុងទីដែលគេរៀបចំទុក, ទ្រង់អនុញ្ញាតឆ្នាំងបស្សាវៈ កំណល់ជាន់វេលាអង្គុយបន្ទោបង់ ជញ្ជាំង ឬរបងសម្រាប់បិទបាំងដែលធ្វើអំពីឥដ្ឋ, ថ្ម ឬឈើ ព្រមទាំងគម្របបិទឆ្នាំងបស្សាវៈ (ដើម្បីការពារ ក្លិនស្អុយ) ។

នៅក្នុងរឿងឧច្ចារៈ ទ្រង់អនុញ្ញាតឲ្យបន្ទោបង់នៅក្នុងទីដែលគេរៀបចំទុក ឲ្យមានរណ្តៅឧច្ចារៈ និងឲ្យលើកទីឲ្យខ្ពស់ដើម្បីការពារទឹកលិច ឲ្យមានជណ្តើរ និងបង្កាន់ដៃ ឲ្យក្រាលថ្មដុំ ចោះប្រហោងកណ្តាល ឲ្យមានជ្រុញ ឬកំណល់ជាន់ ឲ្យមានទបស្សាវៈ ឲ្យប្រើឈើសម្រាប់ជម្រះ ទីសម្រាប់ដាក់ឈើជម្រះ និងគម្របសម្រាប់បិទរណ្តៅឧច្ចារៈ និងឲ្យមានរោងបន្ទោបង់ផ្ទាល់ខ្លួន ហៅថា វច្ចកុដិ

(បន្ទន់) មានជញ្ជាំង ឬរបង ព្រមទាំងគ្រឿងប្រកប ដូចជា រនុក គន្ទិះ ខ្សែចង ស្នួចីវរ ជាដើម ។ មួយទៀត ទ្រង់អនុញ្ញាតឲ្យមានប្រាស់ សម្រាប់ជម្រះ សម្អាត ក្រោយពេលបន្ទោបង់រួចហើយ ឲ្យមានប្រឡាយបង្ហូរទឹក ឲ្យមានឆ្នាំងដាក់ទឹកសម្រាប់លាងជម្រះផ្តិល សម្រាប់ដួសទឹកលាងជម្រះ និងមានកំណល់សម្រាប់លាងជម្រះ ព្រមទាំងជញ្ជាំង ឬរបង ។

## ទ្រង់ហាមប្រព្រឹត្តអនាចារ

ភិក្ខុឆព្វគ្គិយប្រព្រឹត្តអនាចារមានប្រការផ្សេងៗ ដូចជាយកចិត្តគ្រហស្ថ ទាក់ទងជាមួយនឹងស្ត្រីហួសហេតុ លេងរាំច្រៀង លេងកីឡាផ្សេងៗ ទ្រង់ហាមធ្វើដូច្នោះ និងពិន័យអាបត្តិតាមសមគួរដល់កំហុស ។

## ទ្រង់អនុញ្ញាតឧបករណ៍ប្រើប្រាស់

ព្រះឧរុវេលកស្សបៈបួសរួចហើយ មានទាយកប្រគេនគ្រឿងប្រើប្រាស់ធ្វើអំពីលោហៈ, ឈើ, ដីស្អិត ។ លោកសង្ស័យថា ទ្រង់អនុញ្ញាត ឬក៏អត់ហ្ន៎ ទើបព្រះមានព្រះភាគត្រាស់អនុញ្ញាតឲ្យប្រើប្រាស់បាន ។

## ២.សេនាសនខន្ធកៈ (ពោលអំពីទីស្នាក់អាស្រ័យនៅ)

## ទ្រង់អនុញ្ញាតមាន ៥ ប្រភេទ

សេដ្ឋីនៅក្នុងក្រុងរាជគ្រឹះ ជ្រះថ្លានឹងភិក្ខុទាំងឡាយដែលនៅជាមួយនឹងព្រះមានព្រះភាគដែលគង់នៅក្នុងអារាមវេឡុវ័ន ប្រាថ្នានឹងសាងវិហារប្រគេន ទើបសុំឲ្យភិក្ខុទាំងនោះក្រាបទូលដល់ព្រះមានព្រះភាគ ។ ទើបព្រះអង្គទ្រង់អនុញ្ញាតទីអាស្រ័យនៅ ៥ ប្រភេទគឺ

១.វិហារ (កុដិធម្មតា)

២.យ៉ (អឌ្ឍយោគ)

៣.ផ្ទះជាថ្នាក់ៗ (ប្រាសាទ)

៤.ផ្ទះកំពូល ឬមានដំបូលកាត់ (ហម្មិយ)

៥.ល្អាង (គុហា) ។

ក្រោយមកពេលមានគេដឹងថា ទ្រង់អនុញ្ញាតវិហារ ឬទីលំនៅដល់សង្ឃ ទើបនាំគ្នាសង់ទីលំនៅប្រគេនជាច្រើន ព្រះមានព្រះភាគទ្រង់ក៏អនុញ្ញាតបន្ថែម ដើម្បីឲ្យលំនៅនោះមានភាពសម្បូរឡើង ដូចជាទ្វារ, រនុក, គន្ទិះ, បង្អួចជាដើម ។

## ទីអង្គុយ និងទីដេក

ទ្រង់អនុញ្ញាតគ្រែដេក (ដើម្បីពុំចាំបាច់ដេកនៅផ្ទាល់ដី) និងតាំងសម្រាប់អង្គុយច្រើនប្រភេទ ទ្រង់អនុញ្ញាតអាសន្ទិកៈ (កៅអី ៤ ជ្រុង) ទាំងប្រភេទខ្ពស់ និងប្រភេទដែលមានចំណែកប្រកបទាំង ៧ (ភ្នាក់ដៃ ២ បង្អែក ១ និងជើង ៤ មានលក្ខណៈស្រដៀងនឹងកៅអីផ្អែក) និងគ្រែតាំងជាច្រើន ។ ទ្រង់ហាមប្រើគ្រែខ្ពស់ តែឲ្យមានគ្រឿងទ្របាន, គ្រឿងទ្រជើងគ្រែមិនឲ្យ មានកំពស់លើសពី ៨ ធ្នាប់ រួចហើយទ្រង់អនុញ្ញាតគ្រឿងប្រកប ដទៃទៀតជាច្រើន ។ ទ្រង់អនុញ្ញាតខ្នើយញាត់គ ៣ ប្រភេទ គឺ គដើមឈើ, គស្លឹកឈើ គស្មៅ ។ ទ្រង់ហាមប្រើខ្នើយ មានប្រវែងពាក់កណ្ដាលខ្លួន គឺឲ្យប្រើខ្នើយមានខ្នាតល្មមក្បាល ។ ទ្រង់អនុញ្ញាតពូកញាត់ដោយរបស់ ៥ ប្រភេទ គឺរោមសត្វ, កំណាត់សំពត់, សម្បកឈើ និងស្មៅ ឬស្លឹកឈើ ។

បន្ទាប់ពីនោះមកជាការហាមឃាត់ និងអនុញ្ញាតទាក់ទងទៅនឹងលំនៅតូចៗ ជាច្រើនទៀត ដូចជាហាមគូររូបបុរសស្ត្រី នៅក្នុងវិហារ និងបញ្ចប់ដោយទ្រង់អនុញ្ញាតជម្បូល ៥ ប្រភេទ គឺ ធ្វើអំពីឥដ្ឋ, ថ្ម, កំបោរ, ស្មៅ, និងស្លឹកឈើ ។

## អនាថបិណ្ឌិកសេដ្ឋីកាន់ព្រះពុទ្ធសាសនា

អនាថបិណ្ឌិកសេដ្ឋី (សេដ្ឋីក្រុងសាវត្ថី) ជាស្វាមីរបស់ប្អូនស្រីសេដ្ឋីក្រុងរាជគ្រឹះ ធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ ដឹងថាព្រះពុទ្ធជាម្ចាស់កើតឡើងហើយនៅក្នុងលោក ហើយសេដ្ឋីក្រុងរាជគ្រឹះកំពុងត្រៀមប្រគេនអាហារបិណ្ឌបាត្រ ទើបទៅគាល់ព្រះមានព្រះភាគ ស្ដាប់ព្រះធម៌ទេសនាបានធម្មចក្ខុ (ជាព្រះសោតាបន្ន) នៅពេលបានប្រគេនភត្តាហារក្នុងថ្ងៃបន្ទាប់មក ទើបអារាធនាព្រះមានព្រះភាគទៅគង់ចាំព្រះវស្សានៅក្នុងក្រុងសាវត្ថី រួចហើយក៏ធ្វើដំណើរទៅមុន នៅពេលទៅដល់ក្រុងសាវត្ថីហើយ ក៏បានទិញដីក្រៅក្រុងមួយកន្លែងអំពីព្រះរាជកុមារជេត សាងវត្តនៅក្នុងព្រះពុទ្ធសាសនា ។

## ចាត់ភិក្ខុមើលការខុសត្រូវក្នុងការកសាង

ព្រះមានព្រះភាគស្ដេចយាងចាកក្រុងរាជគ្រឹះ ឆ្លងកាត់ក្រុងវេសាលី គង់នៅក្នុងកូដាគារសាលានាព្រៃមហាវ័ន ត្រាស់អនុញ្ញាតឲ្យសង្ឃសូត្រប្រកាសតែងតាំងភិក្ខុអ្នកត្រួតត្រា ក្នុងការសាងវិហារដែលមានគហបតីម្នាក់លះបង់ទ្រព្យកសាង ។

## លំដាប់អាទុរសោ

ក្នុងការស្តេចយាងទៅកាន់ក្រុងសាវត្ថី (អំពីក្រុងវេសាលី) នោះ ភិក្ខុទាំងឡាយដែលត្រូវជាសិស្សរបស់ឆព្វគ្គិយភិក្ខុ ច្រើនធ្វើដំណើរទៅមុន រួចហើយកក់ផ្ទះសំណាក់ទុកជាច្រើន ដើម្បីឧបជ្ឈាយ៍ ដើម្បីអាចារ្យ និងដើម្បីខ្លួនឯង ជាហេតុនាំឲ្យភិក្ខុដទៃ ដូចជាព្រះសារីបុត្ររកទីស្នាក់មិនបាន ត្រូវទៅស្នាក់នៅក្រោមដើមឈើ ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបត្រាស់ឲ្យប្រជុំភិក្ខុសង្ឃកំណត់ឲ្យភិក្ខុទាំងឡាយបដិបត្តិដោយប្រពៃដល់គ្នា និងឲ្យមានសិទ្ធិផ្សេងៗ ដូចជាបានទទួលការក្រាបសំពះ ក្រោកទទួល ធ្វើអញ្ជលី ការសំដែងសេចក្តីគោរព ការបានអាសនៈល្អ បានទឹកល្អ បានអាហារល្អ តាមលំដាប់អាវុសោ (ចាស់វស្សាជាង) អ្នកណាបដិសេធការកាន់យក តាមលំដាប់អាវុសោទាក់ទងនឹងរបស់សង្ឃ អ្នកនោះត្រូវអាបត្តិទុក្កដ ។

## បុគ្គលមិនគួរថ្វាយបង្គំ ១០ ប្រភេទ

ទ្រង់សំដែងដល់បុគ្គលដែល (ភិក្ខុ) មិនគួរថ្វាយបង្គំ ១០ ប្រភេទ គឺ

១.អ្នកបួសក្រោយ មិនគួរឲ្យអ្នកបួសមុនថ្វាយបង្គំ

២.អ្នក មិនបានបួស មិនគួរឲ្យអ្នកបួសថ្វាយបង្គំ

៣.ភិក្ខុដែលជានានាសង្វាស (ផ្សេងនិកាយគ្នា) ចាស់ជាង បើនិយាយមិនប្រកបដោយធម៌ ក៏មិនគួរសំពះថ្វាយបង្គំ

៤.មាតុគ្រាម (ស្ត្រី) មិនគួរថ្វាយបង្គំ

៥.ខ្ទើយ

៦.ភិក្ខុនៅបរិវាស

៧.ភិក្ខុដែលគួរទាញចូលរកអាបត្តិដើម

៨.ភិក្ខុដែលគួរប្រព្រឹត្តមានត្ត

៩.ភិក្ខុប្រព្រឹត្តមានត្ត

១០.ភិក្ខុដែលគួរសូត្រដកចាកអាបត្តិសង្ឃាទិសេស ។

ទាំងអស់នេះ ភិក្ខុមិនគួរថ្វាយបង្គំឡើយ ។

## បុគ្គលគួរថ្វាយបង្គំ ៣ ប្រភេទ

១.អ្នកបួសមុន គួរឲ្យអ្នកបួសក្រោយថ្វាយបង្គំ

២.ភិក្ខុដែលជានានាសង្វាសចាស់ជាង បើនិយាយប្រកបដោយធម៌ក៏គួរថ្វាយបង្គំ ។

៣.ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាបុគ្គលគួរថ្វាយបង្គំ ។

## មណ្ឌបសាងឧទ្ទិសដល់សង្ឃ

សិស្សរបស់ភិក្ខុឆព្វគ្គិយ បានលេសត្រង់បទបញ្ញត្តិដែលឲ្យភិក្ខុកាន់យកតាមលំដាប់អាវុសោទាក់ទងនឹងរបស់សង្ឃ នៅពេលមានអ្នកសាងមណ្ឌបឧទ្ទិសដល់សង្ឃ ក៏ដើរទៅចងទុកឲ្យឧបជ្ឈាយ៍ ឲ្យអាចារ្យ និងដើម្បីខ្លួនឯង ដោយអាងថា ទីដែលហាមនោះ គឺហាមចំពោះជារបស់សង្ឃ មិនបានហាមទាក់ទងនឹងទីដែលគេសាងឧទ្ទិសសង្ឃឡើយ (ជាពាក្យអាងទាក់ទងនឹងពាក្យហាម) ព្រះមានព្រះភាគទ្រង់ជ្រាប ក៏ហាមធ្វើដូចនោះ និងពិន័យអាបត្តិទុក្កដដល់អ្នកប្រព្រឹត្តល្មើស ។

## អាសនៈផ្សេងៗ របស់គ្រហស្ថ

កាលបើទាយកទាំងឡាយ និមន្តភិក្ខុទៅឆាន់នៅក្នុងចន្លោះស្រុក ក៏ចាត់អាសនៈផ្សេងៗ (ល្អៗ ដូចដែលគ្រហស្ថគេប្រើ ប្រាស់) ។ ដំបូងទ្រង់ហាមកំណត់អាសន្ទិ បល្ល័ង្ក និងរបស់ញាត់គ, ក្រោយមក ទ្រង់អនុញ្ញាតឲ្យអង្គុយសង្កត់អាសនៈរបស់គ្រហស្ថ (គ្រប់ប្រភេទ) តែមិនឲ្យដេកសង្កត់ ។

## ការថ្វាយវត្តជេតពន

កាលបើស្ដេចយាងដល់ក្រុងសាវត្ថីហើយ អនាថបិណ្ឌិកសេដ្ឋីនិមន្តឆាន់ចង្ហាន់ក្នុងថ្ងៃស្អែក ។ នៅពេលប្រគេនភត្តាហាររួចរាល់ហើយ ក្រាបទូលសួរថា តើគួរបដិបត្តិដូចម្ដេចទាក់ទងទៅនឹងវត្តជេតពន ។ ទ្រង់ត្រាស់ឲ្យថ្វាយដល់សង្ឃ ៤ ទិស ទាំងដែលមកហើយ និងនៅមិនទាន់មកដល់វត្តជេតពន ។

## បញ្ហាលំដាប់អាវុសោកើនឡើង

ទ្រង់ហាមភិក្ខុចាស់វស្សាជាង ដេញភិក្ខុខ្ចីវស្សាដែលកំពុងអង្គុយឆាន់ ដើម្បីចូលទៅអង្គុយ ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកប្រព្រឹត្តដូចនោះ (ព្រះឧបនន្ទមកដល់យឺត ដេញភិក្ខុដទៃ កើតចលាចលក្នុងខណៈឆាន់) ។តែទ្រង់ឲ្យកាន់យកការអង្គុយតាមលំដាប់អាវុសោ ដែលភិក្ខុខ្ចីវស្សាជាងមិនអាចបដិសេធបាន ។

ទ្រង់ហាមដេញយកទីភិក្ខុអាពាធ ដើម្បីកាន់យកតាមលំដាប់អាវុសោ ទ្រង់ពិន័យអាបត្តិទុក្កដដល់ភិក្ខុអ្នកដេញ ។ ភិក្ខុឆព្វគ្គិយយកលេសខ្លួនអាពាធ រើសសេនាសនៈល្អៗ ដោយគិតថា ពុំមាននរណាដេញខ្លួនបានឡើយ ទើបព្រះមានព្រះភាគត្រាស់ឲ្យរៀបចំទីដេកតាមសមគួរដល់ភិក្ខុអាពាធ (មិនមែនរើសតាមខ្លួនឯងពេញចិត្តឡើយ) ។

ឆព្វគ្គិយភិក្ខុអាងលេស យាត់សេនាសនៈ និងកាន់យកសិទ្ធិ ដេញភិក្ខុទាំង ១៧ រូបចេញពីលំនៅ ទ្រង់ហាមធ្វើដូច្នោះ និង ពិន័យអាបត្តិទុក្កដក្នុងករណីហាមឃាត់សេនាសនៈគ្នា ដោយអាង លេស និងពិន័យអាបត្តិបាចិត្តិយក្នុងករណីបណ្តេញ (មាននៅក្នុង សិក្ខាបទទី ៧) ព្រោះប្រារព្ធហេតុទាំងអស់នេះហើយ ទើបព្រះ មានព្រះភាគចាត់ឲ្យមានភិក្ខុកាន់យកសេនាសនៈ គឺចូលទៅអាស្រ័យ នៅដោយតែងតាំងភិក្ខុអ្នកចាត់ចែងសេនាសនៈ ។

## ការរៀបចំទីលំនៅ

ទ្រង់កំណត់គុណសម្បត្តិភិក្ខុរៀបចំទីសេនាសនៈ (សេនា-សនគ្គាហាបកៈ) ៥ ប្រការ គឺ

១.មិនលំអៀងព្រោះស្រឡាញ់

២.មិនលំអៀងព្រោះស្អប់

៣.មិនលំអៀងព្រោះវង្វេង

៤.មិនលំអៀងព្រោះខ្លាច

៥.ស្គាល់សេនាសនៈដែលរៀបចំហើយ និងនៅមិនទាន់បាន រៀបចំ ។

ទ្រង់ណែនាំពិធីសូត្រប្រកាសតែងតាំងភិក្ខុ អ្នកចាត់ចែង សេនាសនៈសង្ឃ និងណែនាំពិធីចាត់ចែង ដោយឲ្យរាប់ភិក្ខុជាមុន ហើយសឹមរាប់ទីដេក រាប់រួចហើយឲ្យចាត់សេនាសនៈតាមចំនួនដែល មាន ។ កាលបើចាត់ចែងរួចរាល់ហើយ ទីដេកមាននៅសល់ ឲ្យ ចាត់តាមចំនួនវិហារ (កុដិ), បើកុដិនៅសល់ ឲ្យចាត់តាមចំនួនបរិ-វេណ, បើបរិវេណនៅសល់ទៀត ឲ្យបែងជាចំណែកតូចៗ ទៀត ។ កាលបើបានទទួលចំណែកតូចៗ ហើយ បើមានភិក្ខុដទៃមក ទោះបី មិនចង់ឲ្យក៏ត្រូវតែឲ្យ ។ ទ្រង់ហាមចាត់ទីនៅដល់ភិក្ខុ ដែលនៅក្រៅ សីមា និងទ្រង់ហាមកាន់យកទីនៅរហូតកាល, អនុញ្ញាតត្រឹមតែ ៣ ខែ បន្ទាប់ពីនោះ ហួងហែងមិនបានឡើយ ។

ទ្រង់សំដែងការចាត់ទីលំនៅ (សេនាសនគ្គាហៈ) ថា មាន ៣ យ៉ាង គឺ

១.ការចាត់ខាងដើម គឺក្នុងថ្ងៃជិតចូលវស្សាដំបូង

២.ការចាត់ខាងក្រោយ គឺក្នុងថ្ងៃជិតចូលវស្សាក្រោយ

៣.ការចាត់ក្រៅពេលចូលវស្សា គឺនៅពេលជិតដល់ថ្ងៃ បវារណា ចាត់ដើម្បីឲ្យចាំវស្សានៅពេលក្រោយ ។

ទ្រង់ហាមភិក្ខុមួយរូបហួងហែងទីនៅ ២ កន្លែង បើធ្វើដូច្នោះ ត្រូវអាបត្តិទុក្កដ ។

## ការអង្គុយឆាបខ្ពស់

ទ្រង់អនុញ្ញាតឲ្យភិក្ខុអ្នកបង្រៀនដែលបួសថ្មី អង្គុយលើអាសនៈស្មើ ឬខ្ពស់ជាងបាន និងឲ្យភិក្ខុជាព្រះថេរៈ (ចាស់ជាង) ដែលជាអ្នករៀនអង្គុយលើអាសនៈស្មើ ឬទាបជាងបាន ដោយសេចក្ដីគោរពនៅក្នុងព្រះធម៌ (បច្ចុប្បន្ននេះ សូម្បីភិក្ខុអ្នកសំដែងធម៌មានវស្សាតិច ក៏ឲ្យអង្គុយលើធម្មាសនៈខ្ពស់ជាងភិក្ខុទាំងពួង) ។

ទ្រង់អនុញ្ញាតឲ្យភិក្ខុដែលមានសិទ្ធិក្នុងការអង្គុយស្មើគ្នា អង្គុយរួមគ្នាបាន គឺភិក្ខុដែលមានវស្សាក្រោម ៣ ឆ្នាំ អង្គុយលាយឡំគ្នាបាន ។ ភិក្ខុដែលមានសិទ្ធិក្នុងការអង្គុយស្មើគ្នា អង្គុយលើគ្រែនិងតាំងតែមួយ គ្រែនិងតាំងក៏បាក់ដួលរលំ ទើបទ្រង់កំណត់ចំនួនក្នុងការអង្គុយមិនឲ្យលើសពី ៣ រូប, គ្រែ និងតាំងក៏នៅតែបាក់ទៀត ទើបឲ្យអង្គុយបានត្រឹមតែ ២ រូប ។ ចំណែកឯទីអង្គុយវែង សូម្បីភិក្ខុមានសិទ្ធិអង្គុយមិនស្មើគ្នា ក៏អនុញ្ញាតឲ្យអង្គុយរួមគ្នាបាន, វៀរលែងតែខ្ទើយ, ស្ត្រី, អ្នកមានអវយវៈភេទពីរ ។ មានបញ្ហាថា ទីដូចម្ដេចទើបចាត់ថាជាទីអង្គុយវែង ? ទើបទ្រង់កំណត់ថា បើអង្គុយចុះគ្នា ៣ នាក់ ចាត់ថាទីអង្គុយវែង យ៉ាងខ្លីបំផុត (អង្គុយច្រើនជាងនោះបាន) ។

## ប្រាសាទ និងអាសនៈផ្សេងៗ

ទ្រង់អនុញ្ញាតឲ្យប្រើប្រាសាទគ្រប់ប្រភេទបាន (ប្រាសាទ គឺផ្ទះដែលមានរាងជាថ្នាក់ៗ ឬជាជាន់ៗ) ។ ចំណែកឯអាសនៈជាដើម រួមមានច្រើនយ៉ាងដែលប្រគេនដល់សង្ឃ ពេលដែលព្រះអយ្យិកា (យាយ) នៃព្រះបាទបសេនទិកោសលអស់ព្រះជន្មនោះ ទ្រង់អនុញ្ញាតឲ្យកាត់ជើងអាសន្ទិ (តាំងបួនជ្រុង) ហើយប្រើបាន ។ ចំណែកឯបល្លង្ក (កៅអីញាត់ពូក) ឲ្យខ្ទេះយករោមសត្វចេញ រួចប្រើបាន, អាសនៈញាត់សំឡី ឲ្យខ្ទេះយកសំឡីមកញាត់ខ្នើយវិញ, ចំណែកឯអាសនៈដទៃទៀត ឲ្យប្រើធ្វើជាកម្រាលបាន ។

## រឿងទីនៅកើតឡើងម្ដងទៀត

ភិក្ខុដែលនៅប្រចាំក្នុងវត្តក្បែរស្រុកជានិច្ចកាល តែងមានភិក្ខុឆ្លងកាត់ទៅមក លំបាកក្នុងការរៀបចំសេនាសនៈ ដើម្បីកែសម្រួលរឿងនេះ ទើបសង្ឃប្រជុំគ្នាព្រមព្រៀងប្រគល់សេនាសនៈ

ឲ្យទៅភិក្ខុមួយរូប ទើបភិក្ខុគ្រប់រូបបានអាស្រ័យនៅដោយការឲ្យនៃភិក្ខុរូបនោះ ។ នៅពេលមានភិក្ខុឆ្លងកាត់ទៅមកសុំស្នាក់នៅ ក៏អាងថា បានលើកឲ្យដល់ភិក្ខុមួយរូបទៅហើយ មិនមានទីឲ្យស្នាក់ទេ ទើបព្រះមានព្រះភាគទ្រង់ដាក់គោលការណ៍បន្ថែម គឺ

## វត្ថុគរុភណ្ឌ លះឱ្យដល់ (បុគ្គលណា) មិនបាន មាន ៥ ពួក

វត្ថុគរុភណ្ឌ ៥ យ៉ាងដែលសង្ឃ ឬគណៈ ឬបុគ្គលមិនអាចលះឲ្យដល់នរណាបាន សូម្បីលះហើយ ក៏មិនឈ្មោះថាជាការលះ អ្នកលះ (ឬលើកឲ្យ) ត្រូវអាបត្តិថុល្លច្ច័យ គឺ

១.វត្ថុ និងទីវត្ថុ

២.វិហារ និងទីវិហារ

៣.គ្រែ, តាំង, ពូក, ខ្នើយ

៤.ឧបករណ៍ លោហៈ គឺ ឆ្នាំងលោហៈ, អាងលោហៈ, ធុងលោហៈ, ខ្ទះលោហៈ, កាំបិតធំ ឬកាំបិតព្រា, ពូថៅ, ដឹង, ចបកាប់ ឬចបជីក, ស្វានសម្រាប់ចោះឈើ (ពន្លាកក៏ចាត់ចូលនៅក្នុងខនេះដែរ)

៥. វល្លិ ដូចជាផ្តៅ, ឫស្សី, ស្មៅជំណោកទន្សាយ ស្មៅយ៉ា បូង, ស្មៅធម្មតា, ដីស្អិត, វត្ថុធ្វើអំពីឈើ, វត្ថុធ្វើអំពីដី (ដែល ហាមមកទាំងអស់នេះ គឺហាមយករបស់សង្ឃធ្វើជារបស់បុគ្គល) ។

បន្ទាប់មកទ្រង់បន្ថែមសេចក្តីឲ្យច្រើនឡើងអំពីពាក្យថា មិនឲ្យលះ មិនឲ្យចែករបស់ ៥ យ៉ាង, បុគ្គលណាលះ ឬចែក ត្រូវអាបត្តិថុល្លច្ច័យ ។

## ការត្រួតត្រាការកសាង

ហាមប្រគល់ការងារកសាង ក្នុងរឿងបន្តិចបន្តួច ដូចជាដាក់ទ្វារ, លាបថ្នាំ, ប្រក់ដម្បូល និងហាមប្រគល់ការងារកសាងអស់ពេលយូររហូតដល់ទៅ ២០-៣០ ឆ្នាំ ឬរហូតអស់មួយជីវិត នៃអ្នកទទួលការងារ ។

ហាមប្រគល់ការងារកសាងវិហារគ្រប់យ៉ាង, ហាមប្រគល់ការងារកសាង ២ យ៉ាងដល់ភិក្ខុមួយរូប ។ ភិក្ខុអ្នកទទួលការងារកសាង មិនអាចអាងសិទ្ធិហួងហែងលំនៅរបស់សង្ឃបានឡើយ ។ ហាមប្រគល់ការងារកសាង ដល់ភិក្ខុនៅក្រៅសីមា ។ ភិក្ខុអ្នកទទួលការងារកសាង អាចគ្រប់គ្រងការងារកសាងបានត្រឹមតែ ៣ ខែ

ហាមគ្រប់គ្រងវហូត កាលបើផុតកំណត់ ៣ ខែហើយ ត្រូវប្រគល់ឲ្យរៀបចំសារជាថ្មី ។

ភិក្ខុដែលកំពុងតែទទួលការងារកសាង កាលបើសឹក ឬធ្វើដំណើរទៅកាន់ទីដទៃជាដើម ត្រូវប្រគល់ឲ្យអ្នកដទៃធ្វើជំនួស ។ បន្ទាប់ពីនោះមក គឺជាការសំដែងសិទ្ធិក្នុងការកសាងថា តើក្នុងករណីដូចម្តេចជារបស់សង្ឃ និងករណីដូចម្តេចជារបស់បុគ្គល ។

## ហាមជញ្ជូនវត្ថុប្រើប្រាស់ទៅកាន់ទីដទៃនិងរក្សាលំនៅ

ហាមជញ្ជូនវត្ថុប្រើប្រាស់ជាប្រចាំនៅក្នុងលំនៅមួយ ទៅកាន់លំនៅមួយទៀត (ខុសបំណងអ្នកប្រគេន), សុំខ្ចីទៅម្តងម្កាលបាន, នាំទៅដើម្បីជួយរក្សាទុកបាន, ផ្លាស់ប្តូរ (ផាតិកម្ម) បាន ករណីរបស់នោះមានតម្លៃខ្ពស់ពេក (មិនគួរដល់សង្ឃនឹងប្រើប្រាស់ខ្លួនឯងបាន) ។ បន្ទាប់ពីនោះ ជាការអនុញ្ញាតវត្ថុប្រើប្រាស់បន្តិចបន្តួចដូចជាវត្ថុជូតជើង និងឲ្យរក្សាលំនៅ មិនឲ្យជាន់ទាំងដែល ជើងទទឹក និងប្រឡាក់ ឬជាន់ទាំងស្បែកជើង ។ ទ្រង់អនុញ្ញាតកន្ទេល ដើម្បីមិនឲ្យស្តោះទឹកមាត់ដាក់លើផ្ទៃ, ទ្រង់ពិន័យអាបត្តិទុក្កដ ដល់អ្នកស្តោះទឹកមាត់ដាក់លើផ្ទៃ ។ ទ្រង់អនុញ្ញាតឲ្យចងជើងគ្រែ តាំង ដើម្បីមិនឲ្យផ្ទៃខូច ។ ទ្រង់ហាមពិតបង្អែកដែលគេលាបពណ៌ និងអនុញ្ញាតឲ្យមានបន្ទះក្តារសម្រាប់ផ្អែក និងឲ្យរុំសំពត់ពីលើក្តារនោះ ដើម្បីមិនឲ្យឆ្កូតទីបផ្អែក ព្រមទាំងអនុញ្ញាតឲ្យដេក ដោយក្រាលកម្រាលជាមុន ។

## អាហារ និងការចែកអាហារ

ទ្រង់អនុញ្ញាតការប្រគេនអាហារបោះចំពោះ, ការនិមន្ត, ការប្រគេនដោយចាប់ស្លាក, ការប្រគេនប្រចាំបក្ស, ការប្រគេនប្រចាំថ្ងៃឧបោសថ, ការប្រគេនប្រចាំថ្ងៃ និងទ្រង់កំណត់គុណសម្បត្តិរបស់ភិក្ខុអ្នកសំដែងអាហារ (ចាត់ភិក្ខុទៅទទួលអាហារក្នុងទីនិមន្ត) ថាមិនត្រូវមានអគតិទាំង ៤ និងដឹងថាសំដែងហើយ ឬនៅមិនទាន់សំដែង (ចាត់ហើយ ឬនៅមិនទាន់បានចាត់) ។ ទ្រង់សំដែងវិធីសូត្រសន្មត គឺតែងតាំងភិក្ខុអ្នកសំដែងអាហារ និងណែនាំវិធីចែកដោយប្រើស្លាក (ចំរៀកឈើ) ឬកំណាត់សំពត់ ។

## ភ្នាក់ងារធ្វើការសង្ឃដទៃទៀត

ទ្រង់ណែនាំឲ្យមានការតែងតាំងភិក្ខុ ដែលមានគុណសម្បត្តិសមគួរទទួលការងារសង្ឃដទៃទៀត ដោយការសូត្រប្រកាស គឺភិក្ខុអ្នកក្រាលសេនាសនៈ, អ្នកមើលឃ្លាំង, អ្នកទទួលចីវរ, អ្នកចែក

ចីវរ, អ្នកចែកភត្ត, អ្នកចែកផ្លែឈើ, អ្នកចែករបស់ទំពា, អ្នកចែករបស់តូចៗ (ដូចជា ម្ជុរ, កាំបិត, ស្បែកជើង), អ្នកចែកសំពត់ (ផ្លូតទឹកភ្លៀង?), អ្នកចែកបាត្រ, អ្នកប្រើមនុស្សធ្វើការវត្ត, អ្នកប្រើសាមណេរ ។

## ៣.សង្ឃភេទខន្ធកៈ (វគ្គពោលអំពីសង្ឃបែកគ្នា)

ដំណាលអំពីរឿងព្រះរាជកុមារនៅក្នុងសក្យត្រកូល គឺភទ្ទិយ-រាជា, អនុរុទ្ធ, អានន្ទ, ភគុ, កិម្ពិល និងព្រះរាជកុមារនៅក្នុងកោសិយត្រកូល គឺទេវទត្ត រួមទាំងឧបាលីដែលជាជាងកោរកាត់ផងត្រូវជា ៧ រូប គ្រប់អង្គយល់ឃើញថា គួរឲ្យឧបាលីបួសមុនខ្លួននឹងបានគោរពដើម្បីទម្លាយទិដ្ឋិមានៈ ។

នៅពេលបួសហើយ ព្រះភទ្ទិយៈបានសម្រេចវិជ្ជា ៣, ព្រះអនុរុទ្ធបានសម្រេចទិព្វចក្ខុ, ព្រះអានន្ទបានសម្រេចជាសោតាបន្ន, ចំណែកឯព្រះទេវទត្តបានសម្រេចឫទ្ធិបុថុជ្ជន (លោកីយ៍) ។

## ព្រះទេវទត្តគិតរឿងធំ

ព្រះទេវទត្តគិតប្រាថ្នាលាភសក្ការៈ ទើបនិមិត្តកាយជាកូនក្មេងតូច ទៅអង្គុយនៅលើភ្លៅរបស់ព្រះរាជកុមារអជាតសត្រូវ (ដែលជាឱរសរបស់ព្រះបាទពិម្ពិសារដែនមគធៈ)
ដើម្បីធ្វើឲ្យរាជកុមារ ជ្រះថ្លា មានលាភសក្ការៈកើតឡើង ហើយក៏គិតប្រាថ្នានឹងគ្រប់គ្រង
គណៈសង្ឃជំនួសព្រះអង្គដោយខ្លួនឯង ។

រឿងនេះ ដឹងដល់ព្រះមោគ្គល្លានត្ថេរ ទើបលោកចូលទៅគាល់ព្រះមានព្រះភាគ ទ្រង់សំដែងសាស្តាគ្រូ ៥ ប្រភេទ ដែលត្រូវអាស្រ័យ ឬប្រាថ្នាការគ្រប់គ្រងអំពីសាវ័ក គឺសាស្តាដែលមានសីលមិនបរិសុទ្ធិ, មានការចិញ្ចឹមជីវិតមិនបរិសុទ្ធិ, មានការសំដែងធម៌មិនបរិសុទ្ធិ, មានការដោះស្រាយមិនបរិសុទ្ធិ, មានញាណទស្សនៈមិនបរិសុទ្ធិ តែសំដែងខ្លួនថាជាអ្នកបរិសុទ្ធិក្នុងផ្លូវទាំង ៥ យ៉ាងនោះ ។ ចំណែកព្រះអង្គពុំចាំបាច់ប្រាថ្នាការគ្រប់គ្រងអំពីសាវ័កឡើយ ពីព្រោះទ្រង់ពុំមែនជាសាស្តាដូច្នោះទេ ។

## ព្រះទេវទត្តសុំគ្រប់គ្រងគណៈសង្ឃ

នៅពេលបានឱកាស ទើបព្រះទេវទត្តចូលទៅគាល់ព្រះមានព្រះភាគ ដោយលេសថា ព្រះអង្គមានព្រះជន្មច្រើនហើយ សូម

ឲ្យទ្រង់ខ្វល់ខ្វាយតិចចុះ និងសុំឲ្យប្រគល់ភិក្ខុសង្ឃមកខ្លួនដើម្បីគ្រប់គ្រង ព្រះមានព្រះភាគទ្រង់បដិសេធដល់ទៅ ៣ ដង ហើយក្នុងគ្រាទី ៣ ទ្រង់ពោលថា សូម្បីសារីបុត្រ និងមោគ្គល្លាន តថាគតក៏នៅមិនប្រគល់ឲ្យគ្រប់គ្រងផង ដូចម្ដេចនឹងអាចប្រគល់ឲ្យទេវទត្តគ្រប់គ្រងបាន ជាហេតុនាំឲ្យទេវទត្តចងអាឃាតនឹងព្រះអង្គលើកដំបូង ។

## ទ្រង់ត្រាស់ឱ្យសុំមតិសង្ឃប្រកាសរឿងទេវទត្ត

ទ្រង់ត្រាស់បញ្ជាឲ្យប្រជុំសង្ឃ ដើម្បីសុំអនុម័តិប្រកាសឲ្យដឹងមិនទទួលស្គាល់ទង្វើគ្រប់យ៉ាង ទាំងតាមផ្លូវកាយ និងវាចារបស់ទេវទត្តថា មិនពាក់ព័ន្ធជាមួយនឹងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងឲ្យសង្ឃសូត្រប្រកាសតែងតាំងព្រះសារីបុត្រជាអ្នកជូនដំណឹង ដល់អ្នកក្រុងរាជគ្រឹះ ។

## ភិក្ខុទេវទត្តញុះញង់ឱ្យក្បត់

ភិក្ខុទេវទត្តញុះញង់ព្រះរាជកុមារអជាតសត្រូវ ឲ្យគិតសម្លាប់ព្រះរាជបិតា ដើម្បីដណ្ដើមរាជសម្បត្តិ ចំណែកឯខ្លួនឯង នឹងសម្លាប់ព្រះពុទ្ធជាម្ចាស់ ដើម្បីធ្វើជាព្រះពុទ្ធ ។ តែព្រះរាជុមារធ្វើការភ្លាត់ត្រូវចាប់បាន ខណៈពេលទាហានចូលវាំង មហាអាមាត្យថ្វាយព្រះយោបល់ឲ្យសម្លាប់ទាំងភិក្ខុទេវទត្ត និងព្រះរាជកុមារ រួមទាំងភិក្ខុទាំងឡាយ (ដែលជាបក្សពួក) ផងដែរ ។ អ្នកខ្លះឲ្យសម្លាប់ តែភិក្ខុទេវទត្ត និងព្រះរាជកុមារ, អ្នកខ្លះទៀត យល់ថាមិនគួរ សម្លាប់ទាំងអស់ ។

## ការប្រទូសរ៉ាយព្រះពុទ្ធលើកដំបូង

ព្រះបាទពិម្ពិសារទ្រង់ជ្រាបថា ព្រះរាជកុមារចង់បានរាជ-សម្បត្តិ ទ្រង់ក៏ប្រគល់រាជសម្បត្តិឲ្យ ទេវទត្តក៏មានអំណាចច្រើនឡើង ទើបសុំកម្លាំងអំពីព្រះបាទអជាតសត្រូវ បញ្ជូនមនុស្សទៅចាំធ្វើឃាតព្រះពុទ្ធ ហើយបញ្ជាថា បើសម្លាប់ហើយឲ្យទៅផ្លូវនោះៗ ហើយ បញ្ជូនមនុស្ស ២ នាក់ទៀត ទៅលបចាំសម្លាប់ អ្នកដែលទៅធ្វើឃាតព្រះពុទ្ធ, រួចហើយបញ្ជូនមនុស្ស ៤ នាក់ បន្ថែមទៀតទៅលបចាំសម្លាប់មនុស្ស ២ នាក់នោះទៀត, បញ្ជាមនុស្ស ៨ នាក់ ទៅលបចាំសម្លាប់មនុស្ស ២ នាក់នោះ, និងបញ្ជាមនុស្ស ១៦ នាក់ ទៅលបចាំសម្លាប់មនុស្ស ៨ នាក់នោះ (ដើម្បីបំបិទមាត់) ។ ប៉ុន្តែ អ្នកទាំងអស់នោះ ត្រឡប់ជាជ្រះថ្លានៅក្នុងព្រះពុទ្ធ-សាសនា ប្រេដ្ឋាខ្លួនជាឧបាសកទាំងអស់គ្នា ព្រះមានព្រះភាគទ្រង់

បញ្ជូនមនុស្សទាំងអស់នោះ ឲ្យត្រឡប់ទៅកាន់ផ្លូវដទៃពីទេវទត្តបញ្ជា ទើបមិនមាន ការសម្លាប់គ្នាកើតឡើង ហើយនៅពេលអ្នកឃ្លាំចាំមើល ឃើញយូរពេក នឹកសង្ស័យមកសួរព្រះពុទ្ធជាម្ចាស់ ទ្រង់ក៏សំដែងធម៌ឲ្យស្តាប់ គ្រប់គ្នាក៏ប្រកាសខ្លួនជាឧបាសកទាំងអស់ ។

## ការប្រទុស្តរ៉ាយលើកទី ២

នៅពេលប្រើមនុស្សទៅសម្លាប់មិនសម្រេច ទើបទេវទត្តសម្រេចចិត្តធ្វើដោយខ្លួនឯង គឺឡើងទៅលើភ្នំគិជ្ឈកូដ ចាំប្រមៀលដុំថ្មដ៏ធំឲ្យធ្លាក់ចុះមកកិនសង្កត់ព្រះពុទ្ធជាម្ចាស់ តែមិនសម្រេច គ្រាន់តែបំនែកថ្មដែលបែក ខ្ទាតមកប៉ះព្រះបាទធ្វើឲ្យពុះពងប៉ុណ្ណោះ ។ ភិក្ខុទាំងឡាយបារម្ភ ទើបនាំគ្នាមកគាល់រក្សាព្រះពុទ្ធជាម្ចាស់ ជជែកគ្នាដោយសំឡេងខ្លាំង (ក្រែងថាទេវទត្តបញ្ជូនមនុស្សមកប្រទូស្ត ព្រះអង្គទៀត ព្រោះបានកម្លាំងអំពីព្រះបាទអជាតសត្រូវ) ប៉ុន្តែ ព្រះមានព្រះភាគត្រាស់ឲ្យភិក្ខុទាំងនោះត្រឡប់ទៅវិញ ពុំចាំបាច់ឲ្យមានអ្នកនៅឃ្លាំចាំរក្សាព្រះអង្គឡើយ ហើយត្រាស់ថា តថាគតមិនបរិ-និព្វានដោយសារការព្យាយាមអំពីអ្នកដទៃឡើយ ។ រួចហើយត្រាស់សំដែងអំពីសាស្តា ៥ ប្រភេទ ដែលត្រូវប្រាថ្នាការរក្សាអំពីសាវ័កដូចបានត្រាស់ជាមួយនឹងព្រះមោគ្គល្លានដែរ ។

## ការប្រទុស្តលើកទី ៣

ព្រះទេវទត្តទៅរកអ្នកគង្វាលដំរីព្រះរាជា ដោយសម្អាងខ្លួនថា ជាញាតិវង្សរបស់ព្រះរាជា និងសម្អាងខ្លួនថា អាចដំឡើងតំណែង បន្ថែមអាហារ បន្ថែមប្រាក់ខែបាន រួចបញ្ជាឲ្យលែងដំរីនាឡាគិរីទៅ ព្រេចព្រះអង្គ នៅពេលដែលឃើញព្រះអង្គយាងមកតាមផ្លូវនោះៗ ។ គង្វាលដំរីព្រមធ្វើតាម នៅពេលឃើញព្រះពុទ្ធជាម្ចាស់ ស្តេចយាងមកក៏លែងដំរីឲ្យទៅព្រេច ភិក្ខុទាំងឡាយឃើញដូច្នោះ ក៏ក្រាបទូលព្រះអង្គឲ្យយាងចេញពីផ្លូវនោះ តែទ្រង់បដិសេធ រួចក៏ត្រាស់ថា តថាគតមិនបរិនិព្វានដោយសារការព្យាយាម អំពីអ្នកដទៃឡើយ ។ នៅក្នុងហេតុការណ៍នេះ មានអ្នករង់ចាំមើលត្រៀបត្រា នៅលើទីខ្ពស់ ព្រះមានព្រះភាគទ្រង់ផ្សាយមេត្តាចិត្ត ដំរីក៏យកប្រមោយចាប់ធូលីនៅលើព្រះបាទរោយចុះលើក្បាល (ខ្លួនឯង) រួចក៏ត្រឡប់ទៅកាន់រោងដូចដើមវិញ ។

## ព្រះទេវទត្តសុំស្នើបដិបត្តិ ៥ យ៉ាង

ព្រះទេវទត្តគិតធ្វើគតព្រះអង្គមិនបានសម្រេច ទើបបបួលបក្សពួកមានព្រះកោកាលិកៈជាដើម គិតនាំគ្នាសុំស្នើឧបដិបត្តិ ៥ ប្រការ ដើម្បីសំដែងខ្លួនថាជាអ្នកម៉ឺងម៉ាត់ គឺ

១.ឲ្យភិក្ខុនៅព្រៃអស់មួយជីវិត ចូលទៅកាន់ស្រុកមានទោស

២.ឲ្យបិណ្ឌបាតអស់មួយជីវិត ទទួលនិមន្តមានទោស

៣.ឲ្យប្រើប្រាស់សំពត់បង្សុកូលអស់មួយជីវិត ទទួលគហបតីចីវរ (សំពត់គេប្រគេន) មានទោស ។

៤.ឲ្យនៅក្រោមដើមឈើអស់មួយជីវិត ចូលកាន់ទីប្រក់ទីបាំងមានទោស ។

៥.ហាមឆាន់សាច់សត្វអស់មួយជីវិត ឆាន់មានទោស ។

នៅពេលបានឱកាសហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគក្រាបទូលសុំស្នើឧបដិបត្តិទាំង ៥ នោះ ។ ព្រះមានព្រះភាគទ្រង់បដិសេធ គឺក្នុងចំណុច ៤ ខខាងដើម អនុញ្ញាតឲ្យភិក្ខុបដិបត្តិតាមការស្ម័គ្រចិត្ត មិនបង្ខាប់ ជាពិសេសខទី ៤ ទ្រង់អនុញ្ញាតឲ្យនៅក្រោមដើមឈើ បានត្រឹម ៨ ខែ (រដូវភ្លៀងមិនអនុញ្ញាតឲ្យនៅក្រោមដើមឈើ) និងខទី ៥ ការឆាន់សាច់សត្វ ទ្រង់អនុញ្ញាតសាច់សត្វ ដែលបរិសុទ្ធិ ដោយលក្ខណ្ឌ ៣ ប្រការ គឺមិនបានឃើញ មិនបានឮ និងមិននឹកគិតរង្កៀសថាគេសម្លាប់ដើម្បីខ្លួន ។

ព្រះទេវទត្តសប្បាយចិត្ត នៅពេលដែលបានប្រកាសថា ខ្លួនតឹងរឹងជាងព្រះពុទ្ធ ទើបដើរប្រកាសអួតពេញក្រុងរាជគ្រឹះដល់រឿងសុំស្នើនោះ ។

## ធ្វើសង្ឃឲ្យបែកគ្នា

លុះដល់ថ្ងៃឧបោសថ ទេវទត្តក៏បបួលបក្សពួករបស់ខ្លួនបានច្រើន (ជាភិក្ខុបួសថ្មី) រួចហើយនាំភិក្ខុទាំងនោះបែកទៅធ្វើឧបោ-
សថនៅនាតំបន់គយាសីសៈ(នៅក្បែរកន្លែងព្រះអង្គត្រាស់ដឹង) ។

## ព្រះទេវទត្តក្អួតឈាម

ព្រះមានព្រះភាគទ្រង់បញ្ជូនព្រះសារីបុត្រ និងព្រះមោគ្គល្លានទៅពន្យល់ភិក្ខុដែលចូលក្រុមទេវទត្តកុំឲ្យយល់ខុស ។ ទេវទត្តយល់ថាព្រះសារីបុត្រ និងព្រះមោគ្គល្លានមកចូលក្រុមជាមួយខ្លួន ក៏ប្រគល់ឲ្យព្រះសារីបុត្រអប់រំភិក្ខុទាំងនោះ ខ្លួនឯងក៏ទៅរកទីសម្រាក ព្រះសារីបុត្រសំដែងធម៌ឲ្យភិក្ខុទាំងនោះស្តាប់ បានសម្រេចធម្មចក្ខុ (ជាសោតាបន្ន) រួចហើយក៏ត្រឡប់មកវិញ មានភិក្ខុទាំងនោះចំនួន

ប្រមាណ ៥០០ រូបតាមមកជាមួយ ព្រះកោកាលិកៈប្រញាប់ដាស់ព្រះទេវទត្ត រួចប្រាប់ឲ្យដឹងដំណឹង, ព្រះទេវទត្តដល់ថ្នាក់ក្អួតធ្លាក់ឈាម ។

ព្រះមានព្រះភាគ ក៏ឲ្យភិក្ខុទាំងនោះសំដែងអាបត្តិថុល្លច្ច័យព្រោះប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃឲ្យបែកគ្នា និងត្រាស់សរសើរព្រះសារីបុត្រថាមានលក្ខណៈសម្បត្តិធ្វើជាទូត ពីព្រោះប្រកបដោយអង្គ ៨ គឺ

១.ស្តាប់អ្នកដទៃ
២.ធ្វើឲ្យអ្នកដទៃស្តាប់តាមខ្លួន
៣.ដល់ព្រមដោយការសិក្សា
៤.ដល់ព្រមដោយការទ្រទ្រង់ចាំបានល្អ
៥.យល់ដឹងពាក្យអ្នកដទៃ
៦.ធ្វើឲ្យអ្នកដទៃយល់ពាក្យរបស់ខ្លួន
៧.ឆ្លាតឈ្លាសក្នុងការជាប្រយោជន៍និងមិនជាប្រយោជន៍
៨. មិនដឹកនាំឲ្យឈ្លោះគ្នា

លុះត្រាស់រួចហើយ ទ្រង់ក៏សំដែងធម្មិកថាជាច្រើនរឿង ។

## ការប្រេះឆា និងការបែកបាក់នៃសង្ឃ

ទ្រង់សំដែងរឿង "សង្ឃរាជី គឺការប្រេះឆានៃសង្ឃ" ថា បើភិក្ខុពីរក្រុម នៅមិនទាន់គ្រប់ក្រុមម្នាង ៤ រូបទេ គ្រាន់តែជាការប្រេះឆានៃសង្ឃប៉ុណ្ណោះ នៅមិនទាន់ក្លាយជា "សង្ឃភេទ គឺការបែកបាក់នៃសង្ឃ" ឡើយ ។ លុះត្រាតែទាំងពីរក្រុមមានចាប់ពី ៤ រូបឡើងទៅ ហើយមានភិក្ខុទី ៩ សូត្រប្រកាស ទើបឈ្មោះថាជាការប្រេះឆា និងការបែកបាក់នៃសង្ឃ ។

## នរណាអាចធ្វើឱ្យសង្ឃបែកគ្នា និងមិនបែកគ្នា

១.ភិក្ខុនី ២.សិក្ខមានា ៣.សាមណេរ ៤.សាមណេរី ៥.ឧបាសក ៦.ឧបាសិកា ។

បុគ្គល ៦ ប្រភេទនេះ មិនអាចធ្វើឲ្យសង្ឃបែកគ្នាបានឡើយ ។

បកតត្តភិក្ខុ មានសង្វាសស្មើគ្នា នៅក្នុងសីមាតែមួយ ទើបធ្វើសង្ឃឲ្យបែកគ្នាបាន ។

## មូលហេតុធ្វើឱ្យសង្ឃបែកគ្នា និងសាមគ្គីគ្នា

មាន ១៨ ខ គឺ

១.សំដែងអធម៌ថាជាធម៌

២.សំដែងធម៌ថាជាអធម៌

៣.សំដែងអវិន័យថាជាវិន័យ

៤.សំដែងវិន័យថា ជាអវិន័យ

៥.សំដែងខដែលព្រះពុទ្ធមិនបានត្រាស់ ថាទ្រង់បានត្រាស់

៦.សំដែងខដែលព្រះពុទ្ធត្រាស់ទុក ថាទ្រង់មិនបានត្រាស់ទុក

៧.សំដែងខដែលព្រះពុទ្ធមិនបានប្រព្រឹត្ត ថាទ្រង់បានប្រព្រឹត្ត

៨.សំដែងខដែលព្រះពុទ្ធប្រព្រឹត្ត ថាទ្រង់មិនបានប្រព្រឹត្ត

៩.សំដែងខដែលព្រះពុទ្ធមិនបានបញ្ញត្ត ថាទ្រង់បានបញ្ញត្តិ

១០.សំដែងខដែលព្រះពុទ្ធបានបញ្ញត្ត ថាទ្រង់មិនបានបញ្ញត្ត

១១.សំដែងវត្ថុមិនមែនអាបត្តិ ថាជាអាបត្តិ

១២.សំដែងអាបត្តិ ថាមិនមែនអាបត្តិ

១៣.សំដែងអាបត្តិស្រាល ថាធ្ងន់

១៤.សំដែងអាបត្តិធ្ងន់ ថាស្រាល

១៥.សំដែងអាបត្តិមិនមានចំណែកសល់ថាមានចំណែកសល់

១៦. សំដែងអាបត្តិមានចំណែកសល់ថា ជាអាបត្តិមិនមានចំណែកសល់ ។

១៧.សំដែងអាបត្តិគ្រោតគ្រាតថាជាអាបត្តិមិនគ្រោតគ្រាត

១៨.សំដែងអាបត្តិមិនគ្រោតគ្រាតថាជាអាបត្តិគ្រោតគ្រាត រួចហើយធ្វើឧបោសថ ធ្វើបវារណា និងធ្វើសង្ឃកម្មបែកគ្នា ។

ចំណែកហេតុដែលនាំឲ្យសង្ឃសាមគ្គីគ្នា ក៏មាន ១៨ យ៉ាងដូចគ្នាដែរ ប៉ុន្តែចំណុចដែលផ្ទុយគ្នា គឺសំដែងត្រូវតាមការពិតហើយ មិនធ្វើឧបោសថបែកគ្នា មិនធ្វើបវារណាបែកគ្នា និងមិនធ្វើសង្ឃកម្មបែកគ្នា ។

## **ការធ្វើសង្ឃឱ្យបែកគ្នា ជាហេតុនាំឱ្យទៅកាន់អបាយ និងមិនទៅកាន់អបាយ**

ទ្រង់សំដែងគោលការណ៍ធ្វើសង្ឃឲ្យបែកគ្នា មានទោសជាហេតុនាំឲ្យទៅកាន់អបាយ និងមិនជាហេតុនាំឲ្យទៅកាន់អបាយ ដោយ បង្ហាញអំពីការបរិសុទ្ធិនៃចិត្ត និងចេតនា គឺហេតុដែលនាំឲ្យទៅកាន់ អបាយនោះ ដឹងថាខុសធម៌វិន័យ តែក្លែងសំដែងថា ត្រូវតាម ធម៌វិន័យ ចំណែកឯហេតុដែលមិននាំឲ្យទៅកាន់អបាយនោះ គឺធ្វើដោយសេចក្ដីបរិសុទ្ធិនៃចិត្ត និងដោយយល់ថា រឿងដែលប្រកែកតវ៉ាគ្នានោះ ហេតុផលរបស់ខ្លួនត្រឹមត្រូវតាមធម៌វិន័យ ។

### **៤.វត្តក្ខន្ធកៈ** (ពោលអំពីវត្ត ឬឧបដិបត្តិ) ១៤

### **១.អាគន្តុកវត្ត** (ឧបដិបត្តិរបស់អ្នកមកដល់ថ្មី)

អាគន្តុកភិក្ខុ (គឺភិក្ខុដែលមកអំពីវត្តដទៃ) បដិបត្តិមិនត្រឹមត្រូវតាមមារយាទនៃអាគន្តុកៈ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តវត្ត ឬខបដិបត្តិទុក ដូច (រៀបរាប់ដោយសង្ខេប) តទៅនេះ ៖

អាគន្តុកភិក្ខុ កាលចូលទៅកាន់វត្ត (ដែលខ្លួនសុំស្នាក់អាស្រ័យ) ត្រូវដោះស្បែកជើងគោះ (ដី) ចេញទាបៗ តម្លោះឆត្រ ដោះចីវរដែលឃ្លុំចេញ រួចហើយគ្រង រួចសឹមដើរទៅរកភិក្ខុដែលនៅក្នុងវត្ត ដាក់បាត្រចីវរចុះ អង្គុយនៅក្នុងទីដ៏សមគួរ បន្ទាប់មកត្រូវសួររកទឹកដឹក ទឹកប្រើប្រាស់ បើត្រូវការទឹកដឹកក៏គប្បីដឹក បើត្រូវការទឹកប្រើប្រាស់ ក៏គប្បីប្រើទឹកលាងជើង វិធីលាងជើងត្រូវយកដៃម្ខាងចាក់ទឹក យកដៃម្ខាងទៀតលាង រួចហើយត្រូវសួររកសំពត់ជូតជើង វិធីជូតជើង គឺត្រូវយកសំពត់ស្ងួតជូតមុន រួចសឹមយកសំពត់សើមជូតតាមក្រោយ រួចហើយត្រូវបោកសំពត់ជូតជើងពូតឲ្យស្ងួតហាលថ្ងៃចេញ ។ បើភិក្ខុនៅក្នុងវត្តចាស់ជាង គប្បីធ្វើការថ្វាយបង្គំ បើក្មេងជាងក៏ត្រូវបើកឱកាសឲ្យលោកធ្វើការថ្វាយបង្គំ បន្ទាប់ត្រូវសួររកសេនាសនៈ (កន្លែងស្នាក់នៅ) សួរដល់ទីដែលគួរទៅ និងមិនគួរទៅ សួរដល់ត្រកូលដែលខ្លួនសន្មតថាជាសេក្ខៈ សួររកបង្គន់, ទឹកដឹក, ទឹកប្រើប្រាស់, ឈើច្រត់, កតិកា-សង្ឃ, កាលដែលគួរចូល និងគួរចេញចាកវត្ត ។ កាលបើលំនៅមិនមានអ្នកគ្រប់គ្រង គួរគោះទ្វាររង់ចាំមួយស្របក់ រួចសឹមដកគន្លឹះ ប្រាទទ្វារ ឈរនៅខាងក្រៅ បើអាចធ្វើការសម្អាតបាន ក៏គួរធ្វើ ។

## ២.អាវាសិកវត្ត (ខបដិបត្តិរបស់ម្ចាស់លំនៅ)

ភិក្ខុម្ចាស់លំនៅ (អ្នកនៅប្រចាំក្នុងវត្ត) មិនសូវអើពើចំពោះអាគន្តុកភិក្ខុ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តវត្ត ដូច (មានរៀបរាប់ដោយសង្ខេប) តទៅនេះ ៖

កាលបើឃើញភិក្ខុចាស់វស្សាជាង គប្បីក្រាលអាសនៈ តម្កល់ទឹកលាងជើង តាំងទ្រជើង គ្រឿងជូតជើង ក្រោកទទួលៗ យកបាត្រនិងចីវរ សួរដល់ (សេចក្តីត្រូវការ) ទឹកឆាន់ ទឹកប្រើប្រាស់ បើអាចជូតស្បែកជើងឲ្យបាន ក៏គួរជូត រួចហើយក្រាបសំពះ និងប្រាប់ឲ្យដឹងនូវរឿងផ្សេងៗ ដែលគួរដឹង ដូចជា បង្គន់ កតិកាសង្ឃជាដើម ។

បើអាគន្តុកភិក្ខុក្មេងវស្សាជាង ត្រូវអង្គុយប្រាប់ បង្ហាញកន្លែងដាក់បាត្រ និងចីវរ ទីអង្គុយ ប្រាប់ទឹកដឹក, ទឹកប្រើប្រាស់, ប្រាប់សំពត់ជូតជើង បើកឱកាសឲ្យថ្វាយបង្គំ និងប្រាប់រឿងផ្សេងៗ ដែលគួរប្រាប់ ។

## ៣.គមិកវត្ត (ឧបដិបត្តិរបស់ភិក្ខុអ្នកចេញដំណើរ)

សេចក្តីថា គមិកភិក្ខុ ភិក្ខុអ្នកចេញចាកអាវាសទៅកាន់ទីដទៃ គប្បីទុកដាក់គ្រឿងឈើមានគ្រែ និងតាំងជាដើមដែលជារបស់សង្ឃ និងគ្រឿងដី ហើយបិទទ្វារ បិទបង្អួច ប្រគល់សេនាសនៈឲ្យស្រេចដល់ភិក្ខុ បើមិនមានភិក្ខុ គប្បីប្រគល់ឲ្យដល់សាមណេរ បើមិនមានសាមណេរ គប្បីប្រគល់ឲ្យដល់អ្នករក្សាវត្ត បើអ្នករក្សាវត្តមិនមានគប្បីប្រាប់ដល់ឧបាសក បើមិនមានអ្នកណាមួយ គប្បីតម្កល់គ្រែលើដុំថ្ម ៤ ដុំ ហើយលើកគ្រែតម្រួតលើគ្រែ តាំងតម្រួតលើតាំង ដាក់គ្រឿងសេនាសនៈ មានពូកខ្នើយជាដើមទុកខាងលើ ទុកដាក់គ្រឿងឈើ គ្រឿងដី បិទបង្អួចហើយសឹមចេញទៅ បើកុដិភ្លៀងលិចបាន កាលអាចនឹងប្រក់បានគប្បីប្រក់ ឬគប្បីធ្វើឧស្សាហ៍ថាធ្វើដូចម្តេចគប្បីនឹងប្រក់បាន បើបានយ៉ាងនេះជាការល្អ បើមិនបានទេគប្បីតម្កល់គ្រែលើដុំថ្ម ៤ ទុកក្នុងឱកាសដែលភ្លៀងមិនបានលិចហើយរៀបចំទុកដាក់ដូចមុននោះចុះ បើកុដិវិហារទាំងអស់ភ្លៀងលិចបាន កាលអាចនឹងនាំទៅបាន ក៏គប្បីនាំទៅផ្ញើទុកក្នុងស្រុក ឬគប្បីធ្វើឧស្សាហ៍ថា ដូចម្តេចនឹងគប្បីនាំចូលទៅផ្ញើក្នុងស្រុកបាន បើបានដូច្នេះជាការល្អ បើមិនបានទេ គប្បីតម្កល់គ្រែតាំងលើដុំថ្ម ៤ ដុំក្នុងទីវាល ហើយរៀបចំទុកដាក់របស់ទាំងពួងដូចមុន ហើយគ្របដោយស្មៅ ឬស្លឹកឈើ ទើបជៀសចេញទៅដោយគិតថា ធ្វើម្តេចហ្ន៎ សូម្បីអវយវៈ មានមេគ្រែ មេតាំងជាដើមនឹងគប្បីនៅសល់ខ្លះដូច្នេះ ។ សេនាសនៈដែលត្រូវប្រគល់នោះ ចំពោះតែសេនាសនៈដែលធ្វើដោយស្មៅ និងស្លឹកឈើ ដែលគួរកណ្ដៀរកាត់ និងឡើងបាន សេនាសនៈណាគេធ្វើខ្លួងសិលា ឬលើសសរថ្មក្នុងទីដែលកណ្ដៀរឡើងមិនបាន សេនាសនៈនោះ សូម្បីមិនប្រាប់ មិនប្រគល់ហើយទៅ ក៏មិនត្រូវអាបត្តិដែរ ។

## ៤.អនុមោទនវត្ត (វត្តគឺការធ្វើអនុមោទនា)

ខមួយ ទ្រង់អនុញ្ញាតទុកថា តថាគតអនុញ្ញាតឲ្យអនុមោទនាក្នុងរោងឆាន់ ។ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈអនុមោទនាក្នុងរោងឆាន់ ។ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរានុត្ថេរ ៤ រូប ៥ រូប អង្គុយ ចាំនៅក្នុងរោងឆាន់ ។

អដ្ឋកថាពន្យល់ថា ព្រះសង្ឃត្ថេរអង្គុយចាំ ដើម្បីនឹងអនុ-មោទនា ភិក្ខុជាលំដាប់ចុះទៅ គប្បីអង្គុយចាំ ៤ រូបដោយលំដាប់ កាលអនុត្ថេរអង្គុយចាំដើម្បីអនុមោទនា ឲ្យព្រះមហាថេរជាមួយនឹងភិក្ខុបន្ទាប់ចុះទៅទៀត ៣ រូប អង្គុយរង់ចាំ កាលថេរៈទី ៥ អង្គុយដើម្បីអនុមោទនា ឲ្យថេរៈ ៤ រូបខាងលើអង្គុយរង់ចាំ កាល

ព្រះសង្ឃត្ថេរនិមន្តឲ្យភិក្ខុកំឡោះអង្គុយខាងចុងអនុមោទនានោះ ទាំង ៤ រូបតាំងអំពីព្រះសង្ឃត្ថេរចុះទៅ គប្បីអង្គុយរង់ចាំ បើភិក្ខុអ្នកអនុមោទនាពោលថា លោកចូរទៅចុះ កិច្ចដែលនឹងគប្បីចាំមិនមានដូច្នេះនឹងទៅក៏គួរ ។ កាលព្រះថេរៈពោលថា យើងនឹងទៅ លោកចូរនៅចុះ អ្នកអនុមោទនាពោលថា លោកចូរទៅចុះ សូម្បីដូច្នេះក៏គួរ ។ សូម្បីតាំងចិត្តថា យើងនឹងទៅរង់ចាំនៅក្រៅភូមិ ចេញទៅក្រៅភូមិហើយ សូម្បីនឹងបង្គាប់ភិក្ខុជាសិស្សរបស់ខ្លួនឲ្យនៅចាំអ្នកអនុមោទនាហើយទៅ ក៏គួរ ។ បើគ្រហស្ថគេនិមន្តភិក្ខុមួយរូប ឲ្យអនុមោទនាតាមគាប់ចិត្តរបស់គេ ភិក្ខុនោះកាលបើអនុមោទនា ក៏មិនត្រូវអាបត្តិ ព្រោះមិនជាភារៈរបស់មហាថេរ តែថាក្នុងខុបនសិន្ន-កថាពោលថា កាលមនុស្សគេនិមន្តឲ្យសំដែងធម៌ ត្រូវប្រាប់ព្រះមហាថេរជាមុន ។ ដែលត្រូវរង់ចាំនោះ ចំពោះតែភិក្ខុដែលព្រះមហាថេរនិមន្តឲ្យអនុមោទនា ។ បើមានករណីយកិច្ច មានការឈឺបន្ទោបង់ខច្ចារៈជាដើម គប្បីប្រាប់ភិក្ខុដែលអង្គុយជាលំដាប់សិនហើយទៅចុះ ។

## ៥.ភត្តគ្គវត្ត (វត្តនៅក្នុងរោងឆាន់)

មុននឹងទ្រង់បញ្ញត្តខបដិបត្តិនៅក្នុងរោងឆាន់ ទ្រង់បានអនុញ្ញាតឲ្យអនុមោទនានៅក្នុងរោងឆាន់ និងឲ្យមានភិក្ខុជាថេរៈ និងអនុត្ថេរ ៤-៥ រូប នៅជាសំឡាញ់ជាមួយព្រះថេរៈដើម្បីធ្វើការអនុមោទនា (សម័យមុន ធ្វើអនុមោទនាតែព្រះថេរៈមួយរូប), កាលបើមានធុរៈចាំបាច់ ឲ្យព្រះថេរៈត្រឡប់មុនបាន ហើយឲ្យព្រះអនុត្ថេរបន្ទាប់មកជំនួសបាន រួចហើយទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុដែលបដិបត្តិពុំត្រឹមត្រូវ ទើបទ្រង់បញ្ញត្តវត្តនៅក្នុងរោងឆាន់ គឺ

កាលបើមានអ្នកប្រាប់វេលាភត្តនៅក្នុងវត្ត ឲ្យស្លៀកដណ្តប់ជាបរិមណ្ឌល ចងវត្ថពន្ធបង្កេះ កាន់បាត្រចូលទៅក្នុងស្រុកដោយល្អ មិនប្រញាប់ប្រញាល់ មិនត្រូវដើរពីមុខព្រះថេរៈ និងបដិបត្តិតាមសេក្ខិយវត្តអំពីការចូលទៅ និងការអង្គុយនៅក្នុងស្រុកគ្រប់ៗ មិនត្រូវអង្គុយជ្រៀតបៀតព្រះថេរៈ មិនត្រូវអង្គុយពាំងទីអង្គុយរបស់ភិក្ខុដែលក្មេងវស្សាជាង មិនត្រូវអង្គុយសង្កត់សង្ឃាដីនៅក្នុងស្រុក កាលបើមានគេប្រគេនទឹក ត្រូវចាប់បាត្រដោយដៃទាំងពីរទទួលទឹក រួចហើយត្រូវលាងបាត្រ បើមានទីសម្រាប់ចាក់ទឹកត្រូវលាងចាក់ទឹកឲ្យទាបកុំឲ្យខ្ទាតប្រឡាក់ភិក្ខុដទៃ ឬប្រឡាក់សង្ឃាដី ។ បើមិនមានទីសម្រាប់ចាក់ទឹក ត្រូវចាក់លើដីកុំឲ្យខ្ទាត ប្រឡាក់ភិក្ខុដទៃ ឬប្រឡាក់សង្ឃាដី ។ កាលបើមានគេប្រគេនភត្ត ត្រូវចាប់បាត្រដោយដៃទាំងពីរ ។ បើមានទឹកដោះថ្លា ប្រេង ឬសម្ល ឲ្យព្រះថេរៈ

ប្រាប់គេ ដាក់ល្មមសមនឹងបាយ ត្រូវបដិបត្តិតាមសេក្ខិយវត្តអំពីការទទួលបិណ្ឌបាត និងការឆាន់អាហារគ្រប់ខ ។ ព្រះថេរៈមិនត្រូវទទួលទឹកទេ រហូតដល់ភិក្ខុទាំងឡាយឆាន់រួចសិន ។ កាលបើមានគេប្រគេនទឹក ត្រូវយកដៃទាំងពីរចាប់បាត្រទទួលទឹក បើមានទីសម្រាប់ចាក់ទឹក ត្រូវចាក់ទាបៗ មិនឲ្យខ្ទាតប្រឡាក់ភិក្ខុដទៃ ឬសង្ឃាដី ។ល ។ កាលបើដល់ពេលត្រូវត្រឡប់ គប្បីឲ្យភិក្ខុក្មេងវស្សាជាងត្រឡប់ទៅមុន ដោយអាការល្អតាមសេក្ខិយវត្តទាក់ទងទៅនឹងការចូលទៅកាន់ស្រុក ។

## ៦.បិណ្ឌចារិកវត្ត (វត្តរបស់ភិក្ខុអ្នកបិណ្ឌបាត)

ភិក្ខុអ្នកបិណ្ឌបាតនៅពេលជិតចូលទៅកាន់ស្រុក ត្រូវស្លៀកដណ្តប់ឲ្យបានល្អ និងត្រូវបដិបត្តិខណៈពេលចូលទៅកាន់ស្រុក (ដូចភិក្ខុអ្នកចូលទៅឆាន់នៅក្នុងស្រុក) តាមសេក្ខិយវត្ត កាលបើចូលទៅកាន់លំនៅ ត្រូវពិនិត្យមើលផ្លូវចេញចូល មិនត្រូវចេញចូលដោយប្រញាប់រួសរាន់ មិនត្រូវឈរឆ្ងាយ ឬជិតពេក មិនត្រូវឈរយូរ ឬរហ័សពេក ត្រូវសង្កេតមើលថា គេចង់ប្រគេន ឬមួយក៏អត់ បើគេសំដែងអាការនឹងប្រគេន ត្រូវឈរចាំ ។ បើគេប្រគេនអាហារ (ដាក់បាត្រ) ត្រូវលើកសង្ឃាដីដោយដៃឆ្វេង បញ្ចេញបាត្រដោយដៃស្តាំ ចាប់បាត្រដោយដៃទាំងពីរទទួលអាហារ ។ មិនត្រូវសំឡឹងមើលមុខអ្នកប្រគេន ត្រូវសង្កេតមើលថា គេធ្វើអាការប្រគេនសម្ល ឬមួយក៏អត់ បើគេសំដែងអាការប្រគេន ត្រូវឈរ (រង់ចាំ) ពេលគេប្រគេនរួចហើយ ត្រូវបិទបាត្រដោយសង្ឃាដីត្រឡប់ទៅដោយល្អ មិនត្រូវប្រញាប់ប្រញាល់ពេកទេ ។ (បន្ទាប់អំពីនោះ ទ្រង់សំដែងសេក្ខិយវត្តទាក់ទងទៅនឹងការចូលស្រុកគ្រប់ខដែលភិក្ខុអ្នកបិណ្ឌបាត្រត្រូវបដិបត្តិ) ពេលបិណ្ឌបាត្ររួចរាល់ហើយភិក្ខុរូបណាត្រឡប់ទៅមុន ត្រូវក្រាលអាសនៈ (អង្គុយ) តម្កល់ទឹកលាងជើង តាំងទ្រជើង គ្រឿងជូតជើងទុក ត្រូវលាងភាជនៈឲ្យជ្រះសំណល់ អាហាររួចតម្កល់ទុក ត្រូវតម្កល់ទឹកផឹក ទឹកប្រើប្រាស់ ភិក្ខុរូបណា ត្រឡប់ពីបិណ្ឌបាតក្រោយគេ ប្រសិនបើមានរបស់ឆាន់នៅសល់ បើចង់ឆាន់ក៏គួរឆាន់ បើមិនចង់ឆាន់ ក៏គួរនាំយកទៅចោលក្នុងទីមិនមានរបស់ខៀវដុះ ឬក្នុងទឹកមិនមានសត្វ ត្រូវរៀបចំទុកដាក់អាសនៈ ទឹកលាងជើង តាំងទ្រជើង គ្រឿងជូតជើងលាងភាជនៈដែលផ្អាប់ អាហារទុក ទុកដាក់ទឹកឆាន់ ទឹកប្រើប្រាស់បោសរោងឆាន់ ។ ភិក្ខុរូបណា ឃើញឆ្នាំងទឹកផឹក ទឹកប្រើប្រាស់មិនមានទឹក ត្រូវដងទឹកដាក់ បើមិនអាចធ្វើបាន ក៏គួរហៅភិក្ខុរូបទីពីរមក ដោយប្រើដៃ សំដែងឲ្យដឹងថាត្រូវដងទឹកដាក់ មិនត្រូវបញ្ចេញវាចាព្រោះតែរឿងនោះ ។

## ៧.អារញ្ញិកវត្ត (វត្តរបស់ភិក្ខុអ្នកនៅព្រៃ)

ភិក្ខុអ្នកនៅព្រៃ ត្រូវក្រោកអំពីព្រលឹម យកបាត្រដាក់ក្នុងស្បោក (ឬស្រោមបាត្រ) រួចហើយស្ពាយស្មា យកចីវរពាក់លើ-កទុកដាក់គ្រឿងប្រើប្រាស់ដែលធ្វើអំពីឈើនិងដី បិទទ្វារបង្អួចរួចចុះពីលំនៅ (សេនាសនៈ) ។ កាលបើចូលទៅកាន់ស្រុក ត្រូវដោះស្បែកជើងគោះឲ្យទាប ដាក់ទុកក្នុងស្បោកហើយស្ពាយស្មា ស្លៀកឲ្យរៀបរយល្អ ចងវត្ថពន្ធចង្កេះ ត្រួតសំពត់ (ចីវរ និងសង្ឃាដី) ហើយដណ្ដប់ ឬឃ្លុំ ភ្ជាប់ឡេវក្ដុំ លាងបាត្រហើយកាន់ចូលទៅដោយស្រួល មិនត្រូវប្រញាប់ប្រញាល់ពេកទេ (បន្ទាប់អំពីនោះត្រូវបដិបត្តិតាមសេក្ខិយវត្ត ទាក់ទងទៅនឹងការចូលទៅកាន់ស្រុកគ្រប់ៗ) ។ នៅពេលត្រឡប់ពីការបិណ្ឌបាតក្នុងស្រុកហើយ ដាក់បាត្រទុកក្នុងស្រោមស្ពាយស្មា មូរចីវរទុកលើក្បាល ពាក់ស្បែកជើងដើរទៅ ។ ភិក្ខុអ្នកនៅព្រៃ ត្រូវតម្កល់ទឹកផឹក ទឹកប្រើប្រាស់និងបង្កាត់ភ្លើងទុក តម្កល់ឈើស្ទន់ទុក តម្កល់ឈើច្រត់ទុក សិក្សាអំពីនក្ខត្តឫក្សបទ (ដំណើររបស់ផ្កាយ) ទាំងអស់ ឬខ្លះៗ និងត្រូវតែជាអ្នកឆ្លាតនៅក្នុងទិស ។

## ៨.សេនាសនវត្ត (វត្តទាក់ទងនឹងលំនៅឋាន)

សេចក្ដីថា ភិក្ខុអ្នកនៅក្នុងវិហារ កុដិណា បើកុដិមានសំរាម បើអាចនឹងបោសប្រាសបាន គប្បីបោសប្រាសចេញ កាលបោសប្រាស គប្បីជញ្ជូនបាត្រ និងចីវរចេញ យកទៅទុកដាក់ឲ្យសមគួរមួយអន្លើជាមុន ហើយជញ្ជូនសំពត់និសីទនៈ គ្រឿងកម្រាលលើគ្រែ លើតាំង យកទៅគរទុកក្នុងទីសមគួរ គប្បីជញ្ជូនពូកខ្នើយយកទៅគរទុកក្នុងទីសមគួរ គ្រែតាំងគប្បីធ្វើដោយគោរព កុំឲ្យប៉ះទង្គិកោសរូសសន្ទឹកទ្វារ ជញ្ជូនចេញដោយប្រពៃ តាំងមួយចំណែកហើយជញ្ជូនទ្រនាប់ជើងគ្រែ កន្ដោរ និងក្ដារបង្អែក ចេញទៅតម្កល់មួយចំណែក គ្រឿងកម្រាលផ្ទៃ គប្បីកំណត់ទីក្រាលហើយជញ្ជូនចេញទៅដាក់មួយចំណែក បើក្នុងវិហារមានសរសៃពីងពាងគប្បីបបោសអំពីពិតានចុះមកមុន ។ បង្អួចដុះផ្សិតសៅហ្មង គប្បីជូតចេញ ។ បើជញ្ជាំងគេធ្វើបរិកម្មដោយរង្គ ឬផ្ទៃគេលាភពណ៌ខ្មៅដុះ ផ្សិតឡើង គប្បីយកកំណាត់សំពត់ជ្រលក់ទឹកពូតឲ្យស្រស់ជុតចេញ បើផ្ទៃគេមិនលាភពណ៌ទេ គប្បីយកទឹកបំព្រំចុះមុនហើយសឹមជូត ។
កុំឲ្យល្អងធូលីហុយឡើងធ្លាក់ប្រឡាក់កុដិ គប្បីរើសសំរាមទៅចាក់ចោលក្នុងទីសមគួរ កុំបោក កុំគោះសេនាសនៈ គ្រឿងកម្រាល

ជិតភិក្ខុដទៃ ជិតវិហារ កុដិ ឬជិតទឹកឆាន់ ទឹកប្រើ កុំបោកគោះក្នុងទីវាលលើខ្យល់ គប្បីបោកគោះ ក្នុងទីក្រោមខ្យល់ ។ គ្រឿងកម្រាលផ្ទៃ គប្បីហាលក្នុងទីសមគួរ ហើយបោសប្រាសចេញ ជញ្ជូនគ្រឡប់ទៅក្រាលទុកដូចដើមវិញ ។ ទ្រនាប់រងជើងគ្រែ គប្បីហាលទុកមួយចំណែក ហើយជុសជូតជញ្ជូនគ្រឡប់ចូលទៅតាំងទុកដូចដើម គ្រែតាំងក៏គប្បីគោះបោសហាល ធ្វើដោយគោរព កុំឲ្យប៉ះពាល់ជល់ទង្គិច ជញ្ជូនគ្រឡប់យកទៅទុកកន្លែងដើមវិញ ។ ពូកខ្នើយ និងនិសីទនៈគ្រឿងកម្រាល លើគ្រែ លើតាំង គប្បីហាលទុកមួយចំណែក ហើយគោះបោសជញ្ជូនគ្រឡប់ចូលទៅតាំងទុកតាមកន្លែងដើម ។ កន្ថោរ ក្តារបង្អែក ក៏គប្បីហាលជូត ជុសលាង ហើយជញ្ជូនទៅតាំងទុកដូចដើម ។ បាត្រចីវរក៏គប្បីតម្កល់ទុកដាក់ ។ កាលទុកបាត្រ ដៃម្ខាងកាន់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ក្រោមតាំង ហើយសិមទុកដាក់ កុំតម្កល់បាត្រលើផ្ទៃ ដែលមិនមានរបស់ណាមួយមានស្លឹកឈើជាដើមរង ។ កាលទុកដាក់ចីវរ យកដៃម្ខាងកាន់ចីវរ ដៃម្ខាងជូតស្នូចីវរ ឬខ្សែស្បៀង លូកដៃពីខាងក្រោមស្នូចីវរសន្សឹមៗ ហើយពាក់បត់ជាយចីវរខាងនាយមកខាងមុខខ្លួន ។ បើខ្យល់ប្រកបដោយលួងធូលី បក់មកអំពីទិសណា គប្បីបិទបង្អួចខាងទិសនោះចេញ ។ បើក្នុងរដូវរងា វេលាថ្ងៃគប្បីបើកបង្អួច វេលាយប់គប្បីបិទបង្អួច ។ បើក្នុងរដូវក្តៅ វេលាថ្ងៃគប្បីបិទបង្អួច វេលាយប់គប្បីបើក ។ បើបរិវេណ បន្ទប់ទឹក រោងឆាន់ រោងភ្លើង ឬវច្ចកុដិ ទាំងនេះ ណាមួយ មានសំរាម គប្បីបោសចេញ បើមិនមានទឹកឆាន់ ទឹកប្រើ គប្បីដងមកតាំងទុក ។ បើនៅក្នុងកុដិជាមួយនឹងភិក្ខុចាស់ជាង មិនបានប្រាប់ភិក្ខុចាស់ជាមុន កុំឲ្យឧទ្ទេសនិងបរិបុច្ឆា គឺកុំប្រាប់បាលី និងអដ្ឋកថា កុំសា្វធ្យាយទន្ទេញសូត្រ កុំសំដែងធម៌ កុំអុជប្រទីប កុំលត់ប្រទីប កុំបើកបិទបង្អួច តែទ្វារជាធំក្នុងការប្រើប្រាស់ ត្រូវការបិទបើក មិនមានកិច្ចដែលនឹងប្រាប់ភិក្ខុចាស់ជាមុនទេ តែការឲ្យឧទ្ទេសជាដើមក្រៅពីនោះ ត្រូវប្រាប់ភិក្ខុចាស់ជាមុន ទើបធ្វើបាន នឹងប្រាប់រាល់ៗថ្ងៃ ក៏គួរ ។ បើភិក្ខុកំឡោះប្រាប់ទុកឲ្យស្រេចតែម្តង គឺមិនបាច់ប្រាប់ទៀតទេ បើភិក្ខុចាស់ទទួលថាសាធុ ឬភិក្ខុចាស់ពោលខ្លួនឯងថា លោកចូរនៅតាមសប្បាយចុះ បើអនុញ្ញាតដូច្នេះហើយក៏គួរ ។ បើដើរក្នុងទីចង្រ្កមជាមួយនឹងភិក្ខុចាស់ជាងសោត កុំត្រឡប់ឲ្យជួបមុខនឹងភិក្ខុចាស់ជាង កុំឲ្យប៉ះភិក្ខុចាស់ជាងដោយជាយសង្ឃាដី ។

## ៩.ជន្តាឃរវត្ត (វត្តនៅក្នុងរោងភ្លើង)

ភិក្ខុអ្នកចូលទៅកាន់រោងភ្លើងមុន បើផេះមានច្រើន ត្រូវនាំយកទៅចោល ។ បើរោងភ្លើងមានសំរាម ក៏គប្បីបោសសម្អាត ។

បើសំយាបខាងក្រៅ ឬបរិវេណ ជាដើមមានសំរាម ត្រូវបោសសម្អាត ត្រូវនាំផង់ (សម្រាប់ដុសខ្លួន) ទៅតម្កល់ទុក ធ្វើដីស្អិតឲ្យសើម ចាក់ទឹកទុកក្នុងអាងទឹក ពេលចូលទៅក្នុងផ្ទះភ្លើង ត្រូវយកដីស្អិតជូតមុខ បិទខាងមុខខាងក្រោយ (អាចសំដៅយកការបិទផ្ទះភ្លើង) រួចសឹមចូលទៅ ។ មិនត្រូវអង្គុយជ្រៀតបៀតព្រះថេរៈ មិនត្រូវអង្គុយពាំងភិក្ខុដែលខ្ចីវស្សាជាង បើអាចធ្វើបានគួរដុសខ្នងឲ្យព្រះថេរៈ ។ ពេលចេញពីផ្ទះភ្លើង ត្រូវនាំតាំងដែលទុកប្រចាំនៅក្នុងផ្ទះភ្លើងចេញផង ត្រូវបិទខាងមុខខាងក្រោយ រួចហើយសឹមចេញពីផ្ទះភ្លើង ។ សូម្បីនៅក្នុងទឹក បើអាចដុសខ្នងឲ្យព្រះថេរៈបាន ក៏គួរធ្វើ មិនត្រូវងូតទឹកខាងមុខព្រះថេរៈ មិនត្រូវងូតទឹកខាងលើខ្សែទឹកព្រះថេរៈ នៅពេលងូតទឹករួចហើយ មុននឹងឡើងត្រូវបើកផ្លូវឲ្យភិក្ខុទាំងឡាយដែលកំពុងឡើង (អំពីទឹក) ។ ចំណែកឯភិក្ខុដែលចេញពីផ្ទះភ្លើងខាងក្រោយ បើផ្ទះភ្លើងប្រឡាក់ ត្រូវលាងចេញ ត្រូវលាងធុងដាក់ដីស្អិតចេញ រួចទុកដាក់នៅក្នុងផ្ទះភ្លើង រំលត់ភ្លើងបិទទ្វារហើយចេញទៅ ។ (សំដែងថា នៅពេលចូលទៅកម្ដៅកាយនៅក្នុងផ្ទះភ្លើងឲ្យញើសចេញហើយ ក៏ងូតទឹកនៅក្នុងទីជិតៗ គ្នានោះឯង) ។

## ១០.វច្ចកុដិវត្ត (វត្តទាក់ទងទៅនឹងបង្គន់)

មុននឹងទ្រង់បញ្ញត្តខបដិបត្តិទាក់ទងទៅនឹងវច្ចកុដិ ទ្រង់បញ្ញត្តឲ្យភិក្ខុដែលបន្ទោបង់រួចហើយ ប្រើទឹកលាងជម្រះ បើមិនលាងជម្រះត្រូវអាបត្តិទុក្កដ និងទ្រង់អនុញ្ញាតឲ្យចូលទៅកាន់វច្ចកុដិតាមលំដាប់ដែលទៅមុនក្រោយ (ពុំចាំបាច់ទៅតាមលំដាប់វស្សា ពីព្រោះនាំឲ្យភិក្ខុក្មេងវស្សាជាងក្ដៅក្រហាយ) រួចហើយទ្រង់ប្រារព្ធការមិនមានសណ្ដាប់ធ្នាប់ក្នុងការចូល ការប្រើវច្ចកុដិនៃភិក្ខុបញ្ចវគ្គិយ ទើបទ្រង់បញ្ញត្តខបដិបត្តិទាក់ទងទៅនឹងវច្ចកុដិ ដូចតទៅនេះ ៖

ភិក្ខុអ្នកចូលទៅកាន់វច្ចកុដិ ត្រូវឈរនៅខាងក្រៅ ធ្វើសំឡេងគ្រហែម ភិក្ខុនៅខាងក្នុង ត្រូវគ្រហែមតប រួចពាក់ចីវរទុកនៅលើទំពក់ ឬស្នួ ត្រូវចូលទៅដោយស្រួល មិនត្រូវប្រញាប់ មិនត្រូវលើកសំពត់ចូលទៅឡើយ លុះត្រាតែបានជាន់លើជ្រុញហើយទើបលើកបាន មិនត្រូវនិយាយក្នុងពេលកំពុងបន្ទោបង់, មិនត្រូវទំពាឈើស្ទន់ក្នុងពេលកំពុងបន្ទោបង់, មិនត្រូវបន្ទោបង់ក្រៅរណ្ដៅខច្ចារៈ និងក្រៅទបស្សាវៈ, មិនត្រូវស្ដោះទឹកមាត់ដាក់ទបស្សាវៈ មិនត្រូវប្រើឈើជម្រះគ្រោតគ្រាត (មុតរឹង) មិនត្រូវចោលឈើជម្រះទៅក្នុងរណ្ដៅខច្ចារៈ នៅពេលឈរលើជ្រុញហើយ ត្រូវបិទបាំង (សំពត់ស្លៀកឲ្យជិតល្អ) មិនត្រូវចេញដោយប្រញាប់ មិន

ត្រូវលើកសំពត់ចេញមក (នៅពេលជម្រះ) ឈរនៅលើជ្រុញ ហើយសឹមលើកសំពត់ មិនត្រូវជម្រះឲ្យមានសម្លេងខ្លាំង មិនត្រូវលាងទុកទឹកឲ្យនៅសល់ក្នុងផ្តិល ពេលឈរលើជ្រុញសម្រាប់ជាន់ហើយ ត្រូវបិទបាំង ។ (សំដែងឲ្យឃើញថា ទីបន្ទោបង់និងទីជម្រះនៅផ្សេងពីគ្នា តែនៅជិតគ្នា) ។ បើវច្ចកុដិប្រឡាក់ ត្រូវលាងចេញ បើទីសម្រាប់ដាក់ឈើស្ទន់ពេញ ត្រូវនាំយកទៅចោល ។ បើវច្ចកុដិមានសម្បុកពីងពាង ត្រូវបោសចេញ បើសំយាបខាងក្រៅ, បរិវេណ, ស៊ុមទ្វារមានសម្បុកពីងពាង ត្រូវបោសចេញ ។ បើទឹកនៅក្នុងឆ្នាំងជម្រះមិនមាន ត្រូវដងដាក់ ។

## ១១.ឧបជ្ឈាយវត្ត (វត្តទាក់ទងនឹងឧបជ្ឈាយ៍)

សទ្ធិវិហារិក (អ្នកដែលឧបជ្ឈាយ៍បំបួសឲ្យ) ត្រូវក្រោកឡើងអំពីព្រឹក ដោះស្បែកជើង គ្រងចីវរឆៀងស្មាម្ខាង ប្រគេនឈើស្ទន់ ទឹកលាងមុខ ក្រាលអាសនៈ បើមានភត្តយាគូ ត្រូវលាងភាជនៈរួចហើយបង្អោនភត្តយាគូប្រគេន រួចហើយប្រគេនទឹក ទទួលភាជនៈមកលាងទុកដាក់, កាលបើឧបជ្ឈាយ៍ក្រោកឡើងឲ្យលើកអាសនៈឡើង បើកន្លែងមានសម្បុកពីងពាងត្រូវបោសចេញ, បើឧបជ្ឈាយ៍ប្រាថ្នាចូលទៅកាន់ស្រុក ត្រូវប្រគេនស្បង់ ទទួលយកសំពត់បន្លាស់ប្រគេនវត្តពន្ធចង្កេះ យកសំពត់ (ចីវរព្រមទាំងសង្ឃាដី) ត្រួតគ្នាហើយប្រគេន លាងបាត្ររួចហើយប្រគេនទាំងមានទឹក បើឧបជ្ឈាយ៍ត្រូវការភិក្ខុទៅជាមួយ ត្រូវស្លៀកស្បង់ឲ្យរៀបរយ ដណ្តប់ចីវរភ្ជាប់ឡេវក្តុំតាមលោកទៅជាមួយ ។ មិនត្រូវដើរឆ្ងាយ ឬជិតពេក ។ ត្រូវទទួលអាហារឲ្យល្មមនឹងបាត្រ ។ កាលបើឧបជ្ឈាយ៍កំពុងនិយាយ មិនត្រូវនិយាយកាត់ ។ បន្ទាប់ពីនោះ នៅមានឧបដិបត្តិជាច្រើនទៀត ដែលល្មមសង្ខេបបាន គឺ ប្រាថ្នាការសិក្សាជាមួយលោក, ខ្វល់ខ្វាយការពារ ឬរម្ងាប់សេចក្តីវិនាសដែលអាចកើតឡើង ឬកើតឡើងហើយដល់លោក ដូចជា រម្ងាប់សេចក្តីរសាប់រសល់, សេចក្តីនឿយណាយ, ជួយរារាំង ឬទប់ស្កាត់ការយល់ខុសរបស់លោក ខ្វល់ខ្វាយដើម្បីឲ្យសង្ឃលើកលែងទោសដល់លោក ឬសម្រាលទោសដល់លោក រក្សាទឹកចិត្តលោក មិនសេពគប់មនុស្សខាងក្រៅ ជាហេតុនាំឲ្យថ្នាំងថ្នាក់ចិត្ត ដូចជាមានការទទួលនិងឲ្យជាដើមដល់អ្នកទាំងនោះ ប្រាប់លោកជាមុន មិនធ្វើតាមអំពើចិត្ត, មិនត្រាច់ទៅតាមអំពើចិត្ត ទៅណាត្រូវលាលោកមុន, កាលបើលោកអាពាធ យកចិត្តទុកដាក់ព្យាបាល មិនត្រូវទៅណារហូតដល់លោកជាសះស្បើយ ឬធ្វើមរណភាព ។

## ១២.សទ្ធិវិហារិកវត្ត (ឧបដិបត្តិចំពោះសទ្ធិវិហារិក)

ភិក្ខុដែលជាឧបជ្ឈាយ៍ (អ្នកបំបួស) ត្រូវបដិបត្តិឲ្យប្រពៃ នៅក្នុងសទ្ធិវិហារិក (អ្នកដែលខ្លួនបំបួសឲ្យ) ដូចតទៅនេះ

យកធុរៈក្នុងការសិក្សារបស់សទ្ធិវិហារិក, សង្គ្រោះដោយបាត្រចីវរ និងបរិក្ខារដទៃទៀត បើរបស់ខ្លួនមិនមាន ត្រូវខ្វល់ខ្វាយរកឲ្យ, ខ្វល់ខ្វាយការពារ ឬរារាំងសេចក្ដីវិនាសដែលនឹងកើតឡើង ឬកើតឡើងហើយដល់សទ្ធិវិហារិក (ដូចឧបដិបត្តិចំពោះឧបជ្ឈាយ៍), កាលបើសទ្ធិវិហារិកអាពាធ ត្រូវយកចិត្តទុកដាក់ព្យាបាល ។

## ១៣.អាចរិយវត្ត (ឧបដិបត្តិចំពោះអាចារ្យ)

## ១៤.អន្តេវាសិកវត្ត (ឧបដិបត្តិចំពោះអន្តេវាសិក)

(វត្តទាំងពីរយ៉ាងនេះ ដូចឧបដិបត្តិរវាងឧបជ្ឈាយ៍ និងសទ្ធិវិហារិក)

## ៥.បាតិមោក្ខឋបនក្ខន្ធកៈ

## (ពោលអំពីការលើកសំដែងបាតិមោក្ខ)

ក្នុងថ្ងៃឧបោសថ ១៥ កើត ថ្ងៃមួយព្រះមានព្រះភាគប្រថាប់នៅក្នុងប្រាសាទដែលនាងវិសាខាសាងថ្វាយ នៅក្នុងបុព្វារាម ព្រមទាំងភិក្ខុសង្ឃ រហូតដល់បឋមយាមនៃរាត្រី ទើបព្រះអានន្ទក្រាបទូលសុំឲ្យទ្រង់សំដែងបាតិមោក្ខ ប៉ុន្តែព្រះមានព្រះភាគទ្រង់គង់នៅដោយតុណ្ហីភាព ។ កាលបើមជ្ឈិមយាមនៃរាត្រីកន្លងទៅ ព្រះអានន្ទក៏ក្រាបទូលតឿនជាលើកទី ២ តែទ្រង់នៅដោយតុណ្ហីភាព ។ លុះបច្ឆិមយាមនៃរាត្រីកន្លងទៅ អរុណកំពុងរះឡើង ព្រះអានន្ទក៏ក្រាបទូលតឿនម្ដងទៀតជាលើកទី ៣ ទើបព្រះមានព្រះភាគត្រាស់តបថា បរិស័ទ (អ្នកមកប្រជុំគ្នា) មិនបរិសុទ្ធិ ។ ព្រះមោគ្គល្លានពិចារណាដឹងថា មានភិក្ខុដាច់ចាកភាវៈជាភិក្ខុ តែប្ដេជ្ញាខ្លួនថាជាភិក្ខុអង្គុយនៅក្នុងបរិស័ទនោះ ទើបនិយាយជាមួយនឹងភិក្ខុនោះឲ្យចេញទៅ សូម្បីនិយាយដល់ទៅ ៣ លើកហើយ ក៏នៅតែអង្គុយស្ងៀម ទើបលោកចាប់ដៃទាញចេញទៅក្រៅទ្វារ ហើយខ្ទាស់ពីខាងក្នុង ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់នូវសេចក្ដីអស្ចារ្យ ៨ ប្រការនៃមហាសមុទ្រ ប្រៀបជាមួយព្រះធម៌វិន័យរបស់ព្រះអង្គ និងមានហេតុការណ៍ទាក់ទងទៅនឹងរឿងនេះមួយកន្លែង គឺមហាសមុទ្រតែងតែជាត់សាកសពទាំងអស់មកលើគោក ប្រៀបដូចសង្ឃមិនឲ្យសេពគប់ជាមួយអ្នកប្រព្រឹត្តខុស និងត្រូវបណ្ដេញចេញអំពីក្រុម ។

## បន្ទាប់មកទ្រង់លែងសំដែងបាតិមោក្ខទៀត

យោងតាមហេតុការណ៍នោះ ទើបត្រាស់ថា តទៅទ្រង់លែងសំដែងបាតិមោក្ខទៀតហើយ ទ្រង់ប្រគល់ឲ្យសង្ឃធ្វើឧបោសថសូត្របាតិមោក្ខ ទ្រង់លើកហេតុផលថា តថាគតមិនសំដែងបាតិមោក្ខនៅក្នុងបរិស័ទមិនបរិសុទ្ធិ ហើយទ្រង់បញ្ញត្តិព្រះវិន័យហាមភិក្ខុមានអាបត្តិស្តាប់បាតិមោក្ខ បើបំពានត្រូវអាបត្តិទុក្កដ ។ ទ្រង់អនុញ្ញាតឲ្យលើកសំដែងបាតិមោក្ខបាន ព្រោះហេតុមានភិក្ខុដែលមានអាបត្តិនៅស្តាប់ ។ ព្រមទាំងទ្រង់សំដែងវិធីសូត្រប្រកាសរម្ងាប់ការសូត្របាតិមោក្ខផងដែរ ។ ប៉ុន្តែទ្រង់ហាមលើកសំដែងបាតិមោក្ខដល់ភិក្ខុអ្នកបរិសុទ្ធិមិនមានអាបត្តិ ដោយមិនមានហេតុផល ទ្រង់សំដែងការរម្ងាប់ការសូត្របាតិមោក្ខ ដែលមិនប្រកបដោយធម៌ និងប្រកបដោយធម៌ច្រើនប្រការ ព្រមទាំងអន្តរាយ ឬហេតុដែលទ្រង់អនុញ្ញាតឲ្យឈប់សូត្របាតិមោក្ខបាន ១០ ប្រការ គឺ

១. ព្រះរាជាស្តេចយាងមក

២. ចោរប្លន់

៣. ភ្លើងឆេះ

៤. ទឹកលិច

៥. មានមនុស្សមកច្រើន (លើកសូត្រដើម្បីដឹងរឿង ឬដើម្បីទទួល)

៦. អមនុស្សបៀតបៀន

៧. សត្វសាហាវ ដូចជា ខ្លាចូលមក

៨. ពស់វារចូលមក

៩. ភិក្ខុកើតអាពាធដល់ជីវិត

១០. មានអន្តរាយដល់ព្រហ្មចារីយ៍ ។

## ការប្តឹងផ្តល់

ទ្រង់ឆ្លើយពាក្យសួររបស់ព្រះឧបាលី ទាក់ទងទៅនឹងការប្តឹងផ្តល់ (ភិក្ខុដែលមិនសមគួរដល់ការស្តាប់បាតិមោក្ខ) ចាប់ផ្តើមពីការសម្រេចចិត្តនាំខ្លួនចូលទៅពាក់ព័ន្ធជាមួយ ដើម្បីធម៌ ដើម្បីវិន័យ និងការប្តឹងផ្តល់គ្នាប្រកបដោយធម៌ និងមិនប្រកបដោយធម៌ ដែលមានលក្ខណៈផ្សេងគ្នាជាច្រើនប្រការ ។

## ៦.ភិក្ខុនីខន្ធកៈ (ពោលអំពីភិក្ខុនី)

ព្រះនាងមហាបជាបតិគោតមី (ទ្រង់ជាព្រះមាតុច្ឆា និងជាព្រះមាតាចិញ្ចឹមនៃព្រះពុទ្ធ) ទូលសុំបួសនៅក្នុងព្រះពុទ្ធសាសនា ។ ដម្បូងឡើយ ព្រះមានព្រះភាគទ្រង់បដិសេធ តែទីបំផុតទ្រង់អនុញ្ញាត ដោយទ្រង់ដាក់លក្ខខណ្ឌ ៨ ប្រការ ហៅថា គរុធម៌ ៨

ព្រះនាងក៏ទ្រង់ព្រមទទួលយក ទើបព្រះអានន្ទនាំយកសេចក្តីទៅក្រាបទូលព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ការដែលមានស្ត្រីចូលមកបួសនៅក្នុងព្រះពុទ្ធសាសនា នឹងធ្វើឲ្យព្រះពុទ្ធសាសនាតាំងនៅមិនបានយូរតាមកាលកំណត់ ។ (ប៉ុន្តែប្រការដែលទ្រង់ដាក់លក្ខខណ្ឌ មិនឲ្យស្ត្រីបួសដោយងាយៗនោះ ក៏ទទួលបានផលជាវិជ្ជមាន គឺក្រោយពីពុទ្ធបរិនិព្វានមិនយូរប៉ុន្មាន ក៏អស់តំណភិក្ខុនី) ។

## ទ្រង់អនុញ្ញាតការបួសជាភិក្ខុនី

ទ្រង់អនុញ្ញាតឲ្យភិក្ខុទាំងឡាយបំបួសភិក្ខុនី (និងកាលជាខាងក្រោយមកទ្រង់អនុញ្ញាតឲ្យភិក្ខុនី បួសនៅក្នុងសង្ឃទាំងពីរសំណាក់ គឺបួសនៅក្នុងសំណាក់ភិក្ខុនីសង្ឃមុន រួចហើយទើបទៅបួសនៅក្នុងសំណាក់ភិក្ខុសង្ឃ កាលបើមានហេតុកើតឡើង គឺមានអ្នកលេងប្រទូស្តភិក្ខុនីតាមផ្លូវ នៅពេលដែលពួកនាងធ្វើដំណើរទៅបួសនៅក្នុងសំណាក់ភិក្ខុសង្ឃ ទើបទ្រង់អនុញ្ញាតឲ្យបួសដោយទូតបាន គឺកាលបួសនៅក្នុងសំណាក់ភិក្ខុនីសង្ឃរួចហើយ ឲ្យភិក្ខុនីដែលវៃឆ្លាតមួយរូបចូលទៅរកភិក្ខុសង្ឃសូត្រសុំអនុម័តិសង្ឃ ដើម្បីឲ្យឧបសម្ប័ទដល់ភិក្ខុនីដែលធ្វើដំណើរមកមិនបាន រួមមាន ៣ លើក រួចហើយឲ្យភិក្ខុឈ្លាសវៃសូត្រប្រកាសការឧបសម្ប័ទនៅក្នុងទីជុំនុំសង្ឃ ដោយស្មើញត្តិ ១ លើក សូត្រប្រកាស ៣ លើក) ។ ម្យ៉ាងទៀត ទ្រង់ប្រកាសប្រាប់ថា ព្រះនាងមហាបជាបតិគោតមី ជាការបួសល្អហើយដោយការទទួលយកគរុធម៌ ៨ ប្រការ ។

## ការសិក្សាសិក្ខាបទ

ទ្រង់អនុញ្ញាតឲ្យភិក្ខុនីសិក្សានៅក្នុងសាធារណសិក្ខាបទ គឺសិក្ខាបទដែលទាក់ទងទាំងភិក្ខុ និងភិក្ខុនី ។ ចំណែកឯអសាធារណសិក្ខាបទ គឺបញ្ញត្តសម្រាប់ភិក្ខុនី ក៏ទ្រង់អនុញ្ញាតឲ្យសិក្សាដែរ ។

## លក្ខណៈវិនិច្ឆ័យធម្មវិន័យ ៨ ប្រការ

ទ្រង់សំដែងលក្ខណៈវិនិច្ឆ័យធម្មវិន័យ ៨ ប្រការ គឺ

១.បើប្រព្រឹត្តទៅដើម្បីសេចក្តីតម្រេក មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក ។

២.ប្រព្រឹត្តទៅដើម្បីប្រកបសត្វទុកនៅក្នុងភព មិនប្រព្រឹត្តទៅដើម្បីរលាស់ខ្លួនចេញចាកភព ។

៣.ប្រព្រឹត្តទៅដើម្បីសន្សំកិលេស មិនប្រព្រឹត្តទៅដើម្បីលះកិលេស ។

៤.ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ។

៥.ប្រព្រឹត្តទៅដើម្បីមិនត្រេកអរ របស់ដែលខ្លួនមាន មិនប្រព្រឹត្តទៅដើម្បីត្រេកអររបស់ដែលខ្លួនមាន (សន្តោស) ។

៦.ប្រព្រឹត្តទៅដើម្បីនៅច្រឡូកច្រឡំដោយពួកគណៈ មិនប្រព្រឹត្តទៅដើម្បីស្ងាត់ចាកពួកគណៈ ។

៧.ប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិល មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម ។

៨.ប្រព្រឹត្តទៅដើម្បីគេចិញ្ចឹមលំបាក មិនប្រព្រឹត្តទៅដើម្បីគេចិញ្ចឹមងាយ ។

គប្បីដឹងថា លក្ខណៈទាំងអស់នោះមិនមែនធម្មវិន័យ មិនមែនសត្ថុសាសនា, បើមានលក្ខណៈផ្ទុយពីគ្នា ទើបឈ្មោះថា ជាធម្មវិន័យ ជាសត្ថុសាសនា ។

## រឿងទាក់ទងនៅនឹងបាតិមោក្ខ និងសង្ឃកម្ម

ដំបូងបំផុត ទ្រង់អនុញ្ញាតឲ្យភិក្ខុទាំងឡាយសូត្របាតិមោក្ខឲ្យភិក្ខុនីស្តាប់ ក្រោយមកទ្រង់ហាម និងឲ្យភិក្ខុនីសូត្រដោយខ្លួនឯង ដោយឲ្យភិក្ខុទាំងឡាយបង្រៀន ។ ដំបូងទ្រង់អនុញ្ញាតឲ្យភិក្ខុទាំងឡាយទទួលការសំដែងអាបត្តិរបស់ភិក្ខុនីបាន ក្រោយមកទ្រង់ហាម និងឲ្យភិក្ខុនីទទួលការសំដែងអាបត្តិរបស់ភិក្ខុនីដងគ្នា ដោយឲ្យភិក្ខុទាំងឡាយបង្រៀនវិធីសំដែង ។ ទ្រង់អនុញ្ញាតឲ្យភិក្ខុទាំងឡាយ រម្ងាប់អធិករណ៍របស់ភិក្ខុនីបាន ប៉ុន្តែទាក់ទងនឹងការធ្វើកម្ម ទ្រង់អនុញ្ញាតឲ្យភិក្ខុលើកកម្មលើកអាបត្តិរបស់ភិក្ខុនីបាន រួចហើយប្រគល់ឲ្យភិក្ខុនីដងគ្នាធ្វើកម្ម និងទទួលការសំដែងអាបត្តិតទៅ ។ ទ្រង់អនុញ្ញាតឲ្យភិក្ខុបង្រៀនវិន័យដល់ភិក្ខុនីបាន ។

## ការដាក់ទោសភិក្ខុដោយការមិនថ្វាយបង្គំ

ភិក្ខុឆព្វគ្គិយយកទឹកភក់ស្រោចលើភិក្ខុនីខ្លះ សំដែងអាការមិនល្អផ្សេងៗ ដើម្បីឲ្យភិក្ខុនីមានតម្រេកមកលើខ្លួន ទ្រង់ពិន័យអាបត្តិទុក្កដដល់អ្នកដែលប្រព្រឹត្តធ្វើដូច្នោះ រួចហើយឲ្យដាក់ទោស (ទណ្ឌកម្ម) ដល់ភិក្ខុនោះ ដោយឲ្យភិក្ខុនីសង្ឃដាក់កតិកាមិនឲ្យធ្វើការថ្វាយបង្គំភិក្ខុនោះ ។

## ការដាក់ទោសភិក្ខុនី

ឆព្វគ្គិយាភិក្ខុនី (គឺភិក្ខុនីមានគ្នា ៦ នាក់) ប្រព្រឹត្តមិនល្អ

ផ្សេងៗ ដើម្បីឲ្យភិក្ខុមានតម្រេកមកលើខ្លួន ទ្រង់ពិន័យអាបត្តិទុក្កដ និងទ្រង់អនុញ្ញាតឲ្យដាក់ទោសភិក្ខុនីនោះ ដោយការហាមបរិវេណ បើថានៅមិនព្រមលើក ឲ្យបញ្ឈប់ការឲ្យឱវាទ ។ ភិក្ខុនីដែលត្រូវបញ្ឈប់ការឲ្យឱវាទ មិនអាចធ្វើឧបោសថរួមជាមួយភិក្ខុដទៃបានឡើយ រហូតដល់អធិករណ៍រម្ងាប់ ។

## ការឱ្យឱវាទភិក្ខុនី

ភិក្ខុអ្នកឲ្យឱវាទភិក្ខុនី ទោះបីបញ្ឈប់ការឲ្យឱវាទហើយត្រាច់ទៅក៏ដោយ បញ្ឈប់ការឲ្យឱវាទព្រោះល្ងង់ក៏ដោយ បញ្ឈប់ការឲ្យឱវាទ ព្រោះមិនមានហេតុផលគ្រប់គ្រាន់ក៏ដោយ បញ្ឈប់ការឲ្យឱវាទ រួចហើយមិនវិនិច្ឆ័យ (គឺកាលបើដាក់ទោសបញ្ឈប់ការឲ្យឱវាទ ក៏ត្រូវមានការវិនិច្ឆ័យឲ្យឃើញខុស) ក៏ដោយ ត្រូវអាបត្តិទុក្កដ ។ ដំបូងទ្រង់អនុញ្ញាតឲ្យភិក្ខុនីទៅស្តាប់ឱវាទរបស់ភិក្ខុ ក្រោយមកទ្រង់អនុញ្ញាតឲ្យសន្មត គឺតែងតាំងភិក្ខុរូបណាមួយឲ្យទៅបង្រៀនភិក្ខុនីជាដើម ព្រមទាំងរបៀបតូចៗខ្លះទៀត ក្នុងការឲ្យឱវាទ ។

## ខហាមតូចៗ

បន្ទាប់អំពីនោះមក ទ្រង់បញ្ញត្តព្រះវិន័យតូចៗ ដែលពាក់ពន្ធជាមួយនឹងភិក្ខុនី ដូចជា ហាមប្រើវត្តពន្ធចង្កេះវែងជ្រុល ឲ្យចងវត្តពន្ធចង្កេះតែមួយជុំ ហាមប្រើសំពត់ ដូចស្ត្រីជាគ្រហស្ថ) ក្រៅពីនោះទ្រង់ក៏មានការហាមធ្វើដូចស្ត្រីមេផ្ទះជាច្រើនប្រការ ដូចជាផាត់មុខ គូរមុខ លាងមុខ រហូតដល់ហាមមានទាសាទាសី កម្មករប្រុសស្រីជាដើម បម្រើខ្លួន និងហាមប្រើចីវរជ្រលក់ពណ៌មិនត្រឹមត្រូវដូចភិក្ខុដែរ និងហាមប្រើអាវ និងមួកជាដើម ។ (កាលបើ) ភិក្ខុនីធ្វើមរណកាល ទ្រង់បញ្ញត្តឲ្យដាក់គ្រឿងប្រើប្រាស់របស់នាងទាំងអស់ចូលជារបស់ភិក្ខុនីសង្ឃ បន្ទាប់មកមានខហាមឃាត់តូចៗផ្សេងទៀត រួមទាំងការឧបសម្បទ ការធ្វើឧបោសថ និងបវារណា ។

## ៧.បញ្ចសតិកខន្ធកៈ

### (ពោលអំពីព្រះអរហន្ត ៥០០ រូប ធ្វើសង្គាយនាលើកទី ១)

ដំណាលរឿងព្រះមានព្រះភាគបរិនិព្វានហើយ ភិក្ខុទាំងឡាយយំសោយសោក តែមានភិក្ខុបួសចាស់មួយរូបឈ្មោះសុភទ្ទ ពោលហាមឃាត់មិនឲ្យយំសោយសោក គួរតែសប្បាយចិត្តថា តទៅមិនមានអ្នកណាចាំហាមធ្វើនេះធ្វើនោះទៀតទេ ចង់ធ្វើអ្វីក៏បានតាមចិត្ត ព្រះមហាកស្សបប្រារព្ធពាក្យនោះ ទើបសុំស្នើឲ្យធ្វើសង្គាយនា គឺ

ចង់ក្រង ឬរៀបចំព្រះធម្មវិន័យ និងរើសយកព្រះអរហន្ត ៤៩៩ រូប (វៀរទុកមួយរូបសម្រាប់ព្រះអានន្ទដែលនៅមិនទាន់បានជាព្រះអរហន្ត) រួចហើយធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ សូត្រប្រកាសមិនឲ្យសង្ឃដទៃ ដែលមិនមានការពាក់ព័ន្ធជាមួយនឹងការធ្វើសង្គាយនា នៅក្នុងក្រុងរាជគ្រឹះ នឹងប្រើពេលវេលា ១ ខែដម្បូង ក្នុងការធ្វើការជួសជុលរបស់បាក់បែក ។ ព្រឹកឡើងទើបមានការប្រជុំ ព្រះអានន្ទក៏បានសម្រេចអរហត្តផល ។

## ការធ្វើសង្គាយនាលើកទី ១

ព្រះមហាកស្សបសូត្រសុំឲ្យសង្ឃសន្មត គឺតែងតាំងខ្លួនលោកជាអ្នកសួរព្រះវិន័យ ព្រះឧបាលីជាអ្នកឆ្លើយព្រះវិន័យ លុះសួរឆ្លើយរួចហើយ ទើបសុំសន្មតខ្លួនលោកជាអ្នកសួរព្រះធម៌ ព្រះអានន្ទជាអ្នកឆ្លើយព្រះធម៌ បន្ទាប់មកសួរឆ្លើយនិកាយទាំង ៥ ។

(កត់សម្គាល់ៈ រឿងរ៉ាវខ្លីៗនេះសំដែងឲ្យឃើញថា ពាក្យថាធម៌នោះ រួមទាំងព្រះសូត្រ និងព្រះអភិធម្ម តាមព្រះអដ្ឋកថាអធិប្បាយថា អភិធម្មនោះរួមនៅក្នុងខុទ្ទកនិកាយ ដែលជានិកាយទី ៥ ។ ភាគីប្រឆាំងមិនជឿថា ព្រះអភិធម្មមានមកតាំងពីពុទ្ធកាលទេ ទើបតែតែងឡើងជាខាងក្រោយ អាងហេតុផលត្រង់នេះបង្ហាញថា មិនមានការសង្គាយនាអភិធម្មទេ ព្រោះនិកាយ ៥ ជារឿងនៃព្រះសូត្រសុទ្ធៗ) ។

## ការដកសិក្ខាបទតូចៗ

បន្ទាប់អំពីនោះ ព្រះអានន្ទស្នើឲ្យសង្ឃដឹងនូវព្រះពុទ្ធានុញ្ញាតឲ្យសង្ឃ បើប្រាថ្នានឹងដក ក៏ឲ្យដកសិក្ខាបទតូចៗបាន នៅក្នុងទីប្រជុំមិនអាចព្រមព្រៀងគ្នាបានថា ប៉ុន្មានជាសិក្ខាបទតូច ទើបព្រះមហាកស្សបសូត្រស្នើញត្តិឲ្យសង្ឃ ឈប់ធ្វើការដកសិក្ខាបទតូចៗ ដើម្បីការពារមិនឲ្យមានអ្នកនិយាយថា សិក្ខាបទដែលព្រះសមណ-គោតមទ្រង់បញ្ញត្តិនោះ តាំងនៅបានត្រឹមសាស្តានៅប៉ុណ្ណោះ ទើបមានរយៈពេលដូចផ្សែងភ្លើង (គឺសាយនឹងបាត់) ។ នៅទីបំផុត កាលបើពុំមានអ្នកជំទាស់ ក៏ប្រើអំណាចសង្ឃហាមដកសិក្ខាបទតូចៗ ។

## ព្រះអានន្ទត្រូវពិន័យអាបត្តិ

ព្រះថេរៈទាំងឡាយ ពិន័យអាបត្តិទុក្កដដល់ព្រះអានន្ទជាច្រើនខគឺ

១.មិនសួរឲ្យទ្រង់សំដែងថា សិក្ខាបទតូច គឺមានអ្វីខ្លះ

២.នៅពេលដេរសំពត់ផ្លូតទឹកភ្លៀង ថ្វាយព្រះមានព្រះភាគ បានជាន់សំពត់នោះ ។

៣.នៅពេលនាំស្ត្រីចូលទៅថ្វាយបង្គំព្រះសព អ្នកទាំងនោះស្រែកយំ ទឹកភ្នែកប្រឡាក់ព្រះសរីរព្រះមានព្រះភាគ ។

៤.មិនអារាធនាឲ្យព្រះមានព្រះភាគទ្រង់មានព្រះជន្មនៅ ទាំងដែលទ្រង់និម្មិតឱភាសឲ្យប្រាកដ ។

៥.ខ្វល់ខ្វាយឲ្យស្ត្រីបួសនៅក្នុងព្រះពុទ្ធសាសនា ។

ព្រះអានន្ទមានខពន្យល់គ្រប់រឿង ប៉ុន្តែព្រមសំដែងអាបត្តិដោយសទ្ធានៅមុខព្រះថេរៈទាំងនោះ ។

## ព្រះបុរាណៈមិនប្រឆាំង តែកាន់យកតាមរឿងដែលខ្លួនបានស្តាប់ផ្ទាល់

ព្រះបុរាណៈព្រមទាំងភិក្ខុចំនួន ៥០០ រូបត្រាច់ទៅកាន់ទក្ខិណាគិរីជនបទ (ភ្នំភាគខាងត្បូងនៃប្រទេសឥណ្ឌា) ល្មមសមគួរហើយ ក៏ធ្វើដំណើរទៅស្នាក់នៅក្នុងវត្តវេឡុវ័ន ក្រុងរាជគ្រឹះ ។ ពេលចូលទៅរកព្រះថេរៈបានប្រាប់រឿងរ៉ាវថា ព្រះថេរៈទាំងឡាយបានធ្វើការសង្គាយនាព្រះធម៌វិន័យរួចហើយ និងណែនាំឲ្យទទួលយកការធ្វើសង្គាយនានោះ ។ ព្រះបុរាណៈឆ្លើយថា ព្រះធម្មវិន័យគឺព្រះថេរៈទាំងឡាយសង្គាយនាល្អហើយ ប៉ុន្តែខ្ញុំបានឮ និងដឹងមកក្នុងទីចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគយ៉ាងណា ខ្ញុំនឹងចាំទុកយ៉ាងនោះ ។ (រឿងនេះ ជាចំណុចមួយនៅក្នុងប្រវត្តិសាស្ត្រ សំដែងថាការយល់ឃើញផ្សេងគ្នាចាប់ផ្តើមមានខ្លះហើយ) ។

## ដាក់ព្រហ្មទណ្ឌព្រះឆន្នៈ

ព្រះអានន្ទប្រកាសឲ្យសង្ឃជ្រាប នូវព្រះពុទ្ធតម្រាស់ដែលឲ្យដាក់ព្រហ្មទណ្ឌ (ការដាក់ទោសដូចអ្នកធំ ឬអ្នកល្អ) គឺព្រះឆន្នៈចង់ធ្វើអ្វី ក៏បណ្តោយឲ្យធ្វើតាមអំពើចិត្ត ភិក្ខុទាំងឡាយមិនត្រូវដាស់តឿនក្រើនរំឭកទេ ។ ទើបសង្ឃប្រគល់ឲ្យព្រះអានន្ទចាត់ការដាក់ព្រហ្មទណ្ឌ ដោយនាំភិក្ខុជាច្រើនទៅកាន់ក្រុងកោសម្ពី តាមផ្លូវទឹកបានជួបនឹងព្រះបាទឧទេន ទ្រង់ក៏ជ្រះថ្លាការពន្យល់អំពីការប្រើសំពត់ឲ្យជាប្រយោជន៍ សូម្បីចាស់ក៏ដោយ ត្រូវទុកធ្វើជាសំពត់ជូតជើង សំពត់ជូតដៃ និងនាំមកលាយជាមួយនឹងដីស្អិតទុកសម្រាប់បូកលាបកុដិ ។ បន្ទាប់អំពីនោះមក ព្រះអានន្ទក៏ធ្វើដំណើរទៅកាន់ឃោសិតារាមដាក់ព្រហ្មទណ្ឌដល់ព្រះឆន្នៈ ធ្វើឲ្យព្រះឆន្នៈខូចចិត្តរហូតដល់សន្លប់បាត់ស្មារតី និងខំប្រឹងបំពេញព្យាយាមរហូតបានសម្រេចអរហត្តផល ទើបមកសុំដកព្រហ្មទណ្ឌ តែព្រះអានន្ទឆ្លើយថា ព្រហ្មទណ្ឌ

រម្ងាប់ហើយ តាំងពីព្រះឆន្នៈបានសម្រេចអរហត្តផល ។

## ៨.សត្តសតិកខន្ធកៈ

## (ពោលអំពីព្រះអរហន្ត ៧០០ រូបធ្វើសង្គាយនាលើកទី ២) វត្ថុ ១០ ប្រការ

កាលព្រះពុទ្ធបរិនិព្វានកន្លងទៅបាន ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីបុត្រនៅក្នុងក្រុងវេសាលី សំដែងវត្ថុ ១០ ប្រការ (ដែលខុសចាកធម្មវិន័យ) ថា ជាវត្ថុគួរ ឬត្រឹមត្រូវតាមធម្មវិន័យ គឺ

១. ទុកអំបិលនៅក្នុងស្នែងសត្វ (បំពង់, ក្រឡ, ...) ដើម្បីឆាន់ជាមួយអាហារបាន (សេចក្តីពិត ត្រូវអាបត្តិបាចិត្តិយ ព្រោះទុកអំបិល យាំងរាត្រីរួចនាំមកលាយជាមួយនឹងអាហារៗនោះ ក៏ក្លាយជាយាំងរាត្រីដែរ) ។

២.ថ្ងៃជ្រេទៅ ២ ធ្នាប់ហើយ ឆាន់អាហារបាន (សេចក្តីពិត ត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់អាហារក្នុងវេលាវិកាល គឺហួសថ្ងៃត្រង់) ។

៣.ភិក្ខុឆាន់អាហារក្នុងទីនិមន្តឆ្អែតហើយ មិនទទួលអាហារដែលគេថែមឲ្យ រួចគិតថានឹងចូលទៅកាន់ស្រុក ឆាន់អាហារថ្មីបាន (សេចក្តីពិតមិនបានទេ គឺត្រូវអាបត្តិបាចិត្តិយ) ។

៤.ភិក្ខុនៅក្នុងសីមាតែមួយ ធ្វើឧបោសថបែកគ្នាបាន (ការពិតមិនបានទេ គឺត្រូវអាបត្តិទុក្កដ) ។

៥.សង្ឃមិនទាន់មកប្រជុំព្រមគ្នា តែគ្រប់ចំនួនល្មមធ្វើកម្មបាន ក៏គួរធ្វើទៅមុនបាន រួចហើយសុំអនុម័តិ ឬសេចក្តីយល់ឃើញត្រូវអំពីភិក្ខុអ្នកមកដល់ក្រោយ (សេចក្តីពិត មិនគួរទេ) ។

៦.រឿងដែលឧបជ្ឈាយ៍ និងអាចារ្យធ្លាប់ប្រព្រឹត្តមកហើយ ប្រើការបាន (សេចក្តីពិត បើត្រូវ ប្រើការបាន តែបើខុស ប្រើការមិនបាន) ។

៧.ទឹកដោះស្រស់ដែលប្រែសភាពដើមហើយ តែនៅមិនទាន់ជូរ ភិក្ខុឆាន់នៅក្នុងទីនិមន្ត រហូតដល់ប្រាប់មិនទទួលអាហារដែលគេប្រគេនថែមហើយ អាចនៅផឹកទឹកដោះនោះបាន (សេចក្តីពិត មិនបានត្រូវអាបត្តិបាចិត្តិយទេ ព្រោះនៅមិនទាន់ចាត់ចូលលក្ខណៈភេសជ្ជៈ៥) ។

៨.សំពត់ក្រាលអង្គុយមិនមានជាយ គួរប្រើបាន (សេចក្តីពិត មិនគួរទេ) ។

១០.មាសប្រាក់ គួរទទួលបាន (សេចក្ដីពិត មិនគួរទទួល បើទទួល ត្រូវអាបត្តិបាចិត្តិយ) ។

## ព្រះយសកាកណ្ឌកបុត្ររារាំង

ពួកភិក្ខុវជ្ជីបុត្រយកថាសដាក់ទឹក ដើររៃអង្គាសពួកឧបាសក ដែលមកក្នុងថ្ងៃឧបោសថ ដើម្បីជាតម្លៃបរិក្ខាររបស់សង្ឃ ។ ព្រះយសកាកណ្ឌកបុត្រ (ជាភិក្ខុមកអំពីទីដទៃ) និយាយហាមឃាត់ឧបាសកទាំងនោះថា មិនគួរឲ្យ តែព្រោះហេតុមិនដឹងវិន័យ ទើបគេឲ្យទៅតាមដែលគេធ្លាប់ឲ្យមក ។ ពេលយប់ភិក្ខុទាំងនោះចែកប្រាក់គ្នាហើយ បែងមកឲ្យព្រះយសកាកណ្ឌកបុត្រ តែត្រូវលោកបដិសេធ ក៏ក្រោធខឹងរួចចោទប្រកាន់លោកថា បានជេរឧបាសកទាំងនោះ ទើបប្រជុំគ្នាដាក់បដិសារណីយកម្ម (ឲ្យទៅសុំទោសអ្នកស្រុក) ។ ព្រះយសកាកណ្ឌកបុត្រ អាងព្រះវិន័យថា ត្រូវមានភិក្ខុជាទូតទៅជាមួយ ១ រូប ។ កាលបើភិក្ខុវជ្ជីបុត្រសូត្រប្រកាស តែងតាំងភិក្ខុមួយរូបឲ្យទៅហើយ ព្រះយសក៏ចូលទៅរកឧបាសកទាំងនោះបង្ហាញខដែលព្រះពុទ្ធទ្រង់ត្រាស់ទុកជាច្រើនកន្លែង ហាមទទួលមាសប្រាក់ ។ ឧបាសកទាំងនោះបានដឹងវិន័យ ក៏ជ្រះថ្លាមក លើព្រះយស និងពោលទោសភិក្ខុវជ្ជីបុត្រ ។ កាលត្រឡប់ពីទីនោះ ភិក្ខុជាទូត ដែលបានធ្វើដំណើររួមទៅជាមួយ ក៏ប្រាប់ឲ្យភិក្ខុវជ្ជីបុត្រដឹងគ្រប់គ្នា ក្រោធខឹងជាមួយនឹងព្រះយសអាងថា ប្រការដែលព្រះយសទៅនិយាយជាមួយនឹងអ្នកស្រុកទាំងនោះ ជាការទៅប្រាប់ដំណឹងដល់គ្រហស្ថ ដោយពុំបានទទួលការតែងតាំងអំពីសង្ឃ ទើបគួរដាក់ឧក្ខេបនីយកម្ម (បណ្ដេញចេញចាកពួក មិនឲ្យនរណាសេពគប់រក) ។

## ការសង្គាយនាលើកទី ២

ទើបព្រះយសកាកណ្ឌកបុត្រគេចចៀសចេញ បបួលព្រះថេរៈជាអ្នកមានធម៌វិន័យជាច្រើនរូប ដែលជាក្រុមជំនុំសង្ឃនៅក្នុងទីផ្សេងៗ ដូចជា ព្រះសព្វកាមី, ព្រះសាឡ្ហ, ព្រះខុជ្ជសោភិតៈ (កន្លែងខ្លះថា ខុជ្ជសោភិតៈ), ព្រះវាសភគាមិក, ៤ រូបនេះ ជាភិក្ខុតំណាងគណៈសង្ឃភាគខាងកើត ។ ព្រះរេវតៈ, ព្រះសម្ភូតសាណវាសី, ព្រះយសកាកណ្ឌកបុត្រ, ព្រះសុមនៈ, ៤ រូបនេះ ជាអ្នកតំណាងគណៈសង្ឃភាគខាងលិច (អ្នកស្រុកបាឋា) ព្រមទាំងព្រះអរហន្តជាច្រើនអង្គទៀត សរុបចំនួន ៧០០ រូប ប្រជុំគ្នានៅក្នុងវាលិការាម មានព្រះអជិតៈដែលមានវស្សា ១០ ជាអ្នកក្រាលអាសនៈ វិនិច្ឆ័យវត្ថុ ១០ ប្រការ សំដែងហេតុដែលទ្រង់

ធ្វើការហាម ពិន័យអាបត្តិយ៉ាងច្បាស់លាស់ កំណត់ដោយមតិសង្ឃ ឲ្យវត្ថុ ១០ នោះ ខុសធម៌ ខុសវិន័យ មិនមែនសត្ថុសាសនា ។

(ប្រវត្តិនៃការធ្វើសង្គាយនាទាំងពីរលើក គឺលើកទី ១ និង លើកទី ២ នេះ មានមកនៅក្នុងព្រះបិដកដោយអាចឃើញបានថា ជាការបន្ថែមទុកកាលធ្វើសង្គាយនាលើកទី ៣ ដើម្បីជាតឹកតាង ប្រវត្តិសាស្ត្រនៃព្រះធម្មវិន័យ) ។

## ភាគទី ១២-១៣ បរិវារៈ (ជាវិនយបិដក)

ព្រះត្រៃបិដកក្បាលទី ១២-១៣ នោះ ជាភាគបញ្ចប់នៃ វិន័យបិដក និងមានអត្ថន័យដែលគួរនាំមកសង្ខេបទុកត្រឹមតែបន្តិច បន្តួច ពីព្រោះសេចក្តីនៅក្នុងភាគនោះ ជាការពោលបញ្ជាក់បន្ថែម ទៅលើព្រះត្រៃបិដកដែលបានពោលរួចមកហើយ ចាប់តាំងអំពី ក្បាលទី ១ ដល់ក្បាលទី ១២-១៣ នោះឯង ។ ការអធិប្បាយ លើកនេះ គ្រាន់តែជាការប្រមូលន័យសំខាន់ៗ ដែលគួរស្វែងយល់ មកពោលទុក មានមាតិកាធំៗ ២១ គឺ

**១.មហាវិភង្គសោឡសមហាវារ** ជាការពោលបញ្ជាក់ដល់ សីលរបស់ភិក្ខុ ២២៧ ខ្ទ នីមួយៗ មានប្រាកដនៅក្នុងវិនយ-បិដកភាគទី ១ និងទី ២ ឈ្មោះថា មហាវិភង្គ ដោយតាំងបញ្ហា ទុក ២ ចំណែកៗ នីមួយមាន ៨ ចំណុច រួមមាន ១៦ ចំណុច (សោឡសមហាវារ) ។ ចំណែកមុននិងក្រោយ ការពិតដូចគ្នាទាំង ៨ ចំណុច គ្រាន់តែចំណែកដម្បូងពិចារណាដល់ការធ្វើខុសដោយ ត្រង់ ចំណែកក្រោយពិចារណាដល់ផលដែលអាស្រ័យហេតុ គឺការ ធ្វើខុស ឬពោលតាមសព្វប្រាកដ គឺចំណែកក្រោយពិចារណាដល់ បច្ច័យ គឺការធ្វើខុសនោះៗ ជាបច្ច័យ ឬជាហេតុឲ្យកើតអ្វីឡើង ។ ចំណុចទាំង ៨ ដែលមាននៅក្នុង ២ ចំណែកនោះ គឺ

**១.កត្ថ បញ្ញត្តិវារ** ចំណុចស្តីអំពីបញ្ញត្តិទុកនៅក្នុងទីណា សំដៅយកទីកន្លែង ដែលទ្រង់បញ្ញត្តសិក្ខាបទ រួមទាំងបុគ្គលជាដើម ហេតុនៃការបញ្ញត្តសិក្ខាបទ, រឿងរ៉ាវដែលកើតឡើងជាដើម ។

**២.កតាបត្តិវារ** ចំណុចស្តីអំពីការធ្វើខុសនៅក្នុងរឿងនោះៗ ហើយ ត្រូវអាបត្តិអ្វី ដូចភិក្ខុលួចទ្រព្យក្នុងករណីដូចម្តេច ត្រូវ អាបត្តិបារាជិក អាបត្តិថុល្លច្ច័យ និងអាបត្តិទុក្កដ ។

**៣.វិបត្តិវារ** ចំណុចស្តីអំពីការធ្វើខុសនោះៗ ជាសីលវិបត្តិ ឬអាចារវិបត្តិ សេចក្តីសៅហ្មងនៅក្នុងការប្រព្រឹត្តជាដើម ។

**៤.សង្គហិតវារ** ចំណុចស្តីអំពីការធ្វើខុសនោះៗ សង្គ្រោះ ឬចាត់ចូលទៅក្នុងកងអាបត្តិអ្វី ។

**៥.សមុដ្ឋានវារ** ចំណុចស្ដីអំពីការធ្វើខុសនោះ កើតឡើង ឬមានសមុដ្ឋានផ្លូវកាយ, វាចា ឬចិត្ត ។

**៦.អធិករណវារ** ចំណុចស្ដីអំពីការធ្វើខុសនោះៗ ជាអធិ-ករណ៍ ប្រភេទណានៅក្នុង ៤ ប្រភេទ ។

**៧.សមថវារ** ចំណុចស្ដីអំពីការធ្វើខុស ដែលជាអធិករណ៍នោះៗ នឹងរម្ងាប់ដោយវិធី ៧ យ៉ាង ខណាខ្លះ ។

**៨.សមុច្ចយវារ** ចំណុចស្ដីអំពីការធ្វើខុសនោះៗ កាលពោលរួបរួមចាប់ពីចំណុចទី ១ ដល់ទី ៧ នឹងបានសេចក្ដីយ៉ាងណាខ្លះ គឺពោលសាំ ៧ ខដម្បូងម្ដងទៀត ។ នៅក្នុងចំណែកទី ២ ចំណុច ៨ ទៀត ក៏មានទំនងដូចគ្នា គ្រាន់តែដូរវិធីការបន្តិចបន្តួចថា ព្រោះបច្ច័យនៃការធ្វើខុសនោះ មានផលដូចម្ដេចខ្លះ ។

**២.ភិក្ខុនីវិភង្គសោឡសមហាវារ** ជាការពោលបញ្ជាក់បន្ថែមដល់សីលវិបត្តិនៃភិក្ខុនៅក្នុងខនីមួយៗ មានប្រាកដនៅក្នុងវិនយ-បិដក ភាគទី ៥ ឈ្មោះថា ភិក្ខុនីវិភង្គ ដោយតាំងបញ្ហាទុកជា ២ ចំណែក នៅក្នុងចំណែកនីមួយៗ មាន ៨ ចំណុច ដូចភិក្ខុដែរ ។

**៣.សមុដ្ឋានសីសសង្ខេប** ជាការរួបរួមសិក្ខាបទទាំងអស់ មកពោលតែរឿងសមុដ្ឋាន គឺផ្លូវកាយ, ផ្លូវវាចា, ឬផ្លូវចិត្ត ដោយចាត់ជាពួកថា ពួកណាខ្លះកើតអំពីសមុដ្ឋាន ១ ឬសមុដ្ឋាន ២ ឬសមុដ្ឋាន ៣ ឬសមុដ្ឋានផ្សំដទៃទៀតនៅក្នុង ៣ ខនោះ ។

**៤.កតិបុច្ឆាវារ** ជាការតាំងពាក្យសួរថា រឿងនោះៗ មានប៉ុន្មាន ដូចជា អាបត្តិមានប៉ុន្មាន រួចឆ្លើយជាចំណុចៗ ជាដើម ។

**៥.វីសតិ** (ប្រែតាមសព្ទថា ២០ វារៈ សម្រួលន័យថា តាំងបញ្ហាសម្រាប់វិនិច្ឆ័យ ២០ ចំណុច) ជាការតាំងសំនួរ រួចឆ្លើយក្នុងរឿងដែលពាក់ព័ន្ធជាមួយនឹងអាបត្តិ, ទីកើតនៃអាបត្តិ, អធិករណ៍, វិធីរម្ងាប់អធិករណ៍ជាដើម សរុបមាន ២០ ចំណុច ។

**៦.ខន្ធកបុច្ឆា** ពាក្យសួរ-ឆ្លើយទាក់ទងទៅនឹងខន្ធកៈ គឺក្រុមផ្សេងៗ នៅក្នុងព្រះត្រៃបិដកភាគទី ៦ ដល់ភាគទី ១១ គឺទាំងមហាវគ្គ និងចុល្លវគ្គ រួមទាំងអស់មាន ២២ ពួក ឬខន្ធកៈ ថាតើនៅក្នុងពួកនីមួយៗនោះ ពោលដល់អាបត្តិទុកប៉ុន្មានប្រភេទ ។

**៧.ឯកុត្តរិក** ជាការពន្យល់បង្ហាញរឿងទាក់ទងទៅនឹងព្រះវិន័យជាតួរលេខ គឺពួក ១ មានអ្វីខ្លះដែលជាខតែមួយ ពួក ២, មានអ្វីខ្លះ ជា ២ ខ, ពួក ៣ មានអ្វីខ្លះ ជា ៣ ខ, ដូច្នេះជាដើម រហូតដល់ពួក ១១ មានអ្វីខ្លះ ជា ១១ ខ, ដូចជា ឧបោសថ ២ គឺ ១៤ រោច និង ១៥ កើត, បវារណា ២ គឺ ១៤ រោច និង ១៥ កើតជាដើម, កម្ម ២ គឺ អបលោកនកម្ម (ការប្រាប់)

ញត្តិកម្ម (ការស្នើញត្តិ) ទាំងអស់នេះជាដើម ក៏ឋិតនៅក្នុងពួក ២, ស្បែកជើង ១១ ប្រភេទជាវត្ថុមិនគួរ មានអ្វីខ្លះ, បុគ្គល ១១ ប្រភេទមិនគួរថ្វាយបង្គំ មានអ្វីខ្លះ, ទាំងអស់នេះជាដើម ក៏ឋិតនៅក្នុងពួក ១១ ។

**៨.ឧបោសថាទិបុច្ឆាវិសជ្ជនា** ពាក្យសួរ-ឆ្លើយ រឿងឧបោសថជាដើម ដូចជា សួរថា អ្វីជាខាងដើម ជាកណ្ដាល ជាទីបំផុតនៃការធ្វើឧបោសថ រួចឆ្លើយថា សេចក្ដីសាមគ្គីជាខាងដើម ការធ្វើជាកណ្ដាល និងការចប់ជាទីបំផុត នៃការធ្វើឧបោសថ។ សួរថា អ្វីជាខាងដើម ជាកណ្ដាល ជាទីបំផុតនៃការបួស ឆ្លើយថា បុគ្គលជាខាងដើម ការស្នើញត្តិជាកណ្ដាល កម្មវាចា (ការសូត្រប្រកាសសុំសេចក្ដីទុកចិត្ត ឬឧអនុម័តិនៃសង្ឃ) ជាទីបំផុត។

**៩.អត្ថវសេបករណ៍** ពោលអំពីការដែលព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទដើម្បីប្រយោជន៍ ១០ ប្រការ គឺ

១.ដើម្បីសេចក្ដីល្អនៃសង្ឃ

២.ដើម្បីសេចក្ដីសុខនៃសង្ឃ

៣.ដើម្បីសង្កត់សង្កិនអ្នកប្រដៅលំបាក (មុខក្រាស់)

៤.ដើម្បីនៅសប្បាយនៃភិក្ខុអ្នកមានសីលជាទីស្រឡាញ់

៥.ដើម្បីការពារអាសវៈ (កិលេសដែលដេកត្រាំនៅក្នុងសន្ដាន) ក្នុងពេលបច្ចុប្បន្ន។

៦.ដើម្បីការពារអាសវៈនៅក្នុងពេលអនាគត

៧.ដើម្បីសេចក្ដីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លា

៨.ដើម្បីសេចក្ដីជ្រះថ្លាក្រៃលែងឡើង នៃអ្នកដែលមានការជ្រះថ្លាហើយ។

៩.ដើម្បីសេចក្ដីតាំងមាំនៃព្រះសទ្ធម្ម

១០.ដើម្បីអនុគ្រោះព្រះវិន័យ។

**១០.គាថាសង្គណិក** ពួក ឬប្រជុំនៃគាថា គឺពាក្យឆន្ទ ដែលសំដែងពាក្យសួរ ពាក្យឆ្លើយនៃព្រះអាចារ្យអ្នកសង្គាយនាព្រះវិន័យថា សិក្ខាបទប៉ុន្មានដែលលើកឡើងសូត្រ (បាតិមោក្ខ) និងព្រះមានព្រះភាគទ្រង់បញ្ញត្តទុកប៉ុន្មាននគរ មាននគរអ្វីខ្លះ និងក្នុងនគរណា បញ្ញត្តសិក្ខាបទទុកប៉ុន្មាន។ (គាថានេះមានប្រយោជន៍ជួយឲ្យចាំបានល្អឡើង។ ទាំងនៅក្នុងវិន័យរបស់ភិក្ខុ និងភិក្ខុនី)។

**១១.អធិករណភេទ** ពោលអំពីប្រភេទនៃអធិករណ៍ ការសើរើអធិករណ៍ មូលនៃអធិករណ៍ អាបត្តិដែលពាក់ព័ន្ធជាមួយនឹងអធិករណ៍ទាំង ៤ ប្រភេទ វិធីរម្ងាប់អធិករណ៍ (ដែលបានពណ៌នារួចមកហើយ គ្រាន់តែនាំយកមកចាត់ជាពួកសារថ្មី)។

**១២.អបរគាថាសង្គណិក** ពួក ឬប្រជុំគាថា ឬបទនិពន្ធដទៃទៀត ជាការនិពន្ធពាក្យអធិប្បាយជាពាក្យឆន្ទ ដើម្បីជួយដល់ការចងចាំ ទាក់ទងទៅនឹងរឿងបណ្ដឹង ការសួររំឭកជាដើម រួមទាំងលក្ខណៈដែលគិតថាជាអលជ្ជី ។

**១៣.ចោទនាកណ្ឌ** ពោលអំពីវិធីប្ដឹងថានឹងត្រូវធ្វើយ៉ាងណា ភិក្ខុដើមចោទ ចុងចោទ និងសង្ឃ ត្រូវធ្វើយ៉ាងណា ។

**១៤.ចូឡសង្គាម** ពោលអំពីខបដិបត្តិនៃភិក្ខុជាចុងចោទ ប្រៀបដូចអ្នកចូលកាន់សង្គ្រាម គួរត្រៀមខ្លួនបដិបត្តិយ៉ាងណា ព្រមទាំងបណ្ដឹង និងការវិនិច្ឆ័យ ។

**១៥.មហាសង្គាម** ពោលអំពីខបដិបត្តិ ឬតួនាទីដែលគួរយល់ដឹងដទៃទៀត នៃភិក្ខុជាចុងចោទ ដែលស្មើនឹងអ្នកចូលកាន់សង្គ្រាម មានន័យពិស្ដារជាងខ ១៤ ។

**១៦.កឋិនភេទ** ប្រភេទនៃកឋិន នរណាក្រាលមិនបាន នរណាក្រាលបាន កឋិនឈ្មោះថាមិនបានក្រាលដូចម្ដេច និងបានក្រាលដូចម្ដេច ព្រមទាំងបទដទៃទៀតដែលទាក់ទងទៅនឹងកឋិន (ការពិតមានសំដែងទុកនៅក្នុងព្រះត្រៃបិដក ច្បាប់ភាសាបាលីប្រែរួចហើយ តែនាំមកចាត់ជាពួកដើម្បីឲ្យងាយចាំថែមទៀត) ។

**១៧.ឧបាលិបញ្ចក** ពោលអំពីពាក្យទូលសួររបស់ព្រះឧបាលី ព្រះតម្រាស់តបនៃព្រះមានព្រះភាគ ដែលជាបទកំណត់ ៥ ខ សរុបទាំងអស់មាន ១៤ ពួក ឬ ១៤ វគ្គ គឺ

ពួកទី ១ ពោលអំពីភិក្ខុដែលមិនគួរឲ្យនិស្ស័យ គឺមិនគួរទទួលទុកក្រោមបន្ទុករបស់ខ្លួនឡើយ ។

ពួកទី ២ ពោលអំពីភិក្ខុដែលដាក់ទោសរួចហើយ មិនត្រូវរម្ងាប់ការដាក់ទោស ។

ពួកទី ៣ ពោលអំពីភិក្ខុមិនគួរតវ៉ារឿងក្ដីនៅក្នុងសង្ឃ

ពួកទី ៤ ពោលអំពីការសំដែងមតិប្រឆាំង (ទិដ្ឋាវិកម្ម) ប្រកបដោយធម៌ និងមិនប្រកបដោយធម៌ ។

ពួកទី ៥ ពោលអំពីភិក្ខុជាដើមចោទ ។

ពួកទី ៦ ពោលអំពីការប្រព្រឹត្តធុតង្គទាំង ១៣ ខ (កម្ចាត់កិលេស) មានការនៅព្រៃជាដើម ។

ពួកទី ៧ ពោលអំពីការនិយាយកុហក

ពួកទី ៨ ពោលអំពីការឲ្យឱវាទដល់ភិក្ខុនី

ពួកទី ៩ ពោលអំពីឧព្វាហិកា គឺការប្រគល់ឲ្យធ្វើការសង្ឃដាច់ដោយឡែក ឬការតាំងតំណាងសង្ឃឲ្យទៅវិនិច្ឆ័យក្នុងរឿងណាមួយ ក្នុងពេលដែលសភាធំមិនអាចវិនិច្ឆ័យបាន ព្រោះមានសំឡេងវិវាទជាដើម (ប្រៀបធៀបការចាត់តាំងកម្មាធិការ ឬអនុកម្មការ)

ភិក្ខុដែលអាចទទួលយកការងារនេះបាន ត្រូវតែប្រកបដោយគុណ-សម្បត្តិ ៥ យ៉ាង មានអ្វីខ្លះ ។

ពួកទី ១០ ពោលអំពីការរម្ងាប់អធិករណ៍

ពួកទី ១១ ពោលអំពីសង្ឃបែកគ្នាវគ្គទី ១

ពួកទី ១២ ពោលអំពីសង្ឃបែកគ្នាវគ្គទី ២

ពួកទី ១៣ ពោលអំពីភិក្ខុម្ចាស់វត្ត ឬនៅប្រចាំក្នុងវត្ត

ពួកទី ១៤ ពោលអំពីការក្រាលកឋិន ។

**១៨.សមុដ្ឋាន** ពោលអំពីសមុដ្ឋាននៃអាបត្តិ និងការចេញចាកអាបត្តិ ។

**១៩.ទុតិយគាថាសង្គណិក** ពួក ឬប្រជុំគាថា ឬឆន្ទទី ២ ជាការនិពន្ធប្រធានបទ និងពាក្យអធិប្បាយទាក់ទងទៅនឹងព្រះវិន័យ ដើម្បីចាំបានងាយជាច្រើនបញ្ហាទៀត វែងជាងវគ្គមុនៗ ។

**២០.សេទមោចនគាថា** គាថាស្មុគស្មាញ គឺពាក្យចងក្រងតាំងបញ្ហាវិន័យជាប្រភេទឲ្យគិតលំបាក (បែបអត់បាយ គឺគិតមិនចេញរហូតដល់អត់បាយថ្ងៃត្រង់) រួមមាន ៤៣ ខ និងមិនបានឆ្លើយទុក (ពាក្យអធិប្បាយមាននៅក្នុងអដ្ឋកថា) ។

**២១.បញ្ចវគ្គ** ពោលអំពីរឿងផ្សេងៗ រួមមាន ៥ ពួក ឬ ៥ វគ្គ គឺ

វគ្គទី ១ ពោលអំពីកម្ម គឺការធ្វើកម្មនៃសង្ឃមានប្រភេទផ្សេងៗ ។

វគ្គទី ២ ពោលអំពីគោលបំណងក្នុងការបញ្ញត្តិសិក្ខាបទ

វគ្គទី ៣ ពោលអំពីការបញ្ញត្តិឲ្យធ្វើវត្តុនោះ វត្ថុនេះ តាមព្រះវិន័យ ។

វគ្គទី ៤ ពោលអំពីវត្ថុដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុក ហើយថា មានគោលបំណងដូចម្ដេច ។

វគ្គទី ៥ ពោលអំពីការសង្គ្រោះ ឬការរួបរួម (SYNTHESIS) រឿងផ្សេងៗ រួមមាន ៩ ប្រភេទ ។

(បានពោលរួចមកហើយថា ព្រះវិនយបិដកភាគទី ១២-១៣ ឈ្មោះថា បរិវារៈនោះ មិនមានអ្វីប្លែកឡើយ គ្រាន់តែនាំ

រឿង ដែលមានប្រាកដនៅក្នុងព្រះត្រៃបិដកតាំងអំពីភាគ ១ ដល់ភាគ ១១ នោះ មកពោលសារជាថ្មី ដោយជាក្រុម ឬតាំងបញ្ហាផ្សេងៗ ដើម្បីឲ្យចាំ និងយល់បានងាយស្រួល ទើបនៅក្នុងទីនេះមិនបានអធិប្បាយឲ្យពិស្តារដូចទីដទៃឡើយ គឺនៅរួមជាក្រុម ល្មមអាចឲ្យឃើញដល់មុខមាត់នៃព្រះត្រៃបិកដនោះ)

ចប់វិនយបិដកសង្ខេប